ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជា និង នីតិវិធី

## សម្រាប់

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

## អាណត្តិទី ៣

[ ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២ ]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ១៥៥/១២ គ.ជ.ប

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/០៣៥ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញការអនុម័តរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ លើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ប្រកាស

**ប្រការ ១ :** ឱ្យប្រើជាផ្លូវការនូវបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាថ្ងៃ អាទិត្យ ទី ០៣ ខែមិថុនា ឆ្នាំ២០១២ ដែលមាន ១៦ ជំពូក និងឧបសម្ព័ន្ធទាំង ១៤ ។

**ប្រការ ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងបទបញ្ជា និងនីតិវិធីនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១២

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**អ៊ឹម សូស្ដី**

# មាតិកា

ទំព័រ


**ជំពូកទី ១._ បទប្បញ្ញត្តិទូទៅ** ........ ០១

**ជំពូកទី ២._ ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** ........ ០៥

- សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត ........ ០៥
- សមាសភាពនៃ គ.ជ.ប ........ ០៥
- ករណីបាត់បង់មុខតំណែងក្នុងសមាសភាពនៃ គ.ជ.ប ........ ០៥
- លក្ខណវិនិច្ឆ័យនៃការតែងតាំងសមាសភាព គ.ជ.ប ........ ០៦
- រចនាសម្ព័ន្ធនៃ គ.ជ.ប ........ ០៧
- សិទ្ធិអំណាចរបស់ គ.ជ.ប ........ ០៨
- ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត ........ ១០
- រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់ គ.ជ.ប ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោត ........ ១១
- រចនាសម្ព័ន្ធនៃ គធ/ខប ........ ១១
- លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាជិក គធ/ខប ........ ១២
- ភារកិច្ច និងការទទួលខុសត្រូវនៃ គធ/ខប ........ ១៤
- រចនាសម្ព័ន្ធនៃ គឃ/សប ........ ១៦
- លក្ខណវិនិច្ឆ័យដើម្បីជ្រើសរើសសមាសភាព គឃ/សប ........ ១៦
- ភារកិច្ច និងការទទួលខុសត្រូវរបស់ គឃ/សប ........ ១៨
- រចនាសម្ព័ន្ធនៃ គកប/គករ ........ ២០
- លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំងសមាជិក គកប/គករ ........ ២១
- ភារកិច្ច និងការទទួលខុសត្រូវរបស់ គកប/គករ ........ ២៥
- ប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិកនៃ គ.ជ.ប សមាជិក និងមន្ត្រីបុគ្គលិកនៃ គធ/ខប គឃ/សប និងសមាសភាព គកប/គករ ........ ២៥

- ការតែងតាំងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ២៨
- ប្រាក់កម្រៃរបស់សមាជិក និងបុគ្គលិកនៃ គណៈកម្មាធិការជាតិ និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ២៩
- អាណត្តិរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ៣០
- ការតែងតាំងក្នុងរយៈពេលមានកំណត់ ៣០
- ការដាក់វិន័យ ការព្យួរការងារ ការបណ្ដេញចេញពីការងារចំពោះបុគ្គលិក ឬសមាជិកគណៈកម្មការ ៣១
- គោលការណ៍នៃការប្រើប្រាស់សម្ភារៈ និងបរិក្ខារនៃ គ.ជ.ប ៣១
- ប្រតិទិនការងារបោះឆ្នោត ៣១
- ការងារសន្តិសុខបោះឆ្នោត ៣២

**ជំពូកទី ៣._ សិទ្ធិចុះឈ្មោះ និង សិទ្ធិបោះឆ្នោត** ៣៧

- ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត ៣៧
- ភាពមានសិទ្ធិបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើ នៅពេលបោះឆ្នោត ៣៨

**ជំពូកទី ៤._ ប្រព័ន្ធបោះឆ្នោត និង ការបែងចែកអាសនៈ** ៤០

- ប្រព័ន្ធបោះឆ្នោត ៤០
- ការបែងចែកអាសនៈ ៤០
- ជំហានទី១: ការកំណត់កូតា (Quata) ៤១
- ជំហានទី២: ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈលើកទី១ ៤២
- ជំហានទី៣: ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈលើកទី២ ៤៣
- ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ៥០
- ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួនមានមធ្យមភាគខ្ពស់បំផុតស្មើគ្នា ៥៥
- ការចាប់ឆ្នោតជាសាធារណៈ ៥៨
- ការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ៦០
- ការកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ៦១

**ជំពូកទី ៥._ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត** ............ ៦៤
- ការកំណត់ទីតាំងការិយាល័យបោះឆ្នោត ............ ៦៤

**ជំពូកទី ៦._ បញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** ............ ៧១

**ជំពូកទី ៧._ ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** ............ ៧៣
- ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន ............ ៧៣
- ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន ............ ៧៣
- ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនដោយ គឃ/សប ............ ៧៧
- ការពិនិត្យ និងសម្រេចរបស់ គឃ/សប លើពាក្យសុំចុះបញ្ជីបេក្ខជន ............ ៧៨
- ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ...... ៨៦

**ជំពូកទី ៨._ ការឃោសនាបោះឆ្នោត** ............ ៨៩
- គោលការណ៍នៃការឃោសនាបោះឆ្នោត ............ ៨៩
- សម្ភារៈអប់រំអ្នកបោះឆ្នោត ............ ៩៨
- រូបភាព និងសម្ភារៈឃោសនាផ្សព្វផ្សាយ ............ ១០១
- ភារកិច្ច និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ............ ១០៦

**ជំពូកទី ៩._ ភ្នាក់ងារនៃគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន** ............ ១០៨
- ភ្នាក់ងារនៃគណបក្សនយោបាយ ............ ១០៨
- ដំណាក់ការទី១ : ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ............ ១០៨
- ដំណាក់ការទី២ : ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ............ ១១១
- អ្នកសង្កេតការណ៍បោះឆ្នោត ............ ១១៤
- អ្នកសង្កេតការណ៍ជាតិ ............ ១១៤
- អ្នកសង្កេតការណ៍អន្តរជាតិ ............ ១១៤

- គណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជន ហើយមានបំណងសង្កេតការណ៍បោះឆ្នោត ........ ១១៩
- អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ ........ ១២០

**ជំពូកទី ១០.- ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត** ........ ១២៤
- ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ១២៤
- សមាសភាពនៃ គកប/គករ ........ ១២៥
- ការទទួលខុសត្រូវ និងភារកិច្ចរបស់ គកប/គករ ........ ១២៥
- ការត្រៀមសម្ភារៈ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត ........ ១៣២
- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ១៣៧
- ការប្រព្រឹត្តទៅនៃការបោះឆ្នោត ........ ១៣៨

**ជំពូកទី ១១.- ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ប្រគល់ទទួលសម្ភារៈបោះឆ្នោត** ........ ១៥៥
- ការបិទការបោះឆ្នោត ........ ១៥៥
- ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ........ ១៥៩
- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ........ ១៦៨
- ការរៀបចំ និងការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធ ........ ១៧០
- ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ទៅទីស្នាក់ការ គឃ/សប ........ ១៧៤
- ការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ/សប ឬនៅទីតាំងសុវត្ថិភាពណាមួយ ........ ១៧៧
- ការដាក់ពាក្យបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោតការរាប់សន្លឹកឆ្នោតទៅ គឃ/សប ........ ១៨២
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីនៅមួយ (១)ថ្ងៃ មុនថ្ងៃបោះឆ្នោត ទៅ គឃ/សប ........ ១៨៥
- កិច្ចប្រតិបត្តិការរបស់ គឃ/សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ........ ១៨៧

**ជំពូកទី ១២.– លទ្ធផលបណ្ដោះអាសន្ន លទ្ធផលផ្លូវការ និងការជំទាស់ចំពោះលទ្ធផល នៃការបោះឆ្នោត**

**ជំពូកទី ១២.– លទ្ធផលបណ្ដោះអាសន្ន លទ្ធផលផ្លូវការ និងការជំទាស់ចំពោះលទ្ធផលនៃការបោះឆ្នោត** ........ ២០១
- ការបង្កើតមជ្ឈមណ្ឌលនៃ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ........ ២០១
- ការប្រគល់ និងការទទួលកញ្ចប់ " គ " និង " គពិសេស " ដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ/ខប ........ ២០៧
- ការដាក់ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់នៅ គធ/ខប ទាក់ទងនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់ ........ ២០៩
- កិច្ចប្រតិបត្តិការរបស់ គធ/ខប ក្នុងការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ........ ២១១
- ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ/សប និងនៅ គធ/ខប ........ ២១៤
- ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ដាក់នៅ គឃ/សប មានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកនៅ គឃ/សប និងដែលមានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ដាក់នៅ គធ/ខប ........ ២១៧
- ការប្រជុំសម្រេចរបស់ គធ/ខប លើពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ........ ២២១
- ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលមានលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងដែលមានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គធ/ខប ........ ២២៦
- ការកំណត់ចំនួនអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការស្រង់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........ ២២៨
- ការបំពេញលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........ ២៣២
- ការវេចខ្ចប់ និងបញ្ជូនលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងរាល់សម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប ........ ២៣៤

- ការដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ គ.ជ.ប ពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ........ ២៣៨
- ការបង្កើតក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិបម្រើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........ ២៤០
- ការប្រគល់ និងទទួលកញ្ចប់ " ឃ " និងកញ្ចប់ " ឃពិសេស " ដាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្តីការ គ.ជ.ប ........ ២៤៧
- កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមការណែនាំ និងចាត់ចែងរបស់អគ្គលេខាធិការនៃ គ.ជ.ប ..... ២៥០
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែល គធ/ខប បានសម្រេចព្យួរលទ្ធផលជាបណ្តោះអាសន្ន ........ ២៥៣
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប ឬ/និង គ.ជ.ប ........ ២៥៩
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គ.ជ.ប ឬ/និង ត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ត្រូវបានបើកត្រួតពិនិត្យផ្ទៀងផ្ទាត់ ........ ២៦៥
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន និងដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ/ខប ឬ/និង គ.ជ.ប ........ ២៧១
- ការរៀបចំ និងការផ្សព្វផ្សាយសេចក្តីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ........ ២៧៣

**ជំពូកទី ១៣._ ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន និងការបោះឆ្នោតសាជាថ្មី** ........ ២៧៥

- ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន ........ ២៧៥
- ការបោះឆ្នោតសាជាថ្មី ក្នុងករណីបដិសេធលទ្ធផលបណ្ដោះអាសន្ន ........ ២៧៨

**ជំពូកទី ១៤._ ការបោះឆ្នោតឡើងវិញ** ........ ២៨២

**ជំពូកទី ១៥._ ថវិកា និងហិរញ្ញវត្ថុ** ........ ២៨៧

**ជំពូកទី ១៦._ សមត្ថកិច្ច និងនីតិវិធីដោះស្រាយវិវាទក្នុងការបោះឆ្នោត និងនីតិវិធីដាក់/ទទួលពាក្យបណ្ដឹង និងដោះស្រាយបណ្ដឹងចំពោះគ្រប់អំពើល្មើសបោះឆ្នោតដែលអាចនាំឱ្យមានការផ្ដន្ទាទោស** ........ ២៩១

- សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត ........ ២៩១
- សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា ........ ២៩១
- ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់ ........ ២៩៤
- ការដកពាក្យបណ្ដឹង ........ ២៩៥
- ការរួមបញ្ចូលរឿងក្ដី ........ ២៩៦
- សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្ដឹង ចុងចម្លើយ អ្នកតំណាង ឬមេធាវី ........ ២៩៦
- សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ........ ២៩៨
- នីតិវិធីសវនាការ ឬនីតិវិធីប្រជុំសម្រេច ឬនីតិវិធីប្រជុំផ្សះផ្សា ........ ២៩៨
- នីតិវិធីដាក់/ទទួលពាក្យបណ្ដឹង និងដោះស្រាយបណ្ដឹងចំពោះគ្រប់អំពើល្មើសដែលអាចនាំឱ្យមានការផ្ដន្ទាទោស ........ ៣០៧

## ឧបសម្ព័ន្ធ


១. សម្រង់ខ្លឹមសារចេញពីជំពូកទី ៣ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ការិយាល័យចុះឈ្មោះបោះឆ្នោត) ...... ៣១៧

២. សេចក្តីណែនាំស្តីពីការរៀបចំត្រៀមបម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ...... ៣២៨

៣. សេចក្តីណែនាំរួម ស្តីពីការផ្តល់បណ្ណព័ត៌មានអ្នកបោះឆ្នោត ...... ៣៣៣

៤. ជំពូកទី ៤ នៃបទបញ្ជា និងនីតិវិធី សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត) ...... ៣៣៨

៥. សេចក្តីសម្រេច ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១ ...... ៤៨៣

៦. នីតិវិធី ស្តីពីការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ...... ៤៨៧

៧. សេចក្តីណែនាំរួម ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ...... ៤៩១

៨. សម្ភារៈ ឯកសារ ដែលត្រូវប្រគល់ជូន គធ/ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល ...... ៤៩៩

៩. សម្ភារៈ ឯកសារ ដែលត្រូវប្រគល់ជូន គឃ/សប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល ...... ៥០១

១០. សម្ភារៈ ឯកសារ ដែលត្រូវប្រគល់ជូន គកប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ...... ៥០៣

១១. រូបមន្តរកកម្រិតលម្អៀងសំឡេងឆ្នោត ដើម្បីកំណត់កម្រិតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន ...... ៥០៥

១២. ក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារនៃគណបក្សនយោបាយ ...... ៥០៨

១៣. ក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ...... ៥១៦

១៤. គោលការណ៍ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ...... ៥២២

១៥. ក្រមសីលធម៌ សម្រាប់មន្ត្រីបោះឆ្នោត ...... ៥២៥

១៦. ក្រមសីលធម៌ សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ...... ៥៣៣

១៧. បទបញ្ជាផ្ទៃក្នុងពេលបើកសវនាការ ឬអង្គប្រជុំផ្សះផ្សាដោះស្រាយបណ្តឹង ...... ៥៤៨

១៨. ខ្លឹមសារនៃសម្បថ ...... ៥៤៩

# អក្សរកាត់

| | | |
|---|---|---|
| ១_ | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | **គ.ជ.ប** |
| ២_ | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | **គធ/ខប** |
| ៣_ | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | **លធ/ខប** |
| ៤_ | ក្រុមប្រឹក្សាឃុំ សង្កាត់ | **កបឃ/សប** |
| ៥_ | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | **គឃ/សប** |
| ៦_ | គណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោត | **គកប/គករ** |
| ៧_ | ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | **ច.ប.ត.រ** |
| ៨_ | ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | **ច.ប.ឃ.ស** |
| ៩_ | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | **ប.ន.ឃ.ស** |

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**ប្រការ ១.១** អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ឃ.ស) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានសិទ្ធិ និងភារកិច្ចរៀបចំបទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ប.ន.ឃ.ស) ដែលកំណត់អំពីការរៀបចំការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ១.២** ឃុំ សង្កាត់នីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយ ដែលត្រូវបានបោះឆ្នោតជ្រើសរើស ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របតាមនីតិវិធី ដូចមានចែងក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ។

**ប្រការ ១.៣** ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងរៀងរាល់ប្រាំ (៥) ឆ្នាំម្តង ។

១.៣.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយ (១) ថ្ងៃ ។

១.៣.២ កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី ក្នុងរយៈពេលប្រាំបួន (៩) ខែយ៉ាងតិចមុនថ្ងៃបោះឆ្នោត តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

១.៣.៣ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវកាលបរិច្ឆេទនៃការបោះឆ្នោតនេះ នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ។

**ប្រការ ១.៤** ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិប្រាំ (៥) ឆ្នាំ ហើយត្រូវកាន់កាប់មុខតំណែងរបស់ខ្លួនរហូតទាល់តែមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

**ប្រការ ១.៥** រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា អំពីការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ណា ដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន ។ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃចាត់ចែងគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ។

១.៥.១ ក្នុងពេលកំពុងដំណើរការរៀបចំការបោះឆ្នោត គ.ជ.ប ត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រី អំពីការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន ។

១.៥.២ គ.ជ.ប មានសិទ្ធិសម្រេចមិនបើកការិយាល័យបោះឆ្នោត និងមានសិទ្ធិបិទការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួន ក្នុងករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងបរិវេណខាងក្នុង និងនៅក្នុងការិយាល័យបោះឆ្នោត ។

១.៥.៣ ករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន អាចជាករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម ៖

- អសន្តិសុខជាសាធារណៈ ។
- ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយផែនដី ឬគ្រោះធម្មជាតិផ្សេងៗទៀត ។
- ការដួលរលំអគារសម្រាប់បំរើការបោះឆ្នោត ដោយយថាហេតុណាមួយ អគ្គិភ័យ ឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់ ។
- ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន ។

**ប្រការ ១.៦** ការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតបាន ដោយករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន ដូចមានចែងក្រោមប្រការ ១.៥ ខាងលើ នឹងត្រូវដំណើរការនៅពេលស្ថានការណ៍នៅឃុំ សង្កាត់នោះមានប្រក្រតីភាពឡើងវិញ តាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប ។

**ប្រការ ១.៧** ការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួននៃឃុំ សង្កាត់ស្ថិតនៅក្នុងករណីដូចមានចែងក្រោមប្រការ ១.៥ ខាងលើ ត្រូវធ្វើឡើងក្នុងរយៈពេលមិនលើសពីសាមសិប (៣០) ថ្ងៃ បន្ទាប់ពីថ្ងៃដែល គ.ជ.ប សម្រេចមិនបើកនៅមុនពេលបោះឆ្នោត ឬបិទក្នុងពេលកំពុងដំណើរការបោះឆ្នោត ឬបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។

**ប្រការ ១.៨** ការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើឡើងនៅឃុំ សង្កាត់ណាដែលមានករណីដូចខាងក្រោម ៖

- ឃុំ សង្កាត់ដែលត្រូវបានបង្កើតថ្មីតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានរំសាយចោលតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

១.៨.១ ការបោះឆ្នោតឡើងវិញត្រូវធ្វើក្នុងរយៈពេលមួយរយម្ភៃ (១២០) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃសម្រេចឱ្យមានករណីតម្រូវឱ្យមានការបោះឆ្នោតឡើងវិញ ។

១.៨.២ កាលបរិច្ឆេទនៃការបោះឆ្នោតឡើងវិញ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីមានករណីតម្រូវឱ្យមានការបោះឆ្នោតឡើងវិញ ។

១.៨.៣ ការបោះឆ្នោតឡើងវិញ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពីមួយរយប៉ែតសិប (១៨០)ថ្ងៃ ។

**ប្រការ ១.៩** ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយយកឃុំ សង្កាត់ជាមណ្ឌលបោះឆ្នោត និងដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ។

១.៩.១ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែល :

១.៩.១.១ បានចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតក្នុង ឃុំ សង្កាត់នោះ និងមានឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួននៅពេលបោះឆ្នោត ។

១.៩.១.២ មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

១.៩.១.៣ មានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តែមួយប៉ុណ្ណោះ ។

**ប្រការ ១.១០** អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវបានកំណត់ដោយអនុក្រឹត្យក្នុងរយៈពេលយ៉ាងតិចប្រាំបួន (៩) ខែមុនថ្ងៃបោះឆ្នោត ។

១.១០.១ ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពីប្រាំ (៥) ទៅដប់មួយ (១១) រូប ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្រ ។

១.១០.២ ចំនួនសមាជិកក្រុមប្រឹក្សាជាក់ស្តែងក្នុងឃុំ សង្កាត់នីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចប្រាំបួន (៩) ខែ មុនថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

# ជំពូកទី ២
# ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត**

**ប្រការ** ២.១ អនុលោមតាម មាត្រា ៧ថ្មី នៃ ច.ប.ឃ.ស គ.ជ.ប មានសមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ។

២.១.១ គ.ជ.ប ប្រើប្រាស់សិទ្ធិអំណាចដែលមានចែងក្នុង ច.ប.ឃ.ស និង ច.ប.គ.រ សម្រាប់គ្រប់គ្រងការរៀបចំ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.១.២ គ.ជ.ប ត្រូវដាក់ចេញបទបញ្ជា និងនីតិវិធីផ្សេងៗសម្រាប់ចាត់ចែងរៀបចំការបោះឆ្នោតផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុង ច.ប.ឃ.ស ។

២.១.៣ គ.ជ.ប ជាអង្គការឯករាជ និងអព្យាក្រឹត ក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ។ សមាជិក និងមន្ត្រីគ្រប់រូបនៃ គ.ជ.ប គធ/ខប គឃ/សប និង គកប/គករ ត្រូវប្រកាន់ជំហរឯករាជ្យមិនលម្អៀង និងស្មោះត្រង់ក្នុងការអនុវត្តអំណាច មុខងារភារកិច្ចរបស់ខ្លួន ។

**សមាសភាពនៃ គ.ជ.ប**

**ប្រការ** ២.២ គ.ជ.ប រួមមានសមាសភាព ដូចខាងក្រោម ៖

២.២.១ ឥស្សរជនខ្មែរមួយរូប ជាប្រធាន ។

២.២.២ ឥស្សរជនខ្មែរមួយរូប ជាអនុប្រធាន ។

២.២.៣ ឥស្សរជនខ្មែរប្រាំពីរ (៧) រូប ជាសមាជិក ។

**ករណីបាត់បង់មុខតំណែងក្នុងសមាសភាពនៃ គ.ជ.ប**

**ប្រការ** ២.៣ ការសម្រេចបណ្តេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិក គ.ជ.ប ជាសមត្ថកិច្ចរបស់រដ្ឋសភា ។ ប្រធាន ឬអនុប្រធាន ឬសមាជិកនៃ គ.ជ.ប ត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយដូចខាងក្រោម ៖

២.៣.១ សាមីខ្លួនទទួលមរណភាព ។

២.៣.២ សាមីខ្លួនលាឈប់ជាលាយលក្ខណ៍អក្សរ ។

២.៣.៣ សាមីខ្លួនបានបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

២.៣.៤ សាមីខ្លួនប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

**លក្ខណវិនិច្ឆ័យនៃការតែងតាំងសមាសភាព គ.ជ.ប**

**ប្រការ** ២.៤ លក្ខណវិនិច្ឆ័យដើម្បីជ្រើសរើសសមាសភាព គ.ជ.ប ត្រូវបានកំណត់ដោយមាត្រា ១៣ថ្មី(ពីរ) នៃ ច.ប.ត.រ ។

២.៤.១ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនខ្មែរ ដែលមានសមត្ថភាពខាងនយោបាយ មានបទពិសោធន៍ក្នុងការងារ និងមានកេរ្តិ៍ឈ្មោះល្អ ។

២.៤.២ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលជាសមាជិកនៃគណបក្សនយោបាយ ឬ/និងជាអ្នកស្ថិតនៅក្នុងជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគម សហជីព ឬ/និងជាមន្ត្រីរាជការ ក្រោយពីទទួលបានការតែងតាំងក្នុង គ.ជ.ប ត្រូវសុំលាលែងជាស្ថាពរពីគណបក្សនយោបាយ ឬ/និងពីជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគម សហជីព ឬ/និងដាក់ពាក្យសុំទៅបម្រើការងារនៅក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់អាណត្តិ ។

២.៤.៣ បន្ទាប់ពីការតែងតាំងរួចហើយ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ទាំងអស់មិនត្រូវតំណាងឱ្យទស្សនៈបក្សសម្ពន្ធនៃក្រុមមនុស្សរបស់សង្គមដែលបានតែងតាំងខ្លួនឡើយ ។

**ប្រការ** ២.៥ សេចក្តីព្រាងសមាសភាពនៃ គ.ជ.ប ត្រូវបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងដាក់ជូនគណៈរដ្ឋមន្ត្រី ដើម្បីលើកសំណើសុំការទុកចិត្តពីរដ្ឋសភា ។

២.៥.១ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់គណៈរដ្ឋមន្ត្រីក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

២.៥.២ ប្រធាន អនុប្រធាន និងសមាជិកនៃ គ.ជ.ប ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

**រចនាសម្ព័ន្ធ គ.ជ.ប**

**ប្រការ** ២.៦ រចនាសម្ព័ន្ធរបស់ គ.ជ.ប រួមមាន គ.ជ.ប និងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ៖

២.៦.១ គ.ជ.ប អាចបង្កើតអនុគណៈកម្មការសម្របសម្រួល និងអនុគណៈកម្មការចំពោះកិច្ច ដើម្បីត្រួតពិនិត្យការងាររបស់អគ្គលេខាធិការដ្ឋាន ហើយត្រូវរាយការណ៍ជូន គ.ជ.ប ។ អនុគណៈកម្មការនេះត្រូវបង្កើតឡើងស្របតាមប្រការ ៨ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.៦.២ គ.ជ.ប ត្រូវតែងតាំងអគ្គលេខាធិការ ដែលមិនមែនជាសមាជិក គ.ជ.ប ធ្វើជាសេនាធិការដើម្បីអនុវត្តរៀបចំការបោះឆ្នោត និងត្រូវទទួលខុសត្រូវចំពោះមុខ គ.ជ.ប ។ អគ្គលេខាធិការ មានអគ្គលេខាធិការរង ជាជំនួយ ។

២.៦.៣ រចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប រួមមាន ៖

- ខុទ្ទកាល័យអគ្គលេខាធិការដ្ឋាន
- នាយកដ្ឋានប្រាំ (៥) គឺ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ និងនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ។
- គធ/ខប
- លធ/ខប នៅពេលដែល គធ/ខប ពុំទាន់ត្រូវបានជ្រើសរើស និងតែងតាំងក្នុងដំណាក់កាលត្រៀមពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជាផ្លូវការ
- គឃ/សប នៅពេលបោះឆ្នោត
- ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ ជំនួយការស្មៀន នៅពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- គកប/គករ នៅពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.៦.៤ នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធានមួយ (១) រូប និងមានអនុប្រធានយ៉ាងតិចមួយ (១) រូប ជាជំនួយ ។

២.៦.៥ ប្រធាននាយកដ្ឋានត្រូវទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការ ។

២.៦.៦ អនុប្រធាននាយកដ្ឋានត្រូវទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋាន ។

២.៦.៧ នាយកដ្ឋាននីមួយៗត្រូវបែងចែកជាការិយាល័យ ។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានមួយ (១)រូប និងអនុប្រធានជាជំនួយតាមការកំណត់របស់ គ.ជ.ប ។

**សិទ្ធិអំណាចរបស់ គ.ជ.ប**

**ប្រការ ២.៧** គ.ជ.ប មានសិទ្ធិពេញលេញក្នុងការអនុវត្តការងារក្នុងសមត្ថកិច្ចរបស់ខ្លួន ។ គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងទៅនឹងការកសាងផែនការ ការរៀបចំបែបបទ ការចាត់ចែង និងការត្រួតពិនិត្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដូចតទៅ ៖

២.៧.១ ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

២.៧.២ រៀបចំគម្រោងផែនការការងារ ថវិកា និងសម្ភារៈបម្រើឱ្យការបោះឆ្នោត ព្រមទាំងផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

២.៧.៣ តែងតាំង គធ/ខប គឃ/សប និង គកប/គករ ។

២.៧.៤ ធ្វើបទបញ្ជា និងនីតិវិធី និងសេចក្តីណែនាំនានា សម្រាប់ដំណើរការបោះឆ្នោតក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

២.៧.៥ លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

២.៧.៦ ត្រួតពិនិត្យការងាររបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

២.៧.៧ កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

២.៧.៨ ចេញសេចក្តីសម្រេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.៧.៩ ផលិត និងបែងចែកសម្ភារៈ បរិក្ខារបម្រើឱ្យការងារបោះឆ្នោត ។

២.៧.១០ រៀបចំ និងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ។

២.៧.១១ ការពារសុវត្ថិភាព និងរក្សាបញ្ជីបោះឆ្នោត ។

២.៧.១២ ដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬផ្ដល់សិទ្ធិបោះឆ្នោតឡើងវិញ ។
ចុះបញ្ជីបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។
លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះឡើងវិញ ។

២.៧.១៣ ត្រួតពិនិត្យ និងសម្របសម្រួលការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត ។

២.៧.១៤ រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផល ។

២.៧.១៥ ផ្ដល់ព័ត៌មានអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។

២.៧.១៦ ធានាឱ្យមានការផ្លាស់ប្ដូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំអំពីកិច្ចដំណើរការបោះឆ្នោត រវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែលពាក់ព័ន្ធនានា ។

២.៧.១៧ ផលិតឯកសារផ្សព្វផ្សាយអំពីការងារបោះឆ្នោត ។

២.៧.១៨ លើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការងារបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងតាមមធ្យោបាយផ្សេងៗទៀត ។

២.៧.១៩ រៀបចំឯកសារ កម្មវិធី និងបណ្ដុះបណ្ដាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ។

២.៧.២០ ពិនិត្យសម្រេច និងចេញប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ រួមទាំងអ្នកសង្កេតការណ៍នៃគណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

២.៧.២១ ត្រួតពិនិត្យភាពត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធីក្នុងការអនុវត្តការងារបោះឆ្នោត ។

២.៧.២២ សម្រេចលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

២.៧.២៣ បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

២.៧.២៤ ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា ស្តីពីការគ្រប់គ្រង ការប្រព្រឹត្តទៅនៃការបោះឆ្នោត ។

២.៧.២៥ រៀបចំគណៈកម្មការដើម្បីបំផ្លាញសន្លឹកឆ្នោត ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះ រយៈពេលពីរ (២) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោតតាមអាណត្តិនីមួយៗ ។

២.៧.២៦ អនុវត្តការងារដទៃទៀតដែលច្បាប់ បទបញ្ជា និងនីតិវិធីអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

**ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត**

**ប្រការ ២.៨** យោងតាម ច.ប.ឃ.ស និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គ.ជ.ប អាចប្រគល់សិទ្ធិទៅ លធ/ខប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោតណាម្នាក់ ។

២.៨.១ គ.ជ.ប អាចប្រគល់សិទ្ធិទៅ គធ/ខប ឬមន្ត្រីបោះឆ្នោតណាម្នាក់ដែលបានតែងតាំង ។ ក្នុងករណី គធ/ខប ពុំទាន់ត្រូវបានបង្កើត និងតែងតាំង គ.ជ.ប អាចប្រគល់សិទ្ធិទៅ លធ/ខប ដើម្បីបំពេញការងារមួយចំនួនតាមការចាំបាច់ ។

២.៨.២ គ.ជ.ប ត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.៨.៣ គធ/ខប អាចប្រគល់សិទ្ធិទៅ គឃ/សប ឬមន្ត្រីបោះឆ្នោត ដែលត្រូវបានតែងតាំងតាមការចាំបាច់ ។

២.៨.៤ គឃ/សប អាចប្រគល់សិទ្ធិទៅគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គកប/គករ) ដែលត្រូវបានតែងតាំងតាមការចាំបាច់ ។

**រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់ គ.ជ.ប ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

**ប្រការ** ២.៩ លធ/ខប ជាអង្គភាពរដ្ឋបាលថ្នាក់ក្រោមរបស់ គ.ជ.ប នៅក្នុងដំណាក់កាលបន្តនិរន្តរភាព និងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ដោយឡែកនៅក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គ.ជ.ប ត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញតួនាទីជាតំណាងរបស់ខ្លួនក្នុងការអនុវត្តការងារ ។

២.៩.១ ក្នុងដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងក្នុងពេលដែល គធ/ខប ពុំទាន់ត្រូវបានជ្រើសរើស និងតែងតាំង លធ/ខប គឺជាផ្នែករដ្ឋបាលថ្នាក់ក្រោមមួយរបស់ គ.ជ.ប ដែលបំពេញការងារតាមការប្រគល់សិទ្ធិដោយ គ.ជ.ប ។

២.៩.១.១ មន្ត្រី បុគ្គលិកនៃ លធ/ខប ដែលត្រូវបានតែងតាំងឱ្យបន្តនិរន្តរភាពការងារបោះឆ្នោត ក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត មានសិទ្ធិទទួលការតែងតាំងជាថ្មីដោយ គ.ជ.ប សម្រាប់ដំណាក់កាលរៀបចំការបោះឆ្នោត ។

២.៩.១.២ គ.ជ.ប ត្រូវជ្រើសតាំងមន្ត្រីបុគ្គលិកសម្រាប់ លធ/ខប មួយចំនួនបន្ថែមទៀតតាមការចាំបាច់ តាមសំណូមពរនៃការងារដែលត្រូវបានប្រគល់សិទ្ធិ ។

២.៩.១.៣ គ.ជ.ប ត្រូវតែងតាំងមន្ត្រីមួយរូបនៃ លធ/ខប ដែលមានសមត្ថភាពជាប្រធានលេខាធិការដ្ឋាន រហូតដល់ពេលដែល គធ/ខប ត្រូវបានតែងតាំង ។

២.៩.២ ក្នុងដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបាន គ.ជ.ប ធ្វើប្រតិភូកម្មអំណាចឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ត្រូវទទួលការណែនាំ និងការសម្របសម្រួលអនុវត្តការងារពី គ.ជ.ប តាមរយៈ លធ/ខប ។

**រចនាសម្ព័ន្ធនៃ គធ/ខប**

**ប្រការ** ២.១០ គធ/ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលបង្កើតដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោត ។

២.១០.១ គធ/ខប ត្រូវមានសមាសភាពប្រាំពីរ (៧) រូប ដែលរួមមាន ប្រធាន (១) រូប អនុប្រធាន (១) រូប និងសមាជិក (៥) រូប ។

២.១០.២ សមាសភាពនៃ គធ/ខប ត្រូវបានជ្រើសរើស និងតែងតាំងដោយ គ.ជ.ប ដោយអនុលោមតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិក ដូចចែងក្នុងប្រការ ២.១៩ និង ២.២០ នៃ ប.ន.ឃ.ស នេះ ។

២.១០.៣ គធ/ខប ត្រូវបង្កើតលេខាធិការដ្ឋានមួយ ដែលមានផ្នែកជំនាញចំនួនប្រាំ (៥) ។ ផ្នែកជំនាញទាំងប្រាំ (៥)នោះ រួមមាន ៖

- ផ្នែកប្រតិបត្តិការ
- ផ្នែករដ្ឋបាល
- ផ្នែកហិរញ្ញវត្ថុ
- ផ្នែកបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ
- ផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម ។

២.១០.៤ ប្រធាន គធ/ខប មានភារៈទទួលខុសត្រូវការងាររួម ។ អនុប្រធាន គធ/ខប ជាជំនួយឱ្យប្រធាន គធ/ខប និងទទួលភារៈជំនួសប្រធាន ពេលប្រធានអវត្តមាន ។ សមាជិកម្នាក់ៗនៃ គធ/ខប ត្រូវបានបែងចែកឱ្យទទួលបន្ទុកផ្នែកជំនាញមួយ (១) ក្នុងចំណោមផ្នែកជំនាញទាំងប្រាំ (៥) ។

**លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាជិក គធ/ខប**

**ប្រការ** ២.១១ លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ/ខប ត្រូវអនុលោមក្នុងមាត្រា ១១ថ្មី នៃ ច.ប.ឃ.ស ។

២.១១.១ សមាសភាព គធ/ខប ត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងរាជធានី ខេត្តនោះ ។

២.១១.១.១ ដើម្បីគោរពឯករាជភាព និងអព្យាក្រឹតភាពនៃ គ.ជ.ប សមាជិក គធ/ខប ត្រូវតំណាងឱ្យក្រុមទាំងអស់នៃសង្គមកម្ពុជាទាំងមូល ។

២.១១.១.២ ក្រុមទាំងអស់នៃសង្គមកម្ពុជាទាំងមូល ត្រូវបានកំណត់ជាមន្ត្រីរាជការបម្រើការងារក្នុងរាជរដ្ឋាភិបាល គណបក្សនយោបាយ និងសង្គមស៊ីវិល ។

២.១១.១.៣ សង្គមស៊ីវិលត្រូវបានកំណត់ជាអង្គការនានា មិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីរាជរដ្ឋាភិបាលដូចជា សមាគមគណៈមេធាវី អង្គការមិនមែនរដ្ឋាភិបាល សមាគមផ្នែកអប់រំ វប្បធម៌ និងអង្គការ ឬសមាគមមិនគិតផលចំណេញដទៃទៀត ។

២.១១.១.៤ អ្នកដែលមានសិទ្ធិត្រូវបានជ្រើសរើស គឺប្រជាពលរដ្ឋទូទៅ មន្ត្រីរាជការ និងអ្នកមុខអ្នកការនៅក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត ។

២.១១.១.៥ អ្នកដែលពុំមានសិទ្ធិត្រូវបានជ្រើសរើស គឺកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ (ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី) ព្រះសង្ឃ ឬបព្វជិតនៃសាសនាណាមួយ ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ បេក្ខជនឈរឈ្មោះ បោះឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ ។

២.១១.១.៦ សមាជិក គធ/ខប ត្រូវមានកិត្តិស័ព្ទស្មោះត្រង់ និងសុចរិត ទៀងត្រង់ ហើយត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ ។

២.១១.១.៧ ប្រសិនបើអាចធ្វើបាន យ៉ាងហោចណាស់ត្រូវមានស្ត្រីមួយ (១)រូប ជាសមាជិកនៃ គធ/ខប ។ នៅតំបន់ណាដែលមានជនជាតិភាគតិចក្នុងចំនួនសមស្រប ប្រសិនបើអាចធ្វើទៅបាន សមាជិកមួយ (១)រូប នៃ គធ/ខប ត្រូវជ្រើសរើសចេញពីក្រុមជនជាតិភាគតិច ។

២.១១.១.៨ មន្ត្រីបន្តនិរន្តរភាពការងារបោះឆ្នោតនៅតាមរាជធានី ខេត្ត អាចត្រូវបានផ្ដល់អាទិភាពជាបេក្ខជនសម្រាប់ការជ្រើសរើសនេះ ។

២.១១.២ សមាជិក និងបុគ្គលិកនៃ គធ/ខប ត្រូវបានជ្រើសរើសដោយអនុលោមតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដូចបានកំណត់ក្នុងប្រការ ២.១៩ និង ២.២០ ខាងក្រោម ។

២.១១.៣ សមាជិក គធ/ខប នៃរាជធានី ខេត្តនីមួយៗ ត្រូវមានចំនួនប្រាំពីរ (៧)រូប ស្មើគ្នា ។

២.១១.៤ ប្រសិនបើពលរដ្ឋណាម្នាក់មានមូលហេតុដែលអាចជឿបានថា អ្នកដែលត្រូវបានតែងតាំងជាសមាជិក គធ/ខប ពុំមានលក្ខណសម្បត្តិស្របតាមច្បាប់ទេនោះ គាត់អាចប្ដឹងជំទាស់នឹងការតែងតាំងនេះទៅ គ.ជ.ប ។

២.១១.៤.១ ប្រសិនបើមានការប្ដឹងជំទាស់ គ.ជ.ប ត្រូវដោះស្រាយបណ្ដឹងនោះដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុង ~~ម្ល~~/និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

២.១១.៤.២ សេចក្ដីសម្រេចរបស់ គ.ជ.ប គឺជាសេចក្ដីសម្រេចចុងក្រោយ ។

**ភារកិច្ច និងការទទួលខុសត្រូវនៃ គឃ/ខប**

**ប្រការ២.១២** ក្រោមការគ្រប់គ្រង និងការណែនាំនៃ គ.ជ.ប គឃ/ខប ត្រូវមានការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅឃុំ សង្កាត់ ក្នុងរាជធានី ខេត្តរបស់ខ្លួន ។ គឃ/ខប ត្រូវ ៖

២.១២.១ ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

២.១២.២ អនុវត្តផែនការមេ គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសម្ភារៈ បរិក្ខារសម្រាប់ការបោះឆ្នោត និងគោរពប្រតិទិននៃការបោះឆ្នោត ។

២.១២.៣ គោរព និងអនុវត្តបទបញ្ជា និងនីតិវិធី និងគោលការណ៍ណែនាំរបស់ គ.ជ.ប ។

២.១២.៤ ចាត់វិធានការពាក់ព័ន្ធទៅនឹងសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងដំណើរការបោះឆ្នោត ។

២.១២.៥ តាមដានការងារគ្រប់គ្រង និងប្រតិបត្តិការរបស់ គឃ/សប ។

២.១២.៦ លើកគម្រោងជូន គ.ជ.ប អំពីចំនួន និងទីតាំងការិយាល័យបោះឆ្នោត (ប្រសិនបើ គឃ/ខប មិនទាន់ត្រូវបានតែងតាំង លឃ/ខប ត្រូវបំពេញកិច្ចការនេះ) ។

២.១២.៧ បែងចែកសម្ភារៈចុះឈ្មោះ ឯកសារចុះឈ្មោះបោះឆ្នោតជូន គឃ/សប ។

២.១២.៨ ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត ។

២.១២.៩ លើកគម្រោង និងអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីការបោះឆ្នោតក្នុងក្របខ័ណ្ឌរាជធានី ខេត្តដោយយោងតាមការណែនាំរបស់ គ.ជ.ប ។

២.១២.១០ លើកស្ទួយការយល់ដឹងរបស់សាធារណជន អំពីដំណើរការបោះឆ្នោតដោយធ្វើការសម្របសម្រួលការងារអប់រំអ្នកបោះឆ្នោតនៅក្នុងក្របខ័ណ្ឌរាជធានី ខេត្ត ដោយសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាលនានា ។

២.១២.១១ ត្រួតពិនិត្យយុទ្ធនាការឃោសនាបោះឆ្នោតនៅតាមរាជធានី ខេត្ត ។

២.១២.១២ ចាត់គ្រប់វិធានការ ដើម្បីធានាឱ្យមានភាពស្មើគ្នាក្នុងការប្រើប្រាស់អគារសាធារណៈដល់គណបក្សនយោបាយទាំងអស់ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

២.១២.១៣ ដំណើរការកម្មវិធីផ្សព្វផ្សាយព័ត៌មាន ។

២.១២.១៤ លើកសំណើសុំ គ.ជ.ប តែងតាំងសមាសភាព គឃ/សប គកប/គករ ក្នុងរាជធានី ខេត្ត និងធ្វើតារាងប្រាក់កំរៃសម្រាប់សមាជិកនិងមន្ត្រីនៃ គធ/ខប គឃ/សប និង គកប/គករ តាមការណែនាំរបស់ គ.ជ.ប ។

២.១២.១៥ តាមដានការងារគ្រប់គ្រង និងចាត់ចែង គឃ/សប ក្នុងការបូកសរុបលទ្ធផលបណ្ដោះអាសន្នពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។

២.១២.១៦ រៀបចំចាត់ចែងប្រមូលលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន និងប្រកាសលទ្ធផលបណ្ដោះអាសន្ននៅក្នុងឃុំ សង្កាត់នីមួយៗ ។

២.១២.១៧ រៀបចំវេចខ្ចប់ និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ព្រមទាំងសម្ភារៈ និងឯកសារបោះឆ្នោតពាក់ព័ន្ធជូនទៅ គ.ជ.ប ។

២.១២.១៨ ទទួលពាក្យបណ្ដឹងតវ៉ា ឬជំទាស់ និងដំណើរការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ។

២.១២.១៩ ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចដែលបានណែនាំដោយ គ.ជ.ប ។

២.១២.២០ ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត ។

២.១២.២១ សហការចាត់ចែងការងារសន្តិសុខបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ។

២.១២.២២ ជូនយោបល់ដល់ គ.ជ.ប អំពីបរិយាកាសក្នុងរាជធានី ខេត្ត ដើម្បីចាត់វិធានការនានា ធានាឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងមានតម្លាភាព ។

២.១២.២៣ វាយតម្លៃអំពីប្រសិទ្ធភាពការងាររបស់សមាជិកទាំងឡាយនៃ គឃ/សប ។

២.១២.២៤ អនុវត្តការងារដទៃទៀត ដែលច្បាប់បោះឆ្នោតអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

២.១២.២៥ អនុវត្តការងារដទៃទៀត ឬអនុវត្តសិទ្ធិអំណាចដទៃទៀត ដែលត្រូវបានប្រគល់ឱ្យដោយ គ.ជ.ប ។

**រចនាសម្ព័ន្ធនៃគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប)**

**ប្រការ** ២.១៣ គឃ/សប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ដែលតែងតាំងដោយ គ.ជ.ប តាមសំណើរបស់ គធ/ខប ដើម្បីជួយដល់ គ.ជ.ប ក្នុងការធ្វើផែនការរៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោត ។

២.១៣.១ គឃ/សប ត្រូវមានសមាសភាពប្រាំ (៥)រូប រួមមានប្រធានមួយ (១)រូប អនុប្រធានមួយ (១)រូប និងសមាជិកបី (៣)រូប ។

២.១៣.១.១ ប្រធាន ទទួលបន្ទុកដឹកនាំការងាររួម និងការងារហិរញ្ញវត្ថុ ។

២.១៣.១.២ អនុប្រធាន ត្រូវមានភារកិច្ចទទួលខុសត្រូវដឹកនាំផ្នែកប្រតិបត្តិការ ។

២.១៣.១.៣ សមាជិក ទទួលបន្ទុកផ្នែករដ្ឋបាល និងជាលេខាធិការ ។

២.១៣.១.៤ សមាជិក ទទួលបន្ទុកផ្នែកបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ។

២.១៣.១.៥ សមាជិក ទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងការងារសន្តិសុខបោះឆ្នោត ។

២.១៣.២ គឃ/សប អាចមានជំនួយការមួយចំនួនតាមការកំណត់របស់ គ.ជ.ប ។

២.១៣.៣ គឃ/សប ត្រូវទទួលខុសត្រូវចំពោះមុខ គធ/ខប ។

២.១៣.៤ គឃ/សប ទទួលសេចក្តីណែនាំពី គ.ជ.ប តាមរយៈ គធ/ខប ។

**លក្ខណវិនិច្ឆ័យដើម្បីជ្រើសរើសសមាសភាព គឃ/សប**

**ប្រការ** ២.១៤ លក្ខណវិនិច្ឆ័យដើម្បីជ្រើសរើសសមាសភាព គឃ/សប ត្រូវអនុលោមតាមមាត្រា ១១ថ្មីនៃ ច.ប.ឃ.ស ។

២.១៤.១ សមាសភាព គឃ/សប ត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋទូទៅក្នុងរាជធានី ខេត្ត ដែលមានសិទ្ធិបោះឆ្នោត ប្រសិនបើអាចធ្វើបានត្រូវជ្រើសរើសក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនកំពុងរស់នៅ ។

២.១៤.១.១ ដើម្បីគោរពឯករាជភាព និងអព្យាក្រឹតភាពនៃ គ.ជ.ប សមាជិកនៃ គឃ/សប ត្រូវតំណាងឱ្យក្រុមទាំងអស់នៃសង្គមកម្ពុជា ដូចមានកំណត់ក្នុងចំណុច ២.១១.១.២ និងចំណុច ២.១១.១.៣ ។

២.១៤.១.២ អ្នកដែលមានសិទ្ធិត្រូវបានជ្រើសរើស គឺជាប្រជាពលរដ្ឋ មន្ត្រីរាជការ និងអ្នកមុខអ្នកការនៅក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត ។

២.១៤.១.៣ អ្នកដែលពុំមានសិទ្ធិត្រូវបានជ្រើសរើស គឺកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ (ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី) ព្រះសង្ឃ ឬបព្វជិតនៃសាសនាណាមួយប្រតិភូរាជរដ្ឋាភិបាល អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង មេភូមិ អនុប្រធានភូមិ សមាជិកភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ ។

២.១៤.១.៤ សមាជិក គឃ/សប ត្រូវមានកិត្តិស័ព្ទស្មោះត្រង់ និងសុចរិតទៀងត្រង់ ហើយត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយដោយប្រជាពលរដ្ឋ ។

២.១៤.១.៥ ប្រសិនបើអាចធ្វើបាន ប្រធាន និងអនុប្រធានត្រូវជ្រើសរើសក្នុងចំណោមជនចូលនិវត្តន៍ ដែលមានគតិបណ្ឌិត និងមានសិទ្ធិបោះឆ្នោតនៅឃុំ សង្កាត់ ។

២.១៤.១.៦ ប្រសិនបើអាចធ្វើបានយ៉ាងហោចណាស់ត្រូវមានស្ត្រីមួយ (១)រូប ជាសមាជិកនៃ គឃ/សប ។ នៅតំបន់ណាដែលមានជនជាតិភាគតិចក្នុងចំនួនសមស្រប ប្រសិនបើអាចធ្វើបានសមាជិកមួយ (១)រូប នៃ គឃ/សប ត្រូវជ្រើសរើសចេញពីក្រុមជនជាតិភាគតិច ។

២.១៤.២ សមាជិកនៃ គឃ/សប ត្រូវជ្រើសរើសដោយអនុលោមតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិក ដូចបានកំណត់នៅប្រការ ២.១៩ និង ២.២០ ខាងក្រោម ។

២.១៤.៣ ប្រសិនបើពលរដ្ឋណាម្នាក់ មានមូលហេតុដែលអាចជឿបានថា អ្នកដែលត្រូវបានជ្រើសតាំងជាសមាជិក គឃ/សប ពុំមានលក្ខណសម្បត្តិស្របតាមមាត្រា ១១ថ្មី នៃ ច.ប.ឃ.ស ការប្តឹងជំទាស់នឹងការតែងតាំងនេះត្រូវធ្វើទៅ គ.ជ.ប ។

២.១៤.៣.១ ប្រសិនបើមានការប្តឹង គ.ជ.ប ត្រូវដោះស្រាយបណ្តឹងនោះ ដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

២.១៤.៣.២ សេចក្តីសម្រេចរបស់ គ.ជ.ប គឺជាសេចក្តីសម្រេចចុងក្រោយ ។

**ភារកិច្ច និងការទទួលខុសត្រូវរបស់ គឃ/សប**

**ប្រការ** ២.១៥ ក្រោមការគ្រប់គ្រង និងត្រួតពិនិត្យនៃ គ.ជ.ប និងឆ្លងតាម គធ/ខប គឃ/សប ត្រូវមានការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅឃុំ សង្កាត់ របស់ខ្លួន ។ គឃ/សប ត្រូវ ៖

២.១៥.១ ចាត់គ្រប់វិធានការចាំបាច់ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

២.១៥.២ អនុវត្តផែនការមេ គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសម្ភារៈ ឯកសារសម្រាប់ការបោះឆ្នោត និងគោរពប្រតិទិននៃការបោះឆ្នោត ។

២.១៥.៣ ត្រូវបិទផ្សាយលិខិតជូនដំណឹងស្តីពីការជ្រើសរើស គកប និងជ្រើសរើស គកប ព្រមទាំងស្នើតែងតាំងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.៤ វាយតម្លៃ អំពីប្រសិទ្ធភាពការងាររបស់សមាជិកការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.៥ បែងចែកបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ និងសម្ភារៈបោះឆ្នោតឱ្យបានគ្រប់ការិយាល័យបោះឆ្នោត ។

២.១៥.៦ ទទួល និងពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

២.១៥.៧ បិទផ្សាយបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៅទីស្នាក់ការ គឃ/សប ។

២.១៥.៨ ចាប់ឆ្នោត ដើម្បីកំណត់លេខរៀងនៃបញ្ជីបេក្ខជននៅលើសន្លឹកឆ្នោត ។

២.១៥.៩ ធ្វើរបាយការណ៍ស្តីអំពីលទ្ធផលនៃការចាប់ឆ្នោតកំណត់លេខរៀងនៃបញ្ជីបេក្ខជនលើសន្លឹកឆ្នោតជូន គ.ជ.ប តាមរយៈ គធ/ខប ។

២.១៥.១០ ទទួល និងសម្រេចផ្តល់ប័ណ្ណសម្គាល់ជូនភ្នាក់ងារនៃគណបក្សនយោបាយ ។

២.១៥.១១ គោរព និងអនុវត្តបទបញ្ជា និងនីតិវិធី និងគោលការណ៍ណែនាំរបស់ គ.ជ.ប ។

២.១៥.១២ ចាត់វិធានការពាក់ព័ន្ធទៅនឹងសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងដំណើរការបោះឆ្នោត ។

២.១៥.១៣ លើកគម្រោងជូន គធ/ខប អំពីការកែសម្រួលទីតាំងការិយាល័យបោះឆ្នោត ។

២.១៥.១៤ បែងចែកសម្ភារៈ បរិក្ខារបោះឆ្នោត/រាប់សន្លឹកឆ្នោត ទៅឱ្យការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.១៥ បូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។

២.១៥.១៦ ប្រមូល និងរៀបចំប្រគល់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត សម្ភារៈ និងឯកសារផ្សេងៗជូន គធ/ខប ។

២.១៥.១៧ ត្រួតពិនិត្យ និងសម្របសម្រួលការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោតនៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

២.១៥.១៨ ចាត់គ្រប់វិធានការដើម្បីធានាឱ្យមានភាពស្មើគ្នាក្នុងការប្រើប្រាស់អគារសាធារណៈ ដល់គណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះទាំងអស់ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

២.១៥.១៩ ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត ។

២.១៥.២០ លើកគម្រោង និងអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដោយផ្អែកតាមការណែនាំរបស់ គ.ជ.ប និង គធ/ខប ។

២.១៥.២១ លើកស្ទួយការយល់ដឹងរបស់សាធារណជន អំពីដំណើរការបោះឆ្នោត ដោយធ្វើការសម្របសម្រួល ការងារអប់រំអ្នកបោះឆ្នោតនៅឃុំ សង្កាត់ ដោយសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល ។

២.១៥.២២ អនុវត្តតាមកម្មវិធីផ្សព្វផ្សាយព័ត៌មាន ។

២.១៥.២៣ ទទួល និងដោះស្រាយរាល់បណ្ដឹងជំទាស់ ឬ/និងបណ្ដឹងតវ៉ា ទាំងដោយវិធីសម្រុះសម្រួលផ្ទាល់មាត់ និងទាំងដោយការប្រជុំសម្រេច ។

២.១៥.២៤ ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចបានណែនាំរបស់ គ.ជ.ប ។

២.១៥.២៥ ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត ។

២.១៥.២៦ ដឹកនាំការប្រជុំជាមួយភាគីពាក់ព័ន្ធអំពីការងារបោះឆ្នោត និងសន្តិសុខនៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

២.១៥.២៧ ផ្ដល់យោបល់ទៅ គធ/ខប អំពីបរិយាកាសនៅក្នុងឃុំ សង្កាត់ ដើម្បីឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី និងត្រឹមត្រូវ ។

២.១៥.២៨ អនុវត្តការងារដទៃទៀតដែល ច.ប.ឃ.ស អនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

២.១៥.២៩ អនុវត្តការងារដទៃទៀត ឬ/និងសិទ្ធិអំណាចដទៃទៀត ដែលត្រូវបានប្រគល់ឱ្យដោយ គ.ជ.ប ឬ/និង គធ/ខប ។

**រចនាសម្ព័ន្ធនៃគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គកប/គករ)**

**ប្រការ ២.១៦** គកប/គករ ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោត និងទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតដោយផ្ទាល់នៅការិយាល័យបោះឆ្នោត ដែលតែងតាំងដោយ គ.ជ.ប តាមសំណើរបស់ គធ/ខប ។

២.១៦.១ គកប/គករ ត្រូវមានសមាសភាពប្រាំមួយ (៦)រូប ដែលរួមមាន ប្រធានមួយ (១)រូប អនុប្រធានមួយ (១)រូប លេខាធិការមួយ (១)រូប ជំនួយការពីរ (២)រូប និង សមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់មួយ (១)រូប ។

២.១៦.១.១ ប្រធាន មានភារៈទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.១៦.១.២ អនុប្រធាន មានភារៈជាជំនួយរបស់ប្រធាន និងទទួលខុសត្រូវក្នុងការផ្ដល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតនៅពេលបោះឆ្នោត និងក្នុងការកត់ត្រាសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

២.១៦.១.៣ លេខាធិការ មានភារៈទទួលខុសត្រូវក្នុងការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត និងការបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១៦.១.៤ ជំនួយការទី ១ ដែលនៅក្នុងការិយាល័យបោះឆ្នោត មានភារៈទទួលខុសត្រូវ ពិនិត្យការស៊កសន្លឹកឆ្នោតទៅក្នុងហិបឆ្នោត និងជ្រលក់ម្រាមដៃអ្នកបោះឆ្នោតក្នុងទឹកខ្មៅលុបលាងមិនជ្រះ និងទទួលគូសសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

២.១៦.១.៥ ជំនួយការទី ២ ដែលនៅខាងក្រៅការិយាល័យបោះឆ្នោត មានភារកិច្ចទទួលខុសត្រូវ ជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងចាត់ចែងសណ្ដាប់ធ្នាប់ ជូនអ្នកបោះឆ្នោត និងចោះសន្លឹកឆ្នោតដែលមិនបានប្រើ ។

២.១៦.១.៦ សមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ មានភារៈទទួលខុសត្រូវការងារសណ្ដាប់ធ្នាប់ របៀបរៀបរយ និងថែរក្សាសម្ភារៈឯកសារបោះឆ្នោតនៅពេលបោះឆ្នោត និងនៅពេលរាប់សន្លឹកឆ្នោត ។

២.១៦.២ គកប/គករ ត្រូវទទួលខុសត្រូវចំពោះមុខ គឃ/សប ។

២.១៦.៣ គកប/គករ ទទួលសេចក្ដីណែនាំពី គ.ជ.ប តាមរយៈ គធ/ខប និង គឃ/សប ។

**លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំងសមាសភាព គកប/គករ**

**ប្រការ២.១៧** លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គកប/គករ ត្រូវបានកំណត់ដូចខាងក្រោម ៖

២.១៧.១ សមាសភាព គកប/គករ ត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋទូទៅដែលមានសិទ្ធិបោះឆ្នោត និងរស់នៅក្នុងរាជធានី ខេត្ត ។

២.១៧.១.១ ដើម្បីគោរពឯករាជភាព និងអព្យាក្រឹតភាពនៃ គ.ជ.ប សមាជិក គកប/គករ ត្រូវតំណាងឱ្យក្រុមទាំងអស់នៃសង្គមកម្ពុជាទាំងមូលដែលត្រូវបានកំណត់ជាមន្ត្រីរាជការបម្រើការងារក្នុងរាជរដ្ឋាភិបាល គណបក្សនយោបាយ និងសង្គមស៊ីវិល ។

២.១៧.១.២ ប្រសិនបើអាចធ្វើបាន អ្នកដែលមានសិទ្ធិត្រូវបានជ្រើសរើសគឺជាប្រជាពលរដ្ឋ មន្ត្រីរាជការ និងអ្នកមុខអ្នកការដែលមានសិទ្ធិបោះឆ្នោត និងកំពុងរស់នៅក្នុងឃុំ សង្កាត់ ។

២.១៧.១.៣ ចេះអាន និងសរសេរអក្សរខ្មែរ ។

២.១៧.១.៤ សមាជិក គកប/គករ ត្រូវមានកិត្តិស័ព្ទស្មោះត្រង់ និងសុចរិតទៀងត្រង់ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ដោយប្រជាពលរដ្ឋ ។

២.១៧.១.៥ ប្រសិនបើអាចធ្វើបាន ប្រធាន និងអនុប្រធានត្រូវជ្រើសរើសក្នុងចំណោមជនចូលនិវត្តន៍ ដែលមានគតិបណ្ឌិត មានសិទ្ធិបោះឆ្នោត និងកំពុងរស់នៅក្នុងឃុំ សង្កាត់ ។

២.១៧.១.៦ ប្រសិនបើអាចធ្វើបាន យ៉ាងហោចណាស់ត្រូវមានស្ត្រីមួយ(១)នាក់ជាសមាជិកនៃ គកប/គករ ។ នៅតំបន់ណាដែលមានជនជាតិភាគតិច ក្នុងចំនួនសមស្រប ប្រសិនបើអាចធ្វើបាន សមាជិកមួយ (១) នាក់ នៃ គកប/គករ ត្រូវជ្រើសរើសចេញពីក្រុមជនជាតិភាគតិច ។

២.១៧.១.៧ អ្នកដែលពុំមានសិទ្ធិត្រូវបានជ្រើសរើស គឺកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ (ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី) ព្រះសង្ឃ ឬបព្វជិតនៃសាសនាណាមួយ ប្រតិភូរាជរដ្ឋាភិបាល អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ បេក្ខជនឈរឈ្មោះបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ ។

២.១៧.២ អ្នកដែលត្រូវបានជ្រើសរើសជាសមាជិក គកប/គករ គឺជាបេក្ខជនដាក់ពាក្យសុំចូលបម្រើការងារណា ដែលបានទទួលជោគជ័យក្នុងការធ្វើតេស្ត បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង និងបានចុះហត្ថលេខាលើកិច្ចសន្យាបម្រើការងារក្នុង គកប/គករ (ទម្រង់បែបបទលេខ ១០០២) នៅក្រោយពេលវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់ ។ ក្នុងការជ្រើសរើសនេះ ត្រូវផ្តល់អាទិភាពចំពោះបេក្ខជនដែលធ្លាប់មានបទពិសោធន៍ក្នុងការងារបោះឆ្នោតពីមុនមក ។

២.១៧.២.១ បេក្ខជនណាដែលត្រូវបានជ្រើសរើសហើយ ប៉ុន្តែមិនបានចូលរួមវគ្គបណ្តុះបណ្តាល ត្រូវដាក់ជំនួសជាបន្ទាន់ដោយបេក្ខជនបម្រុង ។

២.១៧.២.២ ប្រសិនបើគ្មានបេក្ខជនបម្រុងសម្រាប់ជំនួស គឃ/សប ត្រូវចាត់ចែងជ្រើសរើសអ្នកជំនួសជាបន្ទាន់ ។

២.១៧.៣ ដើម្បីបានជ្រើសរើស និងបានបម្រើការងារក្នុងលក្ខណៈជាប់កិច្ចសន្យាជាសមាជិក គកប/គករ បេក្ខជនដាក់ពាក្យសុំបម្រើការងារត្រូវ ៖

២.១៧.៣.១ ឆ្លងកាត់ដោយជោគជ័យនូវការធ្វើតេស្ត ដែលគ្រប់គ្រងពិនិត្យដោយ គឃ/សប ។

២.១៧.៣.២ គោរពរដ្ឋធម្មនុញ្ញ និងអនុវត្តតាម ច.ប.ឃ.ស ព្រមទាំងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

២.១៧.៣.៣ យល់ព្រមធ្វើសច្ចាប្រណិធានថា ប្រកាន់ជំហរអព្យាក្រឹត និងមិនលំអៀង ។

២.១៧.៣.៤ យល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កំរៃ ។

២.១៧.៣.៥ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង ។

២.១៧.៣.៦ ចុះហត្ថលេខាយល់ព្រមលើកិច្ចសន្យាបម្រើការងារក្នុង គកប/គករ ។

២.១៧.៤ ទម្រង់បែបបទលេខ ១០០២ សម្រាប់បំពេញកិច្ចសន្យាបម្រើការងារក្នុង គកប/គករ ត្រូវបញ្ជាក់ ៖

២.១៧.៤.១ ឈ្មោះ អាសយដ្ឋាន និងភស្តុតាងបញ្ជាក់ពីភាពមានសិទ្ធិបោះឆ្នោត នៃអ្នកដែលត្រូវតែងតាំង ។

២.១៧.៤.២ មុខតំណែងក្នុង គកប/គករ នៃអ្នកដែលត្រូវតែងតាំង ។

២.១៧.៤.៣ លក្ខណៈសម្គាល់នៃអាជ្ញាធររៀបចំការបោះឆ្នោត ។

២.១៧.៤.៤ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត ដែលបុគ្គលនោះត្រូវបានតែងតាំង ។

២.១៧.៤.៥ លក្ខខណ្ឌការងារ ភារកិច្ច និងការទទួលខុសត្រូវនៃអ្នកដែលត្រូវតែងតាំង ។

២.១៧.៤.៦ ការសន្យាយល់ព្រមទទួលយកភារកិច្ចលក្ខខណ្ឌការងារ និងប្រាក់កំរៃ ។

២.១៧.៤.៧ ការសន្យាថានឹងអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត និងមិនលំអៀង ។

២.១៧.៤.៨ ការសន្យាថានឹងអនុវត្តតាម ច.ប.ឃ.ស បទបញ្ជា និងនីតិវិធី ព្រមទាំងរាល់សេចក្តីណែនាំរបស់ គ.ជ.ប ។

២.១៧.៤.៩ ការសន្យាថានឹងគោរពតាមលក្ខការណ៍នៃការបោះឆ្នោត ។

២.១៧.៤.១០ ហត្ថលេខារបស់អ្នកដែលត្រូវតែងតាំង និងហត្ថលេខារបស់សាក្សី ព្រមទាំងហត្ថលេខារបស់ប្រធាន និងលេខាធិការនៃ គឃ/សប ។

២.១៧.៥ សមាសភាព គកប/គករ ត្រូវតែជ្រើសរើស ដោយផ្អែកតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដូចបានកំណត់ក្នុងប្រការ ២.១៩ និង ២.២០ ខាងក្រោម ។

២.១៧.៦ ប្រសិនបើប្រជាពលរដ្ឋណាម្នាក់មានមូលហេតុដែលអាចជឿបានថាអ្នកដែលត្រូវបានជ្រើសតាំងជាសមាជិក គកប/គករ ពុំមានលក្ខណសម្បត្តិស្របតាមច្បាប់ទេនោះ គាត់អាចប្តឹងជំទាស់នឹងការតែងតាំងនេះទៅ គ.ជ.ប ។

២.១៧.៦.១ ប្រសិនបើមានការប្តឹង គ.ជ.ប ត្រូវដោះស្រាយបណ្តឹងនោះដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

២.១៧.៦.២ សេចក្តីសម្រេចរបស់ គ.ជ.ប គឺជាសេចក្តីសម្រេចចុងក្រោយ ។

២.១៧.៧ គឃ/សប ត្រូវប្រគល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងជាសមាជិក គកប/គករ ទាំងអស់ ចំណុះឃុំ សង្កាត់របស់ខ្លួន ដោយភ្ជាប់ជាមួយនូវកិច្ចសន្យាបម្រើការងារក្នុង គកប/គករ (ទម្រង់បែបបទលេខ ១០០២) ដែលបានបំពេញ និងចុះហត្ថលេខារួច ម្នាក់ៗមួយ (១) ច្បាប់ជូនទៅ គធ/ខប ដើម្បីបន្តស្នើសុំសេចក្តីសម្រេចតែងតាំងពី គ.ជ.ប ។

២.១៧.៧.១ គធ/ខប ត្រូវបញ្ជូនបញ្ជីឈ្មោះ និងទម្រង់បែបបទតែងតាំងសមាជិក គកប/គករ ទៅ គ.ជ.ប ។

២.១៧.៧.២ នៅពេលទទួលបានសំណើតែងតាំង ដូចបញ្ជាក់ក្នុងចំណុច ២.១៧.៧.១ ខាងលើ គ.ជ.ប ត្រូវពិនិត្យ និងចេញសេចក្តីសម្រេចតែងតាំង គកប/គករ ហើយត្រូវរក្សាទុកឯកសារនៃបញ្ជីឈ្មោះមន្ត្រីការិយាល័យបោះឆ្នោតទាំងនោះជាផ្លូវការ ។

២.១៧.៧.៣ បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ គ.ជ.ប គឃ/សប ត្រូវបំពេញ និងផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនសមាជិក គកប/គករ សម្រាប់ពាក់នៅពេលបំពេញភារកិច្ចក្នុងអាណត្តិការងាររបស់ខ្លួន ។

២.១៧.៨ សមាជិក គកប/គករ ត្រូវស្ថិតនៅក្នុងមុខតំណែងរហូតដល់ថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅក្នុងការិយាល័យរបស់ខ្លួន និងក្រោយពីបានប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោតចប់សព្វគ្រប់ជូន គឃ/សប ។ ផ្អែកតាមមុខតំណែងរបស់ខ្លួន សមាជិក

គកប/គករ ម្នាក់ៗនឹងទទួលបានប្រាក់កំរៃជាប្រាក់រៀល សម្រាប់ការងាររបស់ខ្លួន ដោយគិតបញ្ចូលទាំងថ្លៃម្ហូបអាហារ និងថ្លៃធ្វើដំណើរផង ។

២.១៧.៨.១ ចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់ជាកំរៃសម្រាប់ការបំពេញការងារ នៃសមាជិក គកប/គករ ក្នុងរយៈពេលបី (៣) ថ្ងៃ ដោយគិតទាំងការចូលរួមវគ្គបណ្តុះបណ្តាលផង ។

២.១៧.៨.២ ក្នុងករណីសមាជិក គកប/គករ ណាដែលតម្រូវឱ្យស្ថិតក្នុងមុខតំណែងយូរជាងការកំណត់ដូចចែងក្នុងចំណុច ២.១៧.៨.១ ខាងលើ មន្រ្តីនោះនឹងត្រូវទទួលបានប្រាក់កំរៃបន្ថែមតាមសេចក្តីសម្រេចរបស់ គ.ជ.ប ។

២.១៧.៩ គឃ/សប ត្រូវអនុវត្តការវាយតម្លៃសមាជិក គកប/គករ ទាំងអស់ចំណុះឃុំ សង្កាត់ រយៈពេលពីរ (២) សប្តាហ៍យ៉ាងយូរបន្ទាប់ពីថ្ងៃបោះឆ្នោត ។

២.១៧.៩.១ នៅមុនបញ្ចប់ភារកិច្ចរបស់ខ្លួន គឃ/សប ត្រូវផ្តល់កំណត់ហេតុវាយតម្លៃសមាជិក គកប/គករ (ទម្រង់បែបបទលេខ ១១១៣) ដែលបានបំពេញរួចហើយទៅ គធ/ខប ។

២.១៧.៩.២ គធ/ខប ត្រូវផ្ញើកំណត់ហេតុវាយតម្លៃសមាជិក គកប/គករ ទាំងអស់ចំណុះរាជធានី ខេត្តម្នាក់ៗមួយ (១) ច្បាប់ជូន គ.ជ.ប ។

២.១៧.៩.៣ គ.ជ.ប ត្រូវកត់ត្រាបន្ថែមទិន្នន័យនៃកំណត់ហេតុវាយតម្លៃសមាជិក គកប/គករ ទាំងអស់ទៅក្នុងបញ្ជីឈ្មោះនៃសមាជិក គកប/គករ ដែលត្រូវរក្សាទុក ។

### ភារកិច្ច និងការទទួលខុសត្រូវរបស់ គកប/គករ

**ប្រការ ២.១៨** គកប/គករ នីមួយៗ មានភារកិច្ចគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ ១០.៣ ១០.៤ និង ១០.៥ នៃ ប.ន.ឃ.ស នេះ ។

### ប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិកនៃ គ.ជ.ប សមាជិក និងបុគ្គលិកនៃ គធ/ខប គឃ/សប និងសមាសភាព គកប/គករ

**ប្រការ ២.១៩** ប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិកនៃ គ.ជ.ប សមាជិក និងបុគ្គលិកនៃ គធ/ខប គឃ/សប និងសមាសភាព គកប/គករ ត្រូវឈរលើគោលការណ៍ស្មើភាពគ្នា សមត្ថភាព និងការងារពាក់ព័ន្ធ ដែលមានកំណត់នៅក្នុងប្រការ ១៩ ដល់ប្រការ ២៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.១៩.១ លក្ខខណ្ឌការងារត្រូវបានកំណត់ក្នុងជំពូកទី ៧ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.១៩.២ សេចក្តីពណ៌នាអំពីការទទួលខុសត្រូវ ភារកិច្ច និងលក្ខណសម្បត្តិតម្រូវសម្រាប់បុគ្គលិកនៃ គ.ជ.ប សមាជិក និងបុគ្គលិកនៃ គធ/ខប គឃ/សប និងសមាសភាព គកប/គករ ត្រូវបានចែងលំអិតក្នុងជំពូកទី១ ដល់ទី៥ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.១៩.៣ គ្រប់តួនាទីត្រូវតែបានផ្សព្វផ្សាយទូលំទូលាយក្នុងរយៈពេលប្រាំ (៥)ថ្ងៃ តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ឬ/និងឯកជន និងបិទផ្សាយនៅទីសាធារណៈ ឬទីប្រជុំជននៃឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ឬ/និងក្នុងទីប្រជុំជននៃរាជធានី ខេត្ត ។

២.១៩.៣.១ ដំណឹងផ្សព្វផ្សាយការងារ ត្រូវលើកឡើងអំពីតួនាទី សេចក្តីពណ៌នាអំពីការទទួលខុសត្រូវ ភារកិច្ច លក្ខណសម្បត្តិ និងលក្ខណៈវិនិច្ឆ័យ ។ ដំណឹងនេះ ក៏ត្រូវជម្រាបសាធារណជនផងដែរនូវទីកន្លែង និងពេលវេលាចែកពាក្យសុំចូលបម្រើការងារ ព្រមទាំងពេលវេលា ទីកន្លែង និងកាលបរិច្ឆេទចុងក្រោយនៃការទទួលពាក្យសុំ ។

២.១៩.៣.២ សម្រាប់ការជ្រើសរើសសមាជិក និងបុគ្គលិកនៃ គធ/ខប ពាក្យសុំត្រូវបានរៀបចំ និងផ្តល់ដោយ គ.ជ.ប ។ សម្រាប់ការជ្រើសរើស គឃ/សប ពាក្យសុំត្រូវផ្តល់ដោយ គធ/ខប ។ សម្រាប់ការជ្រើសរើសសមាសភាពនៃ គកប/គករ និងជំនួយការស្មៀន ពាក្យសុំត្រូវចែកដោយ គឃ/សប ឬក្រុមប្រឹក្សាឃុំ សង្កាត់ ។ ពាក្យសុំចូលបម្រើការងារត្រូវផ្តល់ជូនអ្នកសុំ ដោយឥតគិតថ្លៃ ។

២.១៩.៣.៣ នៅពេលឈប់ទទួលពាក្យសុំបម្រើការងារ គណៈកម្មការជ្រើសរើសបុគ្គលិក ត្រូវជ្រើសរើសសម្រាំងពាក្យសុំចូលបម្រើការងារ ដើម្បីកំណត់ថា តើពាក្យសុំមួយណាដែលឆ្លើយតបទៅនឹងលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌបច្ចេកទេស ។

២.១៩.៣.៤ លក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើសសមាសភាពនៃ គធ/ខប សមាសភាព គឃ/សប និង សមាសភាពនៃ គកប/គករ រួមមាន ៖

- មានសិទ្ធិបោះឆ្នោត
- មានឆន្ទៈបម្រើការងារក្នុងគោលជំហរអព្យាក្រឹត និងមិនលំអៀង
- មានសុឆន្ទៈលាឈប់ ឬមានច្បាប់អនុញ្ញាតឈប់ពីការងារក្នុងតំណែងចាស់ ក្នុងរយៈពេលនៃអាណត្តិការងារ

- មិនមែនជាសមាជិកកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ឬកងនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការ ក្នុងក្របខ័ណ្ឌការងារ (ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី)
- មិនមែនជាព្រះសង្ឃ ឬបព្វជិតនៃសាសនាណាមួយ
- មិនមែនជាប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ឬជំទប់ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ
- មកពីជនជាតិភាគតិច (ប្រសិនបើមាន)
- មានលទ្ធភាពចូលរួម ក្នុងការបណ្តុះបណ្តាល និងការបំពេញការងារពេញម៉ោង និងពេញអាណត្តិការងារ
- មានសុខភាពល្អ
- មានកិត្តិស័ព្ទជាអ្នកមានកិរិយាមារយាទល្អ ស្មោះត្រង់ សុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

២.១៩.៣.៥ លក្ខខណ្ឌបច្ចេកទេសដោយឡែកដែលទាមទារសម្រាប់ការបំពេញការងារជាក់លាក់មួយ រួមមានលក្ខខណ្ឌ ៖
- ត្រូវចេះអាន និងសរសេរអក្សរខ្មែរ
- មានចំណេះដឹង ឬបទពិសោធប្រហាក់ប្រហែល ដែលទាក់ទងជាមួយនឹងតួនាទី
- សម្រាប់តួនាទីមួយចំនួន ទាមទារឱ្យមានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ស្ម័គ្រចិត្តធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងរាជធានី ខេត្ត ឬក្នុងឃុំ សង្កាត់ ។

២.១៩.៣.៦ ពាក្យសុំណាដែលឆ្លើយតបនឹងលក្ខខណ្ឌបច្ចេកទេស ត្រូវធ្វើការសម្រាំងជាលើកទីពីរ ដើម្បីជ្រើសរើសយកបេក្ខជនល្អ ។

២.១៩.៣.៧ បេក្ខជនល្អចំនួនបី (៣)រូប សម្រាប់មុខតំណែងនីមួយៗ ត្រូវបានអញ្ជើញមកធ្វើសម្ភាសន៍ ពេលនោះចំណេះដឹង លក្ខណសម្បត្តិ និងសមត្ថភាពក្នុងការបំពេញការងាររបស់បេក្ខជន នឹងត្រូវបានសាកល្បង និងត្រួតពិនិត្យ ។

២.១៩.៣.៨ ការធ្វើសម្ភាសន៍ ត្រូវពិនិត្យជាបឋមទៅលើកម្រិតវប្បធម៌ និងមុខតំណែង សញ្ញាបត្រ និងបទពិសោធការងារពាក់ព័ន្ធ ។

២.១៩.៣.៩ ជាបន្ទាប់កិច្ចសម្ភាសន៍ ត្រូវធ្វើដោយផ្ទាល់មាត់លើរបៀបធ្វើការងារ និងដោយឱ្យធ្វើតេស្តជាក់ស្តែងដូចជា វាយកុំព្យូទ័រ ឬសរសេរលិខិតស្នាម ព្រមទាំងពិនិត្យលើអត្តចរិត និងកាយសម្បទាផង ។

២.១៩.៣.១០ ក្នុងការធ្វើសម្ភាសន៍ សមាជិកគណៈកម្មការជ្រើសរើសម្នាក់ៗ ត្រូវផ្តល់ពិន្ទុដល់បេក្ខជនម្នាក់ៗក្នុងតារាងវាយតម្លៃមួយ ដើម្បីធ្វើការបូកសរុបពិន្ទុរួម ។

២.១៩.៣.១១ បន្ទាប់ពីការធ្វើសម្ភាសន៍ និងធ្វើតេស្តចប់ គណៈកម្មការជ្រើសរើស ត្រូវធ្វើការបូកសរុបពិន្ទុ ដោយធ្វើចំណាត់ថ្នាក់ដូចខាងក្រោម ៖

- **A** : សម្រាប់បេក្ខជនដែលបានពិន្ទុខ្ពស់ជាងគេ
- **B** : សម្រាប់បេក្ខជនដែលបានពិន្ទុខ្ពស់ជាងបន្ទាប់
- **C** : សម្រាប់បេក្ខជនដែលបានពិន្ទុទាបជាងគេ

២.១៩.៣.១២ បន្ទាប់មក គណៈកម្មការជ្រើសរើស ត្រូវធ្វើការប្រជុំដើម្បីកំណត់ចំណាត់ថ្នាក់បេក្ខជនទាំង (០៣)នាក់ រួចបញ្ជូនឈ្មោះបេក្ខជនទាំងនោះទៅតាមឋានានុក្រម ដើម្បីធ្វើការសម្រេច ។

២.១៩.៣.១៣ សមាសភាព គធ/ខប គឃ/សប និងសមាសភាព គកប ដែលបានតែងតាំងទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចាប់ផ្តើមបម្រើការងារ ។

**ការតែងតាំងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក**

**ប្រការ** ២.២០ ដើម្បីអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិកនៃ គ.ជ.ប សមាជិក និងបុគ្គលិកនៃ គធ/ខប គឃ/សប និងសមាសភាព គកប/គករ គ.ជ.ប ត្រូវបង្កើតឱ្យមានគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិកនៅតាមថ្នាក់នីមួយៗ ។

២.២០.១ គណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដែលមានសមាជិកយ៉ាងតិចបី (៣)រូប ត្រូវបានតែងតាំងដោយ គ.ជ.ប ដើម្បីជ្រើសរើសមន្ត្រីបុគ្គលិកនៃ គ.ជ.ប ឬជ្រើសរើសសមាជិក និងបុគ្គលិកនៃ គធ/ខប ។

២.២០.១.១ គ.ជ.ប ត្រូវតែងតាំងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដោយឡែកពីគ្នា ដើម្បីជ្រើសរើសមន្ត្រី បុគ្គលិកនៃ គ.ជ.ប ឬដើម្បីជ្រើសរើសសមាជិក និងបុគ្គលិកនៃ គធ/ខប ។

២.២០.១.២ គណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិកនីមួយៗ រួមមានសមាសភាព អគ្គលេខាធិការ ឬតំណាង ប្រធាន ឬអនុប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានការិយាល័យបុគ្គលិក ប្រធាន ឬអនុប្រធាននាយកដ្ឋាន និង ប្រធាន ឬអនុប្រធានការិយាល័យ ឬ/និងមន្ត្រីលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ។

២.២០.១.៣ ក្នុងការជ្រើសរើសមន្ត្រីបុគ្គលិកសម្រាប់នាយកដ្ឋានជំនាញនៅ គ.ជ.ប គណៈកម្មការនេះត្រូវមានបន្ថែមសមាសភាពប្រធាន ឬអនុប្រធាន នាយកដ្ឋានពាក់ព័ន្ធ ។

២.២០.២ គណៈកម្មការជ្រើសរើសដែលមានសមាសភាពយ៉ាងតិចបី (៣)រូប នៅ គធ/ខប ត្រូវបាន តែងតាំងដោយ គធ/ខប ដើម្បីជ្រើសរើសសមាសភាព គឃ/សប ។ ដោយឡែក សមាសភាព គកប/គករ ត្រូវជ្រើសរើសដោយ គឃ/សប ហើយជំនួយការ ស្មៀន ត្រូវជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.២០.៣ ករណីចាំបាច់ ប្រធានគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិកអាចចាត់តាំងអនុគណៈ កម្មការមួយក្នុងចំណោមសមាជិក ដែលមានឈ្មោះក្នុងគណៈកម្មការជ្រើសរើស ដើម្បីពិនិត្យជម្រុះលើកទី១ នូវបេក្ខជនដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាម លក្ខខណ្ឌជ្រើសរើស ។

២.២០.៤ សមាជិកនៃគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ត្រូវបំពេញការងារក្នុងជំហរអព្យាក្រឹត យុត្តិធម៌ និងមិនលំអៀង ។

២.២០.៥ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា សមាជិកណាម្នាក់នៃគណៈកម្មការ ជ្រើសរើសមន្ត្រីបុគ្គលិក បានល្មើសនឹងនីតិវិធីនៃការជ្រើសរើសមន្ត្រីបុគ្គលិករបស់ គ.ជ.ប នោះ យោងតាមកំរិតធ្ងន់ ឬស្រាល អ្នកនោះនឹងត្រូវទទួលពិន័យពី គ.ជ.ប ។ រូបភាពពិន័យ រួមមានចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

**ប្រាក់កម្រៃរបស់សមាជិក និងបុគ្គលិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់**

**ប្រការ ២.២១** ប្រាក់កម្រៃរបស់សមាជិក និងបុគ្គលិកនៃគណៈកម្មាធិការជាតិ និងសមាជិក និងបុគ្គលិកនៃ គណៈកម្មការគ្រប់លំដាប់ថ្នាក់ និងមន្ត្រីចុះឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដោយសេចក្តី សម្រេចរបស់ គ.ជ.ប ។

២.២១.១ ប្រាក់កម្រៃត្រូវតែបានពិនិត្យជារៀងរាល់ឆ្នាំ ។

២.២១.២ ប្រាក់កម្រៃត្រូវបើកជារៀងរាល់ខែចំពោះមន្ត្រី បុគ្គលិកជាប់កិច្ចសន្យា ហើយត្រូវបើកផ្តាច់ចំពោះមន្ត្រី បុគ្គលិកម៉ៅការក្រោយការបញ្ចប់ការងារ ។

២.២១.៣ ប្រាក់កម្រៃត្រូវបើកជូនជាប្រាក់រៀលទៅតាមលទ្ធភាពបើកប្រាក់របស់រតនាគារជាតិ ។

**អាណត្តិរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រការ ២.២២** អាណត្តិរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់រួមមាន ៖

២.២២.១ គកប/គករ ត្រូវបំពេញការងាររបស់ខ្លួន រហូតដល់ថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់ខ្លួន និងក្រោយពីបានប្រគល់កំណត់ហេតុនៃការបោះឆ្នោតរាប់សន្លឹកឆ្នោតព្រមទាំងសម្ភារៈឧបករណ៍បោះឆ្នោតចប់សព្វគ្រប់ជូន គឃ/សប រួចរាល់ហើយ ។

២.២២.២ គឃ/សប ត្រូវបំពេញភារកិច្ចរបស់ខ្លួនរហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។

២.២២.៣ គធ/ខប ត្រូវបំពេញភារកិច្ចរបស់ខ្លួន រហូតដល់ថ្ងៃប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្តរបស់ខ្លួន ។

២.២២.៤ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់មានការតែងតាំងថ្មី ។

**ការតែងតាំងក្នុងរយៈពេលមានកំណត់**

**ប្រការ ២.២៣** គ.ជ.ប មានសិទ្ធិតែងតាំង គធ/ខប គឃ/សប ឬ គកប/គករ ក្នុងរយៈពេលមានកំណត់នៅពេលណាមួយបន្ទាប់ពីការបោះឆ្នោតក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែង ការបោះឆ្នោតសាជាថ្មី ។

២.២៣.១ ក្នុងការតែងតាំងក្នុងរយៈពេលមានកំណត់នេះ នីតិវិធីអំពីការជ្រើសរើស រចនាសម្ព័ន្ធសមាសភាព លក្ខណៈវិនិច្ឆ័យ សិទ្ធិអំណាច ការទទួលខុសត្រូវ ប្រាក់កម្រៃ ត្រូវអនុលោមតាមបទបញ្ជា និងនីតិវិធីនេះ និងតាមការសម្រេចរបស់ គ.ជ.ប ។

២.២៣.២ អាណត្តិរបស់ គធ/ខប គឃ/សប និង គកប/គករ ដែលត្រូវបានតែងតាំងក្នុងរយៈពេលមានកំណត់នេះ ត្រូវបញ្ចប់នៅពេលចប់ភារកិច្ចតាមការកំណត់របស់ គ.ជ.ប ។

**ការដាក់វិន័យ ការព្យួរការងារ ការបណ្តេញចេញពីការងារចំពោះបុគ្គលិក ឬសមាជិកគណៈកម្មការ**

**ប្រការ ២.២៤** សមាជិក ឬបុគ្គលិកនៃគណៈកម្មការថ្នាក់ណាមួយដែលធ្វើល្មើសនឹង ច.ប.ឃ.ស បទបញ្ញត្តិក្នុង និង ប.ន.ឃ.ស របស់ គ.ជ.ប ឬអ្នកដែលបដិសេធមិនព្រមប្រតិបត្តិតាមសេចក្តីណែនាំរបស់ គ.ជ.ប ត្រូវទទួលការដាក់ពិន័យដោយអនុលោមតាមទំហំនៃអំពើល្មើស ។ វិធានការដាក់ពិន័យ ត្រូវចាប់ផ្តើមពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

**គោលការណ៍នៃការប្រើប្រាស់សម្ភារៈ និងបរិក្ខារនៃ គ.ជ.ប**

**ប្រការ ២.២៥** សម្ភារៈ និងបរិក្ខារនៃ គ.ជ.ប ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការងាររៀបចំការបោះឆ្នោត លើកលែងតែមានការសម្រេចរបស់ គ.ជ.ប ។

២.២៥.១ គ្មានសមាជិក ឬបុគ្គលិកនៃ គ.ជ.ប ឬនៃគណៈកម្មការថ្នាក់ណាមួយអាចប្រើប្រាស់បរិក្ខារ ឬ/និងសម្ភារៈនៃ គ.ជ.ប ក្រៅពីការរៀបចំការបោះឆ្នោតឡើយ ។ ត្រូវបានកំណត់ជាសម្ភារៈ និងបរិក្ខារមានដូចជា រថយន្ត សម្ភារៈការិយាល័យ សម្ភារៈចុះឈ្មោះបោះឆ្នោត សម្ភារៈបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬសម្ភារៈផ្គត់ផ្គង់ការបោះឆ្នោត និងប្រេងឥន្ធនៈ ។ល។

២.២៥.២ ប្រសិនបើ សមាជិកឬបុគ្គលិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយល្មើសនឹងចំណុច ២.២៥.១ ជននោះនឹងត្រូវដាក់ពិន័យ ។ វិធានការដាក់ពិន័យគឺគិតចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

២.២៥.៣ សមាជិក ឬបុគ្គលិកនៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ដែលល្មើសក្នុងការប្រើប្រាស់សម្ភារៈ បរិក្ខារទាំងនេះ ត្រូវទូទាត់សងតម្លៃទៅតាមការកំណត់របស់ គ.ជ.ប ។

២.២៥.៤ ប្រសិនបើសមាជិក ឬបុគ្គលិកណាម្នាក់នៃគណៈកម្មាធិការ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ធ្វើឱ្យសម្ភារៈ ឯកសារត្រូវបាត់បង់ ឬខូចខាតក្នុងពេល ប្រើប្រាស់ខុសច្បាប់បុគ្គលនោះត្រូវទូទាត់សងតម្លៃនៃសម្ភារៈ ឯកសារដែលបានបាត់បង់ ឬខូចខាតនោះ ។

២.២៥.៥ គ.ជ.ប ត្រូវចេញផ្សាយបទបញ្ជាជាមូលដ្ឋានសម្រាប់ការប្រើប្រាស់សម្ភារៈបរិក្ខារ ។

**ប្រតិទិនការងារបោះឆ្នោត**

**ប្រការ ២.២៦** គ.ជ.ប ត្រូវបោះពុម្ពផ្សាយប្រតិទិនការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.២៦.១ បន្ទាប់ពីប្រកាសថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គ.ជ.ប ត្រូវចាត់ចែងធ្វើប្រតិទិនការងារបោះឆ្នោត និងបោះពុម្ពផ្សាយជាបន្ទាន់ ។

២.២៦.២ ការបោះពុម្ពផ្សាយប្រតិទិនការងារបោះឆ្នោត ត្រូវធ្វើឡើងឱ្យបានមុនថ្ងៃចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

២.២៦.៣ ប្រតិទិនការងារបោះឆ្នោតត្រូវកំណត់ ៖

- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ថ្ងៃចាប់ផ្តើមចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងថ្ងៃបញ្ចប់ទទួលពាក្យ
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត
- ថ្ងៃបោះឆ្នោត និងថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ន និងលទ្ធផលជាផ្លូវការ ។

**ការធានាសន្តិសុខបោះឆ្នោត**

**ប្រការ២.២៧** ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវចំពោះការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការងារដទៃទៀត ត្រូវផ្តល់កិច្ចសហការដល់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាសុវត្ថិភាពសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈក្នុងសម័យបោះឆ្នោត និងក្រោយសម័យបោះឆ្នោត ។

២.២៧.១ ផ្អែកតាមផែនការអន្តរស្ថាប័នមហាផ្ទៃ_ការពារជាតិ និង គ.ជ.ប លេខ ០១៤ ផក/១១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ សម្រាប់ដំណើរការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ_ថ្នាក់ជាតិ ឆ្នាំ២០១១_២០១៤ គឺរាជរដ្ឋាភិបាល បានសម្រេចបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត អក្សរកាត់ (គ.ស.អ) ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានតួនាទី ភារកិច្ចត្រូវសហការ និងរៀបចំចាត់វិធានការ ឬសេចក្តីណែនាំផ្សេងៗ ស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ និងត្រួតពិនិត្យគ្រប់គ្រងការរៀបចំចាត់តាំងកងកម្លាំងនគរបាលជាតិ ឬ/និងកងយោធពលខេមរភូមិន្ទ ឬ/និងកងរាជអាវុធហត្ថឱ្យបំពេញភារកិច្ច ជាភ្នាក់ងារសន្តិសុខបោះឆ្នោតនៅក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.២៧.២ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ជាជំនួយការផ្នែកការងារសន្តិសុខបោះឆ្នោត ឱ្យ គ.ជ.ប មានភារកិច្ចសម្របសម្រួល និងសហការជាមួយលេខាធិការដ្ឋានរបស់ គ.ស.អ ឬ/និងអង្គភាពជំនាញនៃស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំខ្លឹមសារនៃផែនការ ឬសេចក្តីណែនាំផ្សេងៗ ស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.២៧.៣ យន្តការ និងរចនាសម្ព័ន្ធផ្នែកសន្តិសុខរបស់ គ.ជ.ប និង គ.ស.អ ៖




២.២៧.៤ គ.ជ.ប លធ/ខប ឬគធ/ខប ក្រុមប្រឹក្សាឃុំ សង្កាត់ គឃ/សប និង គកប/គករ ត្រូវសហការតាមឋានានុក្រមនៃរចនាសម្ព័ន្ធចាត់តាំងផ្នែកសន្តិសុខ របស់ គ.ស.អ ដែលរួមមាន ៖ លេខាធិការដ្ឋានរបស់ គ.ស.អ គណៈអភិបាល ឬគណៈបញ្ជាការឯកភាព រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងនគរបាលប៉ុស្តិ៍រដ្ឋបាល ឃុំ សង្កាត់ ឬ/និងក្រុមប្រឹក្សាឃុំ សង្កាត់ និងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដូចបានកំណត់បង្ហាញក្នុងចំណុច ២.២៧.៣ ខាងលើ ។

២.២៧.៥ ភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ត្រូវស្ថិតក្នុងឯកសណ្ឋាន កងនគរបាលជាតិ ឬកងរាជអាវុធហត្ថ ឬកងយោធពលខេមរភូមិន្ទ ឱ្យបានត្រឹមត្រូវ និងត្រូវគោរព អនុវត្តតាមគោលការណ៍នៃ ច.ប.ឃ.ស ប.ន.ឃ.ស ក្រមសីលធម៌ ព្រមទាំងសេចក្តីណែនាំផ្សេងៗ នៅក្នុងពេលកំពុងបំពេញភារកិច្ចការពារនៅតាមបណ្តាគោល

ដៅសំខាន់ៗរួមមាន ៖ ការិយាល័យ ចុះឈ្មោះបោះឆ្នោត ការពារការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ដែលឈរឈ្មោះបោះឆ្នោត ការពារទីស្នាក់ការរបស់ គឃ/សប ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការពារការដឹកជញ្ជូន ការរក្សាទុកនូវសម្ភារៈ ឯកសារ និងឧបករណ៍ផ្សេងៗ សម្រាប់ការបោះឆ្នោត ។

២.២៧.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យរៀបចំគម្រោងផលិតឯកសារ និងសម្ភារៈទាក់ទងការងារសន្តិសុខសំខាន់ៗ រួមមាន ៖ សៀវភៅក្រមសីលធម៌សម្រាប់កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ខិត្តប័ណ្ណផ្សព្វផ្សាយផ្សេងៗទាក់ទងការងារសន្តិសុខ និងប្រឡង់ដៃសន្តិសុខដើម្បីសុំគោលការណ៍សម្រេចពី គ.ជ.ប ។

២.២៧.៧ លធ/ខប ឬ គធ/ខប ត្រូវចាត់ចែងរៀបចំកិច្ចប្រជុំចម្រុះ ក្នុងគោលដៅជួបពិភាក្សា និងស្វែងរកដំណោះស្រាយសមស្រប រួមនឹងការចាត់វិធានការផ្សេងៗដើម្បីបង្ការទប់ស្កាត់ និងកាត់បន្ថយឱ្យបានរាល់បញ្ហាទំនាស់ ឬក៏បាតុភាពនានា ដែលអាចនឹងកើតមានឡើងជាយថាហេតុនៅគ្រប់ដំណាក់កាលនៃការរៀបចំការបោះឆ្នោត ។ កិច្ចប្រជុំត្រូវរៀបចំធ្វើឱ្យបានមួយដង ឬពីរដងក្នុងមួយសប្តាហ៍ជាកំណាត់តាមស្ថានការណ៍ជាក់ស្តែង និងចាំបាច់ ។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ រួមមាន ៖

- ប្រធាន លធ/ខប ឬ គធ/ខប ជាប្រធាន
- អភិបាលរាជធានី ខេត្ត ឬតំណាង ១នាក់ ជាសមាជិក
- តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជាសមាជិក
- តំណាងការិយាល័យអង្គការសិទ្ធិមនុស្សប្រចាំរាជធានី ខេត្ត ជាសមាជិក
- តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ជាសមាជិក
- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង ១នាក់ ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង ១នាក់ ជាសមាជិក
- មេបញ្ជាការយោធភូមិភាគពិសេស ឬយោធភូមិភាគ ១-៥ នៃរាជធានី ខេត្តពាក់ព័ន្ធ ឬតំណាង ១នាក់ ជាសមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត
- ឬតំណាង ១នាក់ ជាសមាជិក

២.២៧.៨ នៅពេលឃោសនាបោះឆ្នោត សមាជិកនៃកងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថ ឬភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលកំពុងបំពេញភារកិច្ច មិនត្រូវ ៖

២.២៧.៨.១ ចូលរួមប្រជុំជាសាធារណៈ ដើម្បីសម្តែងការគាំទ្រ ឬប្រឆាំងចំពោះបេក្ខជន បញ្ជីបេក្ខជន និងគណបក្សនយោបាយណាមួយ ។

២.២៧.៨.២ ឈរកៀកពេក ឬក៏ស្ថិតនៅជិតក្បួនឃោសនា ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត របស់បេក្ខជន វាគ្មិន ឬក្រុមឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតណាមួយ ។

២.២៧.៩ នៅថ្ងៃបោះឆ្នោតភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួនបី (៣)នាក់ ការពារសន្តិសុខនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ ត្រូវស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិ ឬកងរាជអាវុធហត្ថ ឬកងយោធពលខេមរភូមិន្ទ ឱ្យបានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប រហូតដល់ចប់ភារកិច្ច ។

២.២៧.៩.១ ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួនមួយ (១) នាក់ ត្រូវចល័តការពារជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬក៏ចល័តការពារនៅក្នុងបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយត្រូវស្ថិតនៅក្នុងចម្ងាយពីដប់ប្រាំ (១៥) ទៅមួយរយ (១០០) ម៉ែត្រ គ្មានសិទ្ធិប្រើប្រាស់អាវុធឡើយ ។

២.២៧.៩.២ ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួនពីរ (២) នាក់ ទៀតត្រូវចល័តការពារជុំវិញបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដោយត្រូវស្ថិតនៅក្នុងចម្ងាយពីមួយរយ (១០០) ទៅមួយរយហាសិប (១៥០) ម៉ែត្រ មានសិទ្ធិប្រើប្រាស់អាវុធវែងមួយ (១) ដើម បង់មួយ (១) មានគ្រាប់យ៉ាងច្រើនចំនួនសាមសិប (៣០) គ្រាប់ ។

២.២៧.១០ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវហាមជនគ្រប់រូបយកអាវុធជាតិផ្ទុះ ឬសារជាតិផ្ទុះ និងវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ដើម្បីជៀសវាងកុំឱ្យមានការរំខាន ការអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬក៏ហេតុការណ៍អសន្តិសុខផ្សេងៗ ដែលនឹងអាចកើតមានជាថែដន្យ ។

២.២៧.១១ ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ ឬ/និង ក្រុមពន្លត់អគ្គិភ័យ...) អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតបានតែក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ/ខប ប្រធាន គឃ/សប ឬពីប្រធាន គកប/គករ ។

# ជំពូកទី ៣
# សិទ្ធិចុះឈ្មោះ និង សិទ្ធិបោះឆ្នោត

**ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត**

**ប្រការ** ៣.១ ភាពមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ត្រូវបានកំណត់ក្នុងមាត្រា៣៤ នៃរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីសញ្ជាតិ និងមាត្រា១៩ថ្មី នៃ ច.ប.ឃ.ស ។ ដើម្បីមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទ រួមទាំងព្រះសង្ឃ និងបព្វជិតសាសនាផង ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម :

៣.១.១ មានសញ្ជាតិខ្មែរ ។

៣.១.២ មានអាយុ ១៨ឆ្នាំឡើង គិតមកទល់ថ្ងៃបោះឆ្នោត ។

៣.១.៣ មានទីលំនៅក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត ។ ទីលំនៅរបស់ជនណាម្នាក់ក្នុងឃុំ សង្កាត់ណាមួយ គឺជាទីកន្លែងដែលជននោះធ្លាប់រស់នៅជាធម្មតា ហើយតែងតែវិលត្រឡប់មកទីកន្លែងនោះវិញបន្ទាប់ពីអវត្តមានជាបណ្តោះអាសន្នមួយរយៈមក ។

៣.១.៤ មិនស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ។

៣.១.៥ មិនមែនជាជនវិកលចរិត ឬមិនមែនជាជនដែលស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

៣.១.៥.១ ជាជនវិកលចរិតលុះត្រាតែមានលិខិតបញ្ជាក់ដែលចេញដោយមន្ទីរពេទ្យ ឬស្ថាប័នសុខាភិបាល ។

៣.១.៥.២ រាល់លិខិតបញ្ជាក់ត្រូវជាទម្រង់បែបបទកំណត់ដោយស្ថាប័នជំនាញ ។

៣.១.៦ ត្រូវមកបង្ហាញខ្លួននៅចំពោះមុខស្មៀនឃុំ សង្កាត់ ឬជំនួយការដែលបំពេញការងារជំនួសស្មៀន ក្នុងអំឡុងពេលដែលកំណត់ដោយ គ.ជ.ប ដោយភ្ជាប់មកនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណស្របតាមច្បាប់ ។

**ប្រការ ៣.២** ត្រូវបានបដិសេធការសុំចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ចំពោះជនទាំងឡាយណាដែលមិនបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌ ដូចមានចែងក្រោមប្រការ ៣.១ ខាងលើ ។

**ប្រការ ៣.៣** គ្មានជនណាម្នាក់មានសិទ្ធិចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានឡើយ ប្រសិនបើជននោះ ៖

៣.៣.១ ស្ថិតនៅក្នុងស្ថានភាពជាប់ពន្ធនាគារ ។

៣.៣.២ ជាជនវិកលចរិត ឬស្ថិតនៅក្រោមអាណាព្យាបាលដែលមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

៣.៣.៣ ជាជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ។

**ភាពមានសិទ្ធិបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើនៅពេលបោះឆ្នោត**

**ប្រការ ៣.៤** ដើម្បីមានសិទ្ធិបោះឆ្នោត ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវ ៖

៣.៤.១ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការដែល គ.ជ.ប បានផ្តល់សុពលភាពចុងក្រោយ ។

៣.៤.២ មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ប្រើនៅពេលបោះឆ្នោត ។ អនុលោមតាម ច.ប.ឃ.ស និង ប.ន.ឃ.ស របស់ គ.ជ.ប ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការរួមមាន ៖

៣.៤.២.១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

៣.៤.២.២ លិខិតឆ្លងដែន ។

៣.៤.២.៣ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ។

៣.៤.២.៤ អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ ។

៣.៤.២.៥ អត្តសញ្ញាណប័ណ្ណនគរបាលជាតិ ។

៣.៤.២.៦ ប័ណ្ណសម្គាល់ខ្លួនចេញដោយក្រសួងស្ថាប័នរដ្ឋ ។

៣.៤.២.៧ សៀវភៅគ្រួសារមានបិទរូបថតសាមីខ្លួនអ្នកបោះឆ្នោត/ប័ណ្ណសម្គាល់គ្រួសារមានបិទរូបថតសាមីខ្លួនអ្នកបោះឆ្នោត ។

៣.៤.២.៨ ឆាយាគណៈមហានិកាយសុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ សង្ឃដីកា។

៣.៤.២.៩ លិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើឱ្យការបោះឆ្នោត ។

**ប្រការ ៣.៥** នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ទោះបីមានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ដូចចែងក្រោមចំណុច ៣.៤.២ ខាងលើ ក៏មិនត្រូវអនុញ្ញាតឱ្យបោះឆ្នោតដែរ ។

**ប្រការ ៣.៦** នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ដូចចែងក្រោមចំណុច ៣.៤.២ ខាងលើ ក៏មិនត្រូវអនុញ្ញាតឱ្យបោះឆ្នោតដែរ ។

# ជំពូកទី ៤
# ប្រព័ន្ធបោះឆ្នោត និង ការបែងចែកអាសនៈ

## ប្រព័ន្ធបោះឆ្នោត

**ប្រការ ៤.១** ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ដោយយកឃុំ សង្កាត់ជាមណ្ឌលបោះឆ្នោត និងបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ។

**ប្រការ ៤.២** ចំនួនអាសនៈនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវស្មើគ្នានឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកំណត់ដោយអនុក្រឹត្យអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**ប្រការ ៤.៣** គជ/ខប ត្រូវធ្វើការបែងចែកអាសនៈក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ៤.៤** អាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបែងចែក ដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ។

**ប្រការ ៤.៥** សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសចេញពីក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលត្រូវបានជាប់ឆ្នោតនៅក្នុងឃុំ សង្កាត់នីមួយៗ ។

## ការបែងចែកអាសនៈ

**ប្រការ ៤.៦** ដើម្បីបែងចែកអាសនៈក្រុមប្រឹក្សានៅឃុំ សង្កាត់នីមួយៗ ត្រូវអនុវត្តតាមករណីដូចតទៅ ៖

៤.៦.១ ឃុំ សង្កាត់ណាដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតែមួយគត់ ឃុំ សង្កាត់នោះក៏ត្រូវធ្វើការបោះឆ្នោតដែរ ។

៤.៦.២ ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សានៅឃុំ សង្កាត់ ក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយឈរឈ្មោះ និងក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយជាប់ឆ្នោត ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះដូចគ្នាតាមលំដាប់លេខរៀងពីលើមកក្រោម រហូតដល់គ្រប់អាសនៈនៅក្នុងក្រុមប្រឹក្សា ។

៤.៦.៣ ក្នុងករណីការបោះឆ្នោតក្នុងឃុំ សង្កាត់ មានបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយជាប់ឆ្នោត អាសនៈនៅក្នុងក្រុមប្រឹក្សានៃឃុំ សង្កាត់នោះត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតតាមជំហានទាំងឡាយដូចខាងក្រោម ៖

**<u>ជំហានទី១</u> ការកំណត់កូតា** (**Quota**)

៤.៦.៣.១ កូតា គឺជាចំនួនសន្លឹកឆ្នោតបានការនៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ដែលកំណត់ឡើងសម្រាប់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ទទួលបានមួយ (១) អាសនៈ ។

៤.៦.៣.២ ដើម្បីកំណត់កូតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់មណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ចែកនឹងចំនួនអាសនៈសរុបដែលបានកំណត់សម្រាប់ក្រុមប្រឹក្សានៃឃុំ សង្កាត់នីមួយៗនោះតាមរូបមន្តដូចខាងក្រោម ៖

$$ក_{ត} \quad \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ

- $ក_{ត}$ តាងឱ្យកូតា ដែលជាផលចែកមិនគិតសំណល់ចែក។
- $ស_{ស}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ។
- $អ_{ស}$ តាងឱ្យចំនួនអាសនៈសរុប ។

**<u>ឧទាហរណ៍</u>**

នៅមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** មាន ៖

- សន្លឹកឆ្នោតបានការសរុប $ស_{ស}$ ៨៣៥២ សន្លឹក
- អាសនៈសរុប $អ_{ស}$ ១១ អាសនៈ

អនុវត្តតាមរូបមន្តខាងលើយើងបាន ៖

$$ក_{ត} \quad \frac{ស_{ស}}{អ_{ស}} \quad \frac{៨៣៥២}{១១} \quad ៧៥៩$$

កូតាស្មើនឹង ៧៥៩ ($ក_{ត}$ ៧៥៩)

**ជំហានទី២ ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈលើកទី ១**

៤.៦.៣.៣ ដើម្បីកំណត់ចំនួនអាសនៈបឋម សម្រាប់ផ្តល់ឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ មកចែកនឹងកូតា តាមរូបមន្តដូចខាងក្រោម ៖

$$អ_ទ \quad \frac{ស_ប}{ក_ត}$$

ក្នុងនោះ

- $អ_ទ$ តាងឱ្យចំនួនអាសនៈ ជាផលចែកមិនគិតសំណល់ចែក ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ។
- $ស_ប$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $ក_ត$ តាងឱ្យកូតា ។

**ឧទាហរណ៍**

ការកំណត់ចំនួនអាសនៈបឋមនៅមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ដដែល ដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៦ ឈរឈ្មោះបោះឆ្នោត ។

| | | | | | |
|---|---|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | **ក** | មានសន្លឹកឆ្នោតបានការ | $ស_ប$ក | ១១៧៩ | សន្លឹក |
| បញ្ជីបេក្ខជននៃគណបក្ស | **ខ** | មានសន្លឹកឆ្នោតបានការ | $ស_ប$ខ | ២២៧៥ | សន្លឹក |
| បញ្ជីបេក្ខជននៃគណបក្ស | **គ** | មានសន្លឹកឆ្នោតបានការ | $ស_ប$គ | ៣១៣១ | សន្លឹក |
| បញ្ជីបេក្ខជននៃគណបក្ស | **ឃ** | មានសន្លឹកឆ្នោតបានការ | $ស_ប$ឃ | ៣៨២ | សន្លឹក |
| បញ្ជីបេក្ខជននៃគណបក្ស | **ង** | មានសន្លឹកឆ្នោតបានការ | $ស_ប$ង | ១០៩១ | សន្លឹក |
| បញ្ជីបេក្ខជននៃគណបក្ស | **ច** | មានសន្លឹកឆ្នោតបានការ | $ស_ប$ច | ២៩៤ | សន្លឹក |

បន្ទាប់ពីអនុវត្តតាមរូបមន្តជំហានទី២ ក្នុងចំណុច ៤.៦.៣.៣ យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស **ក** $អ_ទ$ក $\frac{១១៧៩}{៧៥៩}$ ១,៥៥ ត្រូវជា ១ អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ខ** $អ_ទ$ខ $\frac{២២៧៥}{៧៥៩}$ ២,៩៩ ត្រូវជា ២ អាសនៈ

| | | | | | | | |
|---|---|---|---|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | **គ** | $អ_{ទ}គ$ | $\frac{៣១៣១}{៧៥៩}$ | ៤,១២ | ត្រូវជា | ៤ | អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឃ** | $អ_{ទ}ឃ$ | $\frac{៣៨២}{៧៥៩}$ | ០,៥០ | ត្រូវជា | ០ | អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **ង** | $អ_{ទ}ង$ | $\frac{១០៩១}{៧៥៩}$ | ១,៤៣ | ត្រូវជា | ១ | អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **ច** | $អ_{ទ}ច$ | $\frac{២៩៤}{៧៥៩}$ | ០,៣៨ | ត្រូវជា | ០ | អាសនៈ |

៤.៦.៣.៤ បន្ទាប់ពីគណនាតាមរូបមន្តជំហានទី២ គ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់រួចមក ហើយប្រសិនបើគ្មានអាសនៈនៅសល់ នោះចំនួនអាសនៈត្រូវកំណត់យកតែម្តង ។

**<u>ជំហានទី៣</u> ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈលើកទី ២**

៤.៦.៣.៥ ក្នុងករណីមានអាសនៈនៅសល់ បន្ទាប់ពីការបែងចែកអាសនៈលើកទី១ គធ/ខប ត្រូវបន្តបែងចែកអាសនៈដែលនៅសល់នោះឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមការគណនាដូចខាងក្រោម ។

៤.៦.៣.៥.១ មធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវបានកំណត់ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ចែកនឹងចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗបានទទួលក្នុងការបែងចែកលើកទី ១ បូកនឹងលេខនិមិត្តចំនួនមួយ(១) តាមរូបមន្តដូចខាងក្រោម ៖

$$ម_{ធ} \quad \frac{ស_{ប}}{អ_{ទ}+១}$$

ក្នុងនោះ

- $ម_{ធ}$ តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។

- សᵤ តាងឱ្យសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- អᵤ តាងឱ្យចំនួនអាសនៈបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបាន ។
- ១ ជាលេខនិមិត្ត

៤.៦.៣.៥.២ ក្នុងការរកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវគណនាដល់ចំនួនទសភាគគឺពីរ (២) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ ។

៤.៦.៣.៥.៣ បន្ទាប់ពីកំណត់បានមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចហើយ ត្រូវធ្វើការប្រៀបធៀបគ្នា ។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតទាំងចំនួនទសភាគពីរខ្ទង់ក្រោយក្បៀស) ត្រូវទទួលបានអាសនៈមួយ (១) ។

**<u>ឧទាហរណ៍</u>**

ការបែងចែកអាសនៈលើកទី ២ នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ដដែល តាមការបែងចែកអាសនៈលើកទី ១ តាមរូបមន្តជំហានទី២ យើងបាន ៖

| | | | |
|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | **ក** | បានទទួលអាសនៈ | ១ |
| បញ្ជីបេក្ខជននៃគណបក្ស | **ខ** | បានទទួលអាសនៈ | ២ |
| បញ្ជីបេក្ខជននៃគណបក្ស | **គ** | បានទទួលអាសនៈ | ៤ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឃ** | បានទទួលអាសនៈ | ០ |
| បញ្ជីបេក្ខជននៃគណបក្ស | **ង** | បានទទួលអាសនៈ | ១ |
| បញ្ជីបេក្ខជននៃគណបក្ស | **ច** | បានទទួលអាសនៈ | ០ |

អាសនៈដែលបានបែងចែកលើកទី ១ សរុបមាន ៨ អាសនៈ

អាសនៈសរុបក្នុងក្រុមប្រឹក្សាឃុំ សង្កាត់មាន ១១ អាសនៈ

អាសនៈនៅសល់ត្រូវបន្តធ្វើការបែងចែកមាន ៣ អាសនៈ ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ យើងបាន ៖

| | | | | | | |
|---|---|---|---|---|---|---|
| គណបក្ស | ក | ម្ធក | = | ១១៧៩ / ១+១ | = | ៥៨៩,៥០ |
| គណបក្ស | ខ | ម្ធខ | = | ២២៧៥ / ២+១ | = | ៧៥៨,៣៣ |
| គណបក្ស | គ | ម្ធគ | = | ៣១៣១ / ៤+១ | = | ៦២៦,២០ |
| គណបក្ស | ឃ | ម្ធឃ | = | ៣៨២ / ០+១ | = | ៣៨២,០០ |
| គណបក្ស | ង | ម្ធង | = | ១០៩១ / ១+១ | = | ៥៤៥,៥០ |
| គណបក្ស | ច | ម្ធច | = | ២៩៤ / ០+១ | = | ២៩៤,០០ |

តាមការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងប្រាំមួយខាងលើ បញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ មានមធ្យមភាគធំជាងគេគឺ ៧៥៨,៣៣ ដែលជាមធ្យមភាគខ្ពស់បំផុត ។ ដូចនេះ បញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ត្រូវទទួលបានអាសនៈមួយ (១) ក្នុងការបែងចែកអាសនៈលើកទី ២ នេះ។

៤.៦.៣.៦ ក្នុងករណីនៅមានសល់អាសនៈ បន្ទាប់ពីការបែងចែកលើកទី២ គជ/ខប ត្រូវបន្តបែងចែកអាសនៈដែលនៅសល់នោះ តាមរូបមន្តជំហានទី៣ ដដែល។

**<u>ឧទាហរណ៍</u>**

ការបែងចែកអាសនៈលើកទី ៣ នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ដដែល តាមការបែងចែកអាសនៈលើកទី១ និង ទី២ យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស ក បានទទួលអាសនៈ ១

បញ្ជីបេក្ខជននៃគណបក្ស ខ បានទទួលអាសនៈ ៣ ទើបទទួលបាន១អាសនៈបន្ថែម

បញ្ជីបេក្ខជននៃគណបក្ស គ បានទទួលអាសនៈ ៤

បញ្ជីបេក្ខជននៃគណបក្ស ឃ បានទទួលអាសនៈ ០

បញ្ជីបេក្ខជននៃគណបក្ស ង បានទទួលអាសនៈ ១

បញ្ជីបេក្ខជននៃគណបក្ស ច បានទទួលអាសនៈ ០

អាសនៈដែលបានបែងចែកលើកទី ១ និងទី២ សរុបមាន ៩ អាសនៈ

អាសនៈសរុប ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ **A** មាន ១១ អាសនៈ

អាសនៈ ដែលនៅសល់ត្រូវបន្តធ្វើការបែងចែកមាន ០២ អាសនៈ ។

ក្នុងការបែងចែកលើកទី ៣ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ យើងបាន ៖

| | | | | |
|---|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | ក | ម្ធក | ១១៧៩ / (១+១) | ៥៨៩,៥០ |
| បញ្ជីបេក្ខជននៃគណបក្ស | ខ | ម្ធខ | ២២៧៥ / (៣+១) | ៥៦៨,៧៥ |
| បញ្ជីបេក្ខជននៃគណបក្ស | គ | ម្ធគ | ៣១៣១ / (៤+១) | ៦២៦,២០ |
| បញ្ជីបេក្ខជននៃគណបក្ស | ឃ | ម្ធឃ | ៣៨២ / (០+១) | ៣៨២,០០ |
| បញ្ជីបេក្ខជននៃគណបក្ស | ង | ម្ធង | ១០៩១ / (១+១) | ៥៤៥,៥០ |
| បញ្ជីបេក្ខជននៃគណបក្ស | ច | ម្ធច | ២៩៤ / (០+១) | ២៩៤,០០ |

តាមការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងប្រាំមួយខាងលើ បញ្ជីបេក្ខជននៃគណបក្សនយោបាយ គ មានមធ្យមភាគធំជាងគេគឺ ៦២៦,២០ ដែលជាមធ្យមភាគខ្ពស់បំផុត ។ ដូចនេះ បញ្ជីបេក្ខជននៃគណបក្សនយោបាយ គ ត្រូវទទួលបានអាសនៈមួយ (១) ក្នុងការបែងចែកលើកទី៣ នេះ ដែលនាំឱ្យ ៖

| | | | | |
|---|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | ក | បានទទួលអាសនៈ | ១ | |
| បញ្ជីបេក្ខជននៃគណបក្ស | ខ | បានទទួលអាសនៈ | ៣ | |
| បញ្ជីបេក្ខជននៃគណបក្ស | គ | បានទទួលអាសនៈ | ៥ | ទើបទទួលបាន១អាសនៈបន្ថែម |
| បញ្ជីបេក្ខជននៃគណបក្ស | ឃ | បានទទួលអាសនៈ | ០ | |
| បញ្ជីបេក្ខជននៃគណបក្ស | ង | បានទទួលអាសនៈ | ១ | |
| បញ្ជីបេក្ខជននៃគណបក្ស | ច | បានទទួលអាសនៈ | ០ | |

៤.៦.៣.៧ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀត ការគណនាត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ និងបន្តបែងចែកតាមរបៀបនេះ ម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈ ។

**ឧទាហរណ៍**

ការបែងចែកអាសនៈបន្តនៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ដដែល ។

បន្ទាប់ពីការបែងចែកអាសនៈលើកទី៣ នៅមានសល់អាសនៈចំនួនមួយ (១) ទៀតដែលត្រូវបន្តបែងចែក ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ យើងបាន ៖

| | | | | |
|---|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | ក | មធក | ១១៧៩ / (១ +១) | ៥៨៩,៥០ |
| បញ្ជីបេក្ខជននៃគណបក្ស | ខ | មធខ | ២២៧៥ / (៣ +១) | ៥៦៨,៧៥ |
| បញ្ជីបេក្ខជននៃគណបក្ស | គ | មធគ | ៣១៣១ / (៥ +១) | ៥២១,៨៣ |
| បញ្ជីបេក្ខជននៃគណបក្ស | ឃ | មធឃ | ៣៨២ / (០ +១) | ៣៨២,០០ |
| បញ្ជីបេក្ខជននៃគណបក្ស | ង | មធង | ១០៩១ / (១ +១) | ៥៤៥,៥០ |
| បញ្ជីបេក្ខជននៃគណបក្ស | ច | មធច | ២៩៤ / (០ +១) | ២៩៤,០០ |

តាមការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងប្រាំមួយខាងលើ បញ្ជីបេក្ខជននៃគណបក្ស ក មានមធ្យមភាគធំជាងគេគឺ ៥៨៩,៥០ ដែលជាមធ្យមភាគខ្ពស់បំផុត ។ ដូចនេះ បញ្ជីបេក្ខជននៃគណបក្ស ក ត្រូវបានទទួលមួយ (១) អាសនៈដែលនៅសល់ចុងក្រោយនេះ ។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស ក បានទទួលអាសនៈ ២
បញ្ជីបេក្ខជននៃគណបក្ស ខ បានទទួលអាសនៈ ៣
បញ្ជីបេក្ខជននៃគណបក្ស គ បានទទួលអាសនៈ ៥
បញ្ជីបេក្ខជននៃគណបក្ស ឃ បានទទួលអាសនៈ ០
បញ្ជីបេក្ខជននៃគណបក្ស ង បានទទួលអាសនៈ ១
បញ្ជីបេក្ខជននៃគណបក្ស ច បានទទួលអាសនៈ ០

**សរុប = ដប់មួយ (១១) អាសនៈ**

៤.៦.៣.៤ ក្នុងករណីការបែងចែកអាសនៈលើកទី១ តាមរូបមន្តជំហានទី ២ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈទេនោះ គធ/ខប ត្រូវបន្តបែងចែក ដោយអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ ម្តងមួយអាសនៈៗរហូតដល់អស់អាសនៈ ។

## ឧទាហរណ៍

នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **B** មាន ៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន : ៧
- សន្លឹកឆ្នោតបានការសរុប : $ស_{ស}$ = ៤១០៨
- អាសនៈសរុប : $អ_{ស}$ = ៥ អាសនៈ
- កូតា : $ក_{ត}$ = ៨២១

| បញ្ជីបេក្ខជននៃគណបក្ស | $ស_{ប}$ | $អ_{ទ}$១ | $ម_{ធ}$១ | $អ_{ទ}$២ | $ម_{ធ}$២ | $អ_{ទ}$៣ | $ម_{ធ}$៣ | $អ_{ទ}$៤ | $ម_{ធ}$៤ | $អ_{ទ}$៥ | $ម_{ធ}$៥ | $អ_{ទ}$៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ក | ៥៨២ | ០ | ៥៨២<br>០+១ | ០ | ៥៨២<br>០+១ | ០ | ៥៨២<br>០+១ | ០ | ៥៨២<br>០+១ | ១ | ៥៨២<br>១+១ | ០ |
| ខ | ៧៥៤ | ០ | ៧៥៤<br>០+១ | ១ | ៧៥៤<br>១+១ | ០ | ៧៥៤<br>១+១ | ០ | ៧៥៤<br>១+១ | ០ | ៧៥៤<br>១+១ | ០ |
| គ | ៣៨៣ | ០ | ៣៨៣<br>០+១ | ០ | ៣៨៣<br>០+១ | ០ | ៣៨៣<br>០+១ | ០ | ៣៨៣<br>០+១ | ០ | ៣៨៣<br>០+១ | ០ |
| ឃ | ៦៣៧ | ០ | ៦៣៧<br>០+១ | ០ | ៦៣៧<br>០+១ | ០ | ៦៣៧<br>០+១ | ១ | ៦៣៧<br>១+១ | ០ | ៦៣៧<br>១+១ | ០ |
| ង | ៥៦៤ | ០ | ៥៦៤<br>០+១ | ០ | ៥៦៤<br>០+១ | ០ | ៥៦៤<br>០+១ | ០ | ៥៦៤<br>០+១ | ០ | ៥៦៤<br>០+១ | ១ |
| ច | ៤៦៧ | ០ | ៤៦៧<br>០+១ | ០ | ៤៦៧<br>០+១ | ០ | ៤៦៧<br>០+១ | ០ | ៤៦៧<br>០+១ | ០ | ៤៦៧<br>០+១ | ០ |
| ឆ | ៧២១ | ០ | ៧២១<br>០+១ | ០ | ៧២១<br>០+១ | ១ | ៧២១<br>១+១ | ០ | ៧២១<br>១+១ | ០ | ៧២១<br>១+១ | ០ |

ករណីនេះអាចកើតមាននៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ណា ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានចំនួនសន្លឹកឆ្នោតប្រហាក់ប្រហែលគ្នា ។

តាមតារាងឧទាហរណ៍ខាងលើ យើងបាន ៖

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗ។
- $អ_{ទ}$១ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី ១ តាមរូបមន្តជំហានទី២ ដែលក្នុងនោះពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈឡើយ និងត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទី៣ ។

- ម្ធ១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ១ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ មានមធ្យមភាគធំជាងគេគឺ ៧៥៤,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ្ទ២ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី ២ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ។
- ម្ធ២ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ២ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឆ មានមធ្យមភាគធំជាងគេគឺ ៧២១,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ្ទ៣ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី ៣ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឆ ។
- ម្ធ៣ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឃ មានមធ្យមភាគធំជាងគេគឺ ៦៣៧,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ្ទ៤ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី ៤ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឃ ។
- ម្ធ៤ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ៤ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក មានមធ្យមភាគធំជាងគេគឺ ៥៨២,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ្ទ៥ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី ៥ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក ។
- ម្ធ៥ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ៥ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ មានមធ្យមភាគធំជាងគេគឺ ៥៦៨,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ្ទ៦ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី ៦ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **B** យើងបាន ៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** ទទួលបានមួយ (០១)អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** ទទួលបានមួយ (០១)អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ឃ** ទទួលបានមួយ (០១)អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** ទទួលបានមួយ (០១)អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ឆ** ទទួលបានមួយ (០១)អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **គ** និង **ច** ពុំទទួលបានអាសនៈទេ

**សរុប = ប្រាំ (០៥) អាសនៈ ។**

## ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ

**ប្រការ ៤.៧** ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ឬច្រើន បានទទួលអាសនៈមួយ ឬច្រើន ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែបានប្រកាសបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន គជ/ខប ត្រូវបែងចែកអាសនៈ ដែលបោះបង់ចោលនោះទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀត ដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ក្នុងអំឡុងពេលយ៉ាងយូរដប់បួន (១៤) ថ្ងៃបន្ទាប់ពីថ្ងៃទទួលបានលិខិតបោះបង់ចោលជាផ្លូវការ ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយដូចខាងក្រោម ៖

<u>**ជំហានទី១**</u> ***ការកំណត់កូតា*** (**Quota**)

៤.៧.១ ដើម្បីកំណត់កូតា សម្រាប់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានអាសនៈដែលបោះបង់ចោលមួយ (១)អាសនៈ ត្រូវយកសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានទទួលអាសនៈក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ដកនឹងចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបោះបង់ចោលអាសនៈ រួចយកមកចែកនឹងចំនួនអាសនៈ ដែលបោះបង់ចោលតាមរូបមន្តដូចខាងក្រោម ៖

$$\text{ក់}_{\text{ត}} = \frac{\text{ស់}_{\text{ប}}}{\text{អ់}_{\text{ប}}}$$

ក្នុងនោះ ៖

- ក់ត តាងឱ្យកូតាដែលជាផលចែកមិន គិតសំណល់ចែក ។
- ស់ប តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងមណ្ឌលបោះឆ្នោតនៃឃុំ

សង្កាត់ពាក់ព័ន្ធដកនឹងចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានបោះបង់ចោលអាសនៈ ។

- អ់ប តាងឱ្យចំនួនអាសនៈ ដែលបានបោះបង់ចោល ។

**<u>ឧទាហរណ៍</u>**

ការកំណត់កូតាដែលតម្រូវឱ្យទទួលបានអាសនៈដែលបោះបង់ចោលមួយ (១)អាសនៈ នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ដដែល ដែលក្នុងនោះ ៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** មាន សបក ១១៧៩ ទទួលបាន ២ អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **ខ** មាន សបខ ២២៧៥ ទទួលបាន ៣ អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **គ** មាន សបគ ៣១៣១ ទទួលបាន ៥ អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **ង** មាន សបង ១០៩១ ទទួលបាន ១ អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** មាន សបឃ ៣៨២ ទទួលបាន 0 អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **ច** មាន សបច ២៩៨ ទទួលបាន 0 អាសនៈ

តាមសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ គណបក្ស **ក** បានបោះបង់ចោលអាសនៈទាំងពីរ (២) ដែលទទួលបានក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ។ អនុវត្តតាមប្រការ ៨.៧ អាសនៈដែលបោះបង់នេះត្រូវបែងចែកឱ្យទៅបញ្ជីបេក្ខជននៃគណបក្ស **ខ** **គ** និង **ង** ដែលមានអាសនៈក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នោះ រីឯបញ្ជីបេក្ខជននៃគណបក្ស **ឃ** និង **ច** ដែលពុំមានអាសនៈក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ ពាក់ព័ន្ធខាងលើ ពុំត្រូវបានរាប់បញ្ចូលក្នុងការបែងចែកអាសនៈដែលគណបក្ស **ក** បានបោះបង់ចោលឡើយ ។

ដូចនេះ អនុវត្តតាមរូបមន្តក្នុងចំណុច ៨.៧.១ ខាងលើ យើងបាន ៖

ស់ប = (១១៧៩+២២៧៥+៣១៣១+១០៩១) - ១១៧៩ = ៦៤៩៧

អ់ប = ២

កំត = ស់ប / អ់ប = ៦៤៩៧ / ២ = ៣២៤៨

កូតាស្មើនឹង ៣២៤៨ ។

## <u>ជំហានទី២</u> ការកំណត់ចំនួនអាសនៈបឋម

៨.៧.២ ការបែងចែកអាសនៈដែលបោះបង់ចោលលើកទី ១ ត្រូវបានកំណត់ដោយយកចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលមានអាសនៈក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ មកចែកនឹងកូតានៃអាសនៈដែលបោះបង់ចោលតាមរូបមន្តដូចខាងក្រោម ៖

| | | |
|---|---|---|
| **អ់ទ** | | **សប** / **ក់ត** |

ក្នុងនោះ :

- អ់ទ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗត្រូវទទួលបាន ក្នុងការបែងចែកអាសនៈដែលបោះបង់ចោលលើទី១ តាមរូបមន្ត ជំហានទី២ ។
- សប តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ នីមួយៗ ។
- ក់ត តាងឱ្យកូតា នៃអាសនៈដែលបោះបង់ចោល ។

**ឧទាហរណ៍**

ការបែងចែកអាសនៈដែលបោះបង់ចោលលើកទី ១ នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ដដែល ។

អនុវត្តតាមការបែងចែកអាសនៈដែលបោះបង់ចោលលើកទី ១ តាមរូបមន្តក្នុងជំហានទី២ ចំណុច ៤.៧.២ យើងបាន ៖

| | | | | |
|---|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | ខ | អ់ទខ | ២២៧៥ / ៣២៤៨ | 0,៧0 |
| បញ្ជីបេក្ខជននៃគណបក្ស | គ | អ់ទគ | ៣១៣១ / ៣២៤៨ | 0,៩៦ |
| បញ្ជីបេក្ខជននៃគណបក្ស | ង | អ់ទង | ១0៩១ / ៣២៤៨ | 0,៣៥ |

តាមលទ្ធផលនៃការគណនាខាងលើ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈដែលបោះបង់ចោលនេះទេ ។

៤.៧.៣ ក្នុងករណីពុំមានអាសនៈនៅសល់ បន្ទាប់ពីការបែងចែកលើកទី ១ តាមរូបមន្តជំហានទី ២ ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយបានទទួលក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធត្រូវកំណត់យកតែម្តង ។

**<u>ជំហានទី៣</u> ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈដែលបោះបង់ចោលលើកទី ២**

៤.៧.៤ ក្នុងករណីបន្ទាប់ពីការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោលលើកទី ១ តាមរូបមន្តជំហានទី ២ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួល

បានអាសនៈ ឬនៅមានសល់អាសនៈ អាសនៈទាំងនោះត្រូវយកមកបែងចែកបន្តទៀត តាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទី ៣ ខាងក្រោម ។

៤.៧.៤.១ ដើម្បីកំណត់មធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវធ្វើការគណនាដោយយកចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានអាសនៈក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ចែកនឹងចំនួនអាសនៈ (អ៉ទ) ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលបន្ទាប់ពីការបែងចែកអាសនៈដែលបោះបង់ចោលលើកទី១ បូកនឹងលេខនិមិត្តចំនួន ១ តាមរូបមន្តខាងក្រោម ៖

$$ម៉_{ធ} = \frac{ស_{ប}}{អ៉_{ទ} + ១}$$

ក្នុងនោះ

- ម៉ធ តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- សប តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- អ៉ទ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកអាសនៈដែលបោះបង់ចោលលើកទី ១ ។
- ១ ជាលេខនិមិត្ត ។

៤.៧.៤.២ ក្នុងការរកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវគណនាឱ្យដល់ចំនួនទសភាគគឺពីរ (២) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ ។

៤.៧.៤.៣ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចមក ត្រូវធ្វើការប្រៀបធៀបគ្នា ។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតទាំងចំនួនទសភាគ២ខ្ទង់ក្រោយក្បៀស) នឹងត្រូវទទួលបានអាសនៈមួយ (១) ។

**<u>ឧទាហរណ៍</u>**

ការបែងចែកអាសនៈដែលបោះបង់ចោលលើកទី២ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតនៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ដដែល ។

បន្ទាប់ពីការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី ១ តាមរូបមន្តជំហានទី ២ រួចមក ពុំមានបញ្ជីបេក្ខជននៃគណបក្សណាមួយទទួលបានអាសនៈទេ ។
អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស ខ ម៉ធខ $= \frac{២២៧៥}{០+១} =$ ២២៧៥,០០

បញ្ជីបេក្ខជននៃគណបក្ស គ ម៉ធគ $= \frac{៣១៣១}{០+១} =$ ៣១៣១,០០

បញ្ជីបេក្ខជននៃគណបក្ស ង ម៉ធង $= \frac{១០៩១}{០+១} =$ ១០៩១,០០

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងបីខាងលើ បញ្ជីបេក្ខជននៃគណបក្ស គ មានមធ្យមភាគធំជាងគេគឺ ៣១៣១,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស គ ត្រូវទទួលបានអាសនៈដែលបោះបង់ចោលចំនួនមួយ (១) ក្នុងការបែងចែកលើកនេះ ។

៨.៧.៨.៤ ប្រសិនបើមាននៅសល់អាសនៈទៀត អាសនៈដែលនៅសល់នោះត្រូវបន្តបែងចែកម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ដដែល ។

<u>**ឧទាហរណ៍**</u>

ការបែងចែកអាសនៈដែលបោះបង់ចោលលើកទី ៣ នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **A** ដដែល ។

បន្ទាប់ពីការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី ២ តាមរូបមន្តជំហានទី ៣ រួចមក នៅមានសល់អាសនៈចំនួនមួយ (១)ទៀតត្រូវបែងចែកបន្ត ។
អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស ខ ម៉ធខ $= \frac{២២៧៥}{០+១} =$ ២២៧៥,០០

បញ្ជីបេក្ខជននៃគណបក្ស គ ម៉ធគ $= \frac{៣១៣១}{១+១} =$ ១៥៦៥,៥០

បញ្ជីបេក្ខជននៃគណបក្ស ង ម៉ធង $= \frac{១០៩១}{០+១} =$ ១០៩១,០០

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងបីខាងលើ បញ្ជីបេក្ខជននៃគណបក្ស ខ មានមធ្យមភាគធំជាងគេគឺ ២២៧៥,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស ខ ត្រូវទទួលបានអាសនៈ ដែលបោះបង់ចោលចំនួនមួយ (១) ចុងក្រោយនេះ ។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ A ៖

បញ្ជីបេក្ខជននៃគណបក្ស ខ បានទទួលអាសនៈ ៤

បញ្ជីបេក្ខជននៃគណបក្ស គ បានទទួលអាសនៈ ៦

បញ្ជីបេក្ខជននៃគណបក្ស ង បានទទួលអាសនៈ ១

**សរុប = ដប់មួយ (១១) អាសនៈ**

**ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួនមានមធ្យមភាគខ្ពស់បំផុតស្មើគ្នា**

**ប្រការ ៤.៨** ក្នុងករណីដែលការគណនាតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានចែងក្រោមចំណុច ៤.៦.៣.៥ និង ៤.៧.៤ នៃបទបញ្ជា និងនីតិវិធីនេះមានលទ្ធផលស្មើគ្នា រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន នោះការបែងចែកអាសនៈត្រូវកំណត់ដូចខាងក្រោម ។

៤.៨.១ ក្នុងករណីអាសនៈនៅសល់ បន្ទាប់ពីការបែងចែកលើកទី ១ តាមរូបមន្តជំហានទី២ មានចំនួនស្មើ ឬលើសពីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា គជ/ខប ត្រូវផ្តល់ឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងនោះមួយគណបក្សមួយ (១)អាសនៈ ស្មើគ្នា ។

**<u>ឧទាហរណ៍</u>**

នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ C មាន ៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន : ០៧
- សន្លឹកឆ្នោតបានការសរុប : $សស$ = ៥៧៣២
- អាសនៈសរុប : $អ_{ស}$ = ៩ អាសនៈ
- កូតា : $ក_{ត}$ = ៦៣៦

| បញ្ជីបេក្ខជននៃគណបក្ស | $ស_{ប}$ | $អ_{ទ}១$ | $ម_{ធ}១$ | $អ_{ទ}២$ | $ម_{ធ}២$ | $អ_{ទ}៣$ |
|---|---|---|---|---|---|---|
| ក | ៨៩២ | ១ | $\frac{៨៩២}{១+១}$ = ៤៤៦,០០ | ០ | $\frac{៨៩២}{១+១}$ = ៤៤៦,០០ | ០ |
| ខ | ៤៨៩ | ០ | $\frac{៤៨៩}{០+១}$ = ៤៨៩,០០ | ១ | $\frac{៤៨៩}{១+១}$ = ២៤៤,៥០ | ០ |
| គ | ៣៥៧ | ០ | $\frac{៣៥៧}{០+១}$ = ៣៥៧,០០ | ០ | $\frac{៣៥៧}{០+១}$ = ៣៥៧,០០ | ០ |
| ឃ | ៣៩៥ | ០ | $\frac{៣៩៥}{០+១}$ = ៣៩៥,០០ | ០ | $\frac{៣៩៥}{០+១}$ = ៣៩៥,០០ | ០ |
| ង | ១៣៥២ | ២ | $\frac{១៣៥២}{២+១}$ = ៤៥០,៦៦ | ០ | $\frac{១៣៥២}{២+១}$ = ៤៥០,៦៦ | ១ |
| ច | ១៩៥៦ | ៣ | $\frac{១៩៥៦}{៣+១}$ = ៤៨៩,០០ | ១ | $\frac{១៩៥៦}{៤+១}$ = ៣៩១,២០ | ០ |
| ឆ | ២៩១ | ០ | $\frac{២៩១}{០+១}$ = ២៩១,០០ | ០ | $\frac{២៩១}{០+១}$ = ២៩១,០០ | ០ |

- ស្ប   តាងឱ្យចំនួនសន្លឹកឆ្នោតបានការ   របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- អ្ទ១   តាងឱ្យចំនួនអាសនៈ   ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី ២ នៃចំណុច ៨.៦.៣.៣ ក្នុងនោះ ៖

  បញ្ជីបេក្ខជននៃគណបក្សនយោបាយ ក ទទួលបានមួយ (១) អាសនៈ
  បញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ទទួលបានពីរ (២) អាសនៈ
  បញ្ជីបេក្ខជននៃគណបក្សនយោបាយ ច ទទួលបានបី (៣) អាសនៈ

- ម្ធ១   តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ តាមរូបមន្តជំហានទី ៣ នៃចំណុច ៨.៦.៣.៥ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជន នៃគណបក្សនយោបាយ ខ និង ច មានមធ្យមភាគធំជាងគេស្មើគ្នាគឺ ៥៨៩,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ្ទ២   តាងឱ្យចំនួនអាសនៈ   ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី២ ។ អនុវត្តតាមចំណុច ៨.៨.១ គជ/ខប ត្រូវផ្តល់អាសនៈឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ និង ច មួយគណបក្សមួយ (១)អាសនៈ ស្មើគ្នា។
- ម្ធ២   តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ២ តាមរូបមន្តជំហានទី ៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ មានមធ្យមភាគធំជាងគេគឺ ៥៥០,៦៦ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ្ទ៣   តាងឱ្យចំនួនអាសនៈ   ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី ៣ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ត្រូវទទួលបានអាសនៈដែលនៅសល់មួយ (១) ចុងក្រោយនេះ ។

ជាលទ្ធផលសំរេចក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ C គឺ ៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ ក ទទួលបានមួយ (១) អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ទទួលបានមួយ (១) អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ទទួលបានបី (៣) អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ ច ទទួលបានបួន (៤) អាសនៈ
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ គ ឃ និង ង ពុំបានទទួលអាសនៈ

**សរុប = ប្រាំបួន (៩) អាសនៈ ។**

៤.៨.២ ក្នុងករណីអាសនៈនៅសល់ មានចំនួនតិចជាងចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលមានលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា គធ/ខប ត្រូវអនុវត្ត វិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវ ទទួលបានអាសនៈនោះ ។

**ឧទាហរណ៍**

នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ **D** មាន ៖

- ចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ : ៥
- ចំនួនសន្លឹកឆ្នោតបានការសរុប : $សស$ = ៧៩៦៣
- ចំនួនអាសនៈសរុប : $អស$ = ១១ អាសនៈ
- កូតា : $កត$ = ៧២៣

| បញ្ជីបេក្ខជននៃគណបក្ស | $ស_ប$ | $អ_{ទ១}$ | $ម_{ធ១}$ | $អ_{ទ២}$ | $ម_{ធ២}$ | $អ_{ទ៣}$ |
|---|---|---|---|---|---|---|
| **ក** | ១០២៥ | ១ | $\frac{១០២៥}{១+១}$ = ៥១២,៥០ | ០ | $\frac{១០២៥}{១+១}$ = ៥១២,៥០ | |
| **ខ** | ៧៧៤ | ១ | $\frac{៧៧៤}{១+១}$ = ៣៨៧,០០ | ០ | $\frac{៧៧៤}{១+១}$ = ៣៨៧,០០ | |
| **គ** | ១៨១៧ | ២ | $\frac{១៨១៧}{២+១}$ = ៦០៥,៦៦ | ០ | $\frac{១៨១៧}{២+១}$ = ៦០៥,៦៦ | ? |
| **ឃ** | ៧១៣ | ០ | $\frac{៧១៣}{០+១}$ = ៧១៣,០០ | ១ | $\frac{៧១៣}{១+១}$ = ៣៥៦,៥០ | |
| **ង** | ៣៦៣៤ | ៥ | $\frac{៣៦៣៤}{៥+១}$ = ៦០៥,៦៦ | ០ | $\frac{៣៦៣៤}{៥+១}$ = ៦០៥,៦៦ | ? |

- $ស_ប$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $អ_{ទ១}$ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី ១ តាមរូបមន្តជំហានទី២ ក្នុងនោះ ៖

  បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** ទទួលបានមួយ (១) អាសនៈ

  បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** ទទួលបានមួយ (១) អាសនៈ

បញ្ជីបេក្ខជនរបស់គណបក្សនយោបាយ គ ទទួលបានពីរ (២) អាសនៈ
បញ្ជីបេក្ខជនរបស់គណបក្សនយោបាយ ង ទទួលបានប្រាំ (៥) អាសនៈ

- ម$_{ធ}$១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ តាមរូបមន្តជំហានទី ៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឃ មានមធ្យមភាគធំជាងគេគឺ ៧១៣,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ$_{ទ}$២ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី ២ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឃ ត្រូវទទួលបានមួយ (១) អាសនៈ ។
- ម$_{ធ}$២ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ២ តាមរូបមន្តជំហានទី ៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ គ និង ង មានមធ្យមភាគធំជាងគេស្មើគ្នាគឺ ៦០៥,៦៦ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ$_{ទ}$៣ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី ៣ ដែលក្នុងនោះចំនួនអាសនៈនៅសល់មានតែមួយ(១) តិចជាងចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។ អនុវត្តតាមចំណុច ៨.៨.២ គធ/ខប ត្រូវរៀបចំការចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលត្រូវទទួលបានអាសនៈនៅសល់មួយ (១) ចុងក្រោយនេះ ។

**ការចាប់ឆ្នោតជាសាធារណៈ**

**ប្រការ ៨.៩** ក្នុងករណីដូចមានចែងក្នុងចំណុច ៨.៨.២ គធ/ខប ត្រូវអនុវត្តនូវវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយណា ដែលត្រូវទទួលបានអាសនៈនៅសល់នេះ ។

៨.៩.១ ក្នុងករណីបែបនេះ គធ/ខប ត្រូវប្រគល់ភារកិច្ចឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការចាត់ចែងរៀបចំការចាប់ឆ្នោតជាសាធារណៈ ។

៨.៩.២ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើនៅទីស្នាក់ការ គធ/ខប ក្រោយពេលបញ្ចប់ការបែងចែកអាសនៈនៅតាមមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ផ្សេងទៀតក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ ។

៤.៩.២.១ គធ/ខប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីនៃការចាប់ឆ្នោត ហើយត្រូវអញ្ជើញ ៖

- ភ្នាក់ងារ ឬតំណាងផ្លូវការនៃគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។
- ភ្នាក់ងារ ឬតំណាងផ្លូវការនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ
- អ្នកសង្កេតការណ៍ ដើម្បីចូលរួមក្នុងពិធីចាប់ឆ្នោតនេះ ។

៤.៩.២.២ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមជំហានដូចខាងក្រោម ៖

- មន្ត្រីប្រតិបត្តិការត្រូវសរសេរ ឬបោះពុម្ពនៅលើក្រដាសដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នា នូវឈ្មោះនៃគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាស្មើគ្នា ។ ក្រដាសឆ្នោតមួយសន្លឹកត្រូវសរសេរ ឬបោះពុម្ពឈ្មោះតែមួយគណបក្សនយោបាយប៉ុណ្ណោះ ។ តួអក្សរជាឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា។ ក្រដាសសន្លឹកឆ្នោត ដែលសរសេរ ឬបោះពុម្ពឈ្មោះរបស់គណបក្សនយោបាយ ហើយត្រូវបត់ជាផ្នត់ដូចគ្នា ដាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទ ពណ៌ និងទំហំ ដូចគ្នា រួចបិទភ្ជិត ។
- មន្ត្រីទទួលបន្ទុកប្រតិបត្តិការ ត្រូវបង្ហាញហិបឆ្នោតទទេជាសាធារណៈមុននឹងដាក់សំបុត្រសន្លឹកឆ្នោតចូលទៅក្នុងហិបនោះ និងបិទគម្រប ។
- មន្ត្រីទទួលបន្ទុកប្រតិបត្តិការត្រូវក្រឡុកហិបឆ្នោត រួចលើកហិបឆ្នោត នោះទៅដាក់លើតុខ្ពស់ ។
- តំណាងនៃ គធ/ខប ណាម្នាក់ដែលត្រូវបានគណបក្សនយោបាយពាក់ព័ន្ធទុកចិត្ត និងយល់ព្រម ត្រូវចាប់យកសំបុត្រសន្លឹកឆ្នោតមួយពីក្នុងហិបនោះ រួចជូនទៅប្រធាន ឬតំណាង គធ/ខប ដែលត្រូវបានចាត់តាំង ។
- ប្រធាន ឬតំណាង គធ/ខប ដែលត្រូវបានចាត់តាំង ត្រូវបើកស្រោមសំបុត្រនោះជាសាធារណៈ រួចអានប្រកាសឈ្មោះ

គណបក្សនយោបាយដែលត្រូវទទួលបានអាសនៈ និងលើកបង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ដែលចូលរួមបានឃើញ និងប្រាកដថាឈ្មោះគណបក្សដែលបានប្រកាសដូចគ្នានឹងឈ្មោះរបស់គណបក្សដែលបានសរសេរ ឬបោះពុម្ពនៅលើសន្លឹកឆ្នោតនោះមែន ។

៨.៩.២.៣ មន្ត្រីទទួលបន្ទុកប្រតិបត្តិការត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោតនេះ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងតំណាងចូលរួម (គធ/ខប តំណាងគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគស្មើគ្នា អ្នកសង្កេតការណ៍.......) ដំណើរការចាប់ឆ្នោត និងលទ្ធផលនៃការចាប់ឆ្នោត ។

៨.៩.២.៤ កំណត់ហេតុ ត្រូវចុះហត្ថលេខាដោយ ៖

- អ្នកធ្វើកំណត់ហេតុ
- ប្រធាន ឬតំណាង គធ/ខប ដែលត្រូវបានចាត់តាំង
- តំណាងគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។

៨.៩.២.៥ កំណត់ហេតុត្រូវធ្វើជាច្រើនច្បាប់ តាមតម្រូវការដូចខាងក្រោម ៖

- ផ្ញើជូនទៅ គ.ជ.ប មួយ (១) ច្បាប់ ។
- ផ្ញើជូនទៅគ្រប់គណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។
- រក្សាទុកជាឯកសារ មួយ (១) ច្បាប់ ។

**ការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

**ប្រការ ៨.១០** បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ បានទទួលហើយ គធ/ខប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដូចខាងក្រោម ៖

៨.១០.១ ឈ្មោះបេក្ខជនជាប់ឆ្នោតទាំងអស់ ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលជាប់ឆ្នោត ។ ចំនួនឈ្មោះបេក្ខជនជាប់ឆ្នោតដែលត្រូវស្រង់ត្រូវស្មើគ្នានឹងចំនួនអាសនៈ ដែលបានកំណត់ដោយអនុក្រឹត្យ ។

៨.១០.២ ឈ្មោះបេក្ខជនជាប់ឆ្នោត ត្រូវស្រង់តាមលំដាប់លេខរៀងពីលើមកក្រោម តាមបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ ។

៩.១០.៣ ក្នុងករណីនៅឃុំ សង្កាត់មួយមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតែមួយគត់ ដែលត្រូវបានអនុម័តយល់ព្រមឱ្យចុះបញ្ជីដូចចំណុច ៩.៦.១ ឬមានបញ្ជីបេក្ខជនតែមួយគត់ជាប់ឆ្នោត ឈ្មោះបេក្ខជនត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះតាមលំដាប់លេខរៀងពីលើមកក្រោម រហូតដល់គ្រប់អាសនៈក្នុងក្រុមប្រឹក្សា ។

៩.១០.៤ ឈ្មោះបេក្ខជនណា ដែលត្រូវបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោត ដើម្បីបញ្ចូលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ហើយឈ្មោះបេក្ខជននោះត្រូវលុបចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ ។

**ការកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង**

**ប្រការ ៩.១១** បន្ទាប់ពីបានកំណត់ចំនួនអាសនៈតាមប្រការ ៩.៦ ប្រការ ៩.៧ ប្រការ ៩.៨ និងប្រការ ៩.៩ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមប្រការ ៩.១០ ហើយ គធ/ខប ត្រូវកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោត ដែលទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង តាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដូចខាងក្រោម ៖

៩.១១.១ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវជាមេឃុំ ឬចៅសង្កាត់ត្រូវជ្រើសរើសបេក្ខជន ដែលមានឈ្មោះក្នុងលំដាប់លេខរៀងលើគេបង្អស់ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលទទួលបានសំឡេងឆ្នោតលំដាប់ទី១ (ច្រើនជាងគេ) ។

៩.១១.២ ជំទប់ទី១ ឬចៅសង្កាត់រងទី១ ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះក្នុងលំដាប់លេខរៀងលើគេបង្អស់ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានទទួលសំឡេងឆ្នោតលំដាប់ទី ២ ។

៩.១១.៣ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះក្នុងលំដាប់លេខរៀងលើគេបង្អស់ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានទទួលសំឡេងឆ្នោតលំដាប់ទី ៣ ។

៩.១១.៤ ក្នុងករណីឃុំ សង្កាត់ណាមួយមានបញ្ជីបេក្ខជនតែមួយជាប់ឆ្នោត ដូចមានចែងក្នុងចំណុច ៩.១០.៣ ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

ត្រូវជ្រើសរើសចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះតាមលំដាប់ឈ្មោះពីលើមកក្រោម ដើម្បីទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

៤.១១.៥ ក្នុងករណីឃុំ សង្កាត់ណាមួយ មានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែពីរ (២) ជាប់ឆ្នោតនោះ តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសយកបេក្ខជនជាប់ឆ្នោតជាសមាជិកនៃក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានឈ្មោះក្នុងលំដាប់លេខរៀងទី២ របស់បញ្ជីបេក្ខជនគណបក្សនយោបាយដែលទទួលបានសំឡេងគាំទ្រលំដាប់ទី១ (ច្រើនជាងគេ) រីឯជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសយកបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានឈ្មោះក្នុងលំដាប់លេខរៀងទី១ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានទទួលសំឡេងគាំទ្រលំដាប់ទី ២ ។

៤.១១.៦ ក្នុងការកំណត់បេក្ខជនជាប់ឆ្នោត ទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ប្រសិនបើមានបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ (២) ឬច្រើនមានសំឡេងឆ្នោតស្មើគ្នានោះ គជ/ខប ត្រូវ ៖

៤.១១.៦.១ ពិនិត្យមើលចំនួនអាសនៈរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានអាសនៈច្រើនជាង ជាអ្នកឈ្នះ ។

៤.១១.៦.២ ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងនោះ មានសំឡេងឆ្នោត និងចំនួនអាសនៈស្មើគ្នានោះ គជ/ខប ត្រូវរៀបចំការចាប់ឆ្នោតជាសាធារណៈតាមលំនាំដូចមានចែងក្រោមប្រការ ៤.៩ នៃបទបញ្ជា និងនីតិវិធីនេះ ។

៤.១១.៧ ក្នុងករណីដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតនៅក្នុងឃុំ សង្កាត់ណាមួយ មានចំនួនអាសនៈស្មើគ្នាទាំងអស់ ដូចមានក្នុងឧទាហរណ៍ក្រោមចំណុច ៤.៦.៣.៤ នោះ ការកំណត់បេក្ខជនជាប់ឆ្នោតទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ត្រូវអនុលោមទៅតាមលំដាប់ច្រើន ឬតិចនៃចំនួនសំឡេងឆ្នោតដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបាន ។

**ប្រការ ៤.១២** បន្ទាប់ពីបានកំណត់ចំនួនអាសនៈសំរាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោត ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាប់ឆ្នោត និងឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែល

ទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង រួចហើយ គធ/ខប ត្រូវរាយការណ៍ជូនទៅ គ.ជ.ប តាមទម្រង់បែបបទលេខ ១១១១ ។

**ប្រការ ៤.១៣** អនុលោមតាមមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រសិនបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ត្រូវបាត់បង់សមាជិកភាពដូចករណីមានចែងក្នុងប្រការ ៤.១៤ ខាងក្រោម បេក្ខជនជំនួសត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយពាក់ព័ន្ធដោយមិនចាំបាច់បោះឆ្នោតឡើងវិញឡើយ ។

**ប្រការ ៤.១៤** ការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ អាចកើតមានឡើងដោយករណីណាមួយក្នុងចំណោមករណីខាងក្រោម ៖

៤.១៤.១ សាមីខ្លួនទទួលមរណភាព ។

៤.១៤.២ សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

៤.១៤.៣ សាមីខ្លួនសុំលាលែងជាលាយល័ក្ខណ៍អក្សរ ពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

៤.១៤.៤ សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ។

៤.១៤.៥ សាមីខ្លួនត្រូវបានបណ្តេញចេញ ដោយសារបានប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ។

៤.១៤.៦ ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ ។

៤.១៤.៧ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

# ជំពូកទី ៥
# ការិយាល័យបោះឆ្នោត និង ការិយាល័យរាប់សន្លឹកឆ្នោត

## ការកំណត់ទីតាំងការិយាល័យបោះឆ្នោត

**ប្រការ ៥.១** គ.ជ.ប ត្រូវកំណត់ក្នុងជំហានដំបូងនូវចំនួន និងទីតាំងការិយាល័យបោះឆ្នោតចំនួនមួយ ឬច្រើនក្នុងឃុំ សង្កាត់នីមួយៗ នៅក្នុងរយៈពេលយ៉ាងតិចដប់ប្រាំ (១៥) ថ្ងៃ មុនថ្ងៃចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ ចំនួន និងទីតាំងការិយាល័យបោះឆ្នោតអាចនឹងកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប បន្ទាប់ពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបានបញ្ចប់ និងត្រូវធ្វើឱ្យហើយរួចរាល់នៅរយៈពេលយ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនថ្ងៃផ្ដល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ។

៥.១.១ ការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវផ្អែកលើមូលដ្ឋាននៃចំនួន និងទីតាំងការិយាល័យបោះឆ្នោត ដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះត្រូវបានផ្ដល់សុពលភាពជាផ្លូវការចុងក្រោយដោយ គ.ជ.ប ។ ទន្ទឹមនឹងនេះ គ.ជ.ប ត្រូវកែសម្រួលការិយាល័យបោះឆ្នោត ឬ/និង បង្កើតការិយាល័យបោះឆ្នោតថ្មីបន្ថែមឱ្យសមស្របតាមសភាពជាក់ស្ដែង និងការចាំបាច់ដោយត្រូវប្រើប្រាស់លក្ខណវិនិច្ឆ័យលើកត្តាប្រជាសាស្ត្រ ចម្ងាយផ្លូវ ភូមិសាស្ត្រ សង្គម និងរដ្ឋបាល ។

៥.១.២ គ.ជ.ប អាចធ្វើការកែសម្រួលការិយាល័យបោះឆ្នោត និងតំបន់ស្ថិតក្នុងដែនសមត្ថកិច្ច ដែលការិយាល័យនោះទទួលខុសត្រូវបានតែក្នុងករណីមានការប្រែប្រួលខាងប្រជាសាស្ត្រ សង្គម ឬ/និងមានការប្រែប្រួលខាងភូមិសាស្ត្រ និងរដ្ឋបាល ។

៥.១.៣ ការកំណត់ និងការកែសម្រួលការិយាល័យបោះឆ្នោត ឬ/និងការបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងឃុំ សង្កាត់ ត្រូវគោរពតាមលក្ខខណ្ឌនៃ ច.ប.ឃ.ស និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

៥.១.៤ ការបង្កើតការិយាល័យបោះឆ្នោត ជាដំបូងគឺសម្រាប់បម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ការិយាល័យបោះឆ្នោតដែលបញ្ជីបោះឆ្នោតនៃការិយាល័យ

ទាំងនោះត្រូវបានផ្តល់សុពលភាពជាផ្លូវការចុងក្រោយដោយ គ.ជ.ប និងត្រូវប្រើជាការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ ការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

៥.១.៥ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបម្រើឱ្យតំបន់បោះឆ្នោតមួយដែលបានកំណត់ ។ ការិយាល័យបោះឆ្នោត និងតំបន់ស្ថិតក្នុងដែនសមត្ថកិច្ច ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវតែស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់ ។

៥.១.៦ គ.ជ.ប ត្រូវធានាថាទីតាំងការិយាល័យបោះឆ្នោតនីមួយៗ មិនត្រូវស្ថិតនៅឆ្ងាយជាងប្រាំ (៥) គីឡូម៉ែត្រ ពីទីកន្លែងរស់នៅរបស់អ្នកបោះឆ្នោតឡើយ ។

៥.១.៧ ទីតាំងការិយាល័យបោះឆ្នោតត្រូវតែជាទីកន្លែង ដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ ។

៥.១.៨ នៅទីណាមានស្ទឹង ទន្លេ ឬភូមិសាស្ត្រដែលនាំឱ្យប្រជាពលរដ្ឋពិបាកធ្វើដំណើរឆ្លងកាត់ ត្រូវតែបង្កើតការិយាល័យបោះឆ្នោតនៅទាំងសងខាងស្ទឹង ទន្លេ ឬ/និងនៅទីតាំងជាក់លាក់ណាមួយ ដែលមានលក្ខណៈប្រសើរជាង ។

៥.១.៩ នៅតំបន់ដាច់ស្រយាល ដែលមានប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតតិចជាងប្រាំពីររយ (៧០០) នាក់ ទោះបីជាចំនួនប្រជាពលរដ្ឋរស់នៅតំបន់នោះមានចំនួនប៉ុន្មាននាក់ក៏ដោយ ក៏ត្រូវតែបង្កើតការិយាល័យបោះឆ្នោតមួយដែរ ។

៥.១.១០ គ.ជ.ប ត្រូវចាត់វាលវិធានការចាំបាច់ ដើម្បីបង្កើតការិយាល័យបោះឆ្នោតមួយសម្រាប់ភូមិមួយទាំងមូល ឬក៏ភូមិមួយចំនួន ដែលបង្កលក្ខណៈងាយស្រួលឱ្យអ្នកបោះឆ្នោតដែលជាសមាជិកគ្រួសារទាំងអស់ក្នុងភូមិនោះ ឬភូមិទាំងនោះបានទៅបោះឆ្នោត ។

៥.១.១១ គ.ជ.ប ត្រូវធានាថា ការិយាល័យបោះឆ្នោតមួយ ត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹមចំនួនប្រាំពីររយ (៧០០) នាក់ ។ ក្នុងករណីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយមានអ្នកបោះឆ្នោតប្រាំពីររយ (៧០០) នាក់ហើយនោះ ត្រូវបញ្ចូលអ្នកសុំចុះឈ្មោះថ្មីដែលលើសទៅក្នុង បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដែលនៅជិតបំផុតក្នុងឃុំ សង្កាត់ជាមួយ ។

**ប្រការ ៥.២** ការិយាល័យបោះឆ្នោតជាការិយាល័យនៅមួយកន្លែង ដែលបង្កើតឡើងនៅទីតាំងជាក់លាក់មួយសម្រាប់តំបន់បោះឆ្នោតមួយ ដែលបានកំណត់ ហើយដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

**ប្រការ ៥.៣** ទីតាំងដែលអ្នកបោះឆ្នោតងាយរកឃើញ និងអាចធ្វើដំណើរទៅមកបាន គឺជាលក្ខណវិនិច្ឆ័យសំខាន់ ក្នុងការបង្កើតការិយាល័យបោះឆ្នោត ។

៥.៣.១ ការិយាល័យបោះឆ្នោត ត្រូវមានទីតាំងនៅកន្លែងណាដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ និងគ្មានការរំខានហើយជាការប្រសើរត្រូវស្ថិតនៅជាន់ផ្ទាល់ដី ។

៥.៣.២ ក្នុងករណីចាំបាច់ ការិយាល័យបោះឆ្នោតចំនួនពីរ ឬច្រើនអាចតាំងនៅក្នុងបរិវេណសំណង់ ឬអគារតែមួយ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទេ ។ ការិយាល័យបោះឆ្នោតចំនួនពីរ ឬច្រើនដែលតាំងនៅក្នុងបរិវេណសំណង់ ឬអគារតែមួយនោះ ត្រូវតែរៀបចំខណ្ឌដាច់ពីគ្នា និងគ្រប់គ្រងដោយឡែកពីគ្នា ។

៥.៣.៣ ការិយាល័យបោះឆ្នោតមិនត្រូវបានបង្កើតនៅក្នុងបរិវេណទីធ្លា និងអគាររបស់រាជរដ្ឋាភិបាលដូចជា សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ សង្កាត់ ជាដើម ឬនៅបន្ទាយ ឬអគារនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ឬ/និង អគាររបស់គណបក្សនយោបាយ នៅគ្រប់លំដាប់ថ្នាក់ ។

**ប្រការ ៥.៤** គ.ជ.ប ត្រូវបោះពុម្ពផ្សាយ និងបញ្ជូនបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅតាមដំណាក់កាលនីមួយៗ ហើយត្រូវបង្គាប់អាជ្ញាធររៀបចំការបោះឆ្នោតឱ្យចាត់ចែងបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតទាំងនោះនៅតាមទីកន្លែង និងតាមកាលបរិច្ឆេទដែល គ.ជ.ប បានកំណត់ ។

៥.៤.១ លធ/ខប ត្រូវបន្តចាត់ចែងឱ្យក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួននៅសាលាឃុំ សង្កាត់ និងនៅទីកន្លែងណាមួយក្នុងឃុំ សង្កាត់ យ៉ាងតិចដប់ (១០) ថ្ងៃមុនថ្ងៃចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៥.៤.២ គធ/ខប ត្រូវបន្តចាត់ចែងឱ្យ គឃ/សប បិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ និងនៅទីស្នាក់ការ គឃ/សប ចំនួនពីរលើក (លើកទី១ នៅពីរ (២) ថ្ងៃមុនថ្ងៃចាប់ផ្តើមចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងលើកទី២ នៅមួយ (១) ថ្ងៃមុនថ្ងៃបោះឆ្នោត) ។

**ប្រការ ៥.៥** ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ គឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ។

៥.៥.១ បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអគារដែលការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាំងនៅ ហើយដែលខណ្ឌដោយរង្វង់មណ្ឌលមួយមានកាំប្រវែងយ៉ាងតិចដប់ប្រាំ (១៥) ម៉ែត្រ ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយ និងច្រកចូលមួយ ។

៥.៥.២ បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលខណ្ឌដោយរង្វង់មណ្ឌលមានកាំប្រវែងមួយរយ (១០០) ម៉ែត្រ ឬមានកាំតូចជាងស្របតាមស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជារបងខាងក្រៅបរិវេណនៃសាលារៀន វត្តអារាម សាល ឬទីធ្លាសាធារណៈជាដើម ។

៥.៥.៣ នៅទីប្រជុំជន បរិវេណខាងក្រៅត្រូវបានកំណត់ដោយ គឃ/សប ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងតំបន់នោះ ។

៥.៥.៤ ដោយអនុលោមទៅតាមចំណុច ៥.៥.៣ ខាងលើ បរិវេណសន្តិសុខត្រូវបានបង្កើតឡើងចំពោះតែតំបន់ទីប្រជុំជនណា ដែលមានបញ្ហាអសន្តិសុខ និងខ្វះសណ្តាប់ធ្នាប់ដែលអាចរំខានដល់ដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៥.៥.៥ នៅតំបន់ទីប្រជុំជន ក្នុងករណី ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមួយតាំងនៅប្រមាណមួយរយ (១០០) ម៉ែត្រ ពីការិយាល័យពាក់ព័ន្ធមួយផ្សេងទៀត មួយផ្នែកនៃផ្លូវនេះត្រូវតែបិទចរាចរណ៍ ។

**ប្រការ ៥.៦** ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារសម្ភារៈ ឯកសារបោះឆ្នោតក្នុងការិយាល័យទាំងនោះ គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវចាត់វិធានការចាំបាច់នានាដូចខាងក្រោម ៖

៥.៦.១ ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬសារជាតិ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ បម្រាមនេះត្រូវបានលើកលែងចំពោះអាជ្ញាធរ

មានសមត្ថកិច្ចក្នុងករណីមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលប្រធាន គ.ជ.ប ឬ/និង ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានភារកិច្ច ស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៧ថ្មី នៃ ច.ប.ឃ.ស ។

៥.៦.១.១ ប្រធាន គ.ជ.ប និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវប្រគល់សិទ្ធិអំណាចពេញលេញ ឱ្យដល់ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងការទំនាក់ទំនងស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីដូចបានបញ្ជាក់ក្នុងចំណុច ៥.៦.១ ខាងលើ ។

៥.៦.១.២ ក្នុងករណី មានសំណូមពរពីប្រធានការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោតក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យណាមួយនោះ ភ្នាក់ងារសន្តិសុខមានបំពាក់អាវុធ ដែលត្រូវបានតែងតាំងអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធ ។

៥.៦.២ ហាមនាយ ឬពលនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និងកងនគរបាលជាតិណាម្នាក់ចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខឡើយ ប្រសិនបើអ្នកទាំងនោះមិនទៅបោះឆ្នោតទេនោះ ។ បម្រាមនេះ ត្រូវបានលើកលែងក្នុងករណីអ្នកទាំងនោះត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខ ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតស្នើសុំឱ្យធ្វើអន្តរាគមន៍ ដូចចែងក្នុងប្រការ ៥.៦ និងលក្ខខណ្ឌទាំងឡាយក្រោមចំណុច ៥.៦.១ ខាងលើ ។

៥.៦.៣ ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោតមុនពេលចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម ៖

៥.៦.៣.១ មន្ត្រីបោះឆ្នោត ដែលបានទទួលការតែងតាំងពី គ.ជ.ប ។

៥.៦.៣.២ ភ្នាក់ងារនៃគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ និងដែលបានអនុញ្ញាត និងអ្នកសង្កេតការណ៍ដែលមានប័ណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។

៥.៦.៣.៣ អ្នកយកព័ត៌មានដែលមានប័ណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។ ក្នុងករណីគ្មានប័ណ្ណសម្គាល់អនុញ្ញាត អ្នកយកព័ត៌មានអាចចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីគោលបំណងបោះឆ្នោតតែប៉ុណ្ណោះ ប្រសិនបើគាត់បានចុះឈ្មោះបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

៥.៦.៣.៤ អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

៥.៦.៣.៥ ជនដែលអមដំណើរអ្នកបោះឆ្នោត ជាជនពិការតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១២៦ថ្មី នៃ ច.ប.ឃ.ស ។

៥.៦.៣.៦ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានការិយាល័យបោះឆ្នោត សំណូមពរក្នុងករណីចាំបាច់ ។

៥.៦.៤ ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម ៖

៥.៦.៤.១ មន្ត្រីរាប់សន្លឹកឆ្នោត ដែលបានទទួលការតែងតាំងពី គ.ជ.ប ។

៥.៦.៤.២ ភ្នាក់ងារនៃគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ និងដែលបានអនុញ្ញាត អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មានដែលមានប័ណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។

៥.៦.៤.៣ ភ្នាក់ងារសន្តិសុខនិងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានការិយាល័យរាប់សន្លឹកឆ្នោត សំណូមពរក្នុងករណីចាំបាច់ ។

៥.៦.៥ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

៥.៦.៥.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

៥.៦.៥.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោតបោះឆ្នោតឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ។

៥.៦.៥.៣ ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

៥.៦.៦ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

៥.៦.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

៥.៦.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោតរាប់គាំទ្រសនៅលើសន្លឹកឆ្នោត បំពេញចិត្ត ឬប្រឆាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

៥.៦.៧ ក្នុងករណីចាំបាច់ ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមានភារកិច្ចអនុវត្តនូវលក្ខខណ្ឌ ដូចមានចែងក្រោមចំណុច ៥.៥.៣ និង ៥.៥.៤ ចំពោះបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

៥.៦.៨ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងណែនាំរបស់ គ.ជ.ប ស្របតាមលក្ខខណ្ឌនៃ ច.ប.ឃ.ស ។

**ប្រការ ៥.៧** ចំពោះការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានស័ក្តិ ឬអសន្តិសុខ គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោត នៃការិយាល័យបោះឆ្នោតនោះ នៅកន្លែងផ្សេងទៀត ។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្តីសម្រេចនេះ ។

**ប្រការ ៥.៨** សាលារៀន ទីវត្តអារាម រាល់សំណង់ អគារ សាល ឬទីធ្លាសាធារណៈ ត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់គោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

# ជំពូកទី ៦

# បញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**ប្រការ** ៦.១ នៅមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ គ.ជ.ប ត្រូវកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយ ឬច្រើនក្នុងឃុំ សង្កាត់ នីមួយៗ ។ នីតិវិធីសម្រាប់ការកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តតាមជំពូកទី ៣ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ប.ន.ព.ច.ឆ) (សូមមើលឧបសម្ព័ន្ធទី ១) លើកលែងតែចំណុចមួយចំនួន ដូចខាងក្រោមដែលត្រូវកែសម្រួល ៖

៦.១.១ ក្រោមចំណុច ៣.១.៣ ជំពូកទី ៣ នៃឧបសម្ព័ន្ធទី១ ត្រូវកែសម្រួលដោយមិនអនុវត្តការចល័តការិយាល័យចុះឈ្មោះបោះឆ្នោតទៅតាមមន្ទីរឃុំឃាំង ។

៦.១.២ ចំណុច ៣.៣.៣ នៃឧបសម្ព័ន្ធទី១ ត្រូវបានកែសម្រួល ដោយរក្សាទុកតែគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតប៉ុណ្ណោះ មានសិទ្ធិស្នើសុំពី គ.ជ.ប នូវបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ដោយបង់ថ្លៃត្រឹមតែតម្លៃផលិត ។

**ប្រការ** ៦.២ ដើម្បីឱ្យការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដំណើរការប្រកបដោយប្រសិទ្ធភាព និងភាពរលូន គ.ជ.ប ត្រូវអនុវត្តការត្រៀមរៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលត្រូវធ្វើឡើង ពីថ្ងៃទី ០១ ខែមករា រហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ។ ដំណើរការនេះ ត្រូវអនុវត្តដោយផ្អែកតាមសេចក្តីណែនាំរួមលេខ ០១១ សណន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការរៀបចំត្រៀមបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ របស់ក្រសួងមហាផ្ទៃ និង គ.ជ.ប ។ (សូមមើលឧបសម្ព័ន្ធទី ២)

**ប្រការ** ៦.៣ ដើម្បីជួយដល់អ្នកបោះឆ្នោត ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ បានយល់ដឹងច្បាស់អំពីលេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត លេខកូដ និងទីតាំងការិយាល័យបោះឆ្នោត កាលបរិច្ឆេទនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងពេលវេលានៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ ដែលត្រូវប្រើនៅ

ពេលបោះឆ្នោត គ.ជ.ប ត្រូវអនុវត្តការផ្តល់បណ្ណព័ត៌មានអ្នកបោះឆ្នោត ។ ដំណើរការនេះត្រូវអនុវត្តដោយផ្អែកតាមសេចក្តីណែនាំរួមលេខ ០១០ ស.ណ.ន ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការផ្តល់បណ្ណព័ត៌មានអ្នកបោះឆ្នោត របស់ក្រសួងមហាផ្ទៃ និង គ.ជ.ប ។ (សូមមើលឧបសម្ព័ន្ធទី ៣)

**ប្រការ ៦.៤** អនុលោមតាមមាត្រា ៤២ ថ្មីនៃ ច.ប.ឃ.ស បញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៃឃុំ សង្កាត់នីមួយៗ ត្រូវយកបញ្ជីបោះឆ្នោតចុងក្រោយ ដែលបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុង ច.ប.ត.រ ហើយក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គ.ជ.ប ត្រូវអនុវត្តតាមជំពូកទី ៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (សូមមើលឧបសម្ព័ន្ធទី ៤) លើកលែងតែចំណុចមួយចំនួនដែលត្រូវកែសម្រួល និងមិនត្រូវអនុវត្ត (សូមមើលឧបសម្ព័ន្ធទី ៥ សេចក្តីសម្រេចលេខ ០២៩/១១ គ.ជ.ប ស.ស.រ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត របស់ គ.ជ.ប) និងនីតិវិធីស្តីពីការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយ សម្រាប់ឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ (សូមមើលឧបសម្ព័ន្ធទី ៦) ។

**ប្រការ ៦.៥** អនុលោមតាម ច.ប.ឃ.ស ក្នុងការអនុវត្តជំពូកទី ៤ នៃ ប.ន.ព.ច.ឆ (ឧបសម្ព័ន្ធទី៤) ចំណុច ៤.១.៩ ប្រការ ៤.១ និងចំណុចដែលស្ថិត ក្រោមប្រការ ៤.២៩ មិនត្រូវបានយកមកអនុវត្តឡើយ ។

# ជំពូកទី ៧
# ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ
# សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន**

**ប្រការ** ៧.១ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជន សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

៧.១.១ មានសញ្ជាតិខ្មែរពីកំណើត ។

៧.១.២ ចេះអាន និងសរសេរអក្សរខ្មែរ ។

៧.១.៣ បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត ។

៧.១.៤ មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន**

**ប្រការ** ៧.២ ហាមឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះ ៖

៧.២.១ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល និងចៅក្រម ។

៧.២.២ ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

៧.២.៣ សមាជិក គ.ជ.ប គធ/ខប គឃ/សប គកប បុគ្គលិកបម្រើការងារក្នុង គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៧.២.៤ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង ។

៧.២.៥ ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ ។

៧.២.៦ ស្មៀនឃុំ សង្កាត់ណាមួយ ។

៧.២.៧ ជនដែលស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ។

៧.២.៨ ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ។

៧.២.៩ ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ។

**ប្រការ ៧.៣** មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ (៧) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

៧.៣.១ ប្រសិនបើ សាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមីអង្គភាពទៅបម្រើការក្រៅក្របខណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងឋានៈនេះ សាមីខ្លួនត្រូវមានសិទ្ធិឡើងថ្នាក់ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

៧.៣.២ នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

៧.៣.៣ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីអង្គភាព អាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។ ក្នុងករណីមិនអាចធ្វើទាន់ ត្រូវផ្ញើពាក្យសុំច្បាប់ឈប់ពិសេសជូន គឃ/សប ក្នុងរយៈពេលយ៉ាងតិចប្រាំពីរ (៧)ថ្ងៃមុនថ្ងៃចាប់ផ្តើមបើកយុទ្ធនាការឃោសនាបោះឆ្នោត ។ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេស ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះសាមីជន ដែលបានសុំច្បាប់ឈប់ពិសេស មុខតំណែង ក្រសួង ឬអង្គភាព ដែលសាមីជនកំពុងបម្រើការងារកាលបរិច្ឆេទសុំច្បាប់ឈប់ពិសេស និងមានហត្ថលេខារបស់ថ្នាក់ដឹកនាំរបស់ខ្លួនពេលគឺ នៅថ្នាក់លើមួយថ្នាក់ដែលខ្លួននៅក្រោមឱវាទ ។

**ប្រការ ៧.៤** បន្ទាប់ពីនាយករដ្ឋមន្ត្រីកំណត់កាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣ថ្មី នៃ ច.ប.ឃ.ស គ.ជ.ប ត្រូវផ្សព្វផ្សាយ នៅក្នុងឃុំ សង្កាត់នីមួយៗ នូវកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជន និងទីកន្លែង ។

**ប្រការ ៧.៥** ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

៧.៥.១ បញ្ជីបេក្ខជននីមួយៗ ត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌ ដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។

៧.៥.២ បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង ។

៧.៥.៣ បេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។

**ប្រការ ៧.៦** ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់ គ.ជ.ប ទៅ គឃ/សបយ៉ាងតិចកៅសិប (៩០) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៧.៦.១ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាម ទ. ១០០៨ ចំនួន ពីរ (២) ច្បាប់ ។ ពាក្យសុំចុះបញ្ជីបេក្ខជននេះ ត្រូវបានផ្តល់ដោយឥតគិតថ្លៃ ជូនគណបក្សនយោបាយ ដែលមានបំណងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

៧.៦.២ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាង ដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។

៧.៦.៣ ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ ៖

៧.៦.៣.១ សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ចំនួនមួយ (១) ច្បាប់ ។

៧.៦.៣.២ អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះអ្នកតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ដែលបានដាក់ស្នើបញ្ជីបេក្ខជន ។

៧.៦.៣.៣ បញ្ជីរាយនាមបេក្ខជនចំនួនប្រាំមួយ (៦) ច្បាប់ ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹងពីរដង នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ គឃ/សប ត្រូវរក្សាឱ្យបានបញ្ជីរាយនាមបេក្ខជនទាំងប្រាំមួយ (៦)ច្បាប់ ដើម្បីប្រើប្រាស់ ៖

- មួយ (១) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ/សប ក្រោយពេលទទួលពាក្យសុំចុះបញ្ជីបេក្ខជន
- មួយ (១) ច្បាប់ បិទផ្សាយនៅ គឃ/សប ជាបញ្ជីបេក្ខជនដំបូងក្រោយពេលបញ្ចប់ការប្តឹងជំទាស់
- មួយ (១) ច្បាប់បិទផ្សាយនៅ គឃ/សប ជាបញ្ជីផ្លូវការ
- មួយ (១) ច្បាប់ តម្កល់ទុកជាឯកសារនៅ គឃ/សប
- មួយ (១) ច្បាប់ ផ្ញើជូន គធ/ខប
- មួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប

៧.៦.៣.៤ លិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថា ពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោតដោយបញ្ជាក់ឱ្យបានច្បាស់អំពីនាមត្រកូល នាមខ្លួន និងអាសយដ្ឋាន ។ មេឃុំ ចៅសង្កាត់ ត្រូវចេញលិខិតបញ្ជាក់ជូនតាមការស្នើសុំក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំ ។

៧.៦.៣.៥ ជីវប្រវត្តិសង្ខេបដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ មានបិទរូបថត និងរូបថតបេក្ខជនម្នាក់ចំនួនបី (៣) សន្លឹកទៀត ទំហំ ៤x៦ ថតចំពីមុខតាមគំរូរូបថតធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។ ការប្រើប្រាស់រូបថតរបស់បេក្ខជននៃគណបក្សនយោបាយនីមួយៗ ៖

- មួយ (១) សន្លឹក សម្រាប់បិទផ្សាយជាមួយបញ្ជីបេក្ខជនបន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនរួចនៅទីស្នាក់ការ គឃ/សប
- មួយ (១) សន្លឹក សម្រាប់បិទជាបញ្ជីបេក្ខជនដំបូងនៅទីស្នាក់ការ គឃ/សប
- មួយ (១) សន្លឹក សម្រាប់បិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅទីស្នាក់ការ គឃ/សប ។

របៀបបិទរូបថតបេក្ខជន : គឃ/សប ត្រូវបិទរូបថតតាមលេខរៀងឈ្មោះបេក្ខជននៃគណបក្សនយោបាយនីមួយៗ លើក្រដាសដែលមានទំហំសមស្របទៅតាមចំនួនបេក្ខជន ។

៧.៦.៣.៦ លិខិតសន្យារបស់បេក្ខជនឈរឈ្មោះបោះឆ្នោតដែលជាមន្ត្រីរាជការថា នឹងផ្តល់ច្បាប់សុំឈប់ពិសេសជូន គឃ/សប ។

៧.៦.៣.៧ ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ ។

**ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនដោយ គឃ/សប**

**ប្រការ** ៧.៧ គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជនសម្រាប់ឃុំ សង្កាត់នីមួយៗ ។

៧.៧.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៅគ្រប់ទីស្នាក់ការ គឃ/សប ។

៧.៧.២ ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេលបី (៣) ថ្ងៃ គឺរៀងរាល់ថ្ងៃព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ ១១:៣០នាទី រសៀលចាប់ពីម៉ោង ២:០០នាទី ដល់ ៥:៣០នាទី ។

៧.៧.៣ គឃ/សប ត្រូវចេញបង្កាន់ដៃទទួលពាក្យជូនគណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន និងរក្សាគល់បញ្ជីមួយ (១) ច្បាប់ទុកជាឯកសារ ។

៧.៧.៤ បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួនឯកសារ ដែលបានទទួល ចុះកាលបរិច្ឆេទប្រគល់ ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ ទទួល ។

៧.៧.៥ នៅពេលបញ្ចប់ការទទួលពាក្យ គឃ/សប ត្រូវធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ឃុំ សង្កាត់របស់ខ្លួនចំនួនបួន (៤) ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា គឃ/សប រួចបិទផ្សាយមួយ (១) ច្បាប់ នៅទីស្នាក់ការ គឃ/សប ផ្ញើជូន គធ/ខប មួយ (១) ច្បាប់ ជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះបាន ។

**ប្រការ ៧.៨** បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន គឃ/សឃ ត្រូវធ្វើការពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេលមួយ (១) ថ្ងៃ ។ គឃ/សឃ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន ។

**ប្រការ ៧.៩** ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់មានសិទ្ធិផ្ដល់មតិចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបិទផ្សាយខាងលើ មក គឃ/សឃ ដើម្បីជាព័ត៌មានសម្រាប់ជាមូលដ្ឋានពិចារណា មុនពេលសម្រេចយល់ព្រម ឬបដិសេធការចុះបញ្ជីបេក្ខជន ។

**ការពិនិត្យ និងសម្រេចរបស់ គឃ/សឃ លើពាក្យសុំចុះបញ្ជីបេក្ខជន**

**ប្រការ ៧.១០** គឃ/សឃ ត្រូវពិនិត្យ និងសម្រេចយល់ព្រម ឬបដិសេធលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយតាមលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងប្រការ ៧.១ ៧.២ ៧.៣ ៧.៥ ៧.៦ នៃ ប.ន.ឃ.ស នេះ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំចុះបញ្ជីបេក្ខជន ។

៧.១០.១ ក្នុងករណីគណបក្សនយោបាយណាមួយ បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គឃ/សឃ ត្រូវសម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននោះ ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជន (ទ. ១០០៨) ទាំងពីរ (២) ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា រួចជូនទៅសាមីគណបក្សនយោបាយមួយ (១) ច្បាប់ និងរក្សាទុកមួយ (១) ច្បាប់ ។

៧.១០.១.១ ករណីឃុំ សង្កាត់ណាមួយត្រូវបាន គឃ/សឃ សម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ ដែលបានស្នើសុំទាំងអស់ក្នុងឃុំ សង្កាត់នោះ គឃ/សឃ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចយល់ព្រម ។

៧.១០.១.២ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបិទផ្សាយជាសាធារណៈ ។ នីតិវិធីនៃការប្ដឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៧.១៥ ។

៧.១០.១.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៧.១០.១.២ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថា គ្មានការប្តឹងជំទាស់ ។ បញ្ជីបេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ។ គឃ/សប ត្រូវបិទផ្សាយជាសាធារណៈ នៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ ។

៧.១០.១.៤ គឃ/សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ/ខប ។ ការចាប់ឆ្នោតកំណត់លេខរៀង គឃ/សប ត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៧.២០ ។

៧.១០.២ ក្នុងករណីគណបក្សនយោបាយណាមួយ បំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គឃ/សប ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងណែនាំដល់គណបក្សនយោបាយ ដែលបានដាក់ស្នើបញ្ជីបេក្ខជននោះ ឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវ ហើយផ្តល់ឱកាសឱ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ។

៧.១០.៣ ក្នុងករណីគណបក្សនយោបាយ ដែលបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពី គឃ/សប ឱ្យធ្វើការកែតម្រូវនូវចំណុចខ្វះខាត បានកែតម្រូវត្រឹមត្រូវ និងទាន់ពេលវេលាហើយនោះ គឃ/សប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនដូចក្នុងចំណុច ៧.១០.១ ក្នុងរយៈពេលមួយ (១) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ ។

៧.១០.៣.១ ក្នុងករណីគណបក្សនយោបាយទាំងអស់ដែល គឃ/សប ឱ្យធ្វើការកែតម្រូវនូវចំណុចខ្វះខាត បានកែតម្រូវត្រឹមត្រូវ ហើយត្រូវបាន គឃ/សប សម្រេចដូចចំណុច ៧.១០.៣ ខាងលើ គឃ/សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចយល់ព្រម ។

៧.១០.៣.២ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបិទផ្សាយជាសាធារណៈ ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៧.១៥ ។

៧.១០.៣.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៧.១០.៣.២ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថា គ្មានការប្តឹងជំទាស់ ។ បញ្ជីបេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ។ គឃ/សប ត្រូវបិទផ្សាយជាសាធារណៈ នៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ ។

៧.១០.៣.៤ គឃ/សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ទៅ គ.ជ.ប តាមរយៈ គធ/ខប ។ ការចាប់ឆ្នោតកំណត់លេខរៀង គឃ/សប ត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៧.២០ ។

៧.១០.៤ ក្នុងករណីគណបក្សនយោបាយដែលដាក់ស្នើបញ្ជីបេក្ខជន មិនបានកែតម្រូវចំណុចខ្វះខាតតាមលក្ខខណ្ឌ និងពេលវេលាដូចមានចែងក្នុងប្រការ ៧.១០ និងចំណុច ៧.១០.២ ខាងលើ គឃ/សប ត្រូវបដិសេធពាក្យសុំចុះបញ្ជីបេក្ខជននោះ ។

៧.១០.៥ ក្នុងការសម្រេចបដិសេធ គឃ/សប ត្រូវ ៖

៧.១០.៥.១ បំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសម្រង់សេចក្តីសម្រេចបដិសេធ (ទ. ១២០៣) ចំនួនបី (៣) ច្បាប់ រួចផ្ញើជូន ៖

- គណបក្សនយោបាយសាមី ឬតំណាង មួយ (១)ច្បាប់
- គធ/ខប មួយ (១)ច្បាប់
- រក្សាទុកឯកសារ មួយ (១)ច្បាប់

៧.១០.៥.២ ប្រគល់ទម្រង់បែបបទលេខ ១២០២ ចំនួនបី (៣) ច្បាប់ ជូនដល់សាមីគណបក្សនយោបាយ ដែលបានដាក់ស្នើបញ្ជីបេក្ខជនសម្រាប់បំពេញពាក្យប្តឹងតវ៉ាទៅ គធ/ខប ។

**ប្រការ ៧.១១** គណបក្សនយោបាយណាដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយត្រូវបាន គឃ/សប បដិសេធ សាមីគណបក្ស ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅ គធ/ខប ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

៧.១១.១ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចបដិសេធ ប៉ុន្តែសាមីគណបក្ស ឬតំណាងពុំបានដាក់ពាក្យប្តឹងតវ៉ាទៅ គធ/ខប តាមពេលវេលាដូចចែងក្នុងប្រការ ៧.១១ ទេនោះ ត្រូវចាត់ទុកថាមិនបានប្តឹងតវ៉ា ។

៧.១១.២ ក្នុងករណីមានបណ្តឹងតវ៉ា គធ/ខប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹងតវ៉ាពីសាមីគណបក្ស ឬតំណាង ។ គធ/ខប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលត្រូវបើកសវនាការ ។

៧.១១.៣ ក្នុងករណីសម្រេចយល់ព្រមតាមការតវ៉ា គធ/ខប ត្រូវបំពេញសម្រង់សេចក្តីសម្រេចលើបណ្តឹងតវ៉ា (ទ. ១២០៣) ជាបី (៣) ច្បាប់ ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ រួចផ្ញើជូន ៖

- អ្នកប្តឹងតវ៉ា មួយ (១)ច្បាប់
- គឃ/សប មួយ (១)ច្បាប់
- គ.ជ.ប ដើម្បីជ្រាបជាព័ត៌មាន មួយ (១)ច្បាប់
- រក្សាទុកជាឯកសារ មួយ (១)ច្បាប់

៧.១១.៤ ក្នុងករណីទទួលបានសម្រង់សេចក្តីសម្រេចយល់ព្រមដូចក្នុងចំណុច ៧.១១.៣ គឃ/សប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ និងត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយសាមី ។

៧.១១.៤.១ ករណីបណ្តឹងតវ៉ាទាំងអស់ក្នុងឃុំ សង្កាត់នោះ ត្រូវបានយល់ព្រមដោយ គធ/ខប គឃ/សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចពី គធ/ខប ។

៧.១១.៤.២ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន

ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបិទផ្សាយជាសាធារណៈ ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៧.១៥ ។

៧.១១.៤.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៧.១១.៤.២ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថា គ្មានការប្តឹងជំទាស់ ។ បញ្ជីបេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ។ គឃ/សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ ។

៧.១១.៤.៤ គឃ/សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ទៅ គ.ជ.ប តាមរយៈ គធ/ខប ។ ការចាប់ឆ្នោតកំណត់លេខរៀង គឃ/សប ត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៧.២០ ។

**ប្រការ ៧.១២** ក្នុងករណីសម្រេចបដិសេធបណ្តឹងតវ៉ា គធ/ខប ត្រូវបំពេញសម្រង់សេចក្តីសម្រេចលើបណ្តឹងតវ៉ា (ទ. ១២០៣) ជាបួន (៤) ច្បាប់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់រួចផ្ញើជូន ៖

- គណបក្សនយោបាយសាមី មួយ (១)ច្បាប់
- គ.ជ.ប មួយ (១)ច្បាប់
- គឃ/សប មួយ (១)ច្បាប់
- រក្សាទុកជាឯកសារ មួយ (១)ច្បាប់

គធ/ខប ត្រូវប្រគល់ ទ. ១២០២ ចំនួនបី (៣) ច្បាប់ ជូនគណបក្សនយោបាយ សម្រាប់បំពេញពាក្យប្តឹងតវ៉ាទៅ គ.ជ.ប ។

**ប្រការ ៧.១៣** គណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយបញ្ជីបេក្ខជននោះ ត្រូវបានបដិសេធដោយ គធ/ខប សាមីគណបក្សនយោបាយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

៧.១៣.១ គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃក្រោយពីបានទទួលទម្រង់បែបបទប្តឹងតវ៉ា ។

៧.១៣.២ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនៅទីស្តីការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលត្រូវបើកសវនាការ ។

៧.១៣.៣ ក្នុងករណីយល់ព្រមលើការប្តឹងតវ៉ា គ.ជ.ប ត្រូវ ៖

៧.១៣.៣.១ បំពេញសម្រង់សេចក្តីសម្រេចលើបណ្តឹងតវ៉ា (ទ. ១២០៣) ជាបួន (៤) ច្បាប់ រួចផ្ញើជូន ៖

| | |
|---|---|
| - អ្នកប្តឹងតវ៉ា | មួយ (១)ច្បាប់ |
| - គធ/ខប | មួយ (១)ច្បាប់ |
| - គឃ/សប | មួយ (១)ច្បាប់ |
| - រក្សាទុកជាឯកសារ | មួយ (១)ច្បាប់ |

៧.១៣.៣.២ បន្ទាប់ពីទទួលបានសម្រង់សេចក្តីសម្រេចយល់ព្រម ដូចក្នុងចំណុច ៧.១៣.៣.១ រួចហើយ គឃ/សប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន និងត្រូវចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយ ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយសាមី ។

៧.១៣.៣.៣ គឃ/សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចយល់ព្រមពី គ.ជ.ប ។

៧.១៣.៣.៤ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបិទផ្សាយជាសាធារណៈ ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៧.១៥ ។

៧.១៣.៣.៥ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៧.១៣.៣.៤ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថា គ្មានការប្តឹងជំទាស់ ។ បញ្ជីបេក្ខជនដំបូងក្លាយទៅជា បញ្ជីបេក្ខជនផ្លូវការ ។ គឃ/សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ។

៧.១៣.៣.៦ គឃ/សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ/ខប ។ ការចាប់ឆ្នោតកំណត់លេខរៀង គឃ/សប ត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៧.២០ ។

៧.១៣.៤ ក្នុងករណីបដិសេធបណ្ដឹងតវ៉ា គ.ជ.ប ត្រូវ ៖

- បំពេញសម្រង់សេចក្ដីសម្រេចលើបណ្ដឹងតវ៉ា (ទ. ១២០៣) ចំនួនបី (៣) ច្បាប់ រួចផ្ញើជូន ៖
  - អ្នកប្ដឹងតវ៉ា មួយ (១)ច្បាប់
  - គធ/ខប មួយ (១)ច្បាប់
  - គឃ/សប មួយ (១)ច្បាប់
  - រក្សាទុកជាឯកសារ មួយ (១)ច្បាប់
- ផ្ដល់ដំណឹងដល់គណបក្សនយោបាយ ដែលដាក់ពាក្យបណ្ដឹងតវ៉ាឬតំណាងថា សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយ ។

**ប្រការ** ៧.១៤ បន្ទាប់ពីបញ្ចប់រយៈពេលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ហើយឃុំ សង្កាត់ណាដែលការប្ដឹងតវ៉ាទាំងអស់ ត្រូវបានដោះស្រាយរួចរាល់នៅដំណាក់កាលដំបូង គ.ជ.ប ត្រូវចាត់ឱ្យ គឃ/សប បិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបានទទួលសម្រង់សេចក្ដីសម្រេចពី គ.ជ.ប ។

**ប្រការ** ៧.១៥ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបិទផ្សាយជាសាធារណៈ ។

៧.១៥.១ បណ្ដឹងជំទាស់ត្រូវចោទប្រកាន់ទៅលើបេក្ខជន ឬបញ្ជីបេក្ខជន នៃគណបក្សនយោបាយណាមួយ ដែលបំពេញមិនបានគ្រប់គ្រាន់តាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៧.១ ៧.២ ៧.៣ ៧.៥ និង ៧.៦ នៃ ប.ន.ឃ.ស នេះ ។

៧.១៥.២ បណ្ដឹងជំទាស់ទាំងនោះ ត្រូវបង្ហាញអំពីបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយជាក់លាក់ណាមួយ ដោយបញ្ជាក់ពីចំណុចខ្វះខាតជាក់ស្ដែងរបស់បេក្ខជន ឬបញ្ជីបេក្ខជននោះ និងហេតុផលដែលស្នើសុំឱ្យច្រានចោលបេក្ខជន ឬបញ្ជីបេក្ខជននោះផង ។

**ប្រការ ៧.១៦** គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹងជំទាស់ ។ គ.ជ.ប ត្រូវផ្តល់ព័ត៌មានដល់គណបក្សនយោបាយ ដែលបានដាក់ស្នើបញ្ជីបេក្ខជនមានការប្តឹងជំទាស់ ផ្តល់ព័ត៌មានដល់អ្នកប្តឹងជំទាស់ និងជូនដំណឹងជាសាធារណៈ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលត្រូវបើកសវនាការនោះ ។

**ប្រការ ៧.១៧** ក្នុងករណីយល់ព្រម ឬបដិសេធលើបណ្តឹងជំទាស់ណាមួយ គ.ជ.ប ត្រូវ ៖

៧.១៧.១ បំពេញសម្រង់សេចក្តីសម្រេចលើបណ្តឹងជំទាស់ (ទ. ១២០៣) ជា ប្រាំ (៥) ច្បាប់ រួចផ្ញើជូន ៖

- អ្នកប្តឹងជំទាស់ មួយ (១)ច្បាប់
- គណបក្សនយោបាយ ត្រូវគេប្តឹងជំទាស់មួយ (១)ច្បាប់
- គធ/ខប ពាក់ព័ន្ធ មួយ (១)ច្បាប់
- គឃ/សប ពាក់ព័ន្ធ មួយ (១)ច្បាប់
- រក្សាទុកជាឯកសារ មួយ (១)ច្បាប់ ។

៧.១៧.២ ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ និងសាមីគណបក្សនយោបាយនៃបញ្ជីបេក្ខជននោះថា សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ ។

**ប្រការ ៧.១៨** ក្នុងករណីបណ្តឹងជំទាស់ត្រូវបានយល់ព្រមដោយ គ.ជ.ប តាមសម្រង់សេចក្តីសម្រេចដូចក្នុងចំណុច ៧.១៧.១ គឃ/សប ត្រូវបដិសេធបេក្ខភាព ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់នោះ រួចហើយលុបបេក្ខភាព ឬបញ្ជីបេក្ខជននោះចេញព្រមទាំងដកហូត និងបដិសេធលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជននោះ ។

៧.១៨.១ ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមតាមបណ្តឹងជំទាស់ដោយលុបបេក្ខភាពបេក្ខជននៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់ គឃ/សប ត្រូវបដិសេធបេក្ខភាពដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះតែប៉ុណ្ណោះ ដោយរក្សាបញ្ជីបេក្ខជននោះមានសុពលភាពដដែល ។ គឃ/សប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន និងត្រូវចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយ ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយសាមី ។

៧.១៨.២ ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមតាមបណ្តឹងជំទាស់ដោយលុបបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់ គឃ/សប ត្រូវលុបបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះចេញ ព្រមទាំងដកហូត និងបដិសេធលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជន ។

**ប្រការ** ៧.១៩ បញ្ជីបេក្ខជនដំបូងនឹងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ប្រសិនបើគ្មានបណ្តឹងជំទាស់មកលើបញ្ជីនេះ ក្នុងរយៈពេលដូចដែលបានកំណត់ក្នុងប្រការ ៧.១៤ ឬការប្តឹងជំទាស់ត្រូវបានដោះស្រាយស្រប តាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧.១៥ ៧.១៦ និង ៧.១៧ នៃ ប.ន.ឃ.ស នេះ ។

**ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយ**

**ប្រការ** ៧.២០ គឃ/សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ/ខប ។

៧.២០.១ ផ្អែកលើបញ្ជីបេក្ខជនផ្លូវការ គឃ/សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត ។

៧.២០.២ ការចាប់ឆ្នោតត្រូវធ្វើឡើងជាសាធារណៈ ។ គឃ/សប ត្រូវបិទផ្សាយជាសាធារណៈ អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ម្ភៃបួន(២៤) ម៉ោង មុននឹងចាប់ផ្តើមធ្វើពិធីចាប់ឆ្នោត ។

៧.២០.៣ លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់របស់ខ្លួន និងដែលមានចុះហត្ថលេខារបស់អ្នកទទួលទុកឯកសារយ៉ាងហោចណាស់ម្ភៃបួន(២៤) ម៉ោង មុនពិធីចាប់ឆ្នោត ។

៧.២០.៤ របៀបវារៈនៃពិធីចាប់ឆ្នោតមានដូចខាងក្រោមនេះ ៖

៧.២០.៤.១ សុន្ទរកថាបើកពិធី ថ្លែងដោយប្រធាន គឃ/សប ។

៧.២០.៤.២ ការបង្ហាញសន្លឹកឆ្នោតសម្រាប់ចាប់ឆ្នោត និងស្រោមសំបុត្រ ។

៧.២០.៤.៣ ការចាប់ឆ្នោតត្រូវធ្វើដោយព្រះសង្ឃ ឬឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យ ដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ ។

៧.២០.៤.៤ ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត ។

៧.២០.៤.៥ ការបិទពិធីចាប់ឆ្នោត ។

៧.២០.៥ គឃ/សប ត្រូវរៀបចំក្រដាសសម្លួយសន្លឹកសម្រាប់គណបក្សនយោបាយនីមួយៗ ។

៧.២០.៥.១ ក្រដាសនេះមានប្រភេទដូចគ្នា និងទំហំប៉ុនគ្នា ។

៧.២០.៥.២ ត្រូវសរសេរឈ្មោះគណបក្សជាអក្សរដែលមានពណ៌និងប្រភេទតួអក្សរដូចគ្នា និងមានទំហំប៉ុនគ្នា នៅលើក្រដាសសនេះ ។

៧.២០.៥.៣ ក្រដាសដែលបានសរសេរឈ្មោះគណបក្សនយោបាយនីមួយៗ រួចហើយ ត្រូវក្លាយទៅជាសន្លឹកឆ្នោតរបស់គណបក្សដែលនឹងត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រ ដែលមានទំហំប៉ុនគ្នា ពណ៌ដូចគ្នា។

៧.២០.៦ មុនចាប់ផ្តើមការចាប់ឆ្នោត គឃ/សប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនីមួយៗ នៅចំពោះមុខអង្គពិធីមុននឹងបត់ដាក់ចូល និងបិទភ្ជិតស្រោមសំបុត្រ ។

៧.២០.៦.១ សន្លឹកឆ្នោតនីមួយៗ ត្រូវបត់ជាពីរ (២) ផ្នត់ ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្រ រួចបិទភ្ជិត ។

៧.២០.៦.២ ស្រោមសំបុត្រឆ្នោតទាំងអស់ ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងប្រអប់ ឬឡាំងតែមួយ ហើយត្រូវក្រឡុកប្រអប់ ឬឡាំងឆ្នោតនោះ។

៧.២០.៦.៣ បន្ទាប់មកត្រូវនិមន្តព្រះសង្ឃ ឬអញ្ជើញឥស្សរជនដែលចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យ ដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌដូចចំណុច ៧.២០.៤.៣ ចាប់យកសំបុត្រឆ្នោតម្តងមួយៗ ពីប្រអប់ ឬឡាំងឆ្នោត ។

៧.២០.៦.៤ ស្រោមសំបុត្រឆ្នោត ដែលចាប់បានត្រូវប្រគល់ទៅមន្ត្រីបោះឆ្នោតម្នាក់ក្នុងចំណោមពីរ (២) នាក់ ដែលជាសមាជិក គឃ/សប ។

៧.២០.៦.៥ មន្ត្រី គឃ/សប មួយ (១) នាក់ ត្រូវបើកស្រោមសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណបក្សនៅចំពោះមុខអង្គពិធី ហើយជូនសន្លឹកឆ្នោតនោះទៅឱ្យមន្ត្រីទីពីរ ។

៧.២០.៦.៦ មន្ត្រីទីពីរត្រូវអានឈ្មោះគណបក្សនយោបាយ ដែលសរសេរនៅលើសន្លឹកឆ្នោតឱ្យបានឮ និងសរសេរលេខរៀង « លេខ ១ » នៅលើសន្លឹកឆ្នោតនោះ ហើយត្រូវបន្តធ្វើការចាប់ឆ្នោត និងចុះលេខរៀងតាមលំដាប់រហូតដល់សន្លឹកឆ្នោតចុងក្រោយបង្អស់ ។

៧.២០.៧ លេខាធិការនៃ គឃ/សប ត្រូវធានាបំពេញកំណត់ហេតុនៃអង្គប្រជុំឱ្យបានរួចរាល់ដោយត្រូវដាក់ភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្ស ដែលបានចុះលេខរៀងហើយដូចមានចែងក្នុងចំណុច ៧.២០.៦.៦ ។ តំណាងគណបក្សនយោបាយ អាចចូលរួមចុះហត្ថលេខានៅលើកំណត់ហេតុនេះបាន ។

៧.២០.៨ គឃ/សប ត្រូវធ្វើបញ្ជីកំណត់លេខរៀងបញ្ជីបេក្ខជន ដែលត្រូវដាក់លើសន្លឹកឆ្នោត តាមលទ្ធផលនៃការចាប់ឆ្នោតជាបួន (៤) ច្បាប់ ដើម្បីផ្ញើជូន ៖

- គ.ជ.ប មួយ (១)ច្បាប់
- គធ/ខប មួយ (១)ច្បាប់
- រក្សាទុកជាឯកសារ មួយ (១)ច្បាប
- បិទផ្សាយ មួយ (១)ច្បាប់

គឃ/សប ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុ ដូចចែងក្នុងចំណុច ៧.២០.៧ ដើម្បីផ្ញើជូនទៅ គ.ជ.ប តាមរយៈ គធ/ខប ។

៧.២០.៩ គ.ជ.ប ត្រូវធ្វើគំរូ និង បោះពុម្ពសន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ ។

៧.២០.៩.១ ការបោះពុម្ពសន្លឹកឆ្នោត ត្រូវផ្អែកតាមចំនួនគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនផ្លូវការនៅក្នុងឃុំ សង្កាត់នោះ ។ សន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់ណាប្រើប្រាស់បានតែនៅក្នុងឃុំ សង្កាត់នោះតែប៉ុណ្ណោះ ។

៧.២០.៩.២ ឈ្មោះ រូបសញ្ញា គណបក្សនយោបាយនៅលើសន្លឹកឆ្នោត ត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់គណបក្សនយោបាយ ត្រូវដាក់ជាលេខរៀងតាមលទ្ធផលនៃការចាប់ឆ្នោត ។

**ប្រការ ៧.២១** គឃ/សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជនក្នុងបញ្ជីនីមួយៗ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីថ្ងៃចាប់ឆ្នោតកំណត់លេខរៀងបញ្ជីបេក្ខជន ។ បញ្ជីបេក្ខជនផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

**ប្រការ ៧.២២** គណបក្សនយោបាយ និងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីជាផ្លូវការត្រូវគោរព ច.ប.ឃ.ស ប.ន.ឃ.ស និងក្រមសីលធម៌ ដែលកំណត់ដោយ គ.ជ.ប ។

# ជំពូកទី ៨
# ការឃោសនាបោះឆ្នោត

**គោលការណ៍នៃការឃោសនាបោះឆ្នោត**

**ប្រការ** ៨.១ អនុលោមតាម ច.ប.ឃ.ស ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និង បេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ ជូនដល់អ្នកបោះឆ្នោត ។ ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើង ជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយ ណាមួយ ។

សកម្មភាពមួយចំនួនដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយមានដូចជា ៖

៨.១.១ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ។

៨.១.២ ការជួបជុំ ឬក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ឬការឃោសនាតាមផ្ទះ ដើម្បីគាំទ្រគណបក្ស ឬ/និងគោលនយោបាយគណបក្សនយោបាយ ឬការសម្តែងមតិសំដៅស្វែងរកសំឡេងឆ្នោត ។

៨.១.៣ ការផ្សព្វផ្សាយតាមឧគ្ឃោសនស័ព្ទដើម្បីគាំទ្របេក្ខជនណាម្នាក់ ឬគោលនយោបាយគណបក្សនយោបាយណាមួយ ។

៨.១.៤ ការផ្សព្វផ្សាយដោយស្រែកជាពាក្យស្លោកខ្លីៗតាមឧបករណ៍ បំពងសំឡេង ឬតាមឧបករណ៍បញ្ចាំងរូបភាព ដែលអាចឱ្យប្រជាពលរដ្ឋស្តាប់ និងមើលបាននូវសារនយោបាយ ។

៨.១.៥ ការផ្សព្វផ្សាយតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬនៅទីធ្លាសាធារណៈ ។

៨.១.៦ សកម្មភាពបិទផ្សាយនូវរូបភាពឃោសនានៅតាមទីសាធារណៈ ។

៨.១.៧ សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ដើម្បីឱ្យអ្នកបោះឆ្នោតបោះឆ្នោតឱ្យខ្លួន ឬគណបក្សនយោបាយរបស់ខ្លួន ។

៨.១.៨ សកម្មភាពចែកចាយមួក សម្លៀកបំពាក់ អាវយឺត ស្លាកសញ្ញា ឬសម្ភារៈផ្សេងៗទៀត ដែលបោះពុម្ព ឬគូរ ឬផលិត ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៨.១.៩ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ និងតាំងឡើងបន្ទះក្តារបិទប្រកាសផ្សាយពីគោលនយោបាយរបស់គណបក្សនយោបាយ ឬបេក្ខជន ។

៨.១.១០ ការប្រគំតន្ត្រីដោយដើរជាក្បួន ឬនៅកន្លែងណាមួយ ឬច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ដើម្បីផ្សព្វផ្សាយគាំទ្របេក្ខជនណាម្នាក់ គណបក្សនយោបាយណាមួយ ។

៨.១.១១ ព្រឹត្តិការណ៍កីឡាដើម្បីប្រមូលប្រាក់គាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

**ប្រការ ៨.២** ការឃោសនាត្រូវបើករយៈពេលដប់ប្រាំមួយ (១៦) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៨.២.១ ការឃោសនាបោះឆ្នោតត្រូវដំណើរការក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ។

៨.២.២ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោងប្រាំមួយ (៦) ព្រឹក ដល់ម៉ោងដប់ (១០) យប់ ។

៨.២.៣ គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ត្រូវឈប់សម្រាកនៅចន្លោះពីម៉ោងដប់ (១០) យប់ ដល់ម៉ោងប្រាំមួយ (៦) ព្រឹក ។

៨.២.៤ សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវហាមឃាត់ចាប់ពីម៉ោងដប់ពីរ (១២) ថ្ងៃត្រង់ ដល់ម៉ោងពីរ (២) រសៀល ។

៨.២.៥ ការឃោសនាបោះឆ្នោត ត្រូវបញ្ឈប់ក្នុងរយៈពេលម្ភៃបួន (២៤) ម៉ោង មុនថ្ងៃបោះឆ្នោត ។

៨.២.៦ រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិទាក់ទងទៅនឹងដំណើរការបោះឆ្នោតត្រូវបញ្ឈប់ប្រាំ (៥) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។ ការស្ទង់មតិ គឺជាការប្រើបញ្ជីសំនួរ ដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋ អំពីដំណើរការបោះឆ្នោត ។ ការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិត្រូវបញ្ជាក់អំពីប្រភពពេលវេលា ចំនួនប្រជាពលរដ្ឋដែលត្រូវបានស្ទង់មតិ និងកម្រិតលម្អៀងនៃលទ្ធផល ។

៨.២.៧ ការស្ទង់មតិជាបុគ្គលមិនរាប់បញ្ចូលនៅក្នុងការឃោសនាបោះឆ្នោតទេ ។

៨.២.៨ គ្រប់សកម្មភាពឃោសនាដែលមានចែងក្នុងជំពូក៨ នេះ ត្រូវបញ្ឈប់ទាំងអស់ក្នុងអំឡុងពេលម្ភៃបួន (២៤) ម៉ោង មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។ ជនណាប្រព្រឹត្តល្មើសនឹងបម្រាមនេះ នឹងត្រូវទទួលការពិន័យតាម ច.ប.ឃ.ស ។

**ប្រការ** ៨.៣ គណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ អាចរៀបចំកិច្ចប្រជុំអំពីកម្មវិធីនយោបាយរបស់ខ្លួននៅទីកន្លែងឯកជនបានគ្រប់ពេល និងមានសិទ្ធិលើកស្លាកគណបក្សនយោបាយគ្រប់ពេលនៅលើទីតាំងឯកជន ឬផ្ទះឯកជន ដោយមានការអនុញ្ញាតពីម្ចាស់ទីកន្លែងនោះ ។

៨.៣.១ ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្រុះសម្រួលពីអាជ្ញាធរ ឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ និងសណ្តាប់ធ្នាប់ ។

៨.៣.២ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារៈឃោសនាសម្រាប់គណបក្សនយោបាយមិនត្រូវអនុញ្ញាតឱ្យលើក ឬបិទនៅលើអគារ និងការិយាល័យរបស់រដ្ឋ ។

៨.៣.៣ ស្លាកសញ្ញា ឬសម្ភារៈឃោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់មួយរយ (១០០) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

៨.៣.៤ គណបក្សនយោបាយ ត្រូវប្រមូលយកមកវិញនូវបណ្ណប្រកាស ខិត្តបណ្ណ ស្លាកសញ្ញា ឬសម្ភារៈឃោសនារបស់ខ្លួន ដែលស្ថិតនៅទីសាធារណៈ ក្នុងរយៈពេលយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

**ប្រការ** ៨.៤ ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៨.៤.១ ហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

៨.៤.២ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋត្រូវបានកំណត់ដូចជា ៖ រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬ/និងរដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល ។

៨.៤.៣ ការដឹកជញ្ជូនមានលក្ខណៈកៀងគរ ឬរៀបចំទុកជាមុន ត្រូវហាមឃាត់ ។

**ប្រការ** ៨.៥ ការស្លៀកពាក់ (សម្លៀកបំពាក់_មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា សារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬខាងក្រៅនៃការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

**ប្រការ** ៨.៦ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញភារកិច្ច មិនត្រូវ ៖

- ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ។
- ប្រមូលផ្តុំមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការមកធ្វើការបញ្ចុះបញ្ចូលក្នុងចេតនាស្វែងរកសំឡេងឆ្នោតនៅក្នុងអគារ និងការិយាល័យរបស់រដ្ឋ ។
- ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយណាឡើយ ។ ការចូលរួមសកម្មដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ដូចតទៅ ៖

៨.៦.១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

៨.៦.២ ការចូលរួមក្នុងក្បួនដង្ហែ ការជួបជុំ ឬនិងក្បួនព្យុហយាត្រាដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៨.៦.៣ ការស្ទង់មតិសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៨.៦.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៨.៦.៥ ការធ្វើសកម្មភាពចែកចាយសម្ភារៈដល់អ្នកបោះឆ្នោតក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៨.៦.៦ ការធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ ក្នុងការគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៨.៦.៧ ការលេងភ្លេងគាំទ្រគណបក្សនយោបាយ ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

**ប្រការ ៨.៧** មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬស្ថិតក្នុងច្បាប់ឈប់សម្រាក អាចចូលរួមក្នុងសកម្មភាពឃោសនា គាំទ្រចំពោះបេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ ប៉ុន្តែពុំត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ ។ មន្ត្រីរាជការស៊ីវិល អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលប្រព្រឹត្តផ្ទុយពីប្រការ ៨.៦ និងប្រការ ៨.៧ ត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ១៧៨ថ្មី និងមាត្រា ១៨៧ថ្មី នៃ ច.ប.ឃ.ស ។

**ប្រការ ៨.៨** មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងាររបស់ខ្លួន ។ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវផ្ដល់សេវា និងព័ត៌មានដូចៗគ្នាជូនដល់អ្នកភូមិទាំងអស់ដើម្បីបង្កើតបរិយាកាសជឿទុកចិត្តគ្នា ។ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវអនុវត្តដូចខាងក្រោម ៖

៨.៨.១ ប្រើប្រាស់ឥទ្ធិពល ឬតួនាទីរបស់ខ្លួនរំលោភលើសិទ្ធិសម្រេចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមសកម្មភាពនយោបាយនានា ការទទួលព័ត៌មានអំពីកិច្ចការនយោបាយ និងការបោះឆ្នោត ។ ការរំលោភលើសិទ្ធិរួមមាន ៖

៨.៨.១.១ បំភិតបំភ័យ ឬគំរាមកំហែងអ្នកបោះឆ្នោតក្នុងគោលបំណងឱ្យអ្នកបោះឆ្នោត គាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាមួយ។

៨.៨.១.២ សួរនាំអ្នកបោះឆ្នោត ឬចង់ដឹងអំពីការបោះឆ្នោតជាសម្ងាត់របស់អ្នកបោះឆ្នោត ។

៨.៨.១.៣ ដកហូតឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ពីប្រជាពលរដ្ឋ ទោះក្នុងកាលៈទេសៈណាក៏ដោយ ។

៨.៨.១.៤ ជ្រៀតជ្រែកលើសិទ្ធិអ្នកបោះឆ្នោតក្នុងការធ្វើសេចក្ដីសម្រេចចិត្តដោយសេរី ដើម្បីគាំទ្រដល់គណបក្សនយោបាយ ឬបេក្ខជនណាមួយ។

៨.៨.២ ធ្វើសកម្មភាពណាមួយ ទោះដោយប្រយោលក្ដី ឬផ្ទាល់ក្ដី ដើម្បីបំភិតបំភ័យ គំរាមកំហែងអ្នកបោះឆ្នោត ដែលនាំឱ្យបាត់សេរីភាព នៃការជ្រើសរើសរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត ។

៨.៨.៣ អូសទាញអ្នកបោះឆ្នោតឱ្យគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយ ឬបេក្ខជនណាមួយ ។

៨.៨.៤ ផ្ដិបទុកព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មានដោយមានការរើសអើង ចំពោះអ្នកគាំទ្រគណបក្សនយោបាយ ។

**ប្រការ** ៨.៩ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលប្រព្រឹត្តល្មើសនឹងប្រការ ៨.៨ ត្រូវផ្ដន្ទាទោសទោសដោយអនុលោមតាមសេចក្ដីណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០០៩ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ស្ដីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិ ការតែងតាំងជំនួយការភូមិ និងតួនាទីភារកិច្ចរបៀបរបបធ្វើការរបស់ភូមិ និងផ្ដន្ទាទោសតាម ច.ប.ឃ.ស ។

**ប្រការ** ៨.១០ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជាមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ដូចខាងក្រោម៖

៨.១០.១ ផ្ដួចផ្ដើម ឬចូលរួមនៅក្នុងការឃោសនារបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។ ការផ្ដួចផ្ដើម ឬការចូលរួមឃោសនារួមមាន ៖

៨.១០.១.១ ការបញ្ចុះបញ្ចូល ឬការប្រមូលផ្ដុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនាដើម្បីគាំទ្រគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.១.២ ការចូលរួមក្នុងក្បួនដង្ហែ ការប្រជុំរបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.១.៣ ការចូលរួមផ្សព្វផ្សាយគោលនយោបាយគណបក្សនយោបាយ ឬសម្ភារៈឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.១.៤ ការចូលរួមក្នុងសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយ ។

៨.១០.២ ចេញសេចក្ដីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយដែលគាំទ្រ ឬបង្ហាញ ភាពលម្អៀងឬប្រឆាំងគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។ ការចេញសេចក្ដីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ និងការបង្ហាញភាពលម្អៀងរួមមាន ៖

៨.១០.២.១ ការស្នង់មតិសម្រាប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.២.២ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.២.៣ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ បន្ទុះបង្អាប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.២.៤ ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារបោះឆ្នោតផ្សេងៗទៀត ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន នៅតាមយានយន្តផ្ទាល់ខ្លួន ឬអង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ។

៨.១០.៣ ផ្តល់មធ្យោបាយជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។ ការផ្តល់មធ្យោបាយជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស រួមមាន ៖

៨.១០.៣.១ ការផ្តល់យានយន្តគ្រប់ប្រភេទដល់គណបក្សនយោបាយ ដើម្បីជាមធ្យោបាយសម្រាប់ឃោសនារបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.៣.២ ការផ្តល់សម្ភារៈប្រើប្រាស់ផ្សេងៗ និងថវិកា ដល់ប្រជាពលរដ្ឋសម្រាប់ជាមធ្យោបាយក្នុងការចូលរួម ឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.៣.៣ ការផ្តល់ថវិកា សម្ភារៈ សម្រាប់ក្បួនដង្ហែឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារៈ សម្រាប់ឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

៨.១០.៤ ហាមជនបរទេស ដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ។

**ប្រការ** ៨.១១ មុននឹងបើកការឃោសនាបោះឆ្នោត គជ/ខប និង គឃ/សប ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានរៀបរាប់ក្រោមប្រការ ៨.៦ ៨.៧ និងប្រការ ៨.៨ ខាងលើ តាមរយៈអាជ្ញាធរដែនដី កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីភារកិច្ច និងអព្យាក្រឹតភាពក្នុងម៉ោងធ្វើការទាក់ទិនដល់ការឃោសនាបោះឆ្នោត ។

**ប្រការ ៨.១២** គធ/ខប និង គឃ/សប ត្រូវចាត់ចែងកម្មវិធីប្រជុំប្រចាំសប្តាហ៍ និងប្រជុំបន្ថែម តាមការចាំបាច់ជាមួយនឹងតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានា ដើម្បី ៖

៨.១២.១ ជម្រាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត ។

៨.១២.២ ជម្រាបជូនជាសង្ខេបពី ប.ន.ឃ.ស ។

៨.១២.៣ ស្តាប់ មតិយោបល់ សំណូមពរ និងការកត់សម្គាល់ផ្សេងៗ ។

៨.១២.៤ ពិភាក្សាលើបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត ។

**ប្រការ ៨.១៣** គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវតែគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ដែលអនុម័តដោយ គ.ជ.ប ។

៨.១៣.១ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវតែគោរពច្បាប់បោះឆ្នោត ។

៨.១៣.២ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ ត្រូវតែគោរព បទបញ្ជា និង នីតិវិធី និងសេចក្តីណែនាំផ្សេងៗដែលបានអនុម័តដោយ គ.ជ.ប ។

៨.១៣.៣ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ។

៨.១៣.៤ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវតែអនុវត្តតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចដែលបានរៀបរាប់ក្នុងជំពូកទី៣ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

៨.១៣.៥ គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង មិនត្រូវបង្ខាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួន ទៅហែកចោលនូវក្រដាសផ្សព្វផ្សាយរបស់គណបក្សនយោបាយ ឬ/និង បេក្ខជនដទៃទៀតឡើយ ។

៨.១៣.៦ គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង មិនត្រូវជំរុញឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបំភិតបំភ័យក្នុងអំឡុងពេលធ្វើការឃោសនាបោះឆ្នោតឡើយ ។

៨.១៣.៧ គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ឬជនណាម្នាក់ មិនត្រូវផ្តល់វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារៈ ទោះបីតាមមធ្យោបាយណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។

៨.១៣.៨ គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលទាំងនោះ ឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ ។ ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

៨.១៣.៨.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។

៨.១៣.៨.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថានឹងធ្វើទារុណកម្ម ។

៨.១៣.៨.៣ ការវាយតប់បង្កិចបង្ខូច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់ ។

៨.១៣.៨.៤ ការរំលោភដោយពាក្យសម្ដីថានឹងធ្វើទុក្ខទោសដល់រាងកាយ ។

៨.១៣.៨.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។

៨.១៣.៨.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាលដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

៨.១៣.៨.៧ ការបាញ់ដោយកាំភ្លើងបង្អើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

៨.១៣.៨.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះ មានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន ។

៨.១៣.៨.៩ ការបណ្ដើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន ។

៨.១៣.៨.១០ ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង ។

៨.១៣.៨.១១ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

៨.១៣.៨.១២ ការធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំឱ្យធ្វើសម្បថ ឬបង្ខំឱ្យផ្ដិតមេដៃឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។

៨.១៣.៨.១៣ ការប្រមូល ឬការដកហូត ឬការបំផ្លាញឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត ។

៨.១៣.៨.១៤ ការកំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោតក្នុងការស្វែងរក ឬស្តាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា ។

**ប្រការ ៨.១៤** គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ដែលប្រព្រឹត្តផ្ទុយនឹងប្រការ ៨.១៣ នឹងត្រូវទទួលទោសតាមមាត្រា ១៧៨ថ្មី មាត្រា ១៨១ថ្មី និងមាត្រា ១៨៧ថ្មី នៃ ច.ប.ឃ.ស ។

## សម្ភារៈអប់រំអ្នកបោះឆ្នោត

**ប្រការ ៨.១៥** នាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីដំណើរការបោះឆ្នោត ។

៨.១៥.១ គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចូលរួមយ៉ាងសកម្ម ដើម្បីឱ្យការអប់រំសាធារណជនដែលទាក់ទងដល់ដំណើរការបោះឆ្នោតមានប្រសិទ្ធភាពខ្ពស់ ។

៨.១៥.២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំសាធារណជនអំពីការបោះឆ្នោត អាចទំនាក់ទំនងជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈនៃ គ.ជ.ប ។

៨.១៥.៣ សម្ភារៈអប់រំអ្នកបោះឆ្នោតដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវតែអព្យាក្រឹត និងមិនលម្អៀង ។ សម្ភារៈនោះ មិនត្រូវគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយ ហើយត្រូវគោរពទៅតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

៨.១៥.៤ សម្ភារៈព័ត៌មានសាធារណៈ និងសម្ភារៈអប់រំដែលផលិតដោយ គ.ជ.ប និងសម្ភារៈអប់រំដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលជាតិ

ឬ/និងអន្តរជាតិ ដែលបានសហការជាមួយ គ.ជ.ប ក្នុងការផលិតសម្ភារៈអប់រំសាធារណជន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវការប្រព្រឹត្តខុសពីកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ ។

៨.១៥.៥ ដើម្បីធានាថា ខ្លឹមសារនៃសម្ភារៈអប់រំអ្នកបោះឆ្នោតដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិត្រឹមត្រូវតាមបច្ចេកទេស និងតាមច្បាប់បោះឆ្នោត ហើយ និងតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប គ.ជ.ប នឹងជួយផ្តល់សេវាកម្មពិនិត្យផ្ទៀងផ្ទាត់/យល់ព្រម និងណែនាំ ដល់អង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្របច្បាប់នៃសម្ភារៈអប់រំនេះ ។

៨.១៥.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាកម្មពិនិត្យផ្ទៀងផ្ទាត់ យល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ ។

៨.១៥.៧ ទោះបីជាសម្ភារៈអប់រំត្រូវបានទទួល ឬមិនបានទទួលលិខិតយល់ព្រមក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយមិនទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតចំពោះខ្លឹមសារបច្ចេកទេសនៃសម្ភារៈអប់រំនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ ។ ម្ចាស់សម្ភារៈអប់រំត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

៨.១៥.៨ ក្នុងករណីដែលមានស្នើសុំការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពដែលមានចែងក្រោមចំណុច ៨.១៦.៨ មានភារកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យផ្ទៀងផ្ទាត់/យល់ព្រម ក្នុងរយៈពេលយ៉ាងយូរចិតសិបពីរ (៧២) ម៉ោង បន្ទាប់ពីទទួលបានសំណើពីអង្គការមិនមែនរដ្ឋាភិបាលនានាសុំឱ្យជួយពិនិត្យផ្ទៀងផ្ទាត់សម្ភារៈអប់រំនោះ ។ ក្នុងករណីពិនិត្យឃើញថា សម្ភារៈ ឬខ្លឹមសារអប់រំ មិនសមស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីទេ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យមានការកែតម្រូវតាមមធ្យោបាយណាមួយដែលប្រសើរបំផុត ។ ក្នុងករណីគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ធ្វើការពិនិត្យផ្ទៀងផ្ទាត់សម្ភារៈអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាលហួសរយៈពេលចិតសិបពីរ (៧២)ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពបានឯកភាពលើខ្លឹមសារនិងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន។

៨.១៥.៩ សម្ភារៈអប់រំដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប ដូចជា ៖

៨.១៥.៩.១ ស្ប៉តវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ ។

៨.១៥.៩.២ កាសែត្តម៉ាញ៉េ ឬខ្សែអាត់សំឡេង ។

៨.១៥.៩.៣ ខិត្តប័ណ្ណផ្សេងៗ និងបដា ។

៨.១៥.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត ។

៨.១៥.៩.៥ ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារព័ត៌មាន ។

៨.១៥.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើសម្លៀកបំពាក់ ឬមួក ។

៨.១៥.១០ សម្ភារៈដែលបានពិនិត្យ ផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខមួយច្បាប់សម្រាប់ជាឯកសារ ។

៨.១៥.១១ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យផ្ទៀងផ្ទាត់/យល់ព្រម ដែលផ្តល់ដោយ គ.ជ.ប ត្រូវទទួលខុសត្រូវតាមបញ្ញត្តិ ច.ប.ឃ.ស ។ ប្រសិនបើព័ត៌មានដែលមានក្នុងសម្ភារៈអប់រំ ដែលខ្លួនបានផលិតនោះត្រូវបានរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយពុំត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធី ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ឃ.ស និង ប.ន.ឃ.ស គ.ជ.ប ត្រូវឱ្យសាមីអង្គការធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារៈនោះទាំងស្រុងតែម្តង ។ សម្ភារៈដែលរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ ដូចចំណុច ៨.១៦.៦ ខាងក្រោម ។

៨.១៥.១២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សទាំងអស់ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋានមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបានតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតប៉ុណ្ណោះ ។

៨.១៥.១៣ គ.ជ.ប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬសម្ភារៈអប់រំទាំងអស់ ដែលមិនគោរពតាមចំណុច ៨.១៥.៣ ៨.១៥.១២ និង ៨.១៦.៦ សាមីអង្គការត្រូវធ្វើការកែតម្រូវតាមសំណើរបស់ គ.ជ.ប ជាចាំបាច់ ។ ក្នុងករណីកំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីអង្គការត្រូវទទួលទោសតាមមាត្រា ១៤៧ថ្មី នៃ ច.ប.ឃ.ស ។

**រូបភាព និងសម្ភារៈឃោសនាផ្សព្វផ្សាយ**

**ប្រការ** ៨.១៦ យោងតាមប្រការ ៨.២ គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយ អាចប្រើប្រាស់រូបភាព ឬសម្ភារៈឃោសនាផ្សព្វផ្សាយបានដូចជា ៖

៨.១៦.១ ខិត្តប័ណ្ណឃោសនាបោះឆ្នោត ។

៨.១៦.២ ការឃោសនា តាមឧត្ត្បាសនស័ព្ទ ឬតាមឧបករណ៍បញ្ចាំងរូបភាព ។

៨.១៦.២.១ អត្ថបទឃោសនា ។

៨.១៦.២.២ បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ ។

៨.១៦.២.៣ ការសូត្រកំណាព្យ ។

៨.១៦.២.៤ ការប្រគំតន្ត្រី ។

៨.១៦.២.៥ កិច្ចសម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយមិនបន្តផ្ទាល់ ។

៨.១៦.២.៦ ការសម្ដែងសិល្បៈ ។

៨.១៦.២.៧ ការចាក់កាសែត្តវីដេអូជាសាធារណៈ ។

៨.១៦.៣ ដោយយោងលើរូបភាព និងសម្ភារៈឃោសនាបោះឆ្នោតដូចបានបញ្ជាក់ ខាងលើ មធ្យោបាយផ្សេងៗទៀតរួមមាន ៖

៨.១៦.៣.១ រឿងល្ខោនខ្លីៗ និងការសម្ដែងសិល្បៈ ការបញ្ចាំងខ្សែភាពយន្តវីដេអូ ។

៨.១៦.៣.២ ប៉េងប៉ោង ឬ/និងបង្ហោះខ្លែង ។

៨.១៦.៣.៣ សម្ភារៈបោះពុម្ពដូចជា រូបភាពបិទផ្សាយសម្លៀកបំពាក់ អាវយឺត មួក ស្លាកសញ្ញា ពាក្យស្លោក ឬរូបភាពបិទតាមរថយន្ត ស្លាកសញ្ញាលោហៈខ្វាស់ បដា ។ល។

៨.១៦.៣.៤ ការស្រែកតាមទីសាធារណៈ ។

៨.១៦.៤ គ.ជ.ប បង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពមួយ ដើម្បីពិនិត្យសម្ភារៈអប់រំដែលផលិតដោយ គ.ជ.ប អង្គការមិនមែនរដ្ឋាភិបាលជាតិ ឬអន្តរជាតិ ដូចមានចែងក្នុងចំណុច ៨.១៥.១១ និងសម្ភារៈឃោសនារបស់គណបក្សនយោបាយក្នុងករណីមានការតវ៉ា ឬមានបណ្ដឹងពីគណបក្សនយោបាយ បេក្ខជន ឬតំណាង ។

៨.១៦.៤.១ សមាសភាពគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព មានដូចខាងក្រោម ៖

១. អគ្គលេខាធិការរង ជាប្រធាន

២. ជំនួយការ គ.ជ.ប មួយរូប ជាអនុប្រធាន

៣. ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ជាសមាជិក

៤. ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ជាសមាជិក

៥. អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ទទួលបន្ទុកព័ត៌មានសាធារណៈ ជាសមាជិក

៦. ជំនួយការនាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ជាសមាជិក ។

៨.១៦.៤.២ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត ដើម្បីពន្យល់ប្រាប់អំពីដំណើរការឃោសនាបោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

៨.១៦.៤.៣ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវរៀបចំចាត់ចែងឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ជាផ្លូវការ មានឱកាសផ្សព្វផ្សាយអំពីគោលនយោបាយរួមរបស់គណបក្សនយោបាយនីមួយៗ ក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ដល់អ្នកបោះឆ្នោត តាមទូរទស្សន៍ និងវិទ្យុរបស់រដ្ឋ ផ្អែកតាមគោលការណ៍របស់ គ.ជ.ប និងតាមលំដាប់ពេលមុនក្រោយ ។

៨.១៦.៤.៤ ក្នុងករណីដូចមានចែងក្នុងចំណុច ៨.១៥.១១ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពត្រូវត្រួតពិនិត្យ ឱ្យឃើញថាខ្លឹមសារសម្ភារៈអប់រំនោះមិនរួមបញ្ចូលនូវខ្លឹមសារដូចមានចែងក្នុងចំណុច ៨.១៦.៦ ឡើយ ។

៨.១៦.៤.៥ ក្នុងករណីមានការតវ៉ា ឬមានបណ្តឹងពីគណបក្សនយោបាយ បេក្ខជន ឬតំណាង គណៈកម្មការសម្របសម្រួលត្រូវត្រួតពិនិត្យសម្ភារៈឃោសនានោះ ដោយយោងតាមមាត្រា ១៧៨ថ្មី និងមាត្រា ១៨៧ថ្មី នៃ ច.ប.ឃ.ស និងយោងតាមចំណុច ៨.១៣.៨ ៨.១៦.៦ និង ៨.១៦.៩ ក្នុងជំពូកទី៨ នៃ ប.ន.ឃ.ស នេះ ។

៨.១៦.៥ គ្រប់សម្ភារៈ ឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយដោយបេក្ខជន ឬ/និងគណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសម្គាល់របស់សាមីគណបក្ស (ឈ្មោះ ឬ/និងអាសយដ្ឋាន) ។

៨.១៦.៦ សម្ភារៈអប់រំ និងសម្ភារៈឃោសនាដែលត្រូវបានផ្សព្វផ្សាយជាទម្រង់អត្ថបទបោះពុម្ព ឬតាមឧបករណ៍បំពងសំឡេងមិនត្រូវរួមបញ្ចូល ឬប្រើប្រាស់នូវរូបភាពណាមួយដូចខាងក្រោម ៖

៨.១៦.៦.១ ប្រើប្រាស់រូបភាព ឬភាសាដែលញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ឬធ្វើឱ្យបាត់បង់ជំនឿជឿជាក់លើភាពសម្ងាត់នៃការបោះឆ្នោត ។

៨.១៦.៦.២ ប្រើប្រាស់រូបភាព ឬភាសាដែលមាក់ងាយ បំភិតបំភ័យ ប្រមាថ សម្ដែងការមាក់ងាយ ឬអសីលធម៌ ។

៨.១៦.៦.៣ ប្រើប្រាស់រូបភាព ឬភាសាដែលសាបព្រោះភាពភ័យខ្លាចធ្វើឱ្យភ័ន្តច្រឡំ និងខូចរបៀបរបបសង្គម ។

៨.១៦.៦.៤ ប្រើប្រាស់រូបភាព ឬភាសាដែលមានព័ត៌មានមិនត្រឹមត្រូវចំពោះដំណើរការបោះឆ្នោត ។

៨.១៦.៧ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារៈអប់រំ និងសម្ភារៈឃោសនាដែលត្រូវបានរកឃើញថារំលោភចំណុច ៨.១៦.៦ ខាងលើ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារៈខុសច្បាប់ទាំងនោះ ។

៨.១៦.៨ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះសម្ភារៈដែលខ្លួនផ្សព្វផ្សាយ ចំពោះមុខច្បាប់យោងតាមមាត្រា ១៨៧ថ្មី នៃ ច.ប.ឃ.ស ។

៨.១៦.៩ ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា រូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសំឡេងឆ្នោត ។

៨.១៦.១០ ហាមលើកបដាឃោសនា ស្លាកសញ្ញាគណបក្សនយោបាយ និងរូបសញ្ញាណាមួយដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ឆ្លងកាត់ទទឹងផ្លូវសាធារណៈ ។

**ប្រការ ៨.១៧** អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈ ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលសុំជួលប្រើប្រាស់សម្រាប់ធ្វើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការស្នើសុំ ។ គណបក្សនយោបាយ ឬបេក្ខជន ដែលមានបំណងជួលរោងមហោស្រព ឬមណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈ ត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងយ៉ាងហោច ៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ហើយត្រូវផ្ញើសេចក្តីចម្លងនៃពាក្យសុំនេះមួយច្បាប់ដល់ គឃ/សឃ ។ អ្នកគ្រប់គ្រងត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំមិនឱ្យលើសពីម្ភៃបួន (២៤) ម៉ោង ក្រោយពីបានទទួលពាក្យស្នើសុំ ។

៨.១៧.១ បន្ទាប់ពីបានទទួលនូវសេចក្តីជូនដំណឹង ដូចមានចែងក្រោមប្រការ ៨.១៧ គឃ/សឃ ត្រូវមានវិធានការសម្របសម្រួលអំពីការងារសន្តិសុខ និងសណ្តាប់ធ្នាប់ សម្រាប់ឱ្យគណបក្សនយោបាយ ឬបេក្ខជន ធ្វើការឃោសនា ។

៨.១៧.២ គឃ/សឃ ត្រូវមានសៀវភៅចុះលិខិតចម្លងនៃពាក្យស្នើសុំធ្វើការឃោសនារបស់គណបក្សនយោបាយ ឬបញ្ជីបេក្ខជន ដែលបានចម្លងជូនដើម្បីឱ្យបានដឹងថាគណបក្សនយោបាយណាបានស្នើសុំធ្វើការឃោសនាមុន និងគណបក្សនយោបាយណាបានស្នើសុំធ្វើឃោសនាបន្តបន្ទាប់ ។

៨.១៧.៣ គឃ/សឃ ត្រូវធ្វើកាលវិភាគប្រចាំសប្តាហ៍ ស្តីពីកាលកំណត់តាមលំដាប់លំដោយនៃការស្នើសុំប្រើប្រាស់ទីសាធារណៈ និងទីកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គឃ/សឃ មួយច្បាប់ និងនៅទីកន្លែងដែលត្រូវធ្វើការឃោសនាមួយច្បាប់ ។

៨.១៧.៤ គធ/ខប គឃ/សឃ គ្រាន់តែជាអ្នកជួយសម្របសម្រួល និងរៀបចំតាមលំដាប់នៃការជូនដំណឹងស្តីពីការធ្វើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ និងមានវិធានការទប់ស្កាត់ និងដោះស្រាយចំពោះការឃោសនាទាំងឡាយណា ដែលផ្ទុយនឹង ច.ប.ឃ.ស ប.ន.ឃ.ស និងក្រមសីលធម៌សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ៨.១៨** ក្នុងករណីគណបក្សនយោបាយចង់រៀបចំក្បួនយុទ្ធនាការឃោសនាបោះឆ្នោតរួមគ្នាច្រើនឃុំ សង្កាត់ គណបក្សនយោបាយនោះត្រូវជូនដំណឹងទៅគ្រប់ គឃ/សឃ ដែលក្បួនដង្ហែត្រូវឆ្លងកាត់យ៉ាង

ហោចឱ្យបាន បី (៣) ថ្ងៃមុនថ្ងៃហែក្បួនឃោសនា ។ គឃ/សឃ ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីសម្របសម្រួលពេលវេលារវាងគណបក្សនយោបាយ និងគណបក្សនយោបាយផ្សេងទៀតជៀសវាងជាន់កម្មវិធីគ្នាក្នុងពេលតែមួយនៅពេលយុទ្ធនាការឃោសនាបោះឆ្នោត ។

**ប្រការ ៨.១៩** គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយត្រូវរក្សានូវសណ្តាប់ធ្នាប់ល្អ តាមដងផ្លូវ ទីប្រជុំជន និងទីសាធារណៈ ។

**ប្រការ ៨.២០** គណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត អាចធ្វើសកម្មភាពឃោសនានៅលើទីកន្លែងឯកជន ឬនៅសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ/សឃ យ៉ាងតិច បី (៣) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ។ អ្នកគ្រប់គ្រងទីកន្លែង ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់បម្រើការឃោសនាដោយផ្អែកលើគោលការណ៍ស្មើភាព និងលំដាប់មុនក្រោយ ។

**ប្រការ ៨.២១** គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រផ្សេងទៀតឡើយ ។ សកម្មភាពដែលជ្រៀតជ្រែក និងធ្វើឱ្យរំខាន រាំងស្ទះនោះរួមមាន ៖

៨.២១.១ ការនិយាយដៀមដាមប្រមាថមើលងាយ ។

៨.២១.២ ការធ្វើទុក្ខទោសដល់រាងកាយ ។

៨.២១.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់ ។

៨.២១.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សកំពុងធ្វើការឃោសនា ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាលអ្នកណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ។

៨.២១.៥ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ទុចបង្អាក់មិនឱ្យក្បួនដង្ហែឃោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាផ្សេងៗទៀត ។

៨.២១.៦ ការប្រើគ្រឿងផ្ទុះដើម្បីរំខានដល់សកម្មភាពឃោសនា របស់គណបក្សនយោបាយ ឬបេក្ខជន ។

៨.២១.៧ ការប្រើឧបករណ៍បំពងសំឡេងដើម្បីរំខានដល់ទីកន្លែងដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនា ឬការជួបប្រជុំ ។

៨.២១.៨ ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្សនយោបាយ ឬសម្ភារៈឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ។

**ប្រការ ៨.២២** បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នា ក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

៨.២២.១ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាស សុវត្ថិភាពសម្រាប់ការបោះឆ្នោត ។

៨.២២.២ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មានភារកិច្ច និងការទទួលខុសត្រូវដោយធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

៨.២២.៣ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដែលមានភារកិច្ចការពារ មិនត្រូវឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែង ដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយបេក្ខជន ឬ/និងគណបក្សនយោបាយណាមួយ ។

៨.២២.៤ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គឃ/សប ត្រូវតាមដានជារៀងរាល់ថ្ងៃអំពីកំរិតសន្តិសុខ និងសុវត្ថិភាពក្នុងឃុំ សង្កាត់ និងត្រូវជូនព័ត៌មានទៅ គធ/ខបជារៀងរាល់ថ្ងៃ ។ គធ/ខប ត្រូវសរុបសភាពការណ៍ សន្តិសុខ សុវត្ថិភាព និងរាយការណ៍ជូន គ.ជ.ប ជារៀងរាល់ថ្ងៃ ។

## ភារកិច្ច និងភាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

**ប្រការ ៨.២៣** កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត ។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការ និងការគាំទ្រពីក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោតតាមគោលការណ៍ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធស្តីពីគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (ឧបសម្ព័ន្ធទី ១៤) ។

**ប្រការ ៨.២៤** ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិចរបស់ឯកជន ដែលមានបំណងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ត្រូវអនុវត្តតាមគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចមានចែងក្នុងឧបសម្ព័ន្ធស្តីពីគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី និងយុត្តិធម៌ ។

**ប្រការ ៨.២៥** គ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ទាំងរដ្ឋ និងឯកជនត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងអំឡុងពេលបោះឆ្នោត ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធស្តីពីគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងអំឡុងពេលឃោសនាបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

**ប្រការ ៨.២៦** រាល់បណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវអនុវត្តតាមជំពូកទី១៦ នៃបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

# ជំពូកទី ៩
# ភ្នាក់ងារនៃគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន

**ភ្នាក់ងារនៃគណបក្សនយោបាយ**

**ប្រការ** ៩.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម គឺជាសេនាធិការរបស់ គ.ជ.ប ក្នុងការងារទាក់ទងទៅនឹងភ្នាក់ងារនៃគណបក្សនយោបាយ ។

៩.១.១ ដោយអនុលោមទៅតាម ច.ប.ឃ.ស ភ្នាក់ងារនៃគណបក្សនយោបាយ គឺជាតំណាងដែលតែងតាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬ គឃ/សប ដើម្បីសង្កេតមើលដំណើរការរៀបចំការបោះឆ្នោត ។ ភ្នាក់ងារនៃគណបក្សនយោបាយ គឺជាអ្នកសង្កេតការណ៍ដែលមានសិទ្ធិប្តឹងតវ៉ា ឬជំទាស់ ។

៩.១.២ ការផ្តល់បណ្ណសម្គាល់ភ្នាក់ងារនៃគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចែកចេញជាពីរ (២) ដំណាក់កាល ។

៩.១.២.១ ដំណាក់កាលទី ១ គឺជាដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.១.២.២ ដំណាក់កាលទី ២ គឺជាដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.១.៣ គណបក្សនយោបាយត្រូវហ្វឹកហ្វឺនដល់ភ្នាក់ងាររបស់ខ្លួន អំពី ច.ប.ឃ.ស និងច្បាប់ស្តីពីគណបក្សនយោបាយព្រមទាំង ប.ន.ឃ.ស និងក្រមសីលធម៌ សម្រាប់គណបក្សនយោបាយសម្រាប់ការបោះឆ្នោត ។

**ដំណាក់កាលទី ១ : ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

៩.១.៤ សម្រាប់ដំណាក់កាលទី ១ គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិចាត់តាំងភ្នាក់ងារពេញសិទ្ធិរបស់ខ្លួនមួយ (១) នាក់ និងភ្នាក់ងារបម្រុងមួយ (១) នាក់ ដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ និងការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលកំណត់ដោយ គ.ជ.ប ។

៩.១.៨.១ ភ្នាក់ងារនៃគណបក្សនយោបាយនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះតែម្នាក់ប៉ុណ្ណោះ ។ ភ្នាក់ងារបម្រុងនៃគណបក្សនយោបាយ ត្រូវអនុញ្ញាតឱ្យចាំនៅក្រៅការិយាល័យពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិក្នុងករណីមានការផ្លាស់ប្តូរ ។

៩.១.៨.២ គណបក្សនយោបាយដែលមានបំណងដូចចំណុច ៩.១.៨ ត្រូវដាក់ពាក្យចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ចាប់ពីប្រាំពីរ (៧)ថ្ងៃ មុនចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរហូតដល់ថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.១.៨.៣ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវផ្តល់គំរូពាក្យសុំចុះឈ្មោះជាភ្នាក់ងារនៃគណបក្សនយោបាយដល់គណបក្សនយោបាយ ទម្រង់បែបបទលេខ ១០០៧ ដោយឥតគិតថ្លៃ ។ គណបក្សអាចថតចម្លងគំរូពាក្យសុំទម្រង់បែបបទលេខ ១០០៧ ដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារនៃគណបក្សនយោបាយ ។

៩.១.៨.៤ ពាក្យសុំចុះឈ្មោះ ជាភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវធ្វើជាបី (៣) ច្បាប់ ដោយភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ មួយ (១) ច្បាប់ ។
- បញ្ជីឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលជានីតិជនដោយបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋានបច្ចុប្បន្នរបស់ភ្នាក់ងារនោះ ។
- សេចក្តីប្រកាសគោរពច្បាប់ស្តីពីការបោះឆ្នោតច្បាប់ស្តីពីគណបក្សនយោបាយ ប.ន.ឃ.ស និងក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ ។

៩.១.៨.៥ ភ្នាក់ងារនៃគណបក្សនយោបាយត្រូវ ៖

- មានសិទ្ធិបោះឆ្នោត
- មានសមត្ថភាពអាចបំពេញការងារបាន
- បានទទួលការហ្វឹកហ្វឺន ជាភ្នាក់ងារនៃគណបក្សនយោបាយដោយគណបក្សនយោបាយសាមី ។

៩.១.៨.៦ ភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវចុះហត្ថលេខាក្នុងខ្ទង់ហត្ថលេខា ត្រង់បន្ទាត់ឈ្មោះរបស់ខ្លួន ក្នុងបញ្ជីឈ្មោះភ្នាក់ងារនៃគណបក្សនយោបាយ ដើម្បីជាភស្តុតាងនៃការប្រកាសសន្យាថា ៖

- ស្ម័គ្រចិត្តយល់ព្រមតាមការតែងតាំងរបស់គណបក្ស ធ្វើជាភ្នាក់ងារនៃគណបក្សនយោបាយសម្រាប់សង្កេតការណ៍បោះឆ្នោត ។
- គោរព ច.ប.ឃ.ស ប.ន.ឃ.ស និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារនៃគណបក្សនយោបាយ ។
- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណីសាមីខ្លួនរំលោភបំពានលើសេចក្តីប្រកាសសន្យានៅចំណុចទី ២ ខាងលើនេះ ។

៩.១.៨.៧ ពាក្យសុំចុះឈ្មោះភ្នាក់ងារនៃគណបក្សនយោបាយត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយ ដែលទទួលបានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ ។

៩.១.៨.៨ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានទទួលប្រតិភូកម្មអំណាច ត្រូវពិនិត្យពាក្យសុំចុះឈ្មោះជាភ្នាក់ងារនៃគណបក្សនយោបាយ និងចេញសេចក្តីសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះភ្នាក់ងារនៃគណបក្សនយោបាយ ដែលមានក្នុងបញ្ជីឈ្មោះស្នើសុំមកក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យស្នើសុំ ។ បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងសម្រេចលើបញ្ជីឈ្មោះភ្នាក់ងារនៃគណបក្សនយោបាយរួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចុះហត្ថលេខា និងបោះត្រាលើគ្រប់ទំព័រទាំងបី (៣)ច្បាប់ ដើម្បី ៖

- ផ្ញើទៅសាមីគណបក្សនយោបាយ មួយ (១) ច្បាប់
- ផ្ញើទៅ លធ/ខប ឬ គធ/ខប មួយ (១) ច្បាប់
- រក្សាទុកជាឯកសារមួយ (១)ច្បាប់ ។

៩.១.៨.៩ ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យលើពាក្យស្នើសុំឃើញថាភ្នាក់ងារនៃគណបក្សនយោបាយណាមួយ ពុំមានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ៩.១.៨.៥ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅតំណាងគណបក្សនយោបាយសាមី ក្នុងរយៈពេលយ៉ាងយូរបី (៣)ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ ។ គណបក្សនយោបាយ

មានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងបម្រុងរបស់ខ្លួនជាថ្មីម្ដងទៀតជំនួសឈ្មោះភ្នាក់ងារពេញសិទ្ធិ និងបម្រុង ដែលបានបដិសេធមកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងអំពីការបដិសេធ ។ ក្នុងរយៈពេលនេះ ប្រសិនបើតំណាងគណបក្សនៅតែពុំព្រមកែតម្រូវតាមលក្ខខណ្ឌដូចបានកំណត់ទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវសម្រេចយកឈ្មោះភ្នាក់ងារនៃគណបក្សនយោបាយ ដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ ។

៩.១.៤.១០ បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះរបស់តំណាងគណបក្សនយោបាយរួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្ដល់បណ្ណសម្គាល់ជូនភ្នាក់ងារនៃគណបក្សនយោបាយ ដើម្បីឱ្យបំពេញ និងបិទរូបថត ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រានៅលើជ្រុងខាងស្ដាំនៃរូបថតលើបណ្ណសម្គាល់ភ្នាក់ងារនៃគណបក្សនយោបាយនិងផ្ដល់ជូនដើម្បីពាក់បំពេញការងារ ។

៩.១.៤.១១ បណ្ណសម្គាល់ភ្នាក់ងារនៃគណបក្សនយោបាយ សម្រាប់ដំណាក់កាលទី ១ មានសុពលភាពប្រើប្រាស់បានតែក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ ។

៩.១.៤.១២ ស្មៀនឃុំ សង្កាត់ ត្រូវរាយការណ៍ទៅក្រុមប្រឹក្សាឃុំ សង្កាត់អំពីវត្តមាន និងសកម្មភាពនានារបស់ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

**ដំណាក់កាលទី ២ : ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

៩.១.៥ សម្រាប់ដំណាក់កាលទី ២ គណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឃុំ សង្កាត់ណាមួយ មានសិទ្ធិបញ្ជូនភ្នាក់ងាររបស់ខ្លួនជាភ្នាក់ងារពេញសិទ្ធិមួយ (១) នាក់ និងភ្នាក់ងារបម្រុងមួយ (១) នាក់ ដើម្បីពិនិត្យមើលដំណើរការបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ ដែលខ្លួនឈរឈ្មោះបោះឆ្នោត ។

៩.១.៥.១ បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារនៃគណបក្សនយោបាយ ដើម្បីសង្កេតការណ៍នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។

៩.១.៥.២ ភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតែម្នាក់ប៉ុណ្ណោះ ។ ភ្នាក់ងារបម្រុងនៃគណបក្សនយោបាយ ត្រូវបានអនុញ្ញាតឱ្យចាំនៅក្រៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិក្នុងករណីមានការផ្លាស់ប្តូរ ។

៩.១.៥.៣ ក្នុងដំណាក់កាលទី ២ នេះ គណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះនៅឃុំ សង្កាត់ណាមួយ គណបក្សនយោបាយនោះ ក៏អាចបញ្ជូនសមាជិករបស់ខ្លួនចូលរួមសង្កេតការណ៍នៅក្នុងឃុំ សង្កាត់នោះ ដូចជាអ្នកសង្កេតការណ៍ជាតិតាមការកំណត់ដូចមានចែងក្នុង ប.ន.ឃ.ស នេះ ។ នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះឈ្មោះអ្នកសង្កេតការណ៍នៃគណបក្សនយោបាយនេះ ត្រូវស្នើសុំទៅ គ.ជ.ប ដូចជាអ្នកសង្កេតការណ៍ជាតិ ។ អ្នកសង្កេតការណ៍នៃគណបក្សនយោបាយនោះមានសិទ្ធិ ដូចជាអ្នកសង្កេតការណ៍ជាតិ នៃអង្គការមិនមែនរដ្ឋាភិបាល ។

៩.១.៥.៤ គណបក្សនយោបាយដូចមានចែងក្នុងចំណុច ៩.១.៥ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ គឃ/សប ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ។

៩.១.៥.៥ ពាក្យសុំចុះឈ្មោះជាភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវធ្វើជាបី (៣) ច្បាប់ តាមទម្រង់បែបបទលេខ ១០០៧ ដោយភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ថតចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ មួយ (១) ច្បាប់
- បញ្ជីឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងនៃគណបក្សនយោបាយដោយមាននាមត្រកូល នាមខ្លួន អាសយដ្ឋាន និងលេខការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះត្រូវបំពេញការងារ
- បញ្ជីភ្នាក់ងារគណបក្សនយោបាយ ដែលមានការបញ្ជាក់របស់មេឃុំ ចៅសង្កាត់ ថាបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ។

៩.១.៥.៦ ពាក្យសុំចុះឈ្មោះ ជាភ្នាក់ងារនៃគណបក្សនយោបាយត្រូវចុះហត្ថលេខា ដោយប្រធាន ឬតំណាងនៃគណបក្សនយោបាយ ដែលទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ ។

៩.១.៥.៧ គឃ/សឃ ត្រូវពិនិត្យពាក្យសុំចុះឈ្មោះជាភ្នាក់ងារនៃគណបក្សនយោបាយ និងចេញសេចក្តីសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះនៃភ្នាក់ងារគណបក្សនយោបាយ ដែលមានក្នុងបញ្ជីឈ្មោះស្នើសុំមក ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំ ។

៩.១.៥.៨ គឃ/សឃ ត្រូវសម្រេចអនុញ្ញាត ឬបដិសេធដោយអនុវត្តតាមនីតិវិធីដូចមានក្នុងដំណាក់កាលទី ១ ចំណុច ៩.១.៤.៨ ៩.១.៤.៩ ៩.១.៤.១០ និង ៩.១.៤.១១ ។

៩.១.៥.៩ គណបក្សនយោបាយនីមួយៗ មានសិទ្ធិផ្លាស់ប្តូរភ្នាក់ងាររបស់ខ្លួនក្នុងដំណាក់កាលទី ២ នេះ រហូតដល់ម៉ោង ១៧:៣០ នាទី ថ្ងៃសៅរ៍ មុនថ្ងៃបោះឆ្នោតមួយ (១) ថ្ងៃ ។

៩.១.៥.១០ គណបក្សនយោបាយ ដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះនៅក្នុងឃុំសង្កាត់ណាមួយ ហើយមានបំណងបញ្ជូនភ្នាក់ងាររបស់ខ្លួនទៅសង្កេតការណ៍ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងឃុំសង្កាត់ នោះ គណបក្សនោះត្រូវដាក់ពាក្យសុំចុះឈ្មោះទៅ គ.ជ.ប ដូចមានចែងក្រោមប្រការ ៩.៥ នៃ ប.ន.ឃ.ស នេះ ។

៩.១.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំគំរូ និងខ្លឹមសារនៃពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារនៃគណបក្សនយោបាយទាំងពីរដំណាក់កាល ។ បណ្ណសម្គាល់ភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងនៃគណបក្សនយោបាយសម្រាប់ដំណាក់កាលទី១ និងទី២ ត្រូវប្រើពណ៌ផ្សេងគ្នា ។ គឃ/សឃ ត្រូវផ្តល់បណ្ណសម្គាល់ជូនភ្នាក់ងារគណបក្សនយោបាយដោយឥតគិតថ្លៃ ដើម្បីបំពេញ និងបិទរូបថត ។

៩.១.៧ បណ្ណសម្គាល់ភ្នាក់ងារនៃគណបក្សនយោបាយសម្រាប់ដំណាក់កាលទី២ មានសុពលភាពសម្រាប់សង្កេតមើលការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.១.៨ ភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ច ដូចមានចែងក្នុងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារនៃគណបក្សនយោបាយ ។

៩.១.៩ ភ្នាក់ងារនៃគណបក្សនយោបាយ ដែលរំលោភលើ ច.ប.ឃ.ស ប.ន.ឃ.ស និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយនឹងត្រូវទទួលទោស និងពិន័យទៅតាម ច.ប.ឃ.ស ។

៩.១.១០ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ។

៩.១.១១ គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត គឃ/សប និង គធ/ខប ត្រូវរាយការណ៍ទៅថ្នាក់លើមួយថ្នាក់របស់ខ្លួនអំពីវត្តមាន និងសកម្មភាពនានារបស់ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

**អ្នកសង្កេតការណ៍បោះឆ្នោត**

**ប្រការ** ៩.២ អ្នកសង្កេតការណ៍បោះឆ្នោតរួមមានអ្នកសង្កេតការណ៍ជាតិ និងអ្នកសង្កេតការណ៍អន្តរជាតិ ៖

៩.២.១ អ្នកសង្កេតការណ៍ជាតិ គឺជាជនជាតិខ្មែរ ឬជនបរទេសជាសមាជិកនៃសមាគម និងអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុក ឬជនបរទេសដែលត្រូវបានអញ្ជើញដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតដោយ គ.ជ.ប ។

៩.២.២ អ្នកសង្កេតការណ៍អន្តរជាតិ គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានា ដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប ។

៩.២.៣ រាល់ការចំណាយទាំងឡាយរបស់អ្នកសង្កេតការណ៍បោះឆ្នោត ជាបន្ទុករបស់ស្ថាប័ន អង្គការ ឬសាមីខ្លួន ។

**អ្នកសង្កេតការណ៍ជាតិ**

**ប្រការ** ៩.៣ គ.ជ.ប ត្រូវធ្វើសេចក្តីជូនដំណឹងជាមុន អំពីប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិត្រូវធ្វើនៅ គ.ជ.ប ។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃជូនដំណឹងរហូតដល់ដប់ (១០) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៩.៣.១ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

៩.៣.១.១ មានលិខិតបញ្ជាក់ការចុះបញ្ជីជាផ្លូវការ នៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាយ៉ាងហោចណាស់ប្រាំពីរ (៧) ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

៩.៣.១.២ មានលក្ខន្តិកៈ ឬឯកសារប្រហាក់ប្រហែលគ្នា ដែលបញ្ជាក់ពីគោលបំណង ឬទិសដៅក្នុងការលើកកម្ពស់ការការពារអភិបាលកិច្ចល្អ ប្រជាធិបតេយ្យ ឬការបោះឆ្នោត ឬសិទ្ធិមនុស្ស ឬច្បាប់ ឬយុត្តិធម៌សង្គម ។

៩.៣.១.៣ មានកម្មវិធីបណ្តុះបណ្តាលអប់រំ ស្តីពីការបោះឆ្នោតជូនសមាជិកសង្កេតការណ៍របស់ខ្លួន ។

៩.៣.១.៤ មានផែនការការងារ និងស្ថានភាពថវិការបស់ខ្លួន ។

៩.៣.២ ដើម្បីចូលរួមសង្កេតការណ៍បោះឆ្នោត អ្នកសង្កេតការណ៍ជាតិ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានលក្ខណសម្បត្តិដូចចំណុច ៩.៣.១ ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួនទៅ គ.ជ.ប ។

៩.៣.៣ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ត្រូវផ្តល់គំរូនៃពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតដោយឥតគិតថ្លៃ ។ ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតត្រូវធ្វើជាបី (៣) ច្បាប់ ដោយភ្ជាប់មកជាមួយ ៖

៩.៣.៣.១ លក្ខណសម្បត្តិដូចចំណុច ៩.៣.១ ។

៩.៣.៣.២ បញ្ជីឈ្មោះអ្នកសង្កេតការណ៍តាមរាជធានី ខេត្តដែលត្រូវធ្វើការសង្កេតការណ៍ ។

៩.៣.៣.៣ សេចក្តីប្រកាសគោរពច្បាប់បោះឆ្នោត ប.ន.ឃ.ស និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

៩.៣.៤ អ្នកសង្កេតការណ៍បោះឆ្នោតត្រូវមានសិទ្ធិបោះឆ្នោត និងបានទទួលការហ្វឹកហ្វឺនអំពី ច.ប.ឃ.ស ប.ន.ឃ.ស និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ ។

៩.៣.៥ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំចុះឈ្មោះ ។

៩.៣.៥.១ ក្នុងករណីពិនិត្យបញ្ជីឈ្មោះ ដែលដាក់ស្នើសុំមកឃើញថា អ្នកសង្កេតការណ៍ណាម្នាក់ពុំមានលក្ខណៈគ្រប់គ្រាន់ គ.ជ.ប ត្រូវបដិសេធឈ្មោះរបស់ជននោះ ដោយត្រូវរក្សាទុកឈ្មោះអ្នកសង្កេតការណ៍ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងគូសបន្ទាត់លុបលើឈ្មោះ ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់ និងចារបដិសេធនៅខាងចុងឈ្មោះត្រង់ខ្ទង់ផ្សេងៗ ។

៩.៣.៥.២ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍របស់ខ្លួនជាថ្មីមួយលើកទៀតជំនួសឈ្មោះអ្នកសង្កេតការណ៍ ដែលបានបដិសេធ ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងបដិសេធ ។

៩.៣.៥.៣ ក្នុងរយៈពេលកំណត់ខាងលើ សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល មិនបានកែតម្រូវឈ្មោះអ្នកសង្កេតការណ៍ ដែលពុំមានលក្ខណៈគ្រប់គ្រាន់នោះទេ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាតជាលាយលក្ខណ៍អក្សរចំពោះអ្នកសង្កេតការណ៍ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយចេញសេចក្តីសម្រេចបដិសេធឈ្មោះអ្នកសង្កេតការណ៍ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់នោះចោល ។

៩.៣.៥.៤ សេចក្តីសម្រេចអនុញ្ញាតលើឈ្មោះអ្នកសង្កេតការណ៍ជាតិ ត្រូវធ្វើជាបី (៣) ច្បាប់ ដើម្បី ៖

- រក្សាទុកនៅ គ.ជ.ប មួយ (១) ច្បាប់
- ផ្ញើទៅ គធ/ខប មួយ (១) ច្បាប់
- ជូនសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលមួយ (១) ច្បាប់ ។

៩.៣.៥.៥ បញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលត្រូវបានសម្រេចត្រូវបោះត្រាលើគ្រប់ទំព័ររួចផ្ញើបញ្ជីឈ្មោះនោះទៅ លធ/ខប ឬគធ/ខប ។

៩.៣.៦ មន្ត្រីនៃ លធ/ខប ឬ គធ/ខប ត្រូវផ្តល់បណ្ណសម្គាល់សម្រាប់អ្នកសង្កេតការណ៍ជាតិបំពេញការងារសង្កេតការណ៍បោះឆ្នោត នៅរាជធានី ខេត្តរបស់ខ្លួន ។ មន្ត្រីនៃ លធ/ខប ឬ គធ/ខប ត្រូវផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលតំណាងរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមី បង្ហាញជូនជាមួយនឹងបញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលផ្ញើជូនជាផ្លូវការដោយ គ.ជ.ប ។

៩.៣.៦.១ ក្រោយពីបានពិនិត្យឃើញថា ត្រឹមត្រូវហើយមន្ត្រីនៃ លធ/ខប ឬ គធ/ខប ត្រូវប្រគល់បណ្ណគ្រប់ចំនួនតាមឈ្មោះនៃអ្នកសង្កេតការណ៍ ដែលមាននៅក្នុងបញ្ជីឈ្មោះដើម្បីឱ្យតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល បំពេញ និងបិទរូបថត និងប្រាប់ទៅតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលបណ្ណសម្គាល់អ្នកសង្កេតការណ៍គ្រប់ចំនួនហើយនោះថា ឱ្យប្រញាប់បំពេញ និងបិទរូបថត ដើម្បីទទួលបានសុពលភាពជាផ្លូវការ ។

៩.៣.៦.២ បណ្ណសម្គាល់អ្នកសង្កេតការណ៍ ដែលអាចយកជាផ្លូវការបានក្នុងដំណើរការសង្កេតការណ៍បោះឆ្នោតលុះត្រាតែ ៖

- បណ្ណសម្គាល់ចេញដោយ គ.ជ.ប តាមរយៈ លធ/ខប ឬ គធ/ខប
- បណ្ណមានបិទរូបថត និងបំពេញត្រឹមត្រូវតាមខ្លឹមសារក្នុងបណ្ណសម្គាល់
- ត្រូវបានមន្ត្រីនៃ លធ/ខប ឬ គធ/ខប បោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថត ។

៩.៣.៧ ប្រធាន ឬតំណាងរបស់សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវចុះហត្ថលេខា លើការធានា និងការទទួលខុសត្រូវលើបញ្ជីអ្នកសង្កេតការណ៍របស់ខ្លួន ជាពិសេស គឺការទទួលខុសត្រូវចំពោះមុខច្បាប់ អំពីអត្តសញ្ញាណ របស់អ្នកសង្កេតការណ៍ម្នាក់ៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។

៩.៣.៨ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចស្នើសុំដាក់អ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសសម្រាប់ថ្នាក់ដឹកនាំរបស់ខ្លួនបានយ៉ាងច្រើនប្រាំ (៥) នាក់ ក្នុងករណីសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ មានអ្នកសង្កេតការណ៍របស់ខ្លួនចាប់ពីប្រាំ (៥) រាជធានី ខេត្តឡើងទៅ ។ បណ្ណចល័តទូទាំងប្រទេសមានគំរូ និងពណ៌ផ្សេងគ្នាពីបណ្ណអ្នកសង្កេតការណ៍ជាតិ ។ ការដាក់ពាក្យសុំអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេស មាននីតិវិធីដូចគ្នានឹងការដាក់ពាក្យសុំអ្នកសង្កេតការណ៍ជាតិដែរ ។ អ្នកសង្កេតការណ៍ចល័តទូទាំងប្រទេសមានសិទ្ធិ និងភារកិច្ចដូចមានចែងក្នុងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

៩.៣.៩ អង្គការដែលបង្កើតដោយរាជរដ្ឋាភិបាល មិនអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍បោះឆ្នោតឡើយ ។

៩.៣.១០ លធ/ខប ឬ គធ/ខប ត្រូវធ្វើរបាយការណ៍បូកសរុបចំនួនអ្នកសង្កេតការណ៍ជាតិតាមដំណាក់កាលនីមួយៗរួចផ្ញើមក គ.ជ.ប ។

**អ្នកសង្កេតការណ៍អន្តរជាតិ**

**ប្រការ ៩.៤** អ្នកសង្កេតការណ៍អន្តរជាតិនៅពេលអញ្ជើញចូលមកដល់ព្រះរាជាណាចក្រកម្ពុជា ត្រូវទៅបង្ហាញខ្លួននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីទទួលព័ត៌មានផ្សេងៗ ។

៩.៤.១ អ្នកសង្កេតការណ៍អន្តរជាតិដូចមានចែងក្នុងប្រការ ៩.២ ត្រូវដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍អន្តរជាតិទៅ គ.ជ.ប ក្នុងរយៈពេលចាប់តាំងពីថ្ងៃប្រកាសផ្សាយប្រតិទិនបោះឆ្នោតរហូតដល់បី (៣) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវផ្តល់ជូននូវគំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ និងបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិដោយឥតគិតថ្លៃ ដើម្បីបំពេញ និងបិទរូបថត ។

៩.៤.២ គ.ជ.ប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះ និងបណ្ណសម្គាល់ ដែលបានបំពេញហើយ និងចេញសេចក្តីសម្រេចអនុញ្ញាតយល់ព្រមឱ្យអ្នកសង្កេតការណ៍អន្តរជាតិ ក្នុងរយៈពេលយ៉ាងយូរពីរ (២) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំ ។

៩.៤.៣ ក្រោយពីពិនិត្យឃើញថា ពាក្យសុំចុះឈ្មោះពុំទាន់បានត្រឹមត្រូវ គ.ជ.ប ត្រូវណែនាំអ្នកសង្កេតការណ៍អន្តរជាតិនោះបំពេញកែតម្រូវឡើងវិញភ្លាមៗ ដើម្បី គ.ជ.ប ចេញសេចក្តីសម្រេចអនុញ្ញាត ។

៩.៤.៤ ក្នុងករណីពិនិត្យឃើញថា ពាក្យសុំចុះឈ្មោះមានលក្ខណៈគ្រប់គ្រាន់ហើយ គ.ជ.ប ត្រូវជូនបណ្ណអ្នកសង្កេតការណ៍អន្តរជាតិឱ្យសាមីខ្លួន ឬតំណាង ដើម្បីសរសេរបំពេញ បិទរូបថត និងចុះហត្ថលេខា សាមីខ្លួនរួចហើយ ត្រូវជូនបណ្ណនោះមក គ.ជ.ប វិញ ។

៩.៤.៥ បន្ទាប់ពីទទួលបណ្ណដែលបានបំពេញត្រឹមត្រូវហើយ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាត ចុះហត្ថលេខា និងបោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថតទៅនឹងបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិហើយ រួចជូនទៅអ្នកសង្កេតការណ៍នោះវិញដើម្បីពាក់បំពេញការងារ ។

៩.៤.៦ បណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិអនុញ្ញាតឱ្យអ្នកសង្កេតការណ៍អន្តរជាតិសង្កេតដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាល និងគ្រប់ទីកន្លែងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៩.៤.៧ អ្នកបកប្រែរបស់អ្នកសង្កេតការណ៍អន្តរជាតិ ត្រូវដាក់ពាក្យភ្ជាប់ឈ្មោះមកជាមួយអ្នកសង្កេតការណ៍អន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង ។ អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសង្កេតការណ៍ឡើយ ។

**គណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជន ហើយមានបំណងសង្កេតការណ៍បោះឆ្នោត**

**ប្រការ ៩.៥** គណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយ ហើយមានបំណងចូលរួមសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅឃុំ សង្កាត់នោះ គណបក្សនយោបាយនោះមានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះសមាជិករបស់ខ្លួន ជាប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកសង្កេតការណ៍ជាតិទៅ គ.ជ.ប ចាប់តាំងពីប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ រហូតដល់ដប់ (១០)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៩.៥.១ គ.ជ.ប ត្រូវផ្តល់ជូនគណបក្សនយោបាយ ដែលមានបំណងដូចក្នុងប្រការ ៩.៥ នូវគំរូនៃពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍បោះឆ្នោត ។

៩.៥.២ ពាក្យសុំចុះឈ្មោះរបស់គណបក្សនយោបាយដូចមានក្នុងប្រការ ៩.៥ ត្រូវធ្វើជាបី (៣) ច្បាប់ ដោយភ្ជាប់មកជាមួយនូវ ៖

៩.៥.២.១ លិខិតបញ្ជាក់ថា បានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ ។

៩.៥.២.២ បញ្ជីឈ្មោះអ្នកសង្កេតការណ៍ត្រូវរៀបចំតាមរាជធានី ខេត្ត និងឃុំ សង្កាត់ ដោយបញ្ជាក់នាមត្រកូល នាមខ្លួន អាសយដ្ឋាន និងភាពមានសិទ្ធិបោះឆ្នោតរបស់អ្នកសង្កេតការណ៍ម្នាក់ៗ ព្រមទាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលអ្នកសង្កេតការណ៍នោះត្រូវបំពេញការងារ ។

៩.៥.២.៣ សេចក្តីប្រកាសគោរព ច.ប.ឃ.ស ប.ន.ឃ.ស និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

៩.៥.៣ អ្នកសង្កេតការណ៍នៃគណបក្សនយោបាយ ត្រូវជាសមាជិកនៃគណបក្សនយោបាយនោះ និងត្រូវមានលក្ខណសម្បត្តិ សិទ្ធិ និងភារកិច្ចដូចអ្នកសង្កេតការណ៍ជាតិដែរ ។

៩.៥.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍របស់គណបក្សនយោបាយ ដូចក្នុងប្រការ ៩.៥ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ។

៩.៥.៤.១ ក្នុងករណី គ.ជ.ប ពិនិត្យបញ្ជីឈ្មោះដែលដាក់ស្នើសុំមកឃើញថា អ្នកសង្កេតការណ៍ណាម្នាក់ពុំមានលក្ខណៈគ្រប់គ្រាន់ គ.ជ.ប ត្រូវបដិសេធឈ្មោះរបស់ជននោះដោយត្រូវ រក្សាទុកឈ្មោះអ្នកសង្កេតការណ៍ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងគូសបន្ទាត់លុបលើឈ្មោះ ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់ និងចារ " បដិសេធ " នៅខាងចុងឈ្មោះត្រង់ខ្ទង់ផ្សេងៗ ។

៩.៥.៤.២ គណបក្សនយោបាយសាមីឬតំណាងមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍របស់ខ្លួនជាថ្មីមួយលើកទៀត ជំនួសឈ្មោះអ្នកសង្កេតការណ៍ ដែលបានបដិសេធក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងបដិសេធ ។

៩.៥.៤.៣ ក្នុងរយៈពេលកំណត់ខាងលើ គណបក្សនយោបាយសាមី ឬតំណាងមិនបានកែតម្រូវឈ្មោះអ្នកសង្កេតការណ៍ ដែលពុំបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់នោះទេ គ.ជ.ប ត្រូវចេញលិខិតបដិសេធឈ្មោះអ្នកសង្កេតការណ៍ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់នោះចោល និងសេចក្តីសម្រេចអនុញ្ញាតជាលាយលក្ខណ៍អក្សរចំពោះអ្នកសង្កេតការណ៍ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ។

៩.៥.៤.៤ សេចក្តីសម្រេចអនុញ្ញាតលើឈ្មោះអ្នកសង្កេតការណ៍ នៃគណបក្សនយោបាយត្រូវធ្វើជាបី (៣) ច្បាប់ ដើម្បី ៖

- រក្សាទុកនៅ គ.ជ.ប មួយ (១) ច្បាប់
- ផ្ញើទៅ គធ/ខប មួយ (១) ច្បាប់
- ជូនសាមីគណបក្ស មួយ (១) ច្បាប់

៩.៥.៤.៥ បញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលត្រូវបានអនុញ្ញាតត្រូវបោះត្រាលើគ្រប់ទំព័រ រួចផ្ញើទៅ លធ/ខប ឬ គធ/ខប ។

៩.៥.៥ ការផ្តល់បណ្ណសម្គាល់ដល់អ្នកសង្កេតការណ៍ នៃគណបក្សនយោបាយដែលដាក់ពាក្យសុំចុះឈ្មោះដូចក្នុងប្រការ ៩.៥ ត្រូវអនុវត្តដូចនីតិវិធីសម្រាប់ផ្តល់បណ្ណសម្គាល់អ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែរ ។

**អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ**

**ប្រការ** ៩.៦ សមាគមវិជ្ជាជីវៈអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកយកព័ត៌មានឯករាជ្យ ដែលមានបំណងចូលរួមយកព័ត៌មាន ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់ទៅ គ.ជ.ប ។

៩.៦.១ ផ្នែកព័ត៌មានសាធារណៈ នៃនាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ គឺជាសេនាធិការរបស់ គ.ជ.ប ក្នុងការងារគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកយកព័ត៌មានជាតិ អន្តរជាតិ និងអ្នកយកព័ត៌មានឯករាជ្យ ដែលចូលរួមក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

៩.៦.២ គ.ជ.ប ត្រូវផ្តល់ពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មាន ដល់សមាគមវិជ្ជាជីវៈសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកយកព័ត៌មានឯករាជ្យតាមការស្នើសុំដោយឥតគិតថ្លៃ ។

- រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មានជាតិ គឺចាប់តាំងពីថ្ងៃប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតរហូតដល់ដប់(១០)ថ្ងៃ មុនថ្ងៃបោះ ឆ្នោត ។
- រយៈពេលនៃការដាក់ពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មានអន្តរជាតិ គឺចាប់តាំងពីថ្ងៃប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោត រហូតដល់បី (៣) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៩.៦.៣ ពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មានជាតិ និងអន្តរជាតិត្រូវភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម ៖

៩.៦.៣.១ សម្រាប់អ្នកយកព័ត៌មានជាតិ ត្រូវភ្ជាប់មកជាមួយនូវ ៖

- លិខិតអនុញ្ញាតចេញដោយក្រសួងព័ត៌មាន
- លិខិតបញ្ជាក់ ឬលិខិតស្នើសុំធ្វើបណ្ណព័ត៌មាន គ.ជ.ប ពីសាមីអង្គភាព
- ច្បាប់ចម្លង នៃបណ្ណព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមវិជ្ជាជីវៈ ឬបណ្ណសំគាល់ខ្លួនជាអ្នកយកព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប ។

៩.៦.៣.២ សម្រាប់អ្នកយកព័ត៌មានអន្តរជាតិ ដែលមានការិយាល័យអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់មកជាមួយនូវ ៖

- លិខិតអនុញ្ញាតចេញដោយក្រសួងព័ត៌មាន
- លិខិតបញ្ជាក់ ឬលិខិតស្នើសុំធ្វើបណ្ណព័ត៌មាន គ.ជ.ប ពីសាមីអង្គភាព
- ច្បាប់ចម្លង នៃបណ្ណព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមវិជ្ជាជីវៈ ឬបណ្ណសំគាល់ខ្លួនជាអ្នកយកព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប
- ច្បាប់ចម្លងនៃលិខិតឆ្លងដែន (សំរាប់ជនបរទេស) ។

៩.៦.៣.៣ សម្រាប់អ្នកយកព័ត៌មានអន្តរជាតិ ដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវភ្ជាប់ជាមួយនូវ ៖

- ច្បាប់ចម្លង នៃលិខិតឆ្លងដែន
- បណ្ណសំគាល់ខ្លួនជាអ្នកយកព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប ។

៩.៦.៣.៤ សម្រាប់អ្នកយកព័ត៌មានឯករាជ្យ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងនៃបណ្ណព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមវិជ្ជាជីវៈអ្នកសារព័ត៌មាន
- ប្រវត្តិរូបសង្ខេប
- អត្ថបទចុងក្រោយ ដែលខ្លួនបានសរសេរចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់ក្នុងអំឡុងឆ្នាំចុងក្រោយចំនួនបី (៣) អត្ថបទ ។

៩.៦.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មានក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃយ៉ាងយូរ សម្រាប់អ្នកយកព័ត៌មានជាតិ ។ ក្នុងករណី គ.ជ.ប បដិសេធអ្នកយកព័ត៌មានជាតិ ដែលពុំមានលក្ខណៈគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីជនអ្នកយកព័ត៌មាន អាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំម្ដងលើកទៀត ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ ក្រោយទទួលលិខិតបដិសេធ ។

៩.៦.៥ គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះឈ្មោះ របស់អ្នកយកព័ត៌មានអន្តរជាតិក្នុងរយៈពេលពីរ (២) ថ្ងៃ យ៉ាងយូរ ។ ក្នុងករណី គ.ជ.ប បដិសេធអ្នកយកព័ត៌មានអន្តរជាតិ ដែលពុំមានលក្ខណៈគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីជនអ្នកយកព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំម្ដងលើកទៀតក្នុងរយៈពេលពីរ (២)ថ្ងៃ យ៉ាងយូរ ក្រោយទទួលបានលិខិតបដិសេធ ។

៩.៦.៦ គ.ជ.ប ត្រូវបោះពុម្ពបណ្ណសំគាល់អ្នកយកព័ត៌មានជាតិ និងបណ្ណសំគាល់អ្នកយកព័ត៌មានអន្តរជាតិ ដើម្បីផ្ដល់ជូនដោយឥតគិតថ្លៃដល់អ្នកយកព័ត៌មាន ដែលត្រូវបានអនុញ្ញាតឱ្យយកព័ត៌មានដោយ គ.ជ.ប ដើម្បីពាក់ក្នុងពេលបំពេញការងារ ។

៩.៦.៧ អ្នកយកព័ត៌មានត្រូវគោរពច្បាប់ស្ដីពីរបបសារព័ត៌មាន ច.ប.ឃ.ស ប.ន.ឃ.ស គ.ជ.ប ក្រមសីលធម៌ និងវិជ្ជាជីវៈអ្នកសារព័ត៌មាន ។

៩.៦.៨ អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ ដែលបានទទួលការអនុញ្ញាតដោយ គ.ជ.ប អាចយកព័ត៌មានក្នុងដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាលនៃការបោះឆ្នោត ដោយត្រូវគោរព ច.ប.ឃ.ស ប.ន.ឃ.ស និងគោរពក្រមសីលធម៌សំរាប់អ្នកយកព័ត៌មាន ។

៩.៦.៨.១ អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ មានសិទ្ធិថត និងយកព័ត៌មានពី ៖

- សកម្មភាពរបស់មហាជនចូលរួម ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។
- ការប្រព្រឹត្តទៅ និងសកម្មភាពរបស់ មន្ត្រីបោះឆ្នោតក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៦.៨.២ អ្នកយកព័ត៌មានជាតិ និងអន្តរជាតិមិនត្រូវ ៖

- ជ្រៀតជ្រែក ឬរំខានដល់ការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឬ/និងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ធ្វើសម្ភាសន៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។
- ធ្វើសម្ភាសន៍ជាមួយអ្នកបោះឆ្នោត ដែលកំពុងឋិតនៅក្នុងជួរចូលទៅក្នុងការិយាល័យបោះឆ្នោត ។
- ធ្វើឱ្យរំខានដល់ការងារក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោត និងប៉ះពាល់ដល់សិទ្ធិបុគ្គល ។

៩.៦.៨.៣ ការយកព័ត៌មាន ដោយរូបភាពក្នុងការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ត្រូវសុំការអនុញ្ញាតពីប្រធានការិយាល័យនោះ ។ ការថតរូបភាពនេះ មិនត្រូវឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោតឡើយ ។

៩.៦.៨.៤ អ្នកយកព័ត៌មាន មិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជនឬរដ្ឋ) ដើម្បីគាបសង្កត់លើសមាជិកក្រុមប្រឹក្សា ស្មៀនឃុំ សង្កាត់ ឬសមាជិក គឃ/សប ឬមន្ត្រីបោះឆ្នោត ឬសមាជិក គកប/គករ ឬអ្នកសង្កេតការណ៍ ឬបេក្ខជន ឬតំណាងគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោតឡើយ ។

# ជំពូកទី ១០
# ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត

**ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ ១០.១** អនុវត្តមាត្រា ៣១ថ្មី នៃ ច.ប.ឃ.ស គ.ជ.ប ត្រូវបោះពុម្ព និងចាត់ចែងឱ្យបិទផ្សាយនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត និងនៅទីស្នាក់ការ គឃ/សប យ៉ាងយូរពីរ (២) ថ្ងៃ មុនការចាប់ផ្តើមចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត រហូតដល់ពេលបិទការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

១០.១.១ គ.ជ.ប ត្រូវណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យចាត់ចែងបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ខាងលើបានទាន់ពេលវេលា ។ គ.ជ.ប ត្រូវធានាថា ៖

១០.១.១.១ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងឃុំសង្កាត់នីមួយៗត្រូវបានថតចម្លងឱ្យគ្រប់ចំនួនសម្រាប់ការបិទផ្សាយពីរ (២) លើក នៅការិយាល័យបោះឆ្នោតនីមួយៗមួយ (១) ច្បាប់ និងនៅទីស្នាក់ការ គឃ/សប មួយ (១) ច្បាប់ (លើកទីមួយ (១) ពីរ (២) ថ្ងៃ មុនថ្ងៃចាប់ផ្តើមចុះបញ្ជីបេក្ខជន និងលើកទីពីរ (២) មួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត) ព្រមទាំងរក្សាទុកជាឯកសារនៅ គឃ/សប មួយ (១) ច្បាប់ ។

១០.១.១.២ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងឃុំសង្កាត់ទាំងអស់ ចំណុះរាជធានី ខេត្តនីមួយៗ ត្រូវបានថតចម្លងលើក្រដាស ឬក្នុង ស៊ីឌីផ្ញើជូន គធ/ខប ពាក់ព័ន្ធ ដើម្បីរក្សាទុកជាឯកសារ និងបម្រើសាធារណជន ។

១០.១.២ នាយកដ្ឋានប្រតិបត្តិការត្រូវផ្តល់បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ជូននាយកដ្ឋានរដ្ឋបាលមួយ (១) ច្បាប់ ដើម្បីសហការគ្នាធ្វើជាសេនាធិការជូន គ.ជ.ប ក្នុងការកំណត់ចំនួន ដើម្បីជ្រើសរើសសមាសភាព គកប/គករ ។

**សមាសភាពនៃ គកប/គករ**

**ប្រការ** ១០.២ គឃ/សប ត្រូវចាត់ចែងស្របតាម ច.ប.ឃ.ស និង ប.ន.ឃ.ស ក្នុងការជ្រើសតាំង គកប ដែលមានសមាសភាពប្រាំមួយ (៦) រូប គឺ ប្រធានមួយ (១) រូប អនុប្រធានមួយ (១) រូប លេខាធិការមួយ (១) រូប ជំនួយការពីរ (២) រូបនិងសមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់មួយ (១) រូប លើកលែងតែមានសេចក្ដីសម្រេចផ្សេងពីនេះរបស់ គ.ជ.ប ។

១០.២.១ ការជ្រើសរើស គកប/គករ ត្រូវអនុវត្តតាមប្រការ ២.១៩ និង ២.២០ ជំពូកទី ៣ នៃ ប.ន.ឃ.ស ។

១០.២.២ សមាសភាព គកប/គករ ដែល គឃ/សប បានជ្រើសរើស ត្រូវបានតែងតាំងដោយ គ.ជ.ប តាមសំណើរបស់ គឃ/ខប ។

**ការទទួលខុសត្រូវ និងភារកិច្ចរបស់ គកប/គករ**

**ប្រការ** ១០.៣ គកប/គករ នីមួយៗ មានភារកិច្ចចាត់ចែងគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតដែល គកប/គករ នោះត្រូវទទួលខុស ។

១០.៣.១ ប្រធាន គកប/គករ មានភារកិច្ចចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ដែលខ្លួនទទួលខុសត្រូវ និងត្រូវ ៖

១០.៣.១.១ ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.១.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ឃ.ស ប.ន.ឃ.ស និងការណែនាំរបស់ គ.ជ.ប ។

១០.៣.១.៣ ទទួលពិនិត្យ ផ្ទៀងផ្ទាត់ និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារៈឯកសារ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

១០.៣.១.៤ បោះទីតាំង រៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងបំពាក់គ្រឿងសង្ហារិម ។

១០.៣.១.៥ តាមដាន និងត្រួតពិនិត្យការបំពេញការងាររបស់ សមាសភាព គកប/គករ នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងអាណត្តិរបស់ខ្លួន ។

១០.៣.១.៦ ដាក់ជំនួសតំណែងសមាជិក គកប/គករ ណាដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា ដោយយោងទៅតាមចំណុច ១០.៩.៨ នៃជំពូកនេះ ។

១០.៣.១.៧ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ។ ក្នុងពេលកំពុងដំណើរការបោះឆ្នោត យ៉ាងយូរមួយ (១) ម៉ោងម្តង ត្រូវចូលក្នុងបន្ទប់សម្ងាត់ ដើម្បីត្រួតពិនិត្យសុវត្ថិភាពសម្ភារៈដែលបំពាក់នៅទីនោះ និងសណ្តាប់ធ្នាប់ ក្នុងករណីគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់ ។

១០.៣.១.៨ ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបានបំពេញ និងចុះហត្ថលេខាត្រឹមត្រូវ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី ។

១០.៣.១.៩ ត្រួតពិនិត្យលិខិតតែងតាំង និងទទួលស្គាល់ភ្នាក់ងារនៃគណបក្សនយោបាយ និងលិខិតតែងតាំង និងទទួលស្គាល់អ្នកសង្កេតការណ៍ដែលត្រូវចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

១០.៣.១.១០ អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផ្លាស់ប្តូរទីកន្លែងអង្គុយពិនិត្យមើលដំណើរការបោះឆ្នោត ។

១០.៣.១.១១ ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោត ដល់អ្នកដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ។

១០.៣.១.១២ បើក និងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ។

១០.៣.១.១៣ ធានារបៀបរៀបរយក្នុង និងក្រៅបរិវេណការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.១.១៤ ចាក់ ឬកាត់ផ្តាច់សោឃ្លុំការពារហិបឆ្នោត ។

១០.៣.១.១៥ ធានាឱ្យប្រាកដថា អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានបង្រៀនឱ្យចេះពីរបៀបបោះឆ្នោត និងតាមដានពិនិត្យមើល ដើម្បីឱ្យប្រាកដថា នៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបានបត់សន្លឹកឆ្នោតតាមផ្នត់ដើម ដូចការណែនាំ ។

១០.៣.១.១៦ ធានាឱ្យប្រាកដថា ការប្រើប្រាស់ទឹកខ្មៅលុបលាងមិនជ្រះត្រូវតែបានអនុវត្តតាមការណែនាំ ។

១០.៣.១.១៧ ធានាឱ្យប្រាកដថា ការលើកយោបល់ជំទាស់ និងការប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ក្នុងការិយាល័យបោះឆ្នោត ដោយភ្នាក់ងារគណបក្សនយោបាយ ត្រូវបានដោះស្រាយភ្លាម ដោយអនុវត្តស្របតាម ប.ន.ឃ.ស និងការណែនាំរបស់ គ.ជ.ប ។

១០.៣.១.១៨ ជួយអ្នកបោះឆ្នោតជាជនពិការដែលមិនអាចបោះឆ្នោតបាន ដោយខ្លួនឯង ហើយដែលគ្មានអ្នកជំនួយមកជាមួយ ដោយយោងតាម ចំណុច ១០.៦.១៨ នៃជំពូកនេះ ។

១០.៣.១.១៩ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត ។

១០.៣.១.២០ ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្សនយោបាយដែលបានទទួលសំឡេងឆ្នោត ។

១០.៣.១.២១ ប្រគល់ជូន គឃ/សប នូវកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតផ្សេងទៀត ។

១០.៣.១.២២ ប្រគល់ជូន គឃ/សប នូវកំណត់ហេតុស្ដីពីការបោះឆ្នោត និងហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតផ្សេងទៀត ក្នុងករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្នដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតបាន ។

១០.៣.១.២៣ បំពេញភារកិច្ចរបស់ខ្លួនក្នុងជំហរអព្យាក្រឹត និងមិនលម្អៀង ។

១០.៣.១.២៤ បំពេញភារកិច្ចផ្សេងៗទៀតដែល គឃ/សប តម្រូវឱ្យធ្វើ ។

១០.៣.២ អនុប្រធាន គកប/គករ ត្រូវជួយប្រធាន និងមានភារកិច្ចដោយឡែកដូចខាងក្រោម ៖

១០.៣.២.១ ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.២.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ឃ.ស ប.ន.ឃ.ស និងការណែនាំរបស់ គ.ជ.ប ។

១០.៣.២.៣ ជំនួសតំណែងប្រធាន ក្នុងករណី ដូចចែងក្នុងចំណុច ១០.៤.៨.៣ ។

១០.៣.២.៤ រាប់ចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្ដែង សម្រាប់ប្រើក្នុងការិយាល័យបោះឆ្នោត ។

១០.៣.២.៥ ហែកសន្លឹកឆ្នោតផ្ដាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បោះត្រាសម្ងាត់លើផ្នែកខាងខ្នង និងបត់ជាបួន (៤) ផ្ដត់តាមការណែនាំរបស់ គ.ជ.ប រួចប្រគល់ជូនអ្នកបោះឆ្នោត ។

១០.៣.២.៦ ផ្ដល់ការណែនាំ ស្ដីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត ។

១០.៣.២.៧ អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់ នៅពេលដែលបន្ទប់សម្ងាត់នោះទំនេរ គ្មានអ្នកបោះឆ្នោតផ្សេងទៀត ។

១០.៣.២.៨ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត នៅពេលបញ្ចប់ការបោះឆ្នោត ។

១០.៣.២.៩ ត្រួតពិនិត្យ និងបែងចែកប្រភេទសន្លឹកឆ្នោតបានការ ឬមិនបានការមុននឹងប្រគល់ជូនប្រធាន ។

១០.៣.២.១០ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗ បានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

១០.៣.២.១១ អមដំណើរប្រធាន ក្នុងការបញ្ជូន និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោតផ្សេងទៀត ជូន គឃ/សប ។

១០.៣.២.១២ បំពេញភារកិច្ចផ្សេងទៀត ដែល គឃ/សប និងប្រធាន គកប/គករ តម្រូវឱ្យធ្វើ ។

១០.៣.៣ លេខាធិការនៃ គកប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងជាអ្នកទទួលបន្ទុកការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងការបំពេញ ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ហើយត្រូវ ៖

១០.៣.៣.១ ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.៣.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ឃ.ស ប.ន.ឃ.ស និងការណែនាំរបស់ គ.ជ.ប ។

១០.៣.៣.៣ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.៣.៤ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

១០.៣.៣.៥ ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបលាងមិនជ្រះ នៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត នៅមុនពេលពិនិត្យឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត ។

១០.៣.៣.៦ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពដូចគ្នារវាងឈ្មោះ និងទិន្នន័យក្នុងឯកសារបញ្ជាក់អត្តសញ្ញាណសាមីអ្នកបោះឆ្នោត ជាមួយនឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត រួចគូសសម្គាល់ថាបានបោះឆ្នោតរួចហើយ ក្នុងប្រអប់បួនជ្រុងតូចទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះលើបញ្ជីបោះឆ្នោត ។

១០.៣.៣.៧ រាប់គំនូសសញ្ញាលើបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងមិនបានបោះឆ្នោត ។

១០.៣.៣.៨ បំពេញកំណត់ហេតុនៃការបោះឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា រួចដាក់បង្ហាញឱ្យភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើល ។

១០.៣.៣.៩ កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកឡើងយោបល់តវ៉ា ឬជំទាស់ ឬករណីប្តឹងតវ៉ា និងប្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.៣.១០ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

១០.៣.៣.១១ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា រួចដាក់បង្ហាញភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើល ។

១០.៣.៣.១២ បំពេញក្រដាសលទ្ធផលបណ្តោះអាសន្ន នៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០៤) ។

១០.៣.៣.១៣ បំពេញភារកិច្ចផ្សេងទៀតដែល គឃ/សប និងប្រធាន គកប/គករ តម្រូវឱ្យធ្វើ ។

១០.៣.៤ ជំនួយការទី១ នៃ គកប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

១០.៣.៤.១ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.៤.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារៈ ឯកសារបោះឆ្នោត ។

១០.៣.៤.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

១០.៣.៤.៤ ត្រួតពិនិត្យហិបឆ្នោត និងការស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតក្នុងពេលកំពុងដំណើរការបោះឆ្នោត ។

១០.៣.៤.៥ រាយការណ៍ជូនប្រធាន ក្នុងករណីពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បានស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀត ចូលក្នុងហិបឆ្នោត ។

១០.៣.៤.៦ ជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោត ដែលបានបោះឆ្នោតរួចហើយម្នាក់ម្តងៗ ទៅក្នុងទឹកខ្មៅលុបលាងមិនជ្រះ ឱ្យដល់គល់ក្រចក និងណែនាំគាត់ឱ្យរង់ចាំបន្តិច ដើម្បីឱ្យទឹកខ្មៅស្ងួត មុននឹងចេញពីការិយាល័យបោះឆ្នោត ។

១០.៣.៤.៧ រាប់ចំនួនសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីផ្ទៀងផ្ទាត់ទៅនឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងដកយកវត្ថុមិនមែនជាសន្លឹកឆ្នោតដាក់ទៅក្នុងស្រោមសំបុត្រដោយឡែក ។

១០.៣.៤.៨ លាសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីត្រួតពិនិត្យស្នាមត្រាសម្ងាត់នៅផ្នែកខាងខ្នង និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់ ។

១០.៣.៤.៩ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួល នៅលើផ្ទាំងក្រដាសធំ ។

១០.៣.៤.១០ បំពេញភារកិច្ចផ្សេងទៀតដែល គឃ/សប និងប្រធាន គកប/គករ តម្រូវឱ្យធ្វើ ។

១០.៣.៥ ជំនួយការទី២ នៃ គកប/គករ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

១០.៣.៥.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការ នៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.៥.២ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

១០.៣.៥.៣ ជួយរកឈ្មោះអ្នកបោះឆ្នោត នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅខាងក្រៅការិយាល័យបោះឆ្នោត និងប្រាប់លេខរៀងឈ្មោះរបស់គាត់ ។

១០.៣.៥.៤ ចាត់ចែង និងថែរក្សារបៀបរៀបរយជូនអ្នកបោះឆ្នោត (ក្នុងករណីចាំបាច់ អាចផ្តល់ប័ណ្ណលេខរៀងតាមលំដាប់អ្នកមកមុន មកក្រោយ) ព្រមទាំងរាយការណ៍ជូនប្រធាន អំពីការរំខាន ឬការអុកឡុកនានាក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត (ប្រសិនបើមាន) ។

១០.៣.៥.៥ រាយការណ៍ជូនប្រធាន ក្នុងករណីពិនិត្យឃើញថា មានអ្នកបោះឆ្នោតណាម្នាក់បានយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

១០.៣.៥.៦ ប្រមូលឯកសារបញ្ជាក់អត្តសញ្ញាណពីអ្នកបោះឆ្នោត ដែលស្ថិតក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅពេលដល់ម៉ោងបញ្ចប់ការបោះឆ្នោត (ម៉ោងដប់ប្រាំ(១៥:០០) រសៀល) (ប្រសិនបើមាន)។

១០.៣.៥.៧ ចោះសន្លឹកឆ្នោត ដែលនៅសល់មិនបានប្រើប្រាស់ បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ។

១០.៣.៥.៨ សហការជាមួយសមាជិកទទួលសណ្តាប់ធ្នាប់ ក្នុងការការពារមាត់ទ្វារការិយាល័យបោះឆ្នោត ការថែរក្សាសម្ភារៈ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

១០.៣.៥.៩ បិទផ្សាយកំណត់ហេតុនៃការបោះឆ្នោត ។

១០.៣.៥.១០ បំពេញភារកិច្ចផ្សេងទៀតដែល គឃ/សប និងប្រធាន គកប/គករ តម្រូវឱ្យធ្វើ ។

១០.៣.៦ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់នៃ គកប/គករ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

១០.៣.៦.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការ នៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១០.៣.៦.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារៈ ឯកសារបោះឆ្នោត ។

១០.៣.៦.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

១០.៣.៦.៤ ត្រួតពិនិត្យច្រកទ្វារចូលនៃការិយាល័យបោះឆ្នោត ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តកន្ទុយគ្នា តាមលំដាប់មុនក្រោយ ប្រសិនបើគាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ និងត្រួតពិនិត្យឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ ។

១០.៣.៦.៥ ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត ចំពោះអ្នកបោះឆ្នោតជាព្រះសង្ឃ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ជនពិការ និងអ្នកមានជំងឺ បន្ទាប់មកគឺអ្នកឈរខាងមុខគេក្នុងជួរ ។

១០.៣.៦.៦ ត្រួតពិនិត្យស្នាមទឹកខ្មៅលុបលាងមិនជ្រះនៅ លើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត ។

១០.៣.៦.៧ ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការអុកឡុករំខានជូនប្រធាន ។

១០.៣.៦.៨ សហការជាមួយជំនួយការទី២ ក្នុងការការពារសន្តិសុខនៅច្រកផ្លូវចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារៈ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

១០.៣.៦.៩ បំពេញភារកិច្ចផ្សេងទៀតដែល គឃ/សប និងប្រធាន គកប/គករ តម្រូវឱ្យធ្វើ ។

**ការត្រៀមសម្ភារៈ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត**

**ប្រការ** ១០.៤ គ.ជ.ប ត្រូវធានាថា រាល់សម្ភារៈ ឯកសារបោះឆ្នោត ត្រូវតែបានបញ្ជូន និងប្រគល់ជូន គកប មិនឱ្យលើសពីសាមសិបប្រាំមួយ(៣៦)ម៉ោងមុនថ្ងៃបោះឆ្នោត ។ នៅពេលព្រឹកនៃថ្ងៃមុនថ្ងៃបោះឆ្នោត ប្រធាន គកប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គកប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោតដើម្បីធ្វើការត្រួតពិនិត្យសម្ភារៈ ឯកសារបោះឆ្នោតនិងរៀបចំគំរូប្លង់ការិយាល័យបោះឆ្នោត ។

១០.៤.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារៈ ឯកសារគ្រប់គ្រាន់ សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតជូន គធ/ខប គឃ/សប និង គកប ទាំងអស់ ។

១០.៤.២ នាយកដ្ឋានប្រតិបត្តិការ ត្រូវទទួលខុសត្រូវក្នុងការផលិត និងបញ្ជូនបញ្ជីបោះឆ្នោតផ្លូវការចំនួនបួន (៤) ច្បាប់ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ ដែលត្រូវបែងចែកជូន គឃ/សប ក្រុមប្រឹក្សាឃុំ សង្កាត់ និង គកប សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ នាយកដ្ឋានអាចផលិតស៊ីឌីផ្ទុកបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ ចំណុះរាជធានី ខេត្តនីមួយៗ សម្រាប់ផ្តល់ជូន គធ/ខប ពាក់ព័ន្ធ ។

១០.៤.៣ នាយកដ្ឋានប្រតិបត្តិការត្រូវរៀបចំផែនការ និងត្រៀមសម្ភារៈ ឯកសារសម្រាប់ដឹកជញ្ជូនទៅកាន់គោលដៅនានាដើម្បីបម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឱ្យបានគ្រប់គ្រាន់ជាមុន ។ សម្ភារៈ ឯកសារសម្រាប់បម្រើការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតត្រូវបានរៀបចំដាក់ក្នុងហិប ដែលរួមមាន ៤ប្រភេទ គឺ ៖

១០.៤.៣.១ ហិបបរិក្ខារសម្រាប់បណ្តុះបណ្តាលដែលត្រូវបញ្ជូន និងប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ និង គធ/ខប ។

១០.៨.៣.២ ហិបបរិក្ខារ គធ/ឃប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គធ/ឃប ។

១០.៨.៣.៣ ហិបបរិក្ខារ គឃ/សប ដែលអាចមានមួយ ឬ ច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គឃ/សប ។

១០.៨.៣.៤ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវបញ្ជូន និងប្រគល់ជូន គកប/គករ ។

១០.៨.៤ នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ ទទួលហិបបរិក្ខារ ដូចបានចែងក្រោមចំណុច ១០.៨.៣ ខាងលើ មន្ត្រីដែលទទួលបន្ទុកការបញ្ជូននៅតាមថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត(ទ. ១១០៧) និងត្រូវឱ្យមន្ត្រីដែលទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗ ចុះហត្ថលេខាបញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ ។

១០.៨.៥ ហិបបរិក្ខារ គធ/ឃប ដែលត្រូវបញ្ជូន និងប្រគល់ជូន គធ/ឃប សម្រាប់ប្រើប្រាស់ក្នុងដំណើរការបោះឆ្នោត ដូចមានក្នុងឧបសម្ព័ន្ធទី ៨ ។

១០.៨.៦ ហិបបរិក្ខារ គឃ/សប ដែលត្រូវបញ្ជូន និងប្រគល់ជូន គឃ/សប សម្រាប់ប្រើប្រាស់ក្នុងដំណើរការបោះឆ្នោតទាំងមូល ដូចមានក្នុងឧបសម្ព័ន្ធទី ៩ ។

១០.៨.៧ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារៈ ឧបករណ៍ និងឯកសារផ្សេងទៀត ដូចមានក្នុងឧបសម្ព័ន្ធទី ១០ ដែល គឃ/សប ត្រូវបញ្ជូន និងប្រគល់ជូន គកប នីមួយៗ មិនឱ្យលើសពីសាមសិបប្រាំមួយ (៣៦) ម៉ោង មុនថ្ងៃបោះឆ្នោត ។

១០.៨.៨ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវធានាក្នុងការបញ្ជូន និងប្រគល់ឱ្យបានគ្រប់គ្រាន់ជូន គកប/គករ នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោតនូវសម្ភារៈ ឯកសារបោះឆ្នោតដូចចែងក្នុងចំណុច ១០.៨.៧ ខាងលើ ។ គឃ/សប ត្រូវជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីចូលរួមសង្កេតមើល គកប/គករ នៅពេលធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារៈ ឯកសារបោះឆ្នោត ដូចចែងក្នុងចំណុច ១០.៨.១០ ។

១០.៤.៩ សមាសភាពទាំងអស់នៃគកប/គករ ត្រូវតែមកបង្ហាញខ្លួនតាមការកោះអញ្ជើញរបស់ប្រធាន គកប/គករ និងត្រូវធានាថា នឹងមានវត្តមានក្នុងការបំពេញការងារនៅថ្ងៃបោះឆ្នោត ។

១០.៤.៩.១ ប្រសិនបើសមាសភាពណាម្នាក់នៃ គកប/គករ មិនអាចមកបំពេញការងារក្នុងថ្ងៃបោះឆ្នោត ប្រធានត្រូវតែជូនដំណឹងដល់ គឃ/សប ជាបន្ទាន់ ដើម្បីដាក់អ្នកជំនួស ។

១០.៤.៩.២ ប្រសិនបើ គឃ/សប មិនអាចត្រូវបានជូនដំណឹងអំពីការដាក់អ្នកជំនួសទាន់ពេលវេលាដោយសារតែចម្ងាយផ្លូវ ឬដោយសារតែកង្វះខាតនៃមធ្យោបាយធ្វើដំណើរ គកប ត្រូវជ្រើសរើសមនុស្សដែលមានលក្ខណសម្បត្តិសមស្របតាមការកំណត់ក្នុងមាត្រា ១១ថ្មី នៃ ច.ប.ឃ.ស ឱ្យមកធ្វើការជំនួសតំណែងក្នុង គកប/គករ ដែលអវត្តមាន ។

១០.៤.៩.៣ ប្រសិនបើប្រធាន មិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ហើយជំនួយការទី១ចូលកាន់តំណែងអនុប្រធាន ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មីចេញពីក្នុងចំណោមប្រជាពលរដ្ឋ ត្រូវចូលកាន់តំណែងជំនួសជំនួយការទី១ ។

១០.៤.៩.៤ ប្រសិនបើអនុប្រធាន មិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងជំនួយការទី១ជាអនុប្រធាន ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងកាន់តំណែងជាជំនួយការទី១ ។

១០.៤.៩.៥ ប្រសិនបើលេខាធិការ មិនអាចមកធ្វើការបាន ត្រូវតែងតាំងជំនួយការទី១ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងកាន់តំណែងជាជំនួយការទី១ ។

១០.៤.៩.៦ សមាសភាពទាំងអស់នៃ គកប/គករ រួមទាំងអ្នកដែលទើបតែជ្រើសរើសថ្មី ត្រូវរួមគ្នាសិក្សាឡើងវិញ នូវសៀវភៅណែនាំ គកប/គករ និងនីតិវិធីនៃការបោះឆ្នោត ។

១០.៤.៩.៧ អ្នកតែងតាំងថ្មីទាំងអស់ត្រូវតែបានទទួលការបណ្តុះបណ្តាល ដូចចែងក្នុងចំណុច ១០.៤.៩.៦ ខាងលើ ។

១០.៤.៩.៨ ប្រធាន គកប/គករ ត្រូវតែជូនដំណឹងជាបន្ទាន់ដល់ គឃ/សប អំពីអ្វីដែលបានអនុវត្ត ពាក់ព័ន្ធនឹងការដាក់ជំនួសតំណែងណាមួយនៃ គកប/គករ ។

១០.៩.១០ បន្ទាប់ពីអនុវត្តចំណុច ១០.៩.៩ រួច គកប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារៈ ឯកសារបោះឆ្នោតទាំងអស់ ដែល គកប បានទទួល ហើយដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត(ទ. ១១០៧) ។

១០.៩.១០.១ គកប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារៈ ឯកសារបោះឆ្នោត ដោយប្រើតារាងត្រួតពិនិត្យសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១១២) ។

១០.៩.១០.២ ប្រសិនបើ សម្ភារៈ ឯកសារបោះឆ្នោតដែលបានទទួលមានចំនួនគ្រប់គ្រាន់ហើយ សមាសភាពទាំងអស់នៃ គកប ត្រូវចុះហត្ថលេខាលើតារាងត្រួតពិនិត្យសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១១២) ។

១០.៩.១០.៣ ប្រសិនបើសម្ភារៈ ឯកសារបោះឆ្នោតណាមួយ ឬច្រើនដែលបានទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារៈ ឯកសារបោះឆ្នោតដែលបាត់បង់ នៅលើតារាងត្រួតពិនិត្យសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១១២) ហើយត្រូវផ្ញើតារាងត្រួតពិនិត្យនេះ មួយ (១) ច្បាប់ ជាបន្ទាន់ទៅ គឃ/សប ។

១០.៩.១០.៤ ប្រសិនបើ សម្ភារៈដែលបាត់បង់ទៅនោះ ជាសម្ភារៈសំខាន់សម្រាប់ការបោះឆ្នោត ប្រធាន គកប ត្រូវចាត់សមាជិកពីរ(២)រូប ឱ្យធ្វើដំណើរទៅទីស្នាក់ការ គឃ/សប ដើម្បីទទួលសម្ភារៈថ្មីជំនួសសម្ភារៈដែលខ្វះបានបាត់បង់ទៅ លើកលែងតែមានវិទ្យុទាក់ទង ដែលអាចបញ្ជូនព័ត៌មានស្នើសុំ គឃ/សប ដោះស្រាយបញ្ហាខាងលើបាន ។

១០.៩.១០.៥ ក្នុងការត្រួតពិនិត្យឡើងវិញ នូវសម្ភារៈ ឯកសារបោះឆ្នោតខាងលើនេះ គកប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារៈដូចខាងក្រោម ៖

ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ ហើយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលបានកត់ត្រា នៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតជាដាច់ខាត។

ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថា ពិតជាមានត្រាសម្ងាត់នៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រ ជាដាច់ខាត ។

១០.៩.១១ សម្ភារៈសំខាន់ៗដែល គកប មិនបានទទួល ហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន ៖

១០.៩.១១.១ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។

១០.៩.១១.២ ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

១០.៩.១១.៣ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

១០.៩.១១.៤ ហិបឆ្នោត និងសោឃ្លុំមានលេខ ។

១០.៩.១១.៥ ទឹកខ្មៅលុបលាងមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃ ។

១០.៩.១២ សម្ភារៈដទៃទៀត ដែលប្រសិនបើមិនបានផ្តល់ដោយ គឃ/សប នោះ គកប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ៖

១០.៩.១២.១ កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើបិទបាំងជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

១០.៩.១២.២ ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុជាគំរូ ។

១០.៩.១២.៣ ប៊ិចសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង... ។

១០.៩.១៣ នៅពេលដែលសម្ភារៈ ឯកសារបោះឆ្នោតមានគ្រប់ចំនួនគ្រប់គ្រាន់ហើយ ប្រធាន គកប ត្រូវចាត់ជំនួយការទី២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការមួយ (១) ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត ។

១០.៩.១៤ បន្ទាប់ពីបានអនុវត្តចំណុច ១០.៩.១៣ រួច គកប ត្រូវរៀបចំគំរូប្លង់ការិយាល័យបោះឆ្នោត ដើម្បីឱ្យប្រាកដថា ទីតាំងការិយាល័យបោះឆ្នោតនោះ អាចដំណើរការបោះឆ្នោតបានហើយដែលអាចរៀបចំឱ្យរួចស្រេចនៅម៉ោងប្រាំមួយ(៦)ព្រឹក នៃថ្ងៃបោះឆ្នោត ។

១០.៩.១៤.១ គកប ត្រូវគូរគំរូប្លង់ការិយាល័យបោះឆ្នោត ឯកភាពគ្នាមួយនៅលើទំព័រទំនេរនៅចុងបញ្ចប់នៃសៀវភៅណែនាំ គកប ដោយត្រូវគោរពតាមគោលការណ៍ ដូចបានចែងក្នុងសៀវភៅណែនាំនោះ ។

១០.៩.១៤.២ ប្រសិនបើ គ្មានគ្រឿងសង្ហារឹមនៅក្នុងការិយាល័យបោះឆ្នោតទេ ប្រធាន ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់នូវគ្រឿងសង្ហារឹមចាំបាច់មួយចំនួនសម្រាប់បម្រើការបោះឆ្នោតដូចជា តុ កៅអី និងសម្ភារៈដទៃទៀត ដែលអាចសម្រួលដល់ការងារបោះឆ្នោត ។

១០.៤.១៤.៣ ប្រធានត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខយាមកាម រក្សាសន្តិសុខទីតាំងការិយាល័យបោះឆ្នោត ហើយប្រសិនបើអាចធ្វើបាន ប្រធានត្រូវបិទទ្វារចាក់សោទីតាំងការិយាល័យបោះឆ្នោតនោះផង ។

១០.៤.១៥ ប្រធានរួមជាមួយសមាជិក គកប ត្រូវរក្សាការពារសម្ភារៈ ឯកសារទាំងនោះ ឱ្យបានហ្មត់ចត់នៅមុនពេលបោះឆ្នោត ។

១០.៤.១៥.១ សម្ភារៈ ឯកសារបោះឆ្នោតអាចនឹងរក្សាទុកនៅផ្ទះរបស់ប្រធាន ឬសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គកប ឯកភាពគ្នាថាមានសុវត្ថិភាព ។

១០.៤.១៥.២ យ៉ាងហោចណាស់ត្រូវមានសមាជិក គកប បី (៣) នាក់ គិតទាំងប្រធានផងសម្រាកនៅផ្ទះ ឬទីតាំងដែលទទួលរក្សាសម្ភារៈ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព ។

១០.៤.១៥.៣ ប្រធាន គកប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលទទួលរក្សាទុកសម្ភារៈ ឯកសារបោះឆ្នោត ។

១០.៤.១៦ ប្រធាន គកប ត្រូវណាត់ជាមួយសមាជិក ដទៃទៀតនៃ គកប ឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលទទួលរក្សាទុកសម្ភារៈ ឯកសារបោះឆ្នោត នៅម៉ោងប្រាំកន្លះ (៥:៣០)ព្រឹក នៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីដឹកជញ្ជូនសម្ភារៈ ឯកសារបោះឆ្នោតទៅកាន់ទីតាំងការិយាល័យបោះឆ្នោត ។

១០.៤.១៧ សមាជិកទាំងអស់នៃ គកប ត្រូវត្រៀមអាហារសម្រាប់រយៈពេល មួយ (១) ថ្ងៃ សម្រាប់ហូបនៅពេលទំនេរ ដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប ។

**ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ ១០.៥** ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាលនិងសន្តិសុខ ដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ដូចចែងក្រោមប្រការ ៥.៥ ក្នុងជំពូកទី៥ នៃបទបញ្ជា និងនីតិវិធីនេះ ។ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

១០.៥.១ ប្រធាន គកប ឬប្រធាន គករ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារសម្ភារៈ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ ។

១០.៥.២ ចំពោះក្របខណ្ឌនៃការិយាល័យបោះឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយដែលបានចែងក្នុងប្រការ ៥.៦ និងក្រោមចំណុច ៥.៦.១ ៥.៦.២ ៥.៦.៣ ៥.៦.៥ ៥.៦.៧ និង ៥.៦.៨ ក្នុងជំពូកទី ៥ នៃ ប.ន.ឃ.ស នេះ ត្រូវតែបានអនុវត្ត ។

១០.៥.៣ ចំពោះក្របខណ្ឌនៃការិយាល័យរាប់សន្លឹកឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយដែលបានចែងក្នុងប្រការ ៥.៦ និងក្រោមចំណុច ៥.៦.១ ៥.៦.២ ៥.៦.៤ ៥.៦.៦ ៥.៦.៧ និង ៥.៦.៨ ក្នុងជំពូកទី ៥ នៃ ប.ន.ឃ.ស នេះ ត្រូវតែបានអនុវត្ត ។

## ការប្រព្រឹត្តទៅនៃការបោះឆ្នោត

**ប្រការ** ១០.៦ គកប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត ដោយនាំមកជាមួយនូវសម្ភារៈ ឯកសារបោះឆ្នោតឱ្យបានទាន់ពេលនៅម៉ោងប្រាំមួយ (៦) ព្រឹក នាថ្ងៃបោះឆ្នោតជាកំហិត ដើម្បីគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត ។

១០.៦.១ បន្ទាប់ពី គកប បានចូលដល់ក្នុងការិយាល័យភ្លាម ប្រធាន គកប ត្រូវប្រកាសឱ្យភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យស្លាកសម្គាល់ ឬ/និងសេចក្តីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ រួចប្រាប់ទីកន្លែង ដែលបម្រុងទុកសម្រាប់ពួកគេ ដូចចែងក្នុងចំណុច ១០.៦.២.៥ ខាងក្រោម ។

១០.៦.២ ទន្ទឹមពេលអនុវត្តចំណុច ១០.៦.១ ខាងលើ ប្រធាន គកប ត្រូវចាត់ជំនួយការ ទី២ ឱ្យទៅបំពេញមុខនាទីរបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ព្រមទាំងត្រូវចាត់ចែងសមាជិកដទៃទៀតនៃ គកប ឱ្យរៀបចំគ្រឿងសង្ហារិម និងដាក់សម្ភារៈ ឯកសារសម្រាប់ការបោះឆ្នោតដូចបានកំណត់ឯកភាពគ្នា លើគំរូប្លង់ការិយាល័យបោះឆ្នោត ដែលបានរៀបចំមុនមួយថ្ងៃ និងដូចបានបញ្ជាក់នៅក្នុងសៀវភៅណែនាំ គកប ។

១០.៦.២.១ តុមួយដាក់នៅប៉ែកខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូល សម្រាប់ប្រធាន ដែលនៅលើនោះមានសម្ភារៈ ឯកសារបោះឆ្នោត និងទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹង ។

១០.៦.២.២ តុវែងមួយ ឬ តុតូចពីរដាក់នៅប៉ែកខាងស្តាំដៃ បន្ទាប់ពីផ្លូវចូល សម្រាប់លេខាធិការ និងអនុប្រធានអង្គុយជាប់គ្នា ដែលនៅចំកន្លែងលេខាធិការ មានដាក់បញ្ជីបោះឆ្នោត ទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត និងទម្រង់បែបបទផ្សេងទៀត ហើយនៅចំកន្លែងអនុប្រធានមានដាក់កញ្ចប់សន្លឹកឆ្នោត ត្រាំប៉ុង និងស្រោមសំបុត្រដាក់ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

១០.៦.២.៣ បន្ទប់សម្ងាត់សម្រាប់បិទបាំងការគូសសន្លឹកឆ្នោតចំនួនពីរ (២) ដែលមានបិចចងខ្សែភ្ជាប់ស្រាប់ ដាក់នៅលើតុពីរក្បែរជញ្ជាំងប្រមាណមួយទៅមួយម៉ែត្រកន្លះពីជញ្ជាំង និងមានចម្ងាយពីគ្នាយ៉ាងតិចមួយ (១) ម៉ែត្រ ប៉ុន្តែមិនត្រូវដាក់នៅក្បែរបង្អួចទេ ។ ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោតមួយ (១) សន្លឹកត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់នីមួយៗបន្ទប់សម្ងាត់ ត្រូវមានពន្លឺគ្រប់គ្រាន់ ។

១០.៦.២.៤ ហិបឆ្នោត ទឹកខ្មៅលុបលាងមិនជ្រះ និងកំណាត់សម្រាប់ជូតដាក់នៅលើតុវែងមួយ ដែលស្ថិតនៅត្រង់កណ្តាលបន្ទប់ទល់មុខនឹងតុរបស់ប្រធាន ។

១០.៦.២.៥ តុ និងកៅអីសម្រាប់ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ (ប្រសិនបើមាន) ដាក់នៅអែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន និងនៅក្រោយតុអនុប្រធាន និងលេខាធិការ ។

១០.៦.២.៦ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលមានសម្ភារៈ ឯកសារមិនទាន់ត្រូវប្រើប្រាស់រក្សាទុកនៅក្បែរតុប្រធាន ។

១០.៦.៣ ពេលអនុវត្តចំណុច ១០.៦.១ រួចរាល់ ប្រធានត្រូវពន្យល់ណែនាំជារួម ដល់ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ដែលពួកគេត្រូវធ្វើដូចខាងក្រោម ៖

១០.៦.៣.១ ត្រូវគោរព ច.ប.ឃ.ស ប.ន.ឃ.ស ក្រមសីលធម៌សម្រាប់ភ្នាក់ងារនៃគណបក្សនយោបាយ ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ និងក្រមសីលធម៌សម្រាប់អ្នកយកព័ត៌មាន ដែលកំណត់ដោយ គ.ជ.ប ។

១០.៦.៣.២ ត្រូវតាមដានជាប្រចាំកិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោតបង្ការក្រែងមានករណីមិនប្រក្រតីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

១០.៦.៣.៣ ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

១០.៦.៣.៤ ត្រូវលើកសំណួរ សំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន ។

១០.៦.៣.៥ មិនត្រូវណែនាំអ្វីដល់សមាសភាព គកប/គករ ។

១០.៦.៣.៦ មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត ។

១០.៦.៣.៧ មិនត្រូវធ្វើអ្វីឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។

១០.៦.៤ នៅចន្លោះពីម៉ោងប្រាំមួយ(៦)ដល់ម៉ោងប្រាំមួយកន្លះ (៦:៣០) ព្រឹក នៃថ្ងៃបោះឆ្នោត គកប ត្រូវត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតជូនអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតតាមនីតិវិធីដូចខាងក្រោម ៖

១០.៦.៤.១ ប្រធានត្រូវពិនិត្យឡើងវិញនូវហិបឆ្នោត ដើម្បីឱ្យប្រាកដថាត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ ។

១០.៦.៤.២ ប្រធានត្រូវបើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោត រួចបង្ហាញហិបឆ្នោតទទេ ចំពោះអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវបិទគម្របក្នុងនៃហិបឆ្នោតទៅវិញ មួលភ្ជិតគម្របសន្ទះបិទប្រឡោះសម្រាប់បោះឆ្នោត ហើយខ្ទាស់គន្លឹះគម្របក្នុងរួចចាក់សោឃ្លុំ និងប្រាប់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

១០.៦.៤.៣ ប្រធានត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោត ដោយប៊ិចហ្វឺតលើក្រដាសពីរ (២) សន្លឹក និងបោះត្រា រួចបិទភ្ជាប់ទៅនឹងជញ្ជាំងមុខ ក្រោយនៃហិបឆ្នោត ហើយបន្ទាប់មកអនុញ្ញាតឱ្យភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

១០.៦.៤.៤ លេខាធិការត្រូវកត់ត្រាពេលម៉ោង នៃការពិនិត្យហិបឆ្នោតនៅលើកំណត់ហេតុនៃការបោះឆ្នោត ។

១០.៦.៥ ហិបឆ្នោតដែលបានបិទសម្គាល់លេខកូដ និងចាក់សោឃ្លុំរួចហើយ ដូចចែងក្នុងចំណុច ១០.៦.៤ ខាងលើ គកប ត្រូវធានាដូចខាងក្រោម ៖

១០.៦.៥.១ មិនអនុញ្ញាតឱ្យបើកចំហដាច់ខាត លើកលែងតែក្នុងបំណងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់ពីការបោះឆ្នោតបានបញ្ចប់ ។

១០.៦.៥.២ មិនអនុញ្ញាតឱ្យយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែ គ.ជ.ប សម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ។

១០.៦.៦ ប្រសិនបើ សម្ភារៈ ឯកសារបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោត ត្រូវបានប្រគល់ទទួលនៅក្រោយម៉ោងប្រាំមួយកន្លះ (៦:៣០) ប៉ុន្តែមិនហួសពីម៉ោងប្រាំពីរ (៧:០០) ព្រឹក ប្រធាន គកប ត្រូវព្យួរការអនុវត្តនីតិវិធី បន្ទាប់នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះជាបណ្ដោះអាសន្នសិន រហូតទាល់តែបទបញ្ជា និងនីតិវិធីដូចចែងក្រោមចំណុច ១០.៦.៤ ខាងលើ ត្រូវបានបំពេញចប់សព្វគ្រប់ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាអំពីពេល ម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោតនីមួយៗទៅក្នុងកំណត់ហេតុនៃការបោះឆ្នោតឱ្យ បានច្បាស់លាស់ ។

១០.៦.៧ នៅចន្លោះពីម៉ោងប្រាំមួយកន្លះ (៦:៣០) ដល់ម៉ោងប្រាំពីរ (៧:០០) ព្រឹក នៃថ្ងៃបោះឆ្នោត គកប ត្រូវត្រួតពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោត ដែលទទួលជាក់ស្ដែង ព្រមទាំងត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់ផ្លូវការសម្រាប់ ការិយាល័យបោះឆ្នោតនោះ ចំពោះភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ។

១០.៦.៧.១ អនុប្រធានត្រូវបើកកញ្ចប់សន្លឹកឆ្នោតរួចត្រួតពិនិត្យមើល ដើម្បីឱ្យប្រាកដថា សន្លឹកឆ្នោតនេះ ជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះប្រាកដមែន ។ ក្នុងករណីពិនិត្យឃើញថា សន្លឹកឆ្នោតនេះមិនមែនជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងឃុំ សង្កាត់ ពាក់ព័ន្ធទេ គកប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ គឃ/សប និង គធ/ខប ជូន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ ។

១០.៦.៧.២ បន្ទាប់មក អនុប្រធានត្រូវរាប់សន្លឹកឆ្នោត ដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោត ដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី ៥០ ដល់ ៩៩សន្លឹក ។

១០.៦.៧.៣ លេខាធិការត្រូវកត់ត្រាចំនួនសន្លឹកឆ្នោត ដែលបានរាប់ឃើញជាក់ស្ដែង ព្រមទាំងលេខរៀងដើមដំបូងបង្អស់ និងលេខរៀងចុងបញ្ចប់នៅលើគល់បញ្ជីសន្លឹកឆ្នោត ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្តែងមានចំនួនលើស ឬខ្វះ ធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ឱ្យក្តី ក៏លេខាធិការត្រូវកត់ត្រាចំនួនលើស ឬខ្វះនោះ ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោតដែរ ។

១០.៦.៧.៤ លេខាធិការត្រូវពិនិត្យចំនួនអ្នកបោះឆ្នោត ដែលមាននៅក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

១០.៦.៧.៥ ប្រធានត្រូវបើកស្រោមសំបុត្រ ដែលមានត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រួចដកយកត្រានោះមកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស និងលើកបង្ហាញអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ ឱ្យបានឃើញច្បាស់ និងចំណាំបានរូបសញ្ញានៃត្រានោះ ។

១០.៦.៨ ប្រធាន គកប ត្រូវប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួននៅម៉ោងប្រាំពីរ (៧:០០) ព្រឹក នៃថ្ងៃបោះឆ្នោត និងអញ្ជើញសមាសភាព គកប ឱ្យបោះឆ្នោតមុនគេបង្អស់ រួចបន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន ប្រសិនបើអ្នកទាំងនេះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។ ផ្អែកតាមករណីដូចចែងក្នុងចំណុច ១០.៦.៦ ខាងលើ ប្រសិនបើមាន ប្រធាន គកប អាចប្រកាសបើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោងប្រាំពីរ (៧:០០) ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោងប្រាំបី (៨:០០) ព្រឹកឡើយ ។

១០.៦.៩ បន្ទាប់ពីបានបោះឆ្នោតរួចហើយ ជំនួយការ ទី២ ត្រូវបន្តចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោត នៅបរិវេណខាងក្នុង ដោយជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ប្រាប់លេខរៀងឈ្មោះរបស់គាត់ ចេញក្រដាសលេខរៀងតាមលំដាប់មុនក្រោយ និងណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តកន្ទុយគ្នាជាជួរ ។

១០.៦.១០ បន្ទាប់ពី ប្រធាន គកប ប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ដែលប្រចាំការនៅត្រង់មាត់ទ្វារ ត្រូវជម្រាបអ្នកបោះឆ្នោត ដែលកំពុងឈរជាជួរបន្តកន្ទុយគ្នាតម្រង់ទៅកាន់មាត់ទ្វារចូលការិយាល័យបោះឆ្នោត អំពីអាទិភាពក្នុងការចូលបោះឆ្នោតតាមលំដាប់លំដោយគឺ ព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ អ្នកមានជំងឺ ជនពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយអមដំណើរជនពិការនោះ ព្រមទាំងអ្នកឈរក្នុងជួរខាងមុខគេ ។សមាជិកទទួលសណ្តាប់ធ្នាប់អាចសួររំលឹកអ្នកបោះឆ្នោតថា បាន

ស្នើឱ្យជំនួយការទី២ជួយរកឈ្មោះ និងឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះហើយឬនៅ ។ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលក្នុងការិយាល័យបោះឆ្នោតមួយលើកចំនួនបួន (៤) នាក់ ដែលត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

១០.៦.១០.១ ត្រូវបង្ហាញដល់សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ នូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយរបស់ខ្លួនដូចបានកំណត់ដោយ ច.ប.ឃ.ស និង ប.ន.ឃ.ស ដែលអ្នកបោះឆ្នោតត្រូវប្រើប្រាស់សម្រាប់បោះឆ្នោត រួមជាមួយប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (ប្រសិនបើមាន) ។ ឯកសារបញ្ជាក់អត្តសញ្ញាណអាចជាអត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសៀវភៅគ្រួសារមានបិទរូបថតសាមីខ្លួនអ្នកបោះឆ្នោត ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ឬប័ណ្ណសម្គាល់ខ្លួនចេញដោយក្រសួងស្ថាប័នរដ្ឋ ឬឆាយាគណៈមហានិកាយ ឬសុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ ឬសង្ឃដីកា ឬលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត មានបិទរូបថតអ្នកបោះឆ្នោត ។

១០.៦.១០.២ យល់ព្រមឱ្យសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ពិនិត្យមើលម្រាមដៃរបស់ខ្លួន ដែលពិតជាពុំមានស្នាមទឹកខ្មៅលុបលាងមិនជ្រះមែន ។

១០.៦.១១ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ត្រូវជម្រាបអ្នកបោះឆ្នោត ដែលខ្លួនអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត ឱ្យដើរតម្រង់ទៅរកតុដែលលេខាធិការ និងអនុប្រធានកំពុងអង្គុយ ។ អ្នកបោះឆ្នោត ត្រូវបង្ហាញលេខាធិការនូវឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន រួមទាំងប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (ប្រសិនបើមាន) ។ ពេលនោះលេខាធិការត្រូវ ៖

១០.៦.១១.១ ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថាគ្មានស្នាមទឹកខ្មៅលុបលាងមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ ។

១០.៦.១១.២ មើលលេខរៀងនៅលើប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (ប្រសិនបើមាន) រួចប្រគល់ប័ណ្ណព័ត៌មានជូនអ្នកបោះឆ្នោតវិញ បន្ទាប់មកពិនិត្យផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ ជាមួយនឹងរូបពិតឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត ។

១០.៦.១១.៣ ដាក់បន្ទាត់តម្រង់តាមបណ្ដោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាមួយបញ្ជាក់ការមកបោះឆ្នោតរបស់អ្នកបោះឆ្នោត ក្នុងកូនប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ រួចហុចឯកសារបញ្ជាក់អត្តសញ្ញាណ របស់គាត់បន្តទៅឱ្យអនុប្រធាន ប្រសិនបើឈ្មោះ និងទិន្នន័យក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត ដូចគ្នានឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ។

១០.៦.១១.៤ ប្រាប់អ្នកបោះឆ្នោតឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន ។

១០.៦.១២ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ១០.៦.១១.១ លេខាធិការបានរកឃើញថាមានស្នាមប្រឡាក់ទឹកខ្មៅលុបលាងមិនជ្រះជាប់នៅនឹងម្រាមដៃអ្នកបោះឆ្នោត ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គកប និងរាយការណ៍អំពីករណីនេះជូនប្រធាន ។

១០.៦.១២.១ ប្រធានត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយត្រូវឱ្យអ្នកបោះឆ្នោតរូបនេះ ពន្យល់អំពីស្នាមទឹកខ្មៅលុបលាងមិនជ្រះ ដែលមានជាប់នឹងម្រាមដៃរបស់គាត់ ។

១០.៦.១២.២ ប្រសិនបើ អ្នកបោះឆ្នោតនោះមិនអាចផ្តល់ការពន្យល់របស់ខ្លួនបានសមហេតុផលអំពីបញ្ហាទឹកខ្មៅនេះទេ នោះគាត់នឹងត្រូវបានសន្និដ្ឋានថាមានបំណងបោះឆ្នោតលើសពីមួយដង ដែលត្រូវមានទោសតាមច្បាប់ ។

១០.៦.១២.៣ ប្រធាន ត្រូវដកហូតឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ជាបណ្ដោះអាសន្ន ហើយបញ្ជូនទៅ គឃ/សឃ ដើម្បីចាត់វិធានការបន្ត ។

១០.៦.១២.៤ លេខាធិការត្រូវកត់ត្រាទុកអំពីហេតុការណ៍នេះ នៅក្នុងកំណត់ហេតុនៃការបោះឆ្នោត និងត្រូវស្រង់ឈ្មោះ និងទិន្នន័យពីឯកសារបញ្ជាក់អត្តសញ្ញាណរបស់ជននោះ សម្រាប់ជាការតាមដានបន្ថែមទៀត ។

១០.៦.១២.៥ ប្រសិនបើ អ្នកបោះឆ្នោតនោះមិនយល់ព្រមតាមការអនុវត្តនីតិវិធីខាងលើប្រធាន គកប ឬ គឃ/សឃ ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

១០.៦.១៣ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ១០.៦.១១.២ លេខាធិការមិនឃើញមានឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតទេ ត្រូវជូនអ្នកបោះឆ្នោតនោះ ទៅជួបប្រធាន គកប និងរាយការណ៍អំពីករណីនេះជូនប្រធាន ។

១០.៦.១៣.១ ប្រធានត្រូវប្រាប់អ្នកបោះឆ្នោតនោះថា គាត់មិនអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះបានទេ ព្រោះទោះបីគាត់មានឯកសារបញ្ជាក់អត្តសញ្ញាណក្តី ប៉ុន្តែគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

១០.៦.១៣.២ ប្រសិនបើជាករណីច្រឡំការិយាល័យបោះឆ្នោត ប្រធានអាចសួររកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតរបស់គាត់ដើម្បីផ្ទៀងផ្ទាត់ និងត្រូវណែនាំគាត់អំពីទីតាំងការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលឈ្មោះរបស់គាត់មានក្នុងបញ្ជីបោះឆ្នោត ។

១០.៦.១៣.៣ ប្រធានត្រូវប្រាប់គាត់ឱ្យចេញពីការិយាល័យបោះឆ្នោត ។

១០.៦.១៤ បន្ទាប់ពីអនុវត្តនីតិវិធី ដូចចែងក្រោមចំណុច ១០.៦.១១ រួច អនុប្រធានត្រូវហែកសន្លឹកឆ្នោតមួយ (១) សន្លឹកចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង និងបត់ជាបួន (៤) ផ្នត់ តាមការកំណត់របស់ គ.ជ.ប ហើយប្រគល់ជូនអ្នកបោះឆ្នោត រួមជាមួយឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ផង ។ អនុប្រធានមិនត្រូវប្រគល់សន្លឹកឆ្នោត និងអនុញ្ញាតឱ្យអ្នកបោះឆ្នោតបន្ទាប់ចូលក្នុងបន្ទប់សម្ងាត់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញផុតពីបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោតនៅឡើយ ។ នៅពេលប្រគល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតរួចហើយ អនុប្រធានត្រូវណែនាំជាសង្ខេប ចំពោះអ្នកបោះឆ្នោតដូចខាងក្រោម ៖

១០.៦.១៤.១ នេះគឺជាសន្លឹកឆ្នោត ។

១០.៦.១៤.២ អ្នកត្រូវដើរទៅកាន់បន្ទប់សម្ងាត់ ហើយជាមួយនឹងប៊ិចដែលមាននៅទីនោះស្រាប់ អ្នកត្រូវគូសសញ្ញាគាំទ្រនៅក្នុងប្រឡោះបួនជ្រុងទ្រវែងនៃគណបក្សនយោបាយដែលអ្នកពេញចិត្ត ។ អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់មុននឹងគូសសញ្ញា ដើម្បីបង្ការការខូចសន្លឹកឆ្នោតដោយសារការផ្លាស់ប្តូរចិត្ត បន្ទាប់ពីបានគូសសញ្ញារួច ។

១០.៦.១៤.៣ មុននឹងចេញពីបន្ទប់សម្ងាត់ អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម ដើម្បីឱ្យសញ្ញា ដែលអ្នកបានគូសបត់ចូលក្នុងផ្នត់ មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ ។

១០.៦.១៥ ក្រោយពេលទទួលបានសន្លឹកឆ្នោត អ្នកបោះឆ្នោតមិនត្រូវសួរអ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យបង្ហាញពីគណបក្សនយោបាយជាក់លាក់ណាមួយនៅលើសន្លឹកឆ្នោត ឬ/និងមិនត្រូវធ្វើសកម្មភាពណាមួយ ដែលរំលោភទៅលើការសម្ងាត់នៃការបោះឆ្នោតឡើយ ។

១០.៦.១៥.១ អ្នកបោះឆ្នោតមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យដឹងអំពីគណបក្សនយោបាយជាក់លាក់ណាមួយដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ ។

១០.៦.១៥.២ អ្នកបោះឆ្នោតទូទៅ ទោះបីមិនចេះអក្សរក៏ដោយ ក៏មិនអាចស្នើសុំជំនួយពីជនណាម្នាក់ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ឱ្យជួយគាត់ក្នុងការបោះឆ្នោតឡើយ លើកលែងតែអ្នកបោះឆ្នោតជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ដូចចែងក្នុងចំណុច ១០.៦.១៨ ខាងក្រោម ។

១០.៦.១៥.៣ ភ្នាក់ងារនៃគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលនៅក្នុងការិយាល័យបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតទេ ទោះបីអ្នកបោះឆ្នោតនោះស្នើសុំឱ្យជួយក៏ដោយ។

១០.៦.១៥.៤ ហាមអ្នកបោះឆ្នោត និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប្រើទូរស័ព្ទដៃ ឬ/និងម៉ាស៊ីនថត ឬ/និងឧបករណ៍ផ្សេងទៀត ដែលអាចថតរូបបាន ឬ/និងធ្វើសកម្មភាពរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត លើកលែងតែអ្នកយកព័ត៌មានដែលទទួលស្គាល់ដោយ គ.ជ.ប និងបានការអនុញ្ញាតពីប្រធាន គកប ។

១០.៦.១៦ បន្ទាប់ពីទទួលបានសន្លឹកឆ្នោត និងអនុវត្តតាមការណែនាំរបស់អនុប្រធាន ដូចចែងក្នុងចំណុច ១០.៦.១៤.២ និង ១០.៦.១៤.៣ ខាងលើរួច អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោត ។

១០.៦.១៦.១ អ្នកបោះឆ្នោតត្រូវបង្ហាញសន្លឹកឆ្នោតរបស់ខ្លួន ដែលបានបត់រួចនោះដោយដាក់បែរផ្នែក ដែលមានបោះត្រាសម្ងាត់ទៅរកជំនួយការទី១ ហើយស៊កវាដោយខ្លួនឯង តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត (លើកលែងតែអ្នកបោះឆ្នោតជាជនពិការ ដែលមិនអាចស៊កដោយខ្លួនឯងបាន) ។

១០.៦.១៦.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោត ដែលបត់រួចបំរុងនឹងស៊កទៅក្នុងហិបឆ្នោត ជំនួយការទី១ ត្រូវពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការតែមួយសន្លឹក ដែលមានបោះត្រាសម្ងាត់ជាផ្លូវការសម្រាប់ការិយាល័យនោះ ។ ប្រសិនបើពិនិត្យឃើញថាអ្នកបោះឆ្នោតណាម្នាក់បានស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេង

ទៀត ចូលទៅក្នុងហិបឆ្នោត ត្រូវរាយការណ៍ជាបន្ទាន់ ទៅប្រធាន គកប ។ ក្នុងករណីនេះ ប្រធាន គកប ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការដែកឆេររកសន្លឹកឆ្នោតផ្លូវការ ។

១០.៦.១៦.៣ បន្ទាប់មក អ្នកបោះឆ្នោតត្រូវយល់ព្រមឱ្យជំនួយការទី១ ជ្រលក់ឱ្យលិចដល់គល់ក្រចកនៃម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀត ប្រសិនបើម្រាមចង្អុលដៃស្តាំពិការ ចូលទៅក្នុងដបទឹកខ្មៅលុបលាងមិនជ្រះ ដូចដែលបានកំណត់ក្រោមចំណុច ១០.៦.១៧ ខាងក្រោម ។

១០.៦.១៦.៤ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់ ដែលត្រូវបានជំនួយការទី១ ចាប់ភស្តុតាងបានថា មានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពីមួយ (១) សន្លឹក ទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោស ដោយផ្អែកតាម ច.ប.ឃ.ស ។

១០.៦.១៦.៥ ប្រធាន គកប ត្រូវឃាត់អ្នកបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ១០.៦.១៦.៤ ខាងលើមិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវទាំងនោះ និងដែកឆេររកសន្លឹកឆ្នោតផ្លូវការ (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រមានកាខ្វងថា " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " បន្ទាប់មកត្រូវដកហូតឯកសារបញ្ជាក់អត្តសញ្ញាណរបស់ជននោះ ជាបណ្តោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្តឹងចោទប្រកាន់ជនល្មើសទៅ គឃ/សប ។

១០.៦.១៦.៦ ប្រសិនបើ ជនដែលបានប្រព្រឹត្តល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយបើមានភស្តុតាងគ្រប់គ្រាន់នោះ គឃ/សប ត្រូវបន្តប្តឹងទៅ គធ/ខប និង គ.ជ.ប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

១០.៦.១៧ ទឹកខ្មៅលុបលាងមិនជ្រះដែលអាចមើលឃើញច្បាស់ ត្រូវបានដាក់បញ្ញត្តិឱ្យប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សម្រាប់បង្ការការបោះឆ្នោតលើសពីមួយ (១) ដង ។

១០.៦.១៧.១ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានផ្គត់ផ្គង់ទឹកខ្មៅលុបលាងមិនជ្រះចំនួនពីរ (២) ដប ។

១០.៦.១៧.២ ដបទឹកខ្មៅលុបលាងមិនជ្រះមួយ(១)ដប ត្រូវបានបើកគម្របប្រើនៅពេលបើកការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងបម្រុងទុកមួយ (១) ដបសម្រាប់ប្រើនៅពេលអស់ទឹកខ្មៅដបទីមួយ ។

១០.៦.១៧.៣ បន្ទាប់ពីអ្នកបោះឆ្នោតបានស៊កសន្លឹកឆ្នោតរបស់ខ្លួន ទៅក្នុងហិបឆ្នោត និងនៅមុនពេលគាត់ដើរចេញពីការិយាល័យបោះឆ្នោត គាត់ត្រូវយល់ព្រមឱ្យជំនួយការទី១ ជ្រលក់ម្រាមចង្អុលដៃស្តាំរបស់គាត់ឱ្យលិចគល់ក្រចកទៅក្នុងដបទឹកខ្មៅលុបលាងមិនជ្រះ និងរង់ចាំរហូតដល់ស្ងួតស្រួលបួលក្នុងរយៈពេលកន្លះនាទីទើបចេញពីការិយាល័យបោះឆ្នោត ។

១០.៦.១៧.៤ ក្នុងករណី ម្រាមចង្អុលដៃស្តាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ៖ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ។ ប្រសិនបើ គាត់មិនអាចធ្វើបានតាមការកំណត់ខាងលើរាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាបានការ ។

១០.៦.១៧.៥ រៀងរាល់សាមសិប (៣០) នាទីម្តង ដបទឹកខ្មៅលុបលាងមិនជ្រះត្រូវតែបានបិទគម្របយ៉ាងជិតហើយក្រឡុក ។

១០.៦.១៧.៦ ប្រសិនបើគ្មានអ្នកបោះឆ្នោតមួយរយៈពេលយូរគួរសម ជំនួយការទី១ត្រូវបិទគម្របដបទឹកខ្មៅ ដើម្បីការពារកុំឱ្យវាហួត ។

១០.៦.១៨ គ្មានជនណាម្នាក់នៅក្នុងការិយាល័យបោះឆ្នោត អាចជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានឡើយ លើកលែងតែ អ្នកបោះឆ្នោតនោះជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយបានស្នើសុំអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពី ប្រធាន គកប ដូចចែងក្នុងមាត្រា ១២៦ថ្មី នៃ ច.ប.ឃ.ស ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

១០.៦.១៨.១ បន្ទាប់ពីបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនពិការមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយជានីតិជនម្នាក់ ដែលអមដំណើរជាមួយដើម្បីជួយគាត់ក្នុងការបោះឆ្នោតត្រូវអនុវត្តជាបន្តបន្ទាប់តាមចំណុច ១០.៦.១១ ១០.៦.១៤ និង ១០.៦.១៦ ខាងលើ ។

១០.៦.១៨.២ បន្ទាប់ពីបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនពិការមិនអាចបោះឆ្នោតបានដោយខ្លួនឯង ដែលមានបំណងស្នើសុំជំនួយ

ពីប្រធាន គកប ត្រូវទៅជួបប្រធានដោយផ្ទាល់ ។ បន្ទាប់មក ប្រធាន ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនពិការនោះ អនុវត្តជាបន្តបន្ទាប់តាមចំណុច ១០.៦.១១ ១០.៦.១៤ និង ១០.៦.១៦ ខាងលើ ។ ក្នុងករណីនេះ ប្រធានអាចចាត់សមាជិក គកប ណាម្នាក់ឱ្យជួយក៏បានប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួន ។

១០.៦.១៨.៣ អ្នកបោះឆ្នោតជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ត្រូវសួរនាំ ឬប្រាប់អំពីគណបក្សនយោបាយដែលខ្លួនពេញចិត្តទៅប្រធាន គកប ឬអ្នកជំនួយ ដែលខ្លួនជ្រើសរើសតែនៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតប៉ុណ្ណោះ ។

១០.៦.១៨.៤ នៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ប្រធាន ឬសមាជិក គកប ឬអ្នកជំនួយដែលជួយអ្នកបោះឆ្នោតជាជនពិការក្នុងការបោះឆ្នោត ត្រូវសួរអ្នកបោះឆ្នោតជាជនពិការនោះថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ដោយសួរតិចៗធ្វើយ៉ាងណាកុំឱ្យមនុស្សដែលនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ ។ បន្ទាប់មក ប្រធាន ឬសមាជិក គកប ឬអ្នកជំនួយត្រូវគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ដែលឆ្លើយតបនឹងការជ្រើសរើសរបស់អ្នកបោះឆ្នោតពិការហើយ បត់សន្លឹកឆ្នោតនោះតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅក្នុងផ្នត់រួចត្រូវនាំអ្នកបោះឆ្នោតពិការទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។

១០.៦.១៨.៥ ប្រធាន ឬសមាជិក គកប ឬអ្នកជំនួយដែលបានជួយអ្នកបោះឆ្នោតជាជនពិការ ដូចលក្ខខណ្ឌក្រោមចំណុច ១០.៦.១៨ ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់ ។

១០.៦.១៩ ក្នុងអំឡុងពេលនៃការបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ប្រសិនបើ ក្នុងការិយាល័យបោះឆ្នោតគ្មានអ្នកបោះឆ្នោតទេនោះ ជំនួយការទី១ ត្រូវមូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតជាបណ្តោះអាសន្ន ហើយត្រូវបើកឡើងវិញ នៅពេលមានវត្តមានអ្នកបោះឆ្នោត ។

១០.៦.២០ គ្មានជនណាម្នាក់ ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត អាចពិនិត្យមើលការគូសសញ្ញាលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតឡើយ លើកលែងតែអ្នកដែលជួយអ្នកបោះឆ្នោតជាជនពិការដូចចែងក្នុងចំណុច ១០.៦.១៨ ខាងលើ ។

១០.៦.២០.១ ជនណាក៏ដោយដូចចែងក្នុងចំណុច ១០.៦.២០ ខាងលើដែលប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោត របស់អ្នកបោះឆ្នោត ជននោះនឹងត្រូវទទួលការព្រមានពីប្រធាន គកប ។ ការប៉ុនប៉ងជាលើកទីពីរ ដើម្បីធ្វើឱ្យបែកខ្ញរខ្ញាយនូវគោលការណ៍សម្ងាត់នៃការបោះឆ្នោតនឹងត្រូវចាត់ទុកថា ជាការរំលោភទៅលើច្បាប់ ហើយជនដែលមានការពាក់ព័ន្ធ ត្រូវតែបានបណ្តេញចេញពីការិយាល័យបោះឆ្នោតនិងត្រូវទទួលទោសតាម ច.ប.ឃ.ស ។

១០.៦.២០.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះ ក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត ។

១០.៦.២០.៣ ប្រសិនបើ ជនប្រព្រឹត្តល្មើសគោលការណ៍សម្ងាត់នៃការបោះឆ្នោតដូចចែងក្នុងចំណុច ១០.៦.២០.១ ខាងលើជាបេក្ខជនឈរឈ្មោះបោះឆ្នោត ប្រធាន គកប ត្រូវបញ្ជូនកំណត់ហេតុស្តីពីហេតុការណ៍នោះទៅ គឃ/សប ។

១០.៦.២០.៤ ពេលបានទទួលកំណត់ហេតុដូចចែងក្នុងចំណុច ១០.៦.២០.៣ ខាងលើភ្លាម គឃ/សប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនោះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែនត្រូវតែប្តឹងទៅ គជ/ខប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

១០.៦.២១ អ្នកបោះឆ្នោតណាម្នាក់ ដែលបានធ្វើឱ្យខូច ឬហែកសន្លឹកឆ្នោតដោយអចេតនា ឬដែលបានគូសសញ្ញានៅលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ គាត់អាចសុំសន្លឹកឆ្នោតមួយ (១) សន្លឹកផ្សេងទៀតពីប្រធាន គកប ។

១០.៦.២១.១ អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោតមួយ (១) សន្លឹកផ្សេងទៀតត្រូវបត់សន្លឹកឆ្នោតខូចតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចប្រគល់ជូនប្រធាន គកប ។

១០.៦.២១.២ ប្រធានត្រូវស៊កសន្លឹកឆ្នោតដែលខូចនោះទៅក្នុងស្រោមសំបុត្រមួយដែលមានសរសេរបញ្ជាក់នៅខាងក្រៅថា “ សន្លឹកឆ្នោតខូច ” ។

១០.៦.២១.៣ លេខាធិការដែលបានគូសសញ្ញាសម្គាល់ម្តងហើយ ក្នុងប្រអប់នៅប៉ែកខាងដើមទន្ទឹមនឹងឈ្មោះគាត់ក្នុងបញ្ជីបោះឆ្នោត ដូចចែងក្នុងចំណុច ១០.៦.១១.៣ ខាងលើ មិនចាំបាច់គូសសញ្ញាសម្គាល់ជាលើកទីពីរឡើយ ប៉ុន្តែត្រូវកត់ចំណាំទុក សម្រាប់សរសេរចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

១០.៦.២១.៤ ប្រធាន ត្រូវអនុញ្ញាតឱ្យអនុប្រធានផ្តល់សន្លឹកឆ្នោតមួយ(១)សន្លឹក ផ្សេងទៀតចំពោះអ្នកបោះឆ្នោតដែលចែងក្នុងចំណុច ១០.៦.២១ តែមួយលើកគត់ និងត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

១០.៦.២១.៥ ក្នុងករណីមានអ្នកបោះឆ្នោតមួយចំនួនជាបន្តបន្ទាប់គ្នាសុំសន្លឹកឆ្នោតមួយសន្លឹក (១) ផ្សេងទៀត ដូចចែងក្នុងចំណុច ១០.៦.២១ ខាងលើ ដែលអាចចាត់ទុកថាជាភាពមិនប្រក្រតីមួយនោះ ប្រធាន គកប អាចសម្រេចមិនព្រមផ្តល់សន្លឹកឆ្នោតមួយ (១) សន្លឹក ផ្សេងទៀតតាមការស្នើសុំទេ និងត្រូវរំលឹកអនុប្រធានឱ្យណែនាំអ្នកបោះឆ្នោតតាមខ្លឹមសារនៃចំណុច ១០.៦.១៩.២ ខាងលើ លេខាត្រូវកត់ត្រាបញ្ហាទាំងនេះចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

១០.៦.២២ ប្រសិនបើ ភ្នាក់ងារនៃគណបក្សនយោបាយណាម្នាក់ជំទាស់នឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬសេចក្តីសម្រេចណាមួយរបស់ គកប គាត់ត្រូវលើកការជំទាស់នោះដោយផ្ទាល់ទៅប្រធាន គកប ដោយបង្ហាញអំពីមូលហេតុ ឬ/និងភស្តុតាងដែលនាំឱ្យគាត់ជឿថា មានភាពមិនប្រក្រតី ឬការរំលោភច្បាប់ ឬ/និងការរំលោភ ប.ន.ឃ.ស ក្នុងការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

១០.៦.២២.១ ប្រសិនបើ យល់ឃើញថាសមហេតុសមផល ប្រធានត្រូវបញ្ឈប់ជាបណ្តោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ដើម្បីស្តាប់ការជំទាស់របស់ភ្នាក់ងារនៃគណបក្សនយោបាយនោះ ហើយបន្ទាប់មកពិភាក្សាបញ្ហានេះ ជាមួយនឹងសមាជិក គកប ដទៃទៀត ។

១០.៦.២២.២ បន្ទាប់ពីបានពិនិត្យឡើងវិញអំពីករណីដែលបានលើកជំទាស់ ប្រសិនបើប្រធាន គកប យល់ព្រមតាមការជំទាស់ ប្រធាន ត្រូវណែនាំ និងរំលឹក សមាជិក គកប និងអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆោត អំពីខ្លឹមសារពាក់ព័ន្ធ ដែលចែងក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស ហើយត្រូវចាត់វិធានការដោះស្រាយភាពមិនប្រក្រតីនោះ ។

១០.៦.២២.៣ ប្រសិនបើ ប្រធាន គកប បដិសេធការជំទាស់ គាត់ត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធ ហើយភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិសុំឱ្យកត់ត្រាករណីនៃការជំទាស់នេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ប្រសិនបើ ភ្នាក់ងារនោះយល់ព្រមផ្តិតមេដៃលើកំណត់ហេតុនោះ ។

១០.៦.២២.៤ ប្រសិនបើភ្នាក់ងារនោះមិនយល់ព្រមផ្តិតមេដៃ ករណីនៃការជំទាស់នោះមិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោតទេ ។

១០.៦.២២.៥ សេចក្តីសម្រេច របស់ប្រធាន គកប ត្រូវតែមានប្រសិទ្ធភាព ហើយ ប្រធានត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត ។

១០.៦.២២.៦ ចំណុច ១០.៦.២២.៥ ខាងលើ មិនបានច្រានចោលជាមុននូវការដែលភ្នាក់ងារនៃគណបក្សនយោបាយណាម្នាក់ ចង់បន្តប្តឹងជំទាស់ទៅ គឃ/សប អំពីករណីដែលគាត់បានលើកជំទាស់ក្នុងការិយាល័យបោះឆ្នោតនោះទេ ប៉ុន្តែគាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គកប និងមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

១០.៦.២២.៧ ប្រធានត្រូវផ្តល់ ទ. ១២០២ សម្រាប់បំពេញពាក្យបណ្តឹង ប្រសិនបើភ្នាក់ងារនៃគណបក្សនយោបាយស្នើសុំសម្រាប់ប្តឹងបន្តទៅ គឃ/សប ។

១០.៦.២៣ ប្រសិនបើមាន អ្នកបោះឆ្នោតណាម្នាក់រំខានដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់ស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យក្តី ប្រធាន គកប ត្រូវបញ្ជាអ្នកបោះឆ្នោតរូបនោះឱ្យចេញក្រៅការិយាល័យបោះឆ្នោត និងចេញផុតពីបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ។ ក្នុងករណីអ្នកបោះឆ្នោតនោះបដិសេធមិនព្រមគោរពតាមបញ្ជារបស់ខ្លួន ប្រធាន ត្រូវស្នើកម្លាំងសន្តិសុខឱ្យបណ្តេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

១០.៦.២៤ ប្រធាន គកប អាចស្នើសុំកម្លាំងសន្តិសុខឱ្យរៀបចំសាឡើងវិញ នូវរបៀបរៀបរយនៅខាងក្នុង និងខាងក្រៅការិយាល័យបោះឆ្នោត ប្រសិនបើ កិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិត ដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី ។ ការរំខានដល់អ្នកបោះឆ្នោត ឬដល់ការប្រព្រឹត្តទៅនៃការបោះឆ្នោត គឺជាសកម្មភាពទាំងឡាយណានៅខាងក្នុង ឬបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ដូចខាងក្រោមនេះ ៖

១០.៦.២៤.១ ការបញ្ចេញពាក្យសំដីគំរាមកំហែង ឬជេរប្រមាថ មាក់ងាយ ។

១០.៦.២៤.២ ការបញ្ចេញសម្រែកខ្លាំងៗ ។

១០.៦.២៤.៣ ការរុញច្រានដោយប្រើកម្លាំងធ្ងន់ ។

១០.៦.២៤.៤ ការគប់វត្ថុផ្សេងៗសំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត ។

១០.៦.២៤.៥ ការអុកឡុកនៃបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត ។

១០.៦.២៤.៦ ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ ។

១០.៦.២៤.៧ ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗប្រកបដោយគ្រោះថ្នាក់ ។

១០.៦.២៥ ប្រសិនបើ ការបោះឆ្នោតឈានដល់ម៉ោងដប់ប្រាំ (១៥:០០) រសៀល នៃថ្ងៃបោះឆ្នោត ដែលជាពេលវេលាកំណត់ សម្រាប់ការបញ្ចប់ដំណើរការបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតទៀត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត ។

១០.៦.២៥.១ ក្នុងករណីនេះ ជំនួយការទី២ ត្រូវដើរប្រមូលយកឯកសារបញ្ជាក់អត្តសញ្ញាណ ពីអ្នកបោះឆ្នោត ដែលកំពុងឈរក្នុងជួរ ដោយចាប់ផ្ដើមពីអ្នកបោះឆ្នោត ដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ទៅឱ្យសមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ នៅត្រង់មាត់ទ្វារ ។

១០.៦.២៥.២ សមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ ត្រូវហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្ដងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោតដើម្បីបោះឆ្នោត តាមលំដាប់លេខរៀង និងតាមនីតិវិធី ។

១០.៦.២៥.៣ ជនណាក៏ដោយ ដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងជួរអ្នកបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅនាទីចុងក្រោយនាម៉ោងដប់ប្រាំ (១៥:០០) រសៀល នៃថ្ងៃបោះឆ្នោតទេ អ្នកបោះឆ្នោតទាំងនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

១០.៦.២៦ ប្រសិនបើ អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនទាន់បានមកបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្ដី ប្រធាន គកប មិនអាចបិទការបោះឆ្នោត នៅការិយាល័យរបស់ខ្លួន នៅមុនម៉ោងដប់ប្រាំ(១៥:០០) រសៀល នៃថ្ងៃបោះឆ្នោតបានឡើយ ។

១០.៦.២៧ ប្រសិនបើ អ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គកប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យរបស់ខ្លួន នៅមុនម៉ោងដប់ប្រាំ(១៥:០០)រសៀល ។

១០.៦.២៨ ក្នុងករណី កាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោត នៅក្នុងបរិវេណនៃការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត ប្រធាន គកប អាចសម្រេចមិនបើក ឬអាចបិទការិយាល័យបោះឆ្នោតរបស់ខ្លួន ដោយផ្អែកតាមការកំណត់របស់ គ.ជ.ប ដូចចែងក្រោមប្រការ ១៣.១ ជំពូកទី ១៣ នៃ ប.ន.ឃ.ស នេះ ។

# ជំពូកទី ១១
# ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ប្រគល់ ទទួលសម្ភារៈបោះឆ្នោត

## ការបិទការបោះឆ្នោត

**ប្រការ** ១១.១ នៅពេលដែលអ្នកមានសិទ្ធិបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យ ប្រធាន គកប ត្រូវចាត់សមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ចាត់វិធានការ ចាំបាច់ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោតកុំឱ្យអ្នកគ្មានភារកិច្ចចេញចូល ។ ប្រធាន គកប ត្រូវប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់មកត្រូវចាត់ចែងការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត និងការបំពេញកំណត់ហេតុនៃការបោះឆ្នោត ។

១១.១.១ បន្ទាប់ពីបានប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ប្រធាន គកប ត្រូវចាត់ចែងតាមនីតិវិធីដើម្បីធានាសុវត្ថិភាពហិបឆ្នោត ដែលក្នុងនោះ ៖

១១.១.១.១ ប្រធានត្រូវមូលភ្ជិតសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោត ព្រមទាំងបិទក្រដាសស្តើងមួយសន្លឹក ដែលមានចុះហត្ថលេខារបស់ប្រធាន គកប និងភ្នាក់ងារនៃគណបក្សនយោបាយពាសពីលើសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនោះផង ។

១១.១.១.២ ប្រធានត្រូវបិទគម្របខាងក្រៅនៃហិបឆ្នោត និងចាក់សោឃ្លុំមានលេខនៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោត រួចអនុញ្ញាតឱ្យភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំងពីរនោះ ។

១១.១.១.៣ លេខាធិការត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត (ទ. ១១០១) នូវពេលវេលានៃការបិទការបោះឆ្នោត ព្រមទាំងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំងពីរ ។

១១.១.១.៤ ប្រធានត្រូវចាត់វិធានការការពារហិបឆ្នោត ដែលមានសន្លឹកឆ្នោតនៅខាងក្នុងយ៉ាងហ្មត់ចត់ សម្រាប់ការរាប់សន្លឹកឆ្នោតនៅនឹងកន្លែងការិយាល័យបោះឆ្នោត ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេងប្រសិនបើមានការសម្រេចឱ្យធ្វើដូច្នេះ ដោយ គ.ជ.ប ។

១១.១.២ បន្ទាប់មក ស្ថិតនៅចំពោះមុខវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គកប ត្រូវចាត់ចែងសមាជិកនៃ គកប ឱ្យធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ និងសន្លឹកឆ្នោតខូច ដែលក្នុងនោះ ៖

១១.១.២.១ លេខាធិការត្រូវរាប់ចំនួនគំនូសសញ្ញាក្នុងប្រអប់ផ្នែកខាងដើម នៅក្នុងបញ្ជីបោះឆ្នោត ដូចចែងក្នុងចំណុច ១០.៦.១១.៣ ខាងលើ និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត។

១១.១.២.២ អនុប្រធាន ត្រូវខណ្ឌសម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោត ដែលបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើ ។ បន្ទាប់មករាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូច ដោយឡែកពីគ្នា ។ ប្រសិនបើ ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដូចបញ្ជាក់ក្នុងចំណុច ១០.៦.៧.៣ ខាងលើ ដកនឹងចំនួនសន្លឹកឆ្នោតខូច រួមនឹងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ១១.១.២.១ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខចំនួនទាំងនេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ. ១១០១) ។

១១.១.២.៣ ប្រសិនបើ ក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថា នៅមានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត លេខាធិការត្រូវផ្ទៀងផ្ទាត់ជាលើកទីពីរ នូវចំនួនអ្នកបោះឆ្នោត ដែលបានបោះឆ្នោតនៅលើបញ្ជីបោះឆ្នោត ហើយអនុប្រធានក៏ត្រូវផ្ទៀងផ្ទាត់ឡើងវិញដែរ នូវចំនួនសន្លឹកឆ្នោត ដែលបានប្រើ សន្លឹកឆ្នោតខូច និងសន្លឹកឆ្នោតមិនបានប្រើ ។ ប្រសិនបើភាពខុសគ្នានៅតែមាន លេខាធិការត្រូវកត់ត្រានូវតួលេខនៃចំនួនដែលខុសគ្នានោះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ. ១១០១) ។

១១.១.២.៤ ភាពខុសគ្នារវាងតួលេខដូចបានបញ្ជាក់ក្នុងចំណុច ១១.១.២.៣ ខាងលើ មិនត្រូវបានកំណត់ជាភាពមិនប្រក្រតីមួយនោះទេ ។

១១.១.២.៥ ជំនួយការទី២ត្រូវចោះសន្លឹកឆ្នោត ដែលមិនបានប្រើទាំងអស់ជាមួយនឹងប្រដាប់ចោះ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ ។

១១.១.២.៦ អនុប្រធានត្រូវដាក់សន្លឹកឆ្នោតមិនបានប្រើ ដែលត្រូវបានចោះរន្ធរួចហើយ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងប្លាស្ទិកតែមួយរួចបិទឱ្យជិត ។

១១.១.៣ ប្រធានត្រូវធានាថា លេខាធិការបានកត់ត្រាជាមុននូវលេខសោឃ្លុំដែលនឹងត្រូវប្រើចាក់ឃ្លុំមាត់កញ្ចប់ " ខ " ដូចចែងក្នុងចំណុច ១១.៩.៩ ខាងក្រោម ក្នុងកំណត់ហេតុនៃការបោះឆ្នោត និងបោះត្រាសម្ងាត់នៅជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុនេះ ។ កំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត (ទ. ១១០១) ចំនួនបី (៣) ច្បាប់ ដែលលេខាធិការបានបំពេញរួច ត្រូវចុះហត្ថលេខា ដោយលេខាធិការ ប្រធាន គកប និងបោះត្រាការិយាល័យ ។

១១.១.៣.១ ប្រធានត្រូវដាក់បង្ហាញកំណត់ហេតុ ដូចចែងក្នុងចំណុច ១១.១.៣ ខាងលើ ចំពោះភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ ។

១១.១.៣.២ ភ្នាក់ងារនៃគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុនេះ ។

១១.១.៣.៣ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុ ពីភ្នាក់ងារនៃគណបក្សនយោបាយណាម្នាក់ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានទេ ។

១១.១.៤ ប្រធាន គកប ត្រូវរៀបចំកំណត់ហេតុនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត (ទ. ១១០១) ដែលបានចុះហត្ថលេខារួច ដូចចែងក្រោម ចំណុច ១១.១.៣ ខាងលើ ដូចខាងក្រោម ៖

១១.១.៤.១ ដាក់មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្ទងថា " កំណត់ហេតុនៃការបោះឆ្នោត (ទ. ១១០១) ផ្ញើជូន គ.ជ.ប " ។

១១.១.៤.២ ដាក់មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្ទងថា " កំណត់ហេតុនៃការបោះឆ្នោត (ទ. ១១០១) ផ្ញើជូន គធ/ខប " ។

១១.១.៤.៣ ដាក់មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្ទងថា " កំណត់ហេតុនៃការបោះឆ្នោត (ទ. ១១០១) ផ្ញើជូន គឃ/សប " ។

១១.១.៥ បន្ទាប់មកប្រធាន គកប ត្រូវរៀបចំដាក់សម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ដែលមានបោះពុម្ពសម្គាល់ថា " កំណត់ហេតុនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតលេខ... " នូវ ៖

១១.១.៥.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចចែងក្នុងចំណុច ១១.១.៤.១ ខាងលើ ។

១១.១.៥.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត ។

១១.១.៥.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " ។

១១.១.៥.៤ ស្បោងប្លាស្ទិកដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " ។

១១.១.៥.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

១១.១.៥.៦ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " (ប្រសិនបើមាន) ។

១១.១.៥.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន) ។

១១.១.៦ ប្រធាន គកប ត្រូវពិនិត្យឱ្យបានហ្មត់ចត់ថា រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារៈ ឯកសារ ដូចចែងក្រោមចំណុច ១១.១.៥ ខាងលើត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " ។ ប្រធាន គកប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " មិនទាន់ត្រូវបិទភ្ជិតនៅពេលនេះនៅឡើយ ហើយនឹងត្រូវបិទភ្ជិត ដោយការសុវត្ថិភាពបម្រុងស្រាប់ លុះណាតែ គករ បានបញ្ចប់ការរាប់សន្លឹកឆ្នោត និងបានដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារៈ ឯកសារបោះឆ្នោតផ្សេងទៀតទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធរួចរាល់សិន ។

១១.១.៧ ប្រធាន គកប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " ដូចចែងក្នុងចំណុច ១១.១.៦ និងស្រោមសំបុត្រ ដូចចែងក្នុងចំណុច ១១.១.៤.២ និង ១១.១.៤.៣ ខាងលើ ត្រូវបានបំពេញលេខកូដការិយាល័យពាក់ព័ន្ធយ៉ាងត្រឹមត្រូវ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ក្នុងពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតកំពុងដំណើរការ ។

១១.១.៨ ប្រធាន គកប ត្រូវចាត់ចែងសមាជិកឱ្យរៀបចំទុកដាក់សម្ភារៈ ឯកសារដែលនៅសល់ក្នុងកេសស័ង្កសី និងវេចខ្ចប់ដបទឹកខ្មៅលុបលាងមិនជ្រះដោយឡែក ។ ទន្ទឹមនឹងនេះ ត្រូវរុះរើបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតទាំងពីរ (២) រួចច្រកទៅក្នុងការុងនីឡុងដែលបានប្រើសម្រាប់ដាក់បន្ទប់សម្ងាត់ ដូចនៅពេលប្រគល់ជូន គកប នាពេលដំបូង ។

**ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត**

**ប្រការ** ១១.២ យោងមាត្រា ១៣២ថ្មី នៃ ច.ប.ឃ.ស ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ បន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច លើកលែងតែការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបានដោយសារករណី ប្រធានស័ក្តិ ឬអសន្តិសុខ ហើយដែល គ.ជ.ប បានសម្រេចឱ្យ គឃ/សប ចាត់ចែងរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅទីស្នាក់ការ គឃ/សប ឬនៅកន្លែងណាមួយដែលមានសុវត្ថិភាព ។

១១.២.១ ក្នុងករណីដែលការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោត ការិយាល័យបោះឆ្នោតក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយ គកប ក្លាយជា គករ ។ ក្នុងករណីនេះ ប្រធាន គកប ដែលក្លាយជាប្រធាន គករ ត្រូវចាត់វិធានការដោយអនុវត្តតាមប្រការ ១០.៥ និងចំណុច ១០.៥.១.២ ក្នុងជំពូកទី ១០ នៃ ប.ន.ឃ.ស នេះ ហើយទន្ទឹមនេះត្រូវចាត់ចែងឱ្យប្រមូលទុកដាក់សម្ភារៈ ឯកសារដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ។ បន្ទាប់មក ប្រធាន គករ ត្រូវចាត់ចែងឱ្យរៀបចំឡើងវិញ នូវគំរូប្លង់បន្ទប់សម្រាប់ការរាប់សន្លឹកឆ្នោតដែលក្នុងនោះត្រូវ ៖

១១.២.១.១ រៀបចំតុធំមួយ ឬតុតូចច្រើនផ្គុំគ្នា និងកៅអីបួនសម្រាប់សមាជិក គករ ដោយដាក់នៅចំកណ្តាលបន្ទប់ដើម្បីអាចឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដើរចុះឡើងជុំវិញតុ ក្នុងការសង្កេតតាមដានកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត ។

១១.២.១.២ លើកហិបឆ្នោតដាក់នៅចំកណ្តាលតុ ព្រមទាំងយកកញ្ចប់សុវត្ថិភាព " ក " ដូចបានបញ្ជាក់ក្នុងចំណុច ១១.១.៥ និងរាល់សម្ភារៈ ឯកសារ និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដាក់នៅលើតុ ត្រង់កន្លែងប្រធានអង្គុយ ។

១១.២.១.៣ ចាត់ជំនួយការទី២ និងសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលបើកចំហ កុំឱ្យមានអ្នកចេញចូល មើលថែរក្សាសុវត្ថិភាពសម្ភារៈ ឯកសារបោះឆ្នោត ដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

១១.២.២ កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ត្រូវធ្វើនៅតែមួយកន្លែងសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោតមួយ ដែលប្រសិនបើចាប់ផ្ដើមហើយត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយពុំត្រូវឈប់សម្រាកឡើយ ។ ប្រធាន គករ ត្រូវចាត់ចែងត្រៀមឱ្យមានភ្លើងបំភ្លឺនៅការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីបង្ការក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវអូសបន្លាយដល់ពេលយប់ ។

១១.២.២.១ ក្នុងដំណើរការ នៃការរាប់សន្លឹកឆ្នោតនៅការិយាល័យរាប់សន្លឹកឆ្នោត ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មម ដែលអាចសង្កេតមើលឃើញសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត ។

១១.២.២.២ ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលដំណើរការនៃការរាប់សន្លឹកឆ្នោត នៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ និងត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន (ទ. ១១១៥) នៅមុនពេលចាប់ផ្ដើមរាប់សន្លឹកឆ្នោត ។

១១.២.២.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចផ្លាស់ប្ដូរភ្នាក់ងារបម្រុងរបស់ខ្លួន (ប្រសិនបើមាន) ឱ្យបំពេញភារកិច្ចជំនួស និងត្រូវចូលរួមឱ្យបានចប់ចុងចប់ដើម ។

១១.២.៣ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ប្រធាន គករ ត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយឱ្យអនុប្រធាន និងជំនួយការទី១ អង្គុយនៅអមសងខាងតុទល់មុខគ្នា ។ ស្ថិតនៅចំពោះមុខភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងបន្ទប់ ប្រធាន គករ ត្រូវប្រកាសចាប់ផ្ដើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ហើយត្រូវ ៖

១១.២.៣.១ បម្រុងទុកនៅក្បែរខ្លួនគាត់នូវ ៖

កញ្ចប់សុវត្ថិភាព " ក " ដែលមានស្បោងប្លាស្ទិក ឬស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងសម្ភារៈ ឯកសារបោះឆ្នោតផ្សេងទៀត ។

ទម្រង់បែបបទលេខ ១២០២ សម្រាប់ចែកជូនភ្នាក់ងារគណបក្សនយោបាយបំពេញពាក្យបណ្ដឹង ប្រសិនបើគាត់ស្នើសុំ ។

ស្បោងប្លាស្ទិកថ្លាសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ។
កៅស៊ូកង ។

១១.២.៣.២ ប្រគល់ទៅឱ្យអនុប្រធាននូវតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) មួយ (១) ច្បាប់ ។

១១.២.៣.៣ ប្រគល់ទៅលេខាធិការនូវ ទម្រង់បែបបទលេខ ១១០២ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) មួយ (១) ច្បាប់ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព " ក " ។

១១.២.៣.៤ ប្រគល់ឱ្យជំនួយការទី១ នូវប៊ិចហ្វឺតធំមួយ (១) ដើម និងផ្ទាំងក្រដាសធំ មួយ (១) ផ្ទាំង សម្រាប់កត់ត្រាសំឡេងឆ្នោត ។

១១.២.៣.៥ ចាត់លេខាធិការ ឱ្យចាប់ផ្តើមបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួល សន្លឹកឆ្នោតដែលមិនបានប្រើ សន្លឹកឆ្នោតខូច និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែលតួលេខទាំងនេះត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួចហើយ ដូចចែងក្រោមចំណុច ១១.១.២ ខាងលើ និងដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត (ទ. ១១០១) ។

១១.២.៤ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ ប្រធាន គករ ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ឱ្យច្បាស់ថា សោឃ្លុំទាំងពីរដែលចាក់ជាប់នឹងគម្របខាងក្រៅនៃហិបឆ្នោតស្ថិតក្នុងស្ថានភាពដើម រួចកាត់ផ្តាច់សោឃ្លុំទាំងនេះដោយកន្ត្រៃ ឬកូនកាំបិតដែលអាចរកបានដោយខ្លួនឯង និងបើកគម្របខាងក្រៅចេញ ។ បន្ទាប់មកប្រធានត្រូវបន្តត្រួតពិនិត្យ ផ្ទៀងផ្ទាត់លេខសោឃ្លុំ ដែលចាក់ជាប់នឹងគន្លឹះខ្ទាស់បិទគម្របខាងក្នុងនៃហិបឆ្នោត និងក្រដាសស្អិតដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថាគ្មានការរុះរើ រួចកាត់ផ្តាច់សោឃ្លុំ និងហែកក្រដាសនេះចោល ។ ចុងក្រោយប្រធានត្រូវបើកគម្របខាងក្នុងនៃហិបឆ្នោត និងចាក់សន្លឹកឆ្នោតឱ្យអស់ពីហិបឆ្នោតដាក់នៅលើតុ ត្រង់ចន្លោះអនុប្រធាន និងជំនួយការទី១ ហើយដាក់ហិបឆ្នោតទទេនៅក្បែរគាត់ ។

១១.២.៤.១ ជំនួយការទី១ត្រូវរើសយកវត្ថុមិនមែនជាសន្លឹកឆ្នោត ដែលមិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត (ប្រសិនបើមាន) ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ទៅក្នុងស្រោមសំបុត្រមួយបម្រុងស្រាប់ ។

១១.២.៤.២ លេខាធិការត្រូវកត់ត្រាអំពីករណី ដូចចែងក្នុងចំណុច ១១.២.៤.១ ខាងលើ (ប្រសិនបើមាន) ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) ។

១១.២.៥ ប្រធាន គករ ត្រូវបង្គាប់អនុប្រធាន និងជំនួយការទី១ឱ្យលា និងតម្រៀបសន្លឹកឆ្នោត ដែលទើបបានចាក់ចេញពីហិបឆ្នោត ដោយដាក់ផ្កាប់ចុះក្រោម និងដាក់សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នងក្នុងមួយ (១) បាច់ មានម្ភៃប្រាំ (២៥) សន្លឹក នៅពំនូកទី១ ហើយដាក់សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង (ប្រសិនបើមាន) នៅពំនូកទី២ ។ បន្ទាប់មក អនុប្រធាន និងជំនួយការទី១ត្រូវរាប់សន្លឹកឆ្នោតទាំងពីរ (២) ពំនូក រួចរាយការណ៍ជូនប្រធានអំពីចំនួនសន្លឹកឆ្នោតសរុប ដែលបានរាប់ឃើញ ។ ប្រធាន គករ ត្រូវធានាថា នីតិវិធីមួយចំនួន ដូចខាងក្រោម ត្រូវតែបានអនុវត្ត ៖

១១.២.៥.១ ក្នុងករណី ចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើ មានចំនួនសរុបស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬស្មើនឹងចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដកនឹងផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននេះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

១១.២.៥.២ ប្រសិនបើ ចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើមានចំនួនតិចជាង ឬច្រើនជាងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬម្យ៉ាងបើមានចំនួនតិចជាង ឬច្រើនជាងផលសងរវាងចំនួនសន្លឹកឆ្នោតរួមដែលបានទទួលជាក់ស្តែង ដកនឹងផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនបានប្រើនោះ ប្រធាន គករ ត្រូវរាប់សន្លឹកឆ្នោតដូចបញ្ជាក់ក្នុងចំណុច ១១.២.៥ ខាងលើឡើងវិញជាលើកទីពីរ ។

១១.២.៥.៣ ប្រសិនបើ បន្ទាប់ពីប្រធានបានរាប់ឡើងវិញហើយ តួលេខនៃចំនួនសន្លឹកឆ្នោត នៅតែមានភាពខុសគ្នាដដែល ដូចបញ្ជាក់ក្នុងចំណុច ១១.២.៥.២ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នានោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

១១.២.៥.៤ ប្រធានត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតដូចបញ្ជាក់

ក្នុងចំណុច ១១.២.៥.១ ឬ ១១.២.៥.២ ឬ/និង ១១.២.៥.៣ ខាងលើ ដើម្បីឱ្យអ្នកទាំងនោះ អាចពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនោះបាន ។

១១.២.៥.៥ អនុប្រធានត្រូវហុចសន្លឹកឆ្នោតពំនូកទី ២ ដែលគ្មានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង ប្រសិនបើមាន ជូនប្រធាន ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃគាត់ ។

១១.២.៥.៦ អនុប្រធានត្រូវហុចសន្លឹកឆ្នោតពំនូកទី ១ ដែលខ្ទាស់ជាបាច់ក្នុងមួយបាច់ម្ភៃប្រាំ (២៥) សន្លឹក ជូនប្រធាន ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃគាត់ ។

១១.២.៦ បន្ទាប់ពីការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតបានបញ្ចប់ ប្រធាន គកស ត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ដែលជាដំបូងត្រូវពិនិត្យផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ហើយបន្ទាប់មក ត្រូវប្រកាសសន្លឹកឆ្នោត ដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ។ ប្រធាន គកស ត្រូវធានាថា កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតត្រូវបានអនុវត្តតាមលំដាប់លំដោយ ដូចខាងក្រោម ៖

១១.២.៦.១ ដោយផ្អែកតាមការកំណត់ ដូចចែងក្រោមប្រការ ១១.៣ ខាងក្រោម ប្រធាន គកស ត្រូវយកសន្លឹកឆ្នោតម្តងមួយ (១) សន្លឹក ពីពំនូកទី១ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោតដែលបានកំណត់ហើយនោះ ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចមើលឃើញច្បាស់ ។

១១.២.៦.២ ប្រសិនបើ ប្រធាន គកស កំណត់សន្លឹកឆ្នោតនោះ ជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវប្រកាសថាជាសន្លឹកឆ្នោតមិនបានការ រួចដាក់សន្លឹកឆ្នោតនោះ នៅពំនូកសន្លឹកឆ្នោតមិនបានការនៅខាងស្តាំដៃ ។

១១.២.៦.៣ ប្រសិនបើ ប្រធាន គកស កំណត់សន្លឹកឆ្នោតនោះ ជាសន្លឹកឆ្នោតបានការ គាត់ត្រូវប្រកាសឱ្យឮៗ អំពីគណបក្សនយោបាយ ដែលសន្លឹកឆ្នោតនោះ ត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ ហើយត្រូវដាក់សន្លឹកឆ្នោតនោះ ទៅតាមពំនូកដោយឡែក សម្រាប់គណបក្សនយោបាយពាក់ព័ន្ធនីមួយៗ ។

១១.២.៦.៤ ផ្អែកតាមការប្រកាសរបស់ប្រធាន គកស អនុប្រធាន និងលេខាធិការត្រូវគូសពិន្ទុមួយ (១) សម្រាប់សន្លឹកឆ្នោតមួយ (១) សន្លឹក

ដែលគណបក្សនយោបាយណាមួយត្រូវបានទទួល តាមរបៀបដែល គ.ជ.ប បានណែនាំនៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ។ ទន្ទឹមនឹងនេះ ជំនួយការទី១ ត្រូវប្រើប៊ិចហ្វឺតគូសពិន្ទុមួយ (១) នៅលើផ្ទាំងក្រដាសធំដែលអាចច្នៃប្រឌិត បិទភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀន ។

១១.២.៦.៥ ក្នុងករណី មានការជំទាស់ចំពោះសន្លឹកឆ្នោតដែលបានផ្ទៀងផ្ទាត់រាប់តាមចំណុច ១១.២.៦.៣ ខាងលើ ប្រធាន ត្រូវដាក់សន្លឹកឆ្នោតដែលមានការជំទាស់នោះ ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ដូចចែងក្នុងចំណុច ១១.២.៦.២ ខាងលើ ។ សន្លឹកឆ្នោតទាំងនោះនឹងត្រូវពិនិត្យផ្ទៀងផ្ទាត់ និងកំណត់ម្តងទៀតជាចុងក្រោយ ដោយអនុវត្តតាមចំណុច ១១.២.៦.៦ ខាងក្រោម ។

១១.២.៦.៦ នៅពេលផ្ទៀងផ្ទាត់សុពលភាព និងរាប់អស់សន្លឹកឆ្នោតពីពំនូកទី ១ ប្រធាន ត្រូវបន្តយកសន្លឹកឆ្នោតម្តងមួយ (១) សន្លឹកៗ ពីពំនូកសន្លឹកឆ្នោតមិនបានការ មកពិនិត្យផ្ទៀងផ្ទាត់ សុពលភាព និងកំណត់ម្តងទៀតជាចុងក្រោយ ដើម្បីឱ្យប្រាកដថា ជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ ។

១១.២.៦.៧ ប្រសិនបើ ប្រធាន គករ សម្រេចថា ជាសន្លឹកឆ្នោតបានការវិញ ត្រូវអនុវត្តចំណុច ១១.២.៦.៣ និង ១១.២.៦.៤ ខាងលើ ។

១១.២.៦.៨ ប្រសិនបើ ប្រធានសម្រេចថា ជាសន្លឹកឆ្នោតមិនបានការ ប្រធានត្រូវដាក់សន្លឹកឆ្នោតនោះ ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ។

១១.២.៧ ក្នុងអំឡុងពេលនៃការពិនិត្យផ្ទៀងផ្ទាត់ និងកំណត់សន្លឹកឆ្នោត ដូចចែងក្នុងចំណុច ១១.២.៦.១ និង ១១.២.៦.៦ ខាងលើ ប្រសិនបើ ប្រធាន គករ កត់សម្គាល់ឃើញថា សន្លឹកឆ្នោតណាមួយជាសន្លឹកឆ្នោតមិនច្បាស់លាស់ ដោយយោងទៅតាមសេចក្តីណែនាំ ដូចបានបញ្ជាក់ក្រោមប្រការ ១១.៣ ខាងក្រោម គាត់ត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គករ អំពីសុពលភាព និងការកំណត់ប្រភេទនៃសន្លឹកឆ្នោតនោះម្តងទៀត ដើម្បីកំណត់ចុងក្រោយថា ពិតជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ ។

១១.២.៧.១ ទោះបីប្រធានកំណត់ថា ជាសន្លឹកឆ្នោតបានការក្តី ឬជាសន្លឹកឆ្នោតមិនបានការក្តី ប្រធានត្រូវប្រកាសឱ្យឮៗអំពីហេតុផល សម្រាប់សន្លឹកឆ្នោតនោះ និងត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ

និងអ្នកសង្កេតការណ៍ធ្វើការត្រួតពិនិត្យសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការនោះ និងឱ្យចោទជាសំណួរចំពោះហេតុផលនៃការកំណត់របស់ប្រធានចំពោះសន្លឹកឆ្នោតនោះ ។ ក្នុងករណីនេះ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ មិនត្រូវបានអនុញ្ញាតឱ្យកាន់សន្លឹកឆ្នោតនោះឡើយ ។

១១.២.៧.២ ក្នុងករណី ប្រធានកំណត់ថា ជាសន្លឹកឆ្នោតបានការ ត្រូវអនុវត្តតាមចំណុច ១១.២.៦.៣ និង ១១.២.៦.៤ ខាងលើ ។

១១.២.៧.៣ ក្នុងករណី ប្រធានកំណត់ថា ជាសន្លឹកឆ្នោតមិនបានការ ប្រធានត្រូវដាក់សន្លឹកឆ្នោតនោះនៅពំនូកសន្លឹកឆ្នោតមិនបានការ ។

១១.២.៧.៤ ប្រសិនបើ ភ្នាក់ងារគណបក្សនយោបាយណាម្នាក់មិនឯកភាពជាមួយនឹងសេចក្តីសម្រេចរបស់ប្រធាន ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការខាងលើ ភ្នាក់ងារនោះមានសិទ្ធិ លើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់នោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។ ករណីនៃការជំទាស់នោះនឹងមិនត្រូវបាន កត់ត្រាក្នុងកំណត់ហេតុទេ ប្រសិន បើភ្នាក់ងារនោះមិនយល់ព្រមផ្តិតមេដៃលើកំណត់ហេតុ ។

១១.២.៧.៥ សេចក្តីសម្រេចរបស់ប្រធាន ត្រូវតែមានប្រសិទ្ធភាព ក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត ។

១១.២.៧.៦ ការកំណត់ដូចចែងក្នុងចំណុច ១១.២.៧.៥ ខាងលើ មិនបានច្រានចោលជាមុននូវការ ដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្តឹងជំទាស់ទៅ គឃ/សប អំពីករណីដែលគាត់បានលើកជំទាស់ដូចចែងក្នុងចំណុច ១១.២.៧.៤ ខាងលើនោះទេ ប៉ុន្តែគាត់ត្រូវតែយល់ព្រម ទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធានគករ និងមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតឡើយ ។

១១.២.៧.៧ ប្រធានត្រូវផ្តល់ ទ. ១២០២ ចំនួនបី (៣) ច្បាប់ ជូនភ្នាក់ងារគណបក្សនយោបាយ តាមសំណើសុំសម្រាប់បំពេញពាក្យបណ្តឹងទៅ គឃ/សប ។

១១.២.៨ ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ក្នុងពេលកំពុងរាប់សន្លឹកឆ្នោត ហាមជនគ្រប់រូបធ្វើសកម្មភាព ទោះតាមរូបភាពណាក៏ដោយ ក្នុង

គោលបំណងកត់សម្គាល់ ដើម្បីឱ្យដឹងថា តើអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់ បានបោះឆ្នោតឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ។

១១.២.៨.១ ជនណាក៏ដោយ ដែលបានធ្វើសកម្មភាព ដូចចែងក្នុងចំណុច ១១.២.១៣ នឹងត្រូវទទួលការប្រមានពីប្រធាន គកស ។ ការធ្វើសកម្មភាពដដែលឡើងវិញជាលើកទីពីរ នឹងត្រូវចាត់ទុកថាជាការរំលោភលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ហើយជនដែលមានការពាក់ព័ន្ធ ត្រូវតែបានបណ្តេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ឃ.ស ។

១១.២.៨.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះ ក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត និងរាយការណ៍ជូន គឃ/សប ។

១១.២.៨.៣ ពេលទទួលបានកំណត់ហេតុ ដូចចែងក្នុងចំណុច ១១.២.១៣.២ ខាងលើភ្លាម គឃ/សប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនេះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន ប្រធាន គឃ/សប ត្រូវប្តឹងទៅ គធ/ខប ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់ ។

១១.២.៩ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួចហើយ ប្រធាន គកស ត្រូវចាត់អនុប្រធាននិងលេខាធិការ ឱ្យបូកសរុបនិងកត់ត្រាចំនួនសន្លឹកឆ្នោតមិនបានការសរុប ចំនួនសន្លឹកឆ្នោតបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) ព្រមទាំងបង្គាប់ជំនួយការទី១ ឱ្យធ្វើកិច្ចការដូចគ្នានេះ នៅលើផ្ទាំងក្រដាសធំ ដែលបានប្រើសម្រាប់គូសសំឡេងឆ្នោត ។ ទន្ទឹមនេះដោយមានការពិនិត្យសង្កេតមើលរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គកស ត្រូវរាប់ចំនួនសន្លឹកឆ្នោតបានការ តាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងតាមពំនូកសន្លឹកឆ្នោតមិនបានការ ហើយត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញ ជាមួយនឹងតួលេខចំនួនសន្លឹកឆ្នោតដែលអនុប្រធាន លេខាធិការ និងជំនួយការទី១ បានបូកសរុបឃើញខាងលើ ។ ប្រធាន គកស ត្រូវធានាថាតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) ទាំងពីរ (២) ច្បាប់ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតមួយ (១) ផ្ទាំង ត្រូវបានចុះហត្ថលេខាដោយលេខាធិការ ខ្លួនគាត់ផ្ទាល់ និងភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន (ប្រសិនបើភ្នាក់ងារទាំងនោះយល់ព្រម) ។

១១.២.១០ ប្រធាន គកករ ត្រូវប្រកាសជាចំហនូវលទ្ធផលនៃការបូកសរុប និងការរាប់ចំនួនសន្លឹកឆ្នោត ដែលបានអនុវត្តតាមចំណុច ១១.២.៩ ខាងលើ និងត្រូវធ្វើការផ្ទៀងផ្ទាត់ ដោយធ្វើប្រមាណវិធីបូកបញ្ចូលគ្នា នូវចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ និងចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់ ។

១១.២.១០.១ ប្រសិនបើ ផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ ស្មើគ្នាទៅនឹងចំនួនសន្លឹកឆ្នោត ដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចចែងក្នុងចំណុច ១១.២.៥ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនសន្លឹកឆ្នោត ដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការ ទៅក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) ។

១១.២.១០.២ ប្រសិនបើ ផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះមានចំនួនតិចជាង ឬច្រើនជាងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចចែងក្នុងចំណុច ១១.២.៥ ខាងលើ ប្រធានត្រូវរាប់សន្លឹកឆ្នោតតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការឡើងវិញម្តងទៀត ។

១១.២.១០.៣ ប្រសិនបើ បន្ទាប់ពីប្រធានបានរាប់ឡើងវិញ និងធ្វើប្រមាណវិធីបូកឃើញផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ នៅតែមានភាពខុសគ្នាដដែល ម្យ៉ាងប្រសិនបើគ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោតទេ ឬ/និងគ្មានសន្លឹកឆ្នោត ត្រូវបានគេរកឃើញនៅលើកម្រាលដោយមូលហេតុជ្រុះទេនោះ គេអាចសន្មត់ថា ភាពខុសគ្នានេះបានកើតឡើងមុនដោយយថាហេតុ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) ។

១១.២.១១ ប្រធាន គកករ ត្រូវធានាថា សន្លឹកឆ្នោតបានការ ដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចងនឹងកៅស៊ូកងឱ្យជាប់ដោយឡែកពីគ្នា ។

១១.២.១២ ប្រធាន គកករ ត្រូវធានាថា សន្លឹកឆ្នោតមិនបានការទាំងអស់ត្រូវបានចងនឹងកៅស៊ូកងនិងដាក់បញ្ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ញូងថា " សន្លឹកឆ្នោតមិនបានការ " ។

១១.២.១៣ ប្រធាន គកប ត្រូវធានាថាសន្លឹកឆ្នោតបានការ ដែលបានចងនឹងកៅស៊ូកង ដូចចែងក្នុងចំណុច ១១.២.១១ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ដូចចែងក្នុងចំណុច ១១.២.១២ ផ្ទាំងក្រដាសកត់ត្រាសំឡេងឆ្នោត ដូចចែងក្នុងចំណុច ១១.២.៩ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដូចចែងក្នុងចំណុច ១១.២.៤.១ ខាងលើ ត្រូវបានដាក់រួមគ្នាក្នុងស្បោងប្លាស្ទិកតែមួយ ដែលមានបោះពុម្ពសម្គាល់ពីខាងក្រៅថា " សន្លឹកឆ្នោតបានការនិងសន្លឹកឆ្នោតមិនបានការនៃការិយាល័យបោះឆ្នោតលេខ... " បន្ទាប់មក ត្រូវបិទភ្ជិតមាត់ស្បោងប្លាស្ទិកនេះ និងត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយប្រើប៊ិចហ្វឺតធំលុបមិនជ្រះ នៅលើផ្នែកខាងក្រៅនៃស្បោងប្លាស្ទិក ដើម្បីត្រៀមបញ្ជូន និងប្រគល់ជូន គឃ/សប ។

**សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ**

**ប្រការ ១១.៣** ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គកប ជាពិសេស ប្រធាន និងអនុប្រធាន គកប ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

១១.៣.១ សន្លឹកឆ្នោតបានការគឺជាសន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ និងមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង ហើយដែលនៅលើសន្លឹកឆ្នោតនោះអ្នកបោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ពីឆន្ទៈរបស់ខ្លួន ដោយមានគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ដែលគាត់ពេញចិត្ត ។

១១.៣.២ សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលត្រូវបានចាត់ទុកជាមោឃៈ ដែលក្នុងនោះរួមមានសន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ ឬ/និងសន្លឹកឆ្នោតដែលគ្មានគំនូស ឬមានគំនូស ប៉ុន្តែ គកប ពុំអាចសន្និដ្ឋានថា បោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ ឬ/និងសន្លឹកឆ្នោតដែលមានសញ្ញានាំឱ្យគេស្គាល់ អ្នកបោះឆ្នោត ឬ/និងសន្លឹកឆ្នោតដែលមានរហែក ឬខូច ឬ/និងសន្លឹកឆ្នោតដែលគ្មានបោះត្រាសម្ងាត់ជាផ្លូវការ ។ សន្លឹកឆ្នោតមិនបានការដែលត្រូវបានចាត់ទុកជាមោឃៈ រួមមានប្រាំ (៥) ប្រភេទ ដូចខាងក្រោម ៖

**១_ សន្លឹកឆ្នោតផ្លូវការ**

១១.៣.២.១ សន្លឹកឆ្នោតមានខ្នាតតូចជាងឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។

១១.៣.២.២ សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាងឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។

១១.៣.២.៣ សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។

១១.៣.២.៤ សន្លឹកឆ្នោត ដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើន ដែលបានឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

១១.៣.២.៥ សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយ លើសពីចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

១១.៣.២.៦ សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

១១.៣.២.៧ សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោត ដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការនិងដែលមិនបានផ្តល់ឱ្យដោយ គកប ពាក់ព័ន្ធ ។

**២_ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូស ដែល គករ ពុំអាចសន្និដ្ឋានថា ចោះគាំទ្រគណបក្សនយោបាយណាមួយ**

១១.៣.២.៨ សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ) ។

១១.៣.២.៩ សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយលើសពីមួយគណបក្ស ។

១១.៣.២.១០ សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើន នៅក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយណាមួយក៏ដោយ ។

**៣_ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ ដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត**

១១.៣.២.១១ សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។

១១.៣.២.១២ សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។

១១.៣.២.១៣ សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ ភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។

១១.៣.២.១៤ សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ ។

១១.៣.២.១៥ សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ។

**៤_ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច**

១១.៣.២.១៦ សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយណាមួយ ។

១១.៣.២.១៧ សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង ។

១១.៣.២.១៨ សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងខាងខ្នង ដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរដែលបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូស សញ្ញាដែលបោះគាំទ្រគណបក្សនយោបាយ ។

**៥_ សន្លឹកឆ្នោតគ្មានបោះត្រាសម្គាត់ជាផ្លូវការសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ**

១១.៣.២.១៩ សន្លឹកឆ្នោតគ្មានបោះត្រាសម្គាត់ផ្លូវការ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

១១.៣.២.២០ សន្លឹកឆ្នោតមានបោះត្រាសម្គាត់ ប៉ុន្តែពុំមែនជាត្រាសម្គាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

**ការរៀបចំ និងការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ**

**ប្រការ ១១.៤** នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដូចចែងក្រោមប្រការ ១១.២ ខាងលើត្រូវបានបំពេញរួចរាល់ ប្រធាន គករ ត្រូវធានាថាតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួនពីរ (២) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) ចំនួនប្រាំ (៥) ច្បាប់ ដែលលេខាធិការបានបំពេញត្រឹមត្រូវហើយ ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ ព្រមទាំងបោះត្រា ។ ប្រធាន គករ ត្រូវចាត់ចែងវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួន ព្រមទាំងរាល់សម្ភារៈឯកសារបោះឆ្នោតផ្សេងទៀត ដើម្បីបញ្ជូនទៅ គឃ/សប ។

១១.៤.១ ប្រធាន គករ ត្រូវដាក់បង្ហាញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតដូចចែងក្នុងប្រការ ១១.៤ ខាងលើ ចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ព្រមទាំងអញ្ជើញភ្នាក់ងារគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខា ឬផ្ដិតមេដៃជាសាក្សី ។

១១.៤.១.១ ភ្នាក់ងារគណបក្សនយោបាយ អាចចុះហត្ថលេខា ឬផ្ដិតមេដៃជាសាក្សី លើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតខាងលើ ។

១១.៤.១.២ ការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ពីភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកជាមោឃៈនៃកំណត់ហេតុនេះបានទេ ។

១១.៤.២ ប្រធាន គករ ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតច្បាប់ទីមួយ និងតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) មួយ (១) ច្បាប់ដូចចែងក្នុងចំណុច ១១.២.៩ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ពងថា " ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គ.ជ.ប " ។ បន្ទាប់មក ប្រធាន គករ ត្រូវរៀបចំវេចខ្ចប់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ព្រមទាំងរាល់ស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ហើយត្រូវបិទភ្ជិតដោយកាវសុវត្ថិភាពដែលបម្រុងស្រាប់ និងបំពេញលេខកូដការិយាល័យពាក់ព័ន្ធឱ្យបានត្រឹមត្រូវ ។ ប្រធាន គករ ត្រូវធានាថា នៅក្នុងកញ្ចប់សុវត្ថិភាព " ក " រួមមានសម្ភារៈឯកសារដូចខាងក្រោម ៖

១១.៤.២.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ផ្ញើជូន គ.ជ.ប ។

១១.៤.២.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត ។

១១.៤.២.៣ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

១១.៤.២.៤ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " ។

១១.៤.២.៥ ស្បោងប្លាស្ទិក ឬស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " ។

១១.៤.២.៦ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " (ប្រសិនបើមាន) ។

១១.៤.២.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាង ដែលបានដកហូត (ប្រសិនបើមាន) ។

១១.៩.២.៨ ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដូចចែងក្នុងចំណុច ១១.២.១៣ ខាងលើ ។

១១.៩.៣ ប្រធាន គកស ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ច្បាប់ទីពីរ និងច្បាប់ទីបី និងតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) មួយ (១) ច្បាប់ទៅក្នុងស្រោមសំបុត្រ បោះពុម្ពស្រាប់ដែលមានកាខ្លងថា " កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គឃ/សប" ដូចចែងក្នុង ចំណុច ១១.១.៩.៣ ខាងលើ ។

១១.៩.៣.១ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតមួយ (១) ច្បាប់ នឹងត្រូវប្រើសម្រាប់បិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គឃ/សប ។

១១.៩.៣.២ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតមួយ (១) ច្បាប់ទៀត និងតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) មួយ (១) ច្បាប់នឹងត្រូវប្រើសម្រាប់ការត្រួតពិនិត្យ បូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ/សប ដែលក្រោយមកត្រូវរក្សាទុកជាឯកសារ ។

១១.៩.៤ ប្រធាន គកស ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ច្បាប់ទីបួនទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្លងថា " កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតផ្ញើជូន គជ/ខប " ដូចចែងក្នុងចំណុច ១១.១.៩.២ ខាងលើ ។

១១.៩.៥ ប្រធាន គកស ត្រូវចាត់ជំនួយការទី២ ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតច្បាប់ទីប្រាំ (៥) ជាសាធារណៈនៅត្រង់ច្រកចូលទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ ។

១១.៩.៦ ប្រធាន គកស ត្រូវចាត់ចែងសមាជិក គកស ឱ្យបំពេញក្រដាសលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ (ទ. ១១០៩) ដោយស្រង់តួលេខលទ្ធផល ចេញពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) រួចចុះហត្ថលេខា និងបោះត្រាសម្រាប់ចែកជូនភ្នាក់ងារគណបក្សនយោបាយ ដែលមានវត្តមាន ។

១១.៤.៧ ប្រធាន គករ ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនបី (៣) ច្បាប់ ត្រូវបានបំពេញលំអិតមុខសម្ភារៈ ឯកសារបោះឆ្នោតដោយលេខាធិការ និងចុះហត្ថលេខាដោយប្រធានផ្ទាល់ សម្រាប់ប្រើក្នុងការបញ្ជូន និងប្រគល់ទទួលកញ្ចប់ " ខ " នៅ គឃ/សប ។ ប្រធាន គករ ត្រូវ ៖

១១.៤.៧.១ ដាក់មួយ (១) ច្បាប់ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងកញ្ចប់ " ខ " ។

១១.៤.៧.២ ដាក់មួយ (១) ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " ។

១១.៤.៧.៣ រក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើក្នុងការចុះហត្ថលេខាប្រគល់ទទួលកញ្ចប់ " ខ " នៅ គឃ/សប ។

១១.៤.៨ ប្រធាន គករ ត្រូវធានាក្នុងការវេចខ្ចប់ដាក់ក្នុងកញ្ចប់ " ខ " ដើម្បីបញ្ជូនទៅ គឃ/សប នូវសម្ភារៈ ឯកសារបោះឆ្នោត ដូចខាងក្រោម ៖

១១.៤.៨.១ កញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដូចចែងក្នុងចំណុច ១១.៤.២ ខាងលើ ។

១១.៤.៨.២ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គឃ/សប ដូចចែងក្នុងចំណុច ១១.៤.៣ ខាងលើ ។

១១.៤.៨.៣ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតផ្ញើជូន គធ/ខប ដូចចែងក្នុងចំណុច ១១.៤.៤ ខាងលើ ។

១១.៤.៨.៤ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោតមួយ (១) ច្បាប់ ដូចចែងក្នុងចំណុច ១១.៤.៧.១ ខាងលើ ។

១១.៤.៨.៥ ស្រោមសំបុត្រតូចមួយដាក់ត្រាការិយាល័យបោះឆ្នោត (ដាក់ក្រោយពេលបានបោះត្រាលើ ទ. ១១០៧ រួចរាល់ហើយ) ។

១១.៤.៩ ប្រធាន គករ ត្រូវធានាថា កញ្ចប់ " ខ " ដែលផ្ទុកសម្ភារៈ ឯកសារបោះឆ្នោតដូចមានចែងក្រោមចំណុច ១១.៤.៨ ខាងលើត្រូវបានចងភ្ជិត ចាក់សោឃ្លុំមានលេខ និងសរសេរលេខកូដការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ។

១១.៤.១០ ប្រធាន គករ ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ បានសង្កេតមើលក្នុងរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារៈ ឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គឃ/សប និងបានកត់ត្រាលេខសោឃ្លុំ ដែលបានចាក់នៅត្រង់មាត់កញ្ចប់ " ខ " ដូចចែងក្នុងចំណុច ១១.៤.៩ ខាងលើ ។

១១.៤.១១ ប្រធាន គករ ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ ដែលតម្រូវផ្ញើជូន គ.ជ.ប វិញដូចជា ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ទឹកខ្មៅលុបលាងមិនជ្រះ ស្លាកសញ្ញាការិយាល័យបោះឆ្នោតជាដើម ហើយត្រូវបញ្ជូន និងប្រគល់សម្ភារៈ ឯកសារបោះឆ្នោតទាំងនោះជូន គឃ/សប អមជាមួយនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។ ប្រធាន គករ ត្រូវធានាថា លិខិតបញ្ជូននិងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួនពីរ (២) ច្បាប់ ត្រូវបានបំពេញលំអិតមុខសម្ភារៈ ឯកសារនៅសល់ទាំងអស់ សម្រាប់ប្រើក្នុងពេលប្រគល់ទទួលនៅ គឃ/សប ។

**ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ នៅទីស្នាក់ការ គឃ/សប**

**ប្រការ ១១.៥** បន្ទាប់ពីបានធ្វើការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតរួចសព្វគ្រប់ហើយ ប្រធាន គករ ត្រូវចាត់វិធានការចាំបាច់ទាំងឡាយក្នុងការបញ្ជូនជាបន្ទាន់នូវកញ្ចប់ " ខ " ដូចចែងក្នុងចំណុច ១១.៤.៩ និងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ដូចចែងក្នុងចំណុច ១១.៤.១១ ខាងលើ ឱ្យបានទៅដល់ទីស្នាក់ការ គឃ/សប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត។

១១.៥.១ ប្រសិនបើ ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលាកម្រិតនៃភាពងងឹត និងសភាពការណ៍សន្តិសុខ ប្រធាន គករ យល់ថាអាចនឹងបញ្ជូនកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួន ព្រមទាំងសម្ភារៈ ឯកសារនៅសល់ផ្សេងទៀតទៅដល់ គឃ/សប បានទាន់សមតាមពេលវេលា និងធានាសុវត្ថិភាពនោះ ប្រធាន ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានាឱ្យចូលរួមក្នុងការបញ្ជូនខាងលើ និងត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរ ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ទទួលកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោតទាំងនោះនៅទីស្នាក់ការ គឃ/សប ។

១១.៥.២ ប្រធាន គករ ដែលអមដំណើរដោយអនុប្រធាន ត្រូវទទួលខុសត្រូវដឹកជញ្ជូន ដោយផ្ទាល់នូវកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៃការិយាល័យរបស់ខ្លួនទៅទីស្នាក់ការ គឃ/សប ។ ប្រធានត្រូវ ចាត់សមាជិក គករ តាមការចាំបាច់ ដើម្បីជួយដឹកជញ្ជូនឱ្យអស់សម្ភារៈ ឯកសារនៅសល់ផ្សេងទៀត ។

១១.៥.៣ ប្រសិនបើត្រូវការចាំបាច់ប្រធាន គករ ត្រូវស្នើសុំកម្លាំងសន្តិសុខពីរ (២) រូប ដើម្បីអមដំណើរការដឹកជញ្ជូនកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ទៅ គឃ/សប ។

១១.៥.៤ នៅពេលប្រគល់ ទទួលកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតព្រមទាំងសម្ភារៈ ឯកសារនៅសល់ផ្សេងទៀត គឃ/សប ត្រូវធានាថា បានត្រួតពិនិត្យរាល់សម្ភារៈ ឯកសារទាំងអស់ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) បញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ ។ ដោយឡែកក្នុងការប្រគល់ ទទួលកញ្ចប់ " ខ " គឃ/សប ត្រូវ ៖

១១.៥.៤.១ បើកកញ្ចប់ " ខ " ត្រួតពិនិត្យសម្ភារៈ ឯកសារបោះឆ្នោតខាងក្នុង ដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោតទាំងបី (៣) ច្បាប់ ប៉ុន្តែមិនត្រូវរុះរើកញ្ចប់សុវត្ថិភាព " ក " ឡើយ ។

១១.៥.៤.២ ចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោតទាំងបី (៣) ច្បាប់ បន្ទាប់ពីបានត្រួតពិនិត្យត្រឹមត្រូវហើយ។

១១.៥.៤.៣ អញ្ជើញភ្នាក់ងារគណបក្សនយោបាយ ចូលរួមចុះហត្ថលេខាជាសាក្សីលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោត ។ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈនេះបានទេ ។

១១.៥.៤.៤ ប្រគល់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ដែលចុះហត្ថលេខារួចមួយ (១) ច្បាប់ ជូនប្រធាន គករ ពាក់ព័ន្ធ ស៊កមួយ (១) ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " វិញ និងរក្សាទុកមួយ (១) ច្បាប់ ចងក្រងជាឯកសារ ។

១១.៥.៥ រាល់កញ្ចប់ " ខ " ដែល គឃ/សឃ បានទទួលខាងលើ ត្រូវតែបាន កត់ចំណាំ និងរក្សាទុកនៅកន្លែងមានសុវត្ថិភាពដោយដាក់តាមលំដាប់លេខកូដ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ ។

១១.៥.៦ គឃ/សឃ ត្រូវចាត់វិធានការយ៉ាងហ្មត់ចត់ក្នុងការការពារសន្តិសុខ និងសុវត្ថិភាពនៃ កញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំង សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ។ ក្នុងនោះ គឃ/សឃ ត្រូវ ៖

១១.៥.៦.១ ទំនាក់ទំនងស្នើសុំកម្លាំងសន្តិសុខ ដើម្បីយាមការពារបរិវេណទីស្នាក់ការ គឃ/សឃ ឬអគារដែលត្រូវរក្សាទុកកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោត ។

១១.៥.៦.២ ចាត់ចែងឱ្យមានភ្លើងបំភ្លឺ នៅទីស្នាក់ការ គឃ/សឃ ឬអាគារ ដែលត្រូវរក្សាទុកកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោត ។

**ប្រការ** ១១.៦ ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា កម្រិតនៃភាពងងឹត និង សភាពការណ៍សន្តិសុខ ប្រសិនបើប្រធាន គករ យល់ថាមិនអាចបញ្ជូនកញ្ចប់ " ខ " ដាក់ កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៃការិយាល័យរបស់ខ្លួន ព្រមទាំងសម្ភារៈ ឯកសារនៅសល់ផ្សេងទៀតទៅ គឃ/សឃ នៅពេលល្ងាច ឬយប់នៃថ្ងៃបោះឆ្នោតបាន ទេនោះ ប្រធានត្រូវចាត់វិធានការ ដើម្បីថែរក្សាការពារកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោត ទាំងនោះនៅពេលយប់ នៅទីតាំងសុវត្ថិភាពណាមួយ ដោយត្រូវផ្តល់ព័ត៌មានអំពីបញ្ហានេះដល់ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ។

១១.៦.១ ប្រធាន គករ ត្រូវថែរក្សាការពារកញ្ចប់ " ខ " និងសម្ភារៈ ឯកសារ បោះឆ្នោតខាងលើ នៅផ្ទះរបស់គាត់ ឬផ្ទះរបស់សមាជិកណាម្នាក់នៃ គករ ឬនៅ ទីតាំងសុវត្ថិភាពណាមួយដែលបានកំណត់ ។

១១.៦.២ ប្រធាន គករ ត្រូវប្រាប់ដល់ភ្នាក់ងារគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ឱ្យបានដឹងអំពីផ្ទះ ឬទីតាំងសុវត្ថិភាពដែលនឹងត្រូវរក្សាទុកកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោត នៅពេលយប់ ហើយត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យចូលរួមថែរក្សាការពារ ។ ទន្ទឹមនឹងនេះ ត្រូវជូនដំណឹងអំពី ពេលវេលាចេញដំណើរនៅព្រឹកស្អែក និងពេលវេលានៃការប្រគល់ទទួលកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោតទាំងនោះនៅទីស្នាក់ការ គឃ/សឃ ។

១១.៦.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានាអាចស្នាក់នៅពេលយប់នៅផ្ទះ ឬទីតាំងសុវត្ថិភាព ដែលទទួលរក្សាការពារកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោត ។

១១.៦.៤ ប្រធាន គករ ត្រូវធានាឱ្យមានយ៉ាងហោចណាស់ សមាជិកនៃ គករ ចំនួនបី (៣) នាក់ គិតទាំងប្រធានផង ចូលរួមក្នុងការរក្សាការពារកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោត ។

១១.៦.៥ នៅគ្រប់ពេលវេលាប្រធាន គករ មិនត្រូវទុកកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោតចោលដោយគ្មានការឃ្លាំមើលទេ ។

១១.៦.៦ ប្រសិនបើចាំបាច់ ប្រធាន គករ ត្រូវស្នើសុំកម្លាំងសន្តិសុខពីរ (២) នាក់ ដើម្បីយាមការពារបរិវេណផ្ទះ ឬទីតាំងដែលរក្សាទុកកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោតនៅពេលយប់ ។

១១.៦.៧ នៅព្រឹកថ្ងៃបន្ទាប់ អនុវត្តតាមពេលវេលាដែលបានកំណត់ ប្រធាន គករ ត្រូវទទួលបន្ទុកក្នុងការបញ្ជូនកញ្ចប់ " ខ " និងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅប្រគល់ជូន គឃ/សប ។ ក្នុងករណីនេះ បទបញ្ជា និងនីតិវិធីដូចមានចែងក្នុងចំណុច ១១.៥.២ ១១.៥.៣ ១១.៥.៤ និង ១១.៥.៥ ខាងលើ ត្រូវតែបានអនុវត្ត ។

**ការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ/សប ឬនៅទីតាំងសុវត្ថិភាពណាមួយ**

**ប្រការ** ១១.៧ យោងមាត្រា ១៣២ថ្មី និង ១៣៣ថ្មី នៃ ច.ប.ឃ.ស ចំពោះការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ណាដែលមិនអាចរាប់សន្លឹកឆ្នោត នៅការិយាល័យរបស់ខ្លួនបាន ដោយសារករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្នកើតឡើង នៅពេលបន្ទាប់ពីបានបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច គ.ជ.ប ត្រូវណែនាំដល់ គឃ/សប ពាក់ព័ន្ធឱ្យចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅទីស្នាក់ការ គឃ/សប ឬទីតាំងសុវត្ថិភាពណាមួយ ។

១១.៧.១ ករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន ត្រូវបានកំណត់ក្នុងចំណោមករណីណាមួយ ដូចចែងក្នុងចំណុច ១.៥.៣ ប្រការ ១.៥ ជំពូកទី ១ ។

១១.៧.២ ក្នុងករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន ដែលកើតឡើងនៅក្រោយ ពេល គកប បានអនុវត្តចប់សព្វគ្រប់ នូវរាល់នីតិវិធី ដូចចែងក្រោមប្រការ ១១.១ ខាងលើ ហើយប្រសិនបើគ្រោះអាសន្ននោះ បានបណ្តាលឱ្យខូចខាតដល់ហិប ឆ្នោត ដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងរាល់កំណត់ហេតុនៃការបោះឆ្នោត ប្រធាន គកប ត្រូវចាត់ចែងជាបន្ទាន់ដូចខាងក្រោម ៖

១១.៧.២.១ ធ្វើរបាយការណ៍ស្តីពីស្ថានភាពនៃករណីប្រធានស័ក្តិ ឬកាលៈទេសៈ មានអាសន្ននោះព្រមទាំងការខូចខាតជាក់ស្តែងជូន គឃ/សប ។

១១.៧.២.២ ប្រមូល និងវេចខ្ចប់រាល់សម្ភារៈ ឯកសារនៅសេសសល់ទាំងអស់ ដែលអមដោយរបាយការណ៍ខាងលើ រួចបញ្ជូន និងប្រគល់ជូន គឃ/សប ។

១១.៧.២.៣ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនពីរ (២) ច្បាប់ សម្រាប់ ប្រើនៅពេលប្រគល់ ទទួលសម្ភារៈ ឯកសារនៅ គឃ/សប ។

១១.៧.៣ នៅពេលប្រគល់របាយការណ៍ និងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ខាងលើ ប្រធាន គឃ/សប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈទាំងពីរ (២) ច្បាប់ រួចប្រគល់ជូនប្រធាន គកប វិញមួយ (១) ច្បាប់ ។

១១.៧.៣.១ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃ ជាសាក្សីលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះ ឆ្នោតខាងលើ ។

១១.៧.៣.២ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ ពីភ្នាក់ងារគណបក្ស នយោបាយ មិនអាចចាត់ទុកជាមោឃៈនូវលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈនេះបានទេ ។

១១.៧.៤ នៅពេលទទួលបានរបាយការណ៍ដូចចែងក្នុងចំណុច ១១.៧.៣ ខាងលើ គឃ/សប ត្រូវបន្តលើកយោបល់ស្នើជាបន្ទាន់ទៅ គធ/ខប និង គ.ជ.ប សុំឱ្យមានការ បោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

១១.៧.៥ ក្នុងករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន ដែលកើតឡើងនៅក្រោយ ពេល គកប បានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធី ដូចចែងក្រោមប្រការ ១១.១ ខាងលើ ហើយប្រសិនបើ គ្រោះអាសន្ននោះមិនបានបណ្តាលឱ្យខូចខាតដល់ហិប ឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងរាល់កំណត់ហេតុនៃការបោះឆ្នោតទេ ប្រធាន គកប ត្រូវចាត់ចែងជាបន្ទាន់ ដូចខាងក្រោម ៖

១១.៧.៥.១ ថែរក្សាហិបឆ្នោតដែលបានបិទភ្ជិត និងចាក់សោឃ្លុំរួច ដូចបញ្ជាក់ក្នុងចំណុច ១១.១.១.២ ខាងលើ ឱ្យបានឬ្ចត់ចត់ត្រៀមសម្រាប់ការបញ្ជូនទៅ គឃ/សប ។

១១.៧.៥.២ រៀបចំស្រោមសំបុត្រកំណត់ហេតុនៃការបោះឆ្នោត ដូចចែងក្នុងចំណុច ១១.១.៤ និងវេចខ្ចប់រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារៈ ឯកសារ ដូចចែងក្រោមចំណុច ១១.១.៥ ខាងលើទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ប៉ុន្តែមិនចាំបាច់បិទភ្ជិតដោយការសុវត្ថិភាពនៅពេលនេះទេ បន្ទាប់មក ត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

១១.៧.៥.៣ វេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចចែងក្នុងចំណុច ១១.១.៤.២ និង ១១.១.៤.៣ ខាងលើ ព្រមទាំងស្រោមសំបុត្រដាក់ត្រា គកប (បន្ទាប់ពីបោះត្រាលើ ទ.១១០៧ រួច) ទៅក្នុងកញ្ចប់ " ខ " ហើយចងភ្ជិត និងចាក់សោឃ្លុំ ។

១១.៧.៥.៤ ប្រមូល និងវេចខ្ចប់រាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ទាំងអស់ដោយឡែក ។

១១.៧.៥.៥ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនពីរ (២) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ ទទួលនៅ គឃ/សប ។

១១.៧.៥.៦ បញ្ជូន និងប្រគល់ហិបឆ្នោត កញ្ចប់ " ខ " និងរាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ខាងលើជូន គឃ/សប ។ ប្រធានដោយមានអនុប្រធាន និងសមាជិក គកប មួយចំនួនទៀតអមដំណើរផង ត្រូវទទួលបន្ទុកក្នុងការបញ្ជូន និងប្រគល់ ទទួលនេះដោយផ្ទាល់ ព្រមទាំងត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួម និងត្រូវស្នើសុំកម្លាំងសន្តិសុខពីរ (២) នាក់ឱ្យជួយការពារ និងជូនដំណើរនេះ ។

១១.៧.៦ នៅពេលទទួលហិបឆ្នោតមានសន្លឹកឆ្នោតនៅខាងក្នុង កញ្ចប់ " ខ " និងរាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ខាងលើ ប្រធាន គឃ/សប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលទាំងពីរ (២) ច្បាប់ រួចប្រគល់ជូនប្រធាន គកប វិញមួយ (១) ច្បាប់ ។

១១.៧.៦.១ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្ដិតមេដៃជាសាក្សី លើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោតខាងលើ ។

១១.៧.៦.២ ការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃពីភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកជាមោឃៈនូវលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈនេះបានទេ ។

១១.៧.៧ បន្ទាប់ពីបានទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ដែលមានករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្នភ្លាម គឃ/សប ត្រូវធ្វើការកត់ចំណាំ និងរក្សាទុកដោយឡែកនៅកន្លែងមានសុវត្ថិភាព និងត្រូវជូនដំណឹងដល់សមាសភាព គកប ពាក់ព័ន្ធឱ្យមកកាន់ទីស្នាក់ការ គឃ/សប នៅវេលាម៉ោងប្រាំពីរ (៧:០០) ព្រឹកនៃថ្ងៃបន្ទាប់ ដើម្បីរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតរបស់ខ្លួន ។

១១.៧.៧.១ គឃ/សប អាចចាត់តែងសមាសភាព គកប ផ្សេង ឬសមាជិក គឃ/សប ឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ប្រសិនបើសមាសភាព គកប ពាក់ព័ន្ធអវត្តមាន។

១១.៧.៧.២ សមាសភាព គកប ដែលត្រូវបំពេញភារកិច្ច រាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ/សប ត្រូវតែបានទទួលប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ និងម្ហូបអាហារក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនោះ ។

១១.៧.៨ ទោះបីជា គឃ/សប បានទទួលកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងរាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ ដូចចែងក្រោមប្រការ ១១.៥ និង ១១.៦ ខាងលើ បានគ្រប់ ឬមិនទាន់គ្រប់ការិយាល័យបោះឆ្នោតក្ដី នៅព្រឹកថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត គឃ/សប ត្រូវចាត់ចែងឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលជួបករណីប្រធានស័ក្តិ ឬកាលៈទេសៈមានអាសន្ន ដូចបញ្ជាក់ក្នុងចំណុច ១១.៧.៧ ខាងលើ នៅទីស្នាក់ការរបស់ខ្លួន ឬនៅទីតាំងណាមួយដែលមានសុវត្ថិភាព ។

១១.៧.៩ នៅពេលសមាសភាព គករ ឬមន្ត្រីបោះឆ្នោត ដែលទទួលភារកិច្ចរាប់សន្លឹកឆ្នោតមានវត្តមាននៅក្នុងបន្ទប់រាប់សន្លឹកឆ្នោតហើយប្រធានគឃ/សបត្រូវប្រគល់ហិបឆ្នោត

ដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងកញ្ចប់ " ខ " ដែលមានកញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀត ឱ្យទៅប្រធាន គកស ដើម្បីអនុវត្តការរាប់សន្លឹកឆ្នោត ។ ប្រធាន គកស ត្រូវ ៖

១១.៧.៩.១ ពិនិត្យឱ្យប្រាកដថា ហិបឆ្នោតមានសន្លឹកឆ្នោតនៅខាងក្នុង និងកញ្ចប់ " ខ " ដែលបានទទួលពុំត្រូវបានគេរុះរើឡើយ ។

១១.៧.៩.២ កាត់ផ្តាច់សោឃ្លុំកញ្ចប់ " ខ " និងត្រួតពិនិត្យសម្ភារៈ ឯកសារបោះឆ្នោតខាងក្នុង ដោយផ្ទៀងផ្ទាត់ទៅនឹងលិខិតបញ្ជូន និងប្រគល់ទទួល (ទ. ១១០៧) ។

១១.៧.១០ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតខាងលើ រាល់បទបញ្ញា និងនីតិវិធី ដែលបានចែងក្រោមប្រការ ១១.២ ១១.៣ ១១.៤ និង ១១.៥ ខាងលើ ត្រូវតែបានអនុវត្ត ។ ដោយសារការរាប់សន្លឹកឆ្នោតនេះ ត្រូវបានធ្វើនៅទីស្នាក់ការ គឃ/សប នីតិវិធីពាក់ព័ន្ធមួយចំនួនត្រូវបានកំណត់ឱ្យអនុវត្តដោយឡែក ដែលក្នុងនោះ ប្រធាន គកស ត្រូវ ៖

១១.៧.១០.១ ទទួលខុសត្រូវនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) មួយ (១) ច្បាប់ ទៅបិទផ្សាយនៅខាងមុខទីតាំងការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

១១.៧.១០.២ បង្គាប់ជំនួយការទី២ ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) មួយ (១)ច្បាប់ នៅខាងមុខទីស្នាក់ការ គឃ/សប ។

១១.៧.១០.៣ ធានាថា បន្ទាប់ពីការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ រាល់សម្ភារៈ ឯកសារបោះឆ្នោតត្រូវបានវេចខ្ចប់ក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រ និងដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " រួចបិទភ្ជិតដោយកាវសុវត្ថិភាពបម្រុងស្រាប់ ។ បន្ទាប់មកកញ្ចប់ " ខ " ត្រូវបានវេចខ្ចប់ជាថ្មីដោយដាក់សម្ភារៈ ឯកសារតាមលំនាំដូចចែងក្នុងចំណុច ១១.៤.៨ ខាងលើ តែមិនចាំបាច់ចាក់សោឃ្លុំទេហើយត្រូវប្រគល់ជូនគឃ/សប ដោយផ្ទាល់នៅបន្ទប់រាប់សន្លឹកឆ្នោតនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

១១.៧.១០.៤ ប្រគល់ហិបឆ្នោតទទេ ជូន គឃ/សប ។

១១.៧.១០.៥ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារ (ទ.១១០៧) ត្រូវបានបំពេញ និងប្រើប្រាស់ក្នុងការប្រគល់ ទទួលស្របតាមការកំណត់របស់ គ.ជ.ប ។

១១.៧.១១ បន្ទាប់មក គឃ/សប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធ្វើការត្រួតពិនិត្យ និង បូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ។

**ការដាក់ពាក្យបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅ គឃ/សប**

**ប្រការ ១១.៨** ភ្នាក់ងារគណបក្សនយោបាយ ដែលមិនសុខចិត្តនឹងការសម្រេចរបស់ គកប ពាក់ព័ន្ធនឹងការជំទាស់ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ នៅក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតដូចចែងក្នុងចំណុច ១០.៦.២២ ឬ/និងក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដូចចែងក្រោមចំណុច ១១.២.៧ ខាងលើ និងដែលបានទទួលទម្រង់បែបបទសម្រាប់ប្តឹងរួចហើយ អាចដាក់ពាក្យប្តឹងទៅ គឃ/សប ។

១១.៨.១ ការដាក់ពាក្យ បណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ត្រូវធ្វើឡើងជាបន្ទាន់ស្របពេលនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតផ្សេងទៀត ទៅ គឃ/សប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោងដប់មួយកន្លះ (១១:៣០) ព្រឹកនៃថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។ ប្រសិនបើក្នុងរយៈពេលកំណត់ខាងលើនេះ គឃ/សប មិនបានទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

១១.៨.២ ភ្នាក់ងារគណបក្សនយោបាយ ដែលមានបំណងប្តឹងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យបណ្តឹងតវ៉ាឬបណ្តឹងជំទាស់(ទម្រង់បែបបទលេខ ១២០២) ចំនួនបី (៣) ច្បាប់ ។ ពាក្យបណ្តឹងត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចមានចែងក្នុងចំណុច ១៦.៣.៥ ប្រការ ១៦.៣ ជំពូកទី ១៦ នៃ ប.ន.ឃ.ស ។

១១.៨.៣ ចំពោះពាក្យបណ្តឹងដែលបានទទួលក្រោយរយៈពេលកំណត់ដូចចែងក្នុងចំណុច ១១.៨.១ ខាងលើ ប្រធាន គឃ/សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គឃ/សប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹងវិញមួយ (១) ច្បាប់ រក្សាទុកជាឯកសារ មួយ (១) ច្បាប់ ផ្ញើជូន គធ/ខប មួយ (១) ច្បាប់ និងប្រាប់អ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គឃ/សប មិនអាចទទួលយកមកដោះស្រាយបានទេ ។

១១.៨.៤ ចំពោះពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ និងគ្មានភស្ដុតាងបញ្ជាក់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយទេ គឃ/សប ត្រូវពិនិត្យសម្រេច ក្នុងនោះប្រធាន គឃ/សប ត្រូវ ៖

១១.៨.៤.១ បង្គាប់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មឱ្យបំពេញសម្រង់សេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ (ទ.១២០៣) ជាបី (៣) ច្បាប់ ដោយមានបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះ និងចុះហត្ថលេខាផង ។

១១.៨.៤.២ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គឃ/សប រួចប្រគល់ឱ្យអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូន គជ/ខប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១១.៨.៤.៣ ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គឃ/សប ទៅ គឃ/សប ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេចបដិសេធ ។

១១.៨.៥ ចំពោះពាក្យបណ្ដឹង ដែលបានទទួលក្នុងរយៈពេលកំណត់ ដូចចែងក្នុងចំណុច ១១.៨.១ ខាងលើ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គឃ/សប លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ឱ្យអ្នកប្ដឹងវិញមួយ (១) ច្បាប់ បិទផ្សាយជាសាធារណៈនៅ គឃ/សប មួយ (១) ច្បាប់ និងទុកមួយ (១) ច្បាប់ សម្រាប់ គឃ/សប ប្រើក្នុងពេលប្រជុំសម្រេច ។ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវជំរាបអ្នកប្ដឹងថា គឃ/សប នឹងធ្វើការត្រួតពិនិត្យឡើងវិញ ព្រមទាំងប្រជុំសម្រេចលើពាក្យបណ្ដឹងពាក់ព័ន្ធ នៅក្នុងអំឡុងពេលនៃសមត្ថកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោតនានាក្នុងឃុំ សង្កាត់ ។

១១.៨.៦ ក្នុងករណីពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់មានពាក់ព័ន្ធនឹងភាពមិនប្រក្រតីណាមួយដែលអាចប៉ះពាល់ដល់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គឃ/សប ត្រូវ ៖

១១.៨.៦.១ ចាត់ចែងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការរាប់សន្លឹកឆ្នោតរបស់ការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្ដឹង ។

១១.៨.៦.២ បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមប្រការ ១១.១២ ។

១១.៨.៦.៣ អនុញ្ញាតឱ្យដើមបណ្ដឹង ភ្នាក់ងារនៃគណបក្សនយោបាយ ដែលឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងអ្នកសង្កេតការណ៍ចូលរួមសង្កេតមើលក្នុងការអនុវត្តនីតិវិធី ចំណុច ១១.៨.៦.១ និង ១១.៨.៦.២ ខាងលើ ។

១១.៨.៧ ប្រសិនបើ ក្នុងការត្រួតពិនិត្យឡើងវិញដូចចែងក្នុងចំណុច ១១.៨.៦.១ និង ១១.៨.៦.២ ខាងលើ គឃ/សប មិនឃើញមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីណាមួយក្នុងប្រតិបត្តិនៃការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គឃ/សប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹងនោះ ។ ក្នុងករណី គឃ/សប បដិសេធលើពាក្យបណ្ដឹង ប្រធាន គឃ/សប ត្រូវ ៖

១១.៨.៧.១ ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យបំពេញសម្រង់សេចក្ដីសម្រេចបដិសេធ លើពាក្យបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ( ទ. ១២០៣) ចំនួនបី (៣) ច្បាប់ ដោយមានបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះផង ។

១១.៨.៧.២ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើសម្រង់សេចក្ដីសម្រេច ដែលសមាជិកទទួលបន្ទុកសេវាកម្មច្បាប់បានបំពេញរួចប្រគល់ឱ្យអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូន គជ/ខប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១១.៨.៧.៣ ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គឃ/សប ទៅ គជ/ខប ក្នុងរយៈពេលបី (៣) ថ្ងៃ យ៉ាងយូរបន្ទាប់ពី គឃ/សប បានបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។

១១.៨.៧.៤ ប្រគល់ជូនអ្នកប្ដឹងតវ៉ានូវទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្ដឹងតវ៉ាចំនួនបី (៣) ច្បាប់ (ប្រសិនបើគាត់ស្នើសុំ) ។

១១.៨.៨ ប្រសិនបើ ក្នុងការត្រួតពិនិត្យឡើងវិញដូចចែងក្នុងចំណុច ១១.៨.៦.១ និង ១១.៨.៦.២ ខាងលើ គឃ/សប បានរកឃើញភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងប្រតិបត្តិការនៃការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ គឃ/សប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹងនោះ ។ ក្នុងករណីគឃ/សប យល់ព្រមតាមពាក្យបណ្ដឹង ប្រធាន គឃ/សប ត្រូវ ៖

១១.៨.៨.១ ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ឱ្យបំពេញសម្រង់សេចក្ដីសម្រេចយល់ព្រមលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ (ទ. ១២០៣) ជាបី (៣) ច្បាប់ ។

១១.៨.៨.២ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ លើសម្រង់សេចក្ដីសម្រេចដែលទើបបានបំពេញ រួចប្រគល់ឱ្យអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូន គធ/ខប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ និងជម្រាបអ្នកប្ដឹងថា គឃ/សប នឹងធ្វើរបាយការណ៍ និងលើកយោបល់ស្ដីពីករណីនេះ ផ្ញើអមជាមួយកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ជូន គធ/ខប ដើម្បីពិនិត្យសម្រេច ។

### ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីនៅមួយ(១)ថ្ងៃ មុនថ្ងៃបោះឆ្នោតទៅ គឃ/សប

**ប្រការ ១១.៩** នីតិវិធីដូចបានចែងក្រោមប្រការ ១១.៨ ខាងលើ ក៏មានសុពលភាពផងដែរសម្រាប់បណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ដែលបានកើតមានឡើង នៅក្នុងតំបន់បោះឆ្នោតណាមួយនៅមួយ (១)ថ្ងៃ មុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត ។

១១.៩.១ អំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដូចបញ្ជាក់ក្នុងប្រការ ១១.៩ ខាងលើ ត្រូវបានកំណត់ជាក់ស្ដែងតាមរយៈកិច្ចសង្កេតការណ៍ ឬការរាយការណ៍ ឬការចោទប្រកាន់ដោយមានភស្តុតាងគ្រប់គ្រាន់ ដែលរួមមានប្រភេទបទរំលោភដូចខាងក្រោម ៖

១១.៩.១.១ ការប្រើកម្លាំងដកហូតឯកសារបញ្ជាក់អត្តសញ្ញាណពីអ្នកបោះឆ្នោត។

១១.៩.១.២ ការប្រើកម្លាំង ឬអំពើហិង្សា ដើម្បីរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ។

១១.៩.១.៣ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំអ្នកបោះឆ្នោតឱ្យស្បថថានឹងបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ។

១១.៩.១.៤ ការធ្វើឱ្យខូចរបៀបរៀបរយ ឬការអុកឡុករំខានកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតមិនឱ្យដំណើរការបាន ។

១១.៩.១.៥ ការញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង ឬអំពើហិង្សាទៅលើបេក្ខជននៃគណបក្សនយោបាយណាមួយ ។

១១.៩.១.៦ ការប្រើកម្លាំង ឬអំពើហិង្សា ឬការបំភិតបំភ័យដែលបង្កឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ភាពច្របូកច្របល់ និងការបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

១១.៩.១.៧ ការបោកបញ្ឆោត ឬការលួងលោមទិញសន្លឹកឆ្នោត ដោយសម្ភារៈ ឬប្រាក់កាស ។

១១.៩.២ រូបភាពនៃការបំភិតបំភ័យ ការគាបសង្កត់ ការគំរាមកំហែង ការប្រើកម្លាំង ឬអំពើហិង្សា ការរំលោភបំពាន ឬការគំរាមកំហែងដោយហិង្សា ត្រូវបានកំណត់តាមរយៈការស្តែងឡើង ដោយពាក្យសម្តី ជាលាយលក្ខណ៍អក្សរ ឬដោយកាយវិការដូចខាងក្រោម ៖

១១.៩.២.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬដោយការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិតរូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។

១១.៩.២.២ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថានឹងធ្វើទារុណកម្ម ។

១១.៩.២.៣ ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរ ។

១១.៩.២.៤ ការរំលោភដោយពាក្យសម្តីថា នឹងធ្វើទុក្ខទោសដល់រាងកាយ ។

១១.៩.២.៥ ការបង្ហាញ ឬការប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។

១១.៩.២.៦ ការលើកឡើង ជាពាក្យសម្តី ជាលាយលក្ខណ៍អក្សរ ដោយយកព្រឹត្តិការណ៍គួរឱ្យតក់ស្លុតពីអតីតកាលមកតំណាល ដូចជាឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ។

១១.៩.២.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាល ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ។

១១.៩.២.៨ ការយកសាកសពសត្វធាតុ ឬឧបករណ៍ណាមួយ ឬធ្វើសញ្ញាណាមួយ ទៅដាក់មុខផ្ទះអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ដែលអាចធ្វើឱ្យអ្នកបោះឆ្នោតនោះ ឬបេក្ខជននោះ មានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូន គ្រួសាររបស់ខ្លួន ។

១១.៩.២.៩ ការបណ្តើរ ឬបង្ខាំងអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ដោយបង្ខំដែលធ្វើឱ្យអារម្មណ៍របស់អ្នកទាំងនោះមានការភ័យខ្លាច ចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬគ្រួសាររបស់ខ្លួន ។

១១.៩.២.១០ ការប្រើភាសា អសីលធម៌ បង្ហាញពីការគំរាមកំហែង ។

១១.៩.២.១១ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬការធ្វើឱ្យខូចប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

១១.៩.២.១២ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំឱ្យធ្វើសម្បថ ឬផ្តិតមេដៃសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។

១១.៩.២.១៣ ការប្រមូល ឬដកហូតឯកសារបញ្ជាក់អត្តសញ្ញាណ ដែលត្រូវប្រើសម្រាប់បោះឆ្នោត ។

**កិច្ចប្រតិបត្តិការរបស់ គឃ/សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត**

**ប្រការ** ១១.១០ បន្ទាប់ពីបានទទួលកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធពីគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំណុះឃុំ សង្កាត់ ដូចបានបញ្ជាក់ក្នុងចំណុច ១១.៥.៤ ១១.៦.៧ ១១.៧.៦ និង ១១.៧.១០.៣ ខាងលើ គឃ/សប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនានាក្នុងឃុំ សង្កាត់ បញ្ចូលគ្នាឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើបាន និងមិនត្រូវឱ្យហួសរយៈពេលបី (៣) ថ្ងៃឡើយ ។

១១.១០.១ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងរាល់ដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំណុះឃុំ សង្កាត់ ។

១១.១០.១.១ ភ្នាក់ងារគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃអង្គការនីមួយៗ ប្រចាំការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ត្រូវជ្រើសតាំងឱ្យមានតំណាងរបស់ខ្លួនម្នាក់ និងតំណាងបម្រុងម្នាក់ សម្រាប់ចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គឃ/សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។

១១.១០.១.២ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលដំណើរការ នៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ខាងលើ អាចផ្លាស់ប្ដូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួន ។

១១.១០.១.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មម ដែលអាចសង្កេតមើលឃើញ នូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។

១១.១០.២ កិច្ចប្រតិបត្តិការរបស់ គឃ/សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតចំពោះការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយមិនគិតពីពេលវេលាឡើយ ។ គឃ/សប ត្រូវត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ពីគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ ដែលក្នុងនោះរួមបញ្ចូលទាំងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតរបស់ការិយាល័យ ដែលត្រូវបានរាប់នៅទីស្នាក់ការ គឃ/សប (ប្រសិនបើមាន) និងដែលត្រូវបាន គឃ/សប បើក កញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយផ្អែកលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ (ប្រសិនបើមាន) ។

១១.១០.៣ គឃ/សប ត្រូវបើកកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅទីស្នាក់ការរបស់ខ្លួន ឬនៅអគារណាមួយ ដែលតម្រូវឱ្យមានបរិវេណសន្តិសុខធានាបានសុវត្ថិភាពល្អ ហើយត្រូវរៀបចំបន្ទប់តាមលំនាំគំរូប្លង់បន្ទប់រាប់សន្លឹកឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ១១.២.១.១ ខាងលើ ។ ក្នុងការត្រួតពិនិត្យ និងបូកសរុបខាងលើនេះ ប្រធាន គឃ/សប ត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យសមាជិកទទួលបន្ទុករដ្ឋបាលអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយឱ្យអនុប្រធាន និងសមាជិកទទួលបន្ទុកសេវាកម្មច្បាប់អង្គុយនៅអមសងខាងតុទល់មុខគ្នា ។ ចំណែកសមាជិកទទួលបន្ទុកបណ្ដុះបណ្ដាលត្រូវទទួលបន្ទុកការពារមាត់ទ្វារ និងរក្សាសណ្ដាប់ធ្នាប់ក្នុងបន្ទប់ត្រួតពិនិត្យ បូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត។ ប្រធាន គឃ/សប ត្រូវ ៖

១១.១០.៣.១ ត្រៀមនៅលើតុខាងមុខគាត់នូវ ៖

ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹងដែលត្រូវប្រគល់ជូនភ្នាក់ងារគណបក្សនយោបាយតាមសំណើសុំ ។

ម៉ាស៊ីនគិតលេខមួយ (១) គ្រឿង ។

សម្ភារៈ ឯកសារចាំបាច់ផ្សេងទៀត ។

១១.១០.៣.២ ប្រគល់ជូនអនុប្រធាននូវ ទម្រង់បែបបទលេខ ១១០៩ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងទម្រង់បែបបទចាំបាច់ ផ្សេងទៀតសម្រាប់ប្រើក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនេះ ។

១១.១០.៣.៣ ប្រគល់ជូនសមាជិកទទួលបន្ទុករដ្ឋបាល នូវទម្រង់បែបបទលេខ ១១០៣ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ទម្រង់បែបបទលេខ ១១០៩ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងទម្រង់បែបបទចាំបាច់ផ្សេងទៀត សម្រាប់ប្រើក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនេះ ។

១១.១០.៣.៤ ប្រគល់ជូនសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ នូវទម្រង់បែបបទលេខ ១១០៩ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងទម្រង់បែបបទចាំបាច់ផ្សេងទៀតសម្រាប់ប្រើក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនេះ ។

**ប្រការ ១១.១១** ក្នុងករណីឃុំ សង្កាត់ណាគ្មានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ ឬមានបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ដែលបានដាក់មិនទាន់ពេលវេលាកំណត់ ឬមានបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ដែលគ្មានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតី នាំឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយទេនោះ គឃ/សប មិនអាចបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតទេ ។ ក្នុងករណីនេះ គឃ/សប ត្រូវចាត់ចែងត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ចំណុះឃុំ សង្កាត់ បញ្ចូលគ្នាជាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។

១១.១១.១ ក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ចំពោះករណីដូចចែងក្នុងប្រការ ១១.១១ ខាងលើនេះ គឃ/សប គ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ និងគណនាដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតប៉ុណ្ណោះ ។ ប្រធាន គឃ/សប ត្រូវ ៖

១១.១១.១.១ បង្គាប់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ឱ្យនាំយកកញ្ចប់ " ខ " ដែលដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតម្ដងមួយៗ ពីកន្លែងរក្សាទុក មកដាក់នៅលើតុចំមុខប្រធាន ។

១១.១១.១.២ បើកកញ្ចប់ " ខ " រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ. ១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) ផ្ញើជូន គឃ/សប ដាក់នៅលើតុ បន្ទាប់មកដកយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) មួយ (១) ច្បាប់ក្នុងចំណោមពីរ (២) ច្បាប់ ដែលមានក្នុងស្រោមសំបុត្រនោះ និងប្រគល់ឱ្យសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ យកទៅបិទផ្សាយនៅខាងមុខទីស្នាក់ការ គឃ/សប ។

១១.១១.១.៣ ដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតផ្ញើជូន គជ/ខប ពីក្នុងកញ្ចប់ " ខ " ដាក់ទៅក្នុងកញ្ចប់ " គពិសេស " ដែលត្រៀមបម្រុងជាស្រេច ដូចចែងក្នុងចំណុច ១១.១១.៦ ខាងក្រោម បន្ទាប់មកដាក់កញ្ចប់ " ខ " ដែលមានកញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់ត្រាគកប នៅសល់ខាងក្នុងនៅក្បែរខ្លួនគាត់ ។

១១.១១.១.៤ ត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបតួលេខដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ. ១១០១) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) នៃការិយាល័យបោះឆ្នោតនីមួយៗ រួចធ្វើការប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធ ដែលមានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីឱ្យដឹងប្រាកដថា លទ្ធផលដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុងការគណនាលេខណាមួយ ។

១១.១១.១.៥ សម្រេចកែតម្រូវតួលេខលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ នៅចំពោះមុខភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ប្រសិនបើបានរកឃើញថា គកប/គករ មានកំហុសក្នុងការគណនាលេខ ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធាន គឃ/សប ត្រូវឆូតលុបតួលេខ ដែល

ខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធាន គឃ/សប ផង ។ ក្នុងករណីនេះ ត្រូវឱ្យសមាជិកទទួលបន្ទុករដ្ឋបាលកត់ត្រាអំពីបញ្ហានេះ នៅក្នុងកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំសង្កាត់ (ទ. ១១០៣) ផង ។

១១.១១.១.៦ ស្រង់ និងហៅតួលេខសន្លឹកឆ្នោតបានការ ដែលគាំទ្រគណបក្សនយោបាយនីមួយៗ សន្លឹកឆ្នោតមិនបានការ ទិន្នន័យ និងតួលេខពាក់ព័ន្ធផ្សេងទៀត ដែលបានពិនិត្យត្រឹមត្រូវហើយ ពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ហើយណែនាំអនុប្រធាន សមាជិកទទួលបន្ទុករដ្ឋបាល និងសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យកត់ត្រាតួលេខទាំងនេះទៅក្នុងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ (ទ. ១១០៩) ។

១១.១១.១.៧ ធានាថារាល់កំណត់ហេតុនៃការបោះឆ្នោត (ទ. ១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ. ១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ. ១១០៨) នៃការិយាល័យបោះឆ្នោតនីមួយៗ ដែលបានប្រើប្រាស់ក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលខាងលើនេះរួច ត្រូវតែបានដាក់ទៅក្នុងស្រោមសំបុត្រដដែលវិញ និងចងក្រងទុកជាឯកសាររបស់ គឃ/សប ។

១១.១១.១.៨ ចាត់ចែងសមាជិក គឃ/សប ឱ្យវេចខ្ចប់កញ្ចប់ " ខ " ឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់ត្រា គកប បន្ទាប់មក ឱ្យនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គធ/ខប ។

១១.១១.២ ប្រធាន គឃ/សប ត្រូវធានាថា នីតិវិធីទាំងឡាយដូចចែងក្រោមចំណុច ១១.១១.១ ខាងលើ ត្រូវតែបានអនុវត្តដូចគ្នា សម្រាប់កញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត របស់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតម្ដងមួយៗ រហូតដល់អស់កញ្ចប់ " ខ " នៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់ ។

១១.១១.៣ ប្រធាន គឃ/សប ត្រូវធានាថា តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) ទាំងបី (៣) ច្បាប់ ដែលអនុប្រធាន សមាជិក

ទទួលបន្ទុករដ្ឋបាល និងសមាជិកទទួលបន្ទុកសេវាកម្មច្បាប់បានកត់ត្រាតួលេខលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត ពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវបានគណនាសរុបដោយប្រើប្រមាណវិធីដោយដៃផង និងប្រើម៉ាស៊ីនគិតលេខផង ។ តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ទាំងបី (៣) ច្បាប់នោះត្រូវតែបានពិនិត្យផ្ទៀងផ្ទាត់ជាមួយគ្នាឡើងវិញឱ្យបានត្រឹមត្រូវ និងចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គឃ/សប ហើយដែលត្រូវផ្ញើជូន គធ/ខប មួយ (១) ច្បាប់ ជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១១.១១.៤ ប្រធាន គឃ/សប ត្រូវធានាថាសមាជិកទទួលបន្ទុករដ្ឋបាល បានបំពេញកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់(ទ. ១១០៣) ជាបួន (៤) ច្បាប់ ដោយបញ្ជាក់ច្បាស់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ទិន្នន័យ និងតួលេខពាក់ព័ន្ធផ្សេងទៀត ព្រមទាំងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលបានគណនាសរុបត្រឹមត្រូវរួចហើយ ដូចចែងក្នុងចំណុច ១១.១១.៣ ខាងលើ ។ កំណត់ហេតុនេះ ត្រូវតែបានចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាលនិងប្រធាន គឃ/សបនិងត្រូវដាក់បង្ហាញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ ។

១១.១១.៤.១ ភ្នាក់ងារនៃគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី លើកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់( ទ. ១១០៣ ) ។

១១.១១.៤.២ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានទេ ។

១១.១១.៥ ប្រធាន គឃ/សប ត្រូវរៀបចំបែងចែក និងប្រើប្រាស់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) ដូចចែងក្នុងចំណុច ១១.១១.៤ ខាងលើ ដូចខាងក្រោម ៖

១១.១១.៥.១ បិទផ្សាយមួយ (១) ច្បាប់ នៅខាងមុខទីស្នាក់ការ គឃ/សប និងត្រូវធ្វើកំណត់ហេតុស្តីពីការបិទផ្សាយ ដោយបញ្ជាក់ច្បាស់ពីពេលវេលា និងកាលបរិច្ឆេទនៃការបិទផ្សាយនេះផង ។ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃលើ

កំណត់ហេតុ ស្តីពីការបិទផ្សាយនេះ ប៉ុន្តែការមិនព្រមចុះហត្ថលេខា ឬ ផ្តិតមេដៃរបស់ភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកកំណត់ហេតុនេះ ជាមោឃៈបានទេ ។

១១.១១.៥.២ ផ្ញើជូន គធ/ខប មួយ (១) ច្បាប់ ដែលត្រូវដាក់រួមជាមួយតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) មួយ (១) ច្បាប់ និងកំណត់ហេតុស្តីពីការបិទផ្សាយ ដូចចែងក្នុងចំណុច ១១.១១.៥.១ ខាងលើ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្វងថា " កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) ផ្ញើជូន គធ/ខប " ។

១១.១១.៥.៣ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ដែលត្រូវដាក់រួមជាមួយតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) មួយ (១) ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្វងថា " កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) ផ្ញើជូន គ.ជ.ប " ។

១១.១១.៥.៤ រក្សាទុកមួយ (១) ច្បាប់ ជាឯកសាររបស់ គឃ/សប ។

១១.១១.៦ ប្រធាន គឃ/សប ត្រូវត្រៀមកញ្ចប់ " គពិសេស " មួយ ដែលត្រូវដាក់រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតសម្រាប់ផ្ញើជូន គធ/ខប និងផ្ញើជូន គ.ជ.ប តាមរយៈ គធ/ខប ។ ប្រធាន គឃ/សប ត្រូវប្រមូល និងចងជាបាច់ទៅតាមមុខឯកសារ និងគោលដៅដែលត្រូវទទួល ហើយរៀបចំដាក់ទៅក្នុងកញ្ចប់ " គពិសេស " នូវ ៖

១១.១១.៦.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតផ្ញើជូន គធ/ខប ដែលត្រូវដកយកពីកញ្ចប់ " ខ " នៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ ។

១១.១១.៦.២ រាល់ស្រោមសំបុត្រ ដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដូចចែងក្នុងចំណុច ១១.១១.៥.២ និង ១១.១១.៥.៣ ខាងលើ ។

១១.១១.៦.៣ ស្រោមសំបុត្រតែមួយដាក់រាល់ឯកសារពាក់ព័ន្ធនឹងបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលត្រូវផ្ញើជូន គធ/ខប ។

១១.១១.៦.៤ ក្នុងករណី ឃុំ សង្កាត់ណាមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលតម្រូវឱ្យមានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត នៅការិយាល័យមួយ ឬច្រើន ប្រធាន ត្រូវធានាថា ស្រោមសំបុត្រដាក់របាយការណ៍ផ្ញើជូន គធ/ខប ដូចចែងក្នុងចំណុច ១១.១២.៣.២ ខាងក្រោម ត្រូវតែបានកិបភ្ជាប់ទៅនឹងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដូចចែងក្នុងចំណុច ១១.១១.៥.២ ខាងលើ ។

១១.១១.៧ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវកត់ចម្លងឱ្យបានត្រឹមត្រូវនូវតួលេខលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធពីកំណត់ហេតុដែលបានបិទផ្សាយ ដូចចែងក្នុងចំណុច ១១.១១.៥.១ ខាងលើ ។

**ប្រការ ១១.១២** ក្នុងករណី ឃុំ សង្កាត់ណាមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចចែងក្នុងប្រការ ១១.៨ និង ១១.៩ ដែលត្រូវបានដាក់ពាក្យប្តឹងក្នុងអំឡុងពេល ដូចចែងក្នុងចំណុច ១១.៨.១ ខាងលើ គឃ/សឃ ក៏ត្រូវធ្វើការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតរបស់ការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ចំណុះឃុំ សង្កាត់បញ្ចូលគ្នាជាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផងដែរ ដោយត្រូវអនុវត្តតាមនីតិវិធី ក្នុងជំពូកនេះ ចាប់ពីចំណុច ១១.១១.១ ដល់ ១១.១១.៦ ខាងលើ ។ ប្រសិនបើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់មិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ និងគ្មានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីណាមួយដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់ទេនោះ គឃ/សឃ ត្រូវចាត់ចែងត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត នៅការិយាល័យពាក់ព័ន្ធតាមនីតិវិធីជាធម្មតា ដោយមិនចាំបាច់បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតទេ ។

១១.១២.១ ប្រសិនបើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ មានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ អាចនាំឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន គឃ/សឃ អាចបើកកញ្ចប់

សុវត្ថិភាព " ក " នៃការិយាល័យពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតផង ។ ក្នុងករណីនេះ នៅពេលកំពុងអនុវត្តនីតិវិធីដូចចែងក្រោមចំណុច ១១.១១.១ ខាងលើ ប្រធាន គយ/សប ត្រូវ ៖

១១.១២.១.១ ដកយកកញ្ចប់សុវត្ថិភាព " ក " ពីក្នុងកញ្ចប់ " ខ " មកដាក់នៅលើតុ ។

១១.១២.១.២ ប្រើកន្ត្រៃកាត់បើកកញ្ចប់សុវត្ថិភាព " ក " រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារៈ ឯកសារបោះឆ្នោតទាំងអស់ដែលមាននៅខាងក្នុងមកដាក់ដោយឡែកពីគ្នានៅលើតុខាងមុខគាត់ ។

១១.១២.១.៣ ប្រគល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ឱ្យទៅសមាជិកទទួលបន្ទុករដ្ឋបាលសម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។

១១.១២.១.៤ បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារៈ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីពិនិត្យផ្ទៀងផ្ទាត់តាមនីតិវិធី ដូចចែងក្រោមចំណុច ១១.១២.២ ខាងក្រោម ។

១១.១២.២ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធាន គយ/សប ត្រូវចាត់ចែងឱ្យត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យនោះដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ និងបញ្ហាជារួមដូចខាងក្រោម ៖

១១.១២.២.១ ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១១.១២.២.២ ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ។

១១.១២.២.៣ ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានមកបោះឆ្នោត ។

១១.១២.២.៤ ពិនិត្យផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោត ដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ ។

១១.១២.២.៥ រាប់ចំនួនសន្លឹកឆ្នោតខូច (ប្រសិនបើមាន) ។

១១.១២.២.៦ រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ ។

១១.១២.២.៧ ពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ ។

១១.១២.២.៨ ពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ ។

១១.១២.៣ បន្ទាប់ពីអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ដូចចែងក្រោមចំណុច ១១.១២.២ ខាងលើរួចរាល់ហើយ ប្រធាន គឃ/សប ត្រូវ ៖

១១.១២.៣.១ ធ្វើរបាយការណ៍ និងលើកយោបល់ពាក់ព័ន្ធនឹងលទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតខាងលើ ដោយស្នើសុំ គជ/ខប ពិនិត្យសម្រេចព្យួរលទ្ធផលបោះឆ្នោតជាបណ្ដោះអាសន្ន ឬយល់ព្រមទទួលយកលទ្ធផលបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។ របាយការណ៍នេះត្រូវធ្វើជាពីរ (២) ច្បាប់ និងចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គឃ/សប ។

១១.១២.៣.២ ដាក់រាល់របាយការណ៍ដូចចែងក្នុងចំណុច ១១.១២.៣.១ មួយ (១) ច្បាប់ ទៅក្នុងស្រោមសំបុត្ររួចកាខ្វែងថា " របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ផ្ញើជូន គជ/ខប " ដែលត្រូវកិបភ្ជាប់ទៅនឹងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដូចចែងក្នុងចំណុច ១១.១១.៥.២ ខាងលើ ហើយដែលត្រូវដាក់ទៅក្នុងកញ្ចប់ " គពិសេស " ដូចបញ្ជាក់ក្នុងចំណុច ១១.១៣.១ ខាងក្រោម ។

១១.១២.៣.៣ រក្សាទុករបាយការណ៍ដូចចែងក្នុងចំណុច ១១.១២.៣.១ មួយ (១) ច្បាប់ជាឯកសារ ។

១១.១២.៣.៤ ដាក់សម្ភារៈ ឯកសារបោះឆ្នោត ដែលបានពិនិត្យផ្ទៀងផ្ទាត់ទៅក្នុងស្រោមសំបុត្រ និងស្បោងប្លាស្ទិកនានា រួចវេចខ្ចប់ក្នុងកញ្ចប់សុវត្ថិភាព " ក " ឡើងវិញ តាមលំនាំដើមដូចចែងក្នុងចំណុច ១១.៩.២ ខាងលើ ។

១១.១២.៣.៥ វេចខ្ចប់ដាក់ក្នុងកញ្ចប់ " ខ " ឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់ត្រា គកប រួចនាំយកទៅរក្សាទុកនៅកន្លែងដើមត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គធ/ខប ។

១១.១២.៤ នៅពេលបញ្ចប់ការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់រួចរាល់ហើយ ប្រធាន គឃ/សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង ដោយត្រូវអនុវត្តនីតិវិធីដូចចែងក្រោមចំណុច ១១.៨.៥ និង ១១.៨.៦ ខាងលើ ។

**ប្រការ** ១១.១៣ បន្ទាប់ពីបានអនុវត្តនីតិវិធីដូចចែងក្នុងប្រការ ១១.១១ និង ១១.១២ នៃជំពូកនេះចប់សព្វគ្រប់ហើយ ប្រធាន គឃ/សប ត្រូវធានាថា កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងរាល់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ត្រូវតែបានវេចខ្ចប់ក្នុងកញ្ចប់ " គពិសេស" និងកញ្ចប់ " គ " រួចប្រគល់ជូន គធ/ខប បានយ៉ាងត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបានទទួលកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ ។ ក្នុងករណី ឃុំ សង្កាត់ណាមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដែលតម្រូវឱ្យមានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត នៅការិយាល័យមួយ ឬច្រើន ប្រធាន គឃ/សប ត្រូវធានាថា រាល់កញ្ចប់ " ខ " ដាក់កញ្ចប់សុវត្ថិភាព " ក " ដែលបានបើកត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនោះ ត្រូវតែបានវេចខ្ចប់ក្នុងកញ្ចប់ " **គ** " ដោយឡែក ។

១១.១៣.១ ប្រធាន គឃ/សប ត្រូវធានាដាក់ទៅក្នុងកញ្ចប់ " គពិសេស " ឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវនៅមុនពេលបិទភ្ជិត នូវរាល់ស្រោមសំបុត្រមានកំណត់ហេតុ របាយការណ៍ និងឯកសារបោះឆ្នោតដែលត្រូវផ្ញើជូន គធ/ខប និង គ.ជ.ប ដូចខាងក្រោម ៖

១១.១៣.១.១ ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) មួយ (១) ច្បាប់ តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) មួយ (១) ច្បាប់ និងកំណត់ហេតុស្តីពីការបិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ មួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ។

១១.១៣.១.២ របាយការណ៍របស់ គឃ/សប លើកស្នើយោបល់ជូន គធ/ខប ដើម្បីពិនិត្យសម្រេចទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យដែលមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " ត្រូវបានបើកត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមចំណុច ១១.១២.៣ ខាងលើ (ប្រសិនបើមាន) ។

១១.១៣.១.៣ ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) មួយ (១) ច្បាប់ និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) មួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប ។

១១.១៣.១.៤ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត (ទ. ១១០១ និង ១១០២) តាមការិយាល័យបោះឆ្នោតនីមួយៗ មួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ដែលត្រូវដកចេញពីក្នុងកញ្ចប់ " ខ " ។

១១.១៣.១.៥ រាល់ឯកសារពាក់ព័ន្ធនឹងបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ (ប្រសិនបើមាន) ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រតែមួយ និងកាខ្ចង ផ្ញើជូន គធ/ខប ។

១១.១៣.១.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) មួយ (១) ច្បាប់ ។

១១.១៣.២ ប្រធាន គឃ/សប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូននិងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនបី (៣) ច្បាប់ ដោយមានសរសេររាយមុខសម្ភារៈ ឯកសារដែលបានដាក់ក្នុងកញ្ចប់ " គពិសេស " ខាងលើ ហើយត្រូវដាក់មួយ (១) ច្បាប់ទៅក្នុងកញ្ចប់ " គពិសេស " ដាក់មួយ (១) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " គពិសេស " និងរក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោតនៅ គធ/ខប ។

១១.១៣.៣ ប្រធាន គឃ/សប ត្រូវបិទភ្ជិតកញ្ចប់ " គពិសេស " រួចហើយត្រូវសរសេរសម្គាល់លេខកូដឃុំ សង្កាត់របស់ខ្លួន នៅលើផ្នែកខាងក្រៅនៃកញ្ចប់ " គពិសេស " ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ។

១១.១៣.៤ បន្ទាប់មក ប្រធាន គឃ/សប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ដែលគ្មានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ និងដែលមានបណ្ដឹង ប៉ុន្តែគ្មានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមប្រការ ១១.១១ ខាងលើ ដោយដាក់ទៅក្នុងកញ្ចប់ " **គ** " តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់កញ្ចប់ " ខ" ទាំងនោះ ។ ក្នុងការវេចខ្ចប់នេះ គឃ/សប ត្រូវ ៖

១១.១៣.៤.១ ដាក់កញ្ចប់ " ខ " តាមលំដាប់លេខរៀងនៃលេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទៅក្នុងកញ្ចប់ " **គ** " នីមួយៗ ។

១១.១៣.៤.២ ធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនបី (៣) ច្បាប់ ត្រូវបានបំពេញ ដោយមានរាយមុខសម្ភារៈ ឯកសារដែលបានដាក់ក្នុងកញ្ចប់ " **គ** " នីមួយៗ ហើយត្រូវដាក់មួយ (១) ច្បាប់ ទៅក្នុងកញ្ចប់ " **គ**" ដាក់មួយ (១) ច្បាប់ទៅក្នុងហោប៉ៅនៃកញ្ចប់ " **គ** " និងរក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោតនៅ គធ/ខប ។

១១.១៣.៤.៣ ចងភ្ជិតកញ្ចប់ " **គ** " នីមួយៗ និងចាក់សោឃ្លុំមានលេខ ។ សរសេរសម្គាល់ពីក្រៅកញ្ចប់ " **គ** " នីមួយៗ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ នូវលេខកូដការិយាល័យពាក់ព័ន្ធពីលេខប៉ុន្មានដល់លេខប៉ុន្មាន និងពាក្យថា " ពិនិត្យរួច " ។

១១.១៣.៥ បន្ទាប់មក ប្រធាន គឃ/សប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ និងដែលមានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមប្រការ ១១.១២ ខាងលើ ដោយដាក់ទៅក្នុងកញ្ចប់ " **គ** " ដោយឡែក តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់កញ្ចប់ " ខ" ទាំងនោះ ។ ក្នុងការវេចខ្ចប់នេះ គឃ/សប ត្រូវ ៖

១១.១៣.៥.១ ដាក់កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលមានបណ្ដឹង បើកកញ្ចប់សុវត្ថិភាព " ក " ទៅក្នុងកញ្ចប់ " **គ** " ។

១១.១៣.៥.២ ធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនបី (៣) ច្បាប់ ត្រូវបានបំពេញ ដោយមាន

រាយមុខសម្ភារៈ ឯកសារ ដែលបានដាក់ក្នុងកញ្ចប់ " **គ** " ពាក់ព័ន្ធ ហើយត្រូវដាក់មួយ (១) ច្បាប់ទៅក្នុងកញ្ចប់ " **គ** " ដាក់មួយ (១) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " **គ** " និងរក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោតនៅ គធ/ខប ។

១១.១៣.៥.៣ ចងភ្ជិតកញ្ចប់ " **គ** " និងចាក់សោឃ្លុំ ។

១១.១៣.៥.៤ សរសេរសម្គាល់ពីក្រៅកញ្ចប់ " **គ** " ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ នូវលេខកូដការិយាល័យពាក់ព័ន្ធ និងពាក្យថា " មានបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព " ក " " ។

១១.១៣.៦ ក្នុងករណីមានកញ្ចប់ " **គ** " ដូចចែងក្នុងចំណុច ១១.១៣.៤ ឬ/និង ១១.១៣.៥ ខាងលើ សរុបលើសពីមួយ ប្រធាន គឃ/សប ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃកញ្ចប់ " **គ** " ទាំងនោះ នូវលេខរៀងនៃកញ្ចប់ " **គ** " នីមួយៗ ។ ឧទាហរណ៍ៈ ប្រសិនបើមានកញ្ចប់ " **គ** " សរុបចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀង ១/៣ ២/៣ និង ៣/៣ ។

១១.១៣.៧ ប្រធាន គឃ/សប ត្រូវធានាថា រាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដូចជា ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ត្រា គឃ/សប ម៉ាស៊ីនគិតលេខ គ្រឿងបរិក្ខារវិទ្យុទាក់ទង ទឹកខ្មៅលុបលាងមិនជ្រះ ។ល។ ដែលបានទទួលពីការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឬ/និងមាននៅទីស្នាក់ការ គឃ/សប ត្រូវតែបានវេចខ្ចប់ និងបញ្ជូនទន្ទឹមគ្នានឹងការបញ្ជូនកញ្ចប់ " **គ** " ទៅ គធ/ខប ។ សម្រាប់ការបញ្ជូនសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ខាងលើនេះ ប្រធានត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវតែបានបំពេញដោយឡែក និងអនុវត្តយ៉ាងត្រឹមត្រូវតាមលក្ខការណ៍នៃការប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត ។

១១.១៣.៨ ប្រធាន គឃ/សប ត្រូវប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដែលមានវត្តមានឱ្យចូលរួមជាសាក្សី ក្នុងការបញ្ជូន និងការប្រគល់ទទួលកញ្ចប់ " **គពិសេស** " រាល់កញ្ចប់ " **គ** " និងសម្ភារៈ ឯកសារបោះឆ្នោតផ្សេងទៀតខាងលើនេះ ហើយត្រូវជូនដំណឹងអំពីពេលវេលាចេញនៃការដំណើរការបញ្ជូន ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ទទួលនៅលេខាធិការដ្ឋាននៃ គធ/ខប ផង ។

# ជំពូកទី ១២
# លទ្ធផលបណ្តោះអាសន្ន លទ្ធផលជាផ្លូវការ និងការជំទាស់ចំពោះលទ្ធផលនៃការបោះឆ្នោត

## ការបង្កើតមជ្ឈមណ្ឌលនៃ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់

**ប្រការ ១២.១** គធ/ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់គោលបំណង នៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតតាមឃុំ សង្កាត់ ការកំណត់ចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបាន ការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតដែលត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យសម្រេចជាផ្លូវការ ។

១២.១.១ មជ្ឈមណ្ឌលនៃ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់អាចមានទីតាំងនៅលេខាធិការដ្ឋាន គធ/ខប ឬនៅអគារមួយផ្សេង ឬមួយផ្នែកដែលមានទំហំទូលាយល្មមអាចរៀបចំឱ្យមានកន្លែងបម្រុងដូចខាងក្រោម ៖

១២.១.១.១ កន្លែងសម្រាប់ទទួលកញ្ចប់ " គ " និង " គ ពិសេស " ដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែលត្រូវស្ថិតនៅក្បែរផ្លូវចូល និងត្រូវមានតុនិងកៅអី ។

១២.១.១.២ បន្ទប់មួយទូលាយល្មមដែលអាចស្តុកកញ្ចប់ " គ " និង " គ ពិសេស " ពីគ្រប់ គឃ/សប ក្នុងរាជធានី ខេត្ត ហើយដែលត្រូវដាក់ដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ និងមានសរសេរសម្គាល់លេខកូដឃុំ សង្កាត់ នីមួយៗផង ។

១២.១.១.៣ បន្ទប់ដាក់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែល គឃ/សប ទាំងអស់ក្នុងរាជធានី ខេត្តបានប្រគល់ឱ្យ និងដែលបានវេចខ្ចប់ដោយឡែក ។

១២.១.១.៤ បន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន ដែលត្រូវមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់គោលបំណង នៃការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតតាមឃុំ សង្កាត់ ហើយដែលអាចទទួលបានទាំងក្រុមត្រួតពិនិត្យលទ្ធផលរបស់ គធ/ខប ទាំងភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្ដឹងពាក់ព័ន្ធ ឬតំណាង ។

១២.១.១.៥ បន្ទប់ស្អាតតូចមួយ (ប្រសិនបើអាច) សម្រាប់ដាក់គ្រឿងបរិក្ខារកុំព្យូទ័រមួយសម្រាប់ ដែលមានភ្ជាប់ប្រព័ន្ធអ៊ីមែលមានទិន្នន័យគ្រប់គ្រាន់ពាក់ព័ន្ធនឹងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត និងមានបំពាក់កម្មវិធីប្រតិបត្តិការបែងចែកអាសនៈ ដែលរៀបចំ និងផ្ដល់ជូនដោយ គ.ជ.ប ។

១២.១.២ គធ/ខប ត្រូវធានាថា ទ្វារនិងបង្អួចទាំងអស់នៃអគារមជ្ឈមណ្ឌលរបស់ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ត្រូវតែបានបិទឱ្យជាប់ជារហូត លើកលែងតែទ្វារធំមួយសម្រាប់ចេញចូលដែលត្រូវចាក់សោយ៉ាងត្រឹមត្រូវនៅពេលផុតម៉ោងធ្វើការងារ ។ នៅក្នុងដំណើរការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតតាមឃុំ សង្កាត់ គធ/ខប ត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ទទួលបន្ទុកសណ្ដាប់ធ្នាប់ក្នុងមជ្ឈមណ្ឌល និងមានមន្ត្រីម្នាក់ប្រចាំការនៅមាត់ទ្វារចេញចូលដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន គធ/ខប ។

១២.១.៣ គធ/ខប ត្រូវធានាថា អគារមជ្ឈមណ្ឌលនៃ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ត្រូវតែរៀបចំឱ្យមានបរិវេណសន្តិសុខមួយ ដែលសហការការពារខ្សែក្រវាត់ខាងក្រៅដោយកងកម្លាំងសន្តិសុខរបស់អាជ្ញាធរដែនដីដែលបានទទួលការតែងតាំង និងទទួលបន្ទុកការពារខ្សែក្រវាត់ខាងក្នុង ដោយកម្លាំងសន្តិសុខផ្ទាល់របស់ គធ/ខប នៅគ្រប់ពេលវេលា ។

១២.១.៤ គធ/ខប គឺជាស្ថាប័នតែមួយគត់ ដែលត្រូវគ្រប់គ្រងការចេញចូលមជ្ឈមណ្ឌលនៃ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ និងមានសិទ្ធិអំណាចចេញចូលមជ្ឈមណ្ឌលនេះ ។ ជនគ្រប់រូប ដែលមានវត្តមាន

នៅក្នុងបរិវេណសន្តិសុខ និងក្នុងមជ្ឈមណ្ឌលនៃ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គធ/ខប ។

១២.១.៥ ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលនៃ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងមជ្ឈមណ្ឌលនេះ នូវជនទាំងឡាយ ដូចខាងក្រោម ៖

១២.១.៥.១ មន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ដែលបានទទួលការតែងតាំង ។

១២.១.៥.២ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ដូចបញ្ជាក់ក្រោមចំណុច ១២.៤.១ និង ១២.៤.២ ខាងក្រោម ។

១២.១.៥.៣ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន ឬតំណាង គធ/ខប សំណូមពរក្នុងករណីចាំបាច់ ។

១២.១.៥.៤ មន្ត្រីនៃ គ.ជ.ប ដែលកំពុងបំពេញភារកិច្ចស៊ើបអង្កេតបទល្មើសដែលគេបានចោទប្រកាន់ចំពោះសមាជិក ឬមន្ត្រីនៃ គធ/ខប ឬដែលកំពុងបំពេញបេសកកម្មត្រួតពិនិត្យ ឬជួយក្នុងដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ។

១២.១.៦ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងមជ្ឈមណ្ឌលនៃ គធ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ៖

១២.១.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

១២.១.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីត្រួតពិនិត្យលទ្ធផលនៃ គធ/ខប បំពេញចិត្ត ឬប្រឆាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

១២.១.៧ គធ/ខប ត្រូវតែងតាំងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ចំនួនមួយ ឬច្រើនក្រុម ដោយយោងតាមចំនួនឃុំ សង្កាត់ ក្នុងរាជធានី ខេត្តនីមួយៗ ។ ជាធម្មតា

ត្រូវធានាថា ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ដែលត្រូវបានតែងតាំងអាចត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ចំនួនដប់ (១០) ។ ដោយឡែកចំពោះរាជធានី ខេត្តដែលមានចំនួនឃុំ សង្កាត់តិចពេក ដូចជា ខេត្តកែប ប៉ៃលិន ព្រះសីហនុ... ឬច្រើនពេក ដូចជា ខេត្តកំពង់ចាម កណ្តាល ព្រៃវែង សៀមរាប តាកែវ... ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ដែលត្រូវបានតែងតាំងអាចត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅ ឃុំ សង្កាត់ ចំនួនតិចជាងដប់ (១០) ឬច្រើនជាងដប់ (១០) ។ គធ/ខប អាចបែងចែកឱ្យក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗទទួលបន្ទុកឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌមួយ ឬលើសពីមួយ ។

១២.១.៧.១ សមាសភាពនៃក្រុមត្រួតពិនិត្យលទ្ធផល ត្រូវជ្រើសតាំងពីក្នុងចំណោមសមាជិក និងមន្ត្រីនៃ គធ/ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីណាដែលពេលនោះមិនសូវមានការងារមមាញឹកដូចជា គ្រូបង្គាត់ជាដើម ។ ប្រសិនបើ គធ/ខប ពុំមានមន្ត្រីបុគ្គលិកគ្រប់គ្រាន់ គធ/ខប អាចលើកសំណើសុំតែងតាំងសមាជិកនៃ គឃ/សប ដែលស្ថិតនៅជិតលេខាធិការដ្ឋាន គធ/ខប បញ្ចូលក្នុងក្រុមត្រួតពិនិត្យលទ្ធផលទាំងនេះ ។

១២.១.៧.២ សមាសភាពក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗត្រូវមានបួន (៤) រូប ដឹកនាំដោយប្រធានមួយ (១) រូប ដែលជាសមាជិក ឬមន្ត្រីនៃ គធ/ខប និងមានអនុប្រធានមួយ (១) រូប លេខាធិការមួយ (១) រូប និងជំនួយការមួយ (១) រូប ។

១២.១.៨ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗរបស់ គធ/ខប មានភារកិច្ចត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗទៅតាមករណីដោយឡែកពីគ្នា និងតាមការណែនាំរបស់ប្រធាន គធ/ខប ដោយផ្អែកលើ ៖

១២.១.៨.១ កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ. ១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ. ១១០៩) ។

១២.១.៨.២ របាយការណ៍ របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន) ។

១២.១.៨.៣ សម្រង់ សេចក្ដីសម្រេចរបស់ គឃ/សប យល់ព្រម ឬបដិសេធលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ (ប្រសិនបើមាន) ។

១២.១.៨.៤ ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ដែលបានដាក់នៅ គជ/ខប ដូចចែងក្នុងចំណុច ១២.៣.៥ ខាងក្រោម (ប្រសិនបើមាន) ។

១២.១.៨.៥ ការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ/ខប (ប្រសិនបើ គជ/ខប សម្រេចឱ្យធ្វើដូច្នេះ) ។

១២.១.៩ ផ្អែកតាមការណែនាំរបស់ គជ/ខប ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់ និងតាមលំដាប់លំដោយនៃករណីជាក់ស្ដែងនីមួយៗ ដូចខាងក្រោម ៖

១២.១.៩.១ ក្នុងករណីឃុំ សង្កាត់ណាដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ/សប និងនៅ គជ/ខប ហើយដែលគ្មានកញ្ចប់សុវត្ថិភាព " ក" ណាមួយត្រូវបានបើក ។

១២.១.៩.២ ក្នុងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ដាក់នៅ គឃ/សប និងមានកញ្ចប់សុវត្ថិភាព " ក " ត្រូវបានបើកដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ហើយ គឃ/សប បានយល់ព្រម ឬបដិសេធលើបណ្ដឹងនោះ និងក្នុងករណីឃុំ សង្កាត់ណា ដែលមានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គជ/ខប ។

១២.១.៩.៣ ក្នុងករណីឃុំ សង្កាត់ណា ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន និងក្នុងករណីឃុំ សង្កាត់នោះមានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គជ/ខប ។

១២.១.១០ គជ/ខប ត្រូវប្រគល់ឱ្យសមាជិកទទួលបន្ទុករដ្ឋបាលដឹកនាំផ្ទាល់ក្រុមកំណត់ចំនួនអាសនៈ ដែលមានមន្ត្រីផ្នែកប្រតិបត្តិការមួយ (១) រូប មន្ត្រីផ្នែកសេវាកម្មច្បាប់ និងវិវាទកម្មមួយ (១) រូប និងមន្ត្រីមួយចំនួនទៀតតាមការចាំបាច់ ជាសមាជិក

និងលេខាធិការមួយ (១) រូប ។ ក្នុងចំណោមសមាជិកក្រុម ត្រូវតែមានអ្នកមានចំណេះដឹងផ្នែកកុំព្យូទ័រ និងការប្រើប្រាស់អ៊ីម៉ែល ។ ក្រុមនេះមានការទទួលខុសត្រូវ និងភារកិច្ចដូចខាងក្រោម ៖

១២.១.១០.១ ផ្នែកតាមតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៦តព) របស់ក្រុមត្រួតពិនិត្យលទ្ធផលដែល គធ/ខប បានឯកភាពរួចហើយ បំពេញក្រដាសលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ. ១១០៥ធខ) និងបញ្ចូលទិន្នន័យលទ្ធផល ទៅក្នុងតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) បន្ទាប់មកផ្ទៀងផ្ទាត់តួលេខលទ្ធផលក្នុងទម្រង់បែបបទលេខ ១១០៥ធខ នៃឃុំ សង្កាត់ទាំងអស់ ជាមួយនឹងទម្រង់បែបបទលេខ ១១១០ ដែលបានបោះពុម្ពពីកុំព្យូទ័រ ។

១២.១.១០.២ ផ្អែកតាមលទ្ធផលដូចបានបញ្ជាក់ក្នុងចំណុច ១២.១.១០.១ ខាងលើ អនុវត្តកម្មវិធីកុំព្យូទ័រសម្រាប់ប្រតិបត្តិការបែងចែកអាសនៈ និងគណនាតាមប្រមាណវិធីនានា ដើម្បីកំណត់ចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបាន ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោត ដែលត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ហើយបន្ទាប់មកបំពេញលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ដែលត្រូវចុះហត្ថលេខាដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គធ/ខប ។

១២.១.១១ គ.ជ.ប ត្រូវផ្គត់ផ្គង់កុំព្យូទ័រ ម៉ាស៊ីនស្កេន ម៉ាស៊ីនបោះពុម្ព ព្រមទាំងប្រព័ន្ធអ៊ីម៉ែល និងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូន គធ/ខប ឱ្យបានទាន់ពេលវេលា ។

១២.១.១១.១ អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ត្រូវទទួលបន្ទុកណែនាំមន្ត្រីជំនាញកុំព្យូទ័រនៃ គធ/ខប អំពីចំណេះដឹងក្នុងការអនុវត្តកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ និងការប្រើប្រាស់អ៊ីម៉ែល ។

១២.១.១១.២ គជ/ខប ត្រូវប្រើប្រាស់អ៊ីមែលសម្រាប់តែការបញ្ជូនសារ លិខិតស្នាម ព័ត៌មានបន្ទាន់ និងទិន្នន័យបច្ចេកទេសក្នុងការបោះឆ្នោតប៉ុណ្ណោះ ។

១២.១.១១.៣ គជ/ខប ត្រូវធានាឱ្យមានទិន្នន័យបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ ចំណុះរាជធានី ខេត្តពាក់ព័ន្ធ នៅក្នុងកុំព្យូទ័រ ។

**ការប្រគល់ និងការទទួលកញ្ចប់ " គ " និង " គពិសេស " ដាក់កំណត់ហេតុប្រកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គជ/ខប**

**ប្រការ ១២.២** នៅពេលមកដល់មជ្ឈមណ្ឌលរបស់ គជ/ខប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ភ្លាម ប្រធាន គឃ/សប ត្រូវឧទ្ទេសនាមខ្លួនឯងផ្ទាល់ ហើយត្រូវប្រគល់ជូនមន្ត្រីនៃ គជ/ខប ទទួលបន្ទុកការទទួលសម្ភារៈ ឯកសារនូវកញ្ចប់ " គពិសេស " ដាក់កំណត់ហេតុប្រកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ រាល់កញ្ចប់ " គ " ដាក់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតពីការិយាល័យបោះឆ្នោតទាំងអស់ចំណុះឃុំ សង្កាត់ និងរាល់កញ្ចប់ដែលមានវេចខ្ចប់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ។ ប្រធាន គឃ/សប ត្រូវប្រគល់ជូនមន្ត្រី គជ/ខប ផងដែរនូវលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ពាក់ព័ន្ធ ។

១២.២.១ នៅពេលប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោត ត្រូវធានាថា មន្ត្រីនៃ គជ/ខប បានត្រួតពិនិត្យរាល់កញ្ចប់ " ខ " ដាក់កញ្ចប់សុវត្ថិភាព " ក " រាល់ស្រោមសំបុត្រ និងរាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ ដែលមាននៅក្នុងកញ្ចប់ "គ ពិសេស" ឬកញ្ចប់ "គ" ឬកញ្ចប់សម្ភារៈ ឯកសារផ្សេងទៀត ដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ទទួលដែលប្រធាន គឃ/សប ប្រគល់ឱ្យ និងដូចបញ្ជាក់ក្នុងចំណុច ១១.១៣.២ ១១.១៣.៤.២ ១១.១៣.៥.១ និង ១១.១៣.៧ ខាងលើ ។ បន្ទាប់ពីបានត្រួតពិនិត្យឃើញថាត្រឹមត្រូវហើយ មន្ត្រីទទួលបន្ទុកការ ទទួលសម្ភារៈ ឯកសារត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលទាំងនេះ បញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ ។

១២.២.១.១ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធអាចចូលរួម ចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើលិខិតបញ្ជូននិងប្រគល់ ទទួលខាងលើ ។

១២.២.១.២ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើលិខិតបញ្ជូន និងប្រគល់ទទួលខាងលើពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកលិខិតនេះជាមោឃៈបានឡើយ ។

១២.២.២ មន្ត្រីនៃ គធ/ខប ទទួលបន្ទុកការទទួលសម្ភារៈ ឯកសារ ត្រូវកត់ត្រាមុខសម្ភារៈ ឯកសារដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីទទួលសម្ភារៈ ឯកសាររបស់ខ្លួន និងត្រូវចារសម្គាល់ថា " ការប្រគល់គ្រប់ចំនួន " បន្ទាប់មកត្រូវចាត់ចែងប្រើប្រាស់លិខិតបញ្ជូន និងប្រគល់ទទួលដែលបានចុះហត្ថលេខារួច ដូចចែងក្នុងចំណុច ១២.២.១ ខាងលើ ដូចខាងក្រោម ៖

១២.២.២.១ ប្រគល់ជូនប្រធាន គឃ/សប វិញមួយ (១) ច្បាប់ ។

១២.២.២.២ ដកមួយ (១) ច្បាប់ ចងក្រងទុកជាឯកសារ ។

១២.២.២.៣ ដាក់មួយ (១) ច្បាប់ ទៅក្នុងហោប៉ៅកញ្ចប់ " គពិសេស " ឬកញ្ចប់ " គ " ពាក់ព័ន្ធ ។

១២.២.៣ បន្ទាប់ពីបានអនុវត្តចំណុច ១២.២.២ រួច មន្ត្រីនៃ គធ/ខប ទទួលបន្ទុកការទទួលសម្ភារៈ ឯកសារ ត្រូវប្រគល់រាល់សម្ភារៈ ឯកសារបោះឆ្នោតដែលបានទទួលទាំងអស់ ឱ្យសហការីរបស់ខ្លួនដែលទទួលបន្ទុករក្សាស្តុកនាំយកកញ្ចប់ " គ " និង " គពិសេស " ទៅរក្សាទុកនៅក្នុងបន្ទប់ដូចបញ្ជាក់ក្នុងចំណុច ១២.១.១.២ និងនាំយកសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ទៅរក្សាទុកនៅក្នុងបន្ទប់ ដូចបញ្ជាក់ក្នុងចំណុច ១២.១.១.៣ ខាងលើ ។ មន្ត្រីទទួលបន្ទុករក្សាស្តុក ត្រូវបែងចែក និងរក្សាមុខសម្ភារៈ ឯកសារ ដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ ព្រមទាំងត្រូវសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង ។

១២.២.៤ ប្រសិនបើ នៅក្នុងការប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោតពី គឃ/សប ណាមួយ ដូចចែងក្នុងប្រការ ១២.២ ខាងលើ មានកញ្ចប់ " គ " មួយ ឬច្រើន ត្រូវបានសរសេរសម្គាល់ថា" មានបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក " នោះ នៅពេលកំពុងអនុវត្តនីតិវិធីចំណុច ១២.២.២ ខាងលើ មន្ត្រីនៃ គធ/ខប ទទួលបន្ទុកការទទួលសម្ភារៈ ឯកសារ ត្រូវចារបន្ថែមក្នុងបញ្ជីទទួលសម្ភារៈ ឯកសារ របស់ខ្លួនថា " មានបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក " ។ ក្នុងករណីនេះ មន្ត្រីនៃ គធ/ខប ទទួលបន្ទុកការទទួលសម្ភារៈ ឯកសារបោះឆ្នោតត្រូវ ៖

១២.២.៤.១ ស្រង់កត់ត្រាឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ត្រូវបានបើក ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។

១២.២.៤.២ យកកញ្ចប់ " គ ពិសេស " និងកញ្ចប់ " គ " ដែលមានសរសេរសម្គាល់ថា " មានបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" នៃឃុំ សង្កាត់ពាក់ព័ន្ធ ទៅរក្សាទុកដោយឡែកនៅក្នុងបន្ទប់ស្តុក ដើម្បីងាយស្រួលរក ។

១២.២.៥ មន្ត្រីទទួលបន្ទុកការទទួលសម្ភារៈ ឯកសារ ត្រូវរាយការណ៍អំពី ចំនួនកញ្ចប់ " គពិសេស " កញ្ចប់ " គ " និងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ដែលបានទទួលពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្តរួចហើយ និងបញ្ជាក់ច្បាស់នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹង ដូចចែងក្រោមចំណុច ១២.២.៤.១ ខាងលើ ជូន គជ/ខប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលទៅតាមករណីជាក់ស្តែង ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ គជ/ខប ទាក់ទងនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់**

**ប្រការ ១២.៣** ជនគ្រប់រូប ដែលបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានភស្តុតាងច្បាស់លាស់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងដំណើរការបោះឆ្នោតដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅ គជ/ខប អំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ពាក់ព័ន្ធ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.៣.១ រាល់ការប្តឹងតវ៉ា ឬប្តឹងជំទាស់ដូចបញ្ជាក់ក្នុងប្រការ ១២.៣ ខាងលើ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅ គជ/ខប ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពី គឃ/សប បានបិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ហើយ គជ/ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងទាំងនេះ ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

១២.៣.២ ប្រសិនបើនៅក្នុងរយៈពេលកំណត់ ដូចចែងក្នុងចំណុច ១២.៣.១ ខាងលើ គជ/ខប មិនបានទទួលពាក្យបណ្តឹងណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ចំណុះរាជធានី ខេត្តពាក់ព័ន្ធ ។

១២.៣.៣ ភ្នាក់ងារគណបក្សនយោបាយ ឬជនគ្រប់រូបដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលមានបំណងប្ដឹងតវ៉ា ឬប្ដឹងជំទាស់ ដូចបញ្ជាក់ក្នុងប្រការ ១២.៣ ខាងលើ អាចស្នើសុំទម្រង់បែបបទលេខ ១២០២ ចំនួនបី (៣) ច្បាប់ ពី គឃ/សប ហើយត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ដិតមេដៃ លើពាក្យបណ្ដឹង ដែលក្នុងនោះ ត្រូវផ្ដល់ព័ត៌មានច្បាស់លាស់មួយចំនួន ដូចបានកំណត់ក្នុងចំណុច ១៦.៣.៥ ប្រការ ១៦.៣ ជំពូកទី ១៦ នៃ ប.ន.ឃ.ស នេះ ។

១២.៣.៤ ចំពោះពាក្យបណ្ដឹង ដែលបានទទួលក្រោយរយៈពេលកំណត់ ដូចចែងក្នុងចំណុច ១២.៣.១ ខាងលើ ប្រធាន គធ/ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចុះពេលវេលា និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចចារបញ្ជាក់ពីការហួសអាជ្ញាយុកាលទទួលពាក្យបណ្ដឹង ចុះហត្ថលេខា និងបោះត្រាលើពាក្យបណ្ដឹង ហើយប្រគល់ឱ្យអ្នកប្ដឹងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងជម្រាបអ្នកប្ដឹងថា ពាក្យបណ្ដឹងរបស់គាត់ ដែលបានដាក់នៅក្រោយរយៈពេលកំណត់ គធ/ខប មិនអាចទទួលយកមកដោះស្រាយបានទេ ។

១២.៣.៥ ចំពោះពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ និងគ្មានភស្ដុតាងបញ្ជាក់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយទេ គធ/ខប ត្រូវបដិសេធបណ្ដឹង ក្នុងនោះប្រធាន គធ/ខប ត្រូវ ៖

១២.៣.៥.១ បង្គាប់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ឱ្យបំពេញសម្រង់សេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ (ទ.១២០៣) ជាបី (៣) ច្បាប់ ដោយមានបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះ និងចុះហត្ថលេខាផង ។

១២.៣.៥.២ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសម្រង់សេចក្ដីសម្រេច ដែលសមាជិកទទួបន្ទុកសេវាកម្មច្បាប់បានបំពេញ រួចប្រគល់ជូនអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.៣.៥.៣ ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ/ខប ទៅ គ.ជ.ប ក្នុងរយៈពេលបួន (៤) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេចបដិសេធ ។

១២.៣.៦ ចំពោះពាក្យបណ្ដឹង ដែលបានទទួលក្នុងរយៈពេលកំណត់ និងមានឯកសារ និងភស្តុតាងគ្រប់គ្រាន់ មន្ត្រីទទួលពាក្យបណ្ដឹងនៃ គធ/ខប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្ដឹង ប្រគល់ជូនអ្នកប្ដឹងវិញមួយ (១) ច្បាប់ បិទផ្សាយជាសាធារណៈមួយ (១) ច្បាប់នៅ គធ/ខប និងទុកមួយ (១) ច្បាប់សម្រាប់ គធ/ខប ប្រើក្នុងពេលប្រជុំសម្រេច ។ បន្ទាប់មកប្រាប់អ្នកប្ដឹង ឬអ្នកតំណាងថា គធ/ខប នឹងប្រជុំសម្រេចលើពាក្យបណ្ដឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះ ។

១២.៣.៧ មន្ត្រីទទួលពាក្យបណ្ដឹងនៃ គធ/ខប ត្រូវរាយការណ៍អំពីករណីបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ខាងលើនេះ ជូនប្រធាន គធ/ខប ជាបន្ទាន់ ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផល ឱ្យត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្ដឹងនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្ដឹង ឬអ្នកតំណាងពាក់ព័ន្ធ ។ ប្រសិនបើចាំបាច់ គធ/ខប ត្រូវបង្គាប់ក្រុមត្រួតពិនិត្យលទ្ធផលឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតដែលពាក់ព័ន្ធនឹងពាក្យបណ្ដឹង ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។

**កិច្ចប្រតិបត្តិការរបស់ គធ/ខប ក្នុងការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់**

**ប្រការ ១២.៤** បន្ទាប់ពីបានទទួលរបាយការណ៍ស្ដីពីការទទួលកញ្ចប់ " គពិសេស " កញ្ចប់ " គ " និងសម្ភារៈឯកសារបោះឆ្នោតនៅសល់ ដូចចែងក្នុងចំណុច ១២.២.៥ និងរបាយការណ៍ស្ដីពីការទទួលពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ដូចចែងក្នុងចំណុច ១២.៣.៦ ខាងលើ គធ/ខប ត្រូវកំណត់ និងបែងចែកឱ្យក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ដែលបានតែងតាំងឡើងស្របតាមចំណុច ១២.១.៧ ខាងលើ ទទួលខុសត្រូវអនុវត្ត ។ គធ/ខប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យធ្វើការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់តាមករណីនីមួយៗ ដោយឡែកពីគ្នាទាំងឃុំសង្កាត់គ្មានពាក្យបណ្ដឹង ទាំងឃុំ សង្កាត់មានពាក្យបណ្ដឹង ឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើបាន និងមិនត្រូវឱ្យហួសរយៈពេលប្រាំ (៥) ថ្ងៃឡើយ ដោយគិតចាប់ពីថ្ងៃបានទទួលកញ្ចប់ " គពិសេស " និងកញ្ចប់ " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.៤.១ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងរាល់ដំណើរការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ចំណុះរាជធានី ខេត្ត ។

១២.៤.១.១ ភ្នាក់ងារនៃគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃអង្គការនីមួយៗ ប្រចាំការតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យមានតំណាងរបស់ខ្លួន និងតំណាងបម្រុងតាមចំនួនដែល គធ/ខប បានកំណត់ដែលអាចចូលរួមគ្រប់គ្រាន់ល្មម ក្នុងការសង្កេតមើលកិច្ចប្រតិបត្តិការ របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ។

១២.៤.១.២ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប នីមួយៗ អាចផ្លាស់ប្តូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួន ។

១២.៤.១.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មម ដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយ នៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ។

១២.៤.២ អ្នកប្តឹង ដែលពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់របស់គាត់ ត្រូវបាន គឃ/សប សម្រេចយល់ព្រម ឬបដិសេធ ដូចចែងក្នុងចំណុច ១១.៤.៦ និង ១១.៤.៧ ក្នុងជំពូកទី១១ នៃ ប.ន.ឃ.ស នេះ និងអ្នកប្តឹង ឬតំណាង ដែលបានដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចចែងក្នុងចំណុច ១២.៣.៥ ខាងលើ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.៤.៣ កិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ជាពិសេសចំពោះឃុំ សង្កាត់មានពាក្យបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរដែលតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផល បើកកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។

១២.៤.៤ គធ/ខប ត្រូវចាត់ចែងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត នៅបន្ទប់ធំទូលាយមួយ ឬ

បន្ទប់តូចៗច្រើននៃមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផល ដែលបានបង្កើតឡើងក្រោមប្រការ ១២.១ ក្នុងជំពូកនេះ ។ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ពីរ ឬច្រើន អាចបំពេញការងារនៅតាមតុរៀងខ្លួន ជុំគ្នានៅក្នុងបន្ទប់តែមួយ ឬនៅតាមបន្ទប់ដោយឡែកពីគ្នា ដោយយោងតាមលទ្ធភាពជាក់ស្តែងរបស់រាជធានី ខេត្ត ។ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ត្រូវរៀបចំគំរូប្លង់បន្ទប់ តាមលំនាំបន្ទប់រាប់សន្លឹកឆ្នោត ដូចចែងក្រោមចំណុច ១១.២.១ ជំពូកទី ១១ នៃ ប.ន.ឃ.ស នេះ និងត្រូវមានសម្ភារៈ ឯកសារ និងទម្រង់បែបបទគ្រប់គ្រាន់ សម្រាប់បំពេញការងារ ។

១២.៤.៤.១ ក្នុងការត្រួតពិនិត្យលទ្ធផលខាងលើនេះ ប្រធានក្រុមត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខប្រធាន ហើយឱ្យអនុប្រធានក្រុម និងជំនួយការអង្គុយនៅអមសងខាងតុទល់មុខគ្នា ។

១២.៤.៤.២ ប្រធានក្រុមត្រូវត្រៀមនៅក្បែរខ្លួនគាត់នូវទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹង សម្រាប់ប្រគល់ជូនភ្នាក់ងារគណបក្សនយោបាយតាមសំណើសុំ និងរាល់ទម្រង់បែបបទចាំបាច់ផ្សេងទៀត សម្រាប់ប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ ។

១២.៤.៤.៣ ប្រធានក្រុមត្រូវប្រគល់ឱ្យអនុប្រធាន និងលេខាធិការ នូវទម្រង់បែបបទលេខ ១១១៦តព សម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ។

១២.៤.៤.៤ ប្រធានក្រុមត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខមួយ (១) គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនេះ ។

១២.៤.៥ គធ/ខប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផល ឱ្យត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ដោយឡែកពីគ្នា និងតាមលំដាប់លំដោយ នៃករណីជាក់ស្តែងនីមួយៗ ដូចចែងជាបន្តបន្ទាប់គ្នាក្នុងចំណុច ១២.១.៩.១ ១២.១.៩.២ និង ១២.១.៩.៣ ខាងលើ ។ ប្រសិនបើលក្ខខណ្ឌតម្រូវ ក្រុមត្រួតពិនិត្យលទ្ធផលអាចធ្វើការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ពាក់ព័ន្ធ ដោយគួបផ្សំការអនុវត្តនីតិវិធីសម្រាប់ករណីលើសពីមួយស្របពេលជាមួយគ្នា ។

**ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ/សប និង នៅ គធ/ខប**

**ប្រការ ១២.៥** ក្នុងករណីឃុំ សង្កាត់ណា ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ/សប និងនៅ គធ/ខប ហើយដែលគ្មានកញ្ចប់សុវត្ថិភាព " ក " ណាមួយត្រូវបានបើក ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ គឃ/សប ដូចចែងក្នុងចំណុច ១២.១.៩.១ ខាងលើ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប មិនអាចបើកកញ្ចប់សុវត្ថិភាព " ក " ណាមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ។ ក្នុងករណីនេះ ក្រុមត្រួតពិនិត្យលទ្ធផលគ្រាន់តែធ្វើការត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) ប៉ុណ្ណោះ ។

១២.៥.១ ក្នុងដំណើរការនៃការត្រួតពិនិត្យលទ្ធផលក្នុងករណីខាងលើ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ត្រូវចាត់ចែងអនុវត្តតាមនីតិវិធីដូចខាងក្រោម ដោយត្រូវ ៖

១២.៥.១.១ បង្គាប់ជំនួយការឱ្យនាំយកកញ្ចប់ " គពិសេស " នៃឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងម្ដងមួយៗ ពីកន្លែងរក្សាស្ដុកមកដាក់នៅលើតុចំពីមុខប្រធានក្រុម ។

១២.៥.១.២ ប្រើកន្ត្រៃកាត់បើកកញ្ចប់ " គពិសេស " រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) និងរាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត (ទ. ១១០១ និង ១១០២) ដែលត្រូវផ្ញើជូន គធ/ខប មកដាក់នៅលើតុ ។

១២.៥.១.៣ ដកយកស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) ផ្ញើជូន គ.ជ.ប ពីក្នុងកញ្ចប់ " គពិសេស " យកទៅប្រគល់ជូនប្រធាន គធ/ខប ដើម្បីប្រមូលដាក់ទៅក្នុងកញ្ចប់ "ឃពិសេស " បន្ទាប់មកប្រធានក្រុមត្រូវដាក់កញ្ចប់ " គពិសេស " ទទេនៅក្បែរខ្លួនគាត់ ។

១២.៥.១.៤ ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ នោះ ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ដូចបញ្ជាក់ ក្នុងចំណុច១២.៥.១.២ខាងលើ ។ ក្នុងករណីមានភាពមិនច្បាស់លាស់ក្នុងការត្រួតពិនិត្យនេះ ក្រុមត្រួតពិនិត្យត្រូវផ្ទៀងផ្ទាត់បន្ថែមជាមួយនឹងកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត (ទ. ១១០១ និង ១១០២) នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

១២.៥.១.៥ ធានាថា តារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប (ទ. ១១១៦គ៣) ទាំងពីរ (២) ច្បាប់ ដែលអនុប្រធាន និងលេខាធិការបានបំពេញក្នុងការត្រួតពិនិត្យលទ្ធផល ត្រូវបានផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវជាមួយគ្នា និងត្រូវមានបញ្ជាក់ឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.៥.១.៦ ធានាថាតារាងត្រួតពិនិត្យលទ្ធផលខាងលើទាំងពីរ (២) ច្បាប់ មានបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោម ប្រសិនបើបានរកឃើញថា ៖

តួលេខនៃលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់មានភាពត្រឹមត្រូវ ។

គឃ/សប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផល ។

បញ្ជីបេក្ខជនពីរ ឬច្រើនទទួលបានសន្លឹកឆ្នោតគាំទ្រស្មើគ្នាក្នុងការបោះឆ្នោតនៅឃុំ សង្កាត់នោះ ។

១២.៥.១.៧ ក្នុងករណី ក្រុមត្រួតពិនិត្យលទ្ធផលបានរកឃើញកំហុសក្នុងការគណនាបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ណាមួយ ប្រធានក្រុមត្រូវបង្ហាញកំហុស និងការកែតម្រូវកំហុស ព្រមទាំងហេតុផលនៃការកែតម្រូវនោះ ចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវឆូតលើតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង ។

១២.៥.១.៨ ធានាថាតារាងត្រួតពិនិត្យលទ្ធផ (ទ. ១១១៦តព) ខាងលើ ត្រូវបានចុះហត្ថលេខា ដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផលពាក់ព័ន្ធ ។

១២.៥.១.៩ ធានាថា តារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦តព) ខាងលើ ត្រូវបានដាក់ភ្ជាប់ទៅនឹងកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) ដូចចែងក្នុងចំណុច ១២.៥.១.៤ ខាងលើ រួចដាក់ជូន គធ/ខប ពិនិត្យសម្រេច ។

១២.៥.២ គធ/ខប ត្រូវពិនិត្យសម្រេចលើតារាងត្រួតពិនិត្យលទ្ធផល របស់ក្រុមត្រួតពិនិត្យលទ្ធផល ដែលបានដាក់ជូន ដូចចែងក្នុងចំណុច ១២.៥.១.៩ ខាងលើ ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ ប្រធាន គធ/ខប ត្រូវចារយល់ព្រម រួចចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទ និងដាក់បង្ហាញចំពោះភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ហើយត្រូវ ៖

១២.៥.២.១ ប្រគល់តារាងត្រួតពិនិត្យលទ្ធផល ដែលចារយល់ព្រមខាងលើមួយ (១) ច្បាប់ និងរាល់សំណុំឯកសារភ្ជាប់ជាមួយ ជូនក្រុមត្រួតពិនិត្យលទ្ធផល ដើម្បីដាក់ទៅក្នុងកញ្ចប់ " គពិសេស " រក្សាទុកជាឯកសារនៅ គធ/ខប ។

១២.៥.២.២ ប្រគល់តារាងត្រួតពិនិត្យលទ្ធផល ដែលចារយល់ព្រមខាងលើមួយ (១) ច្បាប់ ជូនក្រុមកំណត់ចំនួនអាសនៈដែលត្រូវបន្តអនុវត្តតាមនីតិវិធី ដូចចែងក្រោមប្រការ ១២.៩ ក្នុងជំពូកនេះ ។

១២.៥.៣ ប្រធាន គធ/ខប ត្រូវធានាថា នៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ប្រធានក្រុមត្រួតពិនិត្យលទ្ធផល បានប្រគល់ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់(ទ. ១១០៣) និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) ផ្ញើជូន គ.ជ.ប ជូនគាត់ ដើម្បីគាត់ប្រមូលផ្ដុំដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " ដែលត្រៀមបម្រុងជាស្រេច ដូចចែងក្នុងចំណុច ១២.១០.២ ខាងក្រោម ។

១២.៥.៤ ប្រធាន គធ/ខប ត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផលមួយ (១) ច្បាប់ និងរាល់ឯកសារ ដូចបញ្ជាក់ក្នុងចំណុច ១២.៥.១.៤ ខាងលើ ដែលបានប្រើក្នុងការត្រួតពិនិត្យលទ្ធផល និងដាក់ជូន គធ/ខប ពិនិត្យសម្រេចរួចហើយ ត្រូវបានក្រុមត្រួតពិនិត្យលទ្ធផលដាក់ទៅក្នុងស្រោមសំបុត្រដូចដើម និងវេចខ្ចប់ក្នុងកញ្ចប់ " គពិសេស " រួចយកទៅរក្សាទុកនៅកន្លែងស្តុកវិញ ដែលត្រូវរក្សាទុកជាឯកសាររបស់ គធ/ខប ។

១២.៥.៥ គធ/ខប ត្រូវធានាថា ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលគ្មានបណ្តឹងទាំងអស់ចំណុះ រាជធានី ខេត្ត ត្រូវបានអនុវត្តម្តងមួយឃុំ សង្កាត់ ហើយរាល់នីតិវិធី ដូចចែងចាប់ពីចំណុច ១២.៥.១ ដល់ ១២.៥.៤ ខាងលើ ត្រូវតែបានអនុវត្ត ។

**ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គឃ/សប មានការបើកកញ្ចប់សុវត្ថិភាព " ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ គឃ/សប និងដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដាក់នៅ គធ/ខប**

**ប្រការ ១២.៦** ក្នុងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ/សប មានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើនត្រូវបានបើកដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ គឃ/សប មានសេចក្តីសម្រេចរបស់ គឃ/សប យល់ព្រម ឬបដិសេធលើបណ្តឹងនោះ និងដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ/ខប ដូចចែងក្នុងចំណុច ១២.១.៩.២ ខាងលើ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ក៏ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះផងដែរ ។ ក្នុងករណីនេះ នីតិវិធីក្នុងជំពូកនេះ ដូចចែងក្រោមចំណុច ១២.៥.១ និង ១២.៥.៣ ខាងលើ ត្រូវតែបានអនុវត្ត ប៉ុន្តែក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ត្រូវអនុវត្តបន្ថែមតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

១២.៦.១ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវត្រួតពិនិត្យជាមុន នូវសេចក្តីសម្រេចរបស់ គឃ/សប លើពាក្យបណ្តឹងពាក់ព័ន្ធ របាយការណ៍របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត និងពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់ ដែលបានដាក់នៅ គធ/ខប ហើយត្រូវស្នើសុំយោបល់សម្រេចរបស់ គធ/ខប អំពីការអនុញ្ញាតឱ្យបើក ឬមិនឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

១២.៦.១.១ ផ្អែកតាមឯកសារខាងលើ ក្នុងករណីគ្មានភាពមិនប្រក្រតី គធ/ខប មិនចាំបាច់តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញឡើយ ។

១២.៦.១.២ ផ្អែកតាមឯកសារខាងលើ ក្នុងករណីមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ គធ/ខប ត្រូវសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។

១២.៦.២ ប្រសិនបើ គធ/ខប សម្រេចមិនឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្នុងចំណុច ១២.៦.១.១ ខាងលើទេ រាល់នីតិវិធីក្នុងជំពូកនេះ ដូចចែងចាប់ពីចំណុច ១២.៥.១ ដល់ ១២.៥.៤ ខាងលើ ត្រូវតែបានអនុវត្ត ។

១២.៦.៣ ប្រសិនបើ គធ/ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្នុងចំណុច ១២.៦.១.២ ខាងលើ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តនីតិវិធីចំណុច ១២.៥.១ និង ១២.៥.៣ ខាងលើ ហើយបន្ទាប់មកប្រធានក្រុមត្រូវ ៖

១២.៦.៣.១ បង្គាប់ជំនួយការឱ្យទៅនាំយកកញ្ចប់ " គ មានបណ្តឹង " នៃឃុំ សង្កាត់ពាក់ព័ន្ធ ពីបន្ទប់រក្សាស្តុក មកដាក់នៅលើតុចំពីមុខប្រធានក្រុម ។

១២.៦.៣.២ កាត់សោឃ្លុំបើកកញ្ចប់ " គ មានបណ្តឹង " ដកយកកញ្ចប់ " ខ " ចេញមកក្រៅ រួចបើក និងដកយកកញ្ចប់សុវត្ថិភាព " ក " មកដាក់នៅលើតុ ។

១២.៦.៣.៣ ប្រើកន្ត្រៃកាត់បើកកញ្ចប់សុវត្ថិភាព " ក " រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារៈ ឯកសារបោះឆ្នោតទាំងអស់ដែលមាននៅខាងក្នុង មកដាក់ដោយឡែកពីគ្នា នៅលើតុខាងមុខគាត់ ។

១២.៦.៣.៤ ប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតឱ្យទៅលេខាធិការ សម្រាប់តាមដានពិនិត្យ

ដោយប្រៀបធៀបទៅនឹងលទ្ធផល នៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។

១២.៦.៣.៥ បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារៈ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់តាមនីតិវិធី ដូចចែងក្រោមចំណុច ១២.៦.៤ ខាងក្រោម ។

១២.៦.៤ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យនោះឡើងវិញ តាមលំនាំនីតិវិធីដូចចែងក្រោមចំណុច ១១.១២.២ ក្នុងជំពូកទី ១១ នៃ ប.ន.ឃ.ស នេះ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាក្នុងកម្មវត្ថុនៃពាក្យបណ្តឹងពាក់ព័ន្ធ និងត្រូវពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការ ដោយត្រូវអនុវត្តតាមលំនាំនីតិវិធីចាប់ពីចំណុច ១១.២.៦ ដល់ ១១.២.១២ ជំពូកទី១១ នៃ ប.ន.ឃ.ស នេះ ។

១២.៦.៥ ក្នុងករណី គជ/ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតលើសពីមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្ត តាមលំនាំនីតិវិធីដដែលដូចចែងក្នុងចំណុច ១២.៦.៣ និង ១២.៦.៤ ខាងលើ សម្រាប់កញ្ចប់សុវត្ថិភាព " ក " នីមួយៗ រហូតទាល់តែអស់កញ្ចប់សុវត្ថិភាព " ក " ដែលត្រូវបើក ។

១២.៦.៦ បន្ទាប់ពីអនុវត្តការបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតណាមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្រោមចំណុច ១២.៦.៣ ១២.៦.៤ និង ១២.៦.៥ ខាងលើ រួចរាល់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងអនុវត្តដូចខាងក្រោម ៖

១២.៦.៦.១ ធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញចំនួនពីរ (២) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ។ ក្នុងរបាយការណ៍នេះត្រូវតែមានលើកយោបល់ស្នើសុំ គជ/ខប ពិនិត្យសម្រេច ៖

យល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ/និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

ព្យួរលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយត្រូវបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.៦.៦.២ ចារលើរបាយការណ៍របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន) ដោយបញ្ជាក់ខ្លឹមសារស្របទៅនឹងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច ១២.៦.៦.១ ខាងលើ ។

១២.៦.៦.៣ ដាក់របាយការណ៍ ដូចចែងក្នុងចំណុច ១២.៦.៦.១ ខាងលើ សេចក្តីសម្រេចរបស់ គឃ/សប លើពាក្យបណ្តឹងពាក់ព័ន្ធ របាយការណ៍របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន) ភ្ជាប់ទៅនឹងតារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារពាក់ព័ន្ធ ដែលក្រុមត្រួតពិនិត្យលទ្ធផលត្រូវដាក់ជូន គជ/ខប ពិនិត្យសម្រេច ដូចបញ្ជាក់ក្នុងចំណុច ១២.៥.១.៩ ខាងលើ ។

១២.៦.៦.៤ ដាក់សម្ភារៈ ឯកសារបោះឆ្នោតទៅក្នុងស្បោងប្លាស្ទិក និងស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់ក្នុងកញ្ចប់សុវត្ថិភាព " ក " វិញ តាមលំនាំដើម ។

១២.៦.៦.៥ ដាក់កញ្ចប់សុវត្ថិភាព " ក " ទៅក្នុងកញ្ចប់ " ខ " រួចចងភ្ជិត និងដាក់កញ្ចប់ " ខ " ទៅក្នុងកញ្ចប់ " គ មានបណ្តឹង បើកកញ្ចប់សុវត្ថិភាព ក " នៃឃុំ សង្កាត់ពាក់ព័ន្ធតាមលំនាំដើម ដែលត្រូវនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប ។

១២.៦.៧ ផ្អែកលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងសំណុំឯកសារ ដូចចែងក្នុងចំណុច ១២.៦.៦.៣ ខាងលើ ព្រមទាំងផ្អែកលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែល គធ/ខប បានទទួល គធ/ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ ដោយត្រូវអនុវត្តតាមចំណុច ១២.៦.១១ ១២.៦.១២ និង ១២.៦.១៣ ខាងក្រោម ។

១២.៦.៨ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចចែងក្រោមចំណុច ១២.៣.៦ ខាងលើ ត្រូវបានដាក់នៅ គធ/ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យរួចហើយ ក្រោមប្រការ ១២.៦ នេះ នូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ គធ/ខប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យរួចហើយនោះ ដើម្បីប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ ។

១២.៦.៩ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចចែងក្រោមចំណុច ១២.៣.៦ ខាងលើ ត្រូវបានដាក់នៅ គធ/ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យរួចហើយ ក្រោមប្រការ ១២.៥ ខាងលើ នូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ គធ/ខប ត្រូវធានាថា រាល់នីតិវិធីដូចចែងក្នុងចំណុច ១២.៦.៣ ១២.៦.៤ ១២.៦.៥ ១២.៦.៦ និង ១២.៦.៧ ត្រូវតែបានអនុវត្តនៅមុនពេល គធ/ខប ប្រជុំសម្រេចលើពាក្យបណ្តឹង ។

១២.៦.១០ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចចែងក្រោមចំណុច ១២.៣.៦ ខាងលើ ពាក់ព័ន្ធនឹងឃុំ សង្កាត់ ដែលមិនទាន់បានត្រួតពិនិត្យ គធ/ខប ត្រូវធានាថា រាល់នីតិវិធី ដូចចែងក្នុងចំណុច ១២.៥.១ ១២.៥.៣ ១២.៦.៣ ១២.៦.៤ ១២.៦.៥ ១២.៦.៦ និង ១២.៦.៧ ខាងលើ ត្រូវតែបានអនុវត្តនៅមុនពេល គធ/ខប ប្រជុំសម្រេចលើពាក្យបណ្តឹង ។

**ការប្រជុំសម្រេចរបស់ គធ/ខប លើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់**

១២.៦.១១ ប្រសិនបើ គធ/ខប សម្រេចយល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ គធ/ខប ត្រូវបដិសេធសេចក្តីសម្រេចរបស់ គឃ/សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធ និងបដិសេធពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលបានដាក់នៅ គធ/ខប ។ ប្រធាន គធ/ខប ត្រូវ ៖

១២.៦.១១.១ ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល និងលើរបាយការណ៍ ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ របស់ ក្រុមត្រួតពិនិត្យលទ្ធផល ឬ/និងលើរបាយការណ៍របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀង ផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន) ដែលបានដាក់ភ្ជាប់ជាមួយសំណុំឯកសារពាក់ព័ន្ធ ជូន គធ/ខប ពិនិត្យសម្រេច ដូចចែងក្នុងចំណុច ១២.៦.៦.៣ ខាងលើ រួចចុះ ហត្ថលេខា បោះត្រា និងកាលបរិច្ឆេទ ព្រមទាំងដាក់បង្ហាញចំពោះ អ្នកប្តឹង ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន ។

១២.៦.១១.២ ចារបដិសេធលើសម្រង់សេចក្តីសម្រេចរបស់ គឃ/សប ដែល បានយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធ រួចចុះហត្ថលេខា កាល បរិច្ឆេទ និងបោះត្រា ។

១២.៦.១១.៣ ធានាថា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ បានបំពេញសម្រង់ សេចក្តីសម្រេចរបស់ គធ/ខប យល់ព្រមទទួលយកលទ្ធផល បណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យ បោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលត្រូវបដិសេធ ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដែលដាក់នៅ គធ/ខប ដោយ បញ្ជាក់ច្បាស់ពី មូលហេតុហើយដែលត្រូវចុះហត្ថលេខា កាល បរិច្ឆេទ និងបោះត្រា ដោយសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងប្រធាន គធ/ខប ។

១២.៦.១១.៤ ប្រគល់សម្រង់សេចក្តីសម្រេចរបស់ គធ/ខប យល់ព្រមទទួលយក លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ជូនអ្នកប្តឹងមួយ (១) ច្បាប់ ជូនគ្រប់ភ្នាក់ងារនៃគណបក្សនយោបាយឈរឈ្មោះក្នុងឃុំ សង្កាត់ មួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ផ្ញើជូន គឃ/សប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារ មួយ (១) ច្បាប់ ។

១២.៦.១១.៥ ជម្រាបអ្នកប្តឹង ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គធ/ខប ខាងលើនេះថា គាត់មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ានៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរបួន (៤) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល សម្រង់សេចក្តីសម្រេចរបស់ គធ/ខប ។

១២.៦.១១.៦ ប្រគល់ ទ. ១២០២ សម្រាប់បំពេញពាក្យបណ្តឹង ចំនួនបី (៣) ច្បាប់ជូនអ្នកប្តឹង (ប្រសិនបើគាត់ស្នើសុំ) ។

១២.៦.១១.៧ ប្រគល់រាល់ឯកសារដូចចែងក្នុងចំណុច ១២.៦.១១.១ ១២.៦.១១.២ ១២.៦.១១.៣ និង ១២.៦.១១.៤ មួយមុខ មួយ (១) ច្បាប់ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលដាក់ក្នុងកញ្ចប់ " គពិសេស " ដើម្បីរក្សាទុកជាឯកសារនៅ គធ/ខប ។

១២.៦.១១.៨ ប្រគល់រាល់ឯកសារដូចចែងក្នុងចំណុច ១២.៦.១១.១ ខាងលើ ក្នុងមួយមុខ មួយ (១) ច្បាប់ ទៅឱ្យក្រុមកំណត់ចំនួនអាសនៈដែលត្រូវបន្តអនុវត្តតាមនីតិវិធី ដូចចែងក្រោមប្រការ ១២.៩ ក្នុងជំពូកនេះ ។

១២.៦.១២ ប្រសិនបើ គធ/ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ដែលត្រូវយល់ព្រមតាមសេចក្តីសម្រេចរបស់ គឃ/សប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងយល់ព្រមតាមបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលបានដាក់នៅ គធ/ខប ប្រធាន គធ/ខប ត្រូវ ៖

១២.៦.១២.១ ចារព្យួរលទ្ធផល លើតារាងត្រួតពិនិត្យលទ្ធផល និងលើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញរបស់ក្រុមត្រួតពិនិត្យលទ្ធផលដែលបានដាក់ជូន គធ/ខប ពិនិត្យសម្រេច ដូចចែងក្នុងចំណុច ១២.៦.៦.៣ ខាងលើ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ព្រមទាំងដាក់បង្ហាញចំពោះអ្នកប្តឹង ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន ។

១២.៦.១២.២ ចារយល់ព្រមលើសម្រង់សេចក្តីសម្រេចរបស់ គឃ/សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពាក់ព័ន្ធ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ។

១២.៦.១២.៣ ធានាថា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ បានបំពេញសម្រង់សេចក្តីសម្រេចរបស់ គធ/ខប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលត្រូវយល់ព្រមតាមបណ្តឹងតវ៉ា ឬ

បណ្តឹងជំទាស់ ដែលបានដាក់នៅ គធ/ខប ដោយបញ្ជាក់ច្បាស់ពីមូលហេតុផង ហើយដែលត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ដោយសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និង ប្រធាន គធ/ខប ។

១២.៦.១២.៤ ប្រគល់សម្រង់សេចក្តីសម្រេចរបស់ គធ/ខប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតខាងលើ ជូនអ្នកប្តឹងមួយ (១) ច្បាប់ ជូនគ្រប់ភ្នាក់ងារនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងឃុំ សង្កាត់មួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ផ្ញើជូន គឃ/សប ពាក់ព័ន្ធ មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.៦.១២.៥ ប្រកាសថា លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះត្រូវបានបដិសេធដោយ គធ/ខប ហើយសេចក្តីសម្រេចនេះស្ថិតក្រោមការត្រួតពិនិត្យឡើងវិញរបស់ គ.ជ.ប ។

១២.៦.១២.៦ ធានាថា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ បានដាក់ទៅក្នុងស្រោមសំបុត្រដោយឡែកពីគ្នាសម្រាប់ផ្ញើជូន គ.ជ.ប នូវសម្រង់សេចក្តីសម្រេចរបស់ គធ/ខប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ មួយ (១) ច្បាប់ ព្រមទាំងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ មួយ (១) ច្បាប់ តារាងត្រួតពិនិត្យលទ្ធផល ដែលត្រូវបាន គធ/ខប ចារឮ្យរជាបណ្តោះអាសន្នមួយ (១) ច្បាប់ និងរបាយការណ៍របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត មួយ (១) ច្បាប់ (ប្រសិនបើមាន) ។

១២.៦.១២.៧ ប្រគល់រាល់ឯកសារដូចចែងក្នុងចំណុច១២.៦.១២.១ ១២.៦.១២.២ ១២.៦.១២.៣ និង ១២.៦.១២.៤ ខាងលើ ក្នុងមួយមុខ មួយ (១) ច្បាប់ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលដាក់ទៅក្នុងកញ្ចប់ " គពិសេស " ដើម្បីរក្សាទុកជាឯកសាររបស់ គធ/ខប ។

១២.៦.១៣ ក្នុងករណី គធ/ខប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រធាន គធ/ខប ត្រូវបញ្ជូនសម្រង់សេចក្ដីសម្រេចបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធជូន គ.ជ.ប មិនឱ្យលើសពីម្ភៃបួន (២៤) ម៉ោង គិតចាប់ពីពេលចេញសម្រង់សេចក្ដីសម្រេចព្យួរលទ្ធផល ។ ប្រធាន គធ/ខប ត្រូវធានាថា សម្ភារៈ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវបានវេចខ្ចប់ដូចខាងក្រោមសម្រាប់បញ្ជូនទៅ គ.ជ.ប ៖

១២.៦.១៣.១ ដាក់ទៅក្នុងស្រោមសំបុត្រធំមួយ នូវរាល់ស្រោមសំបុត្រដាក់ឯកសារ និងទម្រង់បែបបទនានា ដូចចែងក្នុងចំណុច ១២.៦.១២.៧ ខាងលើ និងស្រោមសំបុត្រដាក់ ទ. ១១០៣ និង ១១០៩ នៃឃុំ សង្កាត់ពាក់ព័ន្ធដែលត្រូវផ្ញើជូន គ.ជ.ប ហើយត្រូវសរសេរសម្គាល់ពីក្រៅថា " សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់លេខ... (បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ) " ។

១២.៦.១៣.២ ដាក់រាល់កញ្ចប់ " គ " ផ្ទុកកញ្ចប់ " ខ " នៃឃុំ សង្កាត់ពាក់ព័ន្ធ ទៅក្នុងកញ្ចប់ " ឃ " ទៅតាមចំនួនដែលអាចដាក់ឱ្យអស់កញ្ចប់ " គ " រួចចងភ្ជិតចាក់សោឃ្លុំ និងត្រូវសរសេរសម្គាល់ពីក្រៅកញ្ចប់ " ឃ " ថា " ព្យួរលទ្ធផលឃុំ សង្កាត់លេខ... (បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ) " ។

១២.៦.១៣.៣ ចាត់ចែងបំពេញលិខិតបញ្ជូន និងប្រគល់ ទទួល (ទ. ១១០៧) ចំនួនបី (៣) ច្បាប់ ដោយរាយមុខសម្ភារៈ ឯកសារដែលមាននៅក្នុងស្រោមសំបុត្រធំ និងក្នុងកញ្ចប់ " ឃ " ។

១២.៦.១៣.៤ ដាក់លិខិតបញ្ជូន និងប្រគល់ ទទួលមួយ (១) ច្បាប់ ទៅក្នុងស្រោមសំបុត្រធំ ដូចចែងក្នុងចំណុច ១២.៦.១៣.១ រួចកិបភ្ជាប់ មួយ (១) ច្បាប់ ទៅនឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំនេះ និងរក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលនៅ គ.ជ.ប ។

**ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គជ/ខប**

**ប្រការ ១២.៧** ក្នុងករណី ឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងក្នុងករណីឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គជ/ខប ដូចចែងក្នុង ចំណុច ១២.៣.៦ ខាងលើ គជ/ខប ត្រូវកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផល ឱ្យត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

១២.៧.១ ប្រសិនបើ ឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន ប៉ុន្តែឃុំ សង្កាត់នោះគ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គជ/ខប ដូចចែងក្នុងចំណុច ១២.៣.៦ ខាងលើទេនោះ គជ/ខប ត្រូវកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផល ឱ្យត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដោយត្រូវអនុវត្តតាមនីតិវិធី ដូចចែងក្រោមប្រការ ១២.៥ ក្នុងជំពូកនេះ ។

១២.៧.២ ប្រសិនបើ ឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចចែងក្នុងចំណុច ១២.៣.៦ ខាងលើ ត្រូវបានដាក់នៅ គជ/ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យរួចហើយ ដូចចែងក្រោមប្រការ ១២.៥ និង ១២.៦ ខាងលើ នូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ គជ/ខប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យរួចហើយនោះ ដើម្បីប្រជុំសម្រេចលើពាក្យបណ្តឹង ។

១២.៧.៣ ប្រសិនបើ ឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចចែងក្នុងចំណុច ១២.៣.៦ ខាងលើ ត្រូវបានដាក់នៅ គជ/ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យរួចហើយ ដូចចែងក្រោមប្រការ ១២.៥ ខាងលើ នូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ គជ/ខប ត្រូវធានាថា រាល់នីតិវិធីដូចចែងក្នុងចំណុច ១២.៦.៣ ១២.៦.៤ ១២.៦.៥ ១២.៦.៦ និង ១២.៦.៧ ត្រូវតែបានអនុវត្តនៅមុនពេល គជ/ខប ប្រជុំសម្រេចលើពាក្យបណ្តឹង ។

១២.៧.៤ ប្រសិនបើ ឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនមួយ ឬច្រើន ហើយដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ/ខប ដូចចែងក្នុងចំណុច ១២.៣.៦ ខាងលើ ពាក់ព័ន្ធនឹងឃុំ សង្កាត់ ដែលក្រុមត្រួតពិនិត្យមិនទាន់បានត្រួតពិនិត្យលទ្ធផលនៅឡើយ គធ/ខប ត្រូវធានាថា រាល់នីតិវិធី ដូចចែងក្នុង ចំណុច ១២.៥.១ ១២.៥.៣ ១២.៦.៣ ១២.៦.៤ ១២.៦.៥ ១២.៦.៦ និង ១២.៦.៧ ត្រូវតែបានអនុវត្តនៅមុនពេល គធ/ខប ប្រជុំសម្រេចលើពាក្យបណ្តឹង ។

១២.៧.៥ ប្រសិនបើ ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធឡើងវិញ ដូចបញ្ជាក់ក្នុងចំណុច ១២.៧.២ ១២.៧.៣ និង ១២.៧.៤ ខាងលើ គធ/ខប មិនឃើញមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីណាមួយ ក្នុងដំណើរការនៃការបោះឆ្នោត ដែលនាំឱ្យផ្លាស់ប្តូរ ដល់លទ្ធផលនៃការបោះឆ្នោតទេនោះ គធ/ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង ដោយត្រូវអនុវត្តនីតិវិធី ដូចចែងក្រោមចំណុច ១២.៦.១១ ខាងលើ ។

១២.៧.៦ ប្រសិនបើ ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យ បោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធឡើងវិញ ដូចបញ្ជាក់ក្នុងចំណុច ១២.៧.២ ១២.៧.៣ និង ១២.៧.៤ ខាងលើ គធ/ខប បានរកឃើញភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងដំណើរការនៃការបោះឆ្នោត ដែលនាំឱ្យផ្លាស់ប្តូរដល់លទ្ធផលនៃការបោះឆ្នោតនោះ គធ/ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង ដោយត្រូវអនុវត្តនីតិវិធីដូចចែងក្រោមចំណុច ១២.៦.១២ ខាងលើ ។

១២.៧.៧ ការរកកម្រិតលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ ត្រូវអនុវត្តតាមរូបមន្តដូចមានចែងក្នុងឧបសម្ព័ន្ធទី ១១ នៃ ប.ន.ឃ.ស នេះ ។

១២.៧.៨ ក្នុងករណី គធ/ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រធាន គធ/ខប ត្រូវធានាថា នីតិវិធីដូចចែងក្រោមចំណុច ១២.៦.១៣ ត្រូវតែបានអនុវត្ត ។

**ការកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការស្រង់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**ប្រការ ១២.៨** បន្ទាប់ពីបានប្រគល់តារាងត្រួតពិនិត្យលទ្ធផល និងរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ដែលត្រូវបានចារយល់ព្រមទទួលយកលទ្ធផល ដោយប្រធាន គធ/ខប ដូចបញ្ជាក់ក្នុងចំណុច ១២.៥.២.២ និង ១២.៦.១១.៩ ខាងលើ ប្រធាន គធ/ខប ត្រូវធានាថា ក្រុមកំណត់ចំនួនអាសនៈបានបន្តអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួនដូចចែងក្រោម ចំណុច ១២.១.១០ ខាងលើ ។

១២.៨.១ ប្រធាន គធ/ខប ត្រូវធានាឱ្យមានកុំព្យូទ័រមួយសម្រាប់ ដែលមានម៉ាស៊ីនស្កេន ម៉ាស៊ីនបោះពុម្ព ប្រព័ន្ធអ៊ីមែល និងដែលបំពាក់ដោយកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ ផ្អែកតាមរូបមន្ត និងនីតិវិធីដូចចែងក្នុងជំពូកទី ៤ នៃ ប.ន.ឃ.ស នេះ ។ ប្រធាន គធ/ខប ត្រូវ ៖

១២.៨.១.១ ធានាថា គ្រឿងបរិក្ខារកុំព្យូទ័រត្រូវបានដំឡើងដំណើរការបានល្អត្រឹមត្រូវ និងមានផ្ទុកទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀត ។

១២.៨.១.២ ធានា ឱ្យមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត (បញ្ជីផ្លូវការ) មួយ (១) ច្បាប់ សម្រាប់ក្រុមកំណត់ចំនួនអាសនៈ ប្រើប្រាស់ក្នុងការពិនិត្យផ្ទៀងផ្ទាត់ ។

១២.៨.១.៣ ថែរក្សាថាសទន់ផ្ទុកកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ និងទិន្នន័យបញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្តឱ្យបានល្អ និងគត់មត់ ។

១២.៨.១.៤ ត្រូវរាយការណ៍ និងស្នើសុំជំនួយអន្តរាគមន៍ ជាបន្ទាន់ពី គ.ជ.ប ក្នុងករណីថាសទន់ផ្ទុកកម្មវិធីប្រតិបត្តិការបែងចែកអាសនៈត្រូវខូច ឬមិនអាចដំណើរការបាន ។

១២.៨.២ ប្រធានក្រុមកំណត់ចំនួនអាសនៈត្រូវធានាថា រាល់តារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦តព) និងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ដែលក្រុមបានទទួលដូចបញ្ជាក់ក្នុងប្រការ ១២.៨ ខាងលើ ត្រូវតែបានត្រួតពិនិត្យសុពលភាពឱ្យប្រាកដថា ប្រធាន គធ/ខប បានចារយល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធរួចហើយ ព្រមទាំងត្រូវបានរៀបចំដោយឡែក និងតាមលំដាប់លំដោយនៃលេខកូដឃុំ សង្កាត់ ។

១២.៨.៣ នៅក្នុងការផ្ទៀងផ្ទាត់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ប្រធានក្រុមកំណត់ចំនួនអាសនៈត្រូវ ៖

១២.៨.៣.១ ចាត់ចែងសមាជិកក្រុមឱ្យបំពេញក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ.១១០៥ធខ) ចំនួនបី (៣) ច្បាប់ ដោយចម្លងឱ្យបានត្រឹមត្រូវតាមតារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យ លទ្ធផលនៃ គធ/ខប (ទ. ១១១៦តព) ។

១២.៨.៣.២ ចាត់ចែងលេខាធិការក្រុមឱ្យបញ្ចូលទិន្នន័យលទ្ធផល ពីតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៦តព) ទៅក្នុងតារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ដែលមានស្រាប់ក្នុងកុំព្យូទ័រ ។

១២.៨.៣.៣ ធានាថា (ទ. ១១០៥ធខ) ទាំងអស់ដែលបានបំពេញត្រូវបានផ្ទៀងផ្ទាត់តួលេខលទ្ធផល ដោយការធ្វើប្រមាណវិធីដោយដៃ ឬ/និង ម៉ាស៊ីនគិតលេខ ហើយប្រៀបធៀបជាមួយ នឹងតួលេខលទ្ធផលក្នុង ទ. ១១១០ ដែលបានបោះពុម្ពពីកុំព្យូទ័រ ។

១២.៨.៣.៤ ធានាថា នីតិវិធីចាប់ពីចំណុច ១២.៨.៣.១ ដល់ ១២.៨.៣.៣ ត្រូវបានអនុវត្តឡើងវិញ ឱ្យបានហ្មត់ចត់និងត្រឹមត្រូវ ប្រសិនបើឃើញមានភាពខុសគ្នាក្នុងការផ្ទៀងផ្ទាត់តួលេខលទ្ធផលខាងលើ ។

១២.៨.៣.៥ ធានាថា តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) ចំនួនបី (៣) ច្បាប់ ដែលបានបោះពុម្ព និងផ្ទៀងផ្ទាត់ត្រូវបានចុះហត្ថលេខាសង្ខេប ដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ ។

១២.៨.៣.៦ ធានាថា ក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ.១១០៥ធខ) ទាំងបី (៣) ច្បាប់ ដែលផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ត្រូវបានចុះហត្ថលេខាសង្ខេប ដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ ។

១២.៨.៤ នៅក្នុងការគណនា និងកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធណាមួយប្រធានក្រុមកំណត់ចំនួនអាសនៈត្រូវ ៖

១២.៨.៤.១ ចាត់ចែងសមាជិកក្រុម និងលេខាធិការឱ្យសហការគ្នាបញ្ចូលយ៉ាងត្រឹមត្រូវ នូវទិន្នន័យនៃចំនួនសំឡេងឆ្នោតគាំទ្រគណបក្ស

នយោបាយដែលឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ទៅក្នុងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ដោយផ្អែកតាមតួលេខលទ្ធផលនៅក្នុងតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៦គ៣) និងក្រដាសលទ្ធផល (ទ. ១១០៥ធ២) ពាក់ព័ន្ធ ដែលបានផ្ទៀងផ្ទាត់រួចហើយដូចចែងក្រោមចំណុច ១២.៨.៣ ខាងលើ ។

១២.៨.៤.២ ធានាថា បន្ទាប់ពីបានបញ្ចូលទិន្នន័យត្រឹមត្រូវ និងបញ្ជាកម្មវិធីប្រតិបត្តិការកំណត់ចំនួនអាសនៈក្នុងកុំព្យូទ័រឱ្យគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ លេខាធិការបានបោះពុម្ពលទ្ធផលទាំងនេះ មួយ (១) ច្បាប់ ។

១២.៨.៤.៣ ចាត់ចែងសមាជិកដទៃទៀតក្នុងក្រុមឱ្យអនុវត្តប្រមាណវិធីដោយដៃ ឬ/និងម៉ាស៊ីនគិតលេខ ដោយផ្អែកតាមរូបមន្តនៃការបែងចែកអាសនៈដូចចែងក្នុងជំពូកទី ៨ នៃ ប.ន.ឃ.ស នេះ ដើម្បីគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.៨.៤.៤ ចាត់ចែងសមាជិកក្នុងក្រុមឱ្យសហការគ្នាផ្ទៀងផ្ទាត់ និងគណនាឡើងវិញ ដោយផ្អែកតាមរូបមន្តបែងចែកអាសនៈ ដូចចែងក្នុងជំពូកទី ៨ នៃ ប.ន.ឃ.ស នេះ ប្រសិនបើលទ្ធផលនៃការគណនាតាមរូបភាពទាំងពីរខាងលើមានភាពខុសគ្នា ។

១២.៨.៤.៥ ធានាថា ក្រដាសលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈតាមរូបភាពទាំងពីរ ដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវដូចគ្នា ហើយត្រូវបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ ។

១២.៨.៥ បន្ទាប់ពីបានអនុវត្តរាល់នីតិវិធីដូចចែងក្រោមចំណុច ១២.៨.៣ និង ១២.៨.៤ ខាងលើ ផ្អែកលើលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈ ដូចចែងក្នុងចំណុច ១២.៨.៤.៥ ខាងលើ ប្រធានក្រុមកំណត់ចំនួនអាសនៈត្រូវ ៖

១២.៨.៥.១ ចាត់ចែងសមាជិកក្រុម ឱ្យបំពេញលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ចំនួន បី (៣) ច្បាប់ នូវ ៖

ឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួនសំឡេងឆ្នោតគាំទ្រសរុបតាមគណបក្ស និងចំនួនអាសនៈ

ដែលគណបក្សនយោបាយនីមួយៗទទួលបាន ដោយគិតតាមលំដាប់ពីខ្ពស់ មកទាប ។

ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវជាប់ឆ្នោតជាសមាជិកឃុំ សង្កាត់ ក្នុងនោះត្រូវបញ្ជាក់ចំពោះបេក្ខជនដែលត្រូវជាប់ជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រងផង។

១២.៨.៥.២ ធានាថា ការស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែផ្អែកលើបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយ ដែលបានទទួលអាសនៈ ដោយគិតតាមលំដាប់ពីខ្ពស់មកទាប ។

១២.៨.៥.៣ ធានាថា លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ទាំងបី (៣) ច្បាប់ ត្រូវតែបានចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់ នៃក្រុមកំណត់ចំនួនអាសនៈ ។

១២.៨.៦ ប្រសិនបើការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយមានលទ្ធផលសំឡេងឆ្នោតស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ដែលនឹងត្រូវបានទទួលអាសនៈក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានក្រុមកំណត់ចំនួនអាសនៈត្រូវរាយការណ៍ជូនប្រធាន គធ/ខប ដើម្បីចាត់ចែងអនុវត្តការចាប់ឆ្នោត ដោយផ្អែកតាមលក្ខខណ្ឌ និងនីតិវិធីស្តីពីការចាប់ឆ្នោតដូចចែងក្នុងជំពូកទី ៤ នៃ ប.ន.ឃ.ស នេះ ។ ប្រធាន គធ/ខប ត្រូវធានាថា កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត ដូចបញ្ជាក់ក្នុងចំណុចនេះ ត្រូវបានធ្វើជាពីរ (២) ច្បាប់ ដែលមួយ (១) ច្បាប់ ត្រូវដាក់ក្នុងកញ្ចប់ " គពិសេស " នៃឃុំ សង្កាត់ពាក់ព័ន្ធរក្សាទុកជាឯកសាររបស់ គធ/ខប និងមួយ (១) ច្បាប់ទៀត ត្រូវដាក់ក្នុងកញ្ចប់ " ឃពិសេស " ផ្ញើជូន គ.ជ.ប ។

១២.៨.៧ ប្រសិនបើការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយមានលទ្ធផលសំឡេងឆ្នោតស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ដែលមានបេក្ខជនជាប់ឆ្នោត នឹងត្រូវជាប់ជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ប្រធានក្រុមកំណត់ចំនួនអាសនៈត្រូវរាយការណ៍ជូនប្រធាន គធ/ខប ដើម្បីចាត់ចែងអនុវត្តការចាប់ឆ្នោត ដោយផ្អែកតាមនីតិវិធីដូចចែងក្នុងជំពូកទី ៤ នៃ ប.ន.ឃ.ស នេះ ។ ប្រធាន គធ/ខប ត្រូវធានាថា កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត ដូចបញ្ជាក់ក្នុងចំណុចនេះ ត្រូវបានធ្វើជាពីរ (២) ច្បាប់ ដែលមួយ (១) ច្បាប់ ត្រូវដាក់ក្នុងកញ្ចប់ " គពិសេស " នៃឃុំ សង្កាត់ពាក់ព័ន្ធ រក្សាទុកជាឯកសាររបស់ គធ/ខប និងមួយ (១) ច្បាប់ ទៀតត្រូវ ដាក់ក្នុងកញ្ចប់ " ឃពិសេស " ផ្ញើជូន គ.ជ.ប ។

**ការបំពេញលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**ប្រការ ១២.៩** បន្ទាប់ពីបានត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ កំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ស្រង់ឈ្មោះបេក្ខជនដែលត្រូវជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងកំណត់ឈ្មោះបេក្ខជនដែលត្រូវជាប់ឆ្នោតជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង នៃឃុំ សង្កាត់នីមួយៗ ចំណុះរាជធានី ខេត្ត រួចរាល់ហើយ ប្រធាន គធ/ខប ត្រូវធានាថា តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) ក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ. ១១០៥ធខ) និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ត្រូវតែបានបំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទ រួចបញ្ជូនដោយវេចខ្ចប់អមទៅជាមួយនូវសម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប ដើម្បីពិនិត្យសម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ ។

១២.៩.១ តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) ចំនួនបី (៣) ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវ រួចហើយ ដូចបញ្ជាក់ក្នុងចំណុច ១២.៨.៣.៥ ខាងលើ ត្រូវចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គធ/ខប រួចដាក់បង្ហាញ ចំពោះភ្នាក់ងារនៃគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។ ប្រធាន គធ/ខប ត្រូវចាត់ចែង និងប្រើប្រាស់តារាងលទ្ធផលខាងលើនេះដូចខាងក្រោម ៖

១២.៩.១.១ ផ្ញើជូន គ.ជ.ប ពីរ (២) ច្បាប់ ដែលត្រូវដាក់ក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្ទង់ថា " តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត... ផ្ញើជូន គ.ជ.ប " ។

១២.៩.១.២ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.៩.១.៣ ធានាថា តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត តាមឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត (ទ. ១១១០) ក្នុងកុំព្យូទ័រ ដែលមានទិន្នន័យដូចគ្នានឹងតារាងលទ្ធផល ដែលបានចុះហត្ថលេខាជាផ្លូវការរួចហើយ ត្រូវបានបញ្ជូនតាមអ៊ីមែលជាបន្ទាន់ទៅ គ.ជ.ប តាមអាសយដ្ឋានអ៊ីមែលតែមួយគត់ ដែលបានកំណត់ ។

១២.៩.២ ក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ (ទ. ១១០៥ធខ) ចំនួនបី (៣) ច្បាប់ ដែលបានបំពេញរួចហើយ ដូចបញ្ជាក់ក្នុងចំណុច ១២.៨.៣.៦

ខាងលើ ត្រូវចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គធ/ខប រួចដាក់បង្ហាញចំពោះភ្នាក់ងារនៃគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។ ប្រធាន គធ/ខប ត្រូវចាត់ចែង និងប្រើប្រាស់ក្រដាសលទ្ធផលខាងលើនេះ ដូចខាងក្រោម ៖

១២.៩.២.១ បិទផ្សាយមួយ (១) ច្បាប់ នៅលេខាធិការដ្ឋាន គធ/ខប ។

១២.៩.២.២ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ដែលត្រូវដាក់ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្ពង់ថា " ក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់លេខ... (បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ) ផ្ញើជូន គ.ជ.ប " ។

១២.៩.២.៣ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.៩.៣ លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ចំនួនបី (៣) ច្បាប់ ដែលបានបំពេញរួចហើយដូចបញ្ជាក់ក្នុងចំណុច ១២.៨.៥.៣ ខាងលើ ត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គធ/ខប រួចដាក់បង្ហាញចំពោះភ្នាក់ងារនៃគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។ ប្រធាន គធ/ខប ត្រូវចាត់ចែង និងប្រើប្រាស់លទ្ធផលខាងលើនេះ ដូចខាងក្រោម ៖

១២.៩.៣.១ បិទផ្សាយមួយ (១) ច្បាប់ នៅលេខាធិការដ្ឋាន គធ/ខប ។

១២.៩.៣.២ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ដែលត្រូវដាក់ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្ពង់ថា " លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លេខ... (បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ) ផ្ញើជូន គ.ជ.ប " ។

១២.៩.៣.៣ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.៩.៤ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ត្រូវកត់ចម្លងឱ្យបានត្រឹមត្រូវនូវលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ពីក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតដែលបានបិទផ្សាយ ដូចចែងក្នុងចំណុច ១២.៩.២.១ និង ១២.៩.៣.១ ខាងលើ ។

**ការវេចខ្ចប់ និងបញ្ជូនលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងរាល់សម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប**

**ប្រការ ១២.១០** បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចចែងចាប់ពីប្រការ ១២.៤ ដល់ ១២.៩ នៃជំពូកនេះ ប្រធាន គធ/ខប ត្រូវធានាថា តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) ក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ. ១១០៥ធខ) លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) និងរាល់កញ្ចប់ " គ " ដាក់សម្ភារៈ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ទាំងអស់ចំណុះរាជធានី ខេត្ត ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ " ឃពិសេស " និងកញ្ចប់ " ឃ " បញ្ជូន និងប្រគល់ជូន គ.ជ.ប បានយ៉ាងត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ ក្រោយពេលទទួលកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។ ក្នុងករណីមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់មួយ ឬច្រើនត្រូវបានដាក់នៅ គធ/ខប ប្រធាន គធ/ខប អាចចាត់ចែងវេចខ្ចប់រាល់ក្រដាសលទ្ធផល និងសម្ភារៈ ឯកសារបោះឆ្នោតដូចបញ្ជាក់ ខាងលើ ដើម្បីបញ្ជូន និងប្រគល់ជូន គ.ជ.ប នៅក្រោយពេលដែល គធ/ខប ដោះស្រាយបណ្ដឹងចប់សព្វគ្រប់ ស្របតាម ច.ប.ឃ.ស និង ប.ន.ឃ.ស ។

១២.១០.១ ប្រធាន គធ/ខប ត្រូវធានាថា រាល់សម្រង់សេចក្ដីសម្រេចបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងឃុំ សង្កាត់ដែលលទ្ធផលនៃការបោះឆ្នោតត្រូវបានសម្រេចព្យួរជាបណ្ដោះអាសន្ន ដូចបញ្ជាក់ក្នុងចំណុច ១២.៦.១២ និង ១២.៧.៤ ខាងលើ ត្រូវតែបានវេចខ្ចប់ដោយឡែកតាមឃុំ សង្កាត់ ដូចចែងក្រោមចំណុច ១២.៦.១៣ ខាងលើ និងបញ្ជូនទៅ គ.ជ.ប មិនឱ្យលើសពីម្ភៃបួន (២៤) ម៉ោង បន្ទាប់ពីពេលដែល គធ/ខប បានសម្រេចបដិសេធ ដើម្បី គ.ជ.ប ត្រួតពិនិត្យឡើងវិញ ។

១២.១០.២ ចំពោះករណី ឃុំ សង្កាត់ទាំងឡាយណា ដែលលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះ ត្រូវបាន គធ/ខប សម្រេចយល់ព្រម ប្រធាន គធ/ខប ត្រូវត្រៀមកញ្ចប់ " ឃពិសេស " មួយសម្រាប់ដាក់រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោត ដែលនឹងត្រូវផ្ញើជូន គ.ជ.ប និងត្រូវធានាថា រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតទាំងនោះ ត្រូវតែបានត្រួតពិនិត្យឡើងវិញ និងរៀបចំចងជាបាច់ ដោយឡែកពីគ្នាទៅតាមប្រភេទឯកសារក្នុងស្រោមសំបុត្រ ។ នៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតនៅឃុំ សង្កាត់នីមួយៗ ប្រធាន គធ/ខប ត្រូវប្រមូល និងរៀបចំដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " នូវ ៖

១២.១០.២.១ ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) ផ្ញើជូន គ.ជ.ប ដែលប្រធានក្រុមត្រួតពិនិត្យលទ្ធផលបានប្រគល់ជូន ដូចបញ្ជាក់ក្នុងចំណុច ១២.៥.១.៣ និង ១២.៥.៣ ខាងលើ ។

១២.១០.២.២ រាល់ស្រោមសំបុត្រដាក់តារាងលទ្ធផល (ទ. ១១១០) ក្រដាសលទ្ធផល (ទ. ១១០៥ធខ) និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ដូចចែងក្នុងចំណុច ១២.៩.១.១ ១២.៩.២.២ និង ១២.៩.៣.២ ខាងលើ ។

១២.១០.២.៣ រាល់តារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៦តព) របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ឬ/និងរបាយកាណ៍របស់ គឃ/សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន)ដូចមានបញ្ជាក់ក្នុងចំណុច ១២.៥.២.២ និង១២.៦.១១.១ ខាងលើ និងដែលបានប្រើប្រាស់ក្នុងការអនុវត្តករណី ដូចចែងក្នុងចំណុច ១២.៦.១១ ខាងលើ ។

១២.១០.២.៤ រាល់សម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ពាក់ព័ន្ធនឹងពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រមួយ និងកាខ្ចងផ្ញើជូន គ.ជ.ប ។

១២.១០.២.៥ រាល់កំណត់ហេតុស្ដីពីលទ្ធផល នៃការចាប់ឆ្នោតក្នុងករណីមានសំឡេងឆ្នោតស្មើគ្នា រវាងគណបក្សនយោបាយពីរ ឬច្រើន ឬ/និងដែលមានបេក្ខជនជាប់ឆ្នោតនឹងត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ដូចចែងក្នុងចំណុច ១២.៨.៦ និង ១២.៨.៧ ខាងលើ (ប្រសិនបើមាន) ។

១២.១០.២.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) មួយ (១) ច្បាប់ ។

១២.១០.៣ ប្រធាន គធ/ខប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនបី (៣) ច្បាប់ ដោយមានសរសេររាយ

មុខសម្ភារៈ ឯកសារដែលបានដាក់ក្នុងកញ្ចប់ " ឃពិសេស " ខាងលើ ហើយត្រូវដាក់មួយ (១) ច្បាប់ ទៅក្នុងកញ្ចប់ " ឃពិសេស " ដាក់មួយ (១) ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ឃពិសេស " និងរក្សាទុក មួយ (១) ច្បាប់សម្រាប់ប្រើក្នុងការប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

១២.១០.៤ ប្រធាន គធ/ខប ត្រូវបិទភ្ជិតកញ្ចប់ " ឃពិសេស " រួចហើយត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្តរបស់ខ្លួននៅលើផ្នែកខាងក្រៅនៃកញ្ចប់ " ឃពិសេស" ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ។

១២.១០.៥ បន្ទាប់មកប្រធាន គធ/ខប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់កញ្ចប់ " គ " នៃឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ហើយដែលបានត្រួតពិនិត្យលទ្ធផលឡើងវិញ ដូចចែងក្រោមប្រការ ១២.៥ ខាងលើ ដោយដាក់ទៅក្នុងកញ្ចប់ " ឃ " តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់កញ្ចប់ " គ " នៃឃុំ សង្កាត់ដែលគ្មានបណ្តឹង ។ ក្នុងការវេចខ្ចប់នេះ គធ/ខប ត្រូវ ៖

១២.១០.៥.១ ដាក់កញ្ចប់ " គ " តាមលំដាប់លេខរៀងនៃលេខកូដឃុំ សង្កាត់ ប្រសិនបើអាច ទៅក្នុងកញ្ចប់ " ឃ " នីមួយៗ ។

១២.១០.៥.២ ធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនបី (៣) ច្បាប់ ត្រូវបានបំពេញដោយមានរាយមុខសម្ភារៈ ឯកសារ ដែលបានដាក់ក្នុងកញ្ចប់ " ឃ " នីមួយៗ ហើយត្រូវបានដាក់ មួយ (១) ច្បាប់ ទៅក្នុងកញ្ចប់ " ឃ " ដាក់មួយ (១) ច្បាប់ ទៅក្នុងហោប៉ៅនៃកញ្ចប់ " ឃ " និងរក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

១២.១០.៥.៣ ចងភ្ជិតកញ្ចប់ " ឃ " នីមួយៗ និងចាក់សោឃ្លុំមានលេខ រួចសរសេរសម្គាល់ពីក្រៅកញ្ចប់ " ឃ " នីមួយៗ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះនូវលេខកូដឃុំ សង្កាត់ ពាក់ព័ន្ធពីលេខប៉ុន្មានដល់លេខប៉ុន្មាន និងពាក្យថា " គ្មានបណ្តឹង/ពិនិត្យរួច " ។

១២.១០.៦ ប្រសិនបើ ក្នុងរាជធានី ខេត្តមានឃុំ សង្កាត់មួយចំនួនមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលតម្រូវឱ្យមានការបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យមួយ

ឬច្រើន ប្រធាន គឃ/ខប ត្រូវធានាថា រាល់កញ្ចប់ " គ មានបណ្ដឹងបើកកញ្ចប់សុវត្ថិភាព ក " នៃឃុំ សង្កាត់ពាក់ព័ន្ធទាំងនោះ ត្រូវតែបានវេចខ្ចប់ក្នុងកញ្ចប់ " ឃ " ដោយឡែក ។ ប្រធាន គឃ/ខប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់កញ្ចប់ " គ មានបណ្ដឹងបើកកញ្ចប់សុវត្ថិភាព ក " នៃឃុំ សង្កាត់ទាំងនោះ ហើយដែលបានត្រួតពិនិត្យលទ្ធផលឡើងវិញ ដូចចែងក្រោម ប្រការ ១២.៦ និង ១២.៧ ខាងលើ ដោយដាក់ទៅក្នុងកញ្ចប់ " ឃ " ដោយឡែកតាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់កញ្ចប់ " គ មានបណ្ដឹង បើកកញ្ចប់ សុវត្ថិភាព ក " នៃឃុំ សង្កាត់ទាំងនោះ ។ ក្នុងការវេចខ្ចប់នេះ គឃ/ខប ត្រូវ ៖

១២.១០.៦.១ ដាក់រាល់កញ្ចប់ " គ មានបណ្ដឹង បើកកញ្ចប់សុវត្ថិភាព ក " នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលមានការបើកកញ្ចប់សុវត្ថិភាព " ក " ទៅក្នុងកញ្ចប់ " ឃ " ដោយឡែក ។

១២.១០.៦.២ ធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ. ១១០៧) ចំនួនបី (៣) ច្បាប់ ត្រូវបានបំពេញ ដោយមានរាយមុខសម្ភារៈ ឯកសារដែលបានដាក់ក្នុងកញ្ចប់ " ឃ " ពាក់ព័ន្ធ ហើយត្រូវដាក់មួយ (១) ច្បាប់ទៅក្នុងកញ្ចប់ " ឃ " ដាក់មួយ (១) ច្បាប់ ទៅក្នុងហោប៉ៅនៃកញ្ចប់ " ឃ " និង រក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

១២.១០.៦.៣ ចងភ្ជិតកញ្ចប់ " ឃ " និងចាក់សោឃ្លុំ ។

១២.១០.៦.៤ សរសេរសម្គាល់ពីក្រៅកញ្ចប់ " ឃ " ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ នូវលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ និងពាក្យថា " មានបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព ក " ។

១២.១០.៧ ក្នុងករណីមានកញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ១២.១០.៥ ឬ/និង ១២.១០.៦ ខាងលើ សរុបលើសពីមួយ ប្រធាន គឃ/ខប ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃកញ្ចប់ " ឃ " ទាំងនោះ នូវលេខរៀងនៃកញ្ចប់ " ឃ " នីមួយៗ ។ ឧទាហរណ៍: ប្រសិនបើមានកញ្ចប់ " ឃ " សរុបចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀង ១/៣ ២/៣ និង ៣/៣ ។

១២.១០.៨ ប្រធាន គធ/ខប ត្រូវប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដែលមានវត្តមានឱ្យចូលរួមជាសាក្សី ក្នុងការបញ្ជូន និងការប្រគល់ទទួលកញ្ចប់ " ឃពិសេស " និងរាល់កញ្ចប់ " ឃ " ខាងលើនេះ ហើយត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរនៃការបញ្ជូន ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ទទួលនៅទីស្តីការ គ.ជ.ប ។

១២.១០.៩ ប្រធាន គធ/ខប ត្រូវធានាថារាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែលបានទទួលពី គឃ/សខ ចំណុះរាជធានី ខេត្ត ឬ/និងមាននៅលេខាធិការដ្ឋាន គធ/ខប ត្រូវតែបានវេចខ្ចប់ និងបញ្ជូនដោយឡែកទៅ គ.ជ.ប នៅពេលក្រោយ ។ នៅក្នុងការវេចខ្ចប់ បញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ ប្រធាន គធ/ខប ត្រូវធានាថា ទ. ១១០៧ ត្រូវតែបានបំពេញ និងប្រើប្រាស់តាមលក្ខការណ៍នៃការប្រគល់ ទទួល សម្ភារៈ ឯកសារបោះឆ្នោត ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ គ.ជ.ប ពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់**

**ប្រការ** ១២.១១ អ្នកប្តឹង ឬតំណាង ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គធ/ខប លើពាក្យបណ្តឹងរបស់ខ្លួន ពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ដូចបញ្ជាក់ក្នុងចំណុច ១២.៦.១១.៦ និងដែលត្រូវបានបដិសេធពាក្យបណ្តឹងក្នុងការអនុវត្តករណីដូចចែងក្នុងចំណុច ១២.៧.៥ ខាងលើ មានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរបួន (៤) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធ ។

១២.១១.១ រាល់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដូចបញ្ជាក់ក្នុងប្រការ ១២.១១ ខាងលើ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងដាក់ពាក្យប្តឹងនៅទីស្តីការ គ.ជ.ប ហើយ គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងទាំងនេះ ក្នុងរយៈពេលយ៉ាងយូរបួន (៤)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

១២.១១.២ ប្រសិនបើ នៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានការប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចបដិសេធរបស់ គធ/ខប លើបណ្តឹងពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ពាក់ព័ន្ធ ។

១២.១១.៣ អ្នកប្តឹងជំទាស់ ឬតំណាង ដែលមានបំណងប្តឹងតវ៉ា ឬប្តឹងជំទាស់ ដូចបញ្ជាក់ក្នុងប្រការ ១២.១១ ខាងលើ ត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃ លើពាក្យបណ្តឹង ចំនួនបី (៣) ដែលក្នុងនោះត្រូវផ្តល់ព័ត៌មានច្បាស់លាស់មួយចំនួន ដូចមានចែងក្នុងចំណុច ១៦.៣.៥ ប្រការ ១៦.៣ ជំពូកទី ១៦ នៃ ប.ន.ឃ.ស ។

១២.១១.៤ ពាក្យបណ្តឹងតវ៉ា ដែលត្រូវបានដាក់ប្តឹងនៅ គ.ជ.ប ក្រោយពេលវេលា ដូចចែងក្នុងប្រការ ១២.១១ ខាងលើ និងពាក្យបណ្តឹងដែលគ្មានឯកសារ និងភស្តុតាងគ្រប់គ្រាន់ ដូចចែងក្នុងចំណុច ១២.១១.៣ ខាងលើ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទ ឱ្យបានច្បាស់លាស់ រួចដាក់ជូនអគ្គលេខាធិការចារបញ្ជាក់ពីការហួសពេលទទួលពាក្យបណ្តឹង ចុះហត្ថលេខា និងបោះត្រា លើពាក្យបណ្តឹងនោះ ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ និង ជម្រាបអ្នកប្តឹង ឬតំណាងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គ.ជ.ប មិនអាចទទួលដោះស្រាយបានទេ ។

១២.១១.៥ គ.ជ.ប ត្រូវបដិសេធការទទួលដោះស្រាយ ពាក្យបណ្តឹងតវ៉ា ដែលគ្មានឯកសារ និងភស្តុតាងគ្រប់គ្រាន់ និងប្រគល់សិទ្ធិជូន អគ្គលេខាធិការ ចារបដិសេធលើបណ្តឹងតវ៉ា និងបញ្ជាក់មូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ រួចចុះហត្ថលេខា និងបោះត្រា គ.ជ.ប និងប្រគល់ជូនអ្នកប្តឹង ឬតំណាងមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.១១.៦ ចំពោះពាក្យបណ្តឹងតវ៉ា មានឯកសារ និងភស្តុតាងគ្រប់គ្រាន់ ដែលត្រូវបានដាក់ប្តឹងនៅ គ.ជ.ប ក្នុងរយៈពេលដូចចែងក្នុងប្រការ ១២.១១ ខាងលើ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៃ គ.ជ.ប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង បន្ទាប់មកត្រូវ ៖

១២.១១.៦.១ ប្រគល់ពាក្យបណ្តឹងនោះមួយ (១) ច្បាប់ជូនអ្នកប្តឹង ឬតំណាង ។

១២.១១.៦.២ ប្រាប់អ្នកប្តឹង ឬតំណាងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្តឹងតវ៉ារបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ ។

១២.១១.៧ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរាយការណ៍ ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការអំពីករណីនៃបណ្ដឹង ដោយភ្ជាប់ពាក្យបណ្ដឹងតវ៉ាដែលបានទទួល និងសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប បដិសេធលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ដូចចែងក្នុងចំណុច ១២.៦.១១.៥ ដែលត្រូវដកចេញពីកញ្ចប់ " ឃពិសេស " និងដើម្បីសុំការណែនាំពី គ.ជ.ប អំពីករណីនៃការត្រួតពិនិត្យលទ្ធផល និងភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។ ផ្អែកតាមការណែនាំខាងលើនេះ អគ្គលេខាធិការ ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះ នៅចំពោះមុខភ្នាក់ងារ គណបក្សនយោបាយពាក់ព័ន្ធ អ្នកប្ដឹងតវ៉ា ឬតំណាង និងអ្នកសង្កេតការណ៍ ។

**ការបង្កើតក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិ បម្រើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**ប្រការ ១២.១២** ក្នុងគោលបំណងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ គ.ជ.ប ត្រូវបង្កើតក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតមួយ (១) ក្រុមត្រួតពិនិត្យលទ្ធផលមួយចំនួនតាមការចាំបាច់ និងក្រុមកំណត់បែងចែកអាសនៈមួយ (១) ព្រមទាំងត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីបម្រើឱ្យការងារត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញនេះ ។

១២.១២.១ ក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតមួយត្រូវបានបង្កើតឡើងនៅ គ.ជ.ប ដើម្បីធានាការទទួលកញ្ចប់ " ឃពិសេស " ដាក់សំណុំឯកសារលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងកញ្ចប់ " ឃ " ដាក់សម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធដែល គធ/ខប បានបញ្ជូន និងប្រគល់ជូន គ.ជ.ប ព្រមទាំងធានាការបែងចែក និងរក្សាទុកសម្ភារៈ ឯកសារទាំងនោះ នៅបន្ទប់ស្តុកតាមរាជធានី ខេត្ត នីមួយៗ ។

១២.១២.១.១ ក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតត្រូវដឹកនាំដោយ ប្រធាននាយកដ្ឋានរដ្ឋបាល និងមានមន្ត្រីនាយកដ្ឋានប្រតិបត្តិការ ពីរ (២) រូប មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម មួយ (១) រូប និង មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ មួយ (១) រូប ជាសមាជិក ។

១២.១២.១.២ ក្រុមនេះ ត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ។

១២.១២.២ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប មួយចំនួនត្រូវបានបង្កើតឡើង តាមការចាំបាច់នៅ គ.ជ.ប ដើម្បីអនុវត្តការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ចំណុះរាជធានី ខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ។ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗរួមមានសមាសភាព ដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋាននានាចំណុះអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និងត្រូវបានបែងចែកឱ្យទទួលបន្ទុកត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ សម្រាប់រាជធានី ខេត្តមួយ ឬច្រើន ។

១២.១២.២.១ ក្រុមត្រួតពិនិត្យ លទ្ធផលនីមួយៗត្រូវមានសមាសភាពបួន (៤) រូប ដែលដឹកនាំដោយប្រធានមួយ (១) រូប អនុប្រធានមួយ (១) រូប លេខាធិការមួយ (១) រូប និងជំនួយការមួយ (១) រូប ។

១២.១២.២.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ។

១២.១២.៣ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗរបស់ គ.ជ.ប មានភារកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ ដោយឡែកពីគ្នារួចត្រូវបំពេញតួលេខលទ្ធផលនៃការត្រួតពិនិត្យនេះ នៅលើតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១៧គ៣) ។ ក្នុងករណីឃុំ សង្កាត់ មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវ បានដាក់នៅ គ.ជ.ប ឬលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ត្រូវបានព្យួរជាបណ្តោះអាសន្នដោយ គធ/ខប ក្រុមត្រួតពិនិត្យលទ្ធផល ត្រូវអនុវត្តបន្ថែមដោយធ្វើរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ។ ប្រធានក្រុមត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផល ឬ/និងរបាយការណ៍ខាងលើត្រូវបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមពាក់ព័ន្ធ និងត្រូវដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ ការត្រួតពិនិត្យលទ្ធផលនេះត្រូវអនុវត្តដោយផ្អែកលើ ៖

១២.១២.៣.១ តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ. ១១០៥ធខ) និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ។

១២.១២.៣.២ កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ (ទ. ១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) ដែល គឃ/សប ផ្ញើជូន គ.ជ.ប ។

១២.១២.៣.៣ តារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៦តព) ព្រមទាំងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គឃ/ខប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ឬ/និង របាយការណ៍របស់ គឃ/សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន) ។

១២.១២.៣.៤ សេចក្ដីសម្រេចរបស់ គឃ/ខប លើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ និងរាល់ឯកសារពាក់ព័ន្ធនឹងពាក្យបណ្ដឹង (ប្រសិនបើមាន) ។

១២.១២.៣.៥ កំណត់ហេតុស្ដីពីលទ្ធផលនៃការចាប់ឆ្នោត ដូចចែងក្នុងចំណុច ១២.៨.៦ និង ១២.៨.៧ ខាងលើ (ប្រសិនបើមាន) ។

១២.១២.៣.៦ ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ដែលបានដាក់នៅ គ.ជ.ប ដូចចែងក្រោមប្រការ ១២.១១ ខាងលើ (ប្រសិនបើមាន) ។

១២.១២.៣.៧ លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គ.ជ.ប (ប្រសិនបើ គ.ជ.ប សម្រេចឱ្យធ្វើដូច្នេះ) ។

១២.១២.៤ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប មួយក្រុមត្រូវបានបង្កើតឡើងនៅ គ.ជ.ប ដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ចំណុះរាជធានី ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអនុវត្តការបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងកុំព្យូទ័រ និងការអនុវត្តកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ។

១២.១២.៤.១ ក្រុមកំណត់បែងចែកអាសនៈត្រូវមានសមាសភាពមួយចំនួនតាមការចាំបាច់ ដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងខុទ្ទកាល័យអគ្គលេខាធិការ ។

១២.១២.៤.២ ក្រុមនេះត្រូវដឹកនាំដោយប្រធានមួយ (១) រូប ដែលជាប្រធាននាយកដ្ឋានប្រតិបត្តិការ អនុប្រធាន (១) រូប ដែលជាប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម អនុប្រធានមួយ (១) រូប ទៀតដែលជាអនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវចាត់តាំងឱ្យមានលេខាធិការមួយ (១) រូប ជាជំនួយការ ។

១២.១២.៤.៣ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ។

១២.១២.៥ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួននៅបន្ទប់កុំព្យូទ័រនៃនាយកដ្ឋានប្រតិបត្តិការ និងត្រូវមានការទទួលខុសត្រូវ និងភារកិច្ចដូចខាងក្រោម ៖

១២.១២.៥.១ បញ្ចូលជាបណ្តើរៗ នូវទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោតតាមឃុំសង្កាត់នៃរាជធានី ខេត្តទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) ដែល គធ/ខប បានផ្ញើជូនតាមអ៊ីមែល ឬ/និងទូរសារ បន្ទាប់មកកែតម្រូវ និងផ្ទៀងផ្ទាត់លទ្ធផលបឋមនៃការបោះឆ្នោតតាមឃុំ សង្កាត់ទៅនឹងក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ. ១១០៥ធខ) និងតារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យលទ្ធផល (ទ. ១១១៧តព) ដែល គ.ជ.ប បានពិនិត្យសម្រេចរួចហើយ ។

១២.១២.៥.២ បោះពុម្ពសេចក្តីព្រាងតារាងលទ្ធផលបឋមនៃការបោះឆ្នោត តាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដើម្បីពិនិត្យសម្រេច និងផ្សព្វផ្សាយជាសាធារណៈ ។

១២.១២.៥.៣ កែតម្រូវតួលេខលទ្ធផល យោងតាមសេចក្តីសម្រេចរបស់ គ.ជ.ប លើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ (ប្រសិនបើមាន) និងរៀបចំបោះពុម្ពសេចក្តីព្រាងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោត តាមឃុំ សង្កាត់ទូទាំងប្រទេស និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដើម្បីពិនិត្យសម្រេចជាផ្លូវការ និងផ្សព្វផ្សាយសាធារណៈ ។

១២.១២.៥.៤ កំណត់បែងចែកអាសនៈ យោងតាមតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតតាមឃុំ សង្កាត់ទូទាំងប្រទេស ដោយគណនាតាមការធ្វើប្រមាណវិធីដោយដៃ និងដោយប្រើកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ តាមរូបមន្តដែលកំណត់ដោយច្បាប់ និងដូចចែងក្នុងជំពូកទី៩ នៃ ប.ន.ឃ.ស នេះ ។

១២.១២.៥.៥ បោះពុម្ពតារាងផ្ទៀងផ្ទាត់បែងចែកអាសនៈតាមឃុំ សង្កាត់ដែលគណបក្សនយោបាយនីមួយៗ ត្រូវទទួលបាន រួចផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលនៃការបែងចែកអាសនៈដែលគណនាដោយដៃ បន្ទាប់មកស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តាម

ចំនួនអាសនៈ និងលំដាប់លេខរៀង ពីក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលត្រូវទទួលបានអាសនៈ បំពេញទៅក្នុងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងដោយមានបញ្ជាក់បេក្ខជនជាប់ឆ្នោតជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រងផង ។

១២.១២.៥.៦ ផ្ទៀងផ្ទាត់ជាបន្ថែមនូវតួលេខ និងទិន្នន័យក្នុងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយនឹងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ។

១២.១២.៥.៧ រៀបចំតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ ដែលបានគណនាឃើញតាមរូបភាពទាំងពីរ មួយមុខមួយ (១) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយលេខាធិការ អនុប្រធានក្រុម និងប្រធានក្រុម និងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១៨) ចំនួនប្រាំ (៥) ច្បាប់ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចជាផ្លូវការ ។

១២.១២.៦ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវណែនាំ និងចាត់ចែងក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប នៅក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ អគ្គលេខាធិការត្រូវពិនិត្យរាល់សំណុំឯកសាររបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

១២.១២.៧ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវត្រៀមបន្ទប់មួយចំនួននៅទីស្តីការ គ.ជ.ប សម្រាប់ធ្វើជាឃ្លាំងស្តុកកញ្ចប់ " យពិសេស " ដាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងកញ្ចប់ " យ " ដាក់សម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ ក្នុងនោះត្រូវ ៖

១២.១២.៧.១ ត្រៀមបន្ទប់មួយដោយឡែក នៅជាន់ផ្ទាល់ដីសម្រាប់រក្សាទុករាល់ស្រោមសំបុត្រធំដាក់សេចក្តីសម្រេចរបស់ គឃ/ខប ព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ និងរាល់

កញ្ចប់ " ឃ " ដាក់កញ្ចប់ " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះត្រូវបាន បដិសេធ ។

១២.១២.៧.២ ត្រៀមបន្ទប់មួយដោយឡែកនៅជាន់ទី ១ សម្រាប់ដាក់រាល់កញ្ចប់ " ឃពិសេស " នៃ គឃ/ខប ទាំងអស់ ។

១២.១២.៧.៣ ត្រៀមបន្ទប់មួយចំនួននៅជាន់ផ្ទាល់ដី សម្រាប់ស្តុកកញ្ចប់ " ឃ " ដែលមានដាក់កញ្ចប់ " គ " ហើយដែលត្រូវដាក់ដោយឡែកពីគ្នា ទៅតាមរាជធានី ខេត្តនីមួយៗ ។

១២.១២.៨ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវត្រៀមបន្ទប់ធំទូលាយមួយចំនួន ឬបន្ទប់តូចៗ ច្រើន ដែលអាចឱ្យក្រុមត្រួតពិនិត្យលទ្ធផលបំពេញការងាររបស់ខ្លួនបានល្អ ។

១២.១២.៨.១ ក្រុមត្រួតពិនិត្យលទ្ធផលពីរ ឬច្រើនក្រុមអាចបំពេញការងាររបស់ខ្លួន នៅជុំគ្នាក្នុងបន្ទប់តែមួយ ឬនៅបន្ទប់ដោយឡែកពីគ្នា ដោយផ្អែក តាមលទ្ធភាពជាក់ស្តែង ។

១២.១២.៨.២ សេចក្តីជូនដំណឹងស្តីពី ពេលវេលា កាលបរិច្ឆេទ ទីកន្លែង ឈ្មោះ និងលេខកូដឃុំ សង្កាត់ និងរាជធានី ខេត្ត ដែលត្រូវ ធ្វើការត្រួតពិនិត្យលទ្ធផលឡើងវិញ ព្រមទាំងលេខក្រុម និងឈ្មោះ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលដែលទទួលបន្ទុក ត្រូវតែបានបិទ ផ្សាយជាសាធារណៈនៅមុខទីស្តីការ គ.ជ.ប ដើម្បីជាដំណឹងដល់ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍និងអ្នកប្តឹង ឬតំណាង ដែលទទួលបានការអនុញ្ញាតឱ្យចូលរួមក្នុងដំណើរការ ត្រួតពិនិត្យលទ្ធផលនោះ ។

១២.១២.៩ ក្នុងអំឡុងពេលនៃដំណើរការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញនៅ គ.ជ.ប លក្ខខណ្ឌសន្តិសុខនៅជុំវិញបរិវេណ និងក្នុងទីស្តីការ គ.ជ.ប ព្រមទាំងសណ្តាប់ ធ្នាប់ និងរបៀបរៀបរយត្រូវតែបានពង្រឹងតាមវិធានការរដ្ឋបាលដែលគ្រប់គ្រង និង ចាត់ចែងដោយអគ្គលេខាធិការ ។

១២.១២.៩.១ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍និងអ្នកប្តឹង ឬតំណាង ដែលទទួលបានការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការ

ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញនៅទីស្តីការ គ.ជ.ប ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់អគ្គលេខាធិការនៃ គ.ជ.ប ឬមន្ត្រីដែលត្រូវបានប្រគល់សិទ្ធិ ។

១២.១២.៩.២ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាង ដែលទទួលបានការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញនៅទីស្តីការ គ.ជ.ប ត្រូវគោរពក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត និង ប.ន.ឃ.ស នេះ ហើយមិនត្រូវធ្វើសកម្មភាព ឬអំពើអ្វីមួយដែលរំខានអុកឡុក ឬរារាំងដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ឬបំពានលើសិទ្ធិអំណាច និងឯករាជភាពរបស់ គ.ជ.ប ឡើយ ។

១២.១២.១០ ហាមជនគ្រប់រូបចូលក្នុងបន្ទប់ ដែលក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប កំពុងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលខាងលើនេះ នូវជនទាំងឡាយដូចខាងក្រោម ៖

១២.១២.១០.១ មន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈដែលបានទទួលការតែងតាំងពី គ.ជ.ប ។

១២.១២.១០.២ ភ្នាក់ងារនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងឃុំ សង្កាត់ពាក់ព័ន្ធដែលបានអនុញ្ញាត អ្នកប្តឹងពាក់ព័ន្ធ ឬតំណាង ព្រមទាំងអ្នកសង្កេតការណ៍ និងអ្នកយកពត៌មាន ដែលមានប័ណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។

១២.១២.១០.៣ ប្រធាន អនុប្រធាន សមាជិកនៃ គ.ជ.ប និងអគ្គលេខាធិការនៃ គ.ជ.ប ឬមន្ត្រីដែលបានប្រគល់សិទ្ធិ ដែលមានបំណងត្រួតពិនិត្យតាមដាននិងណែនាំក្នុងដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ។

**ការប្រគល់ និងការទទួលកញ្ចប់ " ឃ " និងកញ្ចប់ " ឃពិសេស " ដាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្តីការ គ.ជ.ប**

**ប្រការ ១២.១៣** មន្ត្រីនៃក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដែលបានតែងតាំងក្រោមចំណុច ១២.១២.១ ខាងលើត្រូវមានវត្តមានជាប្រចាំនៅទីស្តីការ គ.ជ.ប ចាប់ពីពេលដែល គធ/ខប ចាប់ផ្តើមធ្វើការត្រួតពិនិត្យលទ្ធផល ដើម្បីរង់ចាំទទួលសម្ភារៈ ឯកសារបោះឆ្នោត ដែល គធ/ខប ត្រូវបញ្ជូន និងប្រគល់ជូន គ.ជ.ប ។

១២.១៣.១ ក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីទទួលសម្ភារៈ ឯកសារបោះឆ្នោត ដោយផ្អែកតាមករណីដោយឡែកនៃរាជធានី ខេត្តនីមួយៗ ដែល គធ/ខប ពាក់ព័ន្ធ អាចវេចខ្ចប់ និងបញ្ជូនសម្ភារៈ ឯកសារបោះឆ្នោតជូន គ.ជ.ប ជាបី (៣) ផ្នែក ដូចខាងក្រោម ៖

១២.១៣.១.១ រាល់សម្រង់សេចក្តីសម្រេចបដិសេធ លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងឃុំ សង្កាត់ដែលលទ្ធផលនៃការបោះឆ្នោតត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្តោះអាសន្ន ដូចបញ្ជាក់ក្នុងចំណុច ១២.១០.១ ខាងលើ ។

១២.១៣.១.២ រាល់កញ្ចប់ " ឃ " និងកញ្ចប់ " ឃពិសេស " ដាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរាជធានី ខេត្ត និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះត្រូវបាន គធ/ខប សម្រេចយល់ព្រម ដូចបញ្ជាក់ក្នុងចំណុច ១២.១០.២ ១២.១០.៥ និង ១២.១០.៦ ខាងលើ ។

១២.១៣.១.៣ រាល់សម្ភារៈ ឯកសារបោះឆ្នោត នៅសល់ដែលត្រូវបានវេចខ្ចប់ និងបញ្ជូនដោយឡែកមក គ.ជ.ប នៅពេលក្រោយ ដូចចែងក្នុងចំណុច ១២.១០.៩ ខាងលើ ។

១២.១៣.២ ក្នុងករណីមន្ត្រីនៃ គធ/ខប បានបញ្ជូនសម្ភារៈ ឯកសារបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ១២.១៣.១.១ ខាងលើ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យមើលរាល់សម្ភារៈ ឯកសារបោះឆ្នោតដែលមាននៅក្នុងស្រោមសំបុត្រធំ និងរាល់កញ្ចប់ " ឃ " ដាក់

កញ្ចប់ " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្ដោះអាសន្ន ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារៈ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារ (ទ. ១១០៧) ទាំងបី (៣) ច្បាប់ ដែលមួយ (១) ច្បាប់ នៅក្នុងស្រោមសំបុត្រធំមួយ (១) ច្បាប់ កិបជាប់នឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំ និងមួយ (១) ច្បាប់ នៅនឹងមន្ត្រី គធ/ខប ដែលបញ្ជូនសម្ភារៈ ឯកសារមក ។

១២.១៣.២.១ មន្ត្រីក្នុងក្រុមទទួលសម្ភារៈ ឯកសារ ត្រូវកត់ត្រាមុខសម្ភារៈ ឯកសារដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ដែលប្រសិនបើគ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា " គ្រប់ចំនួន " ។

១២.១៣.២.២ ប្រធានក្រុមទទួលសម្ភារៈ ឯកសារត្រូវចុះហត្ថលេខាលើ លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារ ដូចបញ្ជាក់ក្នុងចំណុច ១២.១៣.២ ខាងលើ រួចប្រគល់មួយ (១) ច្បាប់ ជូនមន្ត្រី គធ/ខប ទទួលបន្ទុកការបញ្ជូនវិញ រក្សាមួយ (១) ច្បាប់ ភ្ជាប់ទៅនឹងស្រោមសំបុត្រធំ និងដកមួយ (១) ច្បាប់ ចងក្រងទុកជាឯកសារ ។

១២.១៣.២.៣ មន្ត្រីក្នុងក្រុមទទួលសម្ភារៈ ឯកសារត្រូវនាំយកស្រោមសំបុត្រធំ និងកញ្ចប់ " ឃ " ដាក់រាល់កញ្ចប់ " គ " នៃឃុំ សង្កាត់ ដែលលទ្ធផលនៃការបោះឆ្នោត ត្រូវព្យួរជាបណ្ដោះអាសន្ននោះ ទៅស្តុកទុកនៅក្នុងបន្ទប់ ដែលបានត្រៀមបម្រុងទុក ដូចចែងក្នុងចំណុច ១២.១២.៧.១ ខាងលើ និងត្រូវសរសេរសម្គាល់លេខកូដឃុំ សង្កាត់ និងរាជធានី ខេត្ត ពាក់ព័ន្ធផង ។

១២.១៣.២.៤ ប្រធានក្រុមទទួលសម្ភារៈ ឯកសារត្រូវរាយការណ៍ជាបន្ទាន់ ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការនូវឈ្មោះ និងលេខកូដឃុំ សង្កាត់ ដែលត្រូវ គធ/ខប សម្រេចព្យួរលទ្ធផលជាបណ្ដោះអាសន្ននោះ ដោយដាក់អមទៅជាមួយនូវស្រោមសំបុត្រធំពាក់ព័ន្ធផង ។

១២.១៣.៣ ក្នុងករណីមន្ត្រីនៃ គធ/ខប បានបញ្ជូនសម្ភារៈ ឯកសារបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ១២.១៣.១.២ ខាងលើ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យមើលរាល់សម្ភារៈ ឯកសារបោះឆ្នោត ដែលមាននៅក្នុងកញ្ចប់ " ឃពិសេស " និងរាល់កញ្ចប់ " ឃ " ដាក់កញ្ចប់ " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធទាំងអស់ ដែលលទ្ធផលនៃ

ការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះ ត្រូវបាន គធ/ខប សម្រេចយល់ព្រម ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារៈ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារ (ទ. ១១០៧) ទាំងបី (៣) ច្បាប់ ដោយឡែកពីគ្នា ដែលមួយ (១) ច្បាប់ នៅក្នុងកញ្ចប់ " ឃ " ឬកញ្ចប់ " ឃពិសេស " មួយ (១) ច្បាប់ នៅក្នុងហោប៉ៅនៃកញ្ចប់ " ឃ " ឬកញ្ចប់ " ឃពិសេស " និងមួយ (១) ច្បាប់ នៅនឹងមន្ត្រី គធ/ខប ដែលបញ្ជូនសម្ភារៈ ឯកសារមក ។

១២.១៣.៣.១ មន្ត្រីក្នុងក្រុមទទួលសម្ភារៈ ឯកសារ ត្រូវកត់ត្រាមុខសម្ភារៈ ឯកសារដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ដែលប្រសិនបើគ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា " គ្រប់ចំនួន " ។

១២.១៣.៣.២ ប្រធានក្រុមទទួលសម្ភារៈ ឯកសារ ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារ ដូចបញ្ជាក់ក្នុងចំណុច ១២.១៣.៣ ខាងលើ រួចប្រគល់មួយ (១) ច្បាប់ ជូនមន្ត្រី គធ/ខប ទទួលបន្ទុកការបញ្ជូនវិញ ដាក់មួយ (១) ច្បាប់ ក្នុងហោប៉ៅកញ្ចប់ " ឃ " ឬ កញ្ចប់ " ឃពិសេស " វិញ និងដកមួយ (១) ច្បាប់ ចងក្រងទុកជាឯកសារ ។

១២.១៣.៣.៣ មន្ត្រីក្នុងក្រុមទទួលសម្ភារៈ ឯកសារត្រូវនាំយកកញ្ចប់ " ឃពិសេស " នៃរាជធានី ខេត្តពាក់ព័ន្ធ ទៅស្តុកទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុក ដូចចែងក្នុង ចំណុច ១២.១២.៧.២ ខាងលើ ដោយ ត្រូវដាក់តាមលំដាប់លេខរៀងនៃលេខកូដរាជធានី ខេត្តនីមួយៗ ។

១២.១៣.៣.៤ មន្ត្រីក្នុងក្រុមទទួលសម្ភារៈ ឯកសារត្រូវនាំយករាល់កញ្ចប់ " ឃ " ដាក់កញ្ចប់ " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះ ត្រូវបាន គធ/ខប សម្រេចយល់ព្រម ទៅស្តុកទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុក ដូចចែងក្នុងចំណុច ១២.១២.៧.៣ ខាងលើ និងត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្តពាក់ព័ន្ធផង ។ ប្រសិនបើក្នុងចំណោមកញ្ចប់ " ឃ " នៃរាជធានី ខេត្តពាក់ព័ន្ធមានកញ្ចប់ " ឃ " មួយចំនួន ដែលមានសរសេរសម្គាល់ " មានបណ្តឹងបើកកញ្ចប់សុវត្ថិភាព ក " មន្ត្រីក្នុងក្រុមទទួលសម្ភារៈ ឯកសារ ត្រូវដាក់បំបែករាល់កញ្ចប់ " ឃ " ទាំងនោះដោយឡែក ។

១២.១៣.៣.៥ ប្រធានក្រុមទទួលសម្ភារៈ ឯកសារត្រូវរាយការណ៍ជាបន្ទាន់ ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការនូវរាជធានី ខេត្តដែលបានប្រគល់កញ្ចប់ " ឃពិសេស " និងរាល់កញ្ចប់ " ឃ " ដាក់កញ្ចប់ " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះ ត្រូវបាន គធ/ខប សម្រេចយល់ព្រម ។ ប្រសិនបើ ក្នុងរាជធានី ខេត្តពាក់ព័ន្ធមានឃុំ សង្កាត់ណា ដែលមានបណ្តឹង ត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប និង ដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើនត្រូវបានបើក ប្រធានក្រុមត្រូវបញ្ជាក់បន្ថែមក្នុងរបាយការណ៍ ខាងលើផងដែរ នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ ដែលមានបណ្តឹងទាំងនោះ និងត្រូវដកយករាល់ស្រោមសំបុត្រដាក់សម្រង់សេចក្តីសម្រេចពាក់ព័ន្ធរបស់ គធ/ខប ពីក្នុងកញ្ចប់ " ឃពិសេស " ដាក់អមទៅជាមួយផង ។

១២.១៣.៤ ក្នុងករណីមន្ត្រីនៃ គធ/ខប បានបញ្ជូនសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ ដូចបញ្ជាក់ក្នុងចំណុច ១២.១៣.១.៣ ខាងលើ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើកកញ្ចប់ និងត្រួតពិនិត្យមើលរាល់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់ ដែលបានប្រគល់ជូន គ.ជ.ប ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារៈ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារ (ទ. ១១០៧) ដែលប្រសិនបើត្រឹមត្រូវគ្រប់ចំនួនហើយ ប្រធានក្រុមត្រូវចុះហត្ថលេខា លើលិខិតបញ្ជូន និងប្រគល់ ទទួលនោះ រួចប្រគល់ជូនមន្ត្រី គធ/ខប ទទួលបន្ទុកការបញ្ជូនវិញមួយ (១) ច្បាប់ ។ ប្រធានក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទេររាល់សម្ភារៈ ឯកសារនៅសល់ដែលបានទទួលខាងលើ ដោយភ្ជាប់ជាមួយលិខិតបញ្ជូន និងប្រគល់ទទួលមួយ (១) ច្បាប់ ទៅឱ្យនាយកដ្ឋានប្រតិបត្តិការទទួលគ្រប់គ្រង និងរក្សាទុកនៅឃ្លាំង គ.ជ.ប ឬបន្ទប់ស្តុកដែលបានកំណត់ ។

**កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមការណែនាំ និងចាត់ចែងរបស់អគ្គលេខាធិការនៃ គ.ជ.ប**

**ប្រការ** ១២.១៤ ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប មានភារកិច្ចត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់

ចំណុះរាជធានី ខេត្តទូទាំងប្រទេស ក្នុងគោលបំណងបញ្ជាក់ជាចុងក្រោយ អំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នីមួយៗ ការកំណត់ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ទទួលបាន ការស្រង់ឈ្មោះបេក្ខជនដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងការបញ្ជាក់ឈ្មោះបេក្ខជនជាប់ឆ្នោតដែលត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ដែល គធ/ខប បានធ្វើការត្រួតពិនិត្យម្តងរួចហើយ ។ ប្រសិនបើក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ឡើងវិញនេះ ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប យល់ព្រមតាមលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយនោះ ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈត្រូវបំពេញតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧តព) តារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ និងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចនិងប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះជាផ្លូវការ និងជាសាធារណៈ ។

១២.១៤.១ នៅពេលដែល គ.ជ.ប បានទទួលតាមរយៈអគ្គលេខាធិការ នូវរបាយការណ៍ពីក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ១២.១៣.២.៤ និង ១២.១៣.២ និងពីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដូចបញ្ជាក់ក្នុងចំណុច ១២.១១.៧ ខាងលើ គ.ជ.ប ត្រូវសម្រេចកំណត់ករណីនៃឃុំ សង្កាត់នីមួយៗ ក្នុងរាជធានី ខេត្ត ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល និងត្រូវសម្រេចអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រសិនបើលក្ខខណ្ឌតម្រូវឱ្យធ្វើដូច្នេះ ។

១២.១៤.២ ផ្អែកតាមការកំណត់សម្រេចរបស់ គ.ជ.ប អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ឱ្យអនុវត្តការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ដែលក្រុមនីមួយៗទទួលបន្ទុក ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់និងតាមករណីជាក់ស្តែងនីមួយៗ ដូចខាងក្រោម ៖

១២.១៤.២.១ ក្នុងករណីឃុំ សង្កាត់ណា ដែលលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្តោះអាសន្ន ហើយដែលក្នុងនោះ គធ/ខប បានសម្រេចបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.១៩.២.២ ក្នុងករណីឃុំ សង្កាត់ណាដែលគ្មានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប ឬ/និង គ.ជ.ប ហើយដែលគ្មានកញ្ចប់សុវត្ថិភាព " ក " ណាមួយត្រូវបានបើក។

១២.១៩.២.៣ ក្នុងករណីឃុំ សង្កាត់ណាដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់នឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ត្រូវបានដាក់នៅ គ.ជ.ប ដូចចែងក្នុងលក្ខខណ្ឌក្រោមប្រការ ១២.១១ ខាងលើ និងត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើនត្រូវបាន បើកនៅ គឃ/សប ឬ គធ/ខប ប៉ុន្តែ គធ/ខប បានសម្រេចយល់ព្រមចំពោះលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះ ។

១២.១៩.២.៤ ក្នុងករណីឃុំ សង្កាត់ណា ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងក្នុងករណីឃុំ សង្កាត់នោះមានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គធ/ខប ឬ/និងនៅ គ.ជ.ប ។

១២.១៩.៣ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មានដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប មានសិទ្ធិចូលរួមក្នុងរាល់ដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ នៅទីស្តីការ គ.ជ.ប ។ ប្រសិនបើ បន្ទប់ចង្អៀតការចូលរួមសង្កេតមើលរបស់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍... ដែលចែងក្នុងចំណុចនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ប្រធានក្រុមត្រួតពិនិត្យលទ្ធផល ឬក្រុមកំណត់បែងចែកអាសនៈ តាមរបៀបផ្លាស់ប្តូរវេនគ្នា ។

១២.១៩.៤ អ្នកប្ដឹងពាក់ព័ន្ធ ឬតំណាងដែលពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់របស់គាត់ត្រូវបាន គធ/ខប សម្រេចយល់ព្រម ឬបដិសេធ ដូចចែងក្នុងចំណុច ១២.៦.១១ ១២.៦.១២ ១២.៧.៥ និង ១២.៧.៦ ខាងលើ នៃ ប.ន.ឃ.ស នេះ និងអ្នកប្ដឹងពាក់ព័ន្ធ ឬតំណាងដែលបានដាក់ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់នៅ គ.ជ.ប យោងតាមលក្ខខណ្ឌដូចចែងក្រោមប្រការ ១២.១១ ខាងលើ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះ

ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធនៅទីស្តីការ គ.ជ.ប ។ ប្រសិនបើបន្ទប់ចង្អៀតការចូលរួមសង្កេតមើលរបស់អ្នកប្តឹងពាក់ព័ន្ធ ឬតំណាង ដូចចែងក្នុងចំណុចនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ប្រធានក្រុមត្រួតពិនិត្យលទ្ធផល ឬក្រុមកំណត់បែងចែកអាសនៈតាមរបៀបផ្លាស់ប្តូរវេនគ្នា ។

១២.១៤.៥ កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ។

១២.១៤.៦ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវបើកកិច្ចប្រតិបត្តិការ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ដែលខ្លួនទទួលបន្ទុកម្តងមួយឃុំ សង្កាត់ៗនៅបន្ទប់ធំទូលាយណាមួយឬបន្ទប់តូចៗដោយឡែកពីគ្នា ដែលបានត្រៀមបម្រុងដូចចែងក្រោមចំណុច ១២.១២.៨ ក្នុងជំពូកនេះ ។ ក្នុងការត្រួតពិនិត្យលទ្ធផលខាងលើនេះ ប្រធានក្រុមត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខមួយ (១) គ្រឿង និងទម្រង់បែបបទសម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផល ព្រមទាំងរាល់សំណុំឯកសារយោងដូចចែងចាប់ពីចំណុច ១២.១២.៣.១ ដល់ ១២.១២.៣.៧ ខាងលើ ។

១២.១៤.៧ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបើកកិច្ចប្រតិបត្តិការដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ម្តងមួយឃុំ សង្កាត់ៗបន្ទាប់ពីបានទទួលតារាងត្រួតពិនិត្យលទ្ធផលដែល គ.ជ.ប បានពិនិត្យសម្រេចរួច ។

**ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែល គធ/ខប បានសម្រេចព្យួរលទ្ធផលជាបណ្តោះអាសន្ន**

**ប្រការ១២.១៥** យោងតាមការកំណត់របស់ គ.ជ.ប ដូចចែងក្នុងចំណុច ១២.១៤.១ ខាងលើ ប្រសិនបើឃុំ សង្កាត់ដែលនឹងត្រូវធ្វើការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីដែលលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្តោះអាសន្ន ហើយដែល គធ/ខប បានសម្រេចបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលដែលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈឱ្យធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធីដូចខាងក្រោម ៖

១២.១៥.១ ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ត្រូវធានាថាការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់

ដែលត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្ដោះអាសន្នត្រូវបានអនុវត្តយ៉ាងរួសរាន់ និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដើម្បីពិនិត្យសម្រេចក្នុងរយៈពេលយ៉ាងយូរបួន (៤) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសម្រង់សេចក្ដីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ពាក់ព័ន្ធ ។

១២.១៥.២ ក្នុងករណី គ.ជ.ប សម្រេចមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវធ្វើការត្រួតពិនិត្យដោយ គ្រាន់តែផ្អែកលើរាល់សំណុំឯកសារ ដែលមានក្នុងស្រោមសំបុត្រធំដាក់សម្រង់សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ដូចចែងក្នុងចំណុច ១២.៦.១៣.១ ប៉ុណ្ណោះ ។

១២.១៥.៣ ក្នុងករណី គ.ជ.ប សម្រេចតម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវធ្វើការត្រួតពិនិត្យ ដោយផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំដាក់សម្រង់សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ដូចចែងក្នុង ចំណុច ១២.៦.១៣.១ផង និងត្រូវអនុវត្តបន្ថែមការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញតាមលំនាំនីតិវិធីទាំងឡាយដែល គធ/ខប អនុវត្ត ដូចចែងចាប់ពីចំណុច ១២.៦.៣.១ ដល់ចំណុច ១២.៦.៣.៥ និងចំណុច ១២.៦.៤ ខាងលើ ។

១២.១៥.៤ ក្នុងករណី គ.ជ.ប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតលើសពីមួយក្នុងឃុំ សង្កាត់ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តតាមលំនាំនីតិវិធីដដែល ដូចចែងចាប់ពីចំណុច ១២.៦.៣.១ ដល់ ១២.៦.៣.៥ និងចំណុច ១២.៦.៤ ខាងលើ សម្រាប់កញ្ចប់សុវត្ថិភាព " ក " នីមួយៗ រហូតដល់អស់កញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធដែលត្រូវសម្រេចឱ្យបើក ។

១២.១៥.៥ បន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលឡើងវិញ តាមនីតិវិធីដូចចែងក្នុងចំណុច ១២.១៥.២ ឬដូចចែងក្នុងចំណុច ១២.១៥.៣ និង ១២.១៥.៤ ខាងលើ

ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ (ទ. ១១១៧គ២) ចំនួនមួយ (១) ច្បាប់ និងរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតចំនួនមួយ (១) ច្បាប់ ត្រូវតែបានធ្វើ និងចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។

១២.១៥.៦ អគ្គលេខាធិការត្រូវចារយោបល់លើតារាងត្រួតពិនិត្យលទ្ធផល និងរបាយការណ៍ដែលបានដាក់ជូនពិនិត្យដូចចែងក្នុងចំណុច ១២.១៥.៥ ខាងលើ រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ដើម្បីពិនិត្យសម្រេច ។ អគ្គលេខាធិការ ត្រូវ ៖

១២.១៥.៦.១ ចារលើកយោបល់ស្នើសុំការយល់ព្រមតាមសេចក្ដីសម្រេច របស់ គធ/ខប ដែលព្យួរជាបណ្ដោះអាសន្ននូវលទ្ធផល នៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរ នាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។

១២.១៥.៦.២ ចារលើកយោបល់ស្នើសុំការបដិសេធសេចក្ដីសម្រេចរបស់ គធ/ខប ដែលព្យួរជាបណ្ដោះអាសន្ននូវ លទ្ធផលបោះឆ្នោតនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រសិនបើគ្មានភាពមិនប្រក្រតីនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅឃុំ សង្កាត់ទេ ។

១២.១៥.៧ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ/ខប ដែលបានព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ហើយដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ ៖

១២.១៥.៧.១ ចារយល់ព្រមលើសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

១២.១៥.៧.២ ចារយល់ព្រមលើរបាយការណ៍លើកស្នើយោបល់ របស់ក្រុមត្រួតពិនិត្យ និងចារបដិសេធលើតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៧គ២) ដូចចែងក្នុងចំណុច ១២.១៥.៦ និង ១២.១៥.៦.១ ខាងលើ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

១២.១៥.៧.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្ដីសម្រេចយល់ព្រម លើសេចក្ដីសម្រេចរបស់ គធ/ខប ដែលបានបដិសេធលទ្ធផល នៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ. ១២០៣) ដោយបញ្ជាក់ច្បាស់ពីមូលហេតុ នៃការយល់ព្រមផង ហើយដែលត្រូវចុះហត្ថលេខា និងកាល បរិច្ឆេទ ដោយប្រធាន គ.ជ.ប ។

១២.១៥.៧.៤ ធានាថា សម្រង់សេចក្ដីសម្រេចយល់ព្រមខាងលើ ត្រូវបានត្រៀម ក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនម្ចាស់ដើមបណ្ដឹង មួយ (១) ច្បាប់ ជូនគ្រប់ភ្នាក់ងារនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងឃុំ សង្កាត់មួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ ផ្ញើជូន គឃ/សប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុក ជាឯកសារមួយ (១) ច្បាប់ ។

១២.១៥.៧.៥ ប្រកាសថា សេចក្ដីសម្រេចរបស់ គ.ជ.ប យល់ព្រមតាមសេចក្ដី សម្រេចរបស់ គធ/ខប ដែលបានបដិសេធលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណា មួយក្នុងឃុំ សង្កាត់នោះ ជាសេចក្ដីសម្រេចចុងក្រោយ ហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះ ឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់នៃឃុំ សង្កាត់នោះ មិនឱ្យលើសពីសាមសិប (៣០) ថ្ងៃ បន្ទាប់ពីថ្ងៃ សម្រេចបដិសេធ ។

១២.១៥.៧.៦ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផល សម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្ដីសម្រេចរបស់ គ.ជ.ប បដិសេធ លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោត ណាមួយក្នុងឃុំ សង្កាត់នោះ មួយមុខមួយ (១) ច្បាប់ តាម រយៈអគ្គលេខាធិការ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុក ដាក់ក្នុងស្រោមសំបុត្រធំ រួចដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " នៃរាជធានី ខេត្តពាក់ព័ន្ធ ។

១២.១៥.៧.៧ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផលបានវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធ ដាក់ក្នុងកញ្ចប់ " ខ " និងក្នុងកញ្ចប់ " គ " នៃឃុំ សង្កាត់នោះ រួចនាំយកទៅប្រគល់ឱ្យ ក្រុមទទួលសម្ភារៈ ឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

១២.១៥.៨ យោងសម្រង់សេចក្ដីសម្រេចរបស់ គ.ជ.ប យល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ/ខប ដែលបានព្យួរលទ្ធផល ដូចចែងក្នុងចំណុច ១២.១៥.៧.៣ ខាងលើ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតទាំងនោះត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចចែងក្នុងជំពូកទី ១៣ នៃ ប.ន.ឃ.ស នេះ ។ ការបោះឆ្នោតសាជាថ្មីនេះ ត្រូវអនុវត្តដោយផ្អែកលើបញ្ជីបោះឆ្នោតដដែល បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដដែល និងសន្លឹកឆ្នោតដែលមានទម្រង់ និងខ្លឹមសារដដែល ប៉ុន្តែត្រូវបោះពុម្ពថ្មីលើក្រដាសពណ៌ផ្សេង ។

១២.១៥.៩ ប្រសិនបើ គ.ជ.ប សម្រេចមិនយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ/ខប ដែលព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដោយបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ ៖

១២.១៥.៩.១ ចារបដិសេធលើសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលបានព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

១២.១៥.៩.២ ចារយល់ព្រមលើរបាយការណ៍លើកស្នើយោបល់របស់ក្រុមត្រួតពិនិត្យ សុំបដិសេធសេចក្ដីសម្រេចរបស់ គធ/ខប និងចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៧គ៣) ដូចចែងក្នុងចំណុច ១២.១៥.៦ និង ១២.១៥.៦.២ ខាងលើ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

១២.១៥.៩.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្ដីសម្រេចបដិសេធសេចក្ដីសម្រេចរបស់ គធ/ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ. ១២០៣) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធ ហើយដែលត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទដោយប្រធាន គ.ជ.ប ។

១២.១៥.៩.៤ ធានាថា សម្រង់សេចក្ដីសម្រេចបដិសេធការព្យួរលទ្ធផល ខាងលើ ត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនម្ចាស់ ដើម

បណ្ដឹងមួយ (១) ច្បាប់ ជូនគ្រប់ភ្នាក់ងារនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់មួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ ផ្ញើជូន គឃ/សប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.១៥.៩.៥ ប្រកាសថា សេចក្ដីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធសេចក្ដីសម្រេចរបស់ គធ/ខប និងយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្ដីសម្រេចចុងក្រោយ ។

១២.១៥.៩.៦ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផលសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលមានចំណាររបស់ប្រធាន គ.ជ.ប និងសម្រង់សេចក្ដីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ មួយមុខមួយ (១) ច្បាប់ ព្រមទាំងឯកសារក្នុងស្រោមសំបុត្រធំ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីមុខការ ។

១២.១៥.៩.៧ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផលបានវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធដាក់ក្នុងកញ្ចប់ " ខ " និងកញ្ចប់ " គ " រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារៈ ឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

១២.១៥.១០ នៅពេលទទួលបានសំណុំឯកសារដូចចែងក្នុងចំណុច ១២.១៥.៩.៧ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈត្រូវចាត់ចែង ៖

១២.១៥.១០.១ បញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះទៅក្នុងកុំព្យូទ័រដោយផ្អែកតាមតារាងត្រួតពិនិត្យលទ្ធផល ដែលមានចំណាររបស់ប្រធាន គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.១៥.១០.២ កំណត់បែងចែកអាសនៈ ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ដោយប្រើកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ និងដោយគណនាតាមការធ្វើប្រមាណវិធីតាមរូបមន្ត ដែលកំណត់ដោយច្បាប់ និងដូចចែងក្នុងជំពូកទី៩ នៃ ប.ន.ឃ.ស នេះ ។

១២.១៥.១០.៣ បោះពុម្ពតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈសម្រាប់ឃុំ សង្កាត់នោះដែលគណបក្សនយោបាយនីមួយៗ ត្រូវទទួលបាន រួចផ្ទៀងផ្ទាត់

ជាមួយនឹងលទ្ធផលនៃការបែងចែកអាសនៈ ដែលគណនាតាមការធ្វើប្រមាណវិធី បន្ទាប់មកស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តាមចំនួនអាសនៈ និងលំដាប់លេខរៀងពីក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលត្រូវទទួលបានអាសនៈ បំពេញទៅក្នុងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១៤) និងដោយមានបញ្ជាក់បេក្ខជនជាប់ឆ្នោតជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រងផង ។

១២.១៥.១០.៤ រៀបចំតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ ដែលបានគណនាឃើញតាមរូបភាពទាំងពីរ មួយមុខមួយ (១) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយលេខាធិការ អនុប្រធានក្រុម និងប្រធានក្រុម និងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១៤) ចំនួនប្រាំ (៥) ច្បាប់ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចជាផ្លូវការ ។

១២.១៥.១១ ក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្តោះអាសន្ន ប៉ុន្តែត្រូវបាន គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ នោះ ប្រសិនបើមានករណីសំឡេងឆ្នោតស្មើគ្នា រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ដែលនឹងត្រូវទទួលបានអាសនៈ ឬ/និងដែលមានបេក្ខជនជាប់ឆ្នោតនឹងត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង គ.ជ.ប ត្រូវប្រគល់សិទ្ធិអំណាចជូនអគ្គលេខាធិការ ដើម្បីអនុវត្តការចាប់ឆ្នោត ដោយត្រូវផ្អែកតាមលំនាំនីតិវិធីស្តីពីការចាប់ឆ្នោតនៅ គធ/ខប ដូចចែងក្នុងជំពូកទី ៤ នៃ ប.ន.យ.ស នេះ ។

**ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹង ជំទាស់ត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប ឬ/និង គ.ជ.ប**

**ប្រការ** ១២.១៦ យោងតាមការកំណត់របស់ គ.ជ.ប ដូចចែងក្នុងចំណុច ១២.១៥.១ ខាងលើ ប្រសិនបើឃុំ សង្កាត់ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប

ឬ/និង គ.ជ.ប ហើយដែលគ្មានកញ្ចប់សុវត្ថិភាព " ក" ណាមួយត្រូវបានបើក ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ទេ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណាត់បែងចែកអាសនៈឱ្យធ្វើការ ដើម្បីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាម នីតិវិធីដូចខាងក្រោម ៖

១២.១៦.១ ក្នុងករណីខាងលើនេះ ជាដំបូងផ្អែកតាមការណែនាំរបស់អគ្គលេខាធិការ ក្រុមត្រួតពិនិត្យលទ្ធផលនៃគ.ជ.បត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំសង្កាត់ពាក់ព័ន្ធចំណុះរាជធានី ខេត្តដែលក្រុមទទួលបន្ទុកដោយឡែកពីគ្នា ម្តងមួយឃុំ សង្កាត់ៗ ដោយផ្អែកលើរាល់ឯកសារពាក់ព័ន្ធដែលមាននៅក្នុងកញ្ចប់ " ឃពិសេស" ប៉ុណ្ណោះ និងមិនត្រូវបើកកញ្ចប់សុវត្ថិភាព " ក " ណាមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ។ ក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំសង្កាត់ ចំណុះរាជធានី ខេត្តណាមួយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវ ៖

១២.១៦.១.១ ចាត់សមាជិកក្រុមពីររូប ឱ្យទៅនាំយកកញ្ចប់ " ឃពិសេស " នៃរាជធានី ខេត្តដែលក្រុមទទួលបន្ទុក ម្តងមួយរាជធានី ខេត្តៗ ពីកន្លែងរក្សាស្តុកមកដាក់នៅលើតុចំពីមុខប្រធាន ។

១២.១៦.១.២ បើកកញ្ចប់ " ឃពិសេស " រួចដកយករាល់ស្រោមសំបុត្រដាក់សំណុំឯកសារលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់មកដាក់នៅលើតុ ៖

- ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ. ១១០៥ធខ) ។
- តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) ។
- លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ។

១២.១៦.១.៣ រក្សាទុកកញ្ចប់ " ឃពិសេស" នៅក្បែរខ្លួនគាត់ដែលនៅក្នុងនោះមាន ៖

- តារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យនៃ គធ/ខប (ទ. ១១១៦គ៣) ។
- របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល គធ/ខប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) ។

របាយការណ៍របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន) ។

កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) ។

តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៩) ។

១២.១៦.១.៤ ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នីមួយៗ ដោយផ្អែកលើសំណុំឯកសារលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតតាមឃុំ សង្កាត់ ដូចចែងក្នុងចំណុច ១២.១៦.១.២ ខាងលើ ហើយ ប្រសិនបើមានភាពមិនច្បាស់លាស់ ត្រូវឱ្យពិនិត្យបន្ថែមនូវឯកសារផ្សេងទៀត ដូចបញ្ជាក់ក្នុងចំណុច ១២.១៦.១.៣ ខាងលើ ។

១២.១៦.១.៥ ធានាថា របាយការណ៍សរសេរដៃស្តីពីលទ្ធផលនៃការត្រួតពិនិត្យខាងលើចំនួនមួយ (១) ច្បាប់ សម្រាប់ឃុំ សង្កាត់នីមួយៗ ត្រូវបានធ្វើ និងចុះហត្ថលេខាដោយសមាជិកទាំងអស់ នៃក្រុមត្រួតពិនិត្យលទ្ធផល ដោយត្រូវបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោម ប្រសិនបើបានរកឃើញថា ៖

តួលេខនៃលទ្ធផលដែលបានត្រួតពិនិត្យ មានភាពត្រឹមត្រូវ ។

គធ/ខប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ហើយកំហុសនោះ ត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវគូសឆូតលើតួលេខដែលខុស ដោយរក្សាឱ្យឃើញតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង ។

ក្នុងការបោះឆ្នោតនៅឃុំ សង្កាត់ មានសំឡេងឆ្នោតគាំទ្រស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ឬ/និងដែលមានបេក្ខជនជាប់ឆ្នោតនឹងត្រូវបានទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ។

១២.១៦.១.៦ ធានាថា តារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៧គ៣) ចំនួនមួយ (១) ច្បាប់ ត្រូវបានបំពេញដោយមានបញ្ជាក់ច្បាស់នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ និងត្រូវចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ។

១២.១៦.១.៧ ធានាថារបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដូចបញ្ជាក់ក្នុងចំណុច ១២.១៦.១.៥ និង ១២.១៦.១.៦ ខាងលើ ដែលអមដោយក្រដាសលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ/ខប (ទ. ១១០៥ធខ) និងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ព្រមទាំងកំណត់ហេតុរបស់ គធ/ខប ស្តីពីលទ្ធផលនៃការចាប់ឆ្នោត (ប្រសិនបើមាន) ត្រូវបានដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។

១២.១៦.១.៨ ធានាថា រាល់របាយការណ៍ និងទម្រង់បែបបទ ដូចបានបញ្ជាក់ក្នុងចំណុច ១២.១៦.១.៣ ខាងលើ ដែលបានប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ ត្រូវតែបានច្រកក្នុងស្រោមសំបុត្រដូចដើម និងដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " វិញ ។

១២.១៦.២ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មានបណ្តឹងទាំងអស់ចំណុះរាជធានី ខេត្ត ដោយត្រូវត្រួតពិនិត្យម្តងមួយឃុំ សង្កាត់ រហូតដល់អស់ និងត្រូវអនុវត្តតាមនីតិវិធី ដូចចែងចាប់ពីចំណុច ១២.១៦.១.២ ដល់ ១២.១៦.១.៨ ខាងលើ ។ នៅពេលបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់គ្មានបណ្តឹងទាំងអស់ក្នុងរាជធានី ខេត្តនីមួយៗ និងក្នុងពេលអនុវត្តចំណុច ១២.១៦.១.៧ ខាងលើ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវដាក់ភ្ជាប់អមទៅជាមួយនូវតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ. ១១១០) ផង ។

១២.១៦.៣ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យ និងសំណុំឯកសារភ្ជាប់ជាមួយ ដែលបានដាក់ជូនដូចចែងក្នុងចំណុច ១២.១៦.១.៧ និង ១២.១៦.២ ខាងលើ ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ អគ្គលេខាធិការត្រូវចារលើកយោបល់ស្នើសុំការយល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទលើរបាយការណ៍សរសេរដៃស្តីពីលទ្ធផលនៃការត្រួតពិនិត្យ និងលើតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៧គ៣) និងដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

១២.១៦.៤ ប្រសិនបើ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ប្រធាន គ.ជ.ប ត្រូវចារយល់ព្រមលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច ១២.១៦.៣ ខាងលើ រួចចុះហត្ថលេខា បោះត្រា និង កាលបរិច្ឆេទ បន្ទាប់មកប្រគល់របាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ព្រមទាំង សំណុំឯកសារភ្ជាប់ជាមួយតាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែក អាសនៈ ដើម្បីមុខការ ។

១២.១៦.៥ នៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលពីអគ្គលេខាធិការ ដូចបញ្ជាក់ ក្នុងចំណុច ១២.១៦.៤ ខាងលើ ក្រុមកំណត់បែងចែកអាសនៈ ត្រូវចាត់ចែង អនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួនដូចចែងក្រោមចំណុច ១២.១២.៥ ខាងលើ និង ១២.១៦.៦ ខាងក្រោម ដើម្បីផ្ទៀងផ្ទាត់ បញ្ជាក់អំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ របស់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែល គធ/ខប បានត្រួតពិនិត្យផ្ទៀងផ្ទាត់ម្តងរួចហើយ ។

១២.១៦.៦ ក្នុងដំណើរការនៃការផ្ទៀងផ្ទាត់បញ្ជាក់អំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវរបស់លទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែល គធ/ខប បានត្រួតពិនិត្យ ផ្ទៀងផ្ទាត់ម្តងរួចហើយ ប្រធានក្រុមកំណត់បែងចែកអាសនៈត្រូវចាត់ចែងធ្វើ កុំព្យូទ័រកម្មលទ្ធផលនៃការបោះឆ្នោត និងធ្វើប្រមាណវិធីនានា ដើម្បីគណនា ឬ/និង ផ្ទៀងផ្ទាត់ចំនួនអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទទួលបាន ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងឈ្មោះបេក្ខជន ជាប់ឆ្នោតដែលត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ។ ប្រធានក្រុមកំណត់បែងចែកអាសនៈត្រូវ ចាត់ចែងសមាជិកក្រុមឱ្យបំពេញកិច្ចការ ដូចខាងក្រោម ៖

១២.១៦.៦.១ បញ្ចូលយ៉ាងត្រឹមត្រូវនូវទិន្នន័យនៃចំនួនសំឡេងឆ្នោតគាំទ្របញ្ជីបេក្ខ ជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនីមួយៗក្នុង ឃុំ សង្កាត់ទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៧គព) និងសំណុំឯកសារនៃឃុំ សង្កាត់ពាក់ព័ន្ធ នីមួយៗ ដែលប្រធាន គ.ជ.ប បានចារយល់ព្រមរួចហើយ ។

១២.១៦.៦.២ បញ្ចូលទិន្នន័យ ដូចបញ្ជាក់ក្នុងចំណុច ១២.១៦.៦.១ ខាងលើ ឱ្យបានត្រឹមត្រូវ ទៅក្នុងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ រួច

បញ្ជាកម្មវិធីនេះឱ្យដំណើរការគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។ ទន្ទឹមនឹងនេះ ត្រូវផ្អែកលើទិន្នន័យដដែល គណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈ ដោយការអនុវត្តប្រមាណវិធីតាមរូបមន្តដែលកំណត់ ដោយច្បាប់ និងដូចចែងក្នុងជំពូកទី ៨ នៃ ប.ន.ឃ.ស នេះ ។ ត្រូវធានាថា លទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈ តាមរូបភាពទាំងពីរមានលក្ខណៈត្រឹមត្រូវដូចគ្នា ។

១២.១៦.៦.៣ ស្រង់ឈ្មោះបេក្ខជន ដែលត្រូវជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងឈ្មោះបេក្ខជនដែលត្រូវទទួលតំណែង ជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ពីបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលទទួលបានអាសនៈ បញ្ចូលទៅក្នុងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ។

១២.១៦.៦.៤ ពិនិត្យផ្ទៀងផ្ទាត់បន្ថែមកំណត់ហេតុពាក់ព័ន្ធ ស្តីពីលទ្ធផលនៃការចាប់ឆ្នោតដែល គធ/ខប បានអនុវត្ត ប្រសិនបើក្នុងការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ មានករណីសំឡេងឆ្នោតគាំទ្រស្មើគ្នា រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ឬ/និងដែលមានបេក្ខជនជាប់ឆ្នោតនឹងត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ។

១២.១៦.៦.៥ បោះពុម្ព ឬរៀបចំឯកសារលទ្ធផលនៃការអនុវត្តចំណុច ១២.៦.៦.២ និង ១២.១៦.៦.៣ ខាងលើ មួយមុខមួយ (១) ច្បាប់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់បន្ថែមជាមួយនឹងបញ្ជីបេក្ខជនផ្លូវការ និងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១១) ពាក់ព័ន្ធ ។

១២.១៦.៦.៦ អនុវត្តនីតិវិធីដូចចែងចាប់ពីចំណុច ១២.១៦.៦.២ ដល់ ១២.១៦.៦.៥ ខាងលើឡើងវិញម្តងទៀត ប្រសិនបើលទ្ធផលនៃការផ្ទៀងផ្ទាត់ ដូចចែងក្នុងចំណុច ១២.១៦.៦.៥ ខាងលើ មានភាពខុសគ្នាពីលទ្ធផលដែល គធ/ខប បានត្រួតពិនិត្យម្តងហើយ ។ ក្នុងករណី លទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនេះ នៅតែមានភាពខុសគ្នា ត្រូវយកតាមលទ្ធផលដែលក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បាន គណនា និងផ្ទៀងផ្ទាត់ ។

១២.១៦.៦.៧ បន្ទាប់ពីការផ្ទៀងផ្ទាត់ឃើញលទ្ធផលត្រឹមត្រូវហើយ ប្រធានក្រុមត្រូវធានាថា តារាងផ្ទៀងផ្ទាត់ ការបែងចែកអាសនៈដោយកុំព្យូទ័រមួយ (១) ច្បាប់ និងតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈតាមការធ្វើប្រមាណវិធីមួយ (១) ច្បាប់ ត្រូវបានចុះហត្ថលេខាដោយលេខាធិការ អនុប្រធានក្រុម និងប្រធានក្រុម ហើយសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ចំនួនប្រាំ (៥) ច្បាប់ ដែលភ្ជាប់ជាមួយនូវសំណុំឯកសារពាក់ព័ន្ធ ដែលក្រុមកំណត់បែងចែកអាសនៈបានទទួល ដូចចែងក្នុងចំណុច ១២.១៦.៤ ខាងលើ ត្រូវបានដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។

**ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គ.ជ.ប ឬ/និង ត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ត្រូវបានបើកត្រួតពិនិត្យផ្ទៀងផ្ទាត់**

**ប្រការ ១២.១៧** យោងតាមការកំណត់របស់ គ.ជ.ប ដូចចែងក្នុងចំណុច ១២.១៤.១ ខាងលើ ប្រសិនបើឃុំ សង្កាត់ដែលនឹងត្រូវធ្វើការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ត្រូវបានដាក់នៅ គ.ជ.ប ឬ/និងត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើនត្រូវបានបើកត្រួតពិនិត្យផ្ទៀងផ្ទាត់ ប៉ុន្តែ គធ/ខប បានសម្រេចយល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ អគ្គលេខាធិការ ត្រូវណែនាំក្រុមត្រួតពិនិត្យដែលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈឱ្យធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធី ដូចខាងក្រោម ៖

១២.១៧.១ ប្រសិនបើ ផ្អែកតាមកម្រិតនៃភាពមិនប្រក្រតីពាក់ព័ន្ធនឹងពាក្យបណ្តឹង ដែលមិននាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ គ.ជ.ប ត្រូវសម្រេចមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុកត្រូវពិនិត្យជាមុននូវសម្រង់សេចក្តីសម្រេចរបស់ គធ/ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ និងត្រូវធានាថា ផ្អែកលើរាល់ឯកសារ ដែលមាននៅក្នុងកញ្ចប់ " យពិសេស " ដូចបញ្ជាក់ក្នុងចំណុច ១២.១០.២ ខាងលើ នីតិវិធីក្នុងជំពូកនេះ ចាប់ពីចំណុច ១២.១៦.១.២ ដល់ ១២.១៦.១.៨ ត្រូវតែបានអនុវត្ត ។

១២.១៧.២ បន្ទាប់ពីបានអនុវត្តរាល់នីតិវិធីដូចបញ្ជាក់ក្នុងចំណុច ១២.១៧.១ ខាងលើរួច អគ្គលេខាធិការនៃ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារភ្ជាប់ជាមួយ ដែលក្រុមត្រួតពិនិត្យបានដាក់ជូន ដូចចែងក្នុងចំណុច ១២.១៦.១.៧ ខាងលើ ។ ប្រសិនបើ ពិនិត្យឃើញថាត្រឹមត្រូវហើយ អគ្គលេខាធិការត្រូវចារលើកយោបល់ស្នើសុំការយល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុម (ទ. ១១១៧គព) ហើយដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

១២.១៧.៣ ផ្អែកលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយដូចចែងក្នុងចំណុច ១២.១៧.២ ខាងលើ ទោះបីមានពាក្យបណ្ដឹងដាក់នៅ គឃ/សប ឬ/និង គធ/ខប ក្ដី ក្នុងករណីមានពាក្យបណ្ដឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវប្រជុំសម្រេចលើបណ្ដឹងពាក់ព័ន្ធ ។ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ ៖

១២.១៧.៣.១ ចារយល់ព្រមលើសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

១២.១៧.៣.២ ចារយល់ព្រមលើរបាយការណ៍សរសេរដៃស្ដីពីលទ្ធផលនៃការត្រួតពិនិត្យ និងតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៧គព) រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ។

១២.១៧.៣.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្ដីសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ. ១២០៣) ហើយដែលត្រូវចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទដោយ ប្រធាន គ.ជ.ប ។

១២.១៧.៣.៤ ធានាថា សម្រង់សេចក្ដីសម្រេចយល់ព្រមខាងលើត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនម្ចាស់ដើមបណ្ដឹងមួយ (១) ច្បាប់ (សម្រាប់ពាក្យបណ្ដឹងដាក់នៅ គ.ជ.ប) ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត

ក្នុងឃុំ សង្កាត់ មួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ ផ្ញើជូន គឃ/សប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.១៧.៣.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្តីសម្រេចចុងក្រោយ ។

១២.១៧.៣.៦ ប្រគល់របាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល និងសេចក្តីសម្រេចរបស់ គធ/ខប ដែលមានចំណាររបស់ប្រធាន គ.ជ.ប និងសេចក្តីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់មួយមុខមួយ (១) ច្បាប់ ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយ តាមរយៈអគ្គលេខាធិការទៅឱ្យក្រុមកំណត់បែងចែកអាសនៈដើម្បីមុខការ ។

១២.១៧.៤ នៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផល ដែលមានចំណាររបស់ ប្រធាន គ.ជ.ប ដូចចែងក្នុងចំណុច ១២.១៧.៣.៧ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួន ដូចចែងក្រោមចំណុច ១២.១២.៥ ខាងលើ ហើយត្រូវធានាថា រាល់នីតិវិធីដូចចែងក្រោមចំណុច ១២.១៦.៦ ខាងលើ ត្រូវតែបានអនុវត្ត ។

១២.១៧.៥ ដោយឡែក ប្រសិនបើផ្អែកតាមកម្រិតនៃភាពមិនប្រក្រតីពាក់ព័ន្ធនឹងពាក្យបណ្តឹងដែលអាចនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ គ.ជ.ប បានសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុកត្រូវ ពិនិត្យជាមុននូវពាក្យបណ្តឹងពាក់ព័ន្ធដែលបានដាក់នៅ គ.ជ.ប និងសម្រង់សេចក្តីសម្រេចរបស់ គធ/ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ហើយផ្អែកលើរាល់ឯកសារដែលមាននៅក្នុងកញ្ចប់ " ឃពិសេស " និង " ឃ " ពាក់ព័ន្ធ ដូចបានបញ្ជាក់ក្នុងចំណុច ១២.១០.២ និង ១២.១០.៦ ខាងលើ ត្រូវគួបផ្សំអនុវត្តឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយតាមលំនាំនីតិវិធី ដូចចែងក្នុងជំពូកនេះចាប់ពីចំណុច ១២.១៥.៣ ដល់ ១២.១៥.៥ និងពីចំណុច ១២.១៦.១.១ ដល់ ១២.១៦.១.៤ ខាងលើ ។

១២.១៧.៦ បន្ទាប់ពីបញ្ចប់ការអនុវត្តចំណុច ១២.១៧.៥ ខាងលើ អគ្គលេខាធិការត្រូវពិនិត្យ និងលើកយោបល់លើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលដូចចែងក្នុងចំណុច ១២.១៦.១.៧ ខាងលើ និងរបាយការណ៍ស្តីពីបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្នុងចំណុច ១២.១៥.៥ ខាងលើ ដែលក្រុមត្រួតពិនិត្យលទ្ធផលបានដាក់ជូន រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។ អគ្គលេខាធិការត្រូវ ៖

១២.១៧.៦.១ ចារលើកយោបល់ស្នើសុំបដិសេធសម្រង់សេចក្តីសម្រេចយល់ព្រមរបស់ គធ/ខប និងសុំការយល់ព្រមតាមពាក្យបណ្តឹងដាក់នៅ គ.ជ.ប ដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ។

១២.១៧.៦.២ ចារលើកយោបល់ស្នើសុំយល់ព្រម តាមសម្រង់សេចក្តីសម្រេចយល់ព្រមរបស់ គធ/ខប និងសុំបដិសេធពាក្យបណ្តឹងដាក់នៅ គ.ជ.ប ដែលត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ប្រសិនបើកម្រិតនៃភាពមិនប្រក្រតីមិននាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទេ ។

១២.១៧.៧ ផ្អែកលើសំណុំឯកសារដូចចែងក្រោមចំណុច ១២.១៧.៦ ខាងលើ ទោះបីមានបណ្តឹងដាក់នៅ គឃ/សឃ ឬ/និង គធ/ខប ក្តី ក្នុងករណីមានបណ្តឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវប្រជុំសម្រេចលើបណ្តឹងពាក់ព័ន្ធ ។ ប្រសិនបើ គ.ជ.ប សម្រេចបដិសេធសេចក្តីសម្រេចយល់ព្រមរបស់ គធ/ខប និងយល់ព្រមតាមពាក្យបណ្តឹងដាក់នៅ គ.ជ.ប ដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ ៖

១២.១៧.៧.១ ចារបដិសេធលើសេចក្តីសម្រេចរបស់ គធ/ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

១២.១៧.៧.២ ធានាថា មន្ត្រីជំនាញបានបំពេញ សម្រង់សេចក្តីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ. ១២០៣) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធផង ហើយដែលត្រូវចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទ ដោយប្រធាន គ.ជ.ប ។

១២.១៧.៧.៣ ធានាថា សម្រង់សេចក្តីសម្រេចបដិសេធខាងលើត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនម្ចាស់ដើមបណ្តឹងមួយ (១) ច្បាប់ (សម្រាប់បណ្តឹងដាក់នៅ គ.ជ.ប) ជូនគ្រប់ភ្នាក់ងារគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ មួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ ផ្ញើជូន គឃ/សប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.១៧.៧.៤ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្តីសម្រេចចុងក្រោយហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់នៃឃុំ សង្កាត់នោះ មិនឱ្យលើសពីសាមសិប (៣០) ថ្ងៃបន្ទាប់ពីថ្ងៃសម្រេចបដិសេធ ។

១២.១៧.៧.៥ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផល និងសម្រង់សេចក្តីសម្រេចរបស់ គធ/ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេចរបស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ មួយមុខមួយ (១) ច្បាប់ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុក ដែលត្រូវដាក់ទៅក្នុងកញ្ចប់ " ឃពិសេស" នៃរាជធានី ខេត្តពាក់ព័ន្ធ ។

១២.១៧.៧.៦ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផលបានវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក" ពាក់ព័ន្ធដាក់ក្នុងកញ្ចប់ " ខ " និងកញ្ចប់ " គ " នៃឃុំ សង្កាត់នោះ រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារៈ ឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

១២.១៧.៨ យោងសម្រេចសេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប ដូចចែងក្នុងចំណុច ១២.១៧.៧.២ ខាងលើ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យទាំងនោះ ត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចចែងក្នុងជំពូកទី១៣ នៃ ប.ន.ឃ.ស នេះ ។ ការបោះឆ្នោតសាជាថ្មីនេះ ត្រូវអនុវត្តដោយផ្អែកលើបញ្ជីបោះឆ្នោតដដែល បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដដែល និងសន្លឹកឆ្នោតដែលមានទម្រង់ និងខ្លឹមសារដដែល ប៉ុន្តែត្រូវបោះពុម្ពថ្មីលើក្រដាសពណ៌ផ្សេង ។

១២.១៧.៩ ផ្អែកលើសំណុំឯកសារត្រួតពិនិត្យលទ្ធផលដូចចែងក្រោមចំណុច ១២.១៧.៦ ខាងលើ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្តីសម្រេចរបស់ គធ/ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវធានាថា បញ្ញត្តិ និងនីតិវិធីដូចចែងក្រោមចំណុច ១២.១៧.៣ ខាងលើត្រូវតែបានអនុវត្ត ។

១២.១៧.១០ ក្នុងការអនុវត្តចំណុច ១២.១៧.៩ ខាងលើ និងនៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលដែលមានចំណារប្រធាន គ.ជ.ប ដូចចែងក្នុងចំណុច ១២.១៧.៣.៧ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈត្រូវចាត់ចែងអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួន ដូចចែងក្រោមចំណុច ១២.១២.៥ ខាងលើ និងត្រូវធានាថា រាល់នីតិវិធី ដូចចែងក្រោមចំណុច ១២.១៦.៦ ខាងលើ ត្រូវតែបានអនុវត្ត ។

១២.១៧.១១ នៅពេលដែលក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈបានបញ្ចប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គឃ/សប ឬ/និង គធ/ខប ឬ/និង គ.ជ.ប ហើយដែលត្រូវបាន គ.ជ.ប សម្រេចបដិសេធ ឬយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះរួចហើយ អគ្គលេខាធិការត្រូវធានាថា ក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុកតាមរាជធានី ខេត្តនីមួយៗ និងក្រុមកំណត់បែងចែកអាសនៈបានរៀបចំទុកដាក់រាល់របាយការណ៍ ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធ ដែលបានប្រើក្នុងការត្រួតពិនិត្យ

និងផ្ទៀងផ្ទាត់ខាងលើ ដោយត្រូវច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " ឬ/និងក្នុងកញ្ចប់សុវត្ថិភាព " ក " កញ្ចប់ " ខ " កញ្ចប់ " គ " និងកញ្ចប់ " ឃ " តាមលំនាំដូចដើម និងនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារៈឯកសារដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

**ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន និងដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ/ខប ឬ/និង គ.ជ.ប**

**ប្រការ** ១២.១៨ យោងតាមការកំណត់របស់ គ.ជ.ប ដូចចែងក្នុងចំណុច ១២.១៨.១ ខាងលើ ប្រសិនបើឃុំ សង្កាត់ដែលនឹងត្រូវធ្វើការត្រួតពិនិត្យលទ្ធផលឡើងវិញ ស្ថិតក្នុងករណីឃុំ សង្កាត់ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងក្នុងករណីឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចបញ្ជាក់ក្នុងលក្ខខណ្ឌក្រោមចំណុច ១២.១៨.២ ខាងលើ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈ ឱ្យធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធីដូចខាងក្រោម ៖

១២.១៨.១ ប្រសិនបើគ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ពាក់ព័ន្ធនឹងករណីដូចចែងក្នុងប្រការ ១២.១៨ ខាងលើ ត្រូវបានដាក់ នៅ គ.ជ.ប ដូចបញ្ជាក់ក្រោមប្រការ ១២.១១ ខាងលើទេនោះ គ.ជ.ប និងអគ្គលេខាធិការ ត្រូវធានាថា រាល់នីតិវិធីដូចចែងក្រោមប្រការ ១២.១៦ ខាងលើត្រូវតែបានអនុវត្ត ។

១២.១៨.២ ប្រសិនបើមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពាក់ព័ន្ធនឹងករណីដូចចែងក្នុងប្រការ ១២.១៨ ខាងលើ ត្រូវបានដាក់នៅ គ.ជ.ប ក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតដូចចែងក្រោមប្រការ ១២.១៧ ខាងលើ រួចហើយនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹង គ.ជ.ប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យដែលអគ្គលេខាធិការ បានដាក់ជូនដើម្បីពិនិត្យ សម្រេចដោយមិនចាំបាច់ឱ្យធ្វើការត្រួតពិនិត្យ ឬ/និងបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ។

១២.១៨.៣ ប្រសិនបើមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពាក់ព័ន្ធនឹងករណី ដូចចែងក្នុងប្រការ ១២.១៨ ខាងលើ ត្រូវបានដាក់នៅ គ.ជ.ប ក្រោយពេលដែលក្រុមត្រួតពិនិត្យ

លទ្ធផលបានធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតដូចចែងក្រោមចំណុច ១២.១៦ ខាងលើរួចហើយនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្ដឹង គ.ជ.ប និងអគ្គលេខាធិការ ត្រូវធានាថា រាល់នីតិវិធីដូចចែងចាប់ពីចំណុច ១២.១៧.៥ ដល់ ១២.១៧.៦ ខាងលើត្រូវតែបានអនុវត្ត ។

១២.១៨.៤ ប្រសិនបើ មានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ពាក់ព័ន្ធនឹងករណីដូចចែងក្នុងប្រការ ១២.១៨ ខាងលើ ត្រូវបានដាក់នៅ គ.ជ.ប និងមានជាប់ទាក់ទងនឹងឃុំ សង្កាត់ ដែលមិនទាន់បានត្រួតពិនិត្យលទ្ធផលនៅឡើយ គ.ជ.ប និងអគ្គលេខាធិការ ត្រូវធានាថា រាល់នីតិវិធីដូចចែងចាប់ពីចំណុច១២.១៦.១.១ដល់ ១២.១៦.១.៨ និងពីចំណុច ១២.១៧.៥ ដល់ ១២.១៧.៦ ខាងលើ ត្រូវតែបានអនុវត្ត ។

១២.១៨.៥ ផ្អែកលើលទ្ធផលដោយឡែកពីគ្នានៃការអនុវត្តចំណុច ១២.១៨.១ ១២.១៨.២ ១២.១៨.៣ និង ១២.១៨.៤ គ.ជ.ប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹងពាក់ព័ន្ធនីមួយៗ ។

១២.១៨.៦ ប្រសិនបើ ផ្អែកលើលទ្ធផលនៃការអនុវត្តដូចបញ្ជាក់ក្នុងចំណុច ១២.១៨.៥ ខាងលើ បង្ហាញឱ្យឃើញថា ពិតជាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលនាំឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងបណ្ដឹងនោះមែន គ.ជ.ប ត្រូវសម្រេចយល់ព្រមតាមពាក្យបណ្ដឹងនោះ ។ គ.ជ.ប ត្រូវធានាថា រាល់នីតិវិធី ដូចចែងចាប់ពីចំណុច ១២.១៧.៧.១ ដល់ ១២.១៧.៧.៦ និង ចំណុច ១២.១៧.៨ ខាងលើ ត្រូវតែបានអនុវត្ត ។

១២.១៨.៧ ប្រសិនបើផ្អែកលើលទ្ធផលនៃការអនុវត្តដូចបញ្ជាក់ក្នុងចំណុច ១២.១៨.៥ ខាងលើ បង្ហាញឱ្យឃើញថា កម្រិតនៃភាពមិនប្រក្រតីមិននាំឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះទេ គ.ជ.ប ត្រូវសម្រេចបដិសេធពាក្យបណ្ដឹងតវ៉ានោះ ។ គ.ជ.ប ត្រូវធានាថារាល់នីតិវិធី ដូចចែងចាប់ពីចំណុច ១២.១៧.៩ ១២.១៧.១០ និង ១២.១៧.១១ ខាងលើ ត្រូវតែបានអនុវត្ត ។

១២.១៨.៨ នៅពេលដែលក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈបានបញ្ចប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់

ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងដែលមានពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គ.ជ.ប ហើយដែលត្រូវបាន គ.ជ.ប សម្រេចយល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះរួចហើយ អគ្គលេខាធិការត្រូវធានាថា ក្រុមត្រួតពិនិត្យទទួលបន្ទុករាជធានី ខេត្តនីមួយៗ និងក្រុមកំណត់បែងចែកអាសនៈបានរៀបចំទុកដាក់រាល់របាយការណ៍ ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធដែលបានប្រើក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ខាងលើ ដោយត្រូវច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " ឬ/និងក្នុងកញ្ចប់ សុវត្ថិភាព " ក " កញ្ចប់ " ខ " កញ្ចប់ " គ " និងកញ្ចប់ " ឃ " តាមលំនាំ ដូចដើម រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារៈ ឯកសារដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

**ការរៀបចំ និងការផ្សព្វផ្សាយសេចក្ដីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**ប្រការ ១២.១៩** បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់ នូវរាល់នីតិវិធីនៃការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅ គ.ជ.ប ដូចចែងក្រោមប្រការ ១២.១៥ ១២.១៦ ១២.១៧ និង ១២.១៨ ខាងលើ គ.ជ.ប ត្រូវធានាថា ៖

១២.១៩.១ ផ្អែកតាមរាល់សេចក្ដីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ ដូចចែងក្នុងចំណុច ១២.១៥.៧.៣ ១២.១៧.៧.២ និង ១២.១៨.៦ ខាងលើ គ.ជ.ប បានរៀបចំ និងចាត់ចែងការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យទាំងអស់នៃឃុំ សង្កាត់ពាក់ព័ន្ធដោយត្រូវអនុវត្តតាមលក្ខខណ្ឌដូចចែងក្រោមជំពូកទី ១៣ នៃ ប.ន.ឃ.ស នេះ ។

១២.១៩.២ ផ្អែកតាមរាល់សេចក្ដីសម្រេចរបស់ គ.ជ.ប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ហើយដែលត្រូវបានក្រុមកំណត់បែងចែកអាសនៈ រៀបចំសំណុំឯកសារពាក់ព័ន្ធដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដើម្បីពិនិត្យសម្រេចដូចចែងក្នុងចំណុច ១២.១៥.១០.៤ ១២.១៦.៦.៧ ១២.១៧.៤ ១២.១៧.១០ និង ១២.១៨.៧ ខាងលើ ប្រធាន គ.ជ.ប បានចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទលើសេចក្ដីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ. ១១១៨) ។ ប្រធាន គ.ជ.ប ត្រូវចាត់ចែង និងប្រើប្រាស់សេចក្ដីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដូចខាងក្រោម ៖

១២.១៩.២.១ ផ្ញើជូននាយករដ្ឋមន្ត្រីមួយ (១) ច្បាប់ ។

១២.១៩.២.២ ផ្ញើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមួយ (១) ច្បាប់ ។

១២.១៩.២.៣ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ ដើម្បីបិទផ្សាយនៅលេខាធិការដ្ឋាន គធ/ខប ។

១២.១៩.២.៤ ផ្ញើជូន គឃ/សប ពាក់ព័ន្ធមួយ (១) ច្បាប់ ដើម្បីបិទផ្សាយនៅទីស្នាក់ការ គឃ/សប ។

១២.១៩.២.៥ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

១២.១៩.៣ ផ្អែកតាមរាល់សេចក្តីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបោះឆ្នោតសាជាថ្មី ដូចចែងក្នុងចំណុច ១២.១៩.១ ខាងលើ ប្រធាន គ.ជ.ប បានចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទលើសេចក្តីប្រកាសលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ (ទ. ១១១៨) និងបានចាត់ចែងប្រើប្រាស់តាមការកំណត់ ដូចបញ្ជាក់ចាប់ពីចំណុច ១២.១៩.២.១ ដល់ ១២.១៩.២.៥ ខាងលើ ។

# ជំពូកទី ១៣
# ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន និងការបោះឆ្នោតសារជាថ្មី

**ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន**

**ប្រការ ១៣.១** មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួនស្ថិតក្នុងកាលៈទេសៈមានអាសន្នដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះបាន ។

១៣.១.១ ការសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតបាន លុះត្រាតែការិយាល័យបោះឆ្នោតនោះ ឬទាំងនោះស្ថិតក្នុងកាលៈទេសៈមានអាសន្ន ។ កាលៈទេសៈមានអាសន្នត្រូវបានកំណត់ដូចជាករណីណាមួយក្នុងចំណោមករណីខាងក្រោម ៖

១៣.១.១.១ អសន្តិសុខជាសាធារណៈ ។

១៣.១.១.២ ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយផែនដី ឬគ្រោះធម្មជាតិផ្សេងទៀត ។

១៣.១.១.៣ ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោត ដោយយថាហេតុណាមួយ អគ្គិភ័យ ឬការខូចខាតប្រហាក់ប្រហែលគ្នា ដែលនាំឱ្យមានគ្រោះថ្នាក់ ។

១៣.១.១.៤ ការរាំងស្ទះផ្នែករដ្ឋបាល ដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន ។

១៣.១.២ នៅមុនថ្ងៃបោះឆ្នោត ប្រសិនបើកើតមាន ករណីណាមួយនៃកាលៈទេសៈមានអាសន្នដូចមានចែងក្នុងចំណុច ១៣.១.១ ប្រធានការិយាល័យបោះឆ្នោតត្រូវរាយការណ៍បន្ទាន់ពីស្ថានភាពជាក់ស្តែងទៅ គឃ/សប ។

១៣.១.២.១ គឃ/សប ត្រូវវាយតម្លៃសភាពការណ៍ជាក់ស្តែង ពិនិត្យលទ្ធភាពអាចបើកការិយាល័យបោះឆ្នោតបាន ឬមិនបាន និងរាយការណ៍បន្ទាន់ជូន គធ/ខប ។

១៣.១.២.២ គធ/ខប ត្រូវពិនិត្យ និងវាយតម្លៃសភាពការណ៍ច្បាស់លាស់ដោយផ្តល់យោបល់ និងរាយការណ៍បន្ទាន់ជូន គ.ជ.ប ដើម្បី គ.ជ.ប សម្រេច អំពីការបើក ឬមិនបើកការិយាល័យបោះឆ្នោត ។

១៣.១.២.៣ ក្រោយការសម្រេចបើក ឬមិនបើកការិយាល័យបោះឆ្នោត គ.ជ.ប ត្រូវជូនដំណឹងបន្ទាន់ទៅ គធ/ខប ដើម្បី គធ/ខប ចាត់ចែងបន្ត ។

១៣.១.២.៤ ការរាយការណ៍បន្ទាន់ និងការជូនដំណឹងបន្ទាន់ខាងលើ ត្រូវធ្វើតាម ទូរស័ព្ទ ទូរសារ ឬវិទ្យុទាក់ទង ឬអ៊ីមែល ។

១៣.១.៣ នៅក្នុងថ្ងៃបោះឆ្នោត នៅមុនពេល ឬក្នុងពេលដំណើរការបោះឆ្នោត ប្រសិនបើកើតមានករណីណាមួយនៃកាលៈទេសៈមានអាសន្ន ដូចមានចែងក្នុងចំណុច ១៣.១.១ ប្រធាន គកប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោត ។ ប្រធាន គកប ត្រូវរាយការណ៍ជាបន្ទាន់អំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោត ជូន គឃ/សប ដើម្បី គឃ/សប រាយការណ៍បន្តទៅ គធ/ខប និងដើម្បី គធ/ខប រាយការណ៍បន្ទាន់ជូន គ.ជ.ប ។

១៣.១.៤ ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬដែលត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារកាលៈទេសៈមានអាសន្ន ត្រូវតែបិទរហូតពេញមួយថ្ងៃ ។

**ប្រការ ១៣.២** គ.ជ.ប ត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រីអំពីការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ណាដែលមិនត្រូវបានបើក ឬត្រូវបានបិទដោយសារកាលៈទេសៈមានអាសន្ននៅមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត ។

**ប្រការ ១៣.៣** ក្នុងករណីមានការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ ដោយមាន គកប ជាជំនួយ គឃ/សប ពាក់ព័ន្ធត្រូវ ៖

១៣.៣.១ ជូនដំណឹងដល់អ្នកបោះឆ្នោតពាក់ព័ន្ធ អំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។

១៣.៣.២ ប្រមូលសម្ភារៈ ឯកសារពាក់ព័ន្ធផ្សេងទៀតសម្រាប់បម្រើការបោះឆ្នោតមករក្សាទុកនៅ គឃ/សប ។

១៣.៣.៣ ប្រមូលសន្លឹកឆ្នោត ដែលបោះរួចហើយ នៅការិយាល័យបោះឆ្នោតដែលត្រូវបានបិទក្នុងអំឡុងពេលបោះឆ្នោត រាប់ចំនួន និងកត់ត្រាទុកក្នុងកំណត់ហេតុ រួចដាក់ក្នុងស្បោងមួយដោយឡែក ។ សន្លឹកឆ្នោតទាំងនេះត្រូវទុកជាមោឃៈ គឺមិនត្រូវរាប់បញ្ចូលក្នុងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតឡើយ ។

១៣.៣.៤ ធ្វើកំណត់ហេតុស្ដីពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ និងរាយការណ៍ជូន គធ/ខប ដើម្បីបន្តរាយការណ៍ជូន គ.ជ.ប ។

១៣.៣.៥ ក្នុងករណីកាលៈទេសៈមានអាសន្នកើតមានឡើងនៅការិយាល័យបោះឆ្នោត ក្រោយពេលបិទការបោះឆ្នោត និងបានធ្វើកំណត់ហេតុនៃការបោះឆ្នោតរួចហើយ ហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងឯកសារបោះឆ្នោតនៅរក្សាបានល្អ គកប ត្រូវវេចខ្ចប់សម្ភារៈ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គឃ/សប ដើម្បីចាត់ចែងរាប់សន្លឹកឆ្នោតតាមការកំណត់នៃ ប.ន.ឃ.ស នេះ។

១៣.៣.៦ ក្នុងករណីកាលៈទេសៈមានអាសន្នកើតមានឡើងនៅការិយាល័យបោះឆ្នោត ក្រោយពេលបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងឯកសារបោះឆ្នោតត្រូវខូចខាត គកប ត្រូវវេចខ្ចប់សម្ភារៈ ឯកសារបោះឆ្នោតទាំងនោះ បញ្ជូនទៅ គឃ/សប ដើម្បីបន្តរាយការណ៍ជូន គធ/ខប និង គ.ជ.ប សុំឱ្យមានការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

**ប្រការ** ១៣.៤ សមាសភាព គកប នៃការិយាល័យបោះឆ្នោត ដែលមិនត្រូវបានបើក ឬត្រូវបានបិទ ត្រូវរំសាយ និងទទួលបានប្រាក់កម្រៃស្របតាមកិច្ចសន្យា ។

**ប្រការ** ១៣.៥ នៅការិយាល័យបោះឆ្នោតផ្សេងនៅក្នុងឃុំ សង្កាត់ ដែលមិនត្រូវបានបិទ គកប ទាំងនោះត្រូវអនុវត្តដំណើរការបោះឆ្នោត ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូលការប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោតធម្មតា តាម ប.ន.ឃ.ស នេះ ។

១៣.៥.១ គឃ/សប ត្រូវរក្សាទុក និងការពារឱ្យបានគត់មត់នូវសន្លឹកឆ្នោតដែលបានប្រើប្រាស់ហើយ និងដែលមិនទាន់បានប្រើប្រាស់ លទ្ធផលនៃការរាប់សន្លឹកឆ្នោត និងឯកសារបោះឆ្នោតពាក់ព័ន្ធនៃការិយាល័យដែលមិនត្រូវបានបិទ នៅទីស្នាក់ការ គឃ/សប ឬនៅកន្លែងធានាសុវត្ថិភាពណាមួយ ដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប រហូតដល់ពេលបញ្ចប់ការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ ។

១៣.៥.២ សម្ភារៈ ឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបិទ អាចត្រូវប្រមូល ប្រគល់ទៅឱ្យ គធ/ខប ឬត្រូវរក្សាទុកសិននៅ គឃ/សប ទៅតាមសភាពជាក់ស្ដែង ដែលសម្រេចដោយ គធ/ខប ។

១៣.៥.៣ គឃ/សប ត្រូវរក្សាទុកសម្ភារៈ ឯកសារសម្រាប់បម្រើការបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលត្រូវធ្វើការបោះឆ្នោតសាជាថ្មី តាមការសម្រេចរបស់ គ.ជ.ប ប៉ុន្តែមិនត្រូវលើសពីសាមសិប (៣០) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចមិនបើក ឬបិទ ។

១៣.៥.៤ ការបោះឆ្នោតសាជាថ្មី ដូចករណីចែងក្នុងប្រការ ១៣.១ ខាងលើ ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប ស្របតាម ច.ប.ឃ.ស ។

**ការបោះឆ្នោតសាជាថ្មី ក្នុងករណីបដិសេធលទ្ធផលបណ្ដោះអាសន្ន**

**ប្រការ** ១៣.៦ ក្នុងករណី គ.ជ.ប សម្រេចបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មីក្នុងរយៈពេលមិនលើសពីសាមសិប (៣០) ថ្ងៃ បន្ទាប់ពីថ្ងៃបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះនៅទីតាំងដដែល ឬទីតាំងណាមួយមិនឆ្ងាយពីទីតាំងចាស់នៅក្នុងឃុំ សង្កាត់ដែលមានសន្តិសុខ និងសុវត្ថិភាពល្អ ។

១៣.៦.១ គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទ និងទីតាំងនៃការបោះឆ្នោតសាជាថ្មី និងណែនាំ គឃ/សប ឱ្យផ្សព្វផ្សាយ និងបិទផ្សាយនៅ គឃ/សប និងនៅទីតាំងការិយាល័យដែលត្រូវបោះឆ្នោតសាជាថ្មីយ៉ាងតិចម្ភៃ (២០) ថ្ងៃ មុនថ្ងៃបោះឆ្នោតសាជាថ្មី ។

១៣.៦.២ ដើម្បីគ្រប់គ្រង និងចាត់ចែងការរៀបចំការបោះឆ្នោតសាជាថ្មី គ.ជ.ប ត្រូវ ៖

១_ រក្សាសមាសភាព គធ/ខប និងមន្ត្រីបម្រើការងារនៅ គធ/ខប មួយចំនួនតាមតម្រូវការនៃការងារ ។

២_ រក្សាសមាសភាព គឃ/សប ពាក់ព័ន្ធ ។

៣_ ណែនាំការជ្រើសរើស គកប/គករ សម្រាប់ការបោះឆ្នោតសាជាថ្មី តាមប្រព័ន្ធជ្រើសរើសដូចមានចែងក្នុង ប.ន.ឃ.ស នេះ ។

១៣.៦.៣ អាណត្តិរបស់ គធ/ខប គឃ/សប និង គកប/គករ សម្រាប់ការបោះឆ្នោតសាជាថ្មី ត្រូវបញ្ចប់តាមការកំណត់របស់ គ.ជ.ប ។

១៣.៦.៤ សិទ្ធិអំណាច និងភារកិច្ចរបស់ គធ/ខប គឃ/សប និង គកប/គករ ត្រូវអនុលោមតាម ច.ប.ឃ.ស ប.ន.ឃ.ស នេះ ទៅតាមតម្រូវការជាក់ស្ដែងនៃការបោះឆ្នោតសាជាថ្មី ដែលកំណត់ដោយ គ.ជ.ប ។

១៣.៦.៥ អ្នកបោះឆ្នោតទាំងអស់ដែលមានសិទ្ធិបោះឆ្នោតនៅការិយាល័យនោះ ឬទាំងនោះដែលត្រូវបោះឆ្នោតសាជាថ្មី គឺអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យនោះ ឬទាំងនោះ ទោះបីជាបានបោះឆ្នោតហើយក្តី ឬមិនទាន់បានបោះឆ្នោតក្តី ។

១៣.៦.៦ ដើម្បីមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតសាជាថ្មី ពលរដ្ឋទាំងពីរភេទ ត្រូវ ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ នៃការិយាល័យនោះ ។
- មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ របស់ខ្លួនសម្រាប់ប្រើនៅពេលបោះឆ្នោត ។

១៣.៦.៧ មេឃុំ ចៅសង្កាត់ ត្រូវចេញលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើឱ្យការបោះឆ្នោត ជូនអ្នកបោះឆ្នោត ដែលត្រូវបោះឆ្នោតសាជាថ្មី តាមសំណើសុំរបស់សាមីខ្លួន រហូតដល់ម៉ោងដប់ប្រាំពីរសាមសិប (១៧:៣០) នាទី នៅមួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោតសាជាថ្មី ក្នុងករណីដែលឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ ត្រូវបាត់ ឬខូច ឬដិកហូត ។

១៣.៦.៨ បញ្ជីបោះឆ្នោតផ្លូវការដែលប្រើប្រាស់ក្នុងការបោះឆ្នោតជាសកល ត្រូវបានប្រើប្រាស់សម្រាប់ការបោះឆ្នោតសាជាថ្មី ។ បញ្ជីបោះឆ្នោតនេះ ត្រូវបិទផ្សាយនៅ គឃ/សប និងនៅការិយាល័យបោះឆ្នោតសាជាថ្មីមួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

១៣.៦.៩ បញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការ និងលំដាប់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត ដែលត្រូវបានសម្រេចសម្រាប់ការបោះឆ្នោតសកល ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មី ។ បញ្ជីទាំងនេះត្រូវបិទផ្សាយជាសាធារណៈនៅ គឃ/សប និងនៅការិយាល័យបោះឆ្នោតសាជាថ្មីក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ មុនថ្ងៃបោះឆ្នោតសាជាថ្មី ។

១៣.៦.១០ សមាសភាពភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលត្រូវសង្កេតមើលការិយាល័យបោះឆ្នោតនោះ នៅក្នុងការបោះឆ្នោតសកល ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មី ។

១៣.៦.១១ គ.ជ.ប ត្រូវបោះពុម្ពសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសាជាថ្មីតាមគំរូសន្លឹកឆ្នោតលើកមុន នៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតលើកមុន និងត្រូវឱ្យមានចំនួនគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់ ។

១៣.៦.១២ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារៈ ឯកសារបោះឆ្នោតឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់ គធ/ខប គឃ/សប និង គកប/គករ សម្រាប់ការបោះឆ្នោតសាជាថ្មី ។

១៣.៦.១៣ ក្នុងការបោះឆ្នោតសាជាថ្មី ការឃោសនាបោះឆ្នោត ត្រូវធ្វើតែនៅក្នុងមណ្ឌលឃុំ សង្កាត់ ដែលត្រូវធ្វើការបោះឆ្នោតសាជាថ្មី និង ត្រូវអនុវត្តតាមជំពូកទី ៨ នៃ ប.ន.ឃ.ស នេះ ។ ការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតសាជាថ្មី មានរយៈពេលដប់ប្រាំ (១៥) ថ្ងៃ គឺត្រូវបើកដប់ប្រាំមួយ (១៦) ថ្ងៃមុនថ្ងៃបោះឆ្នោត និងត្រូវបញ្ចប់ម្ភៃបួន (២៤) ម៉ោង មុនថ្ងៃបោះឆ្នោត ។

**ប្រការ** ១៣.៧ នីតិវិធីនៃការបោះឆ្នោតសាជាថ្មីត្រូវអនុវត្តដូចនីតិវិធីនៃការបោះឆ្នោត ដែលបានចែងក្នុងជំពូកទី ១០ នៃ ប.ន.ឃ.ស នេះ ដោយឡែកក្នុងពេលជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ អ្នកបោះឆ្នោតត្រូវប្រើម្រាមចង្អុលដៃឆ្វេងរបស់ខ្លួន ។ ក្នុងករណីម្រាមចង្អុលដៃឆ្វេងពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់ដូចតទៅ ៖ ម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ឬមេដៃឆ្វេង ឬចង្អុលដៃស្តាំ ឬម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ។

**ប្រការ** ១៣.៨ នៅពេលបញ្ចប់ការបោះឆ្នោតសាជាថ្មី គកប/គករ ត្រូវអនុវត្តការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រមូល ប្រគល់ និងទទួលសម្ភារៈបោះឆ្នោត ដូចការបោះឆ្នោតសកលដែលមានចែងក្នុង ប.ន.ឃ.ស នេះ ។

**ប្រការ** ១៣.៩ បន្ទាប់ពីការបោះឆ្នោតសាជាថ្មី គឃ/សប ត្រូវត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងបិទផ្សាយលទ្ធផលបណ្តោះអាសន្នស្របតាម ប.ន.ឃ.ស នេះ ។ គឃ/សប ត្រូវបូកសរុបលទ្ធផលទូទាំងឃុំ សង្កាត់ គឺទាំងលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យដែលមិនត្រូវបានបិទដូចប្រការ ១៣.៥ ទាំងលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតសាជាថ្មី រួចបញ្ជូនកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងសម្ភារៈ ឯកសារពាក់ព័ន្ធ ទៅ គធ/ខប ។

**ប្រការ** ១៣.១០ គធ/ឃប ត្រូវធ្វើការគណនាបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត តាមនីតិវិធីដូចមានចែងក្នុងជំពូកទី ៤ និងប្រការ ១២.៩ នៃ ប.ន.ឃ.ស នេះ ហើយធ្វើរបាយការណ៍ជូន គ.ជ.ប ដើម្បីត្រួតពិនិត្យ និងប្រកាសលទ្ធផលផ្លូវការ ។

**ប្រការ** ១៣.១១ ក្នុងដំណើរការបោះឆ្នោតសាជាថ្មី ចាប់ផ្ដើមពីការរៀបចំដំបូង រហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់ ការប្រជុំសម្រេច ឬ/និងសវនាការដោះស្រាយបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការបោះឆ្នោតសកល ដែលមានចែងក្នុង ប.ន.ឃ.ស នេះ ។

# ជំពូកទី ១៤
# ការបោះឆ្នោតឡើងវិញ

**ប្រការ ១៤.១** អនុលោមតាម ច.ប.ឃ.ស និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការរៀបចំការបោះឆ្នោតឡើងវិញ ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ (១២០) ថ្ងៃ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម ៖

១៤.១.១ ឃុំ សង្កាត់ដែលបង្កើតថ្មី ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

១៤.១.២ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរំសាយចោលតាមលក្ខខណ្ឌ ដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**ប្រការ ១៤.២** ការបោះឆ្នោតឡើងវិញ ត្រូវចាត់ចែងធ្វើឡើងអនុលោមទៅតាម ប.ន.ឃ.ស ដែលមានចែងក្នុង ច.ប.ឃ.ស ។

**ប្រការ ១៤.៣** ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពីមួយរយប៉ែតសិប (១៨០) ថ្ងៃ ។

**ប្រការ ១៤.៤** អនុលោមតាម ច.ប.ឃ.ស ការបោះឆ្នោតឡើងវិញត្រូវប្រព្រឹត្តទៅក្រោមការគ្រប់គ្រង និងចាត់ចែងដោយ គ.ជ.ប ។

**ប្រការ ១៤.៥** កាលបរិច្ឆេទសម្រាប់ការបោះឆ្នោតឡើងវិញត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីមានករណីតម្រូវឱ្យមានការបោះឆ្នោតឡើងវិញ។

**ប្រការ ១៤.៦** គ.ជ.ប ត្រូវចាត់ចែងគ្រប់គ្រងការបោះឆ្នោតឡើងវិញ ដោយអនុលោមតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងពេលវេលាដែលបានកំណត់ដោយច្បាប់ ។

១៤.៦.១ សិទ្ធិអំណាច និងភារកិច្ចរបស់ គ.ជ.ប គធ/ខប គឃ/សប និង គកប ត្រូវអនុលោមតាម ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ។

១៤.៦.២ គ.ជ.ប ត្រូវចាត់ចែងការផ្សព្វផ្សាយដំណឹងអំពីការបោះឆ្នោតឡើងវិញជាសាធារណៈ ដោយឡែកនៅក្នុងឃុំ សង្កាត់ដែលត្រូវធ្វើការបោះឆ្នោតឡើងវិញ ។

១៤.៦.៣ គ.ជ.ប ត្រូវចាត់ចែងការជ្រើសរើស និងតែងតាំង ៖

១_ មន្ត្រីមួយចំនួននៅ គ.ជ.ប តាមតម្រូវការនៃការងារ ។

២_ គធ/ខប ពាក់ព័ន្ធ និងមន្ត្រីមួយចំនួននៃ គធ/ខប នោះតាមតម្រូវការនៃការងារ ។

៣_ គឃ/សប ពាក់ព័ន្ធ ។

៤_ គកប/គករ ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

១៤.៦.៣.១ ការជ្រើសរើស និងតែងតាំងត្រូវអនុលោមតាមប្រព័ន្ធជ្រើសរើសដូចមានចែងក្នុង ប.ន.ឃ.ស នេះ ។ ប្រសិនបើអាចធ្វើបាន គួរជ្រើសរើសមន្ត្រីដែលធ្លាប់បំរើការងារបោះឆ្នោតកន្លងមក ។

១៤.៦.៣.២ រយៈពេលនៃការជ្រើសរើស និងតែងតាំង និងរយៈពេលនៃការបណ្តុះបណ្តាលមន្ត្រីដែលជ្រើសរើសថ្មី ដូចចែងក្នុងចំណុច ១៤.៦.៣ ខាងលើ ត្រូវកាត់បន្ថយសមស្របតាមទំហំការងារ ។

១៤.៦.៣.៣ ពេលវេលានៃការជ្រើសរើស និងតែងតាំង និងអាណត្តិរបស់គណៈកម្មការគ្រប់លំដាប់ថ្នាក់ និងមន្ត្រីដែលជ្រើសរើសថ្មី ត្រូវកំណត់ដោយ គ.ជ.ប ។

១៤.៦.៤ គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលត្រូវបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ (១) នាក់ និង ភ្នាក់ងារបម្រុងមួយ (១) នាក់ នៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗទៅ គឃ/សប ក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីថ្ងៃដែល គឃ/សប ត្រូវបានបង្កើតឡើង ។

១៤.៦.៥ គណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ក្នុងការបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ទៅ គ.ជ.ប នៅក្រោយពេលដែល គ.ជ.ប ប្រកាសអំពីការបោះឆ្នោតឡើងវិញ ។

១៤.៦.៦ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតឱ្យសង្កេតការណ៍ក្នុងការបោះឆ្នោតសកល ដែលមានបំណងសង្កេតមើលដំណើរការរៀបចំការបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ទៅ គ.ជ.ប នៅក្រោយពេលដែល គ.ជ.ប ប្រកាសអំពីការបោះឆ្នោតឡើងវិញ ។

១៤.៦.៧ ក្នុងករណីឃុំ សង្កាត់ត្រូវបង្កើតថ្មី ដូចមានចែងក្នុងចំណុច ១៤.១.១ ខាងលើ លធ/ខប ត្រូវសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានរក្សាសៀវភៅបញ្ជីបោះឆ្នោតពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យ និងលើកសំណើកែសម្រួលទីតាំងការិយាល័យបោះឆ្នោត ដោយត្រូវផ្អែកលើការិយាល័យចាស់ និងការប្រែប្រួលភូមិសាស្ត្រប្រជាសាស្ត្រ និងព្រំប្រទល់រដ្ឋបាលថ្មី ។

១៤.៦.៨ គ.ជ.ប ត្រូវកំណត់ការកែសម្រួលទីតាំងការិយាល័យបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធដោយផ្អែកតាមសំណើរបស់ លធ/ខប ។ បញ្ជីឈ្មោះទីតាំងផ្លូវការនៃការិយាល័យបោះឆ្នោតឡើងវិញ ត្រូវបិទផ្សាយជាសាធារណៈនៅ គឃ/សប និងនៅតាមការិយាល័យបោះឆ្នោតយ៉ាងតិចមួយ (១) ថ្ងៃ មុនកាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជន ។

១៤.៦.៩ បញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញ ត្រូវយកបញ្ជីបោះឆ្នោតដែល គ.ជ.ប បានផ្តល់សុពលភាពចុងក្រោយ ។

១៤.៦.៩.១ ក្នុងករណីឃុំ សង្កាត់ត្រូវបង្កើតថ្មី ដូចមានចែងក្នុងចំណុច ១៤.១.១ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យ និងកែសម្រួលបញ្ជីបោះឆ្នោត ដោយផ្អែកលើបញ្ជីបោះឆ្នោតចុងក្រោយឱ្យបានត្រឹមត្រូវតាមទីតាំងការិយាល័យបោះឆ្នោតដែលត្រូវបានកែសម្រួលថ្មី ដូចមានចែងក្នុងចំណុច ១៤.៦.៧ និង ១៤.៦.៨ ខាងលើ ។

១៤.៦.៩.២ គ.ជ.ប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតដែលកែសម្រួលថ្មី ។ បញ្ជីបោះឆ្នោតផ្លូវការនេះ ត្រូវបិទផ្សាយនៅ គឃ/សប និងនៅការិយាល័យបោះឆ្នោត ដែលត្រូវបោះឆ្នោតឡើងវិញនៅថ្ងៃជាមួយនឹងថ្ងៃបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងត្រូវបិទផ្សាយម្តងទៀត នៅទីកន្លែងដដែលមួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

១៤.៦.១០ មេឃុំ ចៅសង្កាត់ពាក់ព័ន្ធត្រូវចេញលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើឱ្យការបោះឆ្នោត ជូនអ្នកបោះឆ្នោតតាមសំណើសុំរបស់សាមីខ្លួន រហូតដល់ម៉ោងដប់ប្រាំពីរសាមសិបនាទី (១៧:៣០) នៅមួយ (១)ថ្ងៃ មុនថ្ងៃបោះឆ្នោតឡើងវិញក្នុងករណីគាត់គ្មានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ឬឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ត្រូវបាត់ ឬខូច ឬដកហូត ។

១៨.៦.១១ ដើម្បីមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតឡើងវិញ ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ពាក់ព័ន្ធត្រូវ ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតក្នុងឃុំសង្កាត់ ដែលត្រូវបោះឆ្នោតឡើងវិញ ។
- មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយរបស់ខ្លួនសម្រាប់ប្រើនៅពេលបោះឆ្នោត ។

១៨.៦.១២ ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការចាប់ឆ្នោតកំណត់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតឡើងវិញត្រូវអនុវត្តតាមជំពូកទី ៧ នៃ ប.ន.ឃ.ស នេះ ។

១៨.៦.១៣ គ.ជ.ប ត្រូវធ្វើគំរូសន្លឹកឆ្នោត និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញនៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតដែលប្រើប្រាស់ក្នុងការបោះឆ្នោតសកល ។

១៨.៦.១៤ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារៈ ឯកសារបោះឆ្នោតជូន គធ/ខប គឃ/សប និង គកប/គកប សម្រាប់ការរៀបចំបោះឆ្នោតឡើងវិញឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។

១៨.៦.១៥ ការឃោសនាបោះឆ្នោតមានរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ម្ភៃបួន (២៤) ម៉ោង មុនថ្ងៃបោះឆ្នោត ។ ការឃោសនាបោះឆ្នោត ត្រូវធ្វើតែក្នុងមណ្ឌលនៃឃុំ សង្កាត់ ដែលត្រូវធ្វើការបោះឆ្នោតឡើងវិញ និងត្រូវគោរពតាមលក្ខខណ្ឌ ដែលមានចែងក្នុងជំពូកទី ៨ នៃ ប.ន.ឃ.ស នេះ ។

**ប្រការ** ១៨.៧ នីតិវិធីនៃការបោះឆ្នោតឡើងវិញ ត្រូវអនុវត្តដូចនីតិវិធីនៃការបោះឆ្នោត ដែលមានចែងក្នុងជំពូកទី ១០ ទី១១ និងទី ១២ នៃប.ន.ឃ.ស នេះ ។

១៨.៧.១ ការបោះឆ្នោតឡើងវិញ ត្រូវអនុវត្តតែមួយថ្ងៃចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១៥:០០នាទី ។

១៨.៧.២ នៅពេលបញ្ចប់ការបោះឆ្នោតឡើងវិញ គកប/គកក ត្រូវអនុវត្តការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រមូល ប្រគល់ និងទទួលសម្ភារៈ ឯកសារបោះឆ្នោត ដូចការបោះឆ្នោតសកលដែលមានចែងក្នុង ប.ន.ឃ.ស នេះ ។

១៨.៧.៣ គឃ/សប ត្រូវត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតឡើងវិញពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ និងបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។

១៨.៧.៤ គធ/ខប ត្រូវធ្វើការគណនាបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមនីតិវិធីដូចមានចែងក្នុងជំពូកទី ៤ និងប្រការ ១២.៩ នៃ ប.ន.ឃ.ស នេះ ហើយធ្វើរបាយការណ៍ជូន គ.ជ.ប ដើម្បីត្រួតពិនិត្យនិងប្រកាសលទ្ធផលផ្លូវការ ។

**ប្រការ ១៨.៨** ក្នុងការរៀបចំការបោះឆ្នោតឡើងវិញ ចាប់តាំងពីការផ្ដើមដំបូងរហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់ ការប្រជុំសម្រេច ឬ/និងសវនាការដោះស្រាយបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការបោះឆ្នោតជាសកល ដែលមានចែងក្នុង ប.ន.ឃ.ស នេះ ។

# ជំពូកទី ១៥
# ថវិកា និង ហិរញ្ញវត្ថុ

**ប្រការ ១៥.១** ថវិកា នៃគណនីពិសេសនៅរតនាគារ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រើប្រាស់ដោយ គ.ជ.ប ត្រូវបើកនៅរតនាគារជាតិ ។

១៥.១.១ តាមច្បាប់ស្តីពីគណនីពិសេសនៃ គ.ជ.ប រាជរដ្ឋាភិបាលត្រូវដាក់ថវិការួមចំណែករបស់ខ្លួនក្នុងគណនីពិសេសនេះ ។

១៥.១.២ ថវិកានៃគណនីពិសេសនឹងបានមកពីមូលនិធិទាយជ្ជទានដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការមិនមែនរដ្ឋាភិបាល និងចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ១៥.២** គ.ជ.ប ត្រូវបើកគណនីនៅធនាគារមួយ ឬច្រើនតាមតំរូវការជាក់ស្តែង ឬរតនាគាររាជធានី ខេត្ត និងផ្ទេរប្រាក់ចូលក្នុងគណនីនេះតាមចំនួនថវិកា ដែលត្រូវការចាំបាច់សម្រាប់ចំណាយលើការងារបោះឆ្នោត ។

**ប្រការ ១៥.៣** គ.ជ.ប ត្រូវកំណត់បរិបថក្នុងការចំណាយថវិកាដូចបានបញ្ជាក់ក្នុងប្រការ ១៥.១ មានដូចខាងក្រោម ៖

១៥.៣.១ ការប្រើប្រាស់មូលប្បទានប័ត្រសម្រាប់ការចំណាយរបស់ខ្លួន ៖

១៥.៣.១.១ នៅលើមូលប្បទានប័ត្រត្រូវមានហត្ថលេខាចំនួនពីរដែលក្នុងនោះត្រូវតែមានហត្ថលេខាមួយរបស់ប្រធាន គ.ជ.ប ។

១៥.៣.១.២ ក្នុងករណីប្រធាន គ.ជ.ប អវត្តមាន អនុប្រធានអាចចុះហត្ថលេខាជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន គ.ជ.ប ។

១៥.៣.១.៣ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុត្រូវបានផ្តល់សិទ្ធិអំណាច ក្នុងការចុះហត្ថលេខាលើមូលប្បទានប័ត្ររបស់ គ.ជ.ប ។

១៥.៣.១.៤ ក្នុងករណី ដែលប្រធាននាយកដ្ឋានហិរញ្ញវត្ថុមិនអាចបំពេញការងារបានអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុអាចចុះហត្ថលេខាជំនួសប្រសិនបើគាត់ត្រូវបានប្រគល់សិទ្ធិអំណាចឱ្យដោយ គ.ជ.ប ។

១៥.៣.២ រាល់ការចំណាយ ត្រូវតែមានការយល់ព្រមពី នាយកដ្ឋានហិរញ្ញវត្ថុមុនពេលដំណើរការទូទាត់ ។

១៥.៣.២.១ រាល់សក្ខីប័ត្រចំណាយទាំងអស់ត្រូវតែបានផ្ទៀងផ្ទាត់ ដោយត្រឹមត្រូវ ។

១៥.៣.២.២ សក្ខីប័ត្រត្រឹមត្រូវរួមមាន : គម្រោងសំណើសុំ ឯកសារបញ្ជាទិញ ឯកសារស្ទាបស្ទង់តម្លៃ លិខិតប្រគល់ ទទួល និងវិក័យប័ត្រ ។

១៥.៣.២.៣ លិខិតបញ្ជាបេសកកម្មត្រូវមានចុះទិដ្ឋាការច្បាស់លាស់ ហើយមានវិក្កយបត្រលើមធ្យោបាយធ្វើដំណើរ ស្នាក់នៅ ។

១៥.៣.២.៤ ការទូទាត់ប្រាក់កម្រៃដែល គ.ជ.ប ជាអ្នកកំណត់ ត្រូវមានពាក្យសុំចូលបម្រើការងារ កិច្ចសន្យា សេចក្តីសម្រេចកំណត់ប្រាក់កម្រៃ តារាងប្រាក់កម្រៃ តារាងប្រៀបធៀបប្រាក់កម្រៃ ដែលមានចុះហត្ថលេខាដោយ គ.ជ.ប និងមានចុះហត្ថលេខានៃអ្នកដែលត្រូវបានទទួលប្រាក់កម្រៃ ។

១៥.៣.៣ រាល់ការចំណាយដោយផ្ទាល់ ត្រូវមាន ៖

- សំណើសុំទូទាត់
- កំណត់ហេតុប្រគល់ ទទួល
- កំណត់ហេតុដេញថ្លៃ ឬពិគ្រោះថ្លៃ
- ប័ណ្ណបញ្ចេញ និងប័ណ្ណបញ្ចូលទំនិញ សម្ភារៈ
- កិច្ចសន្យា
- ប័ណ្ណប៉ាតង់
- ដីកាអមលិខិតយុត្តិការ
- ដីកាអមបញ្ចេញអាណត្តិបើកប្រាក់
- សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ
- អាណត្តិបើកប្រាក់ ។

១៥.៣.៤ រាល់ការចំណាយដែលផ្ទុយពីចំណុច ១៥.៣.១ ១៥.៣.២ ១៥.៣.៣ ត្រូវតែមានឯកសារដទៃទៀត ដូចជាលិខិតអនុញ្ញាតឱ្យចំណាយពី គ.ជ.ប សំណៅមូលប្បទានប័ត្រ ឯកសារមួយចំនួន ដែលតំរូវឱ្យធ្វើការទូទាត់តាមការកំណត់ដោយនីតិវិធីហិរញ្ញវត្ថុ ឬអនុក្រឹត្យ ។

**ប្រការ ១៥.៤** គ.ជ.ប ត្រូវកំណត់យកប្រព័ន្ធគណនេយ្យមួយសមស្របសម្រាប់ធ្វើការណែនាំដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ឱ្យអនុវត្តការងារចុះបញ្ជីការគណនេយ្យមានការឯកភាពគ្នា និងងាយស្រួលក្នុងការទូទាត់ ។ គំរូលិខិតស្នាម ឯកសារ បទដ្ឋាននានា ត្រូវកំណត់ឱ្យបានច្បាស់លាស់ មានការឯកភាពគ្នាតាមការកំណត់ពី គ.ជ.ប និងការណែនាំពីនាយកដ្ឋានហិរញ្ញវត្ថុ អនុលោមតាមច្បាប់ និងនីតិវិធីហិរញ្ញវត្ថុ ឬអនុក្រឹត្យ ។

**ប្រការ ១៥.៥** គ.ជ.ប ត្រូវកំណត់បរិបថការងារក្នុងការទិញ ការផ្គត់ផ្គង់ ការបែងចែកសម្ភារៈ ទំនិញ និងសេវាកម្មផ្សេងៗ ។

១៥.៥.១ ការត្រួតពិនិត្យក្នុងការទិញ ការផ្គត់ផ្គង់ ការបែងចែកសម្ភារៈ ទំនិញ និងសេវាកម្មផ្សេងៗ ត្រូវធ្វើឡើងដោយសេវាកម្មពីរ (២) ដាច់ពីគ្នា ។

១៥.៥.២ សម្រាប់គោលបំណងនៃចំណុច ១៥.៥.១ គណៈកម្មការត្រួតពិនិត្យក្នុងការទិញសម្ភារៈ បរិក្ខាររួមមាន ៖

១. នាយកដ្ឋាន ហិរញ្ញវត្ថុ

២. នាយកដ្ឋាន រដ្ឋបាល

៣. នាយកដ្ឋាន ពាក់ព័ន្ធ

នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវក្នុងការរៀបចំដាក់ឱ្យដេញថ្លៃ ឬពិគ្រោះថ្លៃសមស្របតាមនីតិវិធីហិរញ្ញវត្ថុ ឯនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធទទួលខុសត្រូវក្នុងការត្រួតពិនិត្យ អំពីបរិមាណ និងគុណភាពទំនិញ សម្ភារៈ បរិក្ខារ និងសេវាកម្មផ្សេងៗ រួចហើយធ្វើការកត់ត្រាបញ្ចូលឃ្លាំង និងធ្វើការបែងចែក ។

១៥.៥.៣ ទំនិញ សម្ភារៈ បរិក្ខារមួយចំនួន ជាចលនវត្ថុ និងអចលនវត្ថុ ទាំងនៅក្នុង ឬក្រៅសន្និធិត្រូវកត់ត្រាឱ្យបានច្បាស់លាស់ បញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌ ដែលជាការទទួលខុសត្រូវរបស់នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ ។

**ប្រការ ១៥.៦** នាយកដ្ឋានហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ត្រូវធានាថា របាយការណ៍ហិរញ្ញវត្ថុប្រចាំខែត្រូវបានបំពេញមិនឱ្យយឺតជាងសប្តាហ៍ទីបី (៣) នៃខែបន្ទាប់ ។

**ប្រការ ១៥.៧** ឆ្នាំសារពើពន្ធនៃ គ.ជ.ប ត្រូវគិតចាប់ពីថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ។

**ប្រការ ១៥.៨** នៅដំណាច់ឆ្នាំសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន ត្រូវធានារៀបចំ និងត្រួតពិនិត្យ ឱ្យបាននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានអនុវត្តមិនយឺតជាងបី (៣) ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ ។

១៥.៨.១ គ.ជ.ប ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមួយច្បាប់ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៥.៨.២ គ.ជ.ប ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីចំណូល និងកម្មវិធីចំណាយមួយច្បាប់ជូនរដ្ឋសភា មួយច្បាប់ជូនព្រឹទ្ធសភា និងមួយច្បាប់ទៀតជូនទៅរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនឱ្យហួសពីបី (៣) ខែ បន្ទាប់ពីប្រតិបត្តិការបោះឆ្នោតត្រូវបានបញ្ចប់ជាស្ថាពរ ។

# ជំពូកទី ១៦

## សមត្ថកិច្ច និងនីតិវិធីដោះស្រាយវិវាទក្នុងការបោះឆ្នោត និងនីតិវិធីដាក់/ទទួលពាក្យបណ្ដឹង និងដោះស្រាយពាក្យបណ្ដឹងចំពោះគ្រប់អំពើល្មើសបោះឆ្នោត ដែលអាចនាំឱ្យមានការផ្ដន្ទាទោស

### សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត

**ប្រការ ១៦.១** គ.ជ.ប គធ/ខប និង គឃ/សប មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើវិវាទដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដោយបើកសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សាជាសាធារណៈលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែបណ្ដឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

១៦.១.១ នីតិវិធីសវនាការ ប្រជុំសម្រេច និងប្រជុំផ្សះផ្សាដោះស្រាយបណ្ដឹងដូចបានចែងក្នុងជំពូកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរួមមាន ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត បិទផ្សាយបញ្ជីបេក្ខជនដំបូង ឃោសនាបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ។

១៦.១.២ ការរាប់ចំនួនថ្ងៃតវ៉ា និងការសម្រេចលើបណ្ដឹងតវ៉ា ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យផ្លូវការ ។

១៦.១.៣ សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

### សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា

**ប្រការ ១៦.២** ការជំនុំជម្រះ ឬការប្រជុំសម្រេច ឬការប្រជុំផ្សះផ្សា ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលបានចាត់តាំងឱ្យចូលរួមដោយ គឃ/សប ឬ គធ/ខប ឬ គ.ជ.ប ។ ចំនួន និងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវធ្វើឡើងតាមចំនួនសេស ជាអាទិ៍ បី (៣) ឬ ប្រាំ (៥) ឬ ប្រាំពីរ (៧) ឬ ប្រាំបួន (៩) ហើយអាចធ្វើការផ្លាស់ប្ដូរតាមការចាំបាច់ដែលសម្រេចដោយ គឃ/សប ឬ គធ/ខប ឬ គ.ជ.ប។

**ក. សមាសភាពក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ/សប**

១៦.២.១ ប្រធាន អនុប្រធាន និងសមាជិក គឃ/សប ដែលបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេចហៅថា ក្រុមប្រឹក្សាប្រជុំសម្រេច ឬបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សាហៅថា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ។

១៦.២.២ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ/សប រួមមាន ៖

១៦.២.២.១ ប្រធាន គឃ/សប ឬអ្នកតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា

១៦.២.២.២ អនុប្រធាន និងសមាជិក គឃ/សប ទាំងអស់ ជាសមាជិក

១៦.២.២.៣ សមាជិក គឃ/សប មួយ (១) នាក់ ទទួលភារកិច្ចបន្ថែមជាលេខាធិការ ។

១៦.២.៣ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ/សប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត ។

១៦.២.៤ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ/សប មិនត្រូវមានសំឡេងអនុបវាទឡើយ ។

១៦.២.៥ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ/សប មានសិទ្ធិអំណាចកោះហៅភាគីទំនាស់ និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំសម្រេច ឬប្រជុំផ្សះផ្សា ។

**ខ. សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គជ/ខប**

១៦.២.៦ ប្រធាន អនុប្រធាន និងសមាជិក គជ/ខប ដែលបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយបណ្តឹងហៅថា ក្រុមប្រឹក្សាជំនុំជម្រះ ឬបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សាហៅថា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ។

១៦.២.៧ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គជ/ខប រួមមាន ៖

១៦.២.៧.១ ប្រធាន គជ/ខប ឬអ្នកតំណាង ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា

១៦.២.៧.២ អនុប្រធាន និងសមាជិក គធ/ខប ទាំងអស់ ជាសមាជិក
១៦.២.៧.៣ មន្ត្រីសេវាកម្មច្បាប់ និងវិវាទកម្ម ជាលេខាធិការ ។

១៦.២.៨ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត ។

១៦.២.៩ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប មិនត្រូវមានសំឡេងអនុបវាទឡើយ ។

១៦.២.១០ ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ/ខប មានសិទ្ធិអំណាចកោះហៅភាគីទំនាស់ និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ ឬប្រជុំផ្សះផ្សា ។

**គ. សមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប**

១៦.២.១១ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយបណ្ដឹងហៅថា ក្រុមប្រឹក្សាជំនុំជម្រះ ។

១៦.២.១២ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន ៖
១៦.៨.៣.១ ប្រធាន គ.ជ.ប ឬអ្នកតំណាង ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
១៦.៨.៣.២ អនុប្រធាន និងសមាជិក គ.ជ.ប ទាំងអស់ ជាសមាជិក
១៦.៨.៣.៣ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដែលបានចាត់តាំងជាលេខាធិការ ។

១៦.២.១៣ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា ១៧ថ្មី នៃ ច.ប.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គឺដូចគ្នានឹងកូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្ដីសម្រេចរបស់ គ.ជ.ប ។

១៦.២.១៤ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មិនត្រូវមានសំឡេងអនុបវាទឡើយ ។

១៦.២.១៥ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ ។

## ការប្តឹងតវ៉ា ឬការប្តឹងជំទាស់

**ប្រការ ១៦.៣** ជនណាក៏ដោយ ឬអ្នកតំណាង មានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់តាមឋានានុក្រមទៅ គឃ/សប ឬ គធ/ខប ឬ គ.ជ.ប អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មានភាពមិនត្រឹមត្រូវតាម ច.ប.ឃ.ស ឬ/និង ប.ន.ឃ.ស ឬ/និង បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែការប្តឹងតវ៉ា និងការប្តឹងជំទាស់ទាក់ទងនឹងការចុះបញ្ជីនៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត ដែលត្រូវប្តឹងដោយសាមីគណបក្សនយោបាយ ការបិទផ្សាយបញ្ជីបេក្ខជនដំបូង ដែលត្រូវប្តឹងដោយប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវប្តឹងដោយភ្នាក់ងារនៃគណបក្សនយោបាយ និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដែលត្រូវប្តឹងដោយជនគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅឃុំ សង្កាត់ ឬគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ។

១៦.៣.១ ពាក្យបណ្តឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា ។

១៦.៣.២ ពាក្យបណ្តឹងប្តឹងពីអញ្ញាតជន ត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អញ្ញាតជននោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម ។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវជូនដំណឹងទៅអ្នកប្តឹងវិញអំពីករណីនេះក្នុងរយៈពេលសមស្រប ។

១៦.៣.៣ ពាក្យបណ្តឹង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួន បី (៣) ច្បាប់ (ចំពោះបណ្តឹងតវ៉ា) ឬចំនួនបួន (៤) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ។ អ្នកប្តឹងអាចថតចម្លងទម្រង់បែបបទដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យអ្នកតំណាងដាក់ពាក្យបណ្តឹង ឬតវ៉ាជួសខ្លួនបាន។

១៦.៣.៤ មន្ត្រីនៃគណៈកម្មការរៀបចំការបោះឆ្នោតត្រូវប្រគល់ជូន ទ.១២០២ ដល់អ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ ។

១៦.៣.៥ ពាក្យបណ្តឹង ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

១_ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង

២_ កម្មវត្ថុនៃបណ្តឹង

៣_ ប្រភេទនៃអំពើល្មើស

៤_ ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្ត អំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង

៥_ បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោត ដែលត្រូវបានរំលោភ

៦_ អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់

៧_ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន

៨_ ភស្តុតាងផ្សេងៗទៀត បើមាន ។

១៦.៣.៦ ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ហើយជាបន្ទាន់ ។

## ការដកពាក្យបណ្តឹង

**ប្រការ** ១៦.៤ ដើមបណ្តឹងអាចដកពាក្យបណ្តឹងទាំងមូល ឬមួយផ្នែកបាន រហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ/សប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា ឬរហូតដល់ពេលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ/សប ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ/ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ។

១៦.៤.១ ការដកពាក្យបណ្តឹង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គឃ/សប ឬ គធ/ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំសម្រេច ឬជំនុំជម្រះ ឬប្រជុំផ្សះផ្សា នោះការដកពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន ។

១៦.៤.២ ប្រសិនបើការដកពាក្យបណ្តឹង ធ្វើឡើងមុនពេលដំណើរការប្រជុំសម្រេច ឬជំនុំជម្រះ ឬការប្រជុំផ្សះផ្សា គឃ/សប ឬ គធ/ខប ឬ គ.ជ.ប ត្រូវសម្រេចលើកបណ្តឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ ។

១៦.៤.៣ ប្រសិនបើការដកពាក្យបណ្តឹង ធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្តឹងដកពាក្យបណ្តឹង ។

១៦.៤.៤ ប្រសិនបើការដកពាក្យបណ្តឹង ធ្វើឡើងនៅពេលកំពុងប្រជុំសម្រេច ឬជំនុំជម្រះ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្តឹងចោលដោយចេញសេចក្តីសម្រេច ។

## ការរួមបញ្ចូលរឿងក្តី

**ប្រការ ១៦.៥** គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះអាចបញ្ចូលរឿងក្តី ក្នុងករណីដែលមានបណ្តឹងច្រើន ប៉ុន្តែកម្មវត្ថុនៃបណ្តឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្តឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលមានតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ ។ ក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្តីសម្រេចជាស្ថាពរ ប៉ុន្តែអ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅតែបន្តប្រព្រឹត្តល្មើសទៀត ហើយបើមានបណ្តឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវដោះស្រាយដោយចាត់ទុកជាករណីថ្មីទៀត ។

## សិទ្ធិ និងភារកិច្ចរបស់ដើមបណ្តឹង ចុងចម្លើយ អ្នកតំណាង ឬមេធាវី

**ប្រការ ១៦.៦** គូភាគីមានសិទ្ធិអញ្ជើញអ្នកតំណាង ឬសាក្សី ឬមេធាវីដើម្បីធ្វើជាអ្នកតំណាង ឬអ្នកការពារក្តី ឬអ្នកដែលពាក់ព័ន្ធនឹងការប្តឹងឱ្យចូលរួមបំភ្លឺក្នុងសវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សា ប៉ុន្តែត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សាមុនពេលបើកសវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សា ។

១៦.៦.១ គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬអ្នកតំណាងដោយមានចុះហត្ថលេខា ឬផ្តិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃអ្នកតំណាងនោះ (អ្នកតំណាងត្រូវតែជានីតិជន) ។

១៦.៦.២ លិខិតប្រគល់សិទ្ធិត្រូវធ្វើជូនក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សាយ៉ាងតិចពីរ (២) ម៉ោង មុនពេលបើកសវនាការ ឬបើកការប្រជុំសម្រេច ឬបើកការប្រជុំផ្សះផ្សា ។

១៦.៦.៣ សិទ្ធិរបស់មេធាវី ឬអ្នកតំណាងត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរ ។

១៦.៦.៤ មេធាវី ឬអ្នកតំណាងមិនអាចប្រគល់សិទ្ធិបន្តទៅមេធាវី ឬអ្នកតំណាង ដទៃទៀតដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

១៦.៦.៥ ដើមបណ្តឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬអ្នកតំណាងដែលបានទទួលសិទ្ធិផងដែរ ។

១៦.៦.៦ ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានាដែលទាក់ទងនឹងបណ្តឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬអ្នកតំណាងដែលបានទទួលសិទ្ធិផងដែរ ។

១៦.៦.៧ ដើមបណ្តឹង ឬ/និងជនរងគ្រោះ មានវិសមិតភាពរវាងឋានៈជាដើមបណ្តឹង ឬ ជនរងគ្រោះ និងឋានៈជាសាក្សី ។ ដើមបណ្តឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាត ឱ្យផ្តល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ ។

១៦.៦.៨ ដើមបណ្តឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារ ភស្តុតាង ឬសាក្សីដើម្បីជាសំអាង ក្នុងរឿងក្តីរបស់ខ្លួន ។

១៦.៦.៩ ចុងចម្លើយត្រូវបង្ហាញឯកសារ ភស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្តី របស់ខ្លួន ។

១៦.៦.១០ នៅក្នុងនីតិវិធីសវនាការប្រតិបក្ស ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ចុងចម្លើយអាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹងអំពីភស្តុតាងដែលគេមាន ដើមបណ្តឹងក៏អាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយពីភស្តុតាងដែលមានដែរ ។

១៦.៦.១១ ចុងចម្លើយអាចបង្ហាញភស្តុតាង ជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ឬអ្នកតំណាងដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង ។

១៦.៦.១២ មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជំនុំជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកប្រើប្រាស់ក្នុងសវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សានេះ ។ ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរពតាម ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ។

១៦.៦.១៣ ក្នុងករណី គធ/ខប ឬ គ.ជ.ប រកឃើញថា ជនណាបានប្រព្រឹត្តការក្លែងលិខិត ឬឯកសារ ដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារនោះ ជននោះនឹងត្រូវមានទោសតាមច្បាប់ជាធរមាន ។

១៦.៦.១៤ ដើមបណ្តឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ ។

១៦.៦.១៥ ដើមបណ្តឹង ឬចុងចម្លើយ ឬមេធាវី ឬអ្នកតំណាងរបស់ភាគីអាចស្នើសុំឱ្យ គ.ជ.ប ឬ គធ/ខប ឬ គឃ/សប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួន ដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ ។ ការថតចម្លងត្រូវធ្វើដោយមន្ត្រីនៅទីស្តីការ គ.ជ.ប ឬ មន្ត្រី គធ/ខប ឬសមាជិក គឃ/សប ដែលបានចាត់តាំង ។

១៦.៦.១៦ មុនពេលក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេចថយទៅពិភាក្សា ពិចារណា ភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយ ដែលខ្លួនយល់ថា មានប្រយោជន៍ដល់ខ្លួនជូនទៅក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេចដើម្បីពិចារណា ។

១៦.៦.១៧ គូភាគីមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច តាមការកំណត់ក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ។

## សិទ្ធិ និងភារកិច្ចរបស់សាក្សី

**ប្រការ ១៦.៧** សាក្សីត្រូវធ្វើសម្បថជាមុន ហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច នៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់ អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត (ខ្លឹមសារសម្បថ មានក្នុងឧបសម្ព័ន្ធទី ១៨) ។

១៦.៧.១ សាក្សីមានសិទ្ធិឆ្លើយបំភ្លឺ នូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំ ដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ ។

១៦.៧.២ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយ ត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យមកបំភ្លឺដោយក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច។

១៦.៧.៣ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយ មិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នាទោះតាមមធ្យោបាយណាក៏ដោយក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមសវនាការ ឬប្រជុំសម្រេច។

១៦.៧.៤ សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់ជំនុំជម្រះ ឬបន្ទប់ប្រជុំសម្រេចឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ។

## នីតិវិធីសវនាការ ឬនីតិវិធីប្រជុំសម្រេច ឬនីតិវិធីប្រជុំផ្សះផ្សា

**ប្រការ ១៦.៨** ដំណើរការសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សាត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សាអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គសវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សា ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់សវនាការ ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់ប្រជុំផ្សះផ្សា ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកសវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សាដោះស្រាយបណ្តឹង (មានចែងក្នុងឧបសម្ព័ន្ធទី ១៧ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកសវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សាដោះស្រាយបណ្តឹង) ។

**ក. ប្រភេទសវនាការ**

១៦.៨.១ ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬ សវនាការប្រតិបក្ស ឬសវនាការសួរដេញដោល សេចក្តីអធិប្បាយសង្ខេបស្តីពីប្រភេទសវនាការនីមួយៗមានដូចខាងក្រោមនេះ ៖

១៦.៨.១.១ សវនាការសង្ខេប ជាសវនាការដែលគ្មានទម្រង់ការច្រើន ។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថា មានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ ។

១៦.៨.១.២ សវនាការប្រតិបក្ស ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងវិវាទ ។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាងដើម្បីដាក់ជូនសវនាការ ។

១៦.៨.១.៣ សវនាការសួរដេញដោល ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី ។ ក្នុងសវនាការប្រភេទនេះ ទាំងក្រុមប្រឹក្សាជំនុំជម្រះទាំងគូក្តីជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលអង្គហេតុផ្សេងៗដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ឯចំណែកគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបាន ដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

**ខ. ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា**

១៦.៨.២ ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែងដែលបានរៀបចំទុក ។ ប្រធានអង្គុយនៅ

កណ្តាល សមាជិកអង្គុយអមសងខាង និងលេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការប្រជុំផ្សះផ្សាត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្តាំដៃនៃក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា ។

១៦.៨.៣ ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវ ៖

១៦.៨.៣.១ ទី១ ប្រកាសសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា ទី២ ប្រកាសសំណុំរឿង និងប្រកាសបើកសវនាការ ឬការប្រជុំសម្រេច ឬការប្រជុំផ្សះផ្សា ។

១៦.៨.៣.២ បង្គាប់ឱ្យលេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេច រាយការណ៍ អំពីវត្តមានដើមបណ្តឹង ចុងចម្លើយ និងសាក្សី (ករណីជំនុំជម្រះ ឬប្រជុំសម្រេច) ។

១៦.៨.៤ មុននឹងចាប់ផ្តើមសួរដេញដោល ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ត្រូវសួរទៅដើមបណ្តឹងថា តើលោក ឬលោកស្រីនៅតែបន្តប្តឹងដូចមានចែងក្នុងកម្មវត្ថុនៃបណ្តឹង ឬមានការកែប្រែឬទេ?

១៦.៨.៤.១ ប្រសិនបើដើមបណ្តឹងឆ្លើយថា ខ្លួនដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវបង្គាប់ឱ្យលេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការអង្គប្រជុំផ្សះផ្សា កត់ត្រាក្នុងកំណត់ហេតុសវនាការ ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុប្រជុំផ្សះផ្សា ហើយឱ្យដើមបណ្តឹងផ្តិតមេដៃលើកំណត់ហេតុនោះ ។ បន្ទាប់មកក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេចអាចថយទៅពិភាក្សា ពិចារណា ឬបន្តទៅជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សាអាចផ្សះផ្សា រឿងក្តីផ្សេងទៀត (ប្រសិនបើមាន) ។

១៦.៨.៤.២ ប្រសិនបើដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវចាប់ផ្តើមដំណើរការសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា ។

១៦.៨.៤.៣ ក្នុងពេលដំណើរការសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា ប្រសិនបើដើមបណ្តឹងសុំដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ត្រូវបញ្ចប់ការសួរដេញដោល ឬការផ្សះផ្សាដោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងចំណុច ១៦.៤.៣ ឬ ១៦.៤.៤ ។

១៦.៨.៥ ជាដំបូងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ត្រូវសួរដេញដោលទៅដើមបណ្តឹងមុន រួចត្រូវសួរទៅចុងចម្លើយ ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្តឹង សាក្សី ចុងចម្លើយ និងអ្នកពាក់ព័ន្ធ ។

១៦.៨.៦ ប្រសិនបើមានមេធាវីការពារក្តី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេចត្រូវផ្តល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្តី សួរភាគី និងធ្វើសេចក្តីសន្និដ្ឋានចុងក្រោយមុន ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេចថយទៅពិភាក្សា ពិចារណា ។

១៦.៨.៧ ក្រោយពីបានដំណើរសវនាការ ឬប្រជុំសម្រេចតាមលំដាប់លំដោយរួចហើយក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេចត្រូវថយទៅពិភាក្សា ពិចារណានៅក្នុងបន្ទប់សម្ងាត់ ។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេចត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់ ។

### គ. លេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការអង្គប្រជុំផ្សះផ្សា

១៦.៨.៨ លេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការអង្គប្រជុំផ្សះផ្សា មានភារកិច្ចដូចខាងក្រោម ៖

១៦.៨.៨.១ បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកសវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សាឱ្យអ្នកចូលរួមបានជ្រាប ។

១៦.៨.៨.២ នាំសាក្សីទៅធ្វើសម្បថ (ករណីសវនាការ)។

១៦.៨.៨.៣ ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរនៅពេលដែលក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សាអញ្ជើញមកដល់ ។

១៦.៨.៨.៤ ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ អ្នកតំណាង ឬមេធាវី និងសាក្សីដែលត្រូវចូលរួមសវនាការ ឬប្រជុំប្រជុំសម្រេច ឬប្រជុំផ្សះផ្សា។

១៦.៨.៨.៥ រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា ។

១៦.៨.៨.៦ ត្រូវធ្វើកំណត់ហេតុសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា ក្នុងពេលជំនុំជម្រះ ឬប្រជុំសម្រេច ឬប្រជុំសម្រេចដោយដៃ ឬដោយកុំព្យូទ័រ ការកត់ត្រាកំណត់ហេតុសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា មិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ ពាក្យឆូតលុបចោល និងពាក្យសរសេរយោង ត្រូវមានសេចក្ដីបញ្ជាក់ និងមានហត្ថលេខាប្រធាន សមាជិកក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា លេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការអង្គប្រជុំផ្សះផ្សា និងភាគី ឬសាក្សី ។

១៦.៨.៨.៧ អានឯកសារផ្សេងៗ ដែលពាក់ព័ន្ធតាមការបង្គាប់ពីក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា ។

១៦.៨.៨.៨ អញ្ជើញភាគីផ្ដិតមេដៃលើកំណត់ហេតុសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា ក្នុងករណីដែលភាគីណាមួយមិនព្រមផ្ដិតមេដៃ លេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការអង្គប្រជុំផ្សះផ្សា ត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនោះ ។

### ឃ. ពេលវេលាដោះស្រាយបណ្ដឹង

១៦.៨.៩ សវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សា អាចធ្វើជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៨:០០ នាទី ព្រឹក ដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់ និងរសៀលចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:៣០ នាទី ។ ក្នុងករណីចាំបាច់ សវនាការ ឬអង្គប្រជុំសម្រេច ឬអង្គប្រជុំផ្សះផ្សា អាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្ដែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ ។

១៦.៨.១០ ក្នុងកម្មវិធីមួយពេលនៃការបើកសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សាលើពាក្យបណ្ដឹង អាចកំណត់ធ្វើការជំនុំជម្រះ ឬប្រជុំសម្រេច ឬផ្សះផ្សាច្រើនករណីនៃបណ្ដឹងបាន ។

**ខ. ការជូនដំណឹងបើកសវនាការ ឬបើកអង្គប្រជុំសម្រេច ឬបើកអង្គប្រជុំផ្សះផ្សា**

១៦.៨.១១ គឃ/សប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំសម្រេច ឬ/និងប្រជុំផ្សះផ្សានៅថ្នាក់របស់ខ្លួនទៅតាមករណីនៃបណ្តឹងក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោត និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស និងត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំសម្រេច ឬប្រជុំផ្សះផ្សាដល់ភាគីបានទាន់ពេលវេលាយ៉ាងតិចម្ភៃបួន (២៤) ម៉ោង មុនពេលប្រជុំសម្រេច ឬប្រជុំផ្សះផ្សា ។

១៦.៨.១២ គធ/ខប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ដោះស្រាយបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់របស់ខ្លួនទៅតាមករណីនៃបណ្តឹងក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោត និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស និងត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការ ឬប្រជុំផ្សះផ្សាដល់ភាគីបានទាន់ពេលវេលាយ៉ាងតិច ម្ភៃបួន (២៤) ម៉ោង មុនពេលប្រជុំផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យដឹងពីកាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្តង ។

១៦.៨.១៣ គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃបណ្តឹងក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោត និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម នៃ គ.ជ.ប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការដល់ភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ ។

១៦.៨.១៤ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប និងសមាជិក ឬមន្ត្រីទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់មានភារកិច្ចស៊ើបអង្កេត និងរៀបចំសំណុំរឿងទាំងឡាយសម្រាប់សវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សានៅតាមថ្នាក់របស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយ ទាំងអង្គហេតុ អង្គច្បាប់ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ និងផ្តល់ប្រឹក្សាផ្នែកច្បាប់ជូនក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៅតាមថ្នាក់របស់ខ្លួន ។

១៦.៨.១៥ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ត្រូវមានវិធានការបណ្តុះបណ្តាលណែនាំសមាជិក ឬមន្ត្រីទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ដើម្បីបំពេញការងារជាសេនាធិការផ្នែកនេះឱ្យបានល្អនៅថ្នាក់របស់ខ្លួន ។

**ច. ការបង្ហាញខ្លួននៅពេលសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា**

១៦.៨.១៦ ប្រសិនបើភាគីដើមបណ្តឹងត្រូវបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះ មិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការ ឬថ្ងៃប្រជុំសម្រេចទេនោះ ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេចត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខ ដោយបញ្ជាក់ពីមូលហេតុលើសេចក្តីសម្រេច ។

១៦.៨.១៧ ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះ មិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេនោះ ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេច លើកបណ្តឹងចោល ដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង ។

១៦.៨.១៨ ប្រសិនបើភាគីដើមបណ្តឹងស្លាប់នោះក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា នៅតែបន្តនីតិវិធីរបស់ខ្លួនដដែល ។

១៦.៨.១៩ ប្រសិនបើភាគីចុងចម្លើយស្លាប់ មុនពេលបើកសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវលុបបណ្តឹងចេញពីបញ្ជី ។

១៦.៨.២០ ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃសវនាការ ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃប្រជុំផ្សះផ្សា ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៅតែបន្តនីតិវិធីរបស់ខ្លួនដដែល ។

១៦.៨.២១ ប្រសិនបើចុងចម្លើយមិនបានបង្ហាញខ្លួននាថ្ងៃសវនាការ ឬថ្ងៃប្រជុំសម្រេច ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេចត្រូវចាត់មន្ត្រីសវនាការ ឬលេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេចបញ្ជូនសម្រង់សេចក្តីសម្រេចទៅជូនចុងចម្លើយនៅអាសយដ្ឋានរបស់ចុងចម្លើយ ឬទីស្នាក់ការគណបក្សនយោបាយរបស់ចុងចម្លើយនោះ ។ ប្រសិនបើចុងចម្លើយបដិសេធមិនទទួលយកសម្រង់សេចក្តីសម្រេចនោះ ឬលេខាធិការសវនាការ ឬលេខាធិការ អង្គប្រជុំសម្រេចត្រូវចារលើសម្រង់សេចក្តីសម្រេចនោះ ដោយបញ្ជាក់អំពីការបដិសេធមិនទទួលយក រួចរក្សាទុកជាឯកសារ ហើយចាត់ទុកថា ចុងចម្លើយបានទទួលសម្រង់សេចក្តីសម្រេចនេះ ។

**ឆ. ការប្រកាសសេចក្តីសម្រេច**

១៦.៨.២២ ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច ត្រូវប្រកាសសេចក្តីសម្រេចភ្លាម បន្ទាប់ពីពិភាក្សាគ្នារួចរាល់ ។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះរឿង វិវាទដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែ មិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយបណ្តឹងឡើយ ។

១៦.៨.២៣ ការប្រកាសសេចក្តីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេចជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ ដើមនៃសេចក្តីសម្រេច ។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សា ប្រជុំសម្រេចអាចចាត់តាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះ ឬសមាជិកក្រុមប្រឹក្សាប្រជុំ សម្រេចណាម្នាក់អានជំនួសបាន ។

**ជ. ការប្រើប្រាស់ និងបំពេញសម្រង់សេចក្តីសម្រេច (ទ. ១២០៣)**

១៦.៨.២៤ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប និងក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ/សប ត្រូវធ្វើឡើងដោយ ផ្អែក តាមកំណត់ហេតុនៃសវនាការជំនុំជម្រះ ឬប្រជុំសម្រេច និងត្រូវចុះហត្ថលេខា ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ។ សេចក្តី សម្រេចនេះត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខា ដោយប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ និងលេខាធិការសវនាការ ឬដោយប្រធានក្រុមប្រឹក្សាប្រជុំ សម្រេច និងលេខាធិការអង្គប្រជុំសម្រេច ដោយត្រូវធ្វើឡើងតាមចំនួន និង កម្មវត្ថុនៃបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់ ។

១៦.៨.២៥ ការបំពេញទ.១២០៣ នៅថ្នាក់ គឃ/សប ត្រូវធ្វើជាបី (៣) ច្បាប់ សម្រាប់ ការប្តឹងតវ៉ា ឬបួន (៤) ច្បាប់ សម្រាប់ការប្តឹងជំទាស់ ដើម្បី ៖

១៦.៨.២៥.១ ផ្ញើជូនសាមីជនអ្នកប្តឹង ឬអ្នកតំណាង មួយ (១) ច្បាប់ ជា បន្ទាន់ ។

១៦.៨.២៥.២ ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬអ្នកតំណាង មួយ (១) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់ ។

១៦.៨.២៥.៣ ផ្ញើជូន គធ/ខប ពាក់ព័ន្ធ មួយ (១) ច្បាប់ ។

១៦.៨.២៥.៤ រក្សាទុកជាឯកសារ មួយ (១) ច្បាប់ ។

១៦.៨.២៦ ការបំពេញ ទ.១២០៣ នៅថ្នាក់ គធ/ខប ត្រូវធ្វើជាបី (៣) ច្បាប់ សម្រាប់ការប្តឹងតវ៉ា ឬបួន (៤) ច្បាប់ សម្រាប់ការប្តឹងជំទាស់ ដើម្បី ៖

១៦.៨.២៦.១ ផ្ញើជូនសាមីជនអ្នកប្តឹង ឬអ្នកតំណាង មួយ (១) ច្បាប់ ជាបន្ទាន់ ។

១៦.៨.២៦.២ ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬអ្នកតំណាង មួយ (១) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់ ។

១៦.៨.២៦.៣ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ។

១៦.៨.២៦.៤ រក្សាទុកជាឯកសារ មួយ (១) ច្បាប់ ។

១៦.៨.២៧ ការបំពេញ ទ.១២០៣ នៅ គ.ជ.ប ត្រូវធ្វើជាបី (៣) ច្បាប់ សម្រាប់ការប្តឹងតវ៉ា ឬបួន (៤) ច្បាប់ សម្រាប់ការប្តឹងជំទាស់ ដើម្បី ៖

១៦.៨.២៧.១ ជូនសាមីអ្នកប្តឹង ឬអ្នកតំណាង មួយ (១) ច្បាប់ ជាបន្ទាន់ ។

១៦.៨.២៧.២ ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬអ្នកតំណាង មួយ (១) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់ ។

១៦.៨.២៧.៣ ផ្ញើជូន គធ/ខប ពាក់ព័ន្ធ មួយ (១) ច្បាប់ ។

១៦.៨.២៧.៤ រក្សាទុកជាឯកសារ មួយ (១) ច្បាប់ ។

### ឈ. ទម្រង់ផ្សេងៗទៀតសម្រាប់សវនាការ ការប្រជុំសម្រេច និងការប្រជុំផ្សះផ្សា

១៦.៨.២៨ ទម្រង់ផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងសវនាការ ឬការប្រជុំសម្រេច ឬការប្រជុំផ្សះផ្សា ដែលបំពេញដោយ គ.ជ.ប ឬ គធ/ខប ឬ គឃ/សប មានជាអាទិ៍ ៖ លិខិតអញ្ជើញឱ្យចូលរួមសវនាការ ឬការប្រជុំសម្រេច ឬការប្រជុំផ្សះផ្សា និងកំណត់ហេតុសវនាការ ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុប្រជុំផ្សះផ្សា ។

១៦.៨.២៩ លិខិតអញ្ជើញឱ្យចូលរួមសវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា ត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវបានអញ្ជើញឱ្យចូលរួម សវនាការ ឬប្រជុំសម្រេច ឬប្រជុំផ្សះផ្សា រួចប្រគល់ជូនភាគីពាក់ព័ន្ធមួយ (១) ច្បាប់ៗ និងទុកជាឯកសារមួយ (១) ច្បាប់ ។

១៦.៨.៣០ កំណត់ហេតុប្រជុំផ្សះផ្សា ត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សាចំនួនមួយ (១) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងបណ្តឹង និងលទ្ធផលនៃការផ្សះផ្សា ។

១៦.៨.៣១ កំណត់ហេតុសវនាការ ឬប្រជុំសម្រេច ត្រូវបំពេញដោយលេខាធិការសវនាការ ឬលេខាធិការអង្គប្រជុំសម្រេច ចំនួនមួយ (១) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងបណ្តឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំសម្រេច។

## នីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងចំពោះគ្រប់អំពើល្មើសដែលអាចនាំឱ្យមានការផ្តន្ទាទោស

**ប្រការ ១៦.៩** ខ្លឹមសារក្រោមប្រការនេះកំណត់អំពីនីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយពាក្យបណ្តឹងចំពោះ គ្រប់អំពើល្មើសនឹងការបោះឆ្នោតដែលអាចនាំឱ្យមានការផ្តន្ទាទោសពិន័យជាប្រាក់ ឬ/និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងព្រមាន ឬ/និងបញ្ឈប់ពីការងារបោះឆ្នោត ដែលប្រព្រឹត្តដោយជនមិនមែនជាមន្ត្រីបោះឆ្នោត ឬ/និងគណបក្សនយោបាយ ឬ/និងជនដែលជាមន្ត្រីបោះឆ្នោតដែលបានរំលោភលើបញ្ញត្តិណាមួយនៃ ច.ប.ឃ.ស និង ប.ន.ឃ.ស និង បទបញ្ជាផ្ទៃក្នុង គ.ជ.ប ដែលអាចកើតឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

### ក. បណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

១៦.៩.១ ជនណាក៏ដោយ ឬអ្នកតំណាង មានសិទ្ធិដាក់ពាក្យបណ្តឹង ចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយតាមឋានានុក្រមទៅ គឃ/សប ឬ គធ/ខប ឬ គ.ជ.ប ក្នុងរយៈពេលបី (៣) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ឬបន្ទាប់ពីថ្ងៃផ្សះផ្សាមិនសះជារបស់ គឃ/សប ឬបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចលើបណ្តឹងរបស់ គធ/ខប លើកលែងតែមានកាលបរិច្ឆេទផ្សេងពីនេះ ។

១៦.៩.២ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុងចំណុច ១៦.៣.៥ នៃ ប.ន.ឃ.ស នេះ ។

### ក.១. នីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយពាក្យបណ្តឹងនៅ គឃ/សប

#### ក.១.១ ការដាក់/ទទួលពាក្យបណ្តឹង

១៦.៩.៣ អ្នកប្តឹង ឬអ្នកតំណាងត្រូវបំពេញ ទ.១២០២ ចំនួនបួន (៤) ច្បាប់ ។

១៦.៩.៤ នៅពេលបានទទួលពាក្យបណ្តឹង គឃ/សប ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់ មួយចំនួនជាអាទិ៍ ៖ ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង ទី២ កម្មវត្ថុនៃបណ្តឹង និងការគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ។

១៦.៩.៥ បន្ទាប់មក ប្រធាន គឃ/សប ត្រូវចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មឱ្យធ្វើកំណត់ហេតុសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬអ្នកតំណាង ដោយត្រូវកត់ត្រា រួចឱ្យអ្នកប្ដឹង ឬអ្នកតំណាងនោះផ្ដិតមេដៃលើកំណត់ហេតុ ។ ក្នុងករណីអ្នកប្ដឹង ឬអ្នកតំណាងមិនព្រមផ្ដិតមេដៃ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិមេដៃលើកំណត់ហេតុនេះ។

១៦.៩.៦ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងសួរកត់ត្រាក្នុងកំណត់ហេតុ ហើយឃើញថា ៖

១៦.៩.៦.១ កម្មវត្ថុនៃបណ្ដឹងមិនពាក់ព័ន្ធនឹងការល្មើស ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ ឬជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ ប្រធាន គឃ/សប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គឃ/សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នក ប្ដឹងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ និងផ្ញើជូន គធ/ខប ពាក់ព័ន្ធ មួយ (១) ច្បាប់ ។

១៦.៩.៦.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬអ្នកតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ ជាអាទិ៍ គឃ/សប ត្រូវណែនាំអ្នកប្ដឹង ឬអ្នកតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាក្នុងកំណត់ហេតុ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គឃ/សប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គឃ/សប និងចុះកាលបរិច្ឆេទ ។

១៦.៩.៦.៣ កម្មវត្ថុនៃបណ្ដឹងពាក់ព័ន្ធនឹងការល្មើសលើ ច.ប.ឃ.ស ឬ ប.ន.ឃ.ស និងពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (ចំពោះសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់) សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គឃ/សប

លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូនចុងចម្លើយមួយ (១) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សាមួយ (១) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈមួយ (១) ច្បាប់។

**ក.១.២ ការដោះស្រាយពាក្យបណ្ដឹង**

១៦.៩.៧ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងជាផ្លូវការហើយ គឃ/សប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើភាពអាចទទួលយកបាននៃបណ្ដឹង ។ ក្នុងករណី គឃ/សប ពិនិត្យ និងយល់ឃើញថា ពាក្យបណ្ដឹង ៖

១៦.៩.៧.១ គ្មានមូលដ្ឋានពាក់ព័ន្ធនឹងការល្មើសលើ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬពុំមានព័ត៌មានចាំបាច់ គឃ/សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គឃ/សប និងចុះកាលបរិច្ឆេទ ។

១៦.៩.៧.២ កម្មវត្ថុ និងមូលហេតុនៃបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងបទល្មើសបោះឆ្នោត គឃ/សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គឃ/សប និងចុះកាលបរិច្ឆេទ ។

១៦.៩.៧.៣ មានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គឃ/សប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ដែលអាចមានសមាសភាពដូចខាងក្រោម ៖

- ប្រធាន គឃ/សប ឬអ្នកតំណាង ជាប្រធានក្រុម
- សមាជិក គឃ/សប មួយ (១) នាក់ ជាសមាជិក
- សមាជិក គឃ/សប មួយ (១) នាក់ ជាលេខាធិការ ។

១៦.៩.៨ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងបណ្ដឹង ។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះអាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្ដឹងអមដំណើរជាមួយបើមានការ យល់ព្រមពីអ្នកប្ដឹង ។

១៦.៩.៩ បន្ទាប់ពីក្រុមត្រួតពិនិត្យស៊ើបអង្កេតចប់ ហើយលទ្ធផលពិនិត្យឃើញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់នោះ មិនបានប្រព្រឹត្តល្មើសពាក់ព័ន្ធទៅនឹងល្មើសលើ ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ គឃ/សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គឃ/សប និងចុះកាលបរិច្ឆេទ ។

១៦.៩.១០ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតឃើញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់បានប្រព្រឹត្តល្មើសនឹង ច.ប.ឃ.ស និង ប.ន.ឃ.ស គឃ/សប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គឃ/សប ។

១៦.៩.១១ គឃ/សប ត្រូវធ្វើកំណត់ហេតុនៃការផ្សះផ្សា ដោយឱ្យគូភាគី និងសាក្សីផ្ដិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ ។

១៦.៩.១១.១ ប្រសិនបើការផ្សះផ្សា ឈានទៅដល់ការព្រមព្រៀងគ្នារវាងភាគីមានទំនាស់ គឃ/សប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្ដិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គធ/ខប ។

១៦.៩.១១.២ ប្រសិនបើការផ្សះផ្សា មិនអាចឈានទៅដល់ការព្រមព្រៀងគ្នារវាងភាគីមានទំនាស់ទេ គឃ/សប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះ ឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ ។

១៦.៩.១២ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ/សប ត្រូវអនុវត្តតាមចំណុច ក ក្រោមប្រការ ១៦.២ នៃ ប.ន.ឃ.ស នេះ ។

## ក.២. នីតិវិធីដាក់/ទទួលពាក្យបណ្ដឹង និងដោះស្រាយពាក្យបណ្ដឹងនៅ គធ/ខប

### ក.២.១ ការដាក់/ទទួលពាក្យបណ្ដឹង

១៦.៩.១៣ ភាគីវិវាទ ឬអ្នកតំណាងដែលមិនសុខចិត្តនឹងការផ្សះផ្សារបស់ គឃ/សប ហើយដែលមានបំណងប្ដឹងទៅ គធ/ខប អាចប្ដឹងទៅ គធ/ខប ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃ គឃ/សប ផ្សះផ្សារួច ។ អ្នកប្ដឹង ឬអ្នកតំណាងត្រូវបំពេញ ទ.១២០២ ចំនួនបួន (៤) ច្បាប់ ។

១៦.៩.១៤ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុងចំណុច ១៦.៣.៥ នៃ ប.ន.ឃ.ស នេះ ។

១៦.៩.១៥ នៅពេលបានទទួលពាក្យបណ្តឹង គធ/ខប ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ៖ ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង ទី២ កម្មវត្ថុនៃបណ្តឹង និងការគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃផ្សះផ្សា ។

១៦.៩.១៦ បន្ទាប់មក ប្រធាន គធ/ខប ត្រូវចាត់ជំនួយការទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬមន្ត្រីដែលបានទទួលសិទ្ធិឱ្យធ្វើកំណត់ហេតុសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬអ្នកតំណាង ដោយត្រូវកត់ត្រា រួចឱ្យអ្នកប្តឹង ឬអ្នកតំណាងនោះផ្តិតមេដៃលើកំណត់ហេតុ ។ ក្នុងករណីអ្នកប្តឹង ឬអ្នកតំណាងមិនព្រមផ្តិតមេដៃ មន្ត្រីដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ ។

១៦.៩.១៧ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងសួរកត់ត្រាក្នុងកំណត់ហេតុ ហើយឃើញថា ៖

១៦.៩.១៧.១ កម្មវត្ថុនៃបណ្តឹងមិនពាក់ព័ន្ធនឹងការល្មើស ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃបន្ទាប់ពីថ្ងៃផ្សះផ្សាមិនសះជា ឬពាក្យបណ្តឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នានឹងគ្នារួចហើយនៅ គឃ/សប ប្រធាន គធ/ខប ឬមន្ត្រីដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ និងផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ។

១៦.៩.១៧.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង មិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ ជាអាទិ៍ គធ/ខប ត្រូវណែនាំអ្នកប្តឹង ឬអ្នកតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់

ហេតុ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គធ/ខប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបាន ។

១៦.៩.១៧.៣ កម្មវត្ថុនៃបណ្តឹងពាក់ព័ន្ធនឹងការល្មើសលើ ច.ប.ឃ.ស ឬ ប.ន.ឃ.ស និងពាក្យបណ្តឹងគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (ចំពោះសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់) ជំនួយការទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬមន្ត្រីដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ/ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹងមួយ (១) ច្បាប់ ផ្ញើជូនចុងចម្លើយ មួយ (១)ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សាមួយ (១)ច្បាប់ និងទុកបិទផ្សាយជាសាធារណៈមួយ (១) ច្បាប់។

**ក.២.២ ការដោះស្រាយពាក្យបណ្តឹង**

១៦.៩.១៨ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជាផ្លូវការហើយ គធ/ខប ត្រូវប្រជុំពិភាក្សា ដើម្បីពិនិត្យជាបន្ទាន់លើភាពអាចទទួលយកបាននៃបណ្តឹង ។ ក្នុងករណី គធ/ខប ពិនិត្យ និងយល់ឃើញថា ពាក្យបណ្តឹង ៖

១៦.៩.១៨.១ គ្មានមូលដ្ឋានពាក់ព័ន្ធនឹងការល្មើសលើ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬពុំមានព័ត៌មានចាំបាច់ គធ/ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ ។

១៦.៩.១៨.២ កម្មវត្ថុ និងមូលហេតុនៃបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ សុទ្ធសាធមិនពាក់ព័ន្ធទៅនឹងបទល្មើសបោះឆ្នោត គធ/ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ ។

១៦.៩.១៨.៣ មានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គធ/ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ដែលអាចមានសមាសភាពដូចខាងក្រោម ៖

- ប្រធាន គធ/ខប ឬអ្នកតំណាង ជាប្រធានក្រុម
- សមាជិក គធ/ខប មួយ (១) នាក់ ជាសមាជិក
- មន្ត្រីសេវាកម្មច្បាប់ និងវិវាទកម្ម មួយ (១) នាក់ ជាលេខាធិការ ។

១៦.៩.១៩ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងបណ្តឹង ។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះអាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹងអមដំណើរ ជាមួយបើមានការយល់ព្រមពីអ្នកប្តឹង ។

១៦.៩.២០ បន្ទាប់ពីក្រុមត្រួតពិនិត្យស៊ើបអង្កេតចប់ ហើយលទ្ធផលពិនិត្យឃើញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះ មិនបានប្រព្រឹត្តល្មើសពាក់ព័ន្ធទៅនឹងល្មើសលើ ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ គធ/ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ ។

១៦.៩.២១ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតឃើញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានប្រព្រឹត្តល្មើសនឹង ច.ប.ឃ.ស និង ប.ន.ព.ស គធ/ខប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គធ/ខប ។

១៦.៩.២២ គធ/ខប ត្រូវធ្វើកំណត់ហេតុនៃការផ្សះផ្សា ដោយឱ្យគូភាគី និងសាក្សីផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ ។

១៦.៩.២២.១ ប្រសិនបើការផ្សះផ្សា ឈានទៅដល់ការព្រមព្រៀងគ្នារវាងភាគីមានទំនាស់ គធ/ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប ។

១៦.៩.២២.២ ប្រសិនបើការផ្សះផ្សា មិនអាចឈានទៅដល់ការព្រមព្រៀងគ្នារវាងភាគីមានទំនាស់ទេ គធ/ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះ

ផ្សានោះ ឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ ។ គឃ/ខប ត្រូវកំណត់កាលបរិច្ឆេទបើកសវនាការជាសាធារណៈ មួយ (១) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា និងត្រូវជូនដំណឹង ភ្លាមនៅនឹងកន្លែងផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យដឹងពីកាលបរិច្ឆេទ និង ទីកន្លែងបើកសវនាការតែម្តង ។

១៦.៩.២៣ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ/ខប ត្រូវអនុវត្តតាមចំណុច ខ. ក្រោមប្រការ ១៦.២ នៃ ប.ន.ឃ.ស នេះ ។

**គ.៣. នីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប**

**គ.៣.១ ការដាក់/ទទួលពាក្យបណ្តឹង**

១៦.៩.២៤ ភាគីវិវាទ ឬអ្នកតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គឃ/ខប អាចប្តឹងបន្តទៅ គ.ជ.ប ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចរបស់ គឃ/ខប ។

១៦.៩.២៥ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវពិនិត្យឱ្យប្រាកដថាព័ត៌មានចាំបាច់មួយចំនួនត្រូវបានបំពេញក្នុងពាក្យបណ្តឹង ដូចមានចែងក្នុងចំណុច ១៦.៣.៥ នៃ ប.ន.ឃ.ស នេះ និងគោរពអំឡុងពេលកំណត់ ។

១៦.៩.២៦ ក្នុងករណីពាក្យបណ្តឹងពុំបានធ្វើឡើងក្នុងអំឡុងពេលកំណត់បី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គឃ/ខប អគ្គលេខាធិការនៃ គជប ត្រូវចារបដិសេធលើពាក្យបណ្តឹងនោះ ដោយបញ្ជាក់អំពីមូលហេតុ។

១៦.៩.២៧ មន្ត្រីស៊ើបអង្កេត ឬមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬអ្នកតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬអ្នកតំណាងផ្តិតមេដៃលើកំណត់ហេតុនោះ ។ ក្នុងករណីអ្នកប្តឹង ឬអ្នកតំណាង មិនព្រមផ្តិតមេដៃ មន្ត្រីដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ ។

១៦.៩.២៨ បន្ទាប់ពីបានទទួលពាក្យបណ្តឹង គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើភាពអាចទទួលយកបាននៃបណ្តឹង ជាអាទិ៍ ៖ អត្តសញ្ញាណនៃអ្នកប្តឹង លិខិតប្រគល់សិទ្ធិ កម្មវត្ថុនៃបណ្តឹង មូលដ្ឋានច្បាប់នៃបណ្តឹង ។

**គ.៣.២ ការដោះស្រាយពាក្យបណ្តឹង**

១៦.៩.២៩ ពាក្យបណ្តឹង ដែលគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវ ឬពុំមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ គ.ជ.ប ត្រូវពិនិត្យសម្រេច ហើយប្រគល់សិទ្ធិឱ្យអគ្គលេខាធិការធ្វើលិខិតជូនដំណឹងបដិសេធដោយបញ្ជាក់អំពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបាន។

១៦.៩.៣០ ប្រសិនបើពាក្យបណ្តឹងមានលក្ខខណ្ឌដូចមានចែងក្រោមចំណុច ១៦.៩.១៥ នៃ ប.ន.ឃ.ស នេះ គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ ។

១៦.៩.៣១ គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ ។

១៦.៩.៣២ បន្ទាប់ពីទទួលបានពាក្យបណ្តឹង និងក្រោយពីបានស្រាវជ្រាវស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកបណ្តឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថា ពាក្យបណ្តឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹងដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងស្រពេចស្រពិល មិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថាផ្ទុយពីការអះអាងក្នុងពាក្យបណ្តឹង ។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ធ្វើតាមរយៈលិខិតជូនដំណឹងបដិសេធតាមបែបបទរដ្ឋបាលក្នុងរយៈពេលសមស្របមួយទៅដើមបណ្តឹង ដើម្បីជូនជ្រាបថាបណ្តឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយទេ ។

១៦.៩.៣៣ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹង គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈដោះស្រាយបណ្តឹងតាមពេលវេលាសមគួរជាបន្ទាន់ ដោយត្រូវចាត់ចែងជូនដំណឹងទៅភាគីពាក់ព័ន្ធឱ្យដឹងពីកាលបរិច្ឆេទ និងទីកន្លែងបើកសវនាការ ។

១៦.៩.៣៤ គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធ ឬយល់ព្រម ឬបដិសេធមួយផ្នែកលើបណ្តឹងដោយចេញ ទ.១២០៣ ចំនួន បួន (៤) ច្បាប់ ។

១៦.៩.៣៥ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមចំណុច គ. ក្រោមប្រការ ១៦.២ នៃ ប.ន.ព.ស នេះ ។

**ខ. បណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត**

១៦.៩.៣៦ គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើល្មើសដែលបានល្មើសលើ ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ដែលប្តឹងមន្ត្រី ឬសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬមន្ត្រីនៅទីស្តីការ គ.ជ.ប ត្រូវដាក់ទៅគណៈកម្មការថ្នាក់លើមួយថ្នាក់ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ លើកលែងតែមានកាលបរិច្ឆេទកំណត់ផ្សេងពីនេះក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ។

១៦.៩.៣៧ បណ្តឹងពាក់ព័ន្ធនឹងសមាជិក គកប/គករ ដំបូងត្រូវប្តឹងទៅ គឃ/សប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១៦.៩.៣ រហូតដល់ចំណុច ១៦.៩.៣៥ ។

១៦.៩.៣៨ បណ្តឹងពាក់ព័ន្ធនឹងសមាជិក គឃ/សប ដំបូងត្រូវប្តឹងទៅ គធ/ខប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១៦.៩.១៣ រហូតដល់ចំណុច ១៦.៩.៣៥ ។

១៦.៩.៣៩ បណ្តឹងពាក់ព័ន្ធនឹងមន្ត្រីនៅ គធ/ខប ត្រូវប្តឹងទៅប្រធាន គធ/ខប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១៦.៩.១៣ រហូតដល់ចំណុច ១៦.៩.៣៥ ។

១៦.៩.៤០ បណ្តឹងពាក់ព័ន្ធនឹងសមាជិក គធ/ខប ត្រូវប្តឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១៦.៩.២៤ រហូតដល់ចំណុច ១៦.៩.៣៥ ។

១៦.៩.៤១ បណ្តឹងពាក់ព័ន្ធនឹងមន្ត្រីនៅទីស្តីការ គ.ជ.ប ត្រូវប្តឹងទៅប្រធាន គ.ជ.ប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១៦.៩.២៤ រហូតដល់ចំណុច ១៦.៩.៣៥ ។

១៦.៩.៤២ បណ្តឹងពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្តឹងទៅរដ្ឋសភាដោយអនុលោមតាម ច.ប.ត.រ ។

១៦.៩.៤៣ បណ្តឹងចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្តឹងដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ និងមិនព្រមដោះស្រាយបណ្តឹងដែលមន្ត្រីនោះបានទទួលពាក្យបណ្តឹងរួចហើយ ត្រូវដាក់ទៅគណៈកម្មការថ្នាក់លើមួយថ្នាក់ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ។ ក្នុងករណីដែល ៖

១៦.៩.៤៣.១ រកឃើញថា សមាជិក ឬមន្ត្រីនោះ ពិតជាបានប្រព្រឹត្តផ្ទុយនឹង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មស្របតាម ច.ប.ឃ.ស ។

១៦.៩.៤៣.២ រកឃើញថា សមាជិក ឬមន្ត្រីនោះ បានគោរពតាម ច.ប.ឃ.ស និង ប.ន.ឃ.ស ត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្តឹងនោះ ហើយពាក្យបណ្តឹងដែលត្រូវបានបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ ។

# ឧបសម្ព័ន្ធទី ១

# សម្រង់ខ្លឹមសារចេញពីជំពូកទី ៣ នៃបទបញ្ជា និងនីតិវិធី សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ការិយាល័យចុះឈ្មោះបោះឆ្នោត)

**ការកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត**

**ប្រការ ៣.១** គជប ត្រូវកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយ ឬ ច្រើនក្នុងឃុំ សង្កាត់នីមួយៗ នៅមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

៣.១.១ គជប ត្រូវធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន បានរួមចំណែកក្នុងការកែសំរួល និងលើកស្នើកំណត់ចំនួន និងទីតាំងថ្មីនៃការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ឱ្យបានសមស្រប ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សំរេចបានលទ្ធផលល្អ ។

៣.១.២ ការិយាល័យចុះឈ្មោះបោះឆ្នោតជាគោលការណ៍ គឺត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ ឬនៅទីតាំងណាមួយសមស្រប ហើយការិយាល័យចុះឈ្មោះបោះឆ្នោតផ្សេងទៀត ត្រូវមានទីតាំងនៅតាមភូមិមួយចំនួន ដែលមានចម្ងាយលើសពី ៥ គីឡូម៉ែត្រ ពីសាលាឃុំ សង្កាត់ ឬមានទីតាំងនៅភូមិសាស្ត្រស្មុគស្មាញដែលប្រជាពលរដ្ឋពិបាកធ្វើដំណើរមកចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ។

៣.១.២.១ ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំសង្កាត់ គឺជាការិយាល័យចុះឈ្មោះបោះឆ្នោតចំបង ដែលត្រូវបើកបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នៅពេលចាប់ផ្តើមនិងពេលបញ្ចប់ ដោយប្រើរយៈពេលប្រមាណមួយភាគពីរនៃរយៈពេលចុះឈ្មោះបោះឆ្នោតសរុប ។

៣.១.២.២ ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅតាមភូមិនានាក្រៅពីសាលាឃុំ សង្កាត់ ត្រូវបើកបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយប្រើពេលវេលាសរុបមិនឱ្យលើសពីមួយភាគពីរនៃរយៈពេលរួម ដែលបានកំណត់ឡើយ ។

៣.១.៣ ការិយាល័យចុះឈ្មោះបោះឆ្នោត គឺ ៖

- ជាការិយាល័យស្ថិតនៅមួយកន្លែង ដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ឬភូមិនានា ។
- ជាការិយាល័យចល័តបំរើការចុះឈ្មោះជូនប្រជាពលរដ្ឋ ដែលពុំមានឱកាសទៅចុះឈ្មោះបោះឆ្នោតបាន ដូចជាអ្នកជម្ងឺកំពុងសំរាកព្យាបាលនៅមន្ទីរពេទ្យ និងពិរុទ្ធជនកំពុងជាប់ក្នុងមន្ទីរឃុំឃាំង ដែលមានទីតាំងក្នុងឃុំ សង្កាត់ជាដើម ។ ក្នុងករណីចាំបាច់ ស្មៀនឃុំ សង្កាត់ និងអ្នករួមការងារដែលត្រូវបានតែងតាំងត្រូវបង្កលក្ខណៈងាយស្រួលចុះទៅជួបអ្នកសុំចុះឈ្មោះ ដែលមិនអាចមកចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យបាន ។

៣.១.៤ ការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវមានទីតាំងនៅទីកន្លែងណា ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតអាចធ្វើដំណើរទៅបាន ដោយគ្មានឧបសគ្គ ឬការរំខានអ្វីឡើយ ហើយប្រសិនបើអាចធ្វើបាន ត្រូវស្ថិតនៅជាន់ផ្ទាល់ដី ។

៣.១.៥ ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវបំរើការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋមានសិទ្ធិចុះឈ្មោះបោះឆ្នោតមកពីគ្រប់ភូមិ និងទីកន្លែងក្នុងព្រំប្រទល់ឃុំ សង្កាត់ ។

៣.១.៥.១ ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវបំរើឱ្យការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយផ្អែកលើបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ដែលបានផ្តល់សុពលភាពជាផ្លូវការចុងក្រោយដោយ គជប ។

៣.១.៥.២ ក្នុងករណីដែល គជប ធ្វើការកែសម្រួល ឬបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងឃុំ សង្កាត់ណាមួយ ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ក៏ត្រូវបំរើឱ្យការពិនិត្យបញ្ជីឈ្មោះ ឬ/និង ចុះឈ្មោះបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ទាំងមូល ។

(.......)

**ការផ្សព្វផ្សាយទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត**

**ប្រការ ៣.៣** គជប ត្រូវបោះពុម្ពផ្សាយនូវបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ហើយត្រូវកំណត់ និងផ្សព្វផ្សាយជាសាធារណៈអំពីកាលបរិច្ឆេទនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ នាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈនៃ

គជប ត្រូវអនុវត្តដោយផ្ទាល់ ឬ/និងសហការជាមួយអាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ និងសង្គមស៊ីវិល ក្នុងការផ្សព្វផ្សាយខ្លឹមសារខាងលើ ឱ្យបានយល់ជ្រួតជ្រាបដល់ប្រជាពលរដ្ឋទូទៅ ។

៣.៣.១ គជប ត្រូវបង្គាប់ទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាឃុំ សង្កាត់/ស្មៀន ឱ្យចម្លងនិងបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនិងការិយាល័យបោះឆ្នោត នៅសាលាឃុំ សង្កាត់ និងទីកន្លែងមួយចំនួន ឬនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ ក្នុងឃុំ សង្កាត់ យ៉ាងតិចដប់ ( ១០ ) ថ្ងៃមុនពេលចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៣.៣.២ គជប ត្រូវកំណត់រយៈពេល និងកាលបរិច្ឆេទសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់ទូទៅ និងកំណត់ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ក្នុងឃុំ សង្កាត់នីមួយៗ ( នៅសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួនដែលបានកំណត់ ) ក្នុងរយៈពេលយ៉ាងតិចបី(៣)ថ្ងៃ មុនពេលចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ។ គជប ត្រូវបង្គាប់មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាឃុំ សង្កាត់/ស្មៀន ឱ្យផ្សព្វផ្សាយជាសាធារណៈ អំពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិនខាងលើនេះ ចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងឃុំ សង្កាត់ និងខេត្ត ក្រុងរបស់ខ្លួន ។

៣.៣.៣ ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតគ្រប់រូប គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍ និងប្រព័ន្ធសារព័ត៌មាន មានសិទ្ធិស្នើសុំពី គជប នូវបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត នៃឃុំ សង្កាត់មួយ ឬច្រើន បន្ទាប់ពីពេលដែលបញ្ជីនេះ ត្រូវបានបោះពុម្ពផ្សាយដោយត្រូវបង់ថ្លៃត្រឹមថ្លៃផលិត ។ ការផ្គត់ផ្គង់ចំពោះការស្នើសុំខាងលើនេះ ត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់លំដោយនៃការស្នើសុំ ។ រាល់ការស្នើសុំតម្រូវឱ្យកក់ប្រាក់មុនស្មើនឹង ១០០ ភាគរយនៃតម្លៃផលិតផលស្នើសុំ ។

**ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យចុះឈ្មោះបោះឆ្នោត**

**ប្រការ ៣.៤** ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗដែលមានទីតាំងនៅតាមភូមិ ក្រៅពីសាលាឃុំ សង្កាត់ គឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ។

៣.៤.១ បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអាគារ ដែលការិយាល័យចុះឈ្មោះបោះឆ្នោតតាំងនៅ ហើយដែលខ័ណ្ឌដោយវ័ណ្ឌមណ្ឌលមួយ មានកាំប្រវែងយ៉ាងតិចដប់ប្រាំ ( ១៥ ) ម៉ែត្រ ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយ និងច្រកចូលមួយ ។

៣.៤.២ បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យចុះឈ្មោះបោះឆ្នោតដែលខ័ណ្ឌដោយវ័ណ្ឌមណ្ឌល មានកាំប្រវែងមួយរយ ( ១០០ ) ម៉ែត្រ ឬមានកាំតូចជាងស្រប តាមស្ថានភាពទីតាំងជាក់ស្តែងឬមានទម្រង់ផ្សេងពីនេះ ដូចជារបងខាងក្រៅបរិវេណនៃវត្តអារាម សាលារៀន សាលមហោស្រព ឬទីធ្លាសាធារណៈជាដើម ។

៣.៤.៣ នៅទីប្រជុំជន បរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដោយក្រុមប្រឹក្សាឃុំ សង្កាត់និងស្មៀន ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងតំបន់នោះ ដោយផ្ទាល់ ។

៣.៤.៤ ដោយអនុលោមទៅតាមចំណុច ៣.៤.៣ ខាងលើ បរិវេណសន្តិសុខត្រូវបានបង្កើតឡើងចំពោះតែតំបន់ទីប្រជុំជនណា ដែលមានបញ្ហាអសន្តិសុខ ដែលអាចរំខានដល់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប៉ុណ្ណោះ ។

**វិធានការការពារសន្តិសុខនៅការិយាល័យចុះឈ្មោះបោះឆ្នោត**

**ប្រការ ៣.៥** ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុង និងបរិវេណខាងក្រៅ នៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬ ការគំរាមកំហែង និងរក្សាការពារឧបករណ៍ សម្ភារៈទាំងអស់ក្នុងការិយាល័យទាំងនោះ គជប មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ/និង ស្មៀនដែលទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោត ត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម ៖

៣.៥.១ ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬសារជាតិ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត លើកលែងតែក្នុងករណីដែលមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត គជប មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់

ឬ/និង ស្មៀនមានភារកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៩ថ្មី និងមាត្រា ៥៥ថ្មី នៃច្បាប់បោះឆ្នោត ។

៣.៥.១.១ ប្រធាន គជប មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ឬ/និង ស្មៀន ត្រូវទំនាក់ទំនងស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ចំពោះករណីដូចដែលបានបញ្ជាក់ក្នុងចំណុច ៣.៥.១ ខាងលើ ។

៣.៥.១.២ ក្នុងករណីមានសំណូមពរពីស្មៀនឃុំ សង្កាត់ ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់និងរបៀបរៀបរយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយនោះ ភ្នាក់ងារសន្តិសុខដែលត្រូវបានបំពាក់អាវុធសមស្រប អាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធ ។

៣.៥.១.៣ គ្មាននាយ ឬពលនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និង កងនគរបាលជាតិណាម្នាក់អាចចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬ ឈរជិតបរិវេណការពារសន្តិសុខបានឡើយ ប្រសិនបើ ពួកគេមិនទៅចុះឈ្មោះបោះឆ្នោតទេនោះ លើកលែងតែពួកគេត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខ ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានស្មៀនឃុំ សង្កាត់ស្នើសុំឱ្យធ្វើអន្តរាគមន៍ ដូចចែងក្នុងប្រការ ៣.៥ និងលក្ខខណ្ឌទាំងឡាយក្រោមចំណុច ៣.៥.១ ខាងលើ ។

៣.៥.២ ហាមជនគ្រប់រូបចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត មុនពេលការិយាល័យចាប់ផ្តើមធ្វើការ ឬក្រោយពេលការិយាល័យបិទទ្វារ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គជប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម ៖

៣.៥.២.១ ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ដែលបានទទួលការតែងតាំងពី គជប ។

៣.៥.២.២ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រួតពិនិត្យមើលការងារស្មៀនឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៣.៥.២.៣ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មានមានប័ណ្ណសម្គាល់ ដែលផ្តល់ឱ្យដោយ គជប ។

៣.៥.២.៤ តំណាងគណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ ហើយដែលបានអនុញ្ញាត ។

៣.៥.២.៥ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងទៅចុះឈ្មោះ ហើយដែលមិនទាន់ចុះឈ្មោះបោះឆ្នោតនៅឡើយ ។

៣.៥.២.៦ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យណាមួយក្នុងឃុំ សង្កាត់រួចហើយ ប៉ុន្តែមានបំណងសុំពិនិត្យបញ្ជីឈ្មោះ សុំកែតម្រូវឈ្មោះ ឬទិន្នន័យពាក់ព័ន្ធ ដែលសរសេរខុស ។

៣.៥.២.៧ នីតិជនអមដំណើរអ្នកសុំចុះឈ្មោះដែលជាជនពិការ ដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតបានដោយខ្លួនឯង ។

៣.៥.២.៨ ភ្នាក់ងារសន្តិសុខនិងភ្នាក់ងារសង្គ្រោះនៅពេលដែលស្មៀនឃុំ សង្កាត់សំណូមពរក្នុងករណីចាំបាច់ ។

៣.៥.៣ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

៣.៥.៣.១ ការស្លៀកពាក់ ឬការបិទផ្សាយ ឬការនិយាយដែលមានការពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

៣.៥.៣.២ ការបង្ហាញការគាំទ្រ ឬការប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

៣.៥.៣.៣ ការរំខានអុកឡុក ឬសកម្មភាពផ្សេងៗ ដែលអាចមានឥទ្ធិពលដល់ជនណាម្នាក់ក្នុងការចុះឈ្មោះបោះឆ្នោត ។

៣.៥.៤ ក្នុងករណីចាំបាច់ គជប មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ/និង ស្មៀន ដែលទទួលខុសត្រូវការិយាល័យចុះឈ្មោះបោះឆ្នោត អាចអនុវត្តនូវល័ក្ខខ័ណ្ឌពាក់ព័ន្ធទាំងឡាយ ដែលបានចែងក្រោមចំណុច ៣.៥.២ ចំពោះបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

៣.៥.៥ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ គជប មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីចុះឈ្មោះបោះឆ្នោត ស្របតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គជប ។

**ប្រការ** ៣.៦ សាលារៀន ទីវត្តអារាម និងរាល់សំណង់ អាគារ សាល និងទីធ្លាសាធារណៈ ត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គជប សម្រាប់គោលបំណងនៃការរៀបចំជាការិយាល័យចុះឈ្មោះបោះឆ្នោតបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

# ឧបសម្ព័ន្ធទី ២
# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំត្រៀមបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងមាត្រា ៤៩ថ្មី មាត្រា ៥៣ថ្មី និងមាត្រា ៥៤ថ្មី នៃច្បាប់វិសោធនកម្ម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចអោយទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសំរេចលេខ ១២-០៩៦/០២ គជប ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០២ របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមធ្វើការណែនាំដល់អភិបាលខេត្ត ក្រុង ប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត និងអភិបាលស្រុក ខណ្ឌ ត្រូវជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ និងត្រូវសហការ ឬចាត់ចែងអនុវត្តការងារតាមឋានានុក្រម និងភារកិច្ចរៀងខ្លួន ដើម្បីធានាអោយការរៀបចំត្រៀមបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជារៀងរាល់ឆ្នាំដំណើរការទៅបានល្អប្រសើរ ។

លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវសហការ និងសំរបសំរួលដោយផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ក្នុងការអនុវត្តការងាររៀបចំត្រៀមបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ត្រូវតែដឹងថាការងាររៀបចំត្រៀម និងការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

គឺជាមុខងារជាភ្នាក់ងាររបស់ឃុំ សង្កាត់ ដែលឃុំ សង្កាត់ត្រូវអនុវត្តតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានផ្សេងៗ ហើយឃុំ សង្កាត់ត្រូវអនុវត្តជាប្រចាំរៀងរាល់ឆ្នាំ ។

ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ត្រូវចាត់ចែងអនុវត្តការងារតាមខ្លឹមសារ ដូចខាងក្រោម ៖

១- ត្រូវទំនាក់ទំនងសហការជាមួយប៉ូលីសប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ និងប្រធានភូមិដើម្បីបំពេញស្ថិតិថ្មីបំផុត និងកែតម្រូវអក្ខរាវិរុទ្ធក្នុងតារាងស្រង់ស្ថិតិប្រជាពលរដ្ឋ ដែលផ្តល់ដោយ គ.ជ.ប សំរាប់បំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជារៀងរាល់ឆ្នាំ ដោយអនុវត្តតាមការណែនាំ ដូចខាងក្រោម ៖

១.១. ខ្ទង់ឈ្មោះភូមិ ទីតាំងការិយាល័យបោះឆ្នោត និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត :

- ត្រូវពិនិត្យ និងកែតម្រូវអក្ខរាវិរុទ្ធ អោយបានត្រឹមត្រូវតាមឈ្មោះភូមិ ឬទីតាំងការិយាល័យបោះឆ្នោត ឬទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ដែលប្រើប្រាស់ជាផ្លូវការ ( ករណីសំណៅដើមមានកំហុសអក្ខរាវិរុទ្ធ ) ។
- ករណីឃុំ សង្កាត់ មានភូមិទើបនឹងបង្កើតថ្មី តាមប្រកាសរបស់ក្រសួងមហាផ្ទៃត្រូវសរសេរឈ្មោះភូមិថ្មីនោះ និងបំពេញទិន្នន័យស្ថិតិតាមខ្ទង់នានាដូចភូមិដទៃទៀត នៅផ្នែកខាងក្រោមនៃតារាង ។ ប្រសិនបើភូមិទើបនឹងបង្កើតថ្មីជាឧបសម្ព័ន្ធរបស់ភូមិណាមួយ និងមានទីតាំងស្ថិតនៅក្បែរភូមិនោះ ត្រូវគូស សញ្ញាព្រួញភ្ជាប់ទៅចំណុចខាងក្រោមឈ្មោះភូមិពាក់ព័ន្ធ ( សូមមើលឧទាហរណ៍នៅក្នុងឧបសម្ព័ន្ធទី ១ ) ។

១.២. ខ្ទង់ប្រជាពលរដ្ឋរួម :

- ត្រូវបំពេញចំនួនប្រជាពលរដ្ឋសរុប គឺទាំងចាស់ ទាំងក្មេង ទាំងប្រុស ទាំងស្រី ដោយគិតរួមទាំងព្រះសង្ឃ និងដូនជីផង ។

១.៣. ខ្ទង់ប្រជាពលរដ្ឋអាយុ ១៨ ឡើង ( បំបែកជាពីរខ្ទង់ ) :

- **សរុប :** ត្រូវបំពេញចំនួនប្រជាពលរដ្ឋសរុប (ទាំងស្រី ទាំងប្រុស ទាំងព្រះសង្ឃ និងដូនជី ) ដែលមានអាយុ ១៨ ឆ្នាំឡើង ( គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត) ។
- **ស្រី :** ត្រូវបំពេញចំនួនប្រជាពលរដ្ឋភេទស្រី អាយុ ១៨ ឆ្នាំឡើង ( គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ) ដោយគិតរួមទាំងដូនជីផង ។

១.៤. ខ្ទង់ប្រជាពលរដ្ឋអាយុ ១៨ឡើងក្រោយបច្ចុប្បន្នភាពចុងក្រោយ( បំបែកជាបួនខ្ទង់) :

- **ផ្លាស់ចូល :** ត្រូវបំពេញចំនួនប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតចាប់ពីអាយុ ១៨ ឆ្នាំឡើង គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត (ទោះបីមាន ឬគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយក្តី ) ដែលបានផ្លាស់ទីលំនៅចូលមកពីភូមិ ឬឃុំ សង្កាត់ដទៃ ។
- **ផ្លាស់ចេញ :** ត្រូវបំពេញចំនួនប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតចាប់ពីអាយុ ១៨ ឆ្នាំឡើង គិតត្រឹម ថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលបានផ្លាស់ទីលំនៅចេញទៅភូមិ ឬឃុំ សង្កាត់ដទៃ ។
- **ដកសិទ្ធិ :** ត្រូវបំពេញចំនួនអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ។
- **ស្លាប់ :** ត្រូវបំពេញចំនួនប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ដែលបានស្លាប់ដោយគិតបញ្ចូលទាំងចំនួនអ្នកស្លាប់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយដែលខកខានពុំទាន់បានលុបចេញក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតចុងក្រោយ ។

១.៥. បន្ទាប់ពីកែតម្រូវអក្ខរាវិរុទ្ធ និងបំពេញតួលេខស្ថិតិគ្រប់ភូមិក្នុងឃុំ សង្កាត់រួចហើយ ត្រូវបូកសរុបស្ថិតិតាមខ្ទង់នីមួយៗ និងបំពេញតួលេខស្ថិតិសរុបរបស់ឃុំ សង្កាត់ នៅខាងក្រោមអោយបានត្រឹមត្រូវ ។

១.៦. ប្រសិនបើផ្អែកលើភាពចាំបាច់ជាក់ស្តែងដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់យល់ថាតម្រូវអោយមានការផ្លាស់ប្តូរទីតាំងការិយាល័យបោះឆ្នោតមួយចំនួន ឬស្នើសុំបន្ថែមទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត នៅតាមភូមិមួយចំនួនទៀត ស្មៀនឃុំ សង្កាត់ត្រូវធ្វើសំណើដោយឡែកមក គ.ជ.ប ដោយមានការបញ្ជាក់ឯកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

១.៧. ក្រោយពីបំពេញតារាងស្រង់ស្ថិតិប្រជាពលរដ្ឋបានត្រឹមត្រូវរួចហើយ ស្មៀនឃុំ សង្កាត់ ត្រូវចុះហត្ថលេខា និងឈ្មោះ រួចដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យបញ្ជាក់ បន្ទាប់មកត្រូវបញ្ជូនតារាងស្រង់ស្ថិតិនេះ ដោយភ្ជាប់មកជាមួយនូវសំណើដោយឡែកដូចបញ្ជាក់ក្នុងចំណុច ១.៦ ខាងលើ (ប្រសិនបើមាន) មកលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតអោយបានមុនកាលបរិច្ឆេទចុងក្រោយថ្ងៃទី ១៥ ខែ កក្កដា នៃឆ្នាំនីមួយៗ ដើម្បីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត បូកសរុប និងបញ្ជូនមក គ.ជ.ប ។

២- ត្រូវរក្សាទុកអោយបានល្អនូវសៀវភៅបញ្ជីបោះឆ្នោតអចិន្ត្រៃយ៍របស់ឃុំ សង្កាត់ និងត្រូវត្រួតពិនិត្យឡើងវិញជាបណ្តើរៗ និងជាប្រចាំ ដើម្បីត្រៀមលក្ខណសម្បត្តិធ្វើសុក្រឹតភាពបញ្ជីបោះឆ្នោត ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ **ក្នុងនោះត្រូវយកចិត្តទុកដាក់ស្រង់ឈ្មោះប្រជាពលរដ្ឋតាមប្រភេទកំណត់បញ្ចូលទៅក្នុងទម្រង់បែបបទដោយឡែកពីគ្នា តាមគំរូផ្តល់ដោយ គ.ជ.ប ដោយចាប់អនុវត្តចាប់តាំងពីដើមឆ្នាំតទៅ ។**

២.១. ស្រង់បញ្ចូលក្នុងទម្រង់លេខ១០២៥ នូវឈ្មោះអ្នកបោះឆ្នោតស្លាប់ ផ្លាស់ចេញ ដកហូតសិទ្ធិបោះឆ្នោត និងគ្មានទីលំនៅក្នុងឃុំ សង្កាត់ ដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ ស្មៀនឃុំ សង្កាត់ត្រូវស្រង់បញ្ចូលក្នុងបញ្ជីដោយឡែកនេះនូវអ្នកបោះឆ្នោត ដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់មានភស្តុតាងច្បាស់លាស់ថា :

- បានទទួលមរណភាពមុន ឬក្រោយការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ដែលពុំទាន់បានលុប ឈ្មោះចេញពីបញ្ជីបោះឆ្នោតចុងក្រោយ
- បានផ្លាស់ទីលំនៅចេញទៅឃុំ សង្កាត់ផ្សេង
- ត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត
- ពុំមែនជាប្រជាពលរដ្ឋមានទីលំនៅអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ននៅក្នុង ឃុំ សង្កាត់ ។

២.២. ស្រង់បញ្ចូលក្នុងទម្រង់លេខ ១០២៦ នូវឈ្មោះអ្នកបោះឆ្នោត ដែលមានឈ្មោះស្ទួន ហើយនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតចុងក្រោយក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ដោយរក្សាទុកឈ្មោះអ្នកបោះឆ្នោតម្នាក់ៗតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់ ។ ក្នុងករណី គ.ជ.ប បានផ្តល់បញ្ជីអ្នកបោះឆ្នោតស្ទួនដែលមានឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើតដូចគ្នា ដោយសារតែគាត់បានចុះឈ្មោះបោះឆ្នោតពីរ ឬច្រើនដង ត្រូវអនុវត្ត ដូចខាងក្រោម ៖

**ក-** ចំពោះអ្នកបោះឆ្នោតដែលមានឈ្មោះដូចគ្នាពីរ ឬច្រើន និងមានទិន្នន័យពាក់ព័ន្ធដូចគ្នា ដែលស្ថិតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យតែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់ តែមួយ ត្រូវស្រាវជ្រាវដើម្បីអោយដឹងប្រាកដថា អ្នកបោះឆ្នោតនោះជាមនុស្សតែម្នាក់ ឬជាមនុស្សពីរនាក់ ឬច្រើននាក់ផ្សេងគ្នា :

- ក្នុងករណីជាមនុស្សពីរនាក់ ឬច្រើននាក់ផ្សេងគ្នា ត្រូវកត់ត្រាលំអិតនូវទិន្នន័យពាក់ព័ន្ធ ដែលមានលក្ខណៈផ្សេងគ្នានៃអ្នកបោះឆ្នោតទាំងនោះ នៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ។
- ក្នុងករណីជាមនុស្សតែម្នាក់ ត្រូវទាក់ទងប្រាប់អ្នកបោះឆ្នោតនោះថា ផ្អែកតាមច្បាប់គាត់មានសិទ្ធិចុះឈ្មោះ និងមានឈ្មោះតែមួយនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យតែមួយគត់ក្នុងឃុំ សង្កាត់ហើយត្រូវអោយគាត់ធ្វើលិខិតផ្តិតមេដៃប្រកាសអំពីការិយាល័យដែលគាត់ចង់រក្សាទុកឈ្មោះ និងការិយាល័យដែលត្រូវលុបឈ្មោះចេញ ។ ស្មៀនឃុំ សង្កាត់ ត្រូវស្រង់ឈ្មោះរបស់គាត់ និងលេខកូដការិយាល័យដែលត្រូវលុបចេញ និងដែលត្រូវរក្សាទុកនៅក្នុងបញ្ជីអ្នកបោះឆ្នោតមានឈ្មោះស្ទួន ត្រៀមសំរាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

ខ- ចំពោះអ្នកបោះឆ្នោត ទោះបីជាមិនមានឈ្មោះដូចគ្នាពីរ ឬច្រើនតាមការិយាល័យក្នុងឃុំ សង្កាត់តែមួយ ប៉ុន្តែអ្នកបោះឆ្នោតទាំងនោះមានឈ្មោះដូចគ្នាពីរ ឬច្រើនស្ទួនគ្នាជាមួយនឹងការិយាល័យនៃឃុំ សង្កាត់ផ្សេងក្នុងខេត្ត ក្រុង ។ ផ្អែកលើការសំរបសំរួលរបស់លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវស្រាវជ្រាវដើម្បីឱ្យដឹងប្រាកដ និងត្រូវអនុវត្តទៅតាមករណីនីមួយៗ ដូចខាងក្រោម ៖

- ក្នុងករណីជា មនុស្សពីរនាក់ ឬច្រើននាក់ផ្សេងគ្នានៅឃុំ សង្កាត់ផ្សេងគ្នា ត្រូវកត់ត្រាអោយបានច្បាស់លាស់ និងលំអិតនូវទិន្នន័យពាក់ព័ន្ធនឹងអ្នកបោះឆ្នោតនោះ ក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ។
- ក្នុងករណីជា មនុស្សតែម្នាក់ដែលបានផ្លាស់ប្តូរទីលំនៅទៅឃុំ សង្កាត់ផ្សេង ត្រូវស្រង់ឈ្មោះរបស់គាត់ដាក់ទៅក្នុងបញ្ជីអ្នកបោះឆ្នោតដែល

មានឈ្មោះស្ទួន ដែលនឹងត្រូវលុបចេញក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ ករណីនេះ ស្មៀនឃុំ សង្កាត់ ត្រូវមានលិខិតបញ្ជាក់ការផ្លាស់ទីលំនៅចេញរបស់អ្នកបោះឆ្នោតនោះជាសំអាង ។

- ក្នុងករណីជាមនុស្សតែម្នាក់ដែលបានចុះឈ្មោះ និងមានឈ្មោះពីរ ឬច្រើនក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់ផ្សេងគ្នា ត្រូវទាក់ទងប្រាប់អ្នកបោះឆ្នោតដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នោះថា ផ្អែកតាមច្បាប់ គាត់មានសិទ្ធិចុះឈ្មោះ និងមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យតែមួយគត់ក្នុងឃុំ សង្កាត់តែមួយគត់ និងត្រូវអោយគាត់ធ្វើលិខិតផ្តិតមេដៃប្រកាសអំពីការិយាល័យនៃឃុំ សង្កាត់ផ្សេងដែលគាត់ត្រូវលុបឈ្មោះចេញ រួចផ្ញើជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

២.៣. ស្រង់បញ្ចូលក្នុងទម្រង់លេខ ១០២៧ នូវឈ្មោះប្រជាពលរដ្ឋដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត

ដើម្បីអញ្ជើញប្រជាពលរដ្ឋទាំងនោះមកបំពេញទម្រង់បែបបទលេខ ១០២៤ ត្រៀមចុះឈ្មោះបោះឆ្នោតនៅ ពេលណាមួយក្នុងចន្លោះ ពីថ្ងៃទី ០១ ខែ មករា រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា នៃឆ្នាំនីមួយៗ ។ ប្រជាពលរដ្ឋដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតរួមមាន ៖

- ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតដែលបានផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ក្រោយការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតចុងក្រោយ
- ប្រជាពលរដ្ឋទើបគ្រប់អាយុបោះឆ្នោត ( គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ) ។

៣- ផ្អែកលើបញ្ជីរាយឈ្មោះអ្នកមានសិទ្ធិបោះឆ្នោត ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ២.៣ ខាងលើ ត្រូវអញ្ជើញប្រជាពលរដ្ឋទាំងនោះមកជួបស្មៀនឃុំ សង្កាត់ ដើម្បីបំពេញទម្រង់បែបបទត្រៀមចុះឈ្មោះបោះឆ្នោត ដោយយកមកជាមួយនូវឯកសារបញ្ជាក់លក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោត ។ សាមីខ្លួនអាចមកបំពេញទម្រង់បែបបទត្រៀមចុះឈ្មោះបោះឆ្នោតនៅពេលវេលាណាមួយសមស្រប ក្នុងចន្លោះចាប់ពីថ្ងៃទី ០១ ខែ មករា រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ជារៀងរាល់ឆ្នាំ ។ ក្នុងករណីនេះ អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវមកជួបស្មៀនម្តងទៀត នៅការិយាល័យចុះឈ្មោះបោះឆ្នោត ( សាលាឃុំ សង្កាត់ ឬតាមភូមិក្នុងឃុំ សង្កាត់ ដែលបានកំណត់ជាមុន ) ដើម្បីបញ្ចប់ការចុះឈ្មោះបោះឆ្នោតរបស់ខ្លួនជាផ្លូវការក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមច្បាប់កំណត់ និងប្រតិទិនការងាររបស់ គ.ជ.ប ដែលចាប់ផ្តើមនៅថ្ងៃទី ០១ ខែ តុលា ។

៣.១. អ្នកមានសិទ្ធិបោះឆ្នោតដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតគ្រប់រូប ( អ្នកមិនធ្លាប់បានចុះឈ្មោះ អ្នកទើបគ្រប់អាយុ និងអ្នកផ្លាស់ចូល ) ទោះបីមាន ឬគ្មានការអញ្ជើញក្តីអាចមកជួបស្មៀនឃុំ សង្កាត់ដើម្បីបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃស្តាំ លើទម្រង់បែបបទត្រៀមចុះឈ្មោះបោះឆ្នោតដែលផ្តល់ដោយ គ.ជ.ប ។ ស្មៀនឃុំ សង្កាត់ត្រូវគូសសំគាល់ពីក្រោមឯកសារបញ្ជាក់លក្ខខណ្ឌសំរាប់ចុះឈ្មោះបោះឆ្នោត ដែលអ្នកសុំចុះឈ្មោះបានបង្ហាញ និងគូសសញ្ញាក្នុងប្រអប់ពាក់ព័ន្ធ ព្រមទាំងផ្តល់យោបល់បញ្ជាក់លើការបំពេញលក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោតបានគ្រប់គ្រាន់ហើយឬនៅ និងបញ្ជាក់ឯកសារដែលត្រូវយកមកបង្ហាញបន្ថែម ក្នុងករណីមិនគ្រប់លក្ខខណ្ឌ ។ ស្មៀនឃុំ សង្កាត់ត្រូវបំពេញ និងផ្តល់យោបល់បញ្ជាក់នៅលើទម្រង់បែបបទទាំងមូល គិតទាំងផ្នែកចុងសន្លឹកផង រួចចុះហត្ថលេខា បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងហែកផ្នែកចុងសន្លឹកជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ។ ស្មៀនឃុំ សង្កាត់ ត្រូវរក្សាទុកផ្នែកគល់បញ្ជីនៃទម្រង់នេះជាឯកសារ ។

៣.២. នៅពេលប្រគល់ចុងសន្លឹកទម្រង់បែបបទត្រៀមចុះឈ្មោះបោះឆ្នោត ត្រូវណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោត អោយត្រឡប់មកបញ្ចប់ការចុះឈ្មោះបោះឆ្នោតជាផ្លូវការរបស់គាត់នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមច្បាប់កំណត់ និងប្រតិទិនការងាររបស់ គ.ជ.ប ដែលត្រូវចាប់ផ្តើមនៅថ្ងៃទី ០១ ខែ តុលា ។ ក្នុងករណីឯកសារដែលគាត់បានបង្ហាញលើកនេះមិនទាន់ឆ្លើយតបគ្រប់គ្រាន់ទៅនឹងលក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោត ត្រូវណែនាំគាត់អោយរកបន្ថែម និងយកមកជាមួយនូវឯកសារបញ្ជាក់លក្ខខណ្ឌដែលខ្វះនៅពេលគាត់មកបញ្ចប់ការចុះឈ្មោះបោះឆ្នោតរបស់គាត់ជាផ្លូវការ ។

៣.៣. ការអញ្ជើញមកបញ្ចប់ការចុះឈ្មោះបោះឆ្នោតជាផ្លូវការរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ត្រូវប្រព្រឹត្តទៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលរាល់នីតិវិធីសំរាប់ការចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តតាមការកំណត់ក្នុងសៀវភៅណែនាំ សំរាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

អភិបាលខេត្ត ក្រុង ប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត អភិបាលស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់អនុវត្តសេចក្តីណែនាំនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃហត្ថលេខាតទៅ ។

# ឧបសម្ព័ន្ធទី ៣
# សេចក្តីណែនាំរួម
# ស្តីពី
# ការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

យោងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរឹមជ្ឈការអំណាច តួនាទី និងភារកិច្ចឱ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់ និងសេចក្តីសំរេចលេខ ១២-០៩៦/០២ គ.ជ.ប ស្តីពីការផ្ទេរប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមណែនាំដល់អភិបាលខេត្ត ក្រុង គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប) អភិបាលស្រុក ខណ្ឌ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ត្រូវសហការ ឬ/និងចាត់ចែងអនុវត្តការងារតាមឋានានុក្រម និងភារកិច្ចរៀងខ្លួន ដើម្បីធានាឱ្យការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នៅមុនការបោះឆ្នោតនានាដែលបានកំណត់ដោយច្បាប់ ដំណើរការទៅប្រកបដោយរលូន និងទទួលបានលទ្ធផលល្អប្រសើរ តាមខ្លឹមសារដូចខាងក្រោម ៖

## I. គោលបំណង

ការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត មានគោលបំណងដូចខាងក្រោម ៖

**១-** ជួយដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការបានយល់ដឹងច្បាស់ អំពីលេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត លេខកូដ និងទីតាំងការិយាល័យបោះឆ្នោត កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ព្រមទាំងប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការនានា ដែលត្រូវប្រើនៅពេលបោះឆ្នោត

**២-** ជួយដល់អ្នកបោះឆ្នោតអាចរកឃើញយ៉ាងងាយស្រួលនូវទីតាំងការិយាល័យបោះឆ្នោត ដែលសាមីខ្លួនត្រូវទៅបោះឆ្នោត

**៣-** ជួយដល់គណៈកម្មការការិយាល័យបោះឆ្នោត ក្នុងការស្វែងរកឱ្យឃើញឈ្មោះសាមីអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតបានឆាប់រហ័ស ដែលបង្កភាពងាយស្រួលដល់កិច្ចប្រតិបត្តិការបោះឆ្នោតឱ្យកាន់តែមានភាពរលូន និងមិនឱ្យអ្នកបោះឆ្នោតរង់ចាំយូរ ។

## II. ខ្លឹមសារប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

បណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវបានផលិតតាមលក្ខណៈបច្ចេកទេសកុំព្យូទ័រ ដោយការផ្ទេរឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោតពីបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។ ប័ណ្ណព័ត៌មាននេះ ត្រូវបានបោះពុម្ពទាំងសងខាង លើក្រដាសសធម្មតា ។

ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត មានខ្លឹមសារសំខាន់៧ដូចខាងក្រោម ៖

- រូបសញ្ញា គ.ជ.ប និងអក្សរគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោតសកលពាក់ព័ន្ធ
- ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋាននៃអ្នកបោះឆ្នោត លេខរៀងអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត លេខកូដ និងទីតាំងការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឈ្មោះឃុំ សង្កាត់ និងឈ្មោះខេត្ត ក្រុង
- កំណត់សំគាល់ថា " ប័ណ្ណព័ត៌មាននេះ មិនអាចប្រើជំនួសឯកសារបញ្ជាក់អត្តសញ្ញាណសាមីខ្លួនបានឡើយ "
- ប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការនានា ដែលសាមីខ្លួនអ្នកបោះឆ្នោតអាចប្រើប្រាស់ឯកសារណាមួយក៏បាននៅពេលបោះឆ្នោត
- សញ្ញាសំគាល់ និងព័ត៌មានផ្សេងទៀត ។

## III. ការអនុវត្តការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

នៅពេលទទួលបានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត មន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវ ដូចខាងក្រោម ៖

### ១- គខ/គប ត្រូវបំពេញការងារ :

- ទំនាក់ទំនងសហការជាមួយអភិបាលខេត្ត ក្រុង និងអភិបាលស្រុក ខណ្ឌពាក់ព័ន្ធ ដើម្បីផ្តល់ការគាំទ្រចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិឱ្យសហការជាមួយ គឃ/សប ក្នុងការអនុវត្តការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

- ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីស្នើចាត់បញ្ជូនតំណាងអង្គការទាំងនោះទៅក្នុងក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅតាមឃុំ សង្កាត់

- ចាត់ចែងការផ្សព្វផ្សាយសេចក្តីណែនាំរួមស្តីពីការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងខ្លឹមសារបច្ចេកទេសនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ជូន គឃ/សប ក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងអង្គការមិនមែនរដ្ឋាភិបាល មេភូមិពាក់ព័ន្ធ និងតំណាងគណបក្សនយោបាយ

- ប្រគល់សៀវភៅប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ជូន គឃ/សប ដែលមានភារកិច្ចទទួលខុសត្រូវរួម ក្នុងការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

- ត្រួតពិនិត្យនូវរាល់សកម្មភាពរបស់ក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងជួយសំរួលដោះស្រាយរាល់បញ្ហាដែលអាចកើតមានជាយថាហេតុ ។

## ២- គឃ/សប ត្រូវបំពេញការងារ :

- រៀបចំ និងតែងតាំងក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត តាមការចាំបាច់ និងមានសមាសភាពដូចខាងក្រោម ៖

ក. សមាជិក គឃ/សប ១រូប ជាប្រធាន

ខ. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មួយ ឬច្រើនរូប ជាសមាជិក

គ. តំណាងអង្គការមិនមែនរដ្ឋាភិបាលមួយ ឬច្រើនរូប ជាសមាជិក ( ប្រសិនបើមាន)

ឃ. មេភូមិពាក់ព័ន្ធ ជាសមាជិក ។

- ផ្សព្វផ្សាយដល់ក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងដល់តំណាងគណបក្សនយោបាយអំពីសេចក្តីណែនាំរួមនេះ ខ្លឹមសារបច្ចេកទេសនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ព្រមទាំងសារប្រយោជន៍នៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងខ្លឹមសារដែលត្រូវបន្តផ្សព្វផ្សាយជូនប្រជាពលរដ្ឋ

- សហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ក្នុងការកំណត់ប្រតិទិនសំរាប់ចុះចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នៅតាមភូមិនានាក្នុងឃុំ សង្កាត់

- ផ្តល់ព័ត៌មានប្រចាំសប្តាហ៍ជូន គខ/កប អំពីលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងហេតុការណ៍កើតមានឡើង ដែលត្រូវស្នើសុំដោះស្រាយ

- ប្រជុំពិនិត្យសម្រេចលើរបាយកាណ៍របស់ក្រុមចែកប័ណ្ណ អំពីលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅពេលបញ្ចប់ការងារ ដើម្បីរាយការណ៍ជូន គ.ជ.ប តាមរយៈ គខ/កប

- រក្សាទុកសៀវភៅប័ណ្ណព័ត៌មានដែលនៅសល់ពុំទាន់ចែកជូនអ្នកបោះឆ្នោត ដើម្បីបន្តចែកជូនអ្នកបោះឆ្នោតរហូតដល់មួយថ្ងៃមុនថ្ងៃបោះឆ្នោត

- ធ្វើរបាយការណ៍តាមការិយាល័យ និងតាមឃុំ សង្កាត់ ស្តីពីលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅក្រោយការបោះឆ្នោត

- ប្រគល់សៀវភៅប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដែលនៅសល់ ជូនក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ ដើម្បីរក្សាទុកជាឯកសារ និងជាជំនួយក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតឱ្យកាន់តែមានភាពសុក្រឹតនៅឆ្នាំបន្ទាប់ ។

## ៣- ក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវចាត់ចែង និងអនុវត្ត :

- ស្រង់ឈ្មោះភូមិដែលទាក់ទងទៅនឹងអាសយដ្ឋានអ្នកបោះឆ្នោត តាមការិយាល័យបោះឆ្នោតនីមួយៗ រួចកត់ចំណាំនៅលើស្រោមសំបុត្រដាក់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដើម្បីបង្កភាពងាយស្រួលក្នុងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នៅតាមភូមិនានាក្នុងឃុំ សង្កាត់

- ចុះចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតតាមភូមិនីមួយៗតាមប្រតិទិនកំណត់ ដោយនាំយកទៅជាមួយនូវប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គ្រប់ការិយាល័យបោះឆ្នោតទាំងអស់

- សហការជាមួយមេភូមិពាក់ព័ន្ធដែលជាសមាជិកក្រុម ក្នុងការពិនិត្យឈ្មោះអ្នកបោះឆ្នោតនៅក្នុងសៀវភៅប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថាតើគាត់ស្គាល់ឈ្មោះប្រជាពលរដ្ឋទាំងនោះដែរឬទេ ? តើផ្ទះរបស់ប្រជាពលរដ្ឋស្ថិតនៅកន្លែងណា និងក្នុងក្រុមណា ? តើប្រជាពលរដ្ឋមានវត្តមាននៅផ្ទះដែរឬទេ ? ដើម្បីបានដឹងព័ត៌មានច្បាស់លាស់នៅមុនពេលចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

- សហការជាមួយមេភូមិពាក់ព័ន្ធដែលជាសមាជិកក្រុម អញ្ជើញប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឱ្យមកប្រមូលផ្តុំគ្នានៅទីកន្លែងកំណត់ណាមួយ ដើម្បីទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។ ផ្អែកតាមលទ្ធភាពជាក់ស្តែង ក្រុមចែកប័ណ្ណអាចចុះតាមលំនៅដ្ឋានប្រជាពលរដ្ឋ ឬ/និងក្នុងភូមិសាស្ត្រភូមិនីមួយៗ ក្នុងឃុំ សង្កាត់ ដើម្បីចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដោយគ្មានការរើសអើងជូនសាមីអ្នកបោះឆ្នោត ឬតំណាងតាមចំនួន និងឈ្មោះដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់

- កាត់ប័ណ្ណព័ត៌មានដែលត្រូវនឹងឈ្មោះ អាយុ និងទិន្នន័យផ្សេងទៀតរបស់សាមីអ្នកបោះឆ្នោត រួចប្រគល់ជូនសាមីខ្លួន ឬតំណាង

- ធ្វើកំណត់ហេតុបូកសរុបលទ្ធផលនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតប្រចាំថ្ងៃ

- ធ្វើរបាយការណ៍តាមការិយាល័យ និងរបាយការណ៍តាមឃុំ សង្កាត់ នៅពេលបញ្ចប់ការចែកប័ណ្ណព័ត៌មាន

- ប្រគល់របាយការណ៍ និងប័ណ្ណព័ត៌មាននៅសល់ជូន គឃ/សប រក្សាទុក ដើម្បីបន្តចែករហូតដល់មួយថ្ងៃមុនថ្ងៃបោះឆ្នោត

**៤- មេភូមិត្រូវបំពេញការងារ :**

- ផ្សព្វផ្សាយជូនប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន អំពីសារប្រយោជន៍នៃការផ្តល់ព័ត៌មានអ្នកបោះឆ្នោត អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាដែលត្រូវទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

- ជួយបង្កលក្ខណៈងាយស្រួលក្នុងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នៅក្នុងភូមិរបស់ខ្លួន

- កត់ចំណាំចំពោះអ្នកបោះឆ្នោតដែលមិនទាន់ទទួលបានប័ណ្ណព័ត៌មាននោះ និងជម្រាបគាត់ឱ្យទៅទទួលយកប័ណ្ណព័ត៌មានរបស់គាត់នៅទីស្នាក់ការ គឃ/សប ដែល គឃ/សប បន្តផ្តល់ជូនរហូតដល់មួយថ្ងៃមុនថ្ងៃបោះឆ្នោត

- ជួយណែនាំអ្នកបោះឆ្នោតដែលបានទទួលប័ណ្ណព័ត៌មានរួចហើយ ឱ្យយល់ដឹងអំពីលេខកូដ និងទីតាំងការិយាល័យបោះឆ្នោត និងព័ត៌មានផ្សេងទៀត ដែលមានបញ្ជាក់នៅក្នុងប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។

## IV. រយៈពេលនៃការអនុវត្តការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

ការអនុវត្តការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវអនុលោមតាមប្រតិទិនការងារ ដែលកំណត់ដោយ គ.ជ.ប ។

## V. ការត្រួតពិនិត្យលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

**១- ក្នុងការត្រួតពិនិត្យវាយតំលៃលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គឃ/សប ត្រូវ :**

- តាមដាន និងណែនាំក្រុមចែកប័ណ្ណព័ត៌មានជាប្រចាំ

- ចុះសាកសួរប្រជាពលរដ្ឋមួយចំនួនដោយផ្ទាល់ នៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដើម្បីវាយតម្លៃអំពីប្រសិទ្ធភាពនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

- បូកសរុបរបាយការណ៍ជូន គខ/កប នៅពេលបញ្ចប់ការចែកប័ណ្ណ តាមការណែនាំ ។

**២- ក្នុងការត្រួតពិនិត្យវាយតំលៃលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គខ/កប ត្រូវតែ ៖**

- ចុះទៅឃុំ សង្កាត់មួយចំនួនក្នុងខេត្ត ក្រុង ដើម្បីត្រួតពិនិត្យលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ក្នុងនោះត្រូវក្តាប់ឱ្យបាននូវចំនួនប័ណ្ណព័ត៌មានដែលក្រុមចែកប័ណ្ណ និង គឃ/សប បានផ្តល់ជូនប្រជាពលរដ្ឋ និងចំនួនប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដែលនៅសល់ ( ប្រសិនបើមាន)

- ចុះសាកសួរប្រជាពលរដ្ឋមួយចំនួនដោយផ្ទាល់ នៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដើម្បីវាយតំលៃអំពីប្រសិទ្ធភាពនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

- ធ្វើរបាយការណ៍បូកសរុបលទ្ធផល នៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងខេត្ត ក្រុង ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការនៃ គ.ជ.ប ។

**៣-** អគ្គលេខាធិការនៃ គ.ជ.ប ត្រូវបូកសរុបលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅទូទាំងប្រទេស ដើម្បីរាយការណ៍ជូន គ.ជ.ប និងចម្លងជូនក្រសួងមហាផ្ទៃ ។

សេចក្តីណែនាំរួមថ្មីនេះ ត្រូវអនុវត្តជំនួសសេចក្តីណែនាំរួមលេខ ០០៥ សណន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត របស់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ទទួលបានសេចក្តីណែនាំរួមនេះ អគ្គលេខាធិការ និងអគ្គនាយករដ្ឋបាលនៃក្រសួងមហាផ្ទៃ អគ្គលេខាធិការនៃ គ.ជ.ប អភិបាលខេត្ត ក្រុង គខ/កប អភិបាលស្រុក ខណ្ឌ គឃ/សប ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ មេភូមិ និងភាគីពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព ។

# ឧបសម្ព័ន្ធទី ៤

# ជំពូកទី ៤ នៃបទបញ្ជា និងនីតិវិធី សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

# (ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត)

**គោលដៅ និងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ**

**ប្រការ ៤.១** អនុលោមតាមជំពូកទី ៥ និងទី ៦ នៃច្បាប់បោះឆ្នោត គោលដៅ និងប្រព័ន្ធនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវបានកំណត់ឡើង ដើម្បីធានាឱ្យប្រជាពលរដ្ឋខ្មែរ ដែលមានលក្ខណៈវិនិច្ឆ័យស្របតាមមាត្រា ៥០ថ្មី នៃច្បាប់បោះឆ្នោត បានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ ក្នុងនេះ មាត្រា ៤៩ថ្មី នៃច្បាប់បោះឆ្នោត បានបញ្ញត្តិឱ្យមានការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំនេះ នឹងផ្តល់ឱ្យប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតនិងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ នូវភាពប្រាកដប្រជាថា ឈ្មោះរបស់គាត់ត្រូវបានរក្សាទុកក្នុងបញ្ជីបោះឆ្នោត ព្រមទាំងផ្តល់ឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតនូវភាពងាយស្រួលក្នុងការចុះឈ្មោះបោះឆ្នោត ហើយឈ្មោះរបស់គាត់នឹងត្រូវបញ្ចូលបន្ថែមទៅក្នុងបញ្ជីបោះឆ្នោត ។ នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត អ្នកសុំចុះឈ្មោះបោះឆ្នោតមានសិទ្ធិប្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះ ហើយអ្នកបានចុះឈ្មោះរួចហើយ មានសិទ្ធិប្តឹងតវ៉ាទៅនឹងការបាត់ឈ្មោះពីបញ្ជីបោះឆ្នោត ឬទាមទារឱ្យកែតម្រូវឈ្មោះ ឬទិន្នន័យពាក់ព័ន្ធ ដែលសរសេរខុស ។ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនេះ សំដៅបង្កើតបញ្ជីបោះឆ្នោតដំបូងសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ក្នុងឃុំ សង្កាត់ ដែលនឹងបិទផ្សាយជាសាធារណៈ ឱ្យអ្នកមានសិទ្ធិបោះឆ្នោតប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅនឹងការចុះឈ្មោះបោះឆ្នោតមិនត្រឹមត្រូវ ។ បន្ទាប់ពីការពិនិត្យ និងកែតម្រូវបញ្ជីបោះឆ្នោតដំបូងឡើងវិញរួច បញ្ជីបោះឆ្នោតនឹងត្រូវបានបោះពុម្ព និងផ្តល់សុពលភាពជាផ្លូវការដោយ គជប ដែលក្នុងនោះ ត្រូវបញ្ជូនមួយ(១)ច្បាប់ទៅរក្សាទុកជាបញ្ជីបោះឆ្នោតអចិន្ត្រៃយ៍ នៅសាលាឃុំ សង្កាត់ ដើម្បីបំរើសាធារណជន ។

៤.១.១ បញ្ជីបោះឆ្នោតដែលត្រូវប្រើសម្រាប់ការបោះឆ្នោត អនុលោមតាមច្បាប់បោះឆ្នោត ត្រូវរៀបចំឡើងដោយផ្អែកលើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតចុងក្រោយ នៃការិយាល័យបោះឆ្នោតក្នុងឃុំ

សង្កាត់ ។ នៅក្នុងចន្លោះឆ្នាំដែលគ្មានការរៀបចំការបោះឆ្នោត ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ នឹងត្រូវអនុវត្តដោយធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលបានផ្តល់សុពលភាពចុងក្រោយដោយ គជប ។

៤.១.២ ក្នុងករណី គជប បានកែសម្រួលការិយាល័យបោះឆ្នោត ឬ/និង បង្កើតការិយាល័យបោះឆ្នោតថ្មីបន្ថែមតាមការចាំបាច់នោះ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវតែបានបំពេញស្របពេលជាមួយគ្នា ក្នុងរយៈពេលដែលកំណត់ដោយ គជប ដោយអនុលោមតាមច្បាប់ ។

៤.១.៣ គជប ត្រូវធានាថា បញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោត ក្នុងឃុំសង្កាត់នីមួយៗ ដែលបានផ្តល់សុពលភាពជាផ្លូវការចុងក្រោយដោយ គជប ត្រូវបានថតចម្លងបន្ថែមចំនួនប្រាំមួយ ( ៦ ) ច្បាប់ ហើយបន្ទាប់មក ត្រូវរក្សាទុកច្បាប់ដើមមួយច្បាប់ជាឯកសារ និងត្រូវវេចខ្ចប់បញ្ជូនច្បាប់ចម្លងទាំងប្រាំមួយ(៦) ច្បាប់ ជូនក្រុមប្រឹក្សានិងស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ សម្រាប់បំរើគោលដៅនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់នីមួយ ៗ ។

៤.១.៤ នៅពេលទទួលបានច្បាប់ចម្លងបញ្ជីបោះឆ្នោតចុងក្រោយទាំងប្រាំមួយ ( ៦ ) ច្បាប់ ស្មៀនឃុំ សង្កាត់ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវបែងចែក និងប្រើប្រាស់ដូចខាងក្រោម ៖

៤.១.៤.១ បិទផ្សាយមួយច្បាប់នៅសាលាឃុំ សង្កាត់ ព្រមទាំងបែងចែកនិងបិទផ្សាយនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗរៀងខ្លួន ក្នុងឃុំ សង្កាត់ នៅរយៈពេលពីរ(២)ថ្ងៃមុនពេលចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៤.១.៤.២ រក្សាទុកចំនួនបួន(៤)ច្បាប់ សម្រាប់ប្រើក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ដែលបានកំណត់ក្នុងឃុំ សង្កាត់ ។ ក្នុងនេះត្រូវត្រៀម ៖

- ពីរច្បាប់សម្រាប់បិទផ្សាយជាបញ្ជីបោះឆ្នោតដំបូង
- មួយច្បាប់សម្រាប់ផ្ញើជូន គជប
- មួយច្បាប់សម្រាប់រក្សាទុកនៅសាលាឃុំ សង្កាត់ជាបញ្ជីបោះឆ្នោតបណ្តោះអាសន្ន បន្ទាប់ពីរាល់បណ្តឹងតវ៉ាពាក់ព័ន្ធទៅនឹងការបដិសេធការសុំចុះឈ្មោះត្រូវបានដោះស្រាយចប់សព្វគ្រប់ ។

៨.១.៥ ស្មៀនឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការរៀបចំ វេចខ្ចប់ និងបញ្ជូនមក គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត នូវបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនានាចំណុះឃុំ សង្កាត់ ដែលបានធ្វើបច្ចុប្បន្នភាពរួច ចំនួនមួយ ( ១ ) ច្បាប់ និងត្រូវរក្សាទុកនៅសាលាឃុំ សង្កាត់មួយ ( ១ ) ច្បាប់ ។

៨.១.៦ បន្ទាប់ពីបញ្ចប់ការដោះស្រាយលើបណ្តឹងតវ៉ា ទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតនៅតាមថ្នាក់នីមួយៗ និងប្រសិនបើ គ្មានបណ្តឹងតវ៉ាត្រូវបានដាក់នៅថ្នាក់លើបន្ទាប់ ក្នុងរយៈពេលកំណត់ទេនោះ ស្មៀនឃុំ សង្កាត់ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួចនៃការិយាល័យទាំងអស់មួយច្បាប់ ៗ នៅសាលាឃុំ សង្កាត់ ព្រមទាំងបំបែក និងបិទផ្សាយមួយច្បាប់ទៀតនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ ជាបញ្ជីបោះឆ្នោតដំបូងសម្រាប់បំរើគោលដៅកែតម្រូវ តាមរយៈការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ ។

៨.១.៧ បន្ទាប់ពីបញ្ចប់ការដោះស្រាយរាល់ការប្តឹងតវ៉ាឬ/និងការប្តឹងជំទាស់ក្នុងដំណើរការកែតម្រូវបញ្ជីបោះឆ្នោតដំបូង គជប ត្រូវពិនិត្យកែតម្រូវឡើងវិញក្នុងកុំព្យូទ័រ និងបោះពុម្ព រួចត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាបញ្ជាក់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំ ។

៨.១.៨ ចំពោះឆ្នាំមានការបោះឆ្នោត គជប ត្រូវរៀបចំឱ្យមានបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការិយាល័យនីមួយៗ នៃឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងតិចកៅសិប ( ៩០ ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ចំពោះឆ្នាំគ្មានការបោះឆ្នោត គជប ត្រូវរៀបចំផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការិយាល័យនីមួយៗ នៃឃុំ សង្កាត់ នៅថ្ងៃទី ៣១ ខែ ធ្នូ ។ បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតទាំងអស់នៃឃុំ សង្កាត់នីមួយៗ រួមបញ្ចូលគ្នាបង្កើតបានជាសៀវភៅបញ្ជីបោះឆ្នោតផ្លូវការនៃឃុំ សង្កាត់ពាក់ព័ន្ធ ។

៨.១.៨.១ សាលាឃុំ សង្កាត់គឺជាកន្លែងរក្សាទុក និងរក្សាការពារសៀវភៅបញ្ជីបោះឆ្នោតផ្លូវការនៃឃុំ សង្កាត់ ។

៨.១.៨.២ បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗនៃឃុំ សង្កាត់ដែលចងក្រងក្នុងសៀវភៅបញ្ជីបោះឆ្នោតផ្លូវការនៃឃុំ សង្កាត់ត្រូវតែជាកម្មវត្ថុបំរើសាធារណជន នៅសាលាឃុំ សង្កាត់ ។

៩.១.៩ នៅក្រោយពេលដែល គជប បានផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រសិនបើ មានសំណើរបស់បេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សុំឱ្យផ្ទេរឈ្មោះខ្លួន សហព័ទ្ធនិងកូន ពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនៅមណ្ឌលផ្សេងទៅបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនៅមណ្ឌល ដែលខ្លួនបានឈរឈ្មោះ គជប ត្រូវដោះស្រាយ និងកែសម្រួលបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ តាមសំណើសុំ ។ ក្នុងករណី បេក្ខជន សហព័ទ្ធ និងកូន ដែលត្រូវបាន គជប យល់ព្រម និងចាត់ចែងផ្ទេរឈ្មោះបោះឆ្នោតជូនរួចហើយ ប៉ុន្តែ នៅក្រោយការបោះឆ្នោត ពួកគាត់បែរជាមានបំណងចង់ចុះឈ្មោះបោះឆ្នោត នៅការិយាល័យបោះឆ្នោតដើម ឬ ការិយាល័យបោះឆ្នោតផ្សេង ពួកគាត់ត្រូវប្រកាសលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យដែលបានផ្ទេរទៅ និងត្រូវទៅបង្ហាញខ្លួនបំពេញបែបបទសុំចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យថ្មី នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

**ករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

**ប្រការ ៩.២** ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតគឺជាករណីយកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ៗ ដែលត្រូវធ្វើឡើងដោយសេរី សកល ស្មើភាព និង ដោយផ្ទាល់ ដោយយោងតាមមាត្រា ៣៤ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានទីលំនៅច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដើម្បីចុះឈ្មោះជាអ្នកបោះឆ្នោត ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោតម្នាក់ៗ ត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់ ។

៩.២.១ ដើម្បីរួមចំណែកក្នុងការពិនិត្យបញ្ជីឈ្មោះ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតចុងក្រោយ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោតជាផ្លូវការប្រចាំឆ្នាំ ប្រជាពលរដ្ឋគ្រប់រូបកំពុងរស់នៅក្នុងឃុំសង្កាត់ ដែលធ្លាប់បានចុះឈ្មោះបោះឆ្នោតចុងក្រោយ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ត្រូវទៅពិនិត្យមើលឈ្មោះរបស់ខ្លួននៅលើបញ្ជីបោះឆ្នោតដែលស្មៀនឃុំ សង្កាត់បានបិទផ្សាយនៅសាលាឃុំ សង្កាត់ និងនៅតាមទីតាំងការិយាល័យបោះឆ្នោត ។

៩.២.១.១ ដើម្បីងាយស្រួលក្នុងការផ្ទៀងផ្ទាត់ឱ្យប្រាកដថា ឈ្មោះរបស់ខ្លួនពិតជាមាន នៅលើបញ្ជីបោះឆ្នោតចុងក្រោយ ប្រជាពលរដ្ឋគ្រប់រូបត្រូវស្គាល់និងចងចាំឱ្យបានច្បាស់លាស់ នូវលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតរបស់ខ្លួន និងត្រូវកត់ត្រាទុកជាចំណាំនៅរៀងរាល់ពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

៤.២.១.២ ប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតចុងក្រោយ និងបានផ្ទៀងផ្ទាត់ឃើញឈ្មោះរបស់ខ្លួន ក្នុងបញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោតណាមួយក្នុង ឃុំ សង្កាត់រួចហើយ ត្រូវកត់ត្រាចំណាំលេខកូដនិងឈ្មោះទីតាំងការិយាល័យបោះឆ្នោតនោះ ព្រមទាំងលេខរៀងឈ្មោះរបស់ខ្លួននៅលើបញ្ជីបោះឆ្នោត ដើម្បីងាយស្រួលក្នុងការពិនិត្យបញ្ជីឈ្មោះជាប្រចាំឆ្នាំ និងក្នុងការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

៤.២.១.៣ ប្រជាពលរដ្ឋ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយរួចហើយ មិនចាំបាច់ត្រូវទៅបង្ហាញខ្លួននៅមុខស្មៀនឃុំ សង្កាត់ ដើម្បីសុំចុះឈ្មោះបោះឆ្នោតម្តងទៀតទេ ។

៤.២.១.៤ ប្រជាពលរដ្ឋគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតចុងក្រោយ ឬ/និង មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលបានបិទផ្សាយ ហើយកំពុងរស់នៅក្នុងឃុំ សង្កាត់ មិនត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតឡើយ ។ ចំពោះករណីនេះ ស្មៀនឃុំ សង្កាត់ត្រូវរក្សាទុកឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតដដែល បើទោះបីជា គាត់មិនមកបង្ហាញខ្លួនសុំចុះឈ្មោះម្តងទៀតក៏ដោយ ។

៤.២.១.៥ ស្មៀនឃុំ សង្កាត់ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋដែលបានទទួលមរណភាព ដែលបានបាត់បង់សិទ្ធិបោះឆ្នោត ដែលគ្មានទីលំនៅក្នុងឃុំ សង្កាត់ និងដែលបានផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ ហើយត្រូវលុបឈ្មោះអ្នកទាំងនោះ ចេញពីបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធក្នុងឃុំ សង្កាត់ ។ ក្នុងករណីនេះ ស្មៀនឃុំ សង្កាត់ត្រូវមានភស្តុតាង ជាឯកសារផ្លូវការ ដែលតម្រូវឱ្យលុបឈ្មោះអ្នកបោះឆ្នោតទាំងនោះចេញពីបញ្ជីបោះឆ្នោត តាមការកំណត់របស់ គជប ។

៤.២.២ ដើម្បីចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋគ្រប់រូបកំពុងរស់នៅក្នុងឃុំ សង្កាត់ ដែលមិនធ្លាប់បានចុះឈ្មោះបោះឆ្នោតពីមុនមក ឬ/និង ដែលទើបមានអាយុដប់ប្រាំបីឆ្នាំគិតដល់ថ្ងៃបោះឆ្នោត ចំពោះឆ្នាំមានការបោះឆ្នោត ឬ គិតដល់ថ្ងៃទី ៣១ ខែ ធ្នូ ចំពោះឆ្នាំគ្មានការបោះឆ្នោត ឬ/និង ដែលធ្លាប់បានចុះឈ្មោះនិងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ តែស្ថិតនៅឆ្ងាយពីទីលំនៅ ឬ/និង ដែលបាន

ផ្លាស់ទីលំនៅចូល ប៉ុន្តែធ្លាប់បានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ផ្សេង ត្រូវទៅបង្ហាញខ្លួនសុំចុះឈ្មោះនៅសាលាឃុំ សង្កាត់ ឬ នៅការិយាល័យចុះឈ្មោះបោះឆ្នោតមានទីតាំងនៅភូមិមួយចំនួនដែលបានកំណត់ ដោយយកមកជាមួយនូវឯកសារ ឬសំអាងចាំបាច់ផ្សេងៗ ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណ សញ្ជាតិ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់នោះ ។

៤.២.៣ កម្មករ សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល កងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងជនទាំងឡាយដែលស្នាក់នៅបណ្តោះអាសន្នក្នុងឃុំ សង្កាត់ មានសិទ្ធិសុំចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយក្នុងឃុំ សង្កាត់ នៅជិតទីកន្លែងដែល ពួកគេសិក្សា បំរើការងារ ស្នាក់នៅ ឬបំពេញបេសកកម្ម ។ ក្នុងករណីនេះ ប្រសិនបើ អ្នកសុំចុះឈ្មោះធ្លាប់បានចុះឈ្មោះបោះឆ្នោតចុងក្រោយនៅឃុំ សង្កាត់ផ្សេងដែលជននោះរស់នៅជាអចិន្ត្រៃយ៍រួចហើយ ស្មៀនឃុំ សង្កាត់ត្រូវចុះឈ្មោះបោះឆ្នោតជូនគាត់ ប៉ុន្តែមិនត្រូវភ្លេចបំពេញទម្រង់បែបបទលុបឈ្មោះគាត់ចេញពីបញ្ជីបោះឆ្នោត ដែលគាត់បានចុះឈ្មោះរួចហើយនោះឡើយ ។

៤.២.៤ ត្រូវបានយល់ព្រមឱ្យចុះឈ្មោះបោះឆ្នោត ចំពោះប្រជាពលរដ្ឋគ្រប់រូបស្ថិតក្នុងល័ក្ខខ័ណ្ឌដូចចែងក្នុងចំណុច ៤.២.២ និង ៤.២.៣ ខាងលើ ដែលបានទៅបង្ហាញខ្លួន និងសុំចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនរស់នៅ ហើយដែលបានឆ្លើយតបនឹងល័ក្ខខ័ណ្ឌទាំងឡាយ ក្នុងមាត្រា ៥០ថ្មី នៃច្បាប់បោះឆ្នោត ។

៤.២.៥ ដើម្បីមានសិទ្ធិបោះឆ្នោត ប្រជាពលរដ្ឋខ្មែរត្រូវមានឈ្មោះ នៅក្នុងបញ្ជីបោះឆ្នោត ហើយត្រូវមានឯកសារជាភស្តុតាង ដើម្បីឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌ ដូចចែងក្នុងមាត្រា ៥០ថ្មី នៃច្បាប់បោះឆ្នោត ។

៤.២.៥.១ នៅថ្ងៃបោះឆ្នោត ប្រជាពលរដ្ឋទាំងពីរភេទណា ដែលគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ទោះបីមានឯកសារបញ្ជាក់អំពីអត្តសញ្ញាណស្របតាមច្បាប់កំណត់ក៏ដោយ ក៏មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដែរ ។

៤.២.៥.២ នៅថ្ងៃបោះឆ្នោត ប្រជាពលរដ្ឋទាំងពីរភេទណា ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ដែលបានកំណត់ក្រោមចំណុច ៤.៩.១ នៃបទបញ្ជានិងនីតិវិធីរបស់ គជប និងច្បាប់បោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

៤.២.៥.៣ ឈ្មោះអ្នកបោះឆ្នោតលើបញ្ជីបោះឆ្នោតត្រូវតែដូចគ្នានឹងឈ្មោះ ដែលមានក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតពាក់ព័ន្ធ ។

៤.២.៦ ត្រូវបានបដិសេធមិនឱ្យចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ_សង្កាត់ ចំពោះជនទាំងឡាយណាដែលមិនបានបំពេញគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដូចចែងក្នុងមាត្រា ៥០ថ្មី នៃច្បាប់បោះឆ្នោត ។

**ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការជ្រើសតាំងមន្ត្រីចុះឈ្មោះបោះឆ្នោត**

**ប្រការ ៤.៣** អនុលោមតាមមាត្រា ៥៣ថ្មី នៃច្បាប់បោះឆ្នោត គជប ត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងក្របខ័ណ្ឌឃុំ សង្កាត់នីមួយៗ ។ គជប ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ អំពីការធ្វើប្រតិភូកម្មអំណាចស្របតាមសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសមស្របដល់ក្រុមប្រឹក្សាឃុំ សង្កាត់និងស្មៀនឃុំ សង្កាត់ ដើម្បីអនុវត្តការទទួលខុសត្រូវនេះ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា ស្មៀនឃុំ សង្កាត់និងជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវបានតែងតាំងឱ្យទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ( នៅសាលាឃុំ សង្កាត់ ឬនៅតាមភូមិ ឬមន្ទីរពេទ្យ ឬមន្ទីរឃុំឃាំងពិរុទ្ធជន ) សម្រាប់ឃុំ សង្កាត់នីមួយៗ និងតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវពិនិត្យនិងមើលការខុសត្រូវការងាររបស់ស្មៀនផង ។

៤.៣.១ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំស្មៀនឃុំ សង្កាត់ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត និងបទបញ្ជានិងនីតិវិធីរបស់ គជប ។ ដើម្បីធានារ៉ាប់រងការអនុវត្តសិទ្ធិអំណាចដែល គជប និង ក្រសួងមហាផ្ទៃបានធ្វើប្រតិភូកម្មអំណាចឱ្យខ្លួន ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

៤.៣.១.១ ចាត់ចែងការជ្រើសរើសជំនួយការស្មៀនឃុំ សង្កាត់ និងលើកសំណើសុំសេចក្តីសំរេចតែងតាំងពី គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ស្របពេលជាមួយគ្នានឹងការលើកស្នើសុំតែងតាំងស្មៀនឃុំ សង្កាត់ ជាមន្ត្រីទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ។ ក្នុងការជ្រើសរើសនេះ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយ គជប ។

៤.៣.១.២ ចាត់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តាមចំនួនដែលកំណត់ដោយច្បាប់ ឱ្យប្រចាំការពិនិត្យនិងមើលការខុសត្រូវលើការងារស្មៀនឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ធានាណែនាំស្មៀនឱ្យអនុវត្តបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៤.៣.១.៣ លើកសំណើជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ដើម្បីតែងតាំងមន្ត្រីចុះឈ្មោះបោះឆ្នោតថ្មីសំរាប់ជំនួសអ្នកដែលមិនអាចមកបំពេញការងារបាន បន្ទាប់ពីតែងតាំងហើយ ។

៤.៣.១.៤ ទទួលពាក្យស្នើសុំចុះឈ្មោះ ជាតំណាងគណបក្សនយោបាយចូលរួមសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្នុងឃុំ សង្កាត់ ព្រមទាំងពិនិត្យសំរេច និង ចេញប័ណ្ណសំគាល់ជូនតំណាងគណបក្សនយោបាយ តាមការណែនាំរបស់ គជប ។

៤.៣.១.៥ ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋកំពុងរស់នៅក្នុងឃុំ សង្កាត់ ឱ្យទៅពិនិត្យផ្ទៀងផ្ទាត់ឈ្មោះរបស់ខ្លួន នៅលើបញ្ជីបោះឆ្នោតចុងក្រោយ ដែលបានបិទផ្សាយតាមកាលបរិច្ឆេទកំណត់ នៅសាលាឃុំ សង្កាត់និងតាមទីតាំងការិយាល័យបោះឆ្នោត ដើម្បីបំរើគោលដៅនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៤.៣.១.៦ ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ឱ្យទៅចុះឈ្មោះនៅការិយាល័យចុះឈ្មោះណាមួយក្នុងឃុំ សង្កាត់ ។

៤.៣.១.៧ ធានាផ្តល់ជំនួយសមស្របចំពោះជនពិការ ដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតបានដោយខ្លួនឯង និងដែលបានស្នើសុំជំនួយ ។

៤.៣.១.៨ ចាត់វិធានការសមស្រប ដើម្បីធានាថា រាល់កិច្ចប្រតិបត្តិការទាក់ទងដល់ការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង ។ ចាត់ចែងដោះស្រាយឱ្យមានអន្តរាគមន៍ពីកំលាំងនគរបាល ឬកំលាំងមានសមត្ថកិច្ច តាមសំណើ របស់ស្មៀនឃុំ សង្កាត់ ក្នុងករណីដែលមានជនណាបង្កការអុកឡុក វំខាន គំរាមកំហែង

ឬប្រព្រឹត្តអំពើល្មើសច្បាប់ សំដៅបង្អាក់ដំណាក់ការណាមួយនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៤.៣.១.៩ ធានាចេញលិខិតបញ្ជាក់អត្តសញ្ញាណ ឬ/និងអាយុ ឬលិខិតបញ្ជាក់ទីលំនៅជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ដែលបានស្នើសុំ ស្របតាមច្បាប់ ដោយពុំមានតម្រូវឱ្យបង់សោហ៊ុយឡើយ ។ ដើម្បីបំរើគោលដៅនេះ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងដែលត្រូវបានប្រគល់សិទ្ធិអំណាចក្នុងការចេញលិខិតបញ្ជាក់ ត្រូវមានវត្តមាននៅសាលាឃុំ សង្កាត់ ឬត្រូវចុះជាប់ជាមួយស្មៀនឃុំ សង្កាត់ ស្របពេលនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមទីតាំងការិយាល័យចុះឈ្មោះនៅសាលាឃុំសង្កាត់ ឬតាមភូមិ ឬត្រូវចល័តទៅតាមមន្ទីរពេទ្យ ឬមន្ទីរឃុំឃាំងដែលមានទីតាំងក្នុងឃុំ សង្កាត់ ។

៤.៣.១.១០ សម្រេចក្នុងការបញ្ជាក់ការឯកភាព ឬមិនឯកភាពលើទម្រង់បែបបទដែលស្មៀនបានឃុំ សង្កាត់បំពេញនិងដាក់ជូន ដោយអនុវត្តតាមការណែនាំរបស់ គជប ។

៤.៣.១.១១ រាយការណ៍ជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត នូវរាល់ហេតុការណ៍ ដែលអាចកើតមានក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដើម្បីសំរបសំរួលដោះស្រាយបញ្ហា ។

៤.៣.១.១២ ទទួល និង ដោះស្រាយរាល់បណ្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដោយការប្រជុំសម្រេចជាសាធារណៈ ។

៤.៣.១.១៣ ទទួល និងដោះស្រាយរាល់បណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ដោយការប្រជុំសម្រេចជាសាធារណៈ ។

៤.៣.១.១៤ ផ្ញើជូន គជប នូវរាល់សេចក្តីសំរេចរបស់ខ្លួនដោះស្រាយលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) និងផ្តល់ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ តាមសំណើសុំរបស់អ្នកប្តឹង ឬតំណាង ។

៤.៣.១.១៥ ផ្តល់ជំនួយដល់ស្មៀនឃុំ សង្កាត់ ក្នុងការផ្ទៀងផ្ទាត់ ការបូកសរុប ការរៀបចំវេចខ្ចប់ និងការបញ្ជូនលទ្ធផល និងសម្ភារៈឯកសារចុះ

ឈ្មោះបោះឆ្នោតជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត។

៤.៣.២ ដើម្បីអនុវត្តតួនាទីទទួលខុសត្រូវក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងក្របខ័ណ្ឌឃុំ សង្កាត់របស់ខ្លួន ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រគល់ភារកិច្ចពេញលេញដល់ស្មៀនឃុំ សង្កាត់ ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ក្នុងគោលដៅនេះ ស្មៀនឃុំ សង្កាត់ត្រូវទទួលមុខងារជាមន្ត្រីចុះឈ្មោះបោះឆ្នោត ទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៤.៣.២.១ ផ្អែកតាមប្រកាសរួមរបស់ គជប និងក្រសួងមហាផ្ទៃស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញតួនាទីក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើលិខិតឧទ្ទេសនាមស្មៀនឃុំ សង្កាត់ ក្នុងមុខតំណែង ដើម្បីស្នើសុំការតែងតាំងជាផ្លូវការពី គជប ជាមន្ត្រីទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៤.៣.២.២ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវឱ្យស្មៀនឃុំ សង្កាត់បំពេញទម្រង់បែបបទកិច្ចសន្យាការងារ ( ទម្រង់បែបបទលេខ ១០០១ ) ចំនួនពីរ(២)ច្បាប់ និងត្រូវចុះហត្ថលេខាដោយ ស្មៀនឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ។ ទម្រង់បែបបទកិច្ចសន្យាការងារចំនួនមួយ(១)ច្បាប់ត្រូវប្រគល់ជូនស្មៀនឃុំ សង្កាត់ ។

៤.៣.២.៣ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនលិខិតស្នើសុំតែងតាំង ដោយភ្ជាប់មកជាមួយនូវទម្រង់បែបបទកិច្ចសន្យាការងាររបស់ស្មៀនឃុំ សង្កាត់ មួយ(១)ច្បាប់ មក គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៤.៣.២.៤ ផ្អែកតាមលិខិតស្នើសុំតែងតាំងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គជប ត្រូវចេញសេចក្តីសំរេចតែងតាំងស្មៀនឃុំ សង្កាត់ ឱ្យទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោត ឱ្យបានមុនថ្ងៃបើកការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ។ ទោះបីយ៉ាងនេះក្តី រយៈពេលនៃការបំពេញការងារនិងប្រាក់កំរៃ នឹងត្រូវកំណត់ដោយ គជប ។

៤.៣.២.៥ នៅពេលទទួលបានសេចក្តីសំរេចតែងតាំងជាផ្លូវការពី គជប ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់ចែងចេញប័ណ្ណសំគាល់មន្ត្រីចុះឈ្មោះបោះឆ្នោតជូនស្មៀនឃុំ សង្កាត់ ។

៤.៣.២.៦ គជប និងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា បន្ទាប់ពីត្រូវបានតែងតាំងហើយ ស្មៀនឃុំ សង្កាត់ ត្រូវតែបានបណ្តុះបណ្តាលនូវចំណេះដឹងស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៤.៣.២.៧ ដោយផ្អែកតាមមុខតំណែងរបស់ខ្លួន ដែលជាមន្ត្រីទទួលបន្ទុកការចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវទទួលបានប្រាក់កំរៃការងារបន្ថែម ដែលរួមបញ្ចូលទាំងថ្លៃអាហារនិងការធ្វើដំណើរផង ស្មើនឹងប្រាក់កំរៃប្រចាំថ្ងៃ គុណនឹងរយៈពេលសរុបដែលគាត់បំពេញការងារពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតដូចដែល គជប បានកំណត់ជាមុន ។

៤.៣.២.៨ រយៈពេលបំពេញកិច្ចសន្យាការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរបស់ស្មៀនឃុំ សង្កាត់ ដែលនឹងទទួលបានប្រាក់កំរៃ ត្រូវបានកំណត់ដោយ គជប ។ ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ ក៏ស្មៀនឃុំ សង្កាត់ ត្រូវតែសហការជាមួយអាជ្ញាធររៀបចំការបោះឆ្នោត នៅគ្រប់លំដាប់ថ្នាក់ ក្នុងការបំពេញការងារដែលសេសសល់ រហូតដល់ពេលដែលត្រូវធ្វើរបាយការណ៍កែតម្រូវចុងក្រោយ បន្ទាប់ពីរាល់បណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងត្រូវបានដោះស្រាយចប់សព្វគ្រប់ ។

៤.៣.២.៩ ក្នុងករណីស្មៀនឃុំ សង្កាត់ អវត្តមាន ឬ មិនអាចមកបំពេញការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបាន ឬ មានកំហុសដែលត្រូវបាន គជប សំរេចដកមុខតំណែងមន្ត្រីចុះឈ្មោះ ជំនួយការស្មៀនមួយរូបដែលត្រូវបានកំណត់បំរុងជាមុន ត្រូវបំពេញភារកិច្ចជំនួស ។

៤.៣.៣ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់សមាជិករបស់ខ្លួនឱ្យប្រចាំការពិនិត្យនិងមើលការខុសត្រូវលើការងារស្មៀនឃុំ សង្កាត់ ដើម្បីធានាថា ស្មៀនឃុំ សង្កាត់បានអនុវត្តយ៉ាងត្រឹមត្រូវតាមច្បាប់បោះឆ្នោត និងបទបញ្ជានិងនីតិវិធីរបស់ គជប ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនមួយ(១)រូបចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាប្រាំ(៥)រូប និងពីរ(២)រូប ចំពោះឃុំ សង្កាត់ ដែលមានសមាជិកក្រុមប្រឹក្សាចាប់ពីប្រាំពីរ(៧)រូបឡើងទៅ ឱ្យប្រចាំការពិនិត្យនិងមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងក្របខ័ណ្ឌឃុំ សង្កាត់របស់ខ្លួន ។ ក្រុមប្រឹក្សា

ឃុំ សង្កាត់ និងសមាជិកក្រុមប្រឹក្សាដែលត្រូវប្រចាំការពិនិត្យ និងមើលការខុសត្រូវលើការងារស្មៀនឃុំ សង្កាត់ ត្រូវបង្ករាល់លក្ខណៈងាយស្រួល ដើម្បីឱ្យប្រជាពលរដ្ឋក្នុងឃុំសង្កាត់បានមកពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតច្រើនកុះករ ។

៤.៣.៣.១ ក្រុមប្រឹក្សាឃុំ សង្កាត់អាចផ្លាស់ប្តូរសមាសភាពសមាជិកក្រុមប្រឹក្សាដែលត្រូវត្រួតពិនិត្យមើលការខុសត្រូវការងាររបស់ស្មៀនឃុំ សង្កាត់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយផ្អែកលើសំណូមពរការងារចាំបាច់របស់ខ្លួន និងសំណូមពរការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៤.៣.៣.២ គជប និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធានាថា សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានតែងតាំង ឬផ្លាស់ប្តូរឱ្យត្រួតពិនិត្យមើលការខុសត្រូវការងាររបស់ស្មៀនឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត សុទ្ធតែត្រូវបានបណ្តុះបណ្តាល ឬ/និងមានការយល់ដឹងច្បាស់លាស់ ដែលអាចបំពេញការងារត្រួតពិនិត្យបានល្អ ។

៤.៣.៣.៣ ក្រុមប្រឹក្សាឃុំ សង្កាត់ គ្រាន់តែត្រូវរាយការណ៍ អំពីសមាសភាពសមាជិករបស់ខ្លួន ដែលត្រូវបានតែងតាំង ឬផ្លាស់ប្តូរឱ្យត្រួតពិនិត្យមើលការងាររបស់ស្មៀនជូន គជប ជាព័ត៌មាន តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតប៉ុណ្ណោះ ។

៤.៣.៣.៤ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្តល់យោបល់ដល់ស្មៀនឃុំ សង្កាត់ ក្នុងការកំណត់ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះនានាក្នុងឃុំ សង្កាត់ ។

៤.៣.៣.៥ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ/និង សមាជិកក្រុមប្រឹក្សាដែលត្រូវប្រចាំការពិនិត្យមើលការខុសត្រូវលើការងារស្មៀនឃុំ សង្កាត់ ត្រូវណែនាំ និងសហការជាមួយប្រធានភូមិនានា ក្នុងឃុំ សង្កាត់ ដើម្បីសំរបសំរួលឱ្យប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោត តាមលំដាប់លំដោយមុនក្រោយ ជាហូរហែ និងគ្មានការកកស្ទះ ។

៤.៣.៣.៦ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ក្នុងការចុះឈ្មោះបោះឆ្នោត សមាជិកក្រុមប្រឹក្សាដែលត្រូវចុះត្រួតពិនិត្យមើលការងារស្មៀននៅតាមទីតាំងការិយាល័យចុះឈ្មោះនៅតាមភូមិ ឬពេលត្រូវចុះចល័ត

ទៅតាមមន្ទីរពេទ្យ ឬមន្ទីរឃុំឃាំង ដែលមានទីតាំងក្នុងឃុំ សង្កាត់ ត្រូវតែជាមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងដែលបានប្រគល់សិទ្ធិអំណាចក្នុងការបញ្ជាក់អត្តសញ្ញាណ ឬ/និងអាយុ ឬ/និងទីលំនៅជូនដល់អ្នកសុំចុះឈ្មោះបោះឆ្នោត ។

៩.៣.៣.៧ ប្រសិនបើ សមាជិកក្រុមប្រឹក្សា ដែលត្រូវត្រួតពិនិត្យមើលការងារស្មៀនមានជំនឿថា ស្មៀនមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមបទបញ្ជានិងនីតិវិធីរបស់ គជប សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សមាជិក រូបនោះត្រូវណែនាំរំលឹកស្មៀនអំពីផ្នែក ឬចំណុចណាមួយដែលស្មៀនមិនបានអនុវត្ត ឬអនុវត្តខុស ។ ក្នុងករណី សមាជិកក្រុមប្រឹក្សាណាម្នាក់យល់ថា ក្នុងការអនុវត្តការងាររបស់ស្មៀនឃុំ សង្កាត់ មានភាពមិនប្រក្រតី ឬមានបញ្ហាធ្ងន់ធ្ងរណាមួយ សមាជិករូបនោះត្រូវរាយការណ៍ជាបន្ទាន់ ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ។ ប្រសិនបើ ក្រុមប្រឹក្សាឃុំ សង្កាត់យល់ស្របតាមយោបល់សមាជិករូបនោះ ត្រូវរាយការណ៍ជាបន្ទាន់ជូន គជប ដើម្បីមានវិធានការផ្លាស់ប្តូរមន្ត្រីចុះឈ្មោះដោយប្រគល់ឱ្យជំនួយការស្មៀនបំពេញការងារបន្តជំនួសស្មៀន និងជ្រើសតាំងបេក្ខជនបំរុងជំនួសតំណែងជំនួយការស្មៀន ។

៩.៣.៣.៨ សមាជិកក្រុមប្រឹក្សា ដែលប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនត្រូវរាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សាឃុំ សង្កាត់ អំពីភាពជឿនលឿនក្នុងដំណាក់ការនីមួយៗ នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៩.៣.៣.៩ សមាជិកក្រុមប្រឹក្សា ដែលត្រូវត្រួតពិនិត្យមើលការងារស្មៀនមិនទទួលបានកំរៃបន្ថែមទេ ប៉ុន្តែ ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលនឹងទទួលបានខ្ចប់ប្រាក់ឧបត្ថម្ភ សម្រាប់សំរួលការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៩.៣.៣.១០ សមាជិកក្រុមប្រឹក្សាដែលត្រូវត្រួតពិនិត្យមើលការងារស្មៀន ត្រូវបញ្ចប់ភារកិច្ចរបស់ខ្លួន ទន្ទឹមគ្នានឹងការបញ្ចប់ភារកិច្ចរបស់ស្មៀនដែរ ។

៩.៣.៤ ផ្អែកលើភាពចាំបាច់ និងទំហំការងារនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ គជប ត្រូវផ្តល់ជំនួយការស្មៀន ដែលជាមន្ត្រីចុះ

ឈ្មោះបោះឆ្នោតពី(១)នាក់ ដល់ប្រាំ(៥)នាក់ យោងទៅតាមចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់តិចឬច្រើន ដើម្បីជាជំនួយដល់ស្មៀនឃុំ សង្កាត់ក្នុងការបំពេញការងារពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។ ប្រសិនបើ ស្មៀនឃុំ សង្កាត់អវត្តមាន ឬមិនអាចបំពេញការងារពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតបាន ឬមានកំហុសដែលត្រូវបាន គជប សំរេចដកមុខតំណែងជាមន្ត្រីចុះឈ្មោះនោះ ជំនួយការស្មៀនម្នាក់ ក្នុងចំណោមជំនួយការស្មៀនទាំងអស់ត្រូវទទួលសិទ្ធិអំណាច បំពេញការងារជំនួសស្មៀនឃុំ សង្កាត់ ក្នុងមុខងារជាមន្ត្រីទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។ ជំនួយការស្មៀនដែលត្រូវទទួលសិទ្ធិអំណាច បំពេញការងារជំនួសស្មៀនឃុំ សង្កាត់ ត្រូវតែបានកំណត់បំរុងជាមុន ។

៤.៣.៤.១ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជាប្រចាំឆ្នាំ គជប ត្រូវប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការជ្រើសរើសជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ស្របពេលជាមួយនឹងការលើកស្នើសុំតែងតាំងស្មៀនឃុំ សង្កាត់ ជាមន្ត្រីទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដែរ ។

៤.៣.៤.២ គជប និងលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត ក្រុង ត្រូវធានាថា ទម្រង់បែបបទពាក់ព័ន្ធសម្រាប់ប្រើប្រាស់ ក្នុងការជ្រើសរើសជំនួយការ និង បំពេញសេចក្តីសម្រេចតែងតាំងមន្ត្រីចុះឈ្មោះបោះឆ្នោត ( ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន ) តាមចំនួនជាក់ស្តែងសម្រាប់ឃុំ សង្កាត់នីមួយៗត្រូវបានប្រគល់ជូនក្រុមប្រឹក្សាឃុំ សង្កាត់នៅមុនពេលធ្វើការជ្រើសរើស ដែលបានកំណត់ក្នុងប្រតិទិន ។

៤.៣.៤.៣ គជប និងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា ជំនួយការស្មៀនដែលត្រូវបានតែងតាំងហើយ ត្រូវតែបានបណ្តុះបណ្តាលស្តីពីការងារពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត រួមជាមួយស្មៀនឃុំ សង្កាត់ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវត្រួតពិនិត្យមើលការខុសត្រូវលើការងាររបស់ស្មៀនឃុំ សង្កាត់ ។

៤.៣.៥ ក្នុងដំណើរការនៃការជ្រើសរើសជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត សេចក្តីជូនដំណឹង ស្តីពីការជ្រើសរើសមុខតំណែងនេះត្រូវតែបានបិទប្រកាសផ្សាយនៅគ្រប់តំបន់បោះឆ្នោតក្នុងឃុំ សង្កាត់ ដើម្បីអញ្ជើញបេក្ខជនឱ្យមកដាក់ពាក្យសុំបំរើការងារនៅសាលាឃុំ សង្កាត់ ។

៨.៣.៥.១ សេចក្តីជូនដំណឹងស្តីពីការជ្រើសរើសជំនួយការស្មៀនដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ចំនួនមន្ត្រីដែលត្រូវជ្រើសរើស សេចក្តីពណ៌នាការងារ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស ត្រូវបិទផ្សាយនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ និងនៅសាលាឃុំ សង្កាត់ ។

៨.៣.៥.២ ទម្រង់បែបបទសម្រាប់បំពេញសុំបំរើការងារមានចែកជូន ដោយឥតគិតថ្លៃ នៅសាលាឃុំ សង្កាត់ ក្នុងរយៈពេលប្រាំ ( ៥ )ថ្ងៃ ក្នុងពេលម៉ោងធ្វើការ ។

៨.៣.៦ ជំនួយការស្មៀន គឺជាមន្ត្រីចុះឈ្មោះបោះឆ្នោតដែលត្រូវប្រកាន់ជំហរឯករាជ្យ មិនលំអៀង និងស្មោះត្រង់ក្នុងការអនុវត្តអំណាច មុខងារ និងភារកិច្ចរបស់ខ្លួនដែលបានកំណត់ដោយច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គជប ជាពិសេសក្នុងពេលដែលខ្លួនត្រូវបំពេញការងារជំនួសស្មៀនឃុំ សង្កាត់ នៅពេលស្មៀនអវត្តមាន ឬមិនអាចមកបំពេញការងារបាន ។ ប្រជាពលរដ្ឋ មន្ត្រីរាជការ និងអ្នកមុខអ្នកការរស់នៅក្នុងឃុំ សង្កាត់ជាបេក្ខជន ដែលមានបំណងដាក់ពាក្យសុំបំរើការងារជាជំនួយការស្មៀនឃុំ សង្កាត់ ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

៨.៣.៦.១ ជាអ្នកមានសិទ្ធិបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយក្នុងឃុំ សង្កាត់នោះ ។

៨.៣.៦.២ ចេះអាន និងសរសេរអក្សរខ្មែរ ហើយប្រសិនបើអាច សរសេរអក្សរបានស្អាតល្អ ។

៨.៣.៦.៣ ជាប់ក្នុងការធ្វើតេស្ត ។

៨.៣.៦.៤ មានលទ្ធភាពពេញម៉ោងសម្រាប់ចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសម្រាប់រយៈពេលទាំងមូលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ដូចដែលបានកំណត់ដោយ គជប ។

៨.៣.៦.៥ មានកិត្តិស័ព្ទស្មោះត្រង់ និងសុចរិតទៀងត្រង់ ព្រមទាំងមានឆន្ទៈគោរពច្បាប់ ព្រមទាំងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៨.៣.៧ នៅក្នុងការជ្រើសរើសជំនួយការស្មៀន ការពិចារណាពិសេស នឹងត្រូវផ្តោតទៅលើបេក្ខជនដាក់ពាក្យសុំបំរើការងារ ដែលមានបទពិសោធន៍ខាងការងារចុះឈ្មោះ និងការងារបោះឆ្នោត ក្នុងសម័យបោះឆ្នោតកន្លងមក ។

៤.៣.៧.១ ជំនួយការស្មៀនគួរតែជាអ្នកដែលមានចំណេះដឹង និងកិត្តិស័ព្ទល្អ និងអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងឃុំ សង្កាត់ ។

៤.៣.៧.២ ជំនួយការស្មៀនដែលត្រូវជ្រើសរើសមានចំនួនលើសពីម្នាក់ ជំនួយការស្មៀនមួយ(១)រូប គួរតែជាស្ត្រីភេទ ។

៤.៣.៨ សមាជិកនៃគណបក្សនយោបាយអាចដាក់ពាក្យសុំបំរើការងារបានជាធម្មតា លើកលែងតែអ្នកដែលកំពុងមានមុខតំណែងក្នុងគណបក្សនយោបាយ ឬបានឈប់ពីមុខតំណែងក្នុងរយៈពេលតិចជាងប្រាំមួយខែ គិតមកដល់ថ្ងៃតែងតាំង ។

៤.៣.៩ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានជាប់សាច់ឈាម ( ឪពុកម្តាយ កូន ប្តីប្រពន្ធ បងប្អូនបង្កើត បងប្អូនជីដូនមួយ ឪពុកធំម្តាយធំ មីងមា ក្មួយ ) ជាមួយនឹងបេក្ខជនដាក់ពាក្យសុំបំរើការងារ មិនត្រូវចូលរួម ក្នុងដំណើរការពិនិត្យជ្រើសរើសបេក្ខជននេះទេ ។

៤.៣.១០ ក្នុងដំណើរការជ្រើសរើសមន្ត្រីចុះឈ្មោះបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តវិធានការឱ្យមានលក្ខណៈយុត្តិធម៌ ហើយមិនត្រូវយោគយល់អធ្យាស្រ័យចំពោះការធ្វើអន្តរាគមន៍ ឬ ការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅដោយពេញចិត្តក្តី ឬពុំពេញចិត្តក្តីចំពោះបេក្ខជនដាក់ពាក្យសុំបំរើការងារណាម្នាក់ឡើយ ។

៤.៣.១១ មិនត្រូវបានតែងតាំងជាជំនួយការស្មៀន ក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ចំពោះជនទាំងឡាយដូចខាងក្រោម ៖

៤.៣.១១.១ នាយ និងពលនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ ឬ នគរបាលជាតិ ។

៤.៣.១១.២ ចៅក្រម ក្រឡាបញ្ជី ឬមន្ត្រីតុលាការ ។

៤.៣.១១.៣ ព្រះសង្ឃ ឬបព្វជិតនៃសាសនាណាមួយ ។

៤.៣.១១.៤ អភិបាល ឬអភិបាលរងស្រុក ខណ្ឌ ។

៤.៣.១១.៥ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ។

៤.៣.១១.៦ ជនដែលកំពុងមានមុខតំណែងក្នុងគណបក្សនយោបាយ ( ប្រធាន អនុប្រធាន លេខាធិការ ហេរញ្ញិក ទីប្រឹក្សា សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឬតំណែងប្រហាក់ប្រហែលនេះ ) ឬជនដែលបានឈប់ពីមុខតំណែងក្នុងគណបក្សនយោបាយណាមួយ ក្នុងរយៈពេលតិចជាងប្រាំមួយ ( ៦ ) ខែ គិតមកដល់ថ្ងៃតែងតាំង ។

៩.៣.១២ អ្នកដែលត្រូវបានជ្រើសរើស និងជួលក្នុងលក្ខណៈជាប់កិច្ចសន្យា ជាជំនួយការស្មៀនឃុំ សង្កាត់ក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ គឺជាបេក្ខជនដាក់ពាក្យសុំចូលបំរើការងារណា ដែលបានបំពេញលក្ខខ័ណ្ឌទាំងឡាយដូចខាងក្រោម ៖

៩.៣.១២.១ ត្រូវឆ្លងកាត់ដោយជោគជ័យនូវការធ្វើតេស្ត ដែលគ្រប់គ្រងពិនិត្យដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

៩.៣.១២.២ ត្រូវគោរពរដ្ឋធម្មនុញ្ញ និងអនុវត្តតាមច្បាប់បោះឆ្នោត ព្រមទាំងបទបញ្ញានិងនីតិវិធីរបស់ គជប ។

៩.៣.១២.៣ ត្រូវយល់ព្រមប្រកាន់ជំហរអព្យាក្រឹត និងមិនលំអៀង ។

៩.៣.១២.៤ ត្រូវយល់ព្រមលើលក្ខខ័ណ្ឌការងារ និងប្រាក់កម្រៃ ។ ជំនួយការស្មៀនត្រូវបានទទួលប្រាក់កំរៃការងារ ដែលរួមបញ្ចូលទាំងថ្លៃអាហារ និងការធ្វើដំណើរផង ស្មើនឹងប្រាក់កំរៃប្រចាំថ្ងៃ គុណនឹងរយៈពេលសរុប ដែលគាត់បំពេញការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដោយ គជប ។ ថ្ងៃចូល និងថ្ងៃឈប់បំរើការងារពិតប្រាកដត្រូវកំណត់ដោយ គជប និងមិនត្រូវបានគិតដោយផ្អែកលើកាលបរិច្ឆេទនៃការចុះកិច្ចសន្យាជួលបំពេញការងារនោះទេ ។

៩.៣.១២.៥ ត្រូវបំពេញ និងចុះហត្ថលេខាយល់ព្រមលើកិច្ចសន្យាបំរើការងារជាជំនួយការស្មៀនឃុំ សង្កាត់ក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ( ទម្រង់បែបបទលេខ ១០០១ ) ចំនួនពីរ (២)ច្បាប់ ។

៩.៣.១២.៦ ត្រូវចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង ។

៩.៣.១៣ បេក្ខជនណាដែលត្រូវបានជ្រើសរើសហើយ ប៉ុន្តែមិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ត្រូវដាក់ជំនួសជាបន្ទាន់ដោយអ្នកបំរុង ។ ប្រសិនបើ គ្មានបេក្ខជនបំរុងសម្រាប់ជំនួស ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ការជ្រើសរើសអ្នកជំនួសជាបន្ទាន់ ។

៩.៣.១៤ ទម្រង់បែបបទលេខ ១០០១ ដែលបេក្ខជនបានបំពេញ និងចុះហត្ថលេខា ដូចចែងក្នុងចំណុច ៩.៣.១២.៥ នឹងក្លាយជាកិច្ចសន្យាការងាររវាង គជប និងជំនួយការស្មៀនឃុំ សង្កាត់ក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលត្រូវមានបញ្ជាក់ ៖

៩.៣.១៤.១ ឈ្មោះ និងអាសយដ្ឋាននៃអ្នកដែលត្រូវតែងតាំង ។

៩.៣.១៤.២ មុខតំណែងនៃអ្នកដែលត្រូវតែងតាំង ។

៩.៣.១៤.៣ លក្ខណៈសម្គាល់នៃឃុំ សង្កាត់ ដែលអ្នកត្រូវបានតែងតាំង ។

៩.៣.១៤.៤ ចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលត្រូវធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.៣.១៤.៥ ល័ក្ខខ័ណ្ឌការងារ ភារកិច្ច និងការទទួលខុសត្រូវនៃអ្នកដែលត្រូវតែងតាំង ។

៩.៣.១៤.៦ ប្រាក់កំរៃដែលត្រូវទទួល ។

៩.៣.១៤.៧ ការសន្យាយល់ព្រមទទួលភារកិច្ច ល័ក្ខខ័ណ្ឌការងារ និងប្រាក់កំរៃ ។

៩.៣.១៤.៨ ការសន្យាថា នឹងអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត និងមិនលំអៀង ។

៩.៣.១៤.៩ ការសន្យាថា នឹងអនុវត្តតាមច្បាប់បោះឆ្នោត បទបញ្ជានិងនីតិវិធី និងរាល់សេចក្តីណែនាំរបស់ គជប ។

៩.៣.១៤.១០ហត្ថលេខារបស់អ្នកដែលត្រូវតែងតាំង ហត្ថលេខារបស់សាក្សីដឹងឮ និងហត្ថលេខារបស់មេឃុំ ចៅសង្កាត់ ។

៩.៣.១៥ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំជាបន្ទាន់នូវលិខិតស្នើសុំតែងតាំងស្មៀនឃុំ សង្កាត់ជាមន្ត្រីទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងសុំតែងតាំងជំនួយការស្មៀនតាមចំនួនដែលបានកំណត់ ស្របពេលជាមួយគ្នា ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាការងារ ( ទម្រង់បែបបទលេខ ១០០១ ) ដែលបានបំពេញ និងចុះហត្ថលេខារួចម្នាក់ៗមួយ( ០១ )ច្បាប់ រួចផ្ញើជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ដើម្បីចេញសេចក្តីសម្រេចតែងតាំងជាផ្លូវការ ។

៩.៣.១៥.១ គជប ត្រូវពិនិត្យនិងចេញសេចក្តីសម្រេចតែងតាំងស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន ជាមន្ត្រីចុះឈ្មោះបោះឆ្នោតជាបន្ទាន់ ហើយត្រូវរក្សាទុកឯកសារនៃបញ្ជីឈ្មោះមន្ត្រីទាំងនោះជាផ្លូវការ ។

៩.៣.១៥.២ បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ គជប ដូចចែងក្នុងចំណុច ៩.៣.១៥.១ ខាងលើ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញ និងផ្តល់

ប័ណ្ណសម្គាល់ខ្លួនជូនស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនម្នាក់ៗ សម្រាប់ពេលបំពេញភារកិច្ចក្នុងអាណត្តិការងាររបស់ខ្លួន ។

៤.៣.១៦ ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន ដែលបានទទួលការតែងតាំងឱ្យបំពេញការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវស្ថិតក្នុងមុខតំណែង តាមការកំណត់របស់ គជប ។

៤.៣.១៧ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ចែងឱ្យមានកំលាំងរក្សាសណ្តាប់ធ្នាប់តាមលទ្ធភាព និងការចាំបាច់ សម្រាប់សម្រួលដល់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។ ការចាត់ចែងប្រើប្រាស់កំលាំងរក្សាសណ្តាប់ធ្នាប់នេះ ស្ថិតក្នុងសមត្ថកិច្ច និងបន្ទុកដោះស្រាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ក្នុងករណី ការិយាល័យចុះឈ្មោះបោះឆ្នោតបើកនៅទីតាំងតាមភូមិ កំលាំងរក្សាសណ្តាប់ធ្នាប់អាចជាកំលាំងដែលផ្តល់ឱ្យដោយប្រធានភូមិ ។

៤.៣.១៧.១ កំលាំងរក្សាសណ្តាប់ធ្នាប់ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការណែនាំរបស់ស្មៀនឃុំ សង្កាត់ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោត ។

៤.៣.១៧.២ កំលាំងរក្សាសណ្តាប់ធ្នាប់ ត្រូវទទួលភារកិច្ចសម្រួលសណ្តាប់ធ្នាប់សម្រាប់ប្រជាពលរដ្ឋ ដែលចូលមកកាន់ការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីសុំចុះឈ្មោះបោះឆ្នោត ។

៤.៣.១៧.៣ កំលាំងរក្សាសណ្តាប់ធ្នាប់ ត្រូវធានាយ៉ាងណាឱ្យមានអ្នកសុំចុះឈ្មោះអ្នកបោះឆ្នោតចំនួនយ៉ាងច្រើនត្រឹមបី(៣)នាក់ ក្នុងពេលតែមួយ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។ នៅពេលអ្នកសុំចុះឈ្មោះម្នាក់ចេញពីការិយាល័យ ទើបអនុញ្ញាតឱ្យម្នាក់ទៀតចូល ។

៤.៣.១៧.៤ កំលាំងរក្សាសណ្តាប់ធ្នាប់ ត្រូវផ្តល់អាទិភាពពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតចំពោះព្រះសង្ឃ មនុស្សចាស់ ស្ត្រីមានកូនតូច ស្ត្រីមានផ្ទៃពោះ និងជនពិការ ។

៤.៣.១៧.៥ កំលាំងរក្សាសណ្តាប់ធ្នាប់ ត្រូវអនុញ្ញាតឱ្យចូលការិយាល័យចុះឈ្មោះបោះឆ្នោត នូវអ្នកជំនួយជាញាតិជនម្នាក់ដែលជូនដំណើរជនពិការណាម្នាក់ ដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតបានដោយខ្លួនឯង ។

៤.៣.១៧.៦ កំលាំងរក្សាសណ្តាប់ធ្នាប់នេះ មិនត្រូវបានបំពាក់អាវុធទេ ។

៤.៣.១៧.៧ ក្នុងករណីមានការអុកឡុករំខានពីជនណាម្នាក់ កំលាំងរក្សាសណ្តាប់ធ្នាប់ត្រូវរាយការណ៍ជាបន្ទាន់ជូនស្មៀនឃុំ សង្កាត់ ដើម្បីមានវិធាន

ការស្នើសុំកិច្ចអន្តរាគមន៍ ពីភ្នាក់ងារសន្តិសុខ ឬ/និង អាជ្ញាធរមានសមត្ថកិច្ច ។

៨.៣.១៨ ដើម្បីធានាក្នុងការបំពេញការងារ នៅថ្ងៃមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ ជំនួយការស្មៀន កំលាំងរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ ព្រមទាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវតែងតាំងឱ្យត្រួតពិនិត្យមើលការខុសត្រូវលើការងាររបស់ស្មៀន ត្រូវមកជួបជុំគ្នានៅសាលាឃុំ សង្កាត់ ដើម្បីបង្ហាញខ្លួន និងពិនិត្យសម្ភារៈឯកសារ ដែលត្រូវប្រើក្នុងការចុះឈ្មោះបោះឆ្នោត ។

៨.៣.១៩ ស្មៀនឃុំ សង្កាត់ដែលទទួលបន្ទុកការងារពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវរាយការណ៍ជាបន្ទាន់អំពីការខកខានមិនបានមកបំពេញការងាររបស់សមាសភាពមន្ត្រីណាម្នាក់ដូចបញ្ជាក់ក្នុងចំណុច ៨.៣.១៨ ខាងលើ ឬ/និង អំពីសកម្មភាពល្មើសឬខុសឆ្គងរបស់សាមីជន ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីមានវិធានការបានទាន់ពេលវេលា ។ ផ្អែកតាមរបាយការណ៍របស់ស្មៀនឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសតាំង ឬ ចាត់ចែងអ្នកថ្មីជំនួសអ្នកដែលមិនអាចមកបំពេញការងារបាននោះជាបន្ទាន់ ។ ក្នុងករណី អ្នកដែលមិនអាចមកបំពេញការងារជាជំនួយការស្មៀន ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសតាំងជំនួយការស្មៀនថ្មីជំនួស ប្រសិនបើ ៖

៨.៣.១៩.១ ជំនួយការស្មៀននោះបានល្មើសនឹងច្បាប់ ឬបទបញ្ជានិងនីតិវិធី ឬពុំបានប្រតិបត្តិតាមសេចក្តីណែនាំរបស់ គជប ដោយអនុលោមតាមច្បាប់បោះឆ្នោត ។

៨.៣.១៩.២ ជំនួយការស្មៀននោះត្រូវបានគេរកឃើញភស្តុតាងបញ្ជាក់ថា ជាជនដែលមានឋានៈ តួនាទី ឬមុខតំណែង ដូចមានចែងក្រោមចំណុច ៨.៣.១១ ខាងលើ ។

៨.៣.១៩.៣ ជំនួយការស្មៀននោះគ្មានលទ្ធភាពមកបំពេញការងារ ដោយមូលហេតុណាមួយ ដែលបណ្តាលឱ្យរាំងស្ទះដល់ដំណើការ នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ មូលហេតុសម្រាប់គោលដៅនៃប្រការនេះគឺ ៖

- ភាពគ្មានលទ្ធភាព ដោយសារតែគាត់មានជំងឺឈឺចាប់កើតឡើងបណ្តាលឱ្យគាត់មានបញ្ហាខាងសុខភាព ដែលរារាំងគាត់មិនអាច

បំពេញភារកិច្ចបានមួយរយៈពេល ឬ ក្នុងអំឡុងពេលទាំងមូល នៃដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

- ភាពគ្មានលទ្ធភាពដោយសារតែគាត់មានជំងឺឆ្លងកើតឡើង ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ឆ្លងដល់អ្នកបំពេញភារកិច្ច ក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬឆ្លងដល់អ្នកមកសុំចុះឈ្មោះបោះឆ្នោត។
- ភាពគ្មានលទ្ធភាពដោយសារតែគាត់បានប្រព្រឹត្តខុស ដូចដែលបានចែងក្នុងចំណុច ៩.៣.១៩.១ និង ៩.៣.១៩.២ ខាងលើ ឬដោយសារតែមានរបួស ឬក៏មានមូលហេតុដទៃទៀត ដែលរារាំងគាត់មិនឱ្យមកបំពេញការងារបាន នៅការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងអំឡុងម៉ោងធ្វើការ ។
- ការដែលជំនួយការស្មៀននោះត្រូវបានចាប់ខ្លួន ឬឃុំខ្លួនដោយខុសច្បាប់ ត្រូវបានចាត់ទុកជាភាពគ្មានលទ្ធភាពបំពេញការងារមួយរបស់គាត់ ប៉ុន្តែមិនត្រូវបានចាត់ទុកជាមូលហេតុដើម្បីដាក់ពិន័យខាងហិរញ្ញវត្ថុឡើយ ។

៩.៣.១៩.៤ ជំនួយការស្មៀននោះត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តបទល្មើសនៅក្នុងអំឡុងពេលបំពេញភារកិច្ចនិងត្រូវទទួលទោសតាមអំពើល្មើស ។ បទល្មើស គឺសំដៅលើអំពើលួច ប្លន់ ឆបោក ឬក្លែងបន្លំ ឬបទល្មើសផ្សេងទៀត ដែលមានចែងក្រោមច្បាប់បោះឆ្នោតនិងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា ។

៩.៣.១៩.៥ ជំនួយការស្មៀននោះបានចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពនយោបាយជាសាធារណៈ បន្ទាប់ពីត្រូវបានតែងតាំងជាមន្ត្រីចុះឈ្មោះបោះឆ្នោត ។

៩.៣.២០ បន្ទាប់ពីបានជ្រើសរើសអ្នកថ្មីសម្រាប់ជំនួសតំណែងជំនួយការស្មៀន ដែលមិនអាចមកបំពេញការងារបាន ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសំណុំលិខិតពាក់ព័ន្ធនឹងការជ្រើសតាំងអ្នកជំនួសតាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ទៅ

គជប ដើម្បីសុំសេចក្តីសម្រេចតែងតាំងជាផ្លូវការ ។ ក្នុងការជ្រើសតាំងអ្នកជំនួសតំណែងមន្ត្រីចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តតាមការកំណត់ ដូចខាងក្រោម ៖

៤.៣.២០.១ ប្រសិនបើ ស្មៀនឃុំ សង្កាត់មិនបានមកបំពេញការងារ ដោយសារមូលហេតុសំខាន់ណាមួយនោះ ជំនួយការស្មៀនដែលបានតែងតាំងបំរុង ត្រូវបានតែងតាំងឱ្យទទួលបំពេញភារកិច្ចជំនួសស្មៀន ក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ហើយអ្នកដែលត្រូវជ្រើសរើសថ្មី ត្រូវចូលកាន់តំណែងជំនួសជំនួយការស្មៀនជាបន្ទាន់ ។

៤.៣.២០.២ ប្រសិនបើ អ្នកដែលមិនអាចមកធ្វើការបានជាជំនួយការស្មៀននោះ ត្រូវជ្រើសតាំងអ្នកថ្មីឱ្យចូលកាន់តំណែងជំនួយការស្មៀន ។

៤.៣.២០.៣ អ្នកដែលបានជ្រើសតាំងថ្មីទាំងអស់ ត្រូវតែបានទទួលការហ្វឹកហ្វឺនសិក្សាស្រាវជ្រាវអំពីបទបញ្ជានិងនីតិវិធីរបស់ គជប និងសៀវភៅណែនាំស្តីពីការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ដែលធានាថាអាចយល់ដឹងបាន និងអាចអនុវត្តភារកិច្ចរបស់ខ្លួនបាន ។

៤.៣.២០.៤ ការបំពេញទម្រង់បែបបទកិច្ចសន្យាការងារ និងការរៀបចំលិខិតស្នើសុំតែងតាំងមន្ត្រីចុះឈ្មោះបោះឆ្នោត ដែលត្រូវជ្រើសតាំងថ្មីជំនួសត្រូវអនុវត្តដូចការបំពេញបែបបទស្នើសុំតែងតាំងស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន នាពេលដំបូងដែរ ។

៤.៣.២១ ប្រសិនបើ ស្មៀនឃុំ សង្កាត់ត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តល្មើស ឬខុសឆ្គង ដូចចែងក្រោមចំណុច ៤.៣.១៩ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលតាមពិនិត្យមើលការខុសត្រូវលើការងារស្មៀន និងជំនួយការស្មៀនត្រូវរាយការណ៍អំពីអំពើល្មើស ឬកំហុសឆ្គងនោះ ជូនក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានឆាប់រហ័ស ។

៤.៣.២២ ប្រសិនបើ អំពើល្មើសរបស់មន្ត្រីចុះឈ្មោះបោះឆ្នោតជារួម មានលក្ខណៈជាអំពើឧក្រិដ្ឋ ដែលស្ថិតនៅក្រោមបញ្ញត្តិច្បាប់ណាមួយ ហើយប្រសិនបើ មានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនល្មើសបាន គជប ត្រូវបញ្ជូនជនល្មើសទៅតុលាការដើម្បីកាត់ទោស លើកលែងតែយោងបទប្បញ្ញត្តិខ្លះនៃច្បាប់បោះឆ្នោត ដែលតម្រូវឱ្យ គជប ដាក់វិធានការ ឬពិន័យចំពោះជនល្មើស ។

៤.៣.២៣ ប្រសិនបើ ជនល្មើសជាមន្ត្រីចុះឈ្មោះបោះឆ្នោត ត្រូវបានផ្តន្ទាទោសចំពោះអំពើល្មើសដូចចែងក្នុងចំណុច ៤.៣.២២ ខាងលើ អនុលោមតាមមាត្រា ១២២ថ្មី

១២៥ថ្មី ១២៦ថ្មី និង ១២៧ថ្មី នៃច្បាប់បោះឆ្នោត គជប ត្រូវដកហូតសិទ្ធិបោះឆ្នោតរបស់សាមីជន ហើយត្រូវលុបឈ្មោះសាមីជនចេញពីបញ្ជីបោះឆ្នោត នៃឃុំ សង្កាត់ សម្រាប់រយៈពេលដូចបានកំណត់ដោយច្បាប់ ។

**ការទទួលខុសត្រូវ និងភារកិច្ចរបស់មន្ត្រីចុះឈ្មោះបោះឆ្នោត** ( ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន )

**ប្រការ ៩.៤** អនុលោមតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី និងសេចក្ដីសម្រេចផ្សេងទៀតដែលបានកំណត់ដោយ គជប ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ត្រូវទទួលខុសត្រូវអនុវត្តរាល់កិច្ចប្រតិបត្តិការបំរើឱ្យគោលបំណងនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៩.៤.១ ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ត្រូវ ៖

៩.៤.១.១ គោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីស្ដីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.៤.១.២ ប្រកាន់ជំហរអព្យាក្រឹត និងមិនលំអៀងក្នុងពេលបំពេញការងារ ។

៩.៤.១.៣ ចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.៤.១.៤ យល់ដឹងយ៉ាងច្បាស់លាស់ និង ចេះម្ចាស់ការបានលើរាល់នីតិវិធីពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.៤.១.៥ ចេះចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យជនគ្រប់រូបបានចូលរួមប្រកបដោយសុវត្ថិភាព គ្មានការភ័យខ្លាច ឬការបំភិតបំភ័យ ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនទទួលខុសត្រូវ សំដៅធ្វើឱ្យដំណើរការនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ។

៩.៤.១.៦ ចេះបំពេញទម្រង់បែបបទពាក់ព័ន្ធផ្សេងៗដែលបានកំណត់ និងចេះធ្វើរបាយការណ៍បានច្បាស់លាស់ ។

៩.៤.១.៧ រក្សាការសម្ងាត់នៃព័ត៌មាន របស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដែលទទួលបានក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.៤.២ ការទទួលខុសត្រូវ និងភារកិច្ចរបស់ស្មៀនឃុំ សង្កាត់ ដែលទទួលបន្ទុកការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត រួមមាន ៖

៤.៤.២.១ បំពេញរាល់ការងារត្រៀមសំរាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដូចជាការស្រង់ស្ថិតិប្រជាពលរដ្ឋ ការស្រង់ឈ្មោះអ្នកត្រូវចុះឈ្មោះបោះឆ្នោត ការស្រង់ឈ្មោះអ្នកបោះឆ្នោត ដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត... តាមសេចក្ដីណែនាំរបស់ គជប ។

៤.៤.២.២ បិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ដើម្បីបំរើការពិនិត្យមើលឈ្មោះនៃអ្នកបោះឆ្នោត នៅសាលាឃុំ សង្កាត់ និងនៅតាមទីតាំងការិយាល័យបោះឆ្នោតដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះ ត្រូវបានផ្តល់សុពលភាពចុងក្រោយ ។

៤.៤.២.៣ ធ្វើគំរូប្លង់ និងធានាថា ការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវបានសំអាត និងថែរក្សាសុវត្ថិភាពបានល្អ ។

៤.៤.២.៤ ត្រួតពិនិត្យ និង គ្រប់គ្រងបរិមាណ និងគុណភាពសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត ។

៤.៤.២.៥ ថែរក្សាសុវត្ថិភាពសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត មុនពេលចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត និងបន្តពិនិត្យតាមដាននៅពេលបញ្ឈប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃនីមួយៗ ។

៤.៤.២.៦ ត្រួតពិនិត្យតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ដែលមានការបញ្ជាក់ទទួលស្គាល់រួចហើយ ។

៤.៤.២.៧ ត្រួតពិនិត្យ គ្រប់គ្រង និងអនុវត្តដោយផ្ទាល់នូវរាល់ដំណើរការ និងជំហាននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ត្រូវចាត់ចែងជំនួយការរបស់ខ្លួនឱ្យជួយបំពេញការងារផ្សេងៗតាមការចាំបាច់ ដើម្បីធានាឱ្យបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ ក្នុងឃុំ សង្កាត់ ត្រូវបានធ្វើបច្ចុប្បន្នភាពរួចយ៉ាងត្រឹមត្រូវ ។

៤.៤.២.៨ ទទួលសម្ភាសន៍ និងពិនិត្យភស្តុតាងដែលអ្នកសុំចុះឈ្មោះបានបង្ហាញបញ្ជាក់លក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោត ព្រមទាំងធ្វើការសំរេចអំពីភាពគ្រប់គ្រាន់ នៃលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោត និងយល់ព្រមចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋដែលមកបង្ហាញខ្លួនសុំចុះឈ្មោះបោះឆ្នោត ។

៤.៤.២.៩ បំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោត និង ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ជូនអ្នកដែលមានគ្រប់លក្ខណៈវិនិច្ឆ័យចុះឈ្មោះបោះឆ្នោត ។

៤.៤.២.១០ កត់ត្រាឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតថ្មី និងទិន្នន័យពាក់ព័ន្ធដែលបានតម្រូវឱ្យបំពេញទៅក្នុងបញ្ជីបោះឆ្នោតបន្ថែម ។ ត្រូវជំរាបអ្នកដែលទើបបានចុះឈ្មោះ ឱ្យចងចាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដើម្បីងាយស្រួល ក្នុងការពិនិត្យបញ្ជីឈ្មោះប្រចាំឆ្នាំ ។ ដោយឡែក ចំពោះឆ្នាំមានការបោះឆ្នោត ត្រូវជំរាបគាត់ឱ្យយកទៅជាមួយនូវឯកសារផ្លូវការបញ្ជាក់អត្តសញ្ញាណ ដើម្បីបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។

៤.៤.២.១១ ទទួលសម្ភាសន៍ និងពិនិត្យភស្តុតាងដែលអ្នកសុំចុះឈ្មោះបានបង្ហាញ ហើយធ្វើការសំរេចអំពីភាពមិនគ្រប់គ្រាន់ នៃលក្ខណៈវិនិច្ឆ័យរបស់អ្នកសុំចុះឈ្មោះ និងបដិសេធការសុំចុះឈ្មោះបោះឆ្នោតនោះ ប្រសិនបើ គាត់ពុំមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ សម្រាប់ការចុះឈ្មោះបោះឆ្នោត ដោយត្រូវផ្អែកតាម ៖

- យោបល់របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រចាំការមើលការខុសត្រូវការងារស្មៀន ចំពោះឃុំ សង្កាត់ដែលបានចាត់សមាជិកមួយ(១)រូប ឬ
- យោបល់ភាគច្រើន ពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រចាំការមើលការខុសត្រូវនិងស្មៀនឃុំសង្កាត់ចំពោះឃុំ សង្កាត់ដែលបានចាត់សមាជិកពីរ(២)រូប ។

៤.៤.២.១២ បំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត សម្រាប់ករណីដូចចែងក្នុងចំណុច ៤.៤.២.១១ ខាងលើ រួចចុះហត្ថលេខាកាលបរិច្ឆេទ និងប្រគល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោតមួយ ( ១ ) ច្បាប់ ជូនអ្នកសុំចុះឈ្មោះ ដែលការសុំចុះឈ្មោះរបស់គាត់ត្រូវបានបដិសេធ រួចជម្រាបគាត់ថា គាត់ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេលបី ( ៣ )ថ្ងៃ បន្ទាប់ពីថ្ងៃចេញសេចក្តីសំរេចបដិសេធ ។ បន្ទាប់មកត្រូវផ្តល់ជូនគាត់ នូវទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាចំនួនបួន(៤)ច្បាប់ ប្រសិនបើគាត់ស្នើសុំ ។

៤.៤.២.១៣ បំពេញទម្រង់បែបបទលុបឈ្មោះអ្នកបោះឆ្នោត ដែលមានភស្តុតាងជាឯកសារផ្លូវការថា បានស្លាប់ ឬផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ ជាស្ថាពរ ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល ឬត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារ ឬគ្មានទីលំនៅក្នុងឃុំ សង្កាត់ និងត្រូវគូសបន្ទាត់លុបឈ្មោះជននោះ ចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ។ ក្នុងករណីអ្នកសុំចុះឈ្មោះធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែជាអ្នកបានផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ ឬជាអ្នកចង់ប្តូរការិយាល័យបោះឆ្នោត ដោយមូលហេតុការិយាល័យមុនស្ថិតនៅឆ្ងាយពីទីលំនៅរបស់សាមីខ្លួន ត្រូវបំពេញទម្រង់បែបបទលុបឈ្មោះអ្នកបោះឆ្នោតនោះ និងឱ្យជននោះផ្តិតមេដៃជាសំគាល់ផង ដើម្បីអនុញ្ញាតឱ្យលុបឈ្មោះជននោះចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលបង្ការកុំឱ្យមានការចុះឈ្មោះបោះឆ្នោតលើសពីម្តង ។ ក្នុងករណីមានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតតែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់តែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់ផ្សេង ត្រូវបំពេញបែបបទលុបឈ្មោះ និងរក្សាឈ្មោះតាមការណែនាំរបស់ គជប ។

៤.៤.២.១៤ ធ្វើបច្ចុប្បន្នភាពដោយរក្សាទុកឈ្មោះអ្នកបោះឆ្នោត ក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ចំពោះអ្នកបោះឆ្នោតណាដែលមិនស្ថិតក្នុងករណីដូចចែងក្នុងចំណុច ៤.៤.២.១៣ ខាងលើ បើទោះបីជាជនពាក់ព័ន្ធមិនបានមកបង្ហាញខ្លួនសុំចុះឈ្មោះចំពោះមុខស្មៀនឃុំ សង្កាត់ក្តី ។

៤.៤.២.១៥ ថែរក្សាទុកជាឯកសាររបស់ខ្លួន នូវរាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត រាល់ទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត រាល់សេចក្តីសំរេចដោះស្រាយលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ និងឯកសារពាក់ព័ន្ធផ្សេងទៀតមួយមុខមួយច្បាប់ៗ ។

៤.៤.២.១៦ ធានាថា បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗ ក្នុងឃុំ សង្កាត់ មានអ្នកបោះឆ្នោតមិនលើសពីប្រាំពីររយ(៧០០)នាក់ទេ ។

៤.៤.២.១៧ ដោះស្រាយជាបន្ទាន់នូវរាល់ការតវ៉ា និងការជំទាស់ចំពោះការរំលោភនានា នៅក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលអាចលើកឡើងដោយសមាជិកក្រុមប្រឹក្សាដែលប្រចាំ

ការពិនិត្យមើលការខុសត្រូវលើការងារស្មៀនឃុំ សង្កាត់ ឬតំណាងគណបក្សនយោបាយ ឬជំនួយការស្មៀន ។

៨.៩.២.១៨ ធ្វើរបាយការណ៍ផ្ទៀងផ្ទាត់លទ្ធផល នៃការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ និងរបាយការណ៍សរុបចុងក្រោយសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ និងសម្រាប់ឃុំ សង្កាត់ទាំងមូល នៅពេលដែលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ ។

៨.៩.២.១៩ បិទផ្សាយបញ្ជីបោះឆ្នោតដំបូងមួយច្បាប់នៅសាលាឃុំ សង្កាត់ ព្រមទាំងបែងចែកនិងបិទផ្សាយមួយច្បាប់ៗរៀងខ្លួននៅតាមទីតាំងការិយាល័យបោះឆ្នោត ដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះត្រូវបានផ្តល់សុពលភាពផ្លូវការចុងក្រោយ និងនៅតាមទីតាំងការិយាល័យដែលបានកែសម្រួល ឬបានបង្កើតថ្មី ប្រសិនបើមាន ។

៨.៩.២.២០ ធានាដោយផ្ទាល់ខ្លួន ក្នុងការផ្ទៀងផ្ទាត់ ការវេចខ្ចប់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗ និងការប្រគល់បញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួចក្នុងឃុំ សង្កាត់ ដោយមានភ្ជាប់មកជាមួយនូវរាល់ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះ ការលុបឈ្មោះ និងការប្តឹងតវ៉ា ព្រមទាំងទម្រង់បែបបទចុះឈ្មោះបោះឆ្នោត/គល់សន្លឹកបង្កាន់ដៃដែលបានប្រើ ទម្រង់បែបបទចុះឈ្មោះបោះឆ្នោតដែលនៅសល់មិនទាន់ប្រើប្រាស់ និងសម្ភារៈឯកសារនៅសល់ផ្សេងទៀត ជូនមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៨.៩.២.២១ ចូលរួមបំភ្លឺក្នុងរាល់ការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដោះស្រាយបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ និង ធ្វើរបាយការណ៍កែតម្រូវលើបញ្ជីបោះឆ្នោតដំបូង ដោយផ្អែកលើសេចក្តីសំរេចដោះស្រាយលើពាក្យបណ្តឹង ប្រសិនបើមាន ។

៨.៩.២.២២ ធានាឱ្យអ្នកសង្កេតការណ៍ និងតំណាងគណបក្សនយោបាយ ដែលមានការបញ្ជាក់ទទួលស្គាល់ មានលទ្ធភាពសង្កេតការណ៍ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅគ្រប់ការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៩.៩.២.២៣ សុំកិច្ចអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬអាជ្ញាធរមានសមត្ថកិច្ចឱ្យនាំខ្លួនជនទាំងឡាយណា ដែលបង្កការអុកឡុក វំខាន ឬធ្វើសកម្មភាពផ្ទុយពីការកំណត់របស់ច្បាប់ ឬបទបញ្ជា និងនីតិវិធីរបស់ គជប ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.៩.២.២៤ សំណូមពរភ្នាក់ងារសង្គ្រោះ ឱ្យជួយដល់ជនទាំងឡាយណា ដែលទទួលរងគ្រោះដោយមូលហេតុណាមួយ ក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។

៩.៩.២.២៥ អនុវត្តការងារដទៃទៀត ដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ព្រមទាំងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៩.៩.៣ ការទទួលខុសត្រូវ និងភារកិច្ចរបស់ជំនួយការស្មៀនឃុំ សង្កាត់ ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត រួមមាន ៖

៩.៩.៣.១ បំពេញការងារតាមការបង្គាប់ និងការណែនាំរបស់ស្មៀនឃុំ សង្កាត់ ក្នុងភារកិច្ចពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.៩.៣.២ ជួយស្មៀនក្នុងការធ្វើគំរូប្លង់ និងធានាក្នុងការសំអាតការិយាល័យចុះឈ្មោះបោះឆ្នោត ។

៩.៩.៣.៣ ជួយស្មៀន ក្នុងការរៀបចំសម្ភារៈឯកសារចុះឈ្មោះសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ក្នុងការរៀបចំទុកដាក់សម្ភារៈឯកសារចុះឈ្មោះនៅពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៃថ្ងៃនីមួយៗ ព្រមទាំងក្នុងការគ្រប់គ្រង និងថែរក្សាសុវត្ថិភាពសម្ភារៈឯកសារទាំងនោះ ។

៩.៩.៣.៤ ជួយស្មៀន ក្នុងការពិនិត្យផ្ទៀងផ្ទាត់ឈ្មោះលើបញ្ជីបោះឆ្នោត ដោយផ្អែកតាមសំណូមពររបស់អ្នកបោះឆ្នោត ដូចជា ៖

- ការរកឈ្មោះដែលបានចុះឈ្មោះរួចហើយ ដើម្បីកត់ចំណាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត
- ការកែតម្រូវឈ្មោះនិងទិន្នន័យពាក់ព័ន្ធដែលសរសេរខុស
- ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយយោងមូលហេតុស្លាប់ ឬបាត់បង់សិទ្ធិបោះឆ្នោត ឬផ្លាស់ទីលំនៅចេញ ឬគ្មានទីលំនៅក្នុងឃុំ សង្កាត់ ឬសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំសង្កាត់តែមួយ ។ ក្នុងករណី ត្រូវកែតម្រូវអក្ខរាវិរុទ្ធ ឬលុប

ឈ្មោះអ្នកបោះឆ្នោតណាម្នាក់ ចាំបាច់ត្រូវតែមានការសំរេចរបស់ស្មៀនឃុំ សង្កាត់ ។

៤.៤.៣.៤ ជួយស្មៀន ក្នុងការសរសេរចម្លងឈ្មោះអ្នកដែលត្រូវបានយល់ព្រមចុះឈ្មោះបោះឆ្នោតថ្មី នៅលើបញ្ជីបោះឆ្នោតបន្ថែមទាំងបួន(៤)ច្បាប់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៤.៤.៣.៥ ជួយស្មៀន ក្នុងការស្រង់ ផ្ទៀងផ្ទាត់ និងធ្វើរបាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមថ្ងៃនីមួយៗ និងក្នុងការធ្វើរបាយការណ៍សរុបសម្រាប់ការិយាល័យនីមួយៗ និងសម្រាប់ឃុំ សង្កាត់ទាំងមូល ។

៤.៤.៣.៦ ជួយស្មៀនក្នុងការបិទផ្សាយចំនួនពីរ(២)លើក នូវបញ្ជីបោះឆ្នោតចុងក្រោយ និង បញ្ជីបោះឆ្នោតដំបូងមួយច្បាប់ៗនៅសាលាឃុំ សង្កាត់ និងមួយច្បាប់ៗរៀងខ្លួន នៅតាមទីតាំងការិយាល័យបោះឆ្នោតពាក់ព័ន្ធក្នុងឃុំ សង្កាត់ តាមកាលបរិច្ឆេទកំណត់របស់ គជប ។

៤.៤.៣.៧ អនុវត្តភារកិច្ចដទៃទៀតដែលតម្រូវដោយច្បាប់ ឬបទបញ្ជា និងនីតិវិធីរបស់ គជប ។

**សម្ភារៈឯកសារសម្រាប់បំរើកិច្ចប្រតិបត្តិការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

**ប្រការ ៤.៥** គជប ត្រូវធានាការផ្គត់ផ្គង់សម្ភារៈឯកសារគ្រប់គ្រាន់ សម្រាប់បំរើកិច្ចប្រតិបត្តិការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឱ្យបានទាន់ពេលវេលា ។ នាយកដ្ឋានប្រតិបត្តិការត្រូវផ្គត់ផ្គង់ហិបសម្ភារៈឯកសារសម្រាប់បណ្តុះបណ្តាលជូននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈឱ្យបានទាន់ពេលវេលា និងត្រូវផ្គត់ផ្គង់ហិបសម្ភារៈឯកសារសម្រាប់ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់គ្រាន់ ដល់លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ដែលទទួលបន្ទុកការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៤.៥.១ នាយកដ្ឋានប្រតិបត្តិការ ( មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ) ត្រូវទទួលខុសត្រូវក្នុងការបោះពុម្ពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ ដែលបានផ្តល់សុពលភាពជាផ្លូវការចុងក្រោយ ដើម្បីបំរើគោលដៅនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជាប្រចាំឆ្នាំ ។ ក្នុងនោះ ត្រូវធានាថា ៖

៤.៥.១.១ បញ្ជីបោះឆ្នោតចុងក្រោយត្រូវតែបានបោះពុម្ពដោយឡែកពីគ្នា តាមការិយាល័យបោះឆ្នោតនីមួយៗ និងរៀបចំក្នុងទម្រង់ឯកភាពគ្នាតែ

មួយដែលរួមមាន ឈ្មោះនិងលេខកូដខេត្ត ក្រុង ឈ្មោះនិងលេខកូដឃុំ សង្កាត់ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត កូនប្រអប់សម្រាប់គូសសំគាល់ លេខរៀងនៃឈ្មោះក្នុងបញ្ជី លេខសំគាល់ផ្ទាល់ខ្លួន ( លេខប័ណ្ណ ឬ លេខបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ) នាមត្រកូល និងនាមខ្លួនដែលរៀបចំតាមលំដាប់អក្ខរក្រមខ្មែរ ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋានក្នុងឃុំ សង្កាត់នៃអ្នកបោះឆ្នោត និងប្រឡោះទំនេរសម្រាប់ចារសម្គាល់ផ្សេងៗ ។

៩.៥.១.២ នៅទំព័រចុងក្រោយរបស់បញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនីមួយៗ ត្រូវតែមានចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប បញ្ជាក់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការចុងក្រោយ ។ នៅគ្រប់ទំព័រផ្សេងទៀតនៃបញ្ជីបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានបោះត្រា គជប ។

៩.៥.១.៣ បញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោតទាំងអស់ ដែលបានបោះពុម្ព ចុះហត្ថលេខានិងបោះត្រា រួចតាមចំណុច ៩.៥.១.១ និង ៩.៥.១.២ ខាងលើ ត្រូវតែបានថតចម្លងបន្ថែមចំនួនប្រាំមួយ ( ៦ ) ច្បាប់ រួចរៀបចំតាមលំដាប់លេខកូដនៃការិយាល័យបោះឆ្នោត ក្នុងឃុំសង្កាត់នីមួយៗ និងវេចខ្ចប់ដោយឡែកពីគ្នាតាមឃុំសង្កាត់ ។

៩.៥.១.៤ ច្បាប់ដើមនៃបញ្ជីបោះឆ្នោតចុងក្រោយ នៃការិយាល័យបោះឆ្នោតមួយ (១)ច្បាប់ ត្រូវបានរក្សាទុកជាឯកសារនៅមជ្ឈមណ្ឌលកុំព្យូទ័រ នៃ គជប ។ ចំណែកច្បាប់ចម្លងប្រាំមួយ(៦)ច្បាប់ទៀត ត្រូវវេចខ្ចប់ និងប្រគល់ឱ្យផ្នែកភស្តុភារធ្វើការបែងចែក និង បញ្ជូនទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ / ស្មៀនឃុំ សង្កាត់ពាក់ព័ន្ធនីមួយៗ ចំណុះខេត្ត ក្រុង ។

៩.៥.២ នាយកដ្ឋានប្រតិបត្តិការ (ផ្នែកប្រតិបត្តិការ និងផ្នែកភស្តុភារ) ត្រូវកសាងគំរោងផែនការផ្គត់ផ្គង់ បែងចែក បញ្ជូន និងត្រៀមសម្ភារៈឯកសារ សម្រាប់បំរើកិច្ចប្រតិបត្តិការនៃការពិនិត្យបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ឱ្យបានគ្រប់គ្រាន់ជាមុន ។

៤.៥.៣ សម្ភារៈឯកសារសម្រាប់បំរើកិច្ចប្រតិបត្តិការ នៃការពិនិត្យបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ត្រូវបានរៀបចំដាក់ក្នុងហិបបរិក្ខារដែលរួមមាន ៣ ប្រភេទគឺ ៖

៤.៥.៣.១ ហិបបរិក្ខារសម្រាប់វគ្គបណ្តុះបណ្តាល ( Training Kit ) ដែលត្រូវបញ្ជូន និងប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ និងលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៤.៥.៣.២ ហិបបរិក្ខារសម្រាប់លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ( Provincial Secretariat Kit ) ដែលអាចមានមួយ ឬ ច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូនមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៤.៥.៣.៣ ហិបបរិក្ខារសម្រាប់ការចុះឈ្មោះ ( Registration Kit ) ដែលអាចមានមួយ ឬច្រើន ហើយដែលត្រូវបញ្ជូន និងប្រគល់មួយផ្នែកទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងមួយផ្នែកទៀតទៅឱ្យស្មៀនឃុំ សង្កាត់ សម្រាប់ប្រើប្រាស់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៤.៥.៣.៤ នៅរាល់ពេលនៃការបញ្ជូននិងប្រគល់ទទួលហិបបរិក្ខារ ដូចបានចែងក្រោមចំណុច ៤.៥.៣ ខាងលើ មន្ត្រីដែលទទួលបន្ទុកការបញ្ជូននៅតាមថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជាក់ការបញ្ជូន និងការប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) និងត្រូវឱ្យមន្ត្រី ដែលទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗ ចុះហត្ថលេខាបញ្ជាក់ថា បានទទួលរួចហើយ ។

៤.៥.៤ សម្ភារៈ និងឯកសារ ដែលមាននៅក្នុងហិបបរិក្ខារសម្រាប់លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត រួមមាន ៖

ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ បំរុងសម្រាប់ខេត្តក្រុង ( មានតារាងបែងចែកដោយឡែក ) ។

ទម្រង់បែបបទសម្រាប់បំពេញបញ្ជីបោះឆ្នោតបន្ថែម បំរុងសម្រាប់ខេត្ត ក្រុង ( មានតារាងបែងចែកដោយឡែក ) ។

ស្បៀង ឬ កញ្ចប់ ក បំរុងសម្រាប់ខេត្ត ក្រុង ( មានតារាងបែងចែកដោយឡែក ) ។

ស្បៀង ខ បំរុងសម្រាប់ខេត្ត ក្រុង ( មានតារាងបែងចែកដោយឡែក )។

ស្បោង " គ " ចំនួនដែលត្រូវទទួល គិតតាមខេត្ត ក្រុងតូចធំ ( មានតារាងបែងចែកដោយឡែក ) ។

ស្រោមសំបុត្របោះពុម្ព ១ ប្រភេទចំនួនស្មើនឹងស្បោង " គ " ដែលខេត្ត ក្រុងត្រូវទទួល ( មានតារាងបែងចែកដោយឡែក ) ។

ស្រោមសំបុត្របោះពុម្ព ២ សន្លឹកគុណនឹងចំនួនឃុំ សង្កាត់ក្នុងខេត្ត ក្រុង និងបូកបន្ថែម ៧០ សន្លឹក ។

ប័ណ្ណសំគាល់អ្នកសង្កេតការណ៍ជាតិ ១៥ សន្លឹកគុណនឹងចំនួនឃុំ សង្កាត់ទាំងអស់ក្នុងខេត្ត ក្រុង ។

ប័ណ្ណសំគាល់តំណាងគណបក្សនយោបាយត្រៀមបំរុង ៣៥ សន្លឹក ។

ទម្រង់បែបបទលេខ ១០០៧ បំរុង ២៧ ច្បាប់ ។

ទម្រង់បែបបទលេខ ១០១៤ សម្រាប់បំពេញលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ខ " ដោយលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ៥ ច្បាប់គុណនឹងចំនួនកញ្ចប់ " គ " សម្រាប់ខេត្ត ក្រុង ។

ទម្រង់បែបបទលេខ ១០១៥ សម្រាប់បំពេញលិខិតបញ្ជាក់សុពលភាព នៃការប្រើប្រាស់សម្ភារៈឯកសារចុះឈ្មោះបំរុង ដែលត្រូវផ្គត់ផ្គង់បន្ថែមចំពោះឃុំ សង្កាត់ ៣ ច្បាប់គុណនឹងចំនួនឃុំ សង្កាត់ក្នុងខេត្ត ក្រុង ។

ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជាក់ការបញ្ជូននិងការប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ១០ ច្បាប់គុណនឹងចំនួនឃុំ សង្កាត់ក្នុងខេត្ត ក្រុង ។

ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ ចំនួន ២៧ ក្បាល ( ១ ក្បាលមាន ១៥ សន្លឹក ) ។

ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសេចក្តីសំរេចលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ចំនួន ២៦ ក្បាល ( ១ ក្បាលមាន ១៥សន្លឹក ) ។

ទម្រង់បែបបទលេខ ១០០៩ ១០១១ ១០១២ ១០១៣ ១០១៦ ១០១៧ ១០១៨ ១០១៩ ១០២០ និង ១០២១ ត្រៀមបំរុងមួយមុខមួយចំនួនសម្រាប់ថតចម្លងជូនស្មៀនឃុំ សង្កាត់ ប្រសិនបើមានការស្នើសុំបន្ថែម ។

៨.៥.៥ សម្ភារៈ និងឯកសារ ដែលដាក់ក្នុងកេសសង្កសីធំមួយ ត្រូវបានកំណត់ជាហិបបរិក្ខារចុះឈ្មោះបោះឆ្នោតរបស់ឃុំ សង្កាត់ ( Commune Registration Kit ) រួមមានពីរ(២)ផ្នែក ដែលមួយផ្នែកសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមួយផ្នែកទៀតសម្រាប់ស្មៀនឃុំ សង្កាត់ ៖

៨.៥.៥.១ សម្ភារៈនិងឯកសារ ដែលត្រូវវេចខ្ចប់ដោយឡែកសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ រួមមាន ៖

ប័ណ្ណសំគាល់មន្ត្រីចុះឈ្មោះបោះឆ្នោត ១ សន្លឹកគុណានឹងចំនួនមន្ត្រីចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប័ណ្ណសំគាល់តំណាងគណបក្សនយោបាយ ១៥ សន្លឹក ។

ស្រោមសំបុត្របោះពុម្ពចំនួន ៦ ។

ទម្រង់បែបបទលេខ ១០០១ សម្រាប់បំពេញកិច្ចសន្យាបំរើការងារជាមន្ត្រីចុះឈ្មោះបោះឆ្នោត ( ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន ) ចំនួន ២ សន្លឹក គុណានឹងចំនួនមន្ត្រីចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១០០៦ សម្រាប់បំពេញបញ្ជីវត្តមាន និងប្រាក់កំរៃរបស់មន្ត្រីចុះឈ្មោះបោះឆ្នោតចំនួន ៣ ច្បាប់ ។

ទម្រង់បែបបទលេខ ១០០៧ ចំនួន ៥ ច្បាប់ ( ១ ច្បាប់មាន ៣ សន្លឹក ) សម្រាប់បំពេញពាក្យសុំចុះបញ្ជីតំណាងគណបក្សនយោបាយ ដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

ទម្រង់បែបបទលេខ ១០១៨ សម្រាប់បំពេញលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និងអាយុនៃអ្នកសុំចុះឈ្មោះបោះឆ្នោត ៤០ សន្លឹកគុណានឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១០១៩ សម្រាប់បំពេញលិខិតបញ្ជាក់ទីលំនៅ ដើម្បីប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត ២០ សន្លឹកគុណានឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត ១៦ សន្លឹក ។

ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញបណ្តឹងតវ៉ា ឬ បណ្តឹងជំទាស់ ៣ ក្បាល ( ១ ក្បាលមាន ១៥ សន្លឹក ) ។

ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសេចក្ដីសំរេចលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ៣ ក្បាល ( ១ ក្បាលមាន ១៥ សន្លឹក ) ។

ស្បោងផ្លាស្ទិកសម្រាប់ដាក់សម្ភារៈឯកសារដោយឡែក របស់ក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនមួយ ( ១ ) ។

៤.៥.៥.២ សម្ភារៈ និងឯកសារចុះឈ្មោះសម្រាប់ស្មៀនឃុំ សង្កាត់ រួមមាន៖

កេសស័ង្កសីចំនួនមួយ ( ១ ) និង សោត្រដោកមួយ ( ១ ) ។

បញ្ជីបោះឆ្នោតចុងក្រោយ នៃការិយាល័យបោះឆ្នោតនីមួយៗ ប្រាំមួយ(៦) ច្បាប់គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទសម្រាប់បំពេញបញ្ជីបោះឆ្នោតបន្ថែមចំនួន ១ កញ្ចប់ ( ២៨ សន្លឹក ) គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។ ក្នុងករណី មានការិយាល័យបោះឆ្នោតបង្កើតថ្មី ត្រូវទទួលបានចំនួន ៤ កញ្ចប់ ( ១ កញ្ចប់មាន ២៨ សន្លឹក ) គុណនឹងចំនួនការិយាល័យបោះឆ្នោតបង្កើតថ្មី ក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ២ ក្បាល ( ១ ក្បាលមាន ៤០ សន្លឹក ) គុណនឹងចំនួនការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំសង្កាត់ ។

ផ្លាកសញ្ញាការិយាល័យចុះឈ្មោះបោះឆ្នោតមួយ( ១ )ផ្ទាំង ។

ត្រាការិយាល័យចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ចំនួនមួយ ( ១ ) ។

តាំប៉ុងក្រហម ១ ប្រអប់ និងទឹកល័ក្ខពណ៌ក្រហម ១ ដប ។

ទម្រង់បែបបទលេខ ១០០៩ សម្រាប់បំពេញសេចក្ដីសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ២០ សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោតចុងក្រោយក្នុងឃុំ សង្កាត់ ។ ក្នុងករណីមានការិយាល័យបោះឆ្នោតបង្កើតថ្មី ត្រូវទទួលបានចំនួន ៦០ សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតបង្កើតថ្មីក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១០១១ សម្រាប់បំពេញរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត តាមការិយាល័យបោះឆ្នោត ៦ សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១០១២ សម្រាប់បំពេញរបាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ចំនួន ៥ សន្លឹក ។

ទម្រង់បែបបទលេខ ១០១៣ សម្រាប់បំពេញលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ក " ដោយស្មៀនឃុំ សង្កាត់ ៦ សន្លឹកគុណនឹងចំនួនកញ្ចប់ " ខ " ក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១០១៦ សម្រាប់បំពេញទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ( ករណីស្លាប់ ឬបាត់បង់សិទ្ធិបោះឆ្នោត ឬគ្មានទីលំនៅក្នុងឃុំ សង្កាត់ ឬផ្លាស់ទីលំនៅចេញ ) ៤៦ សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោតចុងក្រោយក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១០១៧ សម្រាប់បំពេញទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ( ករណីប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់តែមួយ ឬផ្លាស់ទីលំនៅចូល ) ៤០ សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតចុងក្រោយក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១០២០ សម្រាប់ស្មៀនឃុំ សង្កាត់បំពេញរបាយការណ៍សរុបស្តីពីការកែតម្រូវបញ្ជីបោះឆ្នោត នៅក្រោយការបិទបញ្ជីដំបូង ចំនួន ៣ ច្បាប់ ( ១ ច្បាប់មាន ៤ សន្លឹក ) ។

ទម្រង់បែបបទលេខ ១០២១ សម្រាប់បំពេញរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ចំនួន ៣ ច្បាប់ ។

ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និង ប្រគល់ទទួលសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត ២ សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ។

ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ៤ ក្បាល ( ១ ក្បាលមាន ១៥ សន្លឹក ) ។

ស្បោង ឬកញ្ចប់ " ក " ( Bag A ) ចំនួន ១ គុណនឹងចំនួនការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ។

ស្បោងឬកញ្ចប់សម្រាប់ដាក់គល់បញ្ជីទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងទម្រង់បែបបទនេះដែលនៅសល់ ចំនួនមួយ ។

ស្បោង ឬកញ្ចប់ " ខ " ( Bag B ) ចំនួនសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ( មានតារាងបែងចែកដោយឡែក ) ។

ស្រោមសំបុត្របោះពុម្ព ៨ ប្រភេទ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ស្រោមសំបុត្របោះពុម្ព ៧ ប្រភេទ សម្រាប់ឃុំ សង្កាត់នីមួយៗ និង ១ ប្រភេទទៀតចំនួនស្មើនឹងស្បោង " ខ " ដែលឃុំ សង្កាត់ត្រូវទទួល ។

ស្រោមសំបុត្របោះពុម្ព ៨ សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោត ក្នុងឃុំ សង្កាត់ ។

សឺមីមានខ្សែចងសម្រាប់ដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ចំនួនសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ( មានតារាងបែងចែកដោយឡែក ) ។

ប្រដាប់ចោះក្រដាស ( Hole Punches ) ចំនួនមួយ ( ១ ) ។

ឃ្នាបស៊ីក ( Fasteners ) ចំនួនសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ( មានតារាងបែងចែកដោយឡែក ) ។

ក្រដាសរ៉ាម ( A4 ) ៨០ សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

ប្រដាប់កិបតូចចំនួនមួយ ( ១ ) ។

គ្រាប់កិបតូច ចំនួនសមាមាត្រនឹងភាគរយ នៃចំនួនប្រជាពលរដ្ឋ ក្នុងឃុំ សង្កាត់ ( មានតារាងបែងចែកដោយឡែក ) ។

ប៊ិចខៀវនិងប៊ិចក្រហមសរុបពីរ(២)ដើម គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

បន្ទាត់ជ័រមួយ ( ១ ) ដើម ។

ម្ជុលបារាំងមួយ ( ១ ) ប្រអប់ ។

៨.៥.៦ នៅក្រោយពេល ដែលបានទទួលសម្ភារៈឯកសារបំពេញការចុះឈ្មោះបោះឆ្នោតរួចហើយ ស្មៀនឃុំ សង្កាត់ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ត្រូវទុកដាក់សម្ភារៈទាំងនោះនៅក្នុងកេសសង្កសី ចាក់សោឱ្យជិត និងថែរក្សាឱ្យបានល្អនៅបន្ទប់ណាមួយក្នុងសាលាឃុំ សង្កាត់ឬនៅទីតាំងណាមួយដែលធានាថាមានសុវត្ថិភាពជាង ។

៤.៥.៦.១ នៅក្នុងពេលធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ ត្រូវដកយកសម្ភារៈឯកសារបំរើការចុះឈ្មោះបោះឆ្នោត ក្នុងបរិមាណគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃប៉ុណ្ណោះ ។

៤.៥.៦.២ នៅពេលដែលត្រូវចុះធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោត តាមភូមិមួយចំនួន ដែលបានកំណត់ ក្រៅពីសាលាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវនាំយកទៅតាមខ្លួននូវកេសដាក់សម្ភារៈឯកសារ ហើយត្រូវដកយកសម្ភារៈឯកសារបំរើការចុះឈ្មោះបោះឆ្នោត ក្នុងបរិមាណគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃប៉ុណ្ណោះ ។

៤.៥.៦.៣ ចំពោះសម្ភារៈឯកសារដែលនៅសល់ ត្រូវដាក់ក្នុងកេសរួចចាក់សោត្រដោក ហើយរក្សាទុកនៅក្បែរតុស្មៀន ក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដែលកំពុងបំពេញការងារ ។

៤.៥.៦.៤ ចំពោះឃុំ សង្កាត់ធំ ដែលមានសម្ភារៈឯកសារបំរើការចុះឈ្មោះច្រើន ហើយការិយាល័យចុះឈ្មោះនៅតាមភូមិពិបាកធ្វើដំណើរទៅ ឬស្ថិតនៅឆ្ងាយពេកពីសាលាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវរក្សាទុកកេសដាក់សម្ភារៈឯកសារនៅសាលាឃុំ សង្កាត់ ឬនៅទីតាំងណាមួយដែលអាចធានាសុវត្ថិភាពល្អ ។ ក្នុងករណីនេះ ស្មៀនឃុំ សង្កាត់ត្រូវដកយកសម្ភារៈឯកសារបំរើការចុះឈ្មោះបោះឆ្នោត ក្នុងបរិមាណគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត នៅទីតាំងភូមិនោះប៉ុណ្ណោះ ប្រសិនបើ គាត់មិនអាចត្រឡប់មកសាលាឃុំ សង្កាត់នៅពេលល្ងាចនៃថ្ងៃនីមួយៗទេ ។

៤.៥.៦.៥ ស្មៀនឃុំ សង្កាត់ត្រូវរក្សាទុកកូនសោនៃមេសោ ដែលចាក់ជាប់កេសដាក់សម្ភារៈឯកសារទាំងនេះនៅនឹងខ្លួនឱ្យបានល្អ ។

៤.៥.៦.៦ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការចាំបាច់ដើម្បីឱ្យមានអ្នកយាមការពារកេសដាក់សម្ភារៈឯកសារទាំងនេះប្រកបដោយសុវត្ថិភាព ។

**សង្ខេបដំណាក់ការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

**ប្រការ ៤.៦** ការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ រួមមានតំណាក់កាលដូចខាងក្រោម៖

៩.៦.១ ការបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតចុងក្រោយ ដែលបានផ្ដល់ឱ្យដោយ គជប នៅសាលាឃុំ សង្កាត់ និងនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ ដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះ ត្រូវបានផ្ដល់សុពលភាពជាផ្លូវការចុងក្រោយដោយ គជប ដើម្បីបំរើគោលដៅនៃការពិនិត្យបញ្ជីឈ្មោះ ។

៩.៦.២ ការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត ដែលមានទីលំនៅក្នុងឃុំ សង្កាត់ ហើយដែលមិនទាន់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយនៅក្នុងឃុំ សង្កាត់ ។

៩.៦.៣ ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះអ្នកបោះឆ្នោតដែលទទួលមរណភាព ឬដែលបាត់បង់សិទ្ធិបោះឆ្នោត ឬដែលបានផ្លាស់ទីលំនៅចេញទៅឃុំ សង្កាត់ផ្សេង ឬដែលពុំស្របតាមលក្ខខ័ណ្ឌកំណត់នៃច្បាប់ និងបទបញ្ជានិងនីតិវិធីរបស់ គជប ។

៩.៦.៤ ការចងក្រង និងការកត់ត្រាទិន្នន័យ សម្រាប់រៀបចំបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច ដើម្បីផ្ញើជូន គជប ( មជ្ឈមណ្ឌលកំព្យូទ័រ ) និងត្រៀមសម្រាប់ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

៩.៦.៥ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងដែលត្រូវធ្វើនៅសាលាឃុំ សង្កាត់ នៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗដែលបានកែសម្រួលរួច និងនៅតាមទីតាំងការិយាល័យថ្មីដែលត្រូវបង្កើតឡើងដោយ គជប ផ្អែកតាមការចាំបាច់ និងល័ក្ខខ័ណ្ឌកំណត់ដោយច្បាប់បោះឆ្នោត ។

៩.៦.៦ ការចាត់ចែងដោះស្រាយនូវរាល់បណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ដែលទាក់ទងដល់ការបដិសេធការសុំចុះឈ្មោះបោះឆ្នោត និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

៩.៦.៧ ការសរុបបញ្ចប់នូវការកែតម្រូវបញ្ជីបោះឆ្នោតដំបូង បន្ទាប់ពីពេលដែលបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ត្រូវបានដោះស្រាយជាស្ថាពរនិងការបញ្ជូនរបាយការណ៍ពាក់ព័ន្ធនឹងការកែតម្រូវនេះទៅ គជប ។

**រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ**

**ប្រការ ៩.៧** មាត្រា ៤៩ថ្មី នៃច្បាប់បោះឆ្នោតបានចែងថា រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវធ្វើចាប់ពីថ្ងៃទី ០១ ខែ តុលា រហូត

ដល់ថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។ ដូច្នេះ ក្នុងរយៈពេលសរុបចំនួនបី ( ៣ ) ខែនេះ ត្រូវគិតរួមបញ្ចូលទាំងដំណើរការនៃការប្ដឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះ ដំណើរការប្ដឹងតវ៉ា ឬ/និង ប្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ព្រមទាំងការផ្ដល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការផង ។ គជប ត្រូវកំណត់រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ ។ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្ដើមធ្វើនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស នៅថ្ងៃតែមួយដែលបានកំណត់ដោយ គជប ។ នៅថ្ងៃចាប់ផ្ដើមដំបូង ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅសាលាឃុំ សង្កាត់ត្រូវបើកដំណើរការនៅម៉ោងប្រាំពីរ( ៧ )ព្រឹក ។ ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការចាប់ពីម៉ោងប្រាំពីរ(៧)ព្រឹកដល់ម៉ោងប្រាំ(៥)ល្ងាច លើកលែងតែពេលម៉ោងបាយថ្ងៃត្រង់នៅរៀងរាល់ថ្ងៃ ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃអាទិត្យ និងលើកលែងតែមានសេចក្ដីណែនាំផ្សេងពីនេះពី គជប ។

៤.៧.១ គជប ត្រូវណែនាំ និងចាត់ចែងឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនរៀបចំពេលវេលាប្រតិបត្តិការ សម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោតទាំងអស់ ក្នុងឃុំ សង្កាត់នីមួយៗដែល គជប បានកំណត់ និងបិទផ្សាយប្រតិទិនសម្រាប់ការបំពេញការងារតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗរបស់ក្រុមមន្ត្រីចុះឈ្មោះ ដើម្បីធ្វើឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោត តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចទទួលបានព័ត៌មាន ។

៤.៧.១.១ ដោយពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រួតពិនិត្យលើការងាររបស់ខ្លួន ស្មៀនឃុំ សង្កាត់ត្រូវកំណត់ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតសម្រាប់ការិយាល័យចុះឈ្មោះនៅតាមភូមិមួយចំនួន ក្រៅពីការិយាល័យនៅសាលាឃុំ សង្កាត់ ។ ក្នុងករណីនេះ ស្មៀនឃុំ សង្កាត់ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយប្រធានភូមិពាក់ព័ន្ធ ដើម្បីចាត់ចែងអនុវត្តប្រតិទិនដែលបានកំណត់ហើយ ។

៤.៧.២ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ រយៈពេលរួមនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ត្រូវបានកំណត់ដោយ គជប សម្រាប់ការិយាល័យបោះឆ្នោត / តំបន់បោះឆ្នោតទាំងអស់ក្នុងក្របខណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

៤.៧.២.១ ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំសង្កាត់គឺជាការិយាល័យចុះឈ្មោះបោះឆ្នោតចំបង ដែលត្រូវបើកបំរើការ

ពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយប្រើរយៈពេលប្រមាណមួយភាគពីរ នៃរយៈពេលពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតសរុប ។

៩.៧.២.២ ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅតាមភូមិនានាក្រៅពីសាលាឃុំ សង្កាត់ ត្រូវបើកបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយប្រើពេលវេលាសរុបមិនឱ្យលើសពីមួយភាគពីរនៃរយៈពេលរួម ដែលបានកំណត់ឡើយ លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះដោយ គជប ។

៩.៧.២.៣ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត អាចចាប់ផ្តើមធ្វើនៅសាលាឃុំ សង្កាត់ប្រមាណមួយភាគបីនៃរយៈពេលសរុប រួចបន្តធ្វើតាមលំដាប់លំដោយនៅការិយាល័យតាមភូមិមួយចំនួន ដែលបានកំណត់ ឬ/និង តាមមន្ទីរពេទ្យ ឬ/និង តាមមន្ទីរឃុំឃាំងពិរុទ្ធជនដែលមានទីតាំងក្នុងឃុំ សង្កាត់ ប្រមាណមួយភាគពីរនៃរយៈពេលសរុប ហើយត្រូវត្រៀមទុករយៈពេលប្រមាណបី( ៣ )ថ្ងៃ សម្រាប់ធ្វើបញ្ចប់នៅសាលាឃុំ សង្កាត់ ។ នៅពេលដែលស្មៀនឃុំ សង្កាត់កំពុងបំពេញការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត នៅតាមភូមិដែលបានកំណត់ ឬតាមមន្ទីរពេទ្យ ឬមន្ទីរឃុំឃាំងពិរុទ្ធជនដែលមានទីតាំងក្នុងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា ប្រជាពលរដ្ឋដែលមកសុំចុះឈ្មោះនៅសាលាឃុំ សង្កាត់ ត្រូវបានប្រាប់អំពីទីតាំងការិយាល័យដែលកំពុងបំពេញការងារចុះឈ្មោះនោះ ។

៩.៧.២.៤ ស្មៀនឃុំ សង្កាត់អាចកែសម្រួលរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដូចចែងក្នុងចំណុច ៩.៧.២.៣ ខាងលើ តាមការចាំបាច់ និងសភាពជាក់ស្តែង ។ ត្រូវធានាថា រាល់ការកែសម្រួលត្រូវតែបានជូនដំណឹងដល់ប្រធានភូមិ និងប្រជាពលរដ្ឋព្រមទាំងតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

៩.៧.២.៥ នៅគ្រប់ពេលក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវទទួលចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោត ដែលមកពីគ្រប់ភូមិ និងទីកន្លែងក្នុងឃុំ សង្កាត់ ។ ទោះបី ស្មៀនឃុំ សង្កាត់កំពុងធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ

បោះឆ្នោតនៅទីតាំងភូមិណាមួយក៏ដោយ ក៏ត្រូវទទួលចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋមកពីភូមិផ្សេងៗទៀតក្នុងឃុំ សង្កាត់ដែរ ។

៤.៧.២.៦ ក្នុងករណី ដែលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមិនទាន់ផុតរយៈពេលកំណត់ ប៉ុន្តែការិយាល័យបោះឆ្នោតនីមួយៗសុទ្ធតែបានចុះឈ្មោះអ្នកបោះឆ្នោតគ្រប់ចំនួនប្រាំពីររយ ( ៧០០ ) នាក់ហើយ ប្រសិនបើ នៅតែមានអ្នកមកសុំចុះឈ្មោះបោះឆ្នោតទៀត ស្មៀនឃុំ សង្កាត់ត្រូវលើកសំណើជាបន្ទាន់មក គជប ដើម្បីសុំបង្កើតការិយាល័យបោះឆ្នោតថ្មី ។

៤.៧.២.៧ ការិយាល័យចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ត្រូវបើកបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជាប់រហូតសម្រាប់រយៈពេល ដូចចែងក្នុងចំណុច ៤.៧.២ ខាងលើ លើកលែងតែមានករណីប្រធានស័ក្តិ ។ ក្នុងករណីនេះ ដោយមានការឯកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវរាយការណ៍ជាបន្ទាន់ តាមរយៈមន្ត្រីលេខាធិការដ្ឋានខេត្តក្រុងរៀបចំការបោះឆ្នោត ដើម្បីសុំការសំរេចពី គជប ។

៤.៧.៣ នៅតំបន់ដែលប្រជាពលរដ្ឋពុំអាចមកបង្ហាញខ្លួន នៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីចុះឈ្មោះបោះឆ្នោត នៅក្នុងម៉ោងធ្វើការធម្មតាបាន ដោយសារពួកគាត់ជាប់រវល់ធ្វើស្រែចំការឬធ្វើការងារនៅតាមរោងចក្រ ស្មៀនឃុំ សង្កាត់ត្រូវសំរបសំរួលម៉ោងធ្វើការប្រចាំថ្ងៃនៃការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋទាំងនោះអាចមកចុះឈ្មោះបោះឆ្នោតបាន ។

៤.៧.៤ ក្នុងដំណើរការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះ និងដំណើរការប្តឹងតវ៉ាឬ/និងប្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ស្ថិតក្នុងដំណាក់ការ នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ថ្ងៃធ្វើការត្រូវបានកំណត់គិតទាំងថ្ងៃសៅរ៍ អាទិត្យ ប៉ុន្តែលើកលែងតែថ្ងៃបុណ្យជាផ្លូវការ ។

**ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត**

**ប្រការ ៤.៨** ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលបានកំណត់ក្នុងមាត្រា ៣៤ នៃរដ្ឋធម្មនុញ្ញ ត្រូវបានចែងក្នុងច្បាប់ស្តីពីសញ្ជាតិ ចែងក្នុងមាត្រា ១០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង

មាត្រា ៥០ថ្មី នៃច្បាប់បោះឆ្នោត ។ ដើម្បីមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទ ដែលរួមទាំងព្រះសង្ឃ ឬបព្វជិតសាសនាផង ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

៤.៨.១ ត្រូវបង្ហាញខ្លួន និងភស្តុតាងជាឯកសារផ្លូវការបញ្ជាក់អត្តសញ្ញាណ នៅចំពោះមុខស្មៀនឃុំ សង្កាត់ ដែលទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ។

៤.៨.២ មានសញ្ជាតិខ្មែរ ។

៤.៨.៣ មានអាយុដប់ប្រាំបី ( ១៨ ) ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោត ក្នុងករណីមានការរៀបចំការបោះឆ្នោតដែលកំណត់ដោយច្បាប់ ឬគិតដល់ថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

៤.៨.៤ មានទីលំនៅរស់នៅជាធម្មតាក្នុងឃុំ សង្កាត់ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ។

៤.៨.៤.១ ទីលំនៅរបស់ជនណាម្នាក់ក្នុងឃុំ សង្កាត់ណាមួយ គឺជាទីកន្លែងដែលជននោះកំពុងរស់នៅ ឬ ធ្លាប់រស់នៅជាធម្មតាហើយតែងតែវិលត្រឡប់មកទីកន្លែងនោះវិញ បន្ទាប់ពីអវត្តមានជាបណ្តោះអាសន្នមួយរយៈមក ។

៤.៨.៤.២ ទីលំនៅរបស់ជនណាម្នាក់ក្នុងឃុំ សង្កាត់ណាមួយ អាចជាអាគារ ផ្ទះល្វែង បន្ទប់ សំណង់ ឬផ្នែកមួយនៃសំណង់ ឬទីតាំងជាក់លាក់ណាមួយដែលជាប្រក្រតី គេអាចរកគាត់ឃើញក្នុងឃុំ សង្កាត់នោះ ។

៤.៨.៤.៣ កម្មករ សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល នាយ ឬពលនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និង នគរបាលជាតិដែលកំពុងររស់នៅជាប់ជាបណ្តោះអាសន្នក្នុងឃុំ សង្កាត់ សុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ។

៤.៨.៤.៤ អ្នកសុំចុះឈ្មោះអាចមានទីលំនៅ នៅថ្ងៃសុំចុះឈ្មោះបោះឆ្នោត ។ លក្ខខណ្ឌទីលំនៅមិនតម្រូវថា អ្នកសុំចុះឈ្មោះត្រូវតែជាអ្នករស់នៅ

ក្នុងឃុំ សង្កាត់ ក្នុងរយៈពេលកំណត់ណាមួយមុនពេលគាត់សុំចុះឈ្មោះបោះឆ្នោតនោះទេ ។ ទោះបីយ៉ាងនេះក្តី អ្នកទេសចរ ឬអ្នកធ្វើដំណើរឆ្លងកាត់ឃុំ សង្កាត់ មិនអាចកំណត់ជាអ្នកមានទីលំនៅក្នុងឃុំ សង្កាត់បានទេ ។

៩.៨.៤.៥ ប្រជាពលរដ្ឋខ្មែរ ដែលមានទីលំនៅច្រើនជាងមួយកន្លែង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់ដើម្បីចុះឈ្មោះជាអ្នកបោះឆ្នោត ។

៩.៨.៥ ពុំមែនជាជនដែលស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ។

៩.៨.៥.១ ជនដែលស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ គឺគិតរួមបញ្ចូលទាំងជនដែលត្រូវតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារ តែបានទទួលការព្យួរទោស ហើយមិនទាន់មាននីតិសម្បទាឡើងវិញ ។

៩.៨.៦ ពុំមែនជាជនវិកលចរិត ឬ/និង ពុំមែនជាជនស្ថិតនៅក្រោមអាណាព្យាបាល ។

៩.៨.៦.១ ជាជនវិកលចរិត ឬជនស្ថិតនៅក្រោមអាណាព្យាបាល លុះត្រាតែមានលិខិតបញ្ជាក់ដែលចេញដោយមន្ទីរពេទ្យ ឬស្ថាប័នសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ។

៩.៨.៦.២ រាល់លិខិតបញ្ជាក់ខាងលើត្រូវតែជាទម្រង់បែបបទកំណត់ និងចេញដោយស្ថាប័នជំនាញ ។

៩.៨.៦.៣ ស្មៀនឃុំ សង្កាត់ ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត មិនអាចនឹងបដិសេធការសុំចុះឈ្មោះបោះឆ្នោត របស់អ្នកសុំចុះឈ្មោះដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ប៉ុន្តែស្ថិតក្នុងស្ថានភាពជាជនវិកលចរិត និងគ្មានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចនោះឡើយ ។

**ឯកសារដែលអ្នកសុំចុះឈ្មោះបោះឆ្នោតអាចបង្ហាញ សម្រាប់បញ្ជាក់អំពីភាពមានសិទ្ធិដើម្បីចុះឈ្មោះបោះឆ្នោត**

**ប្រការ** ៩.៩ អ្នកសុំចុះឈ្មោះម្នាក់ៗ ត្រូវតែបង្ហាញភស្តុតាងជូនស្មៀនឃុំ សង្កាត់ ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណ សញ្ជាតិ អាយុ និងទីលំនៅរបស់ខ្លួនក្នុងឃុំ សង្កាត់ ដែលជាលក្ខណៈវិនិច្ឆ័យរួម ដើម្បីបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ។

៩.៩.១ ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួន អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញជូនស្មៀនឃុំ សង្កាត់នូវឯកសារ ឬសំអាងណាមួយដូចខាងក្រោម ៖

៤.៩.១.១ អត្តសញ្ញាណប័ណ្ណមានបិទរូបថតជាសម្គាល់ ដែលផ្តល់ជូនដោយ រាជរដ្ឋាភិបាលកម្ពុជា ។ អត្តសញ្ញាណប័ណ្ណទាំងនេះរួមមាន ៖

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលបានផ្តល់ឱ្យអនុលោម ទៅតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ ៣៦ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬ កងយោធពលខេមរ ភូមិន្ទ ឬ នគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

ឆាយាគណៈមហានិកាយ ឬសុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ ឬសង្ឃដីកាមានបិទរូបថត ដែលផ្តល់ដោយចៅអធិការវត្តតាម ការអនុញ្ញាតនិងណែនាំរបស់ក្រសួងធម្មការនិងកិច្ចការសាសនា ។

៤.៩.១.២ លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

៤.៩.១.៣ សៀវភៅគ្រួសារដែលមានបិទរូបថតរបស់អ្នកសុំចុះឈ្មោះ ។

៤.៩.១.៤ លិខិតធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីរ( ២ )រូប ក្នុងឃុំ សង្កាត់នោះ ដែលបញ្ជាក់អំពីអត្តសញ្ញាណ ឬ/និង អាយុរបស់អ្នក សុំចុះឈ្មោះ ធ្វើឡើងនៅចំពោះមុខមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅ សង្កាត់រង គួបផ្សំនឹងការបញ្ជាក់ទីលំនៅរបស់អ្នកសុំចុះឈ្មោះដែល ចេញដោយមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ។

៤.៩.២ ដើម្បីបញ្ជាក់ថា ខ្លួនជាប្រជាពលរដ្ឋខ្មែរ អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញជូន ស្មៀនឃុំ សង្កាត់ នូវឯកសារណាមួយក្នុងចំណោមឯកសារដូចខាងក្រោម ៖

៤.៩.២.១ អត្តសញ្ញាណប័ណ្ណមានបិទរូបថតជាសម្គាល់ ដែលផ្តល់ជូនដោយ រាជរដ្ឋាភិបាលកម្ពុជា ។ អត្តសញ្ញាណប័ណ្ណទាំងនេះរួមមាន ៖

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលបានផ្តល់ឱ្យអនុលោម ទៅតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ ៣៦ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬ កងយោធពលខេមរ ភូមិន្ទ ឬ នគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

ឆាយាគណៈមហានិកាយ ឬ សុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ ឬ សង្ឃដីកាមានបិទរូបថត ដែលផ្តល់ដោយចៅអធិការវត្តតាម ការអនុញ្ញាតនិងណែនាំរបស់ក្រសួងធម្មការនិងកិច្ចការសាសនា ។

៤.៩.២.២ លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

៤.៩.២.៣ សៀវភៅគ្រួសារ ។

៤.៩.២.៤ សំបុត្រកំណើតដែលមានបញ្ជាក់ពីសញ្ជាតិខ្មែររបស់សាមីខ្លួន ។

៤.៩.២.៥ លិខិតបញ្ជាក់ថា ជាប្រជាពលរដ្ឋខ្មែរ ដែលផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជា ។

៤.៩.២.៦ លិខិតបញ្ជាក់ ឬឯកសារ ឬសាលក្រមស្ថាពររបស់តុលាការដែលបញ្ជាក់ថា ឪពុក ឬម្តាយរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ជាប្រជាពលរដ្ឋខ្មែរ និងឯកសារដែលបង្ហាញថា អ្នកសុំចុះឈ្មោះបោះឆ្នោតគឺជាកូនរបស់ឪពុក ឬម្តាយនោះ ។

៤.៩.២.៧ ឯកសារជាផ្លូវការបញ្ជាក់ថា អ្នកសុំចុះឈ្មោះបោះឆ្នោតកើតនៅប្រទេសកម្ពុជា ហើយឪពុក និង ម្តាយរបស់សាមីជនក៏កើត និងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាដែរ ព្រមទាំងឯកសារជាផ្លូវការដែលបញ្ជាក់ថា អ្នកសុំចុះឈ្មោះបោះឆ្នោតគឺជាកូនរបស់ឪពុក និងម្តាយនោះ ។

៤.៩.៣ ដើម្បីបញ្ជាក់ថា ខ្លួនមានអាយុដប់ប្រាំបី ( ១៨ ) ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតក្នុងករណីមានការរៀបចំការបោះឆ្នោតដែលកំណត់ដោយច្បាប់ ឬគិតដល់ថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ ដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជាប្រចាំឆ្នាំ អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញជូនស្មៀនឃុំ សង្កាត់ នូវឯកសារ ឬសំអាងណាមួយដូចខាងក្រោម ៖

៤.៩.៣.១ ឯកសារ ឬសំអាងណាមួយ ដូចមានចែងក្រោមចំណុច ៤.៩.២ ខាងលើ ដែលមានបញ្ជាក់ពីអាយុ ឬ ថ្ងៃខែឆ្នាំកំណើតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ។

៤.៩.៣.២ លិខិតធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីរ( ២ )រូប ក្នុងឃុំ សង្កាត់ ចំពោះអាយុរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនោះ ដូចដែលបានបញ្ជាក់ក្នុងចំណុច ៤.៩.១.៤ ខាងលើ ។

៤.៩.៤ ដើម្បីបញ្ជាក់ថា ខ្លួនមានទីលំនៅក្នុងឃុំ សង្កាត់នោះ អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញជូនស្មៀនឃុំ សង្កាត់ នូវឯកសារ ឬសំអាងណាមួយដូចខាងក្រោម ៖

៤.៩.៤.១ ឯកសារ ឬ សំអាងណាមួយដូចមានចែងក្រោមចំណុច ៦.៩.២ និងក្នុងចំណុច ៤.៩.១.៤ ខាងលើ ដែលមានបញ្ជាក់ថាអ្នកសុំចុះ

ឈ្មោះបោះឆ្នោតពិតជាមានទីលំនៅ នៅក្នុងឃុំ សង្កាត់នោះ ប្រាកដមែន ។

៩.៩.៤.២ សៀវភៅស្នាក់នៅ ( ឯកសារ ក២ ) ។

៩.៩.៤.៣ លិខិតបញ្ជាក់ទីលំនៅចេញដោយអាជ្ញាធរឃុំ សង្កាត់ ដែលអះអាងថា អ្នកសុំចុះឈ្មោះបោះឆ្នោតពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ។

៩.៩.៥ ប្រសិនបើ ស្មៀនឃុំ សង្កាត់ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត យល់ឃើញថា ឯកសារ ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតបានបង្ហាញ មិនមានលក្ខណៈគ្រប់គ្រាន់ ឬបើគាត់មានមន្ទិលសង្ស័យនឹងសុពលភាពនៃឯកសារដែលបានបង្ហាញនោះ គាត់អាចតម្រូវឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោតបង្ហាញឯកសារផ្សេងទៀត ដើម្បីបញ្ជាក់ពីអត្តសញ្ញាណ សញ្ជាតិខ្មែរ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់របស់សាមីខ្លួន ។

៩.៩.៥.១ ឯកសារណាមួយ ដែលបានបង្ហាញដោយអ្នកសុំចុះឈ្មោះ ហើយដែលត្រូវបានសន្មតថា ត្រឹមត្រូវ និងមានសុពលភាព មិនអាចត្រូវបានសួរដេញដោលដោយស្មៀនឃុំ សង្កាត់ទេ ។

**សង្ខេបដំណើរការនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត និងការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ**

**ប្រការ ៩.១០** បន្ទាប់ពីបានទទួលហិបបរិក្ខារចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវប្រគល់សម្ភារៈឯកសារមួយផ្នែកដែលបានវេចខ្ចប់ដោយឡែកជូនក្រុមប្រឹក្សាឃុំ សង្កាត់ ។ ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនត្រូវដកយកច្បាប់ចម្លងនៃបញ្ជីបោះឆ្នោតចុងក្រោយចំនួនពី(២)ច្បាប់ និងត្រៀមបិទផ្សាយសម្រាប់ឱ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ដែលធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយមកពិនិត្យផ្ទៀងផ្ទាត់ឱ្យប្រាកដថា ឈ្មោះរបស់ខ្លួនមាននៅលើបញ្ជីបោះឆ្នោតចុងក្រោយនោះ ។

៩.១០.១ នៅរយៈពេលពីរ(២)ថ្ងៃ មុនការចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់និងជំនួយការស្មៀនត្រូវបំបែក និងបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយមួយច្បាប់ នៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ ដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះត្រូវបានផ្តល់សុពលភាពចុងក្រោយដោយ គជប ។

៩.១០.១.១ ក្នុងករណី មិនអាចបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយនៅតាមទីតាំងដើមនៃការិយាល័យបោះឆ្នោតណាមួយ ឬច្រើន ស្មៀនឃុំ សង្កាត់អាចសំរេចបិទផ្សាយនៅទីតាំងសមស្របណាមួយ ឬប្រមូលផ្តុំបញ្ជី

បោះឆ្នោតចុងក្រោយនៃការិយាល័យមួយចំនួន ដើម្បីបិទផ្សាយនៅទីតាំងសមស្របណាមួយ ។

៤.១០.១.២ ទីតាំងសម្រាប់បិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ត្រូវមានលក្ខណៈធំទូលាយ ដែលអាចអោយអ្នកបោះឆ្នោតទាំងឡាយ ចូលមើលបានងាយស្រួល ។

៤.១០.២ នៅរយៈពេលពីរ(២)ថ្ងៃ មុនការចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនត្រូវបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោតទាំងអស់មួយច្បាប់ នៅទីតាំងសាលាឃុំ សង្កាត់ ។

៤.១០.៣ នាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈរបស់ គជប លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនត្រូវទទួលខុសត្រូវតាមមុខនាទីរបស់ខ្លួន ក្នុងការផ្សព្វផ្សាយឱ្យបានទូលំទូលាយជាសាធារណៈ អំពីកាលបរិច្ឆេទ និងទីកន្លែងបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ។

៤.១០.៣.១ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនត្រូវសហការឱ្យបានជិតស្និទ្ធជាមួយប្រធានភូមិនានាក្នុងឃុំ សង្កាត់ក្នុងការជូនដំណឹង និងលើកទឹកចិត្តប្រជាពលរដ្ឋ ដែលធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ ឱ្យមកផ្ទៀងផ្ទាត់មើលឱ្យប្រាកដថាឈ្មោះរបស់ខ្លួនមាននៅលើបញ្ជីបោះឆ្នោតចុងក្រោយនោះ ។ ក្នុងនោះក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ ៖

- ចាត់ប្រធានភូមិ ឬ តំណាងឱ្យជួយថែរក្សាសុវត្ថិភាពបញ្ជីបោះឆ្នោតចុងក្រោយដែលបានបិទផ្សាយតាមទីតាំងការិយាល័យបោះឆ្នោត បង្ការកុំឱ្យរហែក សម្រាប់បំរើការផ្ទៀងផ្ទាត់ឈ្មោះ ។
- ចាត់ប្រធានភូមិ ឬ តំណាងឱ្យប្រចាំការនៅតាមទីតាំងបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ដើម្បីជួយប្រាប់អំពីទីតាំងបិទផ្សាយផ្សេងទៀត និងជួយពន្យល់ណែនាំប្រជាពលរដ្ឋ អំពីរបៀបក្នុងការផ្ទៀងផ្ទាត់រកឈ្មោះនៅលើបញ្ជីបោះឆ្នោតចុងក្រោយ ។

៤.១០.៣.២ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់និងជំនួយការស្មៀន ត្រូវធានាថា ប្រជាពលរដ្ឋដែលមានឈ្មោះ ក្នុងបញ្ជីបោះឆ្នោតចុងក្រោយ

ត្រូវបានរំលឹកអោយធ្វើការកត់ចំណាំនូវលេខកូដ និងឈ្មោះទីតាំងនៃការិយាល័យបោះឆ្នោតរបស់ខ្លួន ហើយប្រសិនបើអាច ត្រូវកត់ចំណាំលេខរៀងនៃឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោតផងដែរ ។

៩.១០.៣.៣ ប្រជាពលរដ្ឋ ដែលមានឈ្មោះត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោត នៅជិតសមល្មមនឹងទីលំនៅរបស់ខ្លួនរួចហើយ មិនតម្រូវឱ្យមកជួបស្មៀនឃុំ សង្កាត់ នៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីសុំចុះឈ្មោះបោះឆ្នោតម្តងទៀតទេ ។

៩.១០.៤ នាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈរបស់ គជប លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនត្រូវទទួលខុសត្រូវតាមមុខនាទីរបស់ខ្លួន ក្នុងការជូនដំណឹងដល់ប្រជាពលរដ្ឋមានទីលំនៅក្នុងឃុំ សង្កាត់ ដែលមានគ្រប់លក្ខណៈវិនិច្ឆ័យចុះឈ្មោះបោះឆ្នោត និងដែលមិនទាន់បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យណាមួយក្នុងឃុំ សង្កាត់ អំពីសិទ្ធិរបស់គាត់ក្នុងការចុះឈ្មោះបោះឆ្នោត ពេលវេលាដែលត្រូវចុះឈ្មោះ នីតិវិធីដែលត្រូវគោរពតាម និងឯកសារដែលតម្រូវយកមកបង្ហាញស្មៀន ឃុំ សង្កាត់ ។

៩.១០.៤.១ ប្រជាពលរដ្ឋមានទីលំនៅក្នុងឃុំ សង្កាត់ ដែលពុំទាន់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ដែលអាចជាអ្នកទើបគ្រប់អាយុបោះឆ្នោត អ្នកមិនបានចុះឈ្មោះបោះឆ្នោតចុងក្រោយ និងអ្នកផ្លាស់ទីលំនៅចូលមានសិទ្ធិសុំចុះឈ្មោះបោះឆ្នោតជាមួយស្មៀនឃុំ សង្កាត់ នៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.១០.៤.២ ប្រជាពលរដ្ឋ ដែលមានឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោតណាមួយរួចហើយ ប៉ុន្តែឈ្មោះរបស់គាត់ ឬទិន្នន័យពាក់ព័ន្ធសរសេរមិនត្រឹមត្រូវ មានសិទ្ធិស្នើសុំឱ្យស្មៀនឃុំ សង្កាត់ធ្វើការកែតម្រូវ ដើម្បីឱ្យឈ្មោះរបស់គាត់ក្នុងបញ្ជីបោះឆ្នោតដូចគ្នានឹងឈ្មោះនៅក្នុងឯកសារបញ្ជាក់អត្តសញ្ញាណ ។

៩.១០.៤.៣ ប្រជាពលរដ្ឋ ដែលមានឈ្មោះបោះឆ្នោតត្រឹមត្រូវ ក្នុងបញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោតណាមួយ ដែលតាំងនៅឆ្ងាយលើសពីប្រាំ(៥)គីឡូម៉ែត្រពីទីលំនៅរបស់ខ្លួន មានសិទ្ធិសុំឱ្យស្មៀន

ឃុំ សង្កាត់ចុះឈ្មោះរបស់គាត់ ក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយ នៅជិតសមល្មមនឹងទីលំនៅរបស់គាត់ ។

៨.១០.៥ ប្រជាពលរដ្ឋដែលរកមើលមិនឃើញឈ្មោះរបស់ខ្លួន ឬ ខកខានមិនបានទៅផ្ទៀងផ្ទាត់មើលឈ្មោះនៅលើបញ្ជីបោះឆ្នោតចុងក្រោយ ដែលបានបិទផ្សាយនៅតាមទីតាំងការិយាល័យបោះឆ្នោតរបស់ខ្លួន អាចទៅពិនិត្យមើលបញ្ជីបោះឆ្នោតពាក់ព័ន្ធ ដែលមានបិទផ្សាយនៅសាលាឃុំ សង្កាត់ ឬទៅជួបស្មៀនឃុំ សង្កាត់ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ដើម្បីផ្ទៀងផ្ទាត់រកឈ្មោះរបស់ខ្លួន ។

**ជំហានទាំង ៧ នៃការចុះឈ្មោះបោះឆ្នោត**

**ប្រការ ៨.១១** ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនត្រូវធានាថា ការិយាល័យចុះឈ្មោះបោះឆ្នោតនៅទីតាំងសាលាឃុំ សង្កាត់ក្តី ឬនៅតាមភូមិក្តី ត្រូវបានរៀបចំជាស្រេចសម្រាប់បំរើការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ដូចដែលបានចែងក្នុងជំពូក ៥ នៃបទបញ្ជានិងនីតិវិធីរបស់ គជប ។ ក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវតែមានតុកៅអីគ្រប់គ្រាន់សម្រាប់ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនបំពេញការងារ ត្រូវមានកៅអីសម្រាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការមើលការខុសត្រូវលើការងារស្មៀន និងប្រសិនបើអាច គួរមានកៅអីវែងបំរុងសម្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផង ។ បន្ទាប់ពីឆ្លងកាត់បរិវេណខាងក្រៅ អ្នកសុំចុះឈ្មោះបន្តចូលក្នុងបរិវេណខាងក្នុង និងត្រូវឈរបន្តកន្ទុយគ្នានៅខាងក្រៅការិយាល័យចុះឈ្មោះបោះឆ្នោតត្រង់មាត់ទ្វារចូល ដែលនៅទីនោះ កំលាំងរក្សាសណ្តាប់ធ្នាប់ដែលផ្តល់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រធានភូមិ នឹងសំរួលអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តងបី(៣)នាក់ ដូចបានបញ្ជាក់ក្រោមចំណុច ៨.៣.១៧ ខាងលើ ។ នៅពេលបានចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតហើយ អ្នកសុំចុះឈ្មោះត្រូវទៅជួបស្មៀនឃុំ សង្កាត់ ។

៨.១១.១ ដើម្បីចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវអនុវត្តតាមនីតិវិធី ដូចបញ្ជាក់ក្នុងជំហានទាំង៧ ខាងក្រោម ៖

**ជំហានទី ១ : សំណួរបំភ្លឺចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោត**

ស្មៀនឃុំ សង្កាត់ ត្រូវសួរអ្នកសុំចុះឈ្មោះបោះឆ្នោត នូវសំណួរដូចខាងក្រោម ៖

**១_ តើអ្នកបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០២ ឬបានបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៣ ឬធ្លាប់បានចុះឈ្មោះបោះឆ្នោត នៅក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំណាមួយដែរឬទេ ?**

- ប្រសិនបើ អ្នកសុំចុះឈ្មោះឆ្លើយថា « ទេ » នោះ ស្មៀនឃុំ សង្កាត់ត្រូវសួរសំណួរទី ២ ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះឆ្លើយថា « បាទ/ចាស៎ » នោះ ស្មៀនឃុំ សង្កាត់ត្រូវសួរសំណួរទី ៣ ។

**២_ តើអ្នកបានចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ណាមួយ ឬក្នុងឃុំ សង្កាត់នេះនៅក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំនេះ ហើយឬនៅ ?**

- ប្រសិនបើ អ្នកសុំចុះឈ្មោះឆ្លើយថា « ទេ » ស្មៀនឃុំ សង្កាត់ត្រូវបន្តអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោតដូចកំណត់ក្នុងជំហានទី២ ខាងក្រោម ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះឆ្លើយថា « បាទ/ចាស៎ » នោះ ស្មៀនឃុំ សង្កាត់ត្រូវសួរសំណួរទី ៣ ។

**៣_ បើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយហេតុអ្វីបានជាចង់មកចុះឈ្មោះម្តងទៀត ?**

- អ្នកសុំចុះឈ្មោះអាចនឹងឆ្លើយថា ៖
  - ក_ មិនឃើញមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ។
  - ខ_ ឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ សរសេរមិនត្រឹមត្រូវ ។
  - គ_ បានផ្លាស់ប្តូរទីលំនៅមកក្នុងឃុំ សង្កាត់នេះ ចាប់តាំងពីក្រោយពេលបោះឆ្នោតចុងក្រោយ ។
  - ឃ_ឈ្មោះរបស់គាត់មាននៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ នៃការិយាល័យបោះឆ្នោតដែលតាំងនៅឆ្ងាយពេកពីទីលំនៅរបស់គាត់ ។
- ចំពោះករណី « ក » ស្មៀនឃុំ សង្កាត់ស្នើសុំឱ្យអ្នកសុំចុះឈ្មោះប្រាប់លេខកូដនិងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ព្រមទាំងបង្ហាញនូវភស្តុតាងបញ្ជាក់ថាធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ រួចបង្គាប់ទៅជំនួយការស្មៀនឱ្យផ្ទៀងផ្ទាត់រកមើលឈ្មោះជននោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយម្តងទៀត ។ ប្រសិនបើ ជំនួយការស្មៀនរកឃើញឈ្មោះរបស់គាត់ក្នុងបញ្ជីបោះឆ្នោត ត្រូវជំរាបអ្នកសុំចុះឈ្មោះថា គាត់មិនចាំបាច់សុំចុះឈ្មោះម្តងទៀតទេ និងត្រូវកត់ចំណាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតរបស់ខ្លួន ហើយប្រសិនបើអាច ឱ្យកត់ចំណាំលេខរៀងនៃឈ្មោះរបស់គាត់នៅលើបញ្ជីបោះឆ្នោតពាក់ព័ន្ធផង ។ ប៉ុន្តែ ប្រសិនបើជំនួយការស្មៀនរកមិនឃើញឈ្មោះគាត់ក្នុងបញ្ជីបោះឆ្នោតទេ ត្រូវរាយការណ៍អំពីបញ្ហានេះជូនស្មៀនឃុំ សង្កាត់ និងជំរាបអ្នកសុំចុះឈ្មោះឱ្យគាត់ទៅជួបស្មៀនឃុំ សង្កាត់

ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត ដែលត្រូវបន្តអនុវត្តនីតិវិធីនៃជំហានទី ២ ខាងក្រោម ។

- ចំពោះករណី " ខ " ស្មៀនឃុំ សង្កាត់ស្នើសុំឱ្យអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែសរសេរមិនត្រឹមត្រូវនោះ បង្ហាញឯកសារសំគាល់អត្តសញ្ញាណដែលត្រឹមត្រូវ រួចធ្វើការកែតម្រូវដោយគូសរង្វង់ជុំវិញឈ្មោះដែលខុសនឹងប៊ិចក្រហម នៅលើបញ្ជីបោះឆ្នោតពាក់ព័ន្ធ ហើយសរសេរនៅចន្លោះក្បែរនោះនូវឈ្មោះដែលត្រឹមត្រូវ ដូចដែលបានសរសេរនៅលើឯកសារសំគាល់អត្តសញ្ញាណដែលជននោះនឹងប្រើប្រាស់សម្រាប់ការបោះឆ្នោត ។ ស្មៀនឃុំ សង្កាត់មិនចាំបាច់អនុវត្តតាមគ្រប់ចំណុចដូចចែងក្នុងនីតិវិធី ដើម្បីធ្វើការចុះឈ្មោះអ្នកបោះឆ្នោតដែលមានឈ្មោះមិនត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោតនោះឡើយ ។ នៅពេលដែលបានធ្វើការកែតំរូវរួចហើយ ស្មៀនឃុំ សង្កាត់ ត្រូវរំលឹកឱ្យអ្នកបោះឆ្នោតកត់ចំណាំលេខកូដនិងឈ្មោះទីតាំងការិយាល័យបោះឆ្នោតរបស់ខ្លួន ហើយប្រសិនបើអាច ឱ្យកត់ចំណាំលេខរៀងនៃឈ្មោះរបស់គាត់ នៅលើបញ្ជីបោះឆ្នោតពាក់ព័ន្ធផង ដើម្បីផ្ទៀងផ្ទាត់ជាមួយបញ្ជីបោះឆ្នោតដំបូងម្តងទៀត ។ ស្មៀនឃុំ សង្កាត់ត្រូវបង្គាប់ទៅជំនួយការរបស់ខ្លួនឱ្យចម្លងសេចក្តីកែតម្រូវ ដោយប៊ិចក្រហមនៅលើបញ្ជីបោះឆ្នោតពាក់ព័ន្ធចំនួនបី ( ០៣ ) ច្បាប់ទៀត ។
- ចំពោះករណី " គ " និង " ឃ " ចុងក្រោយ ស្មៀនឃុំ សង្កាត់ត្រូវបន្តអនុវត្តនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចបានបញ្ជាក់ក្នុងជំហានទី ២ ខាងក្រោម ។

**ជំហានទី ២ : ការពិនិត្យលក្ខខណ្ឌអត្តសញ្ញាណនៃអ្នកសុំចុះឈ្មោះបោះឆ្នោត**

- ស្មៀនឃុំ សង្កាត់ ត្រូវស្នើអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យបង្ហាញឯកសារដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ។ ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញឯកសារណាមួយដូចមានចែងក្រោមចំណុច ៤.៩.១ ខាងលើ ។

ក_ អត្តសញ្ញាណប័ណ្ណ ដែលផ្តល់អោយដោយរាជរដ្ឋាភិបាលកម្ពុជា ដោយមានបិទរូបថតជាសំគាល់ ។ អត្តសញ្ញាណប័ណ្ណនេះរួមមាន ៖

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលផ្តល់អោយដោយអនុលោមតាមអនុក្រឹត្យលេខ ៣៦ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

ឆាយាគណៈមហានិកាយ ឬសុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ ឬសង្ឃដីកាមានបិទរូបថត ដែលផ្តល់ដោយចៅអធិការវត្តតាមការអនុញ្ញាត និងការណែនាំរបស់ក្រសួងធម្មការ និងកិច្ចការសាសនា ។

ខ_ លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

គ_ សៀវភៅគ្រួសារដែលមានបិទរូបថតរបស់អ្នកសុំចុះឈ្មោះ ។

ឃ_ លិខិតធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីរ ( ២ ) រូប ក្នុងឃុំ សង្កាត់នោះដែលបញ្ជាក់អំពីអត្តសញ្ញាណ និងអាយុរបស់អ្នកសុំចុះឈ្មោះ គួបផ្សំនឹងការបញ្ជាក់ទីលំនៅរបស់អ្នកសុំចុះឈ្មោះ ដែលចេញដោយមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ។

- ស្មៀនឃុំ សង្កាត់មិនអាចសួរដេញដោលទេ ប្រសិនបើ ឯកសារណាមួយដែលបង្ហាញដោយអ្នកសុំចុះឈ្មោះ ត្រូវបានសន្មតថា ត្រឹមត្រូវនិងមានសុពលភាព ។
- កាលណាអ្នកសុំចុះឈ្មោះបានបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ដោយឯកសារដូចបានកំណត់ក្នុងចំណុច ក ខ និង គ ស្មៀនឃុំ សង្កាត់ មិនចាំបាច់ពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌសញ្ជាតិរបស់សាមីជនទៀតទេ ប៉ុន្តែត្រូវបន្តពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌអាយុ និងទីលំនៅរបស់ជននោះ ដូចបានបញ្ជាក់ក្នុងជំហានទី៤ និងជំហានទី៥ រួចត្រូវចុះឈ្មោះជននោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយ ដែលស្ថិតនៅជិតបំផុតនឹងទីលំនៅរបស់សាមីខ្លួន តាមនីតិវិធីដែលបានកំណត់ក្នុងជំហានទី៦ ខាងក្រោម ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះបានបង្ហាញអត្តសញ្ញាណរបស់ខ្លួនដោយសៀវភៅគ្រួសារដែលមានបិទរូបថតរបស់សាមីខ្លួន ស្មៀនឃុំ សង្កាត់មិនចាំបាច់ត្រូវពិនិត្យលក្ខខណ្ឌសញ្ជាតិខ្មែរទេ ។ ប៉ុន្តែ ប្រសិនបើ អ្នកសុំចុះឈ្មោះបានបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ដោយការបង្ហាញលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និង អាយុ ស្មៀនឃុំ សង្កាត់ចាំបាច់ត្រូវពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌសញ្ជាតិរបស់ជននោះ តាមនីតិវិធីដូចបានកំណត់នៅក្នុងជំហានទី ៣ ខាងក្រោម ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះបានបង្ហាញអត្តសញ្ញាណរបស់ខ្លួន ដោយសៀវភៅគ្រួសារ ដែលមិនមានបិទរូបថតសាមីខ្លួន ហើយគ្មានឯកសារអត្តសញ្ញាណអ្វីផ្សេងទៀតទេ ជននោះត្រូវបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ដោយលិខិតធានាអះអាងអត្តសញ្ញាណ ឬ/និង អាយុដូចបានចែងក្នុងចំណុច ឃ ខាងលើ ។ ស្មៀនឃុំ សង្កាត់ត្រូវប្រាប់អ្នកសុំចុះឈ្មោះ ឱ្យទៅជួបអាជ្ញាធរឃុំ សង្កាត់ ដោយនាំទៅជាមួយនូវសាក្សីពីររូប ដើម្បីបំពេញទម្រង់បែបបទលិខិតធានាអះអាងអំពីអត្តសញ្ញាណ

ឬ/និងអាយុ ( ទម្រង់លេខ ១០១៨ ) ចំនួន ២ ច្បាប់ ដែលមានត្រៀមសម្រាប់ផ្តល់ និងបញ្ជាក់ជូនដោយមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង រួចត្រូវត្រឡប់មកសុំចុះឈ្មោះបោះឆ្នោតវិញ ។

- ក្នុងករណី ដែលអ្នកសុំចុះឈ្មោះពុំបានបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណដូចបានកំណត់ចាប់ពីចំណុច ក ដល់ គ ខាងលើទេ ស្មៀនឃុំ សង្កាត់ត្រូវណែនាំជននោះអោយទៅយកឯកសារណាមួយ ក្នុងចំណោមឯកសារទាំងនេះ ឬលិខិតធានាអះអាងអត្តសញ្ញាណ ឬ/និងអាយុ ដូចបានកំណត់ក្នុងចំណុច ឃ នៃជំហានទី២ នេះ ។ ប្រសិនបើ សាមីខ្លួនមិនអាចមានឯកសារណាមួយពី ក ដល់ គ ទេ ស្មៀនឃុំ សង្កាត់ត្រូវប្រាប់អ្នកសុំចុះឈ្មោះ ឱ្យទៅជួបអាជ្ញាធរឃុំ សង្កាត់ ដោយនាំទៅជាមួយនូវសាក្សីពីរ(២)រូប ដើម្បីបំពេញទម្រង់បែបបទលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុ ( ទម្រង់លេខ ១០១៨ ) ចំនួន ២ ច្បាប់ ដែលមានត្រៀមសម្រាប់ផ្តល់ និងបញ្ជាក់ជូនដោយមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង រួចត្រូវត្រឡប់មកសុំចុះឈ្មោះបោះឆ្នោតវិញ ។
- ក្នុងករណី ដែលអ្នកសុំចុះឈ្មោះពុំអាចបង្ហាញ ឬទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណ ដូចបានកំណត់ចាប់ពីចំណុច ក ដល់ ឃ ទេ ការសុំចុះឈ្មោះរបស់ជននោះត្រូវបានបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវសំរេចបដិសេធការសុំចុះឈ្មោះរបស់ជននោះ ដោយអនុវត្តតាមលក្ខខណ្ឌដូចចែងក្នុងចំណុច ៤.៤.២.១១ ខាងលើ ហើយត្រូវបំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោតដោយត្រូវអនុវត្តនីតិវិធីដែលបានកំណត់ក្នុងជំហានទី ៧ ខាងក្រោម និងបង្អាប់ទៅជំនួយការរបស់ខ្លួនឱ្យជួយបំពេញបន្ថែមឱ្យគ្រប់ចំនួនបី(៣)ច្បាប់ រួចដាក់ជូនស្មៀនឃុំ សង្កាត់ចុះហត្ថលេខានិងកាលបរិច្ឆេទ ។ បន្ទាប់មក ស្មៀនឃុំ សង្កាត់ត្រូវផ្តល់សេចក្តីសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោតមួយច្បាប់ ជូនអ្នកសុំចុះឈ្មោះ ដោយបញ្ជាក់ថា ការសុំចុះឈ្មោះត្រូវបានបដិសេធ ដោយមូលហេតុមកពីសាមីខ្លួនគ្មានភស្តុតាង ដែលអាចបង្ហាញអត្តសញ្ញាណរបស់ខ្លួនបាន ។ សេចក្តីសំរេចបដិសេធច្បាប់ទី២ ត្រូវផ្ញើជូនក្រុមប្រឹក្សាឃុំ សង្កាត់ ហើយច្បាប់ទី៣ ត្រូវរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់ ។
- ក្នុងករណីមានការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មានជូនអ្នកសុំចុះឈ្មោះថា សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅនឹងការបដិសេធនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសំរេចបដិសេធ ។ ស្មៀន

ឃុំ សង្កាត់ត្រូវផ្តល់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធតាមសំណើសុំ នូវទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាចំនួន(៤)ច្បាប់ ដែលតម្រូវដោយនីតិវិធីរបស់ គជប ។

**ជំហានទី ៣ : ការផ្ទៀងផ្ទាត់លក្ខខណ្ឌសញ្ជាតិខ្មែរនៃអ្នកសុំចុះឈ្មោះបោះឆ្នោត**

- ប្រសិនបើ អ្នកសុំចុះឈ្មោះបានបង្ហាញអត្តសញ្ញាណរបស់ខ្លួន ដោយឯកសារណាមួយដូចចែងក្នុងចំណុច ក ខ និង គ ដែលបានបញ្ជាក់ក្នុងជំហានទី២ ខាងលើ ស្មៀនឃុំ សង្កាត់មិនចាំបាច់ពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌសញ្ជាតិខ្មែររបស់អ្នកសុំចុះឈ្មោះទៀតទេ ។ ក្នុងករណីនេះ ស្មៀនឃុំ សង្កាត់ត្រូវបន្តពិនិត្យផ្ទៀងផ្ទាត់លើលក្ខខណ្ឌអាយុ និងទីលំនៅរបស់ជននោះ តាមនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតក្នុងជំហានទី៤ និងជំហានទី៥ បន្ទាប់មក ត្រូវចុះឈ្មោះរបស់ជននោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយ ដែលស្ថិតនៅជិតបំផុត នឹងទីលំនៅរបស់សាមីខ្លួន ដោយអនុវត្តតាមនីតិវិធីក្នុងជំហានទី៦ ខាងក្រោម ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះបានបង្ហាញអត្តសញ្ញាណរបស់ខ្លួនដោយសៀវភៅគ្រួសារប្រភេទចាស់មានសុពលភាព ដែលមានបិទរូបថតរបស់សាមីខ្លួន ស្មៀនឃុំ សង្កាត់ត្រូវពិនិត្យ ឱ្យបានប្រាកដថា នៅត្រង់ឈ្មោះរបស់ជននោះក្នុងសៀវភៅគ្រួសារ មានបញ្ជាក់ថា មានសញ្ជាតិខ្មែរ ។ ក្នុងករណីនេះ ចំពោះអ្នកសុំចុះឈ្មោះដែលមានសញ្ជាតិខ្មែរ ស្មៀនឃុំ សង្កាត់ត្រូវបន្តពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌអាយុ និងទីលំនៅរបស់ជននោះតាមនីតិវិធី សម្រាប់ការចុះឈ្មោះបោះឆ្នោតក្នុងជំហានទី៤ និងជំហានទី៥ បន្ទាប់មក ត្រូវចុះឈ្មោះរបស់ជននោះ នៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយ ដែលស្ថិតនៅជិតបំផុតនឹងទីលំនៅរបស់សាមីខ្លួន ដោយអនុវត្តតាមនីតិវិធីក្នុងជំហានទី៦ ខាងក្រោម ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះបានបញ្ជាក់ភស្តុតាង ដើម្បីសុំចុះឈ្មោះដោយបង្ហាញសៀវភៅគ្រួសារ ដែលមានឈ្មោះរបស់ខ្លួនមានសញ្ជាតិខ្មែរក្នុងនោះ តែមិនមានបិទរូបថតសាមីខ្លួនទេ ស្មៀនឃុំ សង្កាត់ត្រូវណែនាំសាមីខ្លួន ឱ្យបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ដោយបង្ហាញបន្ថែមនូវឯកសារណាមួយ ដូចបានចែងក្នុងចំណុច ក និង ខ ឬលិខិតធានាអះអាងអត្តសញ្ញាណឬ/និងអាយុ ដូចបានចែងក្នុងចំណុច ឃ ដែលបានកំណត់ក្នុងជំហានទី២ ខាងលើ រួចត្រូវត្រឡប់មកសុំចុះឈ្មោះបោះឆ្នោតវិញ ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះបានបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ដោយលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុ ដូចបានចែងក្នុងចំណុច ឃ ស្មៀនឃុំ

សង្កាត់ត្រូវស្នើសុំអ្នកសុំចុះឈ្មោះឱ្យបង្ហាញឯកសារណាមួយ ដើម្បីបញ្ជាក់ថា ខ្លួនមានសញ្ជាតិខ្មែរ ។ លិខិតធានាអះអាងអត្តសញ្ញាណ ឬ/និងអាយុរបស់អ្នកសុំចុះឈ្មោះ ដូចបានចែងក្នុងចំណុច ឃ ខាងលើ ឬ/និង សៀវភៅស្នាក់នៅ ( ឯកសារ ក២ ) មិនអាចបញ្ជាក់ និងមិនមានតម្លៃបញ្ជាក់ពីសញ្ជាតិខ្មែរបានទេ ។ ក្នុងករណីនេះ ដើម្បីបំពេញលក្ខខណ្ឌសញ្ជាតិខ្មែរ សម្រាប់ការចុះឈ្មោះបោះឆ្នោត អ្នកសុំចុះឈ្មោះត្រូវបង្ហាញឯកសារដូចបានចែងក្នុងចំណុច ក ខ និង គ ឬឯកសារណាមួយដូចខាងក្រោម ៖

ង_ សំបុត្រកំណើតដែលមានបញ្ជាក់ពីសញ្ជាតិខ្មែររបស់សាមីខ្លួន ។

ច_ លិខិតដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់ថាសាមីខ្លួនមានសញ្ជាតិខ្មែរ។

ឆ_ លិខិតបញ្ជាក់ ឬឯកសារ ឬសេចក្តីសម្រេចស្ថាពររបស់តុលាការ ដែលបញ្ជាក់ថា ឪពុក ឬ ម្តាយរបស់សាមីអ្នកសុំចុះឈ្មោះជាប្រជាពលរដ្ឋខ្មែរ និងឯកសារដែលបង្ហាញថា សាមីអ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុក ឬម្តាយនោះ ។

ជ_ឯកសារជាផ្លូវការបញ្ជាក់ថា សាមីអ្នកសុំចុះឈ្មោះបានកើតនៅក្នុងប្រទេសកម្ពុជា ហើយឪពុក និងម្តាយបរទេសរបស់ជននោះ ក៏កើតនិងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាដែរ និង ឯកសារជាផ្លូវការដែលបង្ហាញថា សាមីអ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុក និងម្តាយនោះ ។

- ស្មៀនឃុំ សង្កាត់មិនអាចសួរដេញដោលទេ ប្រសិនបើ ឯកសារណាមួយដែលបានបង្ហាញដោយអ្នកសុំចុះឈ្មោះ ត្រូវបានសន្មតថាត្រឹមត្រូវនិងមានសុពលភាព ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះមិនមានសញ្ជាតិខ្មែរទេ ការចុះឈ្មោះរបស់ជននោះត្រូវតែបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវសំរេចបដិសេធការសុំចុះឈ្មោះរបស់ជននោះ ដោយអនុវត្តតាមលក្ខខណ្ឌដូចចែងក្នុងចំណុច ៤.៤.២.១១ ខាងលើ ហើយត្រូវបំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោតដោយអះអាងពីមូលហេតុនៃការបដិសេធថា សាមីខ្លួនមិនមានសញ្ជាតិខ្មែរទេ ដែលត្រូវអនុវត្តតាមនីតិវិធីក្នុងជំហានទី៧ ខាងក្រោម ។ ស្មៀនឃុំ សង្កាត់ត្រូវបង្គាប់ទៅជំនួយការរបស់ខ្លួនឱ្យបំពេញបន្ថែមឱ្យគ្រប់ចំនួនបី ( ៣ ) ច្បាប់ រួចដាក់ជូនស្មៀនឃុំសង្កាត់ចុះហត្ថលេខា និងកាលបរិច្ឆេទ បន្ទាប់មក ត្រូវផ្តល់សេចក្តីសំរេចបដិសេធការសុំចុះឈ្មោះមួយ(១)ច្បាប់ ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់មួយច្បាប់ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំសង្កាត់មួយច្បាប់ ។

- ប្រសិនបើ អ្នកសុំចុះឈ្មោះប្រកាសថា គាត់មានសញ្ជាតិខ្មែរ តែមិនអាចផ្តល់ឯកសារផ្លូវការណាមួយ ដូចបានចែងតម្រូវខាងលើជាភស្តុតាង ការសុំចុះឈ្មោះរបស់ជននោះត្រូវតែបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវសំរេចបដិសេធការសុំចុះឈ្មោះរបស់ជននោះ ដោយអនុវត្តតាមលក្ខខណ្ឌដូចចែងក្នុងចំណុច ៤.៤.២.១១ ខាងលើ ហើយត្រូវបំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោតដោយបញ្ជាក់ពីមូលហេតុ នៃការបដិសេធថា សាមីខ្លួនមិនអាចបង្ហាញឯកសារបញ្ជាក់ពីសញ្ជាតិខ្មែរបាន ដែលត្រូវអនុវត្តតាមនីតិវិធីក្នុងជំហានទី៧ ខាងក្រោម ។ ស្មៀនឃុំ សង្កាត់ត្រូវបង្គាប់ទៅជំនួយការរបស់ខ្លួនឱ្យបំពេញទម្រង់បែបបទនេះបន្ថែមឱ្យគ្រប់ចំនួន បី(៣)ច្បាប់ រួចដាក់ជូនស្មៀនឃុំ សង្កាត់ចុះហត្ថលេខា និងកាលបរិច្ឆេទ បន្ទាប់មក ត្រូវផ្តល់សេចក្តីសំរេចបដិសេធការសុំចុះឈ្មោះមួយច្បាប់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់មួយច្បាប់ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់មួយច្បាប់ ។
- ក្នុងករណីមានការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មានជូនអ្នកសុំចុះឈ្មោះថា សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅនឹងការបដិសេធនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេល បី(៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសំរេចបដិសេធ ។ ស្មៀនឃុំ សង្កាត់ ត្រូវផ្តល់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធតាមសំណើសុំ នូវទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាចំនួន(៤)ច្បាប់ ដែលតម្រូវដោយនីតិវិធីរបស់ គជប ។

**ជំហានទី ៤ : ការផ្ទៀងផ្ទាត់លក្ខខណ្ឌអាយុរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត**

- ស្មៀនឃុំ សង្កាត់ត្រូវយល់ដឹងឱ្យប្រាកដថា អ្នកសុំចុះឈ្មោះត្រូវតែមានអាយុយ៉ាងតិចដប់ប្រាំបី ( ១៨ ) ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត ក្នុងករណីមានការរៀបចំការបោះឆ្នោតដែលកំណត់ដោយច្បាប់ ឬគិតដល់ថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជាប្រចាំឆ្នាំ ទើបមានសិទ្ធិចុះឈ្មោះបោះឆ្នោត ។
- ក្នុងករណី អ្នកសុំចុះឈ្មោះបានបង្ហាញឯកសារផ្លូវការ ដែលបញ្ជាក់នូវលក្ខខណ្ឌអត្តសញ្ញាណ និងសញ្ជាតិរួចហើយ និងប្រសិនបើ គ្មានការសង្ស័យថា អ្នកសុំចុះឈ្មោះមានអាយុតិចជាង ១៨ ឆ្នាំទេ ស្មៀនឃុំ សង្កាត់ត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌទីលំនៅរបស់សាមីខ្លួន តាមនីតិវិធីក្នុងជំហានទី៥ ខាងក្រោម បន្ទាប់មក ត្រូវចុះឈ្មោះរបស់ជននោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយ ដែលស្ថិតនៅ

ជិតបំផុតនឹងទីលំនៅរបស់សាមីខ្លួន ឬ នៃការិយាល័យណាមួយតាមសំណូមពររបស់សាមីខ្លួន ដោយអនុវត្តតាមនីតិវិធីក្នុងជំហានទី ៦ ខាងក្រោម ។

- ក្នុងករណី អ្នកសុំចុះឈ្មោះបានបង្ហាញឯកសារផ្លូវការ ដែលបញ្ជាក់នូវលក្ខខណ្ឌអត្តសញ្ញាណ និងសញ្ជាតិរួចហើយ និងប្រសិនបើ មានការសង្ស័យថា អ្នកសុំចុះឈ្មោះពុំទាន់គ្រប់អាយុស្របច្បាប់ សម្រាប់ការចុះឈ្មោះបោះឆ្នោតទេ ស្មៀនឃុំ សង្កាត់ត្រូវពិនិត្យផ្ទៀងផ្ទាត់អោយប្រាកដថា ដោយផ្អែកលើឯកសារបញ្ជាក់អត្តសញ្ញាណណាមួយដែលអ្នកសុំចុះឈ្មោះបានយកមកបង្ហាញ គាត់ត្រូវតែមានអាយុយ៉ាងតិចដប់ប្រាំបី ( ១៨ ) ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត ក្នុងករណីមានការរៀបចំការបោះឆ្នោតដែលកំណត់ដោយច្បាប់ ឬគិតដល់ថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ ដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជាប្រចាំឆ្នាំ ។ ប្រសិនបើឯកសារអត្តសញ្ញាណដែលអ្នកសុំចុះឈ្មោះយកមកបង្ហាញនោះគ្មានបញ្ជាក់អំពីអាយុ ឬថ្ងៃខែឆ្នាំកំណើតទេនោះ អ្នកសុំចុះឈ្មោះត្រូវបញ្ជាក់អាយុរបស់ខ្លួនដោយបង្ហាញបន្ថែមនូវឯកសារណាមួយផ្សេងទៀត ដែលមានបញ្ជាក់អំពីអាយុ ឬ ឆ្នាំកំណើត ឬថ្ងៃខែឆ្នាំកំណើត ក្នុងចំណោមឯកសារដូចបានចែងក្នុងចំណុច ក ខ គ ឃ ង ច ឆ និង ជ ដែលបានកំណត់ក្នុងជំហានទី២ និងជំហានទី៣ ខាងលើ ។

  ប្រសិនបើ មានឯកសារណាមួយក្នុងចំណោមឯកសារដូចបានចែងក្នុងចំណុច ក ខ គ ឃ ង ច ឆ និង ជ ខាងលើ ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតបានបង្ហាញ មានបញ្ជាក់អំពីអាយុ ឬឆ្នាំកំណើត ឬថ្ងៃខែឆ្នាំកំណើតរបស់សាមីខ្លួនដែលគ្រប់អាយុចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌទីលំនៅរបស់សាមីខ្លួន តាមនីតិវិធីក្នុងជំហានទី៥ ខាងក្រោម បន្ទាប់មក ត្រូវចុះឈ្មោះរបស់ជននោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយ ដែលស្ថិតនៅជិតបំផុតនឹងទីលំនៅរបស់សាមីខ្លួន ឬនៃការិយាល័យណាមួយតាមសំណូមពររបស់សាមីខ្លួន ដោយអនុវត្តតាមនីតិវិធីក្នុងជំហានទី ៦ ខាងក្រោម ។

  ប្រសិនបើ ក្នុងចំណោមឯកសារដូចបានចែងក្នុងចំណុច ក ខ គ ង ច ឆ និង ជ ខាងលើ ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតបានបង្ហាញ គ្មានឯកសារណាមួយមានបញ្ជាក់អំពីអាយុ ឬឆ្នាំកំណើត ឬថ្ងៃខែឆ្នាំកំណើតរបស់សាមីខ្លួនទេនោះ ស្មៀនឃុំ សង្កាត់ត្រូវជំរាបអ្នកសុំចុះឈ្មោះថា គាត់អាចបញ្ជាក់អាយុរបស់ខ្លួន ដែលពិតជាមានអាយុយ៉ាងតិចដប់ប្រាំបី ( ១៨ ) ឆ្នាំ

គិតដល់ថ្ងៃបោះឆ្នោតក្នុងករណីមានការរៀបចំការបោះឆ្នោតដែលកំណត់ដោយច្បាប់ ឬគិតដល់ថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ ដែលត្រូវអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជាប្រចាំឆ្នាំ ដោយការបង្ហាញលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុ ដូចចែងក្នុងចំណុច ឃ ក្នុងជំហានទី២ ខាងលើ ។ ក្នុងករណីនេះ ស្មៀនឃុំ សង្កាត់ត្រូវប្រាប់អ្នកសុំចុះឈ្មោះឱ្យទៅជួបអាជ្ញាធរឃុំ សង្កាត់ ដោយនាំទៅជាមួយនូវសាក្សីពីរ(២)រូប ដើម្បីបំពេញទម្រង់បែបបទលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុ ( ទម្រង់លេខ ១០១៨ ) ចំនួន ២ ច្បាប់ ដែលមានត្រៀមសម្រាប់ផ្តល់និងបញ្ជាក់ជូនដោយមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង រួចត្រូវត្រឡប់មកសុំចុះឈ្មោះបោះឆ្នោតវិញ បន្ទាប់ពីទទួលបានលិខិតធានានេះ ។

នៅពេលដែលអ្នកសុំចុះឈ្មោះបានបង្ហាញលិខិតធានាអះអាង អំពីអាយុរបស់សាមីខ្លួនដែលពិតជាគ្រប់អាយុបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌទីលំនៅរបស់សាមីខ្លួន តាមនីតិវិធីក្នុងជំហានទី៥ ខាងក្រោម បន្ទាប់មក ត្រូវចុះឈ្មោះរបស់ជននោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយដែលស្ថិតនៅជិតបំផុតនឹងទីលំនៅរបស់សាមីខ្លួន ឬនៃការិយាល័យណាមួយតាមសំណូមពររបស់សាមីខ្លួន ដោយអនុវត្តតាមនីតិវិធីក្នុងជំហានទី ៦ ខាងក្រោម ។

ប្រសិនបើ ក្នុងចំណោមឯកសារដូចបានចែងក្នុងចំណុច ក ខ គ ឃ ង ច ឆ និង ជ ខាងលើ ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតបានបង្ហាញ គ្មានឯកសារណាមួយមានបញ្ជាក់អំពីអាយុ ឬឆ្នាំកំណើត ឬថ្ងៃខែឆ្នាំកំណើតរបស់សាមីខ្លួនទេ ស្មៀនឃុំ សង្កាត់ត្រូវជំរាបអ្នកសុំចុះឈ្មោះថា ការសុំចុះឈ្មោះត្រូវបានបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវសំរេចបដិសេធការសុំចុះឈ្មោះរបស់ជននោះ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចចែងក្នុងចំណុច ៦.៣.២.១ ខាងលើ ហើយត្រូវបំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធថា សាមីខ្លួនមិនអាចបង្ហាញឯកសារបញ្ជាក់គ្រប់អាយុបោះឆ្នោតបាន ដែលត្រូវអនុវត្តតាមនីតិវិធីក្នុងជំហានទី ៧ ខាងក្រោម ។ ស្មៀនឃុំ សង្កាត់ត្រូវបង្គាប់ទៅជំនួយការរបស់ខ្លួនឱ្យបំពេញបន្ថែមទម្រង់បែបបទនេះឱ្យគ្រប់ចំនួនបី ( ៣ ) ច្បាប់ រួចដាក់ជូនស្មៀនឃុំ សង្កាត់ ចុះហត្ថលេខា និងកាលបរិច្ឆេទ បន្ទាប់មក ត្រូវផ្តល់សេចក្តីសំរេច

បដិសេធការសុំចុះឈ្មោះមួយច្បាប់ ជូនអ្នកសុំចុះឈ្មោះ ដែលត្រូវបដិសេធ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់មួយច្បាប់ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់មួយច្បាប់ ។

- ក្នុងករណីមានការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មានជូនអ្នកសុំចុះឈ្មោះថា សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅនឹងការបដិសេធនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលបី(៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសំរេចបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធតាមសំណើសុំ នូវទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាចំនួន(៤)ច្បាប់ ដែលតម្រូវដោយនីតិវិធីរបស់ គជប ។

**ជំហានទី ៥ : ការផ្ទៀងផ្ទាត់លក្ខខណ្ឌទីលំនៅរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត**

- ស្មៀនឃុំ សង្កាត់ត្រូវយល់ដឹងឱ្យប្រាកដថា អ្នកសុំចុះឈ្មោះត្រូវតែជាប្រជាពលរដ្ឋមានទីលំនៅក្នុងឃុំ សង្កាត់ ដែលគាត់សុំចុះឈ្មោះបោះឆ្នោត ។
- ក្នុងករណី អ្នកសុំចុះឈ្មោះបានបង្ហាញឯកសារផ្លូវការ ដែលបញ្ជាក់នូវលក្ខខណ្ឌអត្តសញ្ញាណ សញ្ជាតិ និងអាយុរួចហើយ ស្មៀនឃុំ សង្កាត់ត្រូវបន្តពិនិត្យផ្ទៀងផ្ទាត់អោយប្រាកដថា អ្នកសុំចុះឈ្មោះមានទីលំនៅក្នុងឃុំ សង្កាត់ ដោយផ្អែកលើឯកសារបញ្ជាក់អត្តសញ្ញាណណាមួយដែលអ្នកសុំចុះឈ្មោះបានយកមកបង្ហាញ ។ ប្រសិនបើ ឯកសារអត្តសញ្ញាណ ដែលអ្នកសុំចុះឈ្មោះយកមកបង្ហាញនោះគ្មានការបញ្ជាក់ទីលំនៅរបស់សាមីខ្លួនទេ អ្នកសុំចុះឈ្មោះត្រូវបញ្ជាក់លក្ខខណ្ឌទីលំនៅរបស់ខ្លួន ដោយបង្ហាញបន្ថែមនូវសៀវភៅស្នាក់នៅ ( ឯកសារ ក២ ) ឬឯកសារណាមួយផ្សេងទៀត ដែលមានបញ្ជាក់ទីលំនៅរបស់សាមីខ្លួន ក្នុងចំណោមឯកសារដូចបានចែងក្នុងចំណុច ក ខ គ ឃ ង ច ឆ និង ជ ដែលបានកំណត់ក្នុងជំហានទី២ និងជំហានទី៣ ខាងលើ ។

  ប្រសិនបើ សៀវភៅស្នាក់នៅ ( ឯកសារ ក២ ) ឬ ឯកសារណាមួយក្នុងចំណោមឯកសារដូចចែងក្នុងចំណុច ក ខ គ ឃ ង ច ឆ និង ជ ខាងលើ ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតបានបង្ហាញ មានបញ្ជាក់អំពីទីលំនៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ ដែលគាត់កំពុងសុំចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវចុះឈ្មោះរបស់ជននោះ នៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យ

ណាមួយ ដែលស្ថិតនៅជិតបំផុតនឹងទីលំនៅរបស់សាមីខ្លួន ដោយអនុវត្តតាមនីតិវិធីក្នុងជំហានទី៦ ខាងក្រោម ។

ប្រសិនបើ ក្នុងចំណោមឯកសារដូចបានចែងក្នុងចំណុច ក ខ គ ឃ ង ច ឆ និង ជ ខាងលើ ឬសៀវភៅស្នាក់នៅ ( ឯកសារ ក២ ) ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតបានបង្ហាញ គ្មានឯកសារណាមួយមានបញ្ជាក់អំពីទីលំនៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ទេ ស្មៀនឃុំ សង្កាត់ត្រូវជំរាបអ្នកសុំចុះឈ្មោះថា គាត់អាចបញ្ជាក់ទីលំនៅរបស់ខ្លួនបាន ដោយលិខិតបញ្ជាក់ទីលំនៅដែលចេញដោយអាជ្ញាធរឃុំ សង្កាត់ ដោយមិនចាំបាច់បង់សោហ៊ុយឡើយ ។ ផ្អែកតាមសំណើសុំរបស់អ្នកសុំចុះឈ្មោះ ដែលមានទីលំនៅពិតប្រាកដក្នុងឃុំ សង្កាត់ ព្រមទាំងយោងតាមនីតិវិធីនិងបែបបទកំណត់ដោយក្រសួងមហាផ្ទៃ អាជ្ញាធរឃុំ សង្កាត់ត្រូវបំពេញនិងចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ( ទម្រង់បែបបទលេខ ១០១៨ ) ចំនួន ២ ច្បាប់ រួចប្រគល់ជូនអ្នកស្នើសុំមួយច្បាប់ និងជំរាបគាត់ឱ្យត្រឡប់ទៅជួបស្មៀន ដើម្បីសុំចុះឈ្មោះបោះឆ្នោតវិញ ។

នៅពេលដែល អ្នកសុំចុះឈ្មោះបានបង្ហាញលិខិតបញ្ជាក់ទីលំនៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវចុះឈ្មោះរបស់ជននោះ នៅក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យណាមួយ ដែលស្ថិតនៅជិតបំផុតនឹងទីលំនៅរបស់សាមីខ្លួន ដោយអនុវត្តតាមនីតិវិធីក្នុងជំហានទី៦ ខាងក្រោម ។

ប្រសិនបើ ក្នុងចំណោមឯកសារដូចបានចែងក្នុងចំណុច ក ខ គ ឃ ង ច ឆ និង ជ ខាងលើ ឬសៀវភៅស្នាក់នៅ ( ឯកសារ ក២ ) ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតបានបង្ហាញ គ្មានឯកសារណាមួយមានបញ្ជាក់អំពីទីលំនៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ទេ ហើយអ្នកសុំចុះឈ្មោះក៏មិនអាចទទួល និងបង្ហាញលិខិតបញ្ជាក់ទីលំនៅបានទេ ស្មៀនឃុំ សង្កាត់ត្រូវជំរាបអ្នកសុំចុះឈ្មោះថា ការសុំចុះឈ្មោះរបស់គាត់ត្រូវបានបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវសំរេចបដិសេធការសុំចុះឈ្មោះរបស់ជននោះ ដោយអនុវត្តតាមលក្ខខណ្ឌដូចចែងក្នុងចំណុច ៨.៨.២.១១ ខាងលើ និងត្រូវបំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធថា សាមីខ្លួនមិនអាចបង្ហាញឯកសារបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់បានដែលត្រូវអនុវត្តតាមនីតិវិធីក្នុងជំហានទី ៧ ខាងក្រោម ។ ស្មៀនឃុំ សង្កាត់ត្រូវបង្កាប់ទៅជំនួយការរបស់ខ្លួន ឱ្យបំពេញទម្រង់បែបបទនេះបន្ថែម

ឱ្យគ្រប់ចំនួនបី(៣)ច្បាប់ រួចដាក់ជូនស្មៀនឃុំ សង្កាត់ចុះហត្ថលេខានិងកាលបរិច្ឆេទ បន្ទាប់មក ត្រូវផ្តល់សេចក្តីសំរេចបដិសេធការសុំចុះឈ្មោះមួយច្បាប់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ និងត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់មួយច្បាប់ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់មួយច្បាប់ ។

- ក្នុងករណីមានការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មានជូនអ្នកសុំចុះឈ្មោះថា សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅនឹងការបដិសេធនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលបី(៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសំរេចបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធតាមសំណើសុំ នូវទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាចំនួន(៤)ច្បាប់ ដែលតម្រូវដោយនីតិវិធីរបស់ គជប ។
- ចំពោះអ្នកសុំចុះឈ្មោះជា កម្មករ សិស្ស និស្សិត មន្ត្រីរាជការ ប៉ូលីស និងយោធា ដែលមានទីលំនៅជាប់ជាបណ្តោះអាសន្នក្នុងឃុំ សង្កាត់ ប្រសិនបើអ្នកសុំចុះឈ្មោះទាំងនោះបានបំពេញលក្ខខណ្ឌអត្តសញ្ញាណ សញ្ជាតិ និងអាយុរួចហើយ គាត់ចាំបាច់ត្រូវមានការបញ្ជាក់ទីលំនៅរបស់ខ្លួនក្នុងឃុំ សង្កាត់ ដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត ។ នៅពេលដែល អ្នកសុំចុះឈ្មោះបានបំពេញលក្ខខណ្ឌទីលំនៅក្នុងឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវចុះឈ្មោះរបស់គាត់ក្នុងបញ្ជីបោះឆ្នោតណាមួយ តាមលំនាំដូចគ្នានឹងការចុះឈ្មោះអ្នកសុំចុះឈ្មោះទូទៅដែរ ។ ក្នុងករណីនេះ ប្រសិនបើ អ្នកសុំចុះឈ្មោះធ្លាប់បានចុះឈ្មោះបោះឆ្នោតចុងក្រោយរួចហើយ ឬទើបនឹងបានចុះឈ្មោះលើកនេះ នៅក្នុងឃុំ សង្កាត់ដទៃទៀត ដែលជននោះរស់នៅជាអចិន្ត្រៃយ៍ ស្មៀនឃុំ សង្កាត់មិនត្រូវភ្លេចបំពេញនិងអោយអ្នកសុំចុះឈ្មោះផ្តិតមេដៃលើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៧ ) ដើម្បីអោយ គជប លុបឈ្មោះជននោះចេញពីបញ្ជីបោះឆ្នោតនៅក្នុងឃុំ សង្កាត់ផ្សេងនោះ ឬការិយាល័យបោះឆ្នោតដទៃទៀត ដែលអ្នកសុំចុះឈ្មោះនោះបានចុះឈ្មោះពីមុន ។

  អ្នកសុំចុះឈ្មោះជា កម្មករ សិស្ស និស្សិត មន្ត្រីរាជការ ប៉ូលីស និងយោធា ដែលមានទីលំនៅជាប់ជាបណ្តោះអាសន្នក្នុងឃុំ សង្កាត់ ហើយមានបំណងស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ត្រូវទៅជួបស្នើសុំពីមេឃុំ ចៅសង្កាត់ ឬ ជំទប់ ចៅសង្កាត់រង ដែលបានប្រគល់សិទ្ធិ ដោយត្រូវអនុវត្តតាមនីតិវិធី និងបែបបទណែនាំរបស់ក្រសួងមហាផ្ទៃ ។

ប្រសិនបើ អ្នកស្នើសុំលិខិតបញ្ជាក់ទីលំនៅបានឆ្លើយតបគ្រប់គ្រាន់តាមបែបបទកំណត់របស់ក្រសួងមហាផ្ទៃហើយ អាជ្ញាធរឃុំ សង្កាត់ត្រូវចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ជូនសាមីជន ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបាន ។

អាជ្ញាធរឃុំ សង្កាត់ត្រូវចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយត្រូវបំពេញទម្រង់បែបបទលេខ ១០១៩ ចំនួនពីរ(២)ច្បាប់ រួចប្រគល់ជូនសាមីខ្លួនមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**ជំហានទី ៦ : ការបំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោត**

- ស្មៀនឃុំ សង្កាត់ គ្មានសិទ្ធិ / ឆន្ទានុសិទ្ធិ ក្នុងចុះការឈ្មោះជនណាម្នាក់ដែលមិនបានបង្ហាញឯកសារផ្លូវការណាមួយ ដូចបានកំណត់ក្នុងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬបានបង្ហាញឯកសារណាមួយ ឬច្រើន ដែលមិនបានឆ្លើយតបគ្រប់គ្រាន់ទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោតនោះឡើយ ។
- ស្មៀនឃុំ សង្កាត់ គ្មានសិទ្ធិ / ឆន្ទានុសិទ្ធិ បដិសេធមិនចុះឈ្មោះជនណាម្នាក់ដែលបានបង្ហាញឯកសារផ្លូវការណាមួយ ឬច្រើន ក្នុងចំណោមឯកសារ ដូចបានកំណត់ក្នុងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ហើយដែលបានឆ្លើយតបគ្រប់គ្រាន់ទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោតនោះឡើយ ។
- នៅពេលដែលអ្នកសុំចុះឈ្មោះបានបង្ហាញឯកសារផ្លូវការមួយឬច្រើន ក្នុងចំណោមឯកសារដូចបានកំណត់ក្នុងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ហើយដែលបានឆ្លើយតបគ្រប់គ្រាន់ទៅនឹងលក្ខណៈវិនិច្ឆ័យ សម្រាប់ការចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវចុះឈ្មោះជូនសាមីខ្លួន ដោយត្រូវបំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោត/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ។

  ជាដំបូង ស្មៀនឃុំ សង្កាត់ត្រូវកំណត់លេខកូដនិងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដែលត្រូវចុះឈ្មោះអ្នកសុំចុះឈ្មោះ និងដែលស្ថិតនៅជិតបំផុតនឹងទីលំនៅរបស់សាមីអ្នកសុំចុះឈ្មោះ ។

  ស្មៀនឃុំ សង្កាត់ត្រូវបំពេញទម្រង់បែបបទនេះនៅលើផ្នែកទាំងពីរ ( ផ្នែកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត និងផ្នែកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ) ដោយសរសេរឱ្យបានច្បាស់លាស់នូវលេខកូដនិងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធរបស់អ្នកសុំចុះឈ្មោះផ្អែកលើឯកសារអត្តសញ្ញាណ ដែលត្រូវប្រើនៅពេលបោះឆ្នោត ព្រមទាំងត្រូវគូសសញ្ញា

សំគាល់ឯកសារ ដែលអ្នកសុំចុះឈ្មោះបានបង្ហាញ និងដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោត ។

ស្មៀនឃុំ សង្កាត់ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោតនៅលើផ្នែកទាំងពីរនៃទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត បន្ទាប់មក ត្រូវហែកផ្នែកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត រួចប្រគល់បង្កាន់ដៃនេះជូនអ្នកសុំចុះឈ្មោះ និងជំរាបគាត់ឱ្យចងចាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតរបស់ខ្លួនដែលមានសរសេរក្នុងបង្កាន់ដៃនេះ ។ មកដល់ដំណាក់ការនេះ អ្នកសុំចុះឈ្មោះអាចកំណត់បានថា ត្រូវបានចុះឈ្មោះជាអ្នកបោះឆ្នោត និងអាចចេញពីការិយាល័យចុះឈ្មោះបោះឆ្នោតបាន ។

ស្មៀនឃុំ សង្កាត់ត្រូវសរសេរឈ្មោះរបស់អ្នកដែលត្រូវបានយល់ព្រមឱ្យចុះឈ្មោះ និងទិន្នន័យពាក់ព័ន្ធ នៅលើបញ្ជីបោះឆ្នោតបន្ថែម ដែលមានបំរុងស្រាប់សម្រាប់បំពេញ ដោយចម្លងចេញពីផ្នែកគល់សន្លឹកនៃទម្រង់បែបបទចុះឈ្មោះបោះឆ្នោត/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ក្នុងនោះ ត្រូវកត់ត្រាលេខទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតផង ។ ស្មៀនឃុំ សង្កាត់ត្រូវបង្គាប់ទៅជំនួយការរបស់ខ្លួន ឱ្យចម្លងបញ្ជីបោះឆ្នោតបន្ថែម ដើម្បីបង្គ្រប់ចំនួនបួន(៤)ច្បាប់ ។ ប្រសិនបើ អ្នកសុំចុះឈ្មោះមានវត្តមានច្រើន ស្មៀនឃុំ សង្កាត់និងជំនួយការស្មៀនអាចបំពេញការងារសរសេរចម្លងឈ្មោះក្នុងបញ្ជីបោះឆ្នោតបន្ថែម នៅចន្លោះពេលទំនេរ ដែលគ្មានវត្តមានអ្នកសុំចុះឈ្មោះបោះឆ្នោត ។

ក្នុងរាល់ករណី ស្មៀនឃុំ សង្កាត់យល់ព្រមចុះឈ្មោះជូនអ្នកសុំចុះឈ្មោះណាម្នាក់ ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនត្រូវបំពេញការងារជាសង្វាក់តាមលំនាំការណែនាំ ដូចបានចែងក្នុងចំណុចនានានៃជំហានទី៦ នេះ ។

- ប្រសិនបើ ស្មៀនឃុំ សង្កាត់មានកំហុស ក្នុងការបំពេញទម្រង់បែបបទចុះឈ្មោះបោះឆ្នោត/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវបដិសេធចោលសន្លឹកទម្រង់បែបបទដែលខុស ដោយសរសេរពាក្យថា “ លុបចោល ” លើទម្រង់ទាំងមូល ( រួមទាំងបង្កាន់ដៃផង ) ហើយត្រូវបំពេញទម្រង់បែបបទថ្មីមួយទៀត ។

- ក្នុងករណី ដែលអ្នកសុំចុះឈ្មោះបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ឬនៅឃុំ សង្កាត់ផ្សេងរួចហើយ ស្មៀនឃុំ សង្កាត់មិនត្រូវភ្លេចបំពេញ និងតម្រូវអោយសាមីខ្លួនផ្តិតមេដៃ លើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត( ១០១៧ )ចំនួនពីរ(២)ច្បាប់ ដើម្បីអោយ គជប លុបឈ្មោះជននោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតផ្សេង ឬ នៃឃុំ សង្កាត់ផ្សេង ដែលអ្នកសុំចុះឈ្មោះនោះបានចុះឈ្មោះកាលពីមុន ។ ស្មៀនឃុំ សង្កាត់ត្រូវចាត់ចែងទំរង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដូចខាងក្រោម ៖

  ទម្រង់បែបបទលុបឈ្មោះអ្នកដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតផ្សេងណាមួយក្នុងឃុំ សង្កាត់ ត្រូវផ្ញើជូន គជប មួយច្បាប់ ដែលត្រូវដាក់ក្នុងកញ្ចប់ ក នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់មួយច្បាប់ ។

  ទម្រង់បែបបទលុបឈ្មោះអ្នកដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ផ្សេង ត្រូវផ្ញើជូន គជប មួយច្បាប់ ដែលត្រូវច្រកស្រោមសំបុត្រដាក់ក្នុងកញ្ចប់ ខ នៃឃុំ សង្កាត់ពាក់ព័ន្ធ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់មួយច្បាប់ ។

- ចំពោះករណី អ្នកសុំចុះឈ្មោះដែលបានចុះឈ្មោះរួចហើយ នៅក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់តែមួយ តែនៅការិយាល័យបោះឆ្នោតផ្សេងគ្នា បន្ទាប់ពីពេលដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យថ្មីរួចហើយ ស្មៀនឃុំ សង្កាត់ត្រូវបង្ការកុំអោយមានការចុះឈ្មោះ ២ ដង ដោយត្រូវគូសបន្ទាត់លុបឈ្មោះអ្នកបោះឆ្នោតនោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដែលបានចុះឈ្មោះលើកមុន ។ ស្មៀនឃុំ សង្កាត់ត្រូវបង្គាប់ទៅជំនួយការរបស់ខ្លួនឱ្យគូសបន្ទាត់លុបឈ្មោះតាមលំនាំដូចគ្នានេះ នៅលើបញ្ជីបោះឆ្នោតបី( ៣ )ច្បាប់ផ្សេងទៀតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។ ស្មៀនឃុំ សង្កាត់អាចលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោតបាន តែក្នុងករណីមានទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដែលមានស្នាមផ្តិតមេដៃរបស់អ្នកសុំចុះឈ្មោះជាសំគាល់តែប៉ុណ្ណោះ ។

**ជំហានទី ៧ : នីតិវិធីក្នុងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត**

- ស្មៀនឃុំ សង្កាត់មិនត្រូវចុះឈ្មោះជនណាម្នាក់ដែលមិនបានបង្ហាញឯកសារផ្លូវការណាមួយ ដូចបានចែងក្នុងជំហានទី២ និងជំហានទី៣ ខាងលើ ដើម្បីកំណត់

លក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬដែលបានបង្ហាញឯកសារមួយ ឬច្រើន ប៉ុន្តែមិនបានឆ្លើយតបគ្រប់គ្រាន់ ទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោតនោះឡើយ ។

- ស្មៀនឃុំ សង្កាត់ត្រូវបដិសេធមិនចុះឈ្មោះអ្នកសុំចុះឈ្មោះផងដែរ ប្រសិនបើមានភស្តុតាងជាក់ស្តែងបង្ហាញថា ឯកសាររបស់អ្នកសុំចុះឈ្មោះនោះ គឺជាឯកសារក្លែងក្លាយ ឬបានមកដោយការបន្លំ ។
- ក្នុងករណី អ្នកសុំចុះឈ្មោះមិនបានឆ្លើយតបគ្រប់គ្រាន់ ទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬ មានភស្តុតាងជាក់ស្តែងបញ្ជាក់ថាឯកសារដែលអ្នកសុំចុះឈ្មោះបានបង្ហាញ គឺជាឯកសារក្លែងក្លាយ ឬបានមកដោយការបន្លំនោះ នៅមុនពេលដែលស្មៀនឃុំ សង្កាត់សំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោតរបស់សាមីខ្លួន ស្មៀនឃុំ សង្កាត់ត្រូវសុំសេចក្តីសំរេចអំពីបញ្ហានេះពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រចាំការពិនិត្យមើលការខុសត្រូវលើការងាររបស់ខ្លួន ។ ស្មៀនឃុំ សង្កាត់ត្រូវសំរេចបដិសេធការសុំចុះឈ្មោះរបស់ជននោះដោយអនុវត្តតាមលក្ខខណ្ឌដូចចែងក្នុងចំណុច ៤.៤.២.១១ ខាងលើ ហើយត្រូវធានាឱ្យប្រាកដថាការសំរេចរបស់ខ្លួនត្រូវបានធ្វើដោយផ្អែកលើលក្ខខណ្ឌនៃច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គជប ។
- ស្មៀនឃុំ សង្កាត់អាចសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត តែក្នុងករណីមានមូលហេតុដូចខាងក្រោម ៖

  អ្នកសុំចុះឈ្មោះគ្មាន ឬ/និង មិនបានបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណដែលមានសុពលភាព ដូចចែងចាប់ពីចំណុច ក ដល់ ឃ ដែលបានកំណត់ក្នុងជំហានទី ២ ខាងលើ ។

  អ្នកសុំចុះឈ្មោះគ្មានភស្តុតាងបញ្ជាក់អំពីសញ្ជាតិខ្មែរ ដែលបានតំរូវ និងដែលបានចែងក្នុងចំណុច ក ខ គ ង ច ឆ និង ជ ដែលបានកំណត់ក្នុងជំហានទី២ និងជំហានទី៣ ខាងលើ ។

  អ្នកសុំចុះឈ្មោះគ្មានភស្តុតាងបញ្ជាក់អំពីអាយុមានសិទ្ធិបោះឆ្នោត ដែលបានតំរូវ និងដែលបានកំណត់ក្នុងជំហានទី៤ ខាងលើ ។

  អ្នកសុំចុះឈ្មោះគ្មានភស្តុតាងបញ្ជាក់អំពីទីលំនៅក្នុងឃុំ សង្កាត់ ដែលបានតំរូវ និងដែលបានកំណត់ក្នុងជំហានទី៥ ខាងលើ ។

អ្នកសុំចុះឈ្មោះមានការយឺតយ៉ាវ ក្នុងការសុំចុះឈ្មោះ ដែលត្រូវបានធ្វើនៅក្រោយរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតបានបញ្ចប់ ។

អ្នកសុំចុះឈ្មោះមិនមានសិទ្ធិក្នុងការចុះឈ្មោះ ដោយមូលហេតុវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលដោយមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យ ឬស្ថាប័នសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ។

អ្នកសុំចុះឈ្មោះគ្មានសិទ្ធិចុះឈ្មោះ ដោយសារតែត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារ ឬត្រូវបានសំរេចព្យួរទោស ដែលមិនទាន់បានអនុវត្តទោសរួច និងមិនទាន់មាននីតិសម្បទាឡើងវិញ ។

- ស្មៀនឃុំ សង្កាត់មិនត្រូវបដិសេធការសុំចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះណាម្នាក់ដោយមូលហេតុណាមួយ ក្រៅពីមូលហេតុ ដែលបានកំណត់សម្រាប់ការបដិសេធ ដូចចែងខាងលើឡើយ ។
- ប្រសិនបើ អ្នកសុំចុះឈ្មោះណាម្នាក់មិនបានឆ្លើយតបគ្រប់គ្រាន់ ទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោត ដោយមូលហេតុណាមួយ ក្នុងចំណោមមូលហេតុដែលត្រូវបដិសេធការសុំចុះឈ្មោះដូចបញ្ជាក់ខាងលើ ស្មៀនឃុំ សង្កាត់ត្រូវសំរេចបដិសេធការសុំចុះឈ្មោះរបស់ជននោះ ដោយអនុវត្តតាមលក្ខខណ្ឌដូចចែងក្នុងចំណុច ៤.៤.២.១១ ខាងលើ ហើយត្រូវបំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះ (១០០៩) ដោយបញ្ជាក់ច្បាស់ពីមូលហេតុណាមួយក្នុងចំណោមមូលហេតុនៃការបដិសេធ ដូចបានកំណត់ខាងលើ ។ ស្មៀនឃុំ សង្កាត់ត្រូវបង្គាប់ទៅជំនួយការរបស់ខ្លួនឱ្យបំពេញបន្ថែមឱ្យគ្រប់ចំនួនបី(៣)ច្បាប់ រួចដាក់ជូនស្មៀនឃុំ សង្កាត់ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត បន្ទាប់មក ត្រូវផ្តល់សេចក្តីសំរេចបដិសេធការសុំចុះឈ្មោះមួយច្បាប់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់មួយច្បាប់ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់មួយច្បាប់ ។

  គជប ត្រូវធានាថា ស្មៀនឃុំ សង្កាត់បានរៀបចំ និងបញ្ជូនរាល់ទម្រង់បែបបទបដិសេធការសុំចុះឈ្មោះ ដែលបានរក្សាទុកមួយរយៈជាឯកសាររបស់ស្មៀនឃុំ សង្កាត់មក គជប បន្ទាប់ពីការដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតនៅក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបញ្ចប់ ។
- ក្នុងករណីមានការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មានជូនអ្នកសុំចុះឈ្មោះថា សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍

អក្សរទៅនឹងការបដិសេធនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលបី(៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសំរេចបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធតាមសំណើសុំ នូវទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាចំនួន(៤)ច្បាប់ ដែលតម្រូវដោយនីតិវិធីរបស់ គជប ។

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដោះស្រាយបណ្តឹងតវ៉ា ក្នុងរយៈពេលបី(៣)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ា ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសំរេចបដិសេធ ឬយល់ព្រមតាមបណ្តឹងតវ៉ា ដោយការប្រជុំសម្រេចជាសាធារណៈ និងផ្អែកតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ ការប្រជុំសម្រេចលើបណ្តឹងតវ៉ានេះ ត្រូវអនុវត្តតាមលំនាំដូចគ្នានឹងការប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែរ ។

៤.១១.២ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រសិនបើ ពិនិត្យឃើញថា អាចនឹងមានការខ្វះសម្ភារៈឯកសារបំរើការចុះឈ្មោះ ស្មៀនឃុំ សង្កាត់ត្រូវធ្វើសំណើសុំជាមុនមកមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវពិនិត្យសំណើសុំ និងត្រូវបើកជូនសម្ភារៈឯកសារក្នុងចំនួនមួយសមស្រប ។ ក្នុងករណី ដែលមានសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោតសំខាន់ៗ ដូចជា ទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ឬ ត្រាការិយាល័យចុះឈ្មោះត្រូវបានបើកបន្ថែម មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបំពេញលិខិតបញ្ជាក់សុពលភាពនៃការប្រើប្រាស់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោតបំរុង ដែលផ្គត់ផ្គង់បន្ថែម ( ទម្រង់បែបបទលេខ ១០១៥ ) ហើយត្រូវប្រគល់ទម្រង់បែបបទនេះមួយច្បាប់ទៅស្មៀនឃុំ សង្កាត់ ផ្ញើមួយច្បាប់ទៅមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**ការបំពេញ / ការចេញលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុរបស់អ្នកសុំចុះឈ្មោះ អមដោយការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ប្រសិនបើចាំបាច់**

**ប្រការ ៤.១២** អ្នកសុំចុះឈ្មោះ ដែលមិនទាន់បានឆ្លើយតបទៅនឹងលក្ខខណ្ឌអត្តសញ្ញាណ ឬ/និងអាយុសម្រាប់ការសុំចុះឈ្មោះបោះឆ្នោត មានសិទ្ធិបញ្ជាក់អត្តសញ្ញាណ ឬ/និង អាយុរបស់ខ្លួនដល់ស្មៀនឃុំ សង្កាត់ តាមរយៈការបង្ហាញលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និង អាយុ ដែលត្រូវធ្វើ

ឡើង ដោយសាក្សីជាអ្នកមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ពីរ(២)នាក់ នៅចំពោះមុខអាជ្ញាធរ ឃុំ សង្កាត់ ( មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិ ) ។

៩.១២.១ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង មិនអាចបដិសេធមិនព្រមបញ្ជាក់ និងចេញលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និង អាយុជូនអ្នកសុំចុះឈ្មោះបោះឆ្នោតដែលធ្វើឡើងស្របតាមច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គជប បានឡើយ ។ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលមិនព្រមបញ្ជាក់ និងចេញលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និង អាយុជូនអ្នកសុំចុះឈ្មោះបោះឆ្នោត នឹងត្រូវទទួលទោសទៅតាមច្បាប់ ។

៩.១២.២ អាជ្ញាធរឃុំ សង្កាត់ ( មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ) ត្រូវបញ្ជាក់ និងចេញលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និង អាយុជូនអ្នកសុំចុះឈ្មោះបោះឆ្នោតតាមការស្នើសុំស្របតាមច្បាប់ ដោយមិនតម្រូវឱ្យបង់ថ្លៃឡើយ ។

៩.១២.២.១ ជនណាក៏ដោយ ដែលបានបង្ខំដកហូតប័ណ្ណសំគាល់ ឬ ឯកសារ ឬ លិខិតបញ្ជាក់អត្តសញ្ញាណពីប្រជាពលរដ្ឋដែលបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ នឹងត្រូវទទួលទោសទៅតាមច្បាប់ ។

៩.១២.៣ លិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និង អាយុនេះ ត្រូវធ្វើឡើងនៅចំពោះមុខមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដោយមានវត្តមានសាក្សីពីររូបគាំទ្រការធានាអះអាងរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ។ សាក្សីម្នាក់ៗត្រូវមានលក្ខខណ្ឌកំណត់ដូចខាងក្រោម ៖

៩.១២.៣.១ មានទីលំនៅក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោតដូចអ្នកសុំចុះឈ្មោះដែរ ។

៩.១២.៣.២ បានចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់នោះ ឬមានសិទ្ធិចុះឈ្មោះជាអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ។

៩.១២.៣.៣ យល់ព្រមបង្ហាញឯកសារផ្សេងៗ ដែលអាចសន្មតថា សាក្សីបានចុះឈ្មោះបោះឆ្នោតរួចហើយ ឬមានលក្ខណៈគ្រប់គ្រាន់ឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការចុះឈ្មោះបោះឆ្នោត តាមការទាមទាររបស់មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ។

៤.១២.៣.៤ យល់ព្រមចុះហត្ថលេខា ឬផ្តិតមេដៃ គាំទ្រការធានាអះអាងអំពីអត្តសញ្ញាណ ឬ/និង អាយុរបស់អ្នកសុំចុះឈ្មោះ នៅលើទម្រង់បែបបទលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និង អាយុ ។

៤.១២.៤ ជនដែលមិនបំពេញបានលក្ខខណ្ឌកំណត់ ដូចចែងក្រោមចំណុច ៤.១២.៣ ខាងលើ មិនអាចធ្វើជាសាក្សីគាំទ្រការធានាអះអាងអំពីអត្តសញ្ញាណ ឬ/និង អាយុរបស់អ្នកសុំចុះឈ្មោះបានឡើយ ។

៤.១២.៥ ដោយមានវត្តមានសាក្សីពីររូបអមដំណើរមកជាមួយ ស្ថិតនៅចំពោះមុខមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង អ្នកសុំចុះឈ្មោះត្រូវបំពេញ បិទរូបថត និងផ្តិតមេដៃលើទម្រង់បែបបទលិខិតធានាអះអាងពីអត្តសញ្ញាណឬ/និងអាយុ ( ១០១៨ ) ចំនួនពីរ(២)ច្បាប់ រួចអញ្ជើញសាក្សីទាំងពីររូបចុះហត្ថលេខា ឬ ផ្តិតមេដៃគាំទ្រការធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុរបស់អ្នកសុំចុះឈ្មោះ ។

៤.១២.៥.១ ការបំពេញ និងចេញលិខិតធានាអះអាងអំពីអត្តសញ្ញាណឬ/និងអាយុ សម្រាប់បំរើតែគោលបំណងសុំចុះឈ្មោះបោះឆ្នោត រូបថតរបស់សាមីអ្នកសុំចុះឈ្មោះ ដែលត្រូវបិទនៅលើលិខិតធានាអះអាងពីអត្តសញ្ញាណឬ/និងអាយុ ពុំមែនជាការតម្រូវ ត្រូវតែមានដោយខានមិនបាននោះទេ ។

៤.១២.៥.២ អ្នកសុំចុះឈ្មោះបោះឆ្នោតដែលគ្មានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយផ្សេង ហើយដែលត្រូវការលិខិតធានាអះអាងកំពុងស្នើសុំសំរាប់ប្រើប្រាស់ក្នុងការបោះឆ្នោត នៅថ្ងៃបោះឆ្នោត ចាំបាច់ត្រូវតែមានរូបថតចំនួនពីរ(២)សន្លឹក សម្រាប់បិទនៅផ្នែកខាងលើ ចំហៀងខាងស្តាំនៃទម្រង់បែបបទលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និង អាយុ ទាំងពីរ(២)ច្បាប់ ។ រូបថតត្រូវមានគុណភាពល្អ ដែលអាចបញ្ជាក់អត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះ,អ្នកបោះឆ្នោតបានត្រឹមត្រូវ និងត្រូវមានទំហំ ៤គុណ៦ ថតចំពីមុខ ដែលបង្ហាញមុខនិងស្មារបស់អ្នកសុំចុះឈ្មោះ ។

៤.១២.៦ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងត្រូវបញ្ជាក់ថា ការធានាអះអាងនេះពិតជាបានធ្វើឡើងនៅចំពោះមុខខ្លួន ហើយអ្នកសុំចុះឈ្មោះពិតជាមានឈ្មោះ និង

អាយុត្រឹមត្រូវតាមការធានាអះអាង ព្រមទាំងមានទីលំនៅក្នុងឃុំ សង្កាត់ប្រាកដមែន បន្ទាប់មក ត្រូវចុះហត្ថលេខា ចុះកាលបរិច្ឆេទនិងបោះត្រារបស់ឃុំ សង្កាត់ លើលិខិតធានាអះអាងអំពីអត្តសញ្ញាណឬ/និងអាយុ និងត្រូវបោះត្រាឃុំ សង្កាត់នៅលើផ្នែកពាក់កណ្តាលខាងក្រោមនៃរូបថតផង ប្រសិនបើមាន ។

៨.១២.៦.១ ប្រសិនបើ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងយល់ថាមិនចាំបាច់តម្រូវអោយធ្វើការបញ្ជាក់ អំពីទីលំនៅរបស់អ្នកសុំចុះឈ្មោះទេ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង អាចគូសលុបពាក្យដែលពាក់ព័ន្ធ ចេញពីទម្រង់បែបបទសម្រាប់បំពេញលិខិតធានាអះអាង ។

៨.១២.៧ លិខិតធានាអះអាងពីអត្តសញ្ញាណឬ/និងអាយុ ត្រូវបានទទួលស្គាល់ថា ជាឯកសារមានសុពលភាព ដែលអាចបញ្ជាក់អត្តសញ្ញាណនិងអាយុ ក្នុងការសុំចុះឈ្មោះបោះឆ្នោត ឬបញ្ជាក់អត្តសញ្ញាណនៃអ្នកបោះឆ្នោតក្នុងការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

៨.១២.៨ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ត្រូវប្រគល់លិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុ ជូនអ្នកសុំចុះឈ្មោះមួយច្បាប់ និងរក្សាទុកជាឯកសាររបស់ឃុំ សង្កាត់មួយច្បាប់ ។

៨.១២.៩ ដោយមានលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និងអាយុ ដែលទើបនឹងទទួលបាន អ្នកសុំចុះឈ្មោះត្រូវត្រឡប់ទៅជួបស្មៀនឃុំ សង្កាត់វិញ និងបង្ហាញលិខិតធានានេះដើម្បីសុំចុះឈ្មោះបោះឆ្នោត ។ ទោះបីជាលិខិតធានានេះ មានបិទរូបថតក្តីឬមិនមានបិទរូបថតក្តី ស្មៀនឃុំ សង្កាត់អាចពិនិត្យឯកសារនេះបានដើម្បីកំណត់លក្ខខណ្ឌអត្តសញ្ញាណនិងអាយុ សម្រាប់ការចុះឈ្មោះបោះឆ្នោត ប៉ុន្តែត្រូវប្រគល់លិខិតធានាអះអាងនេះជូនអ្នកសុំចុះឈ្មោះវិញ ។

៨.១២.១០ ប្រសិនបើ អ្នកសុំចុះឈ្មោះមិនបានបំពេញទៅតាមលក្ខខណ្ឌ ដូចចែងក្នុងចំណុច ៨.១២.៣ ៨.១២.៤ និង ៨.១២.៥ ខាងលើទេ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងមិនត្រូវបញ្ជាក់ និងចេញលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និង អាយុ ជូនអ្នកសុំចុះឈ្មោះទេ ។ ក្នុងករណីនេះ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងត្រូវប្រាប់ទៅអ្នកសុំចុះឈ្មោះ អោយទៅជួបស្មៀនឃុំ សង្កាត់ ដែលគាត់នឹងចេញសេចក្តីសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោតជាផ្លូវការ ។

៩.១២.១០.១ស្មៀនឃុំ សង្កាត់ត្រូវបំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត ( ១០០៩ ) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធ ហើយត្រូវបង្គាប់ទៅជំនួយការរបស់ខ្លួនឱ្យបំពេញបន្ថែមឱ្យគ្រប់ចំនួនបី(៣)ច្បាប់ រួចដាក់ជូនស្មៀនឃុំ សង្កាត់ចុះហត្ថលេខាកាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត ។

៩.១២.១០.២ស្មៀនឃុំ សង្កាត់ ត្រូវផ្តល់សេចក្តីសំរេចបដិសេធការសុំចុះឈ្មោះមួយច្បាប់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់មួយច្បាប់ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់មួយច្បាប់ ។

៩.១២.១០.៣ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មានជូនអ្នកសុំចុះឈ្មោះថា សាមីខ្លួនឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ទៅនឹងការបដិសេធនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលបី(៣)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសេចក្តីសំរេចបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ តាមសំណើសុំ នូវទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាចំនួន (៤) ច្បាប់ ដែលតម្រូវដោយនីតិវិធីរបស់ គជប ។

**ការស្នើសុំ និងការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត**

**ប្រការ ៩.១៣** អ្នកសុំចុះឈ្មោះ ដែលបានឆ្លើយតបទៅនឹងលក្ខខណ្ឌអត្តសញ្ញាណ សញ្ជាតិ និងអាយុរួចហើយប៉ុន្តែពុំមានភស្តុតាងបង្ហាញដោយឯកសារណាមួយរបស់អ្នកសុំចុះឈ្មោះ ដែលបញ្ជាក់អំពីទីលំនៅរបស់សាមីខ្លួន មានសិទ្ធិស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់សម្រាប់ប្រើប្រាស់ក្នុងគោលដៅនៃការសុំចុះឈ្មោះបោះឆ្នោត ពីអាជ្ញាធរឃុំ សង្កាត់ ដោយត្រូវអនុវត្តតាមនីតិវិធីនិងបែបបទណែនាំរបស់ក្រសួងមហាផ្ទៃ ។

៩.១៣.១ អាជ្ញាធរឃុំ សង្កាត់ ដែលបដិសេធដោយមិនស្របច្បាប់ មិនព្រមចេញលិខិតបញ្ជាក់ទីលំនៅជូនជនដែលពិតជាមានទីលំនៅក្នុងឃុំ សង្កាត់នោះ ដូចបានកំណត់នៅក្នុងច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គជប នឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់ ។

៩.១៣.២ ស្មៀនឃុំ សង្កាត់អាចទាមទារលិខិតបញ្ជាក់ទីលំនៅរបស់អ្នកសុំចុះឈ្មោះ តែនៅពេលណាដែលរាល់ឯកសារដែលបានបង្ហាញ មិនមានបញ្ជាក់ថា សាមីអ្នកសុំចុះឈ្មោះមានទីលំនៅក្នុងឃុំ សង្កាត់ ដែលគាត់មានបំណងសុំចុះឈ្មោះ ។

៤.១៣.២.១ ពលរដ្ឋខ្មែរណាម្នាក់ ដែលមានទីលំនៅច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់សម្រាប់ការចុះឈ្មោះបោះឆ្នោត ។

៤.១៣.២.២ ទីលំនៅរបស់ជនណាម្នាក់នៅក្នុងឃុំ សង្កាត់ត្រូវបានកំណត់ថា ជាកន្លែងដែលជននោះរស់នៅធម្មតា នៅក្នុងរយៈពេលនៃការចុះឈ្មោះបោះឆ្នោត ។ ទីលំនៅរបស់ជនណាម្នាក់អាចជាអគារ ផ្ទះល្វែង បន្ទប់ សំណង់ ឬមួយផ្នែកនៃសំណង់ ឬទីកន្លែងជាក់លាក់ណាមួយដែលគេអាចរកជននោះឃើញជាធម្មតា ឬដោយទៀងទាត់ ។

៤.១៣.២.៣ អ្នកសុំចុះឈ្មោះអាចមានទីលំនៅក្នុងឃុំ សង្កាត់មួយ នៅថ្ងៃដែលខ្លួនសុំចុះឈ្មោះបោះឆ្នោត ។ ស្មៀនឃុំ សង្កាត់មិនអាចតម្រូវឱ្យអ្នកសុំចុះឈ្មោះត្រូវតែរស់នៅ ក្នុងពេលវេលាកំណត់ណាមួយ មុនការសុំចុះឈ្មោះបោះឆ្នោតនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ជនដែលគ្រាន់តែធ្វើដំណើរឆ្លងកាត់ ឬគ្រាន់តែមកធ្វើទស្សនកិច្ចនៅក្នុងឃុំ សង្កាត់នោះ មិនអាចចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះបានឡើយ ។ ជននោះត្រូវទៅចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅជាធម្មតា ។

៤.១៣.២.៤ កម្មករ សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល នគរបាល និងយោធា មានសិទ្ធិចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ដែលខ្លួនកំពុងរស់នៅជាប់ជាបណ្តោះអាសន្ន ។ ក្នុងករណីនេះ ប្រសិនបើ អ្នកសុំចុះឈ្មោះបានចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ដែលខ្លួនមានទីលំនៅជាអចិន្ត្រៃយ៍រួចហើយ ស្មៀនឃុំ សង្កាត់មិនត្រូវភ្លេចបំពេញទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៧ ) និងឱ្យជននោះផ្តិតមេដៃជាសំគាល់ផង ដើម្បីអនុញ្ញាតឱ្យ គជប អាចលុបឈ្មោះជននោះចេញពីបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតផ្សេង ឬនៃឃុំ សង្កាត់ផ្សេងដែលជននោះបានចុះឈ្មោះកន្លងមក ។

៤.១៣.៣ ផ្អែកតាមសំណើរបស់អ្នកសុំចុះឈ្មោះ អាជ្ញាធរឃុំ សង្កាត់ត្រូវផ្តល់លិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ជូនសាមីជន ដែលមានទីលំនៅពិតប្រាកដនៅក្នុងឃុំ សង្កាត់នោះ ដោយផ្អែកតាមនីតិវិធី និងបែបបទកំណត់របស់ក្រសួងមហាផ្ទៃ ព្រមទាំងបទបញ្ជានិងនីតិវិធីរបស់ គជប អនុលោមតាមច្បាប់បោះឆ្នោត ។

៤.១៣.៣.១ អាជ្ញាធរឃុំ សង្កាត់ គឺមេឃុំ ចៅសង្កាត់ ឬ ជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិអំណាចជំនួសមេឃុំ ចៅសង្កាត់ ។

៤.១៣.៣.២ អាជ្ញាធរឃុំ សង្កាត់ ត្រូវចេញលិខិតបញ្ជាក់ទីលំនៅ សម្រាប់គោលបំណងនៃការសុំចុះឈ្មោះបោះឆ្នោត ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានយ៉ាងយូរ ៤៨ ម៉ោង បន្ទាប់ពីបានទទួលការស្នើសុំពីអ្នកសុំចុះឈ្មោះ ។

៤.១៣.៣.៣ អាជ្ញាធរឃុំ សង្កាត់ អាចប្រើប្រាស់បណ្តាញរដ្ឋបាលណាមួយក៏បាន រួមបញ្ចូលទាំងព័ត៌មាន ដែលទទួលបានពីនគរបាលប៉ុស្តិ៍រដ្ឋបាល ដើម្បីបញ្ជាក់ទីលំនៅរបស់អ្នកសុំចុះឈ្មោះ ។

៤.១៣.៣.៤ អាជ្ញាធរឃុំ សង្កាត់ត្រូវសន្មតជឿជាក់លើបំណងល្អនៃជនដែលស្នើសុំលិខិតបញ្ជាក់ទីលំនៅ ។ លិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ត្រូវតែបានចេញជូនជនដែលស្នើសុំ លើកលែងតែអាជ្ញាធរឃុំ សង្កាត់ជឿជាក់យ៉ាងច្បាស់លាស់ថា ជនដែលស្នើសុំនោះមិនមានទីលំនៅក្នុងឃុំ សង្កាត់នោះទេ ។

៤.១៣.៣.៥ អាជ្ញាធរឃុំ សង្កាត់ ត្រូវចេញលិខិតបញ្ជាក់ទីលំនៅនេះ ដោយគ្មានការបង់ថ្លៃ ដូចបានកំណត់នៅក្នុងបទបញ្ជានិងនីតិវិធីរបស់ គជប ។

៤.១៣.៣.៦ អាជ្ញាធរឃុំ សង្កាត់ត្រូវបំពេញទម្រង់បែបបទលិខិតបញ្ជាក់ទីលំនៅ ( ១០១៩ ) ចំនួនពីរ(២)ច្បាប់ រួចត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រារបស់ឃុំ សង្កាត់ ដែលក្នុងនោះ ត្រូវប្រគល់ជូនអ្នកសុំចុះឈ្មោះមួយច្បាប់ និងត្រូវរក្សាទុកមួយច្បាប់ជាឯកសាររបស់ឃុំ សង្កាត់ ។

៤.១៣.៣.៧ បន្ទាប់មក អ្នកសុំចុះឈ្មោះអាចត្រឡប់ទៅជួបស្មៀនឃុំ សង្កាត់ដើម្បីសុំចុះឈ្មោះបោះឆ្នោត ដោយការបង្ហាញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដែលទើបនឹងបានទទួលពីអាជ្ញាធរឃុំ សង្កាត់ ។ ស្មៀនឃុំ សង្កាត់ត្រូវពិនិត្យលិខិតបញ្ជាក់ទីលំនៅនេះរួចហើយ ត្រូវប្រគល់ជូនអ្នកសុំចុះឈ្មោះវិញ ។

៤.១៣.៤ ប្រសិនបើ អាជ្ញាធរឃុំ សង្កាត់មានការជឿជាក់ប្រាកដថា ជនដែលស្នើសុំលិខិតបញ្ជាក់ទីលំនៅពិតជាមិនមានទីលំនៅក្នុងឃុំ សង្កាត់នោះទេ មេឃុំ ចៅសង្កាត់ ឬ ជំទប់ ចៅសង្កាត់រងមិនត្រូវចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ជូនឡើយ ។

៤.១៣.៤.១ ក្នុងករណីនេះ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រងត្រូវណែនាំអ្នកសុំចុះឈ្មោះ ឱ្យទៅជួបស្មៀនឃុំ សង្កាត់ ។ ក្នុងពេលនោះ ស្មៀនឃុំ សង្កាត់ត្រូវណែនាំដល់អ្នកសុំចុះឈ្មោះអំពីនីតិវិធីនៃការប្ដឹងតវ៉ា ឬណែនាំគាត់ឱ្យទៅសុំចុះឈ្មោះនៅឃុំ សង្កាត់ដែលខ្លួនមានទីលំនៅ ។

៤.១៣.៤.២ ស្មៀនឃុំ សង្កាត់ត្រូវបំពេញទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត ( ១០០៩ ) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធ ដោយសារគាត់មិនមានភស្តុតាងបញ្ជាក់ថា គាត់ពិតជាមានទីលំនៅក្នុងឃុំ សង្កាត់នោះ ហើយត្រូវបង្កាប់ទៅជំនួយការរបស់ខ្លួនឱ្យបំពេញបន្ថែមឱ្យគ្រប់ចំនួនបី( ៣ )ច្បាប់ រួចដាក់ជូនស្មៀនឃុំ សង្កាត់ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត ។

៤.១៣.៤.៣ ស្មៀនឃុំ សង្កាត់ ត្រូវផ្ដល់សេចក្ដីសំរេចបដិសេធការសុំចុះឈ្មោះមួយច្បាប់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់មួយច្បាប់ និងរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់មួយច្បាប់ ។

៤.១៣.៤.៤ ស្មៀនឃុំ សង្កាត់ត្រូវផ្ដល់ព័ត៌មានជូនអ្នកសុំចុះឈ្មោះថា សាមីខ្លួនឬតំណាងអាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរ ទៅនឹងការបដិសេធនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលបី(៣)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសំរេចបដិសេធ ។ ស្មៀនឃុំ សង្កាត់ត្រូវផ្ដល់ជូនអ្នកសុំចុះឈ្មោះដែលត្រូវបដិសេធ តាមសំណើសុំ នូវទម្រង់បែបបទសម្រាប់ប្ដឹងតវ៉ាចំនួន(៤)ច្បាប់ ដែលបានតម្រូវដោយនីតិវិធីរបស់ គជប ។

**ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត យោងតាមទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត**

**ប្រការ ៤.១៤** ស្មៀនឃុំ សង្កាត់ ដែលជាមន្ត្រីចុះឈ្មោះទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវធានាថា អ្នកបោះឆ្នោតដែលបានស្លាប់ ដែលបានបាត់បង់សិទ្ធិបោះឆ្នោតដោយមូលហេតុវិកលចរិត ឬ ស្ថិតក្រោមអាណាព្យាបាល ឬត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារ ដែលបានផ្លាស់ទីលំនៅចេញទៅឃុំ សង្កាត់ផ្សេង ដែលគ្មានទីលំនៅអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្នក្នុងឃុំ សង្កាត់ ដែលមានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត

តែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់តែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់ផ្សេង និងដែលបានចុះឈ្មោះប្តូរការិយាល័យបោះឆ្នោតផ្សេងក្នុងឃុំ សង្កាត់តែមួយ ត្រូវតែបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយយោងតាមទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៦ ឬ ១០១៧ ) ដែលបានបំពេញទុកជាភស្តុតាង និងយោងតាមបែបបទដែល គជប បានណែនាំដោយឡែកសម្រាប់ករណីនីមួយៗ ។ ស្មៀនឃុំ សង្កាត់ត្រូវធ្វើបច្ចុប្បន្នភាពលុបឈ្មោះអ្នកទាំងនោះ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតទាំងមូល ដោយផ្អែកតាមបទបញ្ជា និងនីតិវិធីរបស់ គជប ។

៨.១៤.១ ស្មៀនឃុំ សង្កាត់ត្រូវគូសបន្ទាត់លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធក្នុងឃុំ សង្កាត់ ចំពោះអ្នកបោះឆ្នោត ដែលមានឯកសារជាភស្តុតាងបញ្ជាក់ថា បានចូលមរណភាព ឬបានបាត់បង់សិទ្ធិបោះឆ្នោត ដោយមូលហេតុវិកលចរិត ឬ ស្ថិតក្រោមអាណាព្យាបាល ឬត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារ ឬបានផ្លាស់ទីលំនៅចេញទៅឃុំ សង្កាត់ផ្សេង ឬគ្មានទីលំនៅអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នក្នុងឃុំ សង្កាត់ ។

៨.១៤.១.១ ក្នុងករណីដូចចែងក្នុងចំណុច ៨.១៤.១ ខាងលើ ស្មៀនឃុំ សង្កាត់ត្រូវបំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត( ១០១៦ )ចំនួនពីរ(២)ច្បាប់ ដោយបញ្ជាក់មូលហេតុដែលតម្រូវឱ្យលុបឈ្មោះនិងយោងឯកសារជាភស្តុតាងពាក់ព័ន្ធផង ។

៨.១៤.១.២ ផ្អែកលើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៦ ) ដែលបានបំពេញ និងចុះហត្ថលេខារួចហើយខាងលើនេះ ស្មៀនឃុំ សង្កាត់ត្រូវគូសបន្ទាត់លុបឈ្មោះអ្នកបោះឆ្នោតនោះ ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងចារបញ្ជាក់ទន្ទឹមនឹងជួរឈ្មោះនោះ ដោយយោងមូលហេតុថា " ស្លាប់ " ឬ " បាត់សិទ្ធិ " ឬ " ផ្លាស់ចេញ " ឬ " គ្មានទីលំនៅក្នុងឃុំ សង្កាត់ " រួចបង្ហាប់ជំនួយការរបស់ខ្លួនឱ្យលុបឈ្មោះតាមលំនាំដូចគ្នានេះ នៅលើបញ្ជីបោះឆ្នោតទាំងអស់គម្រប់ជា ៤ ច្បាប់ ។

៨.១៤.១.៣ ស្មៀនឃុំ សង្កាត់ត្រូវធានាថា ទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត( ១០១៦ )មួយច្បាប់ៗ ត្រូវបានច្រកក្នុងស្រោមសំបុត្រដាក់អមជាមួយបញ្ជីបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួចទៅក្នុងកញ្ចប់ " ក " នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធផ្ញើជូន គជប និងត្រូវរក្សាទុកមួយច្បាប់ជាឯកសារ ដែលភ្ជាប់ជាមួយនឹងរាល់ឯកសារជាភស្តុតាងពាក់ព័ន្ធ ។

៤.១៤.២ ចំពោះករណីអ្នកដែលបានផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ ឬគ្មានទីលំនៅអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នក្នុងឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ចាំបាច់ត្រូវមានភស្តុតាងជាឯកសារផ្លូវការពីអាជ្ញាធរឃុំ សង្កាត់ឬពីប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ឬ/និងត្រូវផ្អែកលើបែបបទឯកសារណែនាំអនុវត្តដោយ គជប ដែលមានការបញ្ជាក់ឯកភាពពីអាជ្ញាធរឃុំ សង្កាត់ ។

៤.១៤.៣ ស្មៀនឃុំ សង្កាត់ត្រូវផ្ទៀងផ្ទាត់ និងធានាបង្ការកុំឱ្យមានអ្នកសុំចុះឈ្មោះណាម្នាក់ចុះឈ្មោះបោះឆ្នោត ២ ដងក្នុងឃុំ សង្កាត់របស់ខ្លួន ។ ក្នុងករណី អ្នកបោះឆ្នោតបានសុំចុះឈ្មោះថ្មី ដោយប្តូរពីការិយាល័យបោះឆ្នោតមួយ ដែលស្ថិតនៅឆ្ងាយពេកពីទីលំនៅរបស់គាត់ ទៅការិយាល័យបោះឆ្នោតមួយទៀតនៅក្នុងឃុំ សង្កាត់ដដែល ស្មៀនឃុំ សង្កាត់ត្រូវបំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៧ ) ចំនួនពីរ(២)ច្បាប់ ដែលក្នុងនោះ ត្រូវឱ្យសាមីអ្នកសុំចុះឈ្មោះផ្តិតមេដៃជាភស្តុតាងផង ។

៤.១៤.៣.១ ផ្អែកលើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត (១០១៧) ដូចចែងក្នុងចំណុច ៤.១៤.៣ ខាងលើ ស្មៀនឃុំ សង្កាត់ត្រូវគូសបន្ទាត់លុបឈ្មោះអ្នកបោះឆ្នោតនោះ ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងត្រូវចារបញ្ជាក់ទន្ទឹមនឹងជួរឈ្មោះនោះថា " ប្តូរការិ. " រួចបង្ហាប់ជំនួយការរបស់ខ្លួន ឱ្យលុបឈ្មោះតាមលំនាំដូចគ្នានេះ នៅលើបញ្ជីបោះឆ្នោតទាំងអស់គម្រប់ជា ៤ ច្បាប់ ។

៤.១៤.៣.២ ស្មៀនឃុំ សង្កាត់ត្រូវធានាថា ទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត(១០១៧)មួយច្បាប់ៗ ត្រូវបានច្រកក្នុងស្រោមសំបុត្រដាក់អមជាមួយបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច ទៅក្នុងកញ្ចប់ " ក " នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធផ្ញើជូន គជប និងត្រូវរក្សាទុកមួយច្បាប់ជាឯកសារ ។

៤.១៤.៤ ស្មៀនឃុំ សង្កាត់ត្រូវរួមចំណែកជួយដល់ គជប ក្នុងការបង្ការកុំឱ្យមានអ្នកសុំចុះឈ្មោះណាម្នាក់ ចុះឈ្មោះបោះឆ្នោត ២ ដង ក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណី អ្នកសុំចុះឈ្មោះជាអ្នកដែលបានផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់នោះ ប៉ុន្តែធ្លាប់បានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេង ក្នុងព្រះរាជាណាចក្រកម្ពុជារួចហើយ ស្មៀនឃុំ សង្កាត់ត្រូវបំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទ

លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៧ ) ចំនួនពីរ(២)ច្បាប់ ដែលក្នុងនោះត្រូវកត់ត្រាឱ្យច្បាស់លាស់ នូវលេខកូដការិយាល័យបោះឆ្នោត ឃុំ សង្កាត់ និងខេត្ត ក្រុង ដែលគាត់ធ្លាប់បានចុះឈ្មោះ និងត្រូវឱ្យសាមីអ្នកសុំចុះឈ្មោះផ្តិតមេដៃជាភស្តុតាងផង ។

៤.១៤.៤.១ ស្មៀនឃុំ សង្កាត់ត្រូវធានាថា ទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត(១០១៧)មួយច្បាប់ៗ ត្រូវបានច្រកក្នុងស្រោមសំបុត្រនិងដាក់ក្នុងកញ្ចប់ " ខ១ " ដែលត្រូវផ្ទុកកញ្ចប់ដាក់គល់សន្លឹកទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃ ដែលបានប្រើ និងនៅសល់ក្នុងឃុំ សង្កាត់ ផ្ញើជូន គជប និងត្រូវរក្សាទុកមួយច្បាប់ជាឯកសារដែលភ្ជាប់ជាមួយនឹងរាល់ឯកសារជាភស្តុតាងពាក់ព័ន្ធ ។

៤.១៤.៤.២ ផ្អែកលើទិន្នន័យដែលបានបំពេញ ក្នុងទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៧ ) ដូចចែងក្នុងចំណុច ៤.១៤.៤ ខាងលើ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវលុបឈ្មោះអ្នកបោះឆ្នោតនោះចេញពីបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

៤.១៤.៥ ក្នុងករណី មានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់តែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់ផ្សេង ស្មៀនឃុំ សង្កាត់ត្រូវចាត់ចែងអនុវត្តការលុបឈ្មោះអ្នកបោះឆ្នោត ដែលមានឈ្មោះស្ទួន ដោយផ្អែកតាមការណែនាំដោយឡែករបស់ គជប សម្រាប់ករណីនីមួយៗ ។ ស្មៀនឃុំ សង្កាត់ត្រូវស្រាវជ្រាវឱ្យប្រាកដថា ឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោត ជាមនុស្សតែម្នាក់ ឬជាមនុស្សពីរនាក់ ឬច្រើននាក់ផ្សេងគ្នា ។

៤.១៤.៥.១ ស្មៀនឃុំ សង្កាត់ត្រូវស្រង់ឈ្មោះអ្នកបោះឆ្នោតដែលមានឈ្មោះស្ទួនក្នុងបញ្ជីមួយដោយឡែក ដោយត្រូវកត់ត្រាច្បាស់នូវលេខកូដការិយាល័យបោះឆ្នោតដែលត្រូវលុបឈ្មោះចេញ និងលេខកូដការិយាល័យបោះឆ្នោតមួយដែលត្រូវរក្សាទុកឈ្មោះតែមួយគត់ តាមសំណូមពររបស់សាមីខ្លួន ។ ស្មៀនឃុំ សង្កាត់ត្រូវដាក់បញ្ជីនេះជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីសុំការបញ្ជាក់ឯកភាព ។

៤.១៤.៥.២ ផ្អែកតាមបញ្ជីស្រង់ឈ្មោះអ្នកបោះឆ្នោតស្ទួន ដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបញ្ជាក់ឯកភាពរួចហើយ ស្មៀនឃុំ សង្កាត់ត្រូវគូសបន្ទាត់លុបឈ្មោះអ្នកបោះឆ្នោតនោះ ឬទាំងនោះ ចេញពីបញ្ជីបោះឆ្នោតនៃ

ការិយាល័យបោះឆ្នោតដែលត្រូវលុប និងត្រូវចារបញ្ជាក់ទន្ទឹមនឹងជួរឈ្មោះនោះថា " ស្ទួន " រួចបង្គាប់ជំនួយការស្មៀនឱ្យលុបឈ្មោះតាមលំនាំដូចគ្នានេះ នៅលើបញ្ជីបោះឆ្នោតគម្រប់ជា ៤ ច្បាប់ ។

៨.១៨.៥.៣ ស្មៀនឃុំ សង្កាត់ត្រូវធានាថា បញ្ជីស្រង់ឈ្មោះអ្នកបោះឆ្នោតស្ទួនដែលមានការបញ្ជាក់ឯកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់មួយច្បាប់ ត្រូវបានដាក់ជាមួយរាល់ទម្រង់បែបបទលេខ ១០១៧ ដូចចែងក្នុងចំណុច ៨.១៨.៤.១ ខាងលើ ទៅក្នុងស្រោមសំបុត្រតែមួយ រួចដាក់ក្នុងកញ្ចប់" ១១" ដែលត្រូវផ្ទុកកញ្ចប់ដាក់គល់សន្លឹកទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃ ដែលបានប្រើ និងនៅសល់ក្នុងឃុំ សង្កាត់ ដើម្បីផ្ញើជូន គជប និងត្រូវរក្សាទុកមួយច្បាប់ជាឯកសារ ។

៨.១៨.៥.៤ ផ្អែកលើបញ្ជីស្រង់ឈ្មោះស្ទួន ដែលមានការបញ្ជាក់ឯកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ ដូចចែងក្នុងចំណុច ៨.១៨.៥.៣ ខាងលើ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវលុបឈ្មោះអ្នកបោះឆ្នោតនោះ ឬទាំងនោះ ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដែលត្រូវលុប និងត្រូវរក្សាទុកឈ្មោះពាក់ព័ន្ធតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យតែមួយគត់ តាមសំណូមពររបស់សាមីខ្លួន ។

៨.១៨.៦ ស្មៀនឃុំ សង្កាត់ពុំមានសិទ្ធិលុបឈ្មោះជនណាម្នាក់ចេញពីបញ្ជីបោះឆ្នោត ដោយសារហេតុផលផ្សេងក្រៅអំពីហេតុផលដូចបានបញ្ជាក់ក្នុងប្រការ ៨.១៨ ឡើយ ។

**ការពិនិត្យផ្ទៀងផ្ទាត់ និងការផ្តុំបញ្ជីបោះឆ្នោតដែលត្រូវបានធ្វើបច្ចុប្បន្នភាពរួច**

**ប្រការ ៨.១៩** នៅពេលបន្ទាប់ពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ ស្មៀនឃុំ សង្កាត់ត្រូវត្រួតពិនិត្យឡើងវិញ និងត្រូវផ្តុំបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួចឱ្យបានត្រឹមត្រូវនៅមុនការធ្វើរបាយការណ៍លទ្ធផល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការវេចខ្ចប់បញ្ជូនកញ្ចប់ " ក " ទៅ គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៨.១៩.១ ឃុំ សង្កាត់ត្រូវធានាថា បញ្ជីបោះឆ្នោតចុងក្រោយទាំងបួន(៤)ច្បាប់ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត ដោយយោងទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៦ ឬ/និង ១០១៧ ) ឬ/និង ផ្អែកលើបែបបទឯកសារលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដែលមានការបញ្ជាក់ឯកភាពពីអាជ្ញាធរឃុំ សង្កាត់ ហើយដែលត្រូវអនុវត្តតាមនីតិវិធី ដូចចែងក្រោមប្រការ ៨.១៨ ខាងលើ ។

៩.១៥.១.១ ស្មៀនឃុំ សង្កាត់ត្រូវចារបញ្ជាក់នៅលើសន្លឹកខាងចុងបង្អស់នៃបញ្ជីបោះឆ្នោតចុងក្រោយទាំងបួន(៤)ច្បាប់ នូវចំនួនសរុបនៃឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានគូសលុបចេញ និងចំនួនសរុបនៃឈ្មោះអ្នកបោះឆ្នោតដែលបានរក្សាទុកដដែលក្នុងបញ្ជីបោះឆ្នោត ព្រមទាំងត្រូវសរសេរបញ្ជាក់ចំនួនសន្លឹកនៃបញ្ជីបោះឆ្នោតបន្ថែម ដែលត្រូវដាក់ភ្ជាប់ទៅនឹងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធផង ។

៩.១៥.១.២ ស្មៀនឃុំ សង្កាត់ត្រូវចុះហត្ថលេខា ចុះកាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោតនៅលើសន្លឹកចុងក្រោយ ព្រមទាំងត្រូវបោះត្រានៅលើគ្រប់សន្លឹកនៃបញ្ជីបោះឆ្នោតពាក់ព័ន្ធ ។

៩.១៥.២ ស្រដៀងគ្នានេះដែរ ស្មៀនឃុំ សង្កាត់ត្រូវធានាថា ការកែតម្រូវឈ្មោះអ្នកបោះឆ្នោតនៅលើបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធក្នុងឃុំ សង្កាត់ ដោយប្រើប៊ិចក្រហម ត្រូវបានធ្វើលើបញ្ជីបោះឆ្នោតទាំងបួន(៤)ច្បាប់ និងត្រូវអនុវត្តតាមនីតិវិធី ដូចចែងក្នុងជំហានទី១ នៃការចុះឈ្មោះបោះឆ្នោតខាងលើ ។

៩.១៥.៣ នៅក្នុងរយៈពេល និងបន្ទាប់ពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ភ្លាម ស្មៀនឃុំ សង្កាត់ ដោយមានជំនួយការជាជំនួយ ត្រូវចម្លងចូលឱ្យបានឆាប់រហ័សលើទម្រង់បែបបទបញ្ជីបោះឆ្នោតបន្ថែមចំនួនបួន (៤) ច្បាប់ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ នូវឈ្មោះអ្នកសុំចុះឈ្មោះ ដែលបានទទួលយល់ព្រមឱ្យចុះឈ្មោះបោះឆ្នោត និងព័ត៌មានពាក់ព័ន្ធ ដោយត្រូវស្រង់ចេញពីគល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ។

៩.១៥.៣.១ ស្មៀនឃុំ សង្កាត់ត្រូវចារបញ្ជាក់នៅលើសន្លឹកខាងចុងបង្អស់នៃបញ្ជីបោះឆ្នោតបន្ថែមតាមការិយាល័យនីមួយៗទាំងបួន(៤)ច្បាប់ នូវចំនួនសរុបនៃឈ្មោះអ្នកសុំចុះឈ្មោះ ដែលត្រូវបានយល់ព្រមឱ្យចុះឈ្មោះបោះឆ្នោត និងត្រូវសរសេរបញ្ជាក់ចំនួនសន្លឹកនៃបញ្ជីបោះឆ្នោតបន្ថែម ដែលត្រូវដាក់ភ្ជាប់ទៅនឹងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដូចចែងក្នុងចំណុច ៩.១៥.១.២ ខាងលើ ។

៩.១៥.៣.២ ស្មៀនឃុំ សង្កាត់ត្រូវចុះហត្ថលេខា ចុះកាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោតនៅលើសន្លឹកចុងក្រោយ ព្រមទាំងត្រូវបោះត្រានៅលើគ្រប់សន្លឹកនៃបញ្ជីបោះឆ្នោតបន្ថែមពាក់ព័ន្ធ ។

៩.១៥.៤ ស្មៀនឃុំ សង្កាត់ត្រូវធានាថា បញ្ជីបោះឆ្នោតទាំងបួន(៤)ច្បាប់នៃការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ៩.១៥.១ និងបញ្ជីបោះឆ្នោតបន្ថែមចំនួនបួន(៤) ច្បាប់នៃការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ៩.១៥.៣ ខាងលើ ត្រូវបានផ្គុំបញ្ចូលគ្នាទៅជាបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ ។

៩.១៥.៥ នៅពេលដែលបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួចទាំងបួន (៤) ច្បាប់ ត្រូវបានផ្គុំគ្នាតាមការិយាល័យបោះឆ្នោតនីមួយៗរួចហើយ ស្មៀនឃុំ សង្កាត់ត្រូវផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឱ្យបានប្រាកដថា ៖

៩.១៥.៥.១ ចំនួនឈ្មោះអ្នកបោះឆ្នោតសរុប ដែលបានលុបចេញពីបញ្ជីបោះឆ្នោតស៊ីសង្វាក់គ្នាទៅនឹងទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៦ និង ១០១៧ ) និងបែបបទឯកសារលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដែលមានការបញ្ជាក់ឯកភាពពីអាជ្ញាធរឃុំ សង្កាត់ ។

៩.១៥.៥.២ ចំនួនឈ្មោះសរុបដែលមាននៅក្នុងបញ្ជីបោះឆ្នោតបន្ថែម ស៊ីសង្វាក់គ្នាទៅនឹងគល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ។

៩.១៥.៦ ស្មៀនឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត មុនជាបណ្តើរៗចំពោះការិយាល័យបោះឆ្នោតណាដែលគ្មានការបដិសេធការសុំចុះឈ្មោះ ។ ស្មៀនឃុំ សង្កាត់ត្រូវបំពេញរបាយការណ៍សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដោយឡែកពីគ្នា ដោយប្រើទម្រង់បែបបទលេខ ១០១១ តាមនីតិវិធី ដូចចែងក្រោមប្រការ ៩.១៧ ខាងក្រោម ។

៩.១៥.៧ ស្មៀនឃុំ សង្កាត់ត្រូវរង់ចាំរយៈពេលបី(៣)ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដើម្បីអោយដឹងប្រាកដថា ពុំមានការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោតណាមួយ ត្រូវបានដាក់ប្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ទេ ។ ប្រសិនបើ គ្មានការប្តឹងតវ៉ាទេ ស្មៀនឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ហើយត្រូវវេចខ្ចប់បញ្ជូនកញ្ចប់ " ក " មក គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។ ក្នុងករណីនេះ ការបញ្ជូនបញ្ជីបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួច ត្រូវអនុវត្តនៅថ្ងៃទីបួន បន្ទាប់ពីថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោត ។

៨.១៥.៨ ប្រសិនបើ មានបណ្ដឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតណាមួយត្រូវបានដាក់ប្ដឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវរង់ចាំការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោះស្រាយបណ្ដឹងចប់សិន ទើបធ្វើរបាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងវេចខ្ចប់បញ្ជូនកញ្ចប់ " ក " មក គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។ ក្នុងករណីនេះ ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់សំរេចយល់ព្រមតាមបណ្ដឹងតវ៉ា ស្មៀនឃុំ សង្កាត់ត្រូវចុះបន្ថែមឈ្មោះដែលពាក់ព័ន្ធនឹងបណ្ដឹងតវ៉ាទៅក្នុងបញ្ជីបោះឆ្នោតបន្ថែមទាំងបួន(៤)ច្បាប់ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយយោងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើបណ្ដឹងតវ៉ានោះ ។

៨.១៥.៩ ស្មៀនឃុំ សង្កាត់ត្រូវត្រៀមចាត់ចែងប្រើប្រាស់បញ្ជីបោះឆ្នោត តាមការិយាល័យបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួច ទាំងបួន(៤)ច្បាប់ ដូចខាងក្រោម ៖

៨.១៥.៩.១ ផ្ញើជូន គជប មួយច្បាប់ ដោយដាក់អមជាមួយនូវរាល់ឯកសារចុះឈ្មោះនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ក្នុងកញ្ចប់ " ក " ។

៨.១៥.៩.២ រក្សាទុកមួយច្បាប់ ជាបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ជាបណ្ដោះអាសន្នសម្រាប់ជាកម្មវត្ថុបំរើសាធារណជន ។

៨.១៥.៩.៣ បិទផ្សាយមួយច្បាប់ជាបញ្ជីបោះឆ្នោតដំបូង នៅសាលាឃុំ សង្កាត់ដើម្បីបំរើគោលដៅនៃការប្ដឹងតវ៉ា ឬ/និង ប្ដឹងជំទាស់ ។

៨.១៥.៩.៤ បិទផ្សាយមួយច្បាប់ជាបញ្ជីបោះឆ្នោតដំបូងនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ ក្នុងឃុំ សង្កាត់ ដើម្បីបំរើគោលដៅនៃការប្ដឹងតវ៉ា ឬ/និង ប្ដឹងជំទាស់ ។

៨.១៥.១០ នៅពេលដែលបណ្ដឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ( ប្រសិនបើមាន ) ត្រូវបានដោះស្រាយចប់សព្វគ្រប់ នៅក្រុមប្រឹក្សាឃុំ សង្កាត់ហើយស្មៀនឃុំ សង្កាត់ត្រូវចាត់ចែងវេចខ្ចប់បញ្ជូនកញ្ចប់ " ក " ដាក់បញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច និងរាល់ឯកសារចុះឈ្មោះពាក់ព័ន្ធ នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។ កាលបរិច្ឆេទកំណត់សម្រាប់ការបញ្ជូនបញ្ជីបោះឆ្នោតនេះ ពីឃុំ សង្កាត់ទៅខេត្ត ក្រុង និង គជប គឺមានរយៈពេលប្រាំបួន(៩)ថ្ងៃ ដែលត្រូវចាប់ផ្ដើមនៅថ្ងៃទី៨ នៅក្រោយការបញ្ចប់រយៈពេល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

**ការដាក់ពាក្យបណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត និង ការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការដោះស្រាយបណ្តឹងតវ៉ា**

**ប្រការ ៤.១៦** អ្នកសុំចុះឈ្មោះបោះឆ្នោត ដែលត្រូវបានស្មៀនឃុំ សង្កាត់បដិសេធការសុំចុះឈ្មោះបោះឆ្នោត ឬតំណាង មានសិទ្ធិប្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងយូរបី(៣)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

៤.១៦.១ អ្នកសុំចុះឈ្មោះ ឬ តំណាង ដែលមានបំណងប្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតត្រូវបំពេញពាក្យបណ្តឹងតវ៉ា (ទម្រង់បែបបទលេខ ១២០២) ចំនួនបួន(៤)ច្បាប់ រួចដាក់ពាក្យបណ្តឹងនេះ នៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

៤.១៦.២ អ្នកសុំចុះឈ្មោះ ដែលត្រូវបានស្មៀនឃុំ សង្កាត់បដិសេធការសុំចុះឈ្មោះបោះឆ្នោតរបស់ខ្លួន ហើយដែលបានទទួលទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញបណ្តឹងតវ៉ារួចហើយ ដូចចែងក្នុងជំហានទី ៧ ក្រោមប្រការ ៤.១១ ខាងលើ ប៉ុន្តែមិនបានមកដាក់ពាក្យបណ្តឹងតវ៉ានៅក្រុមប្រឹក្សាឃុំ សង្កាត់ តាមពេលវេលាកំណត់ដូចចែងក្នុងប្រការ ៤.១៦ ខាងលើ ត្រូវបានចាត់ទុកថា មិនប្តឹងតវ៉ា ។

៤.១៦.៣ ប្រសិនបើ អ្នកប្តឹងតវ៉ា ឬតំណាងបានមកដាក់ពាក្យបណ្តឹងរបស់ខ្លួន ប៉ុន្តែមិនទាន់ពេលវេលា តាមការកំណត់ដូចបានបញ្ជាក់ក្នុងប្រការ ៤.១៦ ខាងលើ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សា ដែលបានប្រគល់សិទ្ធិ ត្រូវសរសេរលើពាក្យបណ្តឹងគ្រប់ច្បាប់ថា « ពាក្យបណ្តឹងបានទទួលក្រោយថ្ងៃកំណត់នៅថ្ងៃទី ( កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង ) » ។ បន្ទាប់មក ត្រូវប្រគល់ត្រឡប់ទៅអ្នកប្តឹងតវ៉ា ឬតំណាងវិញនូវពាក្យបណ្តឹងតវ៉ាមួយច្បាប់ ហើយត្រូវរក្សាទុកពីរច្បាប់ជាឯកសារឃុំ សង្កាត់ និងផ្ញើជូន គជប មួយច្បាប់ តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៤.១៦.៤ បន្ទាប់ពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបានចាប់ផ្តើមដំណើរការ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា រាល់បណ្តឹងតវ៉ានឹងការសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោតរបស់ស្មៀនឃុំ សង្កាត់ ត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំសម្រេចជាសាធារណៈ ក្នុងអំឡុងពេលយ៉ាងយូរបី ( ៣ ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ាទាំងនោះ ។

៨.១៦.៤.១ ដើម្បីបង្កលក្ខណសម្បត្តិសម្រាប់ការប្រជុំសម្រេច របស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោះស្រាយលើបណ្តឹងតវ៉ា ត្រូវប្រមូលផ្តុំរាល់ទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ហើយដែលស្មៀនឃុំ សង្កាត់បានប្រគល់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដូចចែងក្នុងជំហានទី៧ ក្រោមប្រការ ៨.១១ ខាងលើ ។

៨.១៦.៤.២ នៅពេលទទួលពាក្យបណ្តឹងតវ៉ា មេឃុំ ចៅសង្កាត់ ឬ ជំទប់ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានប្រគល់សិទ្ធិ ត្រូវបំពេញលើពាក្យបណ្តឹងតវ៉ាទាំងបួន(៤)ច្បាប់ នូវពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង ព្រមទាំងពេលវេលា កាលបរិច្ឆេទ និងទីកន្លែងដែលនឹងត្រូវប្រជុំសម្រេចលើបណ្តឹងតវ៉ា រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬ តំណាងមួយច្បាប់ ហើយត្រូវបិទផ្សាយសេចក្តីជូនដំណឹងនេះជាសាធារណៈ នៅសាលាឃុំ សង្កាត់ មួយច្បាប់ និងត្រៀមបំរុងពីរច្បាប់សម្រាប់ការប្រជុំសម្រេច ។

៨.១៦.៥ ការប្រជុំសម្រេចជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដោះស្រាយបណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តតាមបទបញ្ជាដូចគ្នានឹងការប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែរ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការសំរេចយល់ព្រម ឬ បដិសេធលើបណ្តឹងតវ៉ានេះ ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

៨.១៦.៦ លក្ខណៈវិនិច្ឆ័យដែលក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រកាន់យកជាមូលដ្ឋានសម្រាប់ធ្វើការសំរេចលើបណ្តឹងតវ៉ា ទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត គឺត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដែលកំណត់អំពីភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះ ដូចមានចែងក្រោមប្រការ ៨.៨ នៃបទបញ្ជា និង នីតិវិធីរបស់ គជប និងផ្អែកលើមូលហេតុទាំងឡាយសម្រាប់ការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងជំហានទី៧ ក្រោមប្រការ ៨.១១ ខាងលើ ។ ក្រុមប្រឹក្សាឃុំ សង្កាត់មិនមានសិទ្ធិអំណាចអ្វីក្នុងការសំរេច ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យនិងមូលហេតុផ្សេងអំពីអ្វីដែលបានចែងក្នុងច្បាប់បោះឆ្នោត និងបទបញ្ជានិងនីតិវិធីរបស់ គជប ឡើយ ។

៩.១៦.៦.១ នៅមុនពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់សំរេចបដិសេធបណ្តឹងតវ៉ា គប្បីពិនិត្យពិចារណាអំពីមូលហេតុបដិសេធ ដែលបញ្ជាក់ក្នុងសេចក្តីសំរេចបដិសេធការសុំចុះឈ្មោះរបស់ស្មៀនឃុំ សង្កាត់ ដោយប្រៀបធៀបទៅនឹងមូលហេតុបដិសេធនៃសេចក្តីសំរេចរបស់ខ្លួន ។

៩.១៦.៧ នៅក្នុងការប្រជុំសម្រេចជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើបណ្តឹងតវ៉ា អ្នកប្តឹងតវ៉ា ឬតំណាងមានសិទ្ធិបង្ហាញភស្តុតាងជាឯកសារផ្សេងៗ ប្រសិនបើមាន ដែលបញ្ជាក់អំពីភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកប្តឹងតវ៉ាសុំចុះឈ្មោះ ស្រប តាមច្បាប់ និងបទបញ្ជានិងនីតិវិធីរបស់ គជប ។

៩.១៦.៨ ក្នុងករណី ក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចបដិសេធលើបណ្តឹងតវ៉ា មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលធ្វើជាអធិបតីក្នុងការប្រជុំសម្រេចជាសាធារណៈនោះ ត្រូវ ៖

៩.១៦.៨.១ ចារបដិសេធ ចុះហត្ថលេខា និងកាលបរិច្ឆេទលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬ តំណាងមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៩.១៦.៨.២ ចាត់ចែងឱ្យបំពេញសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបីច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

៩.១៦.៨.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់លើសេចក្តីសម្រេចដែលបានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ាឬតំណាងមួយច្បាប់ ប្រគល់ឱ្យស្មៀនឃុំ សង្កាត់សម្រាប់ផ្ញើជូន គជប មួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៩.១៦.៨.៤ ប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាង នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ តាមសំណើសុំ សម្រាប់បំពេញបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គជប និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងតវ៉ា អំពីករណីនេះ ទៅ គជប យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ។

៩.១៦.៩ ក្នុងករណី ក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចយល់ព្រមលើបណ្តឹងតវ៉ា មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលធ្វើជាអធិបតីក្នុងការប្រជុំសម្រេចជាសាធារណៈនោះ ត្រូវ ៖

៩.១៦.៩.១ ចារយល់ព្រម ចុះហត្ថលេខា និងកាលបរិច្ឆេទលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ាឬតំណាងមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៩.១៦.៩.២ ចាត់ចែងឱ្យបំពេញសេចក្តីសម្រេចយល់ព្រមលើបណ្តឹងតវ៉ា (ទម្រង់បែបបទលេខ ១២០៣ ) ជាបី (៣)ច្បាប់ ។

៩.១៦.៩.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់លើសេចក្តីសម្រេចដែលបានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាងមួយច្បាប់ ប្រគល់ឱ្យស្មៀនឃុំ សង្កាត់មួយច្បាប់ ដែលក្រោយមកត្រូវផ្ញើជូន គជប និងរក្សាទុកជាឯកសារមួយច្បាប់ ។

៩.១៦.១០ ផ្អែកតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើបណ្តឹងតវ៉ា ដូចបានចែងក្រោមចំណុច ៩.១៦.៩.៣ ខាងលើ ស្មៀនឃុំ សង្កាត់ត្រូវចុះឈ្មោះបោះឆ្នោតជូនអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ដោយត្រូវ ៖

៩.១៦.១០.១ ណាត់ជាមួយអ្នកប្តឹងតវ៉ាសុំចុះឈ្មោះជាមុន អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលា ដើម្បីទៅចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើបណ្តឹងតវ៉ា ។

៩.១៦.១០.២ បំពេញឈ្មោះអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត និងទិន្នន័យពាក់ព័ន្ធលើទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះនៅផ្នែកទាំងពីរ ដូចចែងក្នុងជំហានទី៦ ក្នុងប្រការ ៩.១១ ខាងលើ ។

៩.១៦.១០.៣ ហែកផ្នែកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត រួចប្រគល់ជូនអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត និងរំលឹកគាត់អំពីលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដែលមាននៅក្នុងបង្កាន់ដៃស្រាប់ ។

៩.១៦.១០.៤ សរសេរបំពេញឈ្មោះនិងទិន្នន័យនៃអ្នកប្តឹងតវ៉ាសុំចុះឈ្មោះ នៅក្នុងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយយោងតាមគល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ។

៩.១៦.១១ ស្មៀនឃុំ សង្កាត់ត្រូវធានាថា រាល់សេចក្តីសម្រេចបដិសេធ ដូចចែងក្នុងចំណុច ៩.១៦.៨.៣ ឬ សេចក្តីសំរេចយល់ព្រមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ដូចចែងក្នុងចំណុច ៩.១៦.៩.៣ ខាងលើ ត្រូវតែបានដាក់ផ្ញើស្របពេលនឹងការវេចខ្ចប់បញ្ជូនកញ្ចប់ " ក " ជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៩.១៦.១២ ស្មៀនឃុំ សង្កាត់ ត្រូវធានាថា គល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដូចបានចែងក្នុងចំណុច ៩.១៦.១០.២ និងបញ្ជីបោះឆ្នោតបន្ថែម ដូចចែងក្នុងចំណុច ៩.១៦.១០.៤ ខាងលើ ត្រូវតែបានវេចខ្ចប់ដាក់អមជាមួយកញ្ចប់ " ក " ទៅក្នុងកញ្ចប់ " ខ " ផ្ញើជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

**ការបំពេញរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត តាមការិយាល័យនីមួយៗ**

**ប្រការ ៩.១៧** នៅពេលដែលការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ ស្មៀនឃុំ សង្កាត់ត្រូវបំពេញរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត តាមការិយាល័យបោះឆ្នោត ជាបណ្តើរៗ ចំពោះការិយាល័យបោះឆ្នោតដែលមិនមានអ្នកសុំចុះឈ្មោះណាម្នាក់ត្រូវបានបដិសេធការសុំចុះឈ្មោះ ។ ស្មៀនឃុំ សង្កាត់ត្រូវធានាថា របាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត ដែលមានអ្នកសុំចុះឈ្មោះម្នាក់ ឬច្រើននាក់ ត្រូវបានបដិសេធការសុំចុះឈ្មោះ ត្រូវបានបំពេញរួចរាល់ មុនពេលវេចខ្ចប់បញ្ជូនកញ្ចប់ " ក " ទៅ គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៩.១៧.១ ប្រសិនបើ គ្មានបណ្តឹងតវ៉ាត្រូវបានដាក់ប្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេលបី(៣)ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតទេ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យឱ្យរួចរាល់ នៅមុនពេលត្រូវវេចខ្ចប់បញ្ជូនកញ្ចប់ " ក " ដែលនឹងត្រូវអនុវត្តនៅថ្ងៃទី៤ បន្ទាប់ពីថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោត ។

៩.១៧.២ ប្រសិនបើ មានបណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតមួយ ឬច្រើនត្រូវបានដាក់ប្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យពាក់ព័ន្ធក្នុងឃុំ សង្កាត់ បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់បានសំរេចដោះស្រាយបណ្តឹងចប់ និងនៅមុនពេលវេចខ្ចប់បញ្ជូនកញ្ចប់ " ក " ដែលអាចនឹងត្រូវអនុវត្តនៅថ្ងៃទី៧ បន្ទាប់ពីថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោត ។

៩.១៧.៣ ស្មៀនឃុំ សង្កាត់ ត្រូវបំពេញរបាយការណ៍សម្រាប់ការិយាល័យនីមួយៗ ដោយ ឡែកពីគ្នាចំនួនបួន(៤)ច្បាប់ ដោយប្រើទម្រង់បែបបទលេខ ១០១១ ។ របាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យត្រូវមានបញ្ជាក់ចំណុចសំខាន់ៗ ដូចខាងក្រោម ៖

៩.១៧.៣.១ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ឃុំ សង្កាត់ និងខេត្ត ក្រុង ។

៩.១៧.៣.២ រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.១៧.៣.៣ ចំនួនឈ្មោះអ្នកបោះឆ្នោតមានក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ។

៩.១៧.៣.៤ ចំនួនឈ្មោះដែលបានលុបចេញពីបញ្ជីបោះឆ្នោតចុងក្រោយ ។

៩.១៧.៣.៥ ចំនួនឈ្មោះដែលរក្សាទុកក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ។

៩.១៧.៣.៦ ចំនួនឈ្មោះអ្នកចុះឈ្មោះថ្មីក្នុងបញ្ជីបោះឆ្នោតបន្ថែម ។

៩.១៧.៣.៧ ចំនួនគល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលបានចេញសម្រាប់ការិយាល័យនេះ ។

៩.១៧.៣.៨ សរុបចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួច ដោយយោងការផ្ទៀងផ្ទាត់តាមរយៈធ្វើប្រមាណវិធីតាមរូបមន្ត ៖ សរុបចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួច ស្មើនឹង ចំនួនឈ្មោះដែលរក្សាទុកក្នុងបញ្ជីបោះឆ្នោតចុងក្រោយ បូកនឹង ចំនួនឈ្មោះអ្នកចុះឈ្មោះថ្មីក្នុងបញ្ជីបោះឆ្នោតបន្ថែម ។

៩.១៧.៣.៩ ចំនួនសេចក្តីសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត សម្រាប់ការិយាល័យនេះ ដែលបានចេញ ។

៩.១៧.៣.១០ ហត្ថលេខារបស់ស្មៀនឃុំ សង្កាត់ កាលបរិច្ឆេទ និងត្រាការិយាល័យចុះឈ្មោះបោះឆ្នោត ។

៩.១៧.៣.១១ការចូលរួមចុះហត្ថលេខាឬផ្តិតមេដៃជាសាក្សីរបស់តំណាងគណបក្សនយោបាយ ។

៩.១៧.៤ របាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យ ( ទម្រង់បែបបទលេខ ១០១១ ) ទាំងបួន(៤)ច្បាប់ ដែលស្មៀនឃុំ សង្កាត់បានបំពេញ ត្រូវចាត់ចែងប្រើប្រាស់ និងបញ្ជូន ដូចខាងក្រោម ៖

៩.១៧.៤.១ ច្រកស្រោមសំបុត្រដាក់ក្នុងកញ្ចប់ " ក " មួយច្បាប់ ។

៩.១៧.៤.២ កិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ " ក " ពីរច្បាប់ ។

៩.១៧.៤.៣ រក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់ មួយច្បាប់ ។

**ការវេចខ្ចប់កញ្ចប់ " ក " ដាក់បញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច និងរាល់ឯកសារចុះឈ្មោះពាក់ព័ន្ធ តាមការិយាល័យនីមួយៗ**

**ប្រការ ៩.១៨** នៅក្រោយពេលបានបំពេញរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយរួចភ្លាម ស្មៀនឃុំ សង្កាត់ត្រូវរៀបចំវេចខ្ចប់បញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច នៃការិយាល័យបោះឆ្នោតនោះ និងរាល់ឯកសារចុះឈ្មោះពាក់ព័ន្ធ ដោយដាក់ទៅក្នុងកញ្ចប់ " ក " ដែលត្រូវមានសរសេរសំគាល់ពីក្រៅនូវលេខកូដខេត្ត ក្រុង ឃុំ សង្កាត់ និងលេខកូដការិយាល័យបោះឆ្នោតនោះផង ។

៩.១៨.១ ស្មៀនឃុំ សង្កាត់ត្រូវធានាថា រាល់កញ្ចប់ " ក " នីមួយៗត្រូវបានរៀបចំវេចខ្ចប់ដាក់បញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច និងរាល់ឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះយ៉ាងត្រឹមត្រូវតាមការកំណត់ដូចខាងក្រោម ៖

៩.១៨.១.១ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួច នៃការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់មួយច្បាប់ ដែលក្នុងនោះ រួមមានទាំងបញ្ជីបោះឆ្នោតបន្ថែមសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធផង ។

៩.១៨.១.២ ស្រោមសំបុត្រដាក់រួមបញ្ចូលគ្នា នូវ ៖

រាល់ទម្រង់បែបបទ ១០១៦ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យនោះ ចំពោះករណីអ្នកបោះឆ្នោតដែលស្លាប់ ឬបាត់បង់សិទ្ធិបោះឆ្នោត ឬផ្លាស់ទីលំនៅចេញ ឬគ្មានទីលំនៅអចិន្ត្រៃយ៍ឬបណ្ដោះអាសន្នក្នុងឃុំ សង្កាត់ ។

រាល់ទម្រង់បែបបទ ១០១៧ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យនោះ ចំពោះករណីអ្នកបោះឆ្នោតបានសុំចុះឈ្មោះថ្មី ដោយប្ដូរពីការិយាល័យបោះឆ្នោតមួយ ទៅការិយាល័យបោះឆ្នោតមួយទៀត នៅក្នុងឃុំ សង្កាត់ដដែល ។

រាល់ឯកសារភស្តុតាងពាក់ព័ន្ធនឹងទម្រង់ ១០១៦ និង ១០១៧ ។

៩.១៨.១.៣ ស្រោមសំបុត្រដាក់រាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់យល់ព្រមលើបណ្ដឹងតវ៉ា ( ទម្រង់បែបបទ ១២០៣ ) ដែលតម្រូវឱ្យស្មៀនឃុំ សង្កាត់ចុះឈ្មោះអ្នកប្ដឹងតវ៉ាសុំចុះឈ្មោះ ទៅក្នុងបញ្ជីបោះឆ្នោតបន្ថែម នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៩.១៨.១.៩ ស្រោមសំបុត្រដាក់របាយការណ៍លទ្ធផល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យ ( ទម្រង់បែបបទលេខ ១០១១ ) ចំនួនមួយ(១)ច្បាប់ ។

៩.១៨.២ ស្មៀនឃុំ សង្កាត់ត្រូវធានាថា មិនត្រូវឱ្យមាននៅសល់សម្ភារៈឯកសារណាមួយ ដូចចែងក្រោមចំណុច ៩.១៨.១ ខាងលើ ដែលត្រូវភ្លេចមិនទាន់ដាក់ក្នុងកញ្ចប់ " ក " នីមួយៗនោះឡើយ ។ ស្មៀនឃុំ សង្កាត់ត្រូវធានាថា ៖

៩.១៨.២.១ សម្ភារៈឯកសារដូចចែងក្រោមចំណុច ៦.១៨.១ ខាងលើ ត្រូវបានដាក់ចូលក្នុងកញ្ចប់ " ក " និងបិទឱ្យជិតនៅចំពោះមុខជំនួយការស្មៀន សមាជិកក្រុមប្រឹក្សាដែលប្រចាំការពិនិត្យមើលការងារស្មៀន តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន ។

៩.១៨.២.២ របាយការណ៍លទ្ធផល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យ ( ទម្រង់បែបបទលេខ ១០១១ ) ចំនួនពីរ(២)ច្បាប់ ត្រូវកិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ " ក " ។

៩.១៨.២.៣ កញ្ចប់ " ក " ដែលទើបបានបិទភ្ជិតរួច ត្រូវបានសរសេរសំគាល់ដោយហ្វឺតលុបមិនជ្រះ នូវលេខកូដខេត្ត ក្រុង ឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតយ៉ាងត្រឹមត្រូវ នៅត្រង់ចន្លោះទំនេរនៅផ្នែកខាងក្រៅនៃកញ្ចប់ " ក " ។

៩.១៨.២.៤ កញ្ចប់ " ក " ដែលបានដាក់បញ្ជីបោះឆ្នោត និងសម្ភារៈឯកសារចុះឈ្មោះនៃការិយាល័យបោះឆ្នោតនីមួយៗរួចហើយ ត្រូវបានថែរក្សាសុវត្ថិភាព មុនពេលវេចខ្ចប់ក្នុងកញ្ចប់ " ខ " ដើម្បីបញ្ជូនទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៩.១៨.៣ ស្មៀនឃុំ សង្កាត់ត្រូវធានាថា បន្ទាប់ពីកញ្ចប់ " ក " នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ត្រូវបានវេចខ្ចប់ និងបិទភ្ជិតរួចរាល់ហើយ ត្រូវបន្តធ្វើរបាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងរៀបចំវេចខ្ចប់កញ្ចប់ " ក " ទាំងនោះ និងសម្ភារៈឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះផ្សេងទៀត ទៅក្នុងកញ្ចប់ " ខ " ដើម្បីបញ្ជូនទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៨.១៨.៤ ស្មៀនឃុំ សង្កាត់ត្រូវរក្សាទុកបញ្ជីបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ នៅសល់បី(៣)ច្បាប់ទៀត សម្រាប់បំរើការបិទផ្សាយបញ្ជីដំបូងពីរ(២)ច្បាប់ និង រក្សាទុកជាបញ្ជីបោះឆ្នោតជាបណ្ដោះអាសន្នមួយ(១)ច្បាប់នៅសាលាឃុំ សង្កាត់ ។

**ការបំពេញរបាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និង ការវេចខ្ចប់កញ្ចប់ " ក " ដាក់ក្នុងកញ្ចប់ " ខ " ដើម្បីបញ្ជូន និងប្រគល់ជូនលេខាធិការដ្ឋានខេត្ត ក្រុង រៀបចំការបោះឆ្នោត**

**ប្រការ ៨.១៩** នៅពេលដែលដំណើរការនៃការដាក់ពាក្យ និង ការដោះស្រាយបណ្ដឹងតវ៉ាទៅនឹងការបដិសេធ ការសុំចុះឈ្មោះបោះឆ្នោត នៅក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបញ្ចប់ ស្មៀនឃុំ សង្កាត់ត្រូវ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយផ្អែកលើរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយា ល័យបោះឆ្នោតទាំងអស់ និងតួលេខមួយចំនួនទៀត ដែលទាក់ទងទៅនឹងចំនួនការិយាល័យ បោះឆ្នោតសរុប និងចំនួនទម្រង់បែបបទចុះឈ្មោះបោះឆ្នោត/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែល បានទទួលសរុប បានប្រើប្រាស់ និងនៅសល់ ។

៨.១៩.១ ប្រសិនបើ គ្មានបណ្ដឹងតវ៉ាត្រូវបានដាក់ប្ដឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈ ពេលបី(៣)ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតទេ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើរបាយការណ៍សរុបលទ្ធផល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ឱ្យរួចរាល់ នៅមុនពេលត្រូវវេចខ្ចប់កញ្ចប់ " ក " ដាក់ក្នុងកញ្ចប់ " ខ " ។

៨.១៩.២ ប្រសិនបើ មានបណ្ដឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតមួយ ឬច្រើន ត្រូវបានដាក់ប្ដឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍ សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់បានសំរេចដោះស្រាយបណ្ដឹងចប់ និងនៅមុនពេល វេចខ្ចប់កញ្ចប់ " ក " ដាក់ក្នុងកញ្ចប់ " ខ " ។

៨.១៩.៣ ស្មៀនឃុំ សង្កាត់ ត្រូវបំពេញរបាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួនបី(៣)ច្បាប់ ដោយប្រើទម្រង់បែប បទលេខ ១០១២ ។ របាយការណ៍នេះ ត្រូវមានបញ្ជាក់តួលេខលទ្ធផល ដែល បានមកពីការបូកសរុបបញ្ចូលគ្នា នូវតួលេខក្នុងរបាយការណ៍លទ្ធផលនៃការពិនិត្យ បញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់

ដូចចែងក្នុងចំណុច ៩.១៧.៣ និងដែលបានចងក្រងទុកជាឯកសាររបស់ស្មៀន ឃុំ សង្កាត់ ដូចចែងក្នុងចំណុច ៩.១៧.៩.៣ ខាងលើ ។ របាយការណ៍រួម មានចំណុចសំខាន់ៗ ដូចខាងក្រោម ៖

៩.១៩.៣.១ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ឃុំ សង្កាត់ និងខេត្ត ក្រុង ។

៩.១៩.៣.២ ចំនួនការិយាល័យបោះឆ្នោតសរុបមុនចុះឈ្មោះ ចំនួនការិយាល័យបិទមិនចុះឈ្មោះ និងចំនួនការិយាល័យបង្កើតថ្មី ។

៩.១៩.៣.៣ ចំនួន និងឈ្មោះទីតាំងការិយាល័យចុះឈ្មោះ ។

៩.១៩.៣.៤ ចំនួន និងឈ្មោះមន្ត្រីចុះឈ្មោះ ( ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀន ) ។

៩.១៩.៣.៥ រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.១៩.៣.៦ សរុបចំនួនឈ្មោះអ្នកបោះឆ្នោតមានក្នុងបញ្ជីបោះឆ្នោតចុងក្រោយ នៃការិយាល័យទាំងអស់ ។

៩.១៩.៣.៧ សរុបចំនួនឈ្មោះដែលបានលុបចេញពីបញ្ជីបោះឆ្នោតចុងក្រោយ នៃការិយាល័យទាំងអស់ ។

៩.១៩.៣.៨ សរុបចំនួនឈ្មោះដែលរក្សាទុកក្នុងបញ្ជីបោះឆ្នោតចុងក្រោយ នៃការិយាល័យទាំងអស់ ។

៩.១៩.៣.៩ សរុបចំនួនឈ្មោះអ្នកចុះឈ្មោះថ្មីក្នុងបញ្ជីបោះឆ្នោតបន្ថែម នៃការិយាល័យទាំងអស់ ។

៩.១៩.៣.១០ សរុបចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួច នៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់ ។

៩.១៩.៣.១១ ចំនួនទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះសរុបដែលបានទទួលសម្រាប់ឃុំ សង្កាត់ ។

៩.១៩.៣.១២ សរុបចំនួនគល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានចេញសម្រាប់ការិយាល័យទាំងអស់ ។

៩.១៩.៣.១៣ ចំនួនទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលនៅសល់មិនទាន់ប្រើក្នុងឃុំ សង្កាត់ ។

៩.១៩.៣.១៤ សរុបចំនួនសេចក្តីសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដែលបានចេញក្នុងឃុំ សង្កាត់ ។

៩.១៩.៣.១៥ ហត្ថលេខារបស់ស្មៀនឃុំ សង្កាត់ កាលបរិច្ឆេទ និងត្រាការិយាល័យចុះឈ្មោះបោះឆ្នោត ។

៨.១៩.៤ របាយការណ៍សរុបលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្នុងឃុំ សង្កាត់ ( ទម្រង់បែបបទលេខ ១០១២ ) ទាំងបី(៣)ច្បាប់ ដែលស្មៀនឃុំ សង្កាត់បានបំពេញ ត្រូវចាត់ចែងប្រើប្រាស់ និងបញ្ជូន ដូចខាងក្រោម ៖

៨.១៩.៤.១ ច្រកស្រោមសំបុត្រដាក់ក្នុងកញ្ចប់ " ខ " ចំនួនពីរ( ២ )ច្បាប់ ដែលត្រូវផ្ញើជូនលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត មួយច្បាប់ និងផ្ញើជូន គជប មួយច្បាប់ ។

៨.១៩.៤.២ រក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់ មួយច្បាប់ ។

៨.១៩.៥ នៅក្រោយពេលបានបំពេញរបាយការណ៍សរុបលទ្ធផល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់រួចភ្លាម ស្មៀនឃុំ សង្កាត់ត្រូវរៀបចំវេចខ្ចប់កញ្ចប់ " ក " ឬ/និង រាល់សម្ភារៈឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះទាំងអស់ ដោយដាក់ក្នុងកញ្ចប់ " ខ " តាមចំនួនដែលអាចដាក់ឱ្យអស់កញ្ចប់ " ក " និង រាល់សម្ភារៈឯកសារទាំងនោះ ។

៨.១៩.៥.១ ស្មៀនឃុំ សង្កាត់ត្រូវបំពេញលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ក " (ទម្រង់បែបបទលេខ ១០១៣) ចំនួនបួន(៤)ច្បាប់ សម្រាប់កញ្ចប់ " ខ " នីមួយៗដោយត្រូវបញ្ជាក់ចំនួនកញ្ចប់ " ក " ឬ/និងសម្ភារៈឯកសារចុះឈ្មោះ ដែលបានដាក់ក្នុងកញ្ចប់ " ខ " នោះ ។

៨.១៩.៥.២ ស្មៀនឃុំ សង្កាត់ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត លើលិខិតបញ្ជាក់ការវេចខ្ចប់និងការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ទាំងបួន (៤)ច្បាប់ដែលបានបំពេញ ។

៨.១៩.៥.៣ ស្មៀនឃុំ សង្កាត់ត្រូវបែងចែក និងបញ្ជូនលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ដូចខាងក្រោម ៖

ច្រកពីរច្បាប់ក្នុងស្រោមសំបុត្រ ដាក់ក្នុងកញ្ចប់ " ខ " ។

ដាក់មួយច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " ។

ទុកមួយច្បាប់សម្រាប់ប្រើក្នុងការប្រគល់/ទទួលកញ្ចប់ " ខ " នៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ហើយដែលក្រោយមក ត្រូវរក្សាទុកជាឯកសាររបស់ស្មៀនឃុំ សង្កាត់ ។

៤.១៩.៦ ស្មៀនឃុំ សង្កាត់ត្រូវធានាថា រាល់គល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលបានប្រើហើយ និងទម្រង់បែបបទនេះ ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ត្រូវដាក់ទៅក្នុងកញ្ចប់មួយដោយឡែក ដែលត្រៀមបំរុងស្រាប់ ដោយដាក់ភ្ជាប់ជាមួយនូវរបាយការណ៍ស្តីពីតុល្យភាពនៃការទទួលនិងការប្រើប្រាស់ទម្រង់បែបបទនេះផង ។ ក្នុងនោះស្មៀនឃុំ សង្កាត់ត្រូវ ៖

៤.១៩.៦.១ បំពេញរបាយការណ៍ស្តីពីតុល្យភាពនៃ ការទទួល និងការប្រើប្រាស់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដោយប្រើទម្រង់បែបបទលេខ ១០២១ ចំនួនបី(៣)ច្បាប់ ។

៤.១៩.៦.២ ដាក់ក្នុងកញ្ចប់នូវ ៖

- រាល់គល់សន្លឹកទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលបានប្រើហើយ ក្នុងឃុំ សង្កាត់ ។
- រាល់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ។
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដូចចែងក្នុងចំណុច ៤.១៩.៦.១ ចំនួនមួយ(១)ច្បាប់ ។

៤.១៩.៦.៣ កិបភ្ជាប់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដូចចែងក្នុងចំណុច ៤.១៩.៦.១ ចំនួនមួយ(១)ច្បាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ និងរក្សាទុកមួយច្បាប់ជាឯកសារ ។

៤.១៩.៦.៤ សរសេរសំគាល់លេខកូដឃុំ សង្កាត់នៅលើផ្នែកខាងក្រៅនៃកញ្ចប់នេះផង ។

៤.១៩.៧ ស្មៀនឃុំ សង្កាត់ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់ " ក " ឬ/និង រាល់សម្ភារៈឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះទាំងអស់ ដោយដាក់ក្នុងកញ្ចប់ " ខ " តាមចំនួនដែលអាចដាក់ឱ្យអស់កញ្ចប់ " ក " និងរាល់សម្ភារៈឯកសារទាំងនោះ ។ ស្មៀនឃុំ សង្កាត់ត្រូវរៀបចំវេចខ្ចប់ដាក់ក្នុងកញ្ចប់ " ខ " ទី១ ដូចខាងក្រោម ៖

៩.១៩.៧.១ កញ្ចប់ដាក់គល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលបានប្រើហើយ និងទម្រង់បែបបទនេះ ដែលនៅសល់មិនទាន់ប្រើទាំងអស់ក្នុងឃុំ សង្កាត់ ។

៩.១៩.៧.២ ស្រោមសំបុត្រដាក់របាយការណ៍សរុបលទ្ធផល នៃ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ( ទម្រង់បែបបទលេខ ១០១២ ) ចំនួនពីរ(២)ច្បាប់ ។

៩.១៩.៧.៣ ស្រោមសំបុត្រដាក់ទម្រង់បែបបទលុបឈ្មោះ ចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ផ្សេង (ទម្រង់បែបបទលេខ ១០១៧ ដែលប្រើសម្រាប់អ្នកផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់) និងបញ្ជីស្រង់ឈ្មោះស្នួលត្រូវលុបចេញពីបញ្ជីបោះឆ្នោត ដែលមានការបញ្ជាក់ឯកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

៩.១៩.៧.៤ ស្រោមសំបុត្រដាក់ រាល់សេចក្ដីសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ( ទម្រង់បែបបទលេខ ១០០៩ ) ។

៩.១៩.៧.៥ ស្រោមសំបុត្រដាក់រាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បដិសេធបណ្ដឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ( ទម្រង់បែបបទលេខ ១២០៣ ) ។

៩.១៩.៧.៦ ស្រោមសំបុត្រដាក់រាល់បណ្ដឹងតវ៉ា នឹងការបដិសេធការសុំចុះឈ្មោះ ( ទម្រង់លេខ ១២០២ ) ដែលដាក់នៅក្រោយពេលកំណត់ ។

៩.១៩.៧.៧ ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់ និងបញ្ជូនសំភារ:ឯកសារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ( ទម្រង់បែបបទលេខ ១០១៣ ) ចំនួនពីរ(២)ច្បាប់ ។

៩.១៩.៨ កញ្ចប់ " ខ " ទី២ និង កញ្ចប់ " ខ " បន្តបន្ទាប់ តាមចំនួនចាំបាច់ ដែលត្រូវរៀបចំដាក់កញ្ចប់ " ក " នៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ឯកសារពាក់ព័ន្ធ ដូចខាងក្រោម ៖

៩.១៩.៨.១ កញ្ចប់ " ក " តាមចំនួនដែលអាចដាក់បាន ក្នុងកញ្ចប់ " ខ " នីមួយៗ ។ កញ្ចប់ " ក " ដែលត្រូវដាក់ក្នុងកញ្ចប់ " ខ " តែមួយត្រូវតែបានរៀបចំតាមលេខរៀងជាប់គ្នា និងតាមលំដាប់លំដោយ ។

៩.១៩.៨.២ ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់ និងបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ចំនួនពីរ(២)ច្បាប់ ។

៩.១៩.៩ ស្មៀនឃុំ សង្កាត់ត្រូវធានាថា មិនត្រូវឱ្យមាននៅសល់សម្ភារៈឯកសារណាមួយ ដូចចែងក្រោមចំណុច ៩.១៩.៧ ឬ ៩.១៩.៨ ខាងលើ ដែលត្រូវភ្លេចមិនទាន់ដាក់ក្នុងកញ្ចប់ " ខ " នីមួយៗនោះឡើយ ។ កញ្ចប់ " ខ " ដែលបានចងភ្ជិតរួចហើយ អាចនឹងបើកឡើងវិញបាន តែក្នុងពេលបំពេញភារកិច្ចត្រួតពិនិត្យការទទួលសម្ភារៈឯកសារនៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត និងនៅមជ្ឈមណ្ឌលកំព្យូទ័រនៃ គជប ប៉ុណ្ណោះ ។ ស្មៀនឃុំ សង្កាត់ ត្រូវធានាថា ៖

៩.១៩.៩.១ សម្ភារៈឯកសារដូចចែងក្រោមចំណុច ៩.១៩.៧ ខាងលើ ត្រូវបានដាក់ចូលក្នុងកញ្ចប់ " ខ " ទី១ ហើយសម្ភារៈឯកសារដូចចែងក្រោមចំណុច ៩.១៩.៨ ខាងលើ ត្រូវបានដាក់ចូលក្នុងកញ្ចប់ " ខ " ទី២ និងកញ្ចប់ " ខ " បន្តបន្ទាប់ រួចត្រូវចងភ្ជិត នៅចំពោះមុខជំនួយការស្មៀន សមាជិកក្រុមប្រឹក្សា ដែលប្រចាំការពិនិត្យមើលការងារស្មៀន តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ។

៩.១៩.៩.២ ចំពោះឃុំ សង្កាត់ដែលមានការិយាល័យបោះឆ្នោតតិច អាចប្រើកញ្ចប់ " ខ " តែមួយសម្រាប់ដាក់សម្ភារៈឯកសារទាំងអស់ ដូចបានចែងក្នុងចំណុច ៩.១៩.៧ និង ៩.១៩.៨ ខាងលើ រួមបញ្ចូលគ្នា ។

៩.១៩.៩.៣ លិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ចំនួនមួយ(១)ច្បាប់ ត្រូវដាក់ក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " ។

៩.១៩.៩.៤ កញ្ចប់ " ខ " នីមួយៗដែលទើបបានបិទភ្ជិតរួច ត្រូវបានសរសេរសំគាល់ដោយហ្វឺតលុបមិនជ្រះនូវលេខកូដខេត្ត ក្រុង និងឃុំ សង្កាត់ យ៉ាងត្រឹមត្រូវ នៅត្រង់ចន្លោះទំនេរនៅផ្នែកខាងលើហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " ។

៩.១៩.៩.៥ កញ្ចប់ " ខ " ដែលបានវេចខ្ចប់ត្រឹមត្រូវរួចហើយ ត្រូវតែបានការពារ និងថែរក្សាសុវត្ថិភាព នៅមុនពេល និងក្នុងពេលបញ្ជូនទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៩.១៩.១០ ស្មៀនឃុំ សង្កាត់ត្រូវទទួលបន្ទុកការបញ្ជូន និងប្រគល់កញ្ចប់ " ខ " ដោយផ្ទាល់ទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។ ទន្ទឹមនឹងនេះ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត អាចចាត់មន្ត្រីរបស់ខ្លួនឱ្យចុះត្រួតពិនិត្យ

និងទទួលយកកញ្ចប់ " ខ " នៅតាមឃុំ សង្កាត់ក៏បាន ។ នៅក្នុងរាល់ការប្រគល់ទទួលកញ្ចប់ " ខ " ស្មៀនឃុំ សង្កាត់ ត្រូវធានាថា មន្ត្រីទទួលបន្ទុកការទទួលឯកសារ នៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតបានចុះហត្ថលេខាលើលិខិតបញ្ជាក់ការវេចខ្ចប់ និងបញ្ជូនកញ្ចប់ " ខ " ( ទម្រង់បែបបទលេខ ១០១៣ ) ទាំងបួន(៤)ច្បាប់ ដូចចែងក្នុងចំណុច ៩.១៩.៥.៣ ដើម្បីបញ្ជាក់ថាមន្ត្រីនោះបានទទួលមែន និងប្រគល់មួយច្បាប់មកឱ្យស្មៀនឃុំ សង្កាត់វិញ ។

៩.១៩.១១ នៅចុងបញ្ចប់នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវប្រគល់សម្ភារៈឧបករណ៍បំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅសល់ ដូចជា កេសសង្កសី ( សំបកហិបបរិក្ខារ )... មក គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ស្របពេលនឹងការបញ្ជូន និងការប្រគល់កញ្ចប់ " ខ " ដែរ ។ ដោយឡែក សម្ភារៈឧបករណ៍ផ្សេងទៀតដូចជា វិទ្យុទាក់ទង គ្រឿងបរិក្ខារវិទ្យុទាក់ទង ត្រា តាំប៉ុង ទម្រង់បែបបទ និងសំភារៈផ្សេងទៀត ដែលកំណត់ជាក់ស្តែងដោយ គជប ត្រូវតែរក្សាទុកនៅនឹងស្មៀនឃុំ សង្កាត់ សម្រាប់ប្រើប្រាស់រហូតដល់ពេលបញ្ចប់ការធ្វើរបាយការណ៍ ស្តីពីការកែតម្រូវលើបញ្ជីបោះឆ្នោតដំបូង ទើបបញ្ជូនមក គជប តាមក្រោយ ។

៩.១៩.១២ សម្រាប់ឆ្នាំដែលមានការរៀបចំការបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវប្រគល់ជូន គឃ/សប នៅពេលដែលត្រូវបានតែងតាំង នូវរាល់ឯកសារឬ/និងទម្រង់បែបបទផ្សេងៗដែលនៅសល់ ហើយដែលអាចប្រើប្រាស់បន្ត នៅក្នុងដំណើរការបន្ទាប់ពីបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.១៩.១៣ តំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត ប្រចាំឃុំ សង្កាត់នីមួយៗ អាចរួមដំណើរសង្កេតមើល និងអាចធ្វើជាសាក្សីក្នុងការប្រគល់ទទួលកញ្ចប់ " ខ " និងសម្ភារៈឯកសារខាងលើ ។

**ការវាយតំលៃការងារជំនួយការស្មៀន ឃុំ សង្កាត់**

**ប្រការ ៩.២០** គជប ត្រូវតែងតាំងក្រុមត្រួតពិនិត្យប្រសិទ្ធភាពការងារមួយក្រុម ឬច្រើនក្រុម ដើម្បីចុះទៅត្រួតពិនិត្យនៅតាមខេត្ត ក្រុងនានា ដើម្បីធានាថា បទបញ្ជា និងនីតិវិធីរបស់ គជប ត្រូវបានគោរព ហើយដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី

និងត្រឹមត្រូវ ។ គជប ត្រូវដំណើរការផងដែរ នូវការវាយតម្លៃចំពោះជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ។

៨.២០.១ ក្រុមត្រួតពិនិត្យប្រសិទ្ធភាពការងារត្រូវចុះត្រួតពិនិត្យ តាមការិយាល័យចុះឈ្មោះបោះឆ្នោតមួយចំនួនក្នុងឃុំ សង្កាត់ផ្សេងៗគ្នានៃខេត្ត ក្រុង ដែលបានកំណត់ដោយ គជប ព្រមទាំងត្រួតពិនិត្យប្រសិទ្ធភាពការងារនៃការវេចខ្ចប់បញ្ជូន និងការប្រគល់ទទួលសម្ភារៈឯកសារនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរបស់ស្មៀនឃុំ សង្កាត់ និងលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៨.២០.១.១ ក្រុមត្រួតពិនិត្យប្រសិទ្ធភាពការងារ ត្រូវជូនយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឬ/និង ស្មៀនឃុំ សង្កាត់ និងមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត នូវកំហុសឆ្គងដែលក្រុមត្រួតពិនិត្យបានរកឃើញ និងផ្តល់ការណែនាំសមស្របដល់ពួកគាត់ ។

៨.២០.១.២ នៅកន្លែង ដែលក្រុមត្រួតពិនិត្យប្រសិទ្ធភាពការងារបានរកឃើញថាប្រការណាមួយនៃបទបញ្ជា និងនីតិវិធីរបស់ គជប មិនត្រូវបានគេគោរពអនុវត្តតាម ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ/និង ស្មៀនឃុំ សង្កាត់ និងមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវទទួលខុសត្រូវអនុវត្តតាមការណែនាំរបស់ក្រុមត្រួតពិនិត្យប្រសិទ្ធភាពការងារ ។

៨.២០.១.៣ ក្រុមត្រួតពិនិត្យប្រសិទ្ធភាពការងារត្រូវរាយការណ៍ផ្ទាល់ទៅ គជប ។

៨.២០.២ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវតាមដានក្តាប់ជាប់សភាពការណ៍រួម និងរាល់ហេតុការណ៍ដែលអាចកើតមានឡើង ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់នីមួយៗ ហើយត្រូវរាយការណ៍ជាប្រចាំ និងជាបន្ទាន់ អំពីករណីដែលត្រូវសុំយោបល់ណែនាំ ឬស្នើសុំការដោះស្រាយពី គជប ដើម្បី គជប មានវិធានការដោះស្រាយបានទាន់ពេលវេលា ។ ក្នុងនេះ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវយកចិត្តទុកដាក់បញ្ហាមួយចំនួន ដូចខាងក្រោម ៖

៨.២០.២.១ ស្ថានភាពនៃការប្រើប្រាស់សម្ភារៈឯកសារបំរើការចុះឈ្មោះបោះឆ្នោត ជាពិសេស ចំពោះឃុំ សង្កាត់ដែលជួបប្រទះការខ្វះសម្ភារៈឯកសារ ដែលនាំឱ្យរាំងស្ទះដល់ការចុះឈ្មោះបោះឆ្នោត ។

៨.២០.២.២ ស្ថានភាព និងរបាយការណ៍ស្តីពីការរំលោភច្បាប់ ការរំលោភបទបញ្ជា និងនីតិវិធីរបស់ គជប ទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ។

៩.២០.២.៣ ស្ថានភាព និងរបាយការណ៍ស្តីពីការគំរាមកំហែង អំពើល្មើសច្បាប់ និងការរំលោភបំពានផ្សេងទៀត ដែលអាចកើតមានក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.២០.២.៤ ភាពមិនប្រក្រតីនានាក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រសិនបើមាន ។

៩.២០.២.៥ សភាពការណ៍សន្តិសុខ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.២០.២.៦ សំណើសុំយោបល់ណែនាំឬ/និងសំណើសុំការដោះស្រាយផ្សេងៗ ។

៩.២០.៣ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវរាយការណ៍អំពីសភាពការណ៍រួម និងរាល់ហេតុការណ៍ដែលអាចកើតមានឡើង ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជូន គជប ឱ្យបានឆាប់រហ័ស ដោយប្រើបណ្តាញវិទ្យុទាក់ទងរវាង គជប ខេត្ត ក្រុង និងឃុំ សង្កាត់ ឬតាមរយៈមធ្យោបាយបញ្ជូនព័ត៌មានផ្សេងទៀត ។

៩.២០.៤ គជប ត្រូវធានាថា នៅពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត មន្ត្រីលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត ក្រុងបានសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការវាយតម្លៃចំពោះជំនួយការស្មៀន ។

៩.២០.៥ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណា ដែលជាប់សាច់ញាតិជាមួយនឹងជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការវាយតម្លៃចំពោះជំនួយការស្មៀននោះឡើយ ។

៩.២០.៦ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទទួលខុសត្រូវធ្វើកំណត់ហេតុសង្ខេបវាយតម្លៃជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោតម្នាក់ៗ ដោយផ្អែកលើការទទួលខុសត្រូវ និងភារកិច្ចរៀងខ្លួន ដូចបានកំណត់ក្នុងចំណុច ៩.៩.៣ នៃបទបញ្ជា និង នីតិវិធីរបស់ គជប និងផ្អែកលើកត្តាមួយចំនួនដូចខាងក្រោម ៖

៩.២០.៦.១ បានចូលរួមវគ្គបណ្តុះបណ្តាល ។

៩.២០.៦.២ បានឆ្លងកាត់ការធ្វើតេស្ត ពេលចប់វគ្គបណ្តុះបណ្តាល ។

៤.២០.៦.៣ មានវត្តមានជាប្រចាំក្នុងរយៈពេលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៤.២០.៦.៤ មានលទ្ធភាពក្នុងការបំពេញទម្រង់បែបបទ ។

៤.២០.៦.៥ មានសមត្ថភាពបំពេញការងារតាមការបង្គាប់របស់ស្មៀនឃុំ សង្កាត់ ។

៤.២០.៦.៦ មានសមត្ថភាពបំពេញការងារជាមន្ត្រីចុះឈ្មោះបោះឆ្នោត ។

៤.២០.៦.៧ មានលទ្ធភាពកត់ត្រា និងធ្វើតុល្យការលទ្ធផលការងារប្រចាំថ្ងៃ ។

៤.២០.៦.៨ មានគោលជំហរអព្យាក្រឹតក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៤.២០.៦.៩ មានចំណេះដឹងក្នុងការអនុវត្តបទបញ្ជា និងនីតិវិធីរបស់ គជប ។

៤.២០.៦.១០ មាន ឬគ្មានបណ្តឹងពីស្មៀនឃុំ សង្កាត់ ឬជំនួយការស្មៀនដទៃ ។

៤.២០.៦.១១ មាន ឬគ្មានបណ្តឹងពីប្រជាពលរដ្ឋ ។

៤.២០.៦.១២ អាកប្បកិរិយាជាមន្ត្រីចុះឈ្មោះបោះឆ្នោត និង រូបភាពស្តែងឡើងជាទូទៅ ។

៤.២០.៦.១៣ យោបល់របស់ក្រុមត្រួតពិនិត្យប្រសិទ្ធភាពការងារនៃ គជប ចំពោះជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោតណាម្នាក់ ប្រសិនបើមាន ។

៤.២០.៧ ផ្អែកតាមការវាយតម្លៃខាងលើ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា លទ្ធផលនៃការវាយតម្លៃជាវិជ្ជមាន ឬអវិជ្ជមានសម្រាប់ជំនួយការស្មៀន ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត គឺជាកត្តាកំណត់លក្ខណសម្បត្តិរបស់សាមីខ្លួនម្នាក់ៗ ។ ក្នុងនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវ ៖

៤.២០.៧.១ ចុះហត្ថលេខាលើកំណត់ហេតុវាយតម្លៃដូចចែងក្នុងប្រការ ៤.២០.៦ ខាងលើ ដោយមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលដឹកនាំការប្រជុំវាយតម្លៃនោះ ។

៤.២០.៧.២ ផ្ញើកំណត់ហេតុវាយតម្លៃជំនួយការស្មៀនមួយច្បាប់ ជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៤.២០.៧.៣ រក្សាទុកជាឯកសារមួយច្បាប់ ។

**ការដាក់ពាក្យបណ្តឹងតវ៉ា និងការបើកសវនាការរបស់ គជប ដោះស្រាយលើបណ្តឹងតវ៉ានឹងសេចក្តីសំរេចបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**

**ប្រការ ៤.២១** អ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតដែលត្រូវបានក្រុមប្រឹក្សាឃុំសង្កាត់ប្រជុំសម្រេចជាសាធារណៈបដិសេធលើបណ្តឹងតវ៉ា ដូចចែងក្នុងចំណុច ៤.១៦.៨ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅនឹង

សេចក្តីសំរេចបដិសេធនោះទៅ គជប ក្នុងរយៈពេលយ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ។

៨.២១.១ អ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ឬតំណាង ដែលមានបំណងប្តឹងតវ៉ាទៅនឹងសេចក្តីសំរេចបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញពាក្យបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០២ ) ចំនួនពីរ(២)ច្បាប់ រួចដាក់ពាក្យបណ្តឹងនេះនៅ គជប ( ការិយាល័យទទួលនិងដោះស្រាយបណ្តឹង នៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ) ។

៨.២១.២ អ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំសំរេចជាសាធារណៈបដិសេធលើបណ្តឹងតវ៉ារបស់គាត់ និង បានទទួលទម្រង់បែបបទសម្រាប់ប្តឹងតវ៉ារួចហើយ ដូចចែងក្នុងចំណុច ៨.១៦.៨ ខាងលើ ប៉ុន្តែមិនបានមកដាក់ពាក្យបណ្តឹងតវ៉ានៅ គជប តាមពេលវេលាកំណត់ ដូចចែងក្នុងប្រការ ៨.២១ ខាងលើ ត្រូវបានចាត់ទុកថា មិនប្តឹងតវ៉ា ។

៨.២១.៣ ប្រសិនបើ អ្នកប្តឹងតវ៉ា ឬតំណាងបានមកដាក់ពាក្យបណ្តឹងរបស់ខ្លួន ប៉ុន្តែមិនទាន់ពេលវេលា តាមការកំណត់ដូចបានបញ្ជាក់ក្នុងប្រការ ៨.២១ ខាងលើ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ដែលបានប្រគល់សិទ្ធិ ត្រូវសរសេរលើពាក្យបណ្តឹងគ្រប់ច្បាប់ថា « ពាក្យបណ្តឹងបានទទួលក្រោយថ្ងៃកំណត់នៅថ្ងៃទី ( កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង ) » ។ បន្ទាប់មក ត្រូវប្រគល់ត្រឡប់ទៅអ្នកប្តឹងតវ៉ា ឬតំណាងវិញនូវពាក្យបណ្តឹងតវ៉ាមួយច្បាប់ ហើយត្រូវរក្សាទុកមួយច្បាប់ជាឯកសារនៅនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គជប ។

៨.២១.៤ បន្ទាប់ពីការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតបានចាប់ផ្តើមដំណើរការ គជប ត្រូវធានាថា រាល់បណ្តឹងតវ៉ានឹងសេចក្តីសំរេចបដិសេធលើបណ្តឹងតវ៉ា របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបាន គជប បើកសវនាការសម្រេច ក្នុងអំឡុងពេលយ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ាទាំងនោះ ។

៨.២១.៤.១ ដើម្បីបង្កលក្ខណសម្បត្តិសម្រាប់ការបើកសវនាការរបស់ គជប ក្នុងការដោះស្រាយលើបណ្តឹងតវ៉ា នាយកដ្ឋានសេវាកម្មច្បាប់ត្រូវប្រមូលផ្តុំរាល់ទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត របស់ស្មៀន និងសេចក្តីសំរេចបដិសេធលើពាក្យបណ្តឹងតវ៉ា របស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ហើយដែលត្រូវបានផ្ញើជូន គជប ដោយទ្បែកគ្គី ឬ តាមការបញ្ជូនកញ្ចប់ " ខ " និងកញ្ចប់ " គ " ក្តី ។

៩.២១.៤.២ នៅពេលទទួលពាក្យបណ្តឹងតវ៉ា មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និង វិវាទកម្មដែលបានប្រគល់សិទ្ធិ ត្រូវបំពេញលើពាក្យបណ្តឹងតវ៉ាទាំងពីរ (២)ច្បាប់ នូវពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង រួចប្រគល់ជូនអ្នកប្តឹងតវ៉ាឬតំណាងមួយច្បាប់ និងត្រូវជំរាបគាត់ថា ពេលវេលា កាលបរិច្ឆេទ និង ទីកន្លែងដែលនឹងត្រូវបើកសវនាការ ដោះស្រាយបណ្តឹងតវ៉ា នឹងជូនដំណឹងជាក្រោយក្នុងរយៈពេលយ៉ាង តិចពីរ(២)ថ្ងៃ មុនថ្ងៃបើកសវនាការ ។

៩.២១.៤.៣ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ដែលបានប្រគល់សិទ្ធិ ត្រូវថតចម្លង ពាក្យបណ្តឹងតវ៉ាដែលបានទទួលនោះចំនួនបី(៣)ច្បាប់បន្ថែម ដែល ក្នុងនោះ ត្រូវរក្សាទុកច្បាប់ចម្លងមួយច្បាប់ជាឯកសារនៅនាយកដ្ឋាន សេវាកម្មច្បាប់ បិទផ្សាយជាសេចក្តីជូនដំណឹងមួយច្បាប់ និងត្រៀម ពាក្យបណ្តឹងពីរច្បាប់ទៀត សម្រាប់ត្រៀមប្រើប្រាស់ ក្នុងសវនាការ របស់ គជប ។

៩.២១.៥ លក្ខណៈវិនិច្ឆ័យដែល គជប ត្រូវប្រកាន់យកជាមូលដ្ឋានសម្រាប់ធ្វើការសំរេចលើ បណ្តឹងតវ៉ាទៅនឹងសេចក្តីសំរេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត គឺមានលក្ខណៈ ដូចគ្នានឹងលក្ខណៈវិនិច្ឆ័យមានសិទ្ធិចុះឈ្មោះបោះឆ្នោត និងមូលហេតុសម្រាប់ការ បដិសេធការចុះឈ្មោះបោះឆ្នោត ដែលបានចែងក្នុងច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៩.២១.៦ ក្នុងពេលបើកសវនាការជាសាធារណៈរបស់ គជប អ្នកប្តឹងតវ៉ា ឬ តំណាងមាន សិទ្ធិបង្ហាញភស្តុតាងជាឯកសារផ្សេងៗ ប្រសិនបើមាន ដែលបញ្ជាក់អំពីភាពមាន សិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកប្តឹងតវ៉ាសុំចុះឈ្មោះស្របតាមច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៩.២១.៧ ក្នុងករណី គជប សម្រេចបដិសេធលើបណ្តឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃ អង្គសវនាការ ត្រូវ ៖

៩.២១.៧.១ ចារបដិសេធ ចុះហត្ថលេខា និងកាលបរិច្ឆេទលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាងមួយច្បាប់ និងរក្សាទុកជាឯកសារ មួយច្បាប់ ។

៤.២១.៧.២ ចាត់ចែងឱ្យបំពេញសេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបី(៣)ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុ នៃការបដិសេធនោះផង ។

៤.២១.៧.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប លើសេចក្ដីសម្រេចដែលបានបំពេញ រួចប្រគល់ឱ្យអ្នកប្ដឹងតវ៉ា ឬតំណាងមួយច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញមួយច្បាប់ និង រក្សាទុកជាឯកសារមួយច្បាប់ ។

៤.២១.៧.៤ ប្រគល់ឱ្យអ្នកប្ដឹងតវ៉ា ឬតំណាង នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ តាមសំណើសុំ សម្រាប់បំពេញពាក្យបណ្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ារបស់ គជប ទៅក្រុមប្រឹក្សាធម្មនុញ្ញ និងជម្រាបគាត់ថា គាត់មានសិទ្ធិប្ដឹងតវ៉ា អំពីករណីនេះ ទៅក្រុមប្រឹក្សាធម្មនុញ្ញ យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ា ។

៤.២១.៨ ក្នុងករណី គជប សម្រេចយល់ព្រមលើបណ្ដឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

៤.២១.៨.១ ចារយល់ព្រម ចុះហត្ថលេខា និងកាលបរិច្ឆេទលើបណ្ដឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្ដឹងតវ៉ា ឬ តំណាងមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៤.២១.៨.២ ចាត់ចែងឱ្យបំពេញសេចក្ដីសម្រេចយល់ព្រមលើបណ្ដឹងតវ៉ា (ទម្រង់បែបបទលេខ ១២០៣ ) ជាបី (០៣)ច្បាប់ ។

៤.២១.៨.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប លើសេចក្ដីសំរេចដែលបានបំពេញ រួចប្រគល់ឱ្យអ្នកប្ដឹងតវ៉ា ឬតំណាងមួយច្បាប់ រក្សាទុកជាឯកសារមួយច្បាប់ និង

៤.២១.៨.៤ ផ្ញើជូនឬ/និងជូនដំណឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់នូវសេចក្ដីសម្រេចយល់ព្រមលើបណ្ដឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) មួយច្បាប់ ដើម្បីណែនាំឱ្យស្មៀនឃុំ សង្កាត់ចុះឈ្មោះអ្នកសុំចុះឈ្មោះដែលស្មៀនបានបដិសេធពីមុននោះ តាមនីតិវិធី សម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចចែងក្នុងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៤.២១.៩ ផ្អែកតាមសេចក្តីសម្រេចសវនាការរបស់ គជប យល់ព្រមតាមពាក្យបណ្តឹងតវ៉ា ដូចចែងក្រោមចំណុច ៤.២១.៨ ខាងលើ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវណែនាំ ស្មៀនឃុំ សង្កាត់ឱ្យចុះឈ្មោះបោះឆ្នោត ជូនអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ។ ស្មៀនឃុំ សង្កាត់ ត្រូវ ៖

៤.២១.៩.១ ណាត់ជាមួយអ្នកប្តឹងតវ៉ាសុំចុះឈ្មោះជាមុន អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលា ដើម្បីទៅចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាមសេចក្តីសំរេចសវនាការរបស់ គជប ។

៤.២១.៩.២ បំពេញឈ្មោះអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត និងទិន្នន័យពាក់ព័ន្ធលើទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ នៅផ្នែកទាំងពីរ ដូចចែងក្នុងជំហានទី៦ ក្នុងប្រការ ៤.១១ ខាងលើ ។

៤.២១.៩.៣ ហែកផ្នែកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត រួចប្រគល់ជូនអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត និងរំលឹកគាត់អំពីលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដែលមាននៅក្នុងបង្កាន់ដៃស្រាប់ ។

៤.២១.៩.៤ សរសេរបំពេញឈ្មោះនិងទិន្នន័យនៃអ្នកប្តឹងតវ៉ាសុំចុះឈ្មោះ នៅក្នុងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយយោងតាមគល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ។

៤.២១.៩.៥ រក្សាទុកសេចក្តីសម្រេចរបស់ គជប យល់ព្រមលើបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) ដូចចែងក្នុងចំណុច ៤.២១.៨.៤ ជាឯកសាររបស់ឃុំ សង្កាត់ ។

៤.២១.១០ គជប ត្រូវធានាថា រាល់សេចក្តីសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ដូចចែងក្រោមចំណុច ៤.២១.៨ ខាងលើ ត្រូវតែបានជូនដំណឹងតាមរយៈទូរសារ ឬវិទ្យុទាក់ទង ហើយត្រូវផ្ញើច្បាប់ដើមនៃសេចក្តីសំរេចនេះ ដោយអមជាមួយនូវទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ មួយសន្លឹក ជូនក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបាន ។

៤.២១.១១ ស្មៀនឃុំ សង្កាត់ ត្រូវធានាថា គល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដូចបានចែងក្នុងចំណុច ៤.២១.៩.២ និងបញ្ជីបោះឆ្នោតបន្ថែម ដូចចែងក្នុងចំណុច ៤.២១.៩.៤ ខាងលើ ត្រូវតែបានផ្ញើជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

**ការដាក់ពាក្យបណ្តឹងតវ៉ានឹងសេចក្តីសំរេចបដិសេធរបស់ គជប និងសវនាការជាសាធារណៈរបស់ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយបណ្តឹងតវ៉ា**

**ប្រការ ៤.២២** អ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ដែលត្រូវបានសវនាការរបស់ គជប សម្រេចបដិសេធលើបណ្តឹងតវ៉ា ដូចចែងក្នុងចំណុច ៤.២១.៧ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅនឹងសេចក្តីសំរេចបដិសេធនោះទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរប្រាំ ( ៥ ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ។

៤.២២.១ អ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ឬ តំណាង ដែលមានចំណាងប្តឹងតវ៉ាទៅនឹងសេចក្តីសំរេចបដិសេធរបស់ គជប ត្រូវបំពេញពាក្យបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០២ ) ចំនួនពីរ(២)ច្បាប់ រួចដាក់ពាក្យបណ្តឹងនេះ នៅក្រុមប្រឹក្សាធម្មនុញ្ញ ។

៤.២២.២ អ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ដែលត្រូវបានសវនាការរបស់ គជប សម្រេចបដិសេធលើបណ្តឹងតវ៉ារបស់គាត់ និងបានទទួលទម្រង់បែបបទសម្រាប់ប្តឹងតវ៉ារួចហើយ ដូចចែងក្នុងចំណុច ៤.២១.៧ ខាងលើ ប៉ុន្តែមិនបានមកដាក់ពាក្យប្តឹងតវ៉ានៅក្រុមប្រឹក្សាធម្មនុញ្ញ តាមពេលវេលាកំណត់ ដូចចែងក្នុងប្រការ ៤.២២ ខាងលើ ត្រូវបានចាត់ទុកថា មិនប្តឹងតវ៉ា ។

៤.២២.៣ បន្ទាប់ពីការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតបានចាប់ផ្តើមដំណើរការ ក្រុមប្រឹក្សាធម្មនុញ្ញនឹងដោះស្រាយរាល់បណ្តឹងតវ៉ានឹងសេចក្តីសំរេចរបស់ គជប ដែលបានបដិសេធលើបណ្តឹងតវ៉ា ដោយបើកសវនាការជាសាធារណៈសម្រេចក្នុងអំឡុងពេលយ៉ាងយូរដប់ ( ១០ ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ាទាំងនោះ អនុលោមតាមមាត្រា ៦២ថ្មី នៃច្បាប់បោះឆ្នោត ។

៤.២២.៤ ក្នុងពេលបើកសវនាការជាសាធារណៈរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អ្នកប្តឹងតវ៉ា ឬ តំណាងមានសិទ្ធិបង្ហាញភស្តុតាងជាឯកសារផ្សេងៗ ប្រសិនបើមាន ដែលបញ្ជាក់អំពីភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកប្តឹងតវ៉ាសុំចុះឈ្មោះ ស្របតាមច្បាប់និងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៤.២២.៥ ក្រុមប្រឹក្សាធម្មនុញ្ញអនុវត្តការទទួលពាក្យបណ្តឹងតវ៉ា និងការដោះស្រាយបណ្តឹងតវ៉ាក្រោមនីតិវិធីរបស់ខ្លួន រួចជូនដំណឹងទៅ គជប អំពីសេចក្តីសំរេចរបស់ខ្លួន ។

៩.២២.៦ ក្នុងករណី ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធលើបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញនឹង ៖

៩.២២.៦.១ ចេញសេចក្តីសម្រេចបដិសេធបណ្តឹងតវ៉ា ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះ និងបញ្ជាក់ថា សេចក្តីសំរេចនេះជាសេចក្តីសំរេចចុងក្រោយ ។

៩.២២.៦.២ ប្រគល់ ឬ ផ្ញើសេចក្តីសម្រេចបដិសេធបណ្តឹងតវ៉ា ជូនអ្នកប្តឹងតវ៉ា ឬតំណាងមួយច្បាប់ ។

៩.២២.៦.៣ ផ្ញើសេចក្តីសម្រេចបដិសេធបណ្តឹងតវ៉ាជូន គជប មួយច្បាប់ ។

៩.២២.៧ ក្នុងករណី ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញនឹង ៖

៦.២២.៧.១ ចេញសេចក្តីសម្រេចយល់ព្រមតាមបណ្តឹងតវ៉ា អនុញ្ញាតឱ្យចុះឈ្មោះបោះឆ្នោតជូនអ្នកប្តឹងតវ៉ាសុំចុះឈ្មោះ ។

៦.២២.៧.២ ប្រគល់ ឬផ្ញើសេចក្តីសម្រេចយល់ព្រមបណ្តឹងតវ៉ា ជូនអ្នកប្តឹងតវ៉ា ឬតំណាងមួយច្បាប់ ។

៦.២២.៧.៣ ផ្ញើសេចក្តីសម្រេចយល់ព្រមតាមបណ្តឹងតវ៉ាជូន គជប មួយច្បាប់ ។

៩.២២.៨ ផ្អែកតាមសេចក្តីសម្រេចសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ យល់ព្រមតាមពាក្យបណ្តឹងតវ៉ា ដូចចែងក្រោមចំណុច ៩.២២.៧ ខាងលើ គជប ត្រូវណែនាំទៅក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបង្គាប់ស្មៀនឃុំ សង្កាត់ឱ្យចុះឈ្មោះបោះឆ្នោត ជូនអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត ។ ស្មៀនឃុំ សង្កាត់ ត្រូវ ៖

៩.២២.៨.១ ណាត់ជាមួយអ្នកប្តឹងតវ៉ាសុំចុះឈ្មោះជាមុន អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលា ដើម្បីទៅចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាមសេចក្តីសំរេចសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

៩.២២.៨.២ បំពេញឈ្មោះអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត និងទិន្នន័យពាក់ព័ន្ធលើទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះនៅផ្នែកទាំងពីរដូចចែងក្នុងជំហានទី៦ ក្នុងប្រការ ៩.១១ ខាងលើ ។

៩.២២.៨.៣ ហែកផ្នែកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត រួចប្រគល់ជូនអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត និងរំលឹកគាត់អំពីលេខនិងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដែលមាននៅក្នុងបង្កាន់ដៃស្រាប់ ។

៩.២២.៨.៤ សរសេរបំពេញឈ្មោះនិងទិន្នន័យនៃអ្នកប្ដឹងតវ៉ាសុំចុះឈ្មោះ នៅក្នុងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយយោងតាមគល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ។

៩.២២.៨.៥ រក្សាទុកសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលបានយល់ព្រមលើបណ្ដឹងតវ៉ា ជាឯកសាររបស់ឃុំ សង្កាត់ ។

៩.២២.៩ គជប ត្រូវធានាថា រាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ដូចចែងក្នុងចំណុច ៩.២២.៧ ខាងលើ ត្រូវតែបានជូនដំណឹងតាមរយៈទូរសារ ឬវិទ្យុទាក់ទង ហើយត្រូវផ្ញើច្បាប់ដើមនៃសេចក្ដីសំរេចនេះ ដោយអមជាមួយនូវទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះមួយសន្លឹក ជូនក្រុមប្រឹក្សា / ស្មៀនឃុំ សង្កាត់ តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឱ្យបានឆាប់រហ័សតាម ដែលអាចធ្វើបាន ។

៩.២២.៩.១ បន្ទាប់ពីបានចុះឈ្មោះអ្នកប្ដឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោត យោងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញរួចហើយ គជប ត្រូវផ្ញើបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដែលបានកែប្រែហើយមួយច្បាប់ ជូនក្រុមប្រឹក្សាធម្មនុញ្ញ ។

៩.២២.១០ ស្មៀនឃុំ សង្កាត់ ត្រូវធានាថា គល់សន្លឹកទម្រង់បែបបទចុះឈ្មោះបោះឆ្នោត / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដូចបានចែងក្នុងចំណុច ៩.២២.៨.២ និងបញ្ជីបោះឆ្នោតបន្ថែម ដូចចែងក្នុងចំណុច ៩.២២.៨.៤ ខាងលើ ត្រូវតែបានផ្ញើជាបន្ទាន់ជូន គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

**ការត្រួតពិនិត្យ និងការវេចខ្ចប់កញ្ចប់ " ខ " នៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ដើម្បីបញ្ជូនទៅមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប**

**ប្រការ ៩.២៣** នៅក្នុងការប្រគល់/ទទួលកញ្ចប់ " ខ " ពីស្មៀនឃុំ សង្កាត់ ដូចចែងក្នុងចំណុច ៩.១៩.១០ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវត្រួតពិនិត្យថា កញ្ចប់ " ខ " ទាំងឡាយមិនត្រូវបានគេរុះរើឡើយ ។ នៅចំពោះមុខស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវត្រួតពិនិត្យឱ្យប្រាកដថា កញ្ចប់ " ខ " នីមួយៗមានផ្ទុកកញ្ចប់

" ក " ឬ/និងកញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ/និង ស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតគ្រប់ចំនួន ។ បន្ទាប់មក មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចាត់ចែងវេចខ្ចប់កញ្ចប់ " ខ " ឡើងវិញ តាមលំនាំដដែល ដូច ដែលស្មៀនឃុំ សង្កាត់បានធ្វើនៅឃុំ សង្កាត់ រួចត្រូវវេចខ្ចប់កញ្ចប់ " ខ " ដាក់ទៅក្នុងកញ្ចប់ " គ " ដើម្បីបញ្ជូន និងប្រគល់ទៅឱ្យមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ។

៤.២៣.១ ក្នុងការត្រួតពិនិត្យ ប្រសិនបើ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត មិនឃើញមានកញ្ចប់ " ខ " ណាមួយត្រូវបានគេរុះរើទេ ត្រូវបន្តការត្រួតពិនិត្យ ដោយការបើកកញ្ចប់ " ខ " ម្តងមួយៗ ដើម្បីផ្ទៀងផ្ទាត់ចំនួនកញ្ចប់ " ក " ឬ/និងកញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ/និង ស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀត ដែលមានក្នុងកញ្ចប់ " ខ " នោះ ។

៤.២៣.២ មន្ត្រីលេខាធិការដ្ឋានខេត្តក្រុងរៀបចំការបោះឆ្នោតត្រូវបើកកញ្ចប់ " ខ " ម្តងមួយៗ រហូតដល់អស់កញ្ចប់ " ខ " នៃឃុំ សង្កាត់ពាក់ព័ន្ធដើម្បីផ្ទៀងផ្ទាត់កញ្ចប់ " ក " ឬ/និង កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ/និង ស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀត ដែលមាននៅខាងក្នុង យ៉ាងម៉ត់ចត់ ដោយផ្អែកលើលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ដែលដាក់ក្នុងហោប៉ៅក្រៅនៃកញ្ចប់ " ខ " ។ ប្រសិនបើគ្មានកញ្ចប់ " ក " ឬ/និងកញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃ បញ្ជាក់ការចុះឈ្មោះបោះឆ្នោតណាមួយត្រូវបានគេរុះរើទេ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវ ៖

៤.២៣.២.១ គ្រាន់តែពិនិត្យ និងរាប់ចំនួនកញ្ចប់ " ក " ឬ/និងកញ្ចប់ដាក់ទម្រង់ បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ ស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងៗទៀតប៉ុណ្ណោះ ដោយមិន ចាំបាច់បើកកញ្ចប់ " ក " ឬ កញ្ចប់សម្ភារៈឯកសារទាំងនោះ ដើម្បី ធ្វើការផ្ទៀងផ្ទាត់ឡើងវិញទេ ។

៤.២៣.២.២ ដកយករបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ បោះឆ្នោតមួយច្បាប់ក្នុងចំណោមពីរច្បាប់ ដែលមានកិបភ្ជាប់នៅនឹង ផ្នែកខាងក្រៅនៃកញ្ចប់ " ក " ដើម្បីប្រើសម្រាប់ផ្ទៀងផ្ទាត់ និងចង ក្រង ទុកជាឯកសារ ។

៩.២៣.២.៣ ដកយកលិខិតបញ្ជាក់ការវេចខ្ចប់និងការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ដែលមានក្នុងស្រោមសំបុត្រ ក្នុងកញ្ចប់ " ខ " ពីរ(២)ច្បាប់ មានក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " មួយ(១)ច្បាប់ និងយកមួយច្បាប់ទៀតពីស្មៀនឃុំ សង្កាត់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ហើយប្រគល់មួយ(១)ច្បាប់ជូនស្មៀនឃុំ សង្កាត់វិញ ដើម្បីបញ្ជាក់ថាបានទទួលមែន ។

៩.២៣.២.៤ រៀបចំដាក់កញ្ចប់ " ក " ឬ/និងកញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ ស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតទៅក្នុងកញ្ចប់ " ខ " ដដែលវិញ រួចច្រកលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) មួយ(១)ច្បាប់ ក្នុងស្រោមសំបុត្រដាក់ទៅក្នុងកញ្ចប់ " ខ " និងដាក់មួយ(១)ច្បាប់ទៀតទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " ។

៩.២៣.២.៥ ចងភ្ជិតកញ្ចប់ " ខ " រួចរក្សាទុកម្តុំនៅកន្លែងមានសុវត្ថិភាពសម្រាប់ត្រៀមវេចខ្ចប់ក្នុងកញ្ចប់ " គ " ដើម្បីបញ្ជូនទៅ គជប ។

៩.២៣.៣ ក្នុងការត្រួតពិនិត្យ ប្រសិនបើ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត រកឃើញថា មានកញ្ចប់ " ខ " ណាមួយត្រូវបានគេរុះរើ ស្មៀនឃុំ សង្កាត់ ដែលបានបញ្ជូន និងប្រគល់កញ្ចប់ " ខ " ពាក់ព័ន្ធ នឹងត្រូវបានស្នើឱ្យបកស្រាយបំភ្លឺករណីនេះ ។

៩.២៣.៤ ប្រសិនបើ ក្នុងការត្រួតពិនិត្យដូចចែងក្នុងចំណុច ៩.២៣.២ ខាងលើ មានភស្តុតាងបញ្ជាក់ថា មានកញ្ចប់ " ក " ណាមួយ ឬកញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃចុះឈ្មោះបោះឆ្នោត នៅក្នុងកញ្ចប់ " ខ " ត្រូវបានគេរុះរើ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវ ៖

៩.២៣.៤.១ បើកកញ្ចប់ " ក " ដែលមានការរុះរើនោះ និងផ្ទៀងផ្ទាត់សម្ភារៈឯកសារមាននៅខាងក្នុងយ៉ាងម៉ត់ចត់ ទៅនឹងរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត ( ទម្រង់បែបបទលេខ ១០១១ ) ដែលមាននៅខាងក្នុងកញ្ចប់ " ក " និងមានកិបភ្ជាប់នៅផ្នែកខាងក្រៅនៃកញ្ចប់ " ក " ។

៤.២៣.៤.២ ដកយករបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមួយច្បាប់ក្នុងចំណោមពីរច្បាប់ ដែលមានកិបភ្ជាប់នៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ " ក " ដើម្បីប្រើសម្រាប់ចងក្រងទុកជាឯកសារ ។

៤.២៣.៤.៣ ឱ្យស្មៀនឃុំ សង្កាត់ ដែលបានបញ្ជូន និងប្រគល់កញ្ចប់ " ខ " ធ្វើការស្រាយបំភ្លឺ ក្នុងករណីដែលបានរកឃើញថា មានភាពមិនត្រឹមត្រូវ ។

៤.២៣.៤.៤ តែងតាំងក្រុមស្រាវជ្រាវមួយដែលមានសមាសភាពពីរ ( ២ ) នាក់ជាបន្ទាន់ ដើម្បីសហការជាមួយស្មៀនឃុំ សង្កាត់ពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវរាល់សម្ភារៈឯកសារដែលមានក្នុងកញ្ចប់ " ក " ទៅនឹងរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត ( ទម្រង់បែបបទលេខ ១០១១ ) ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងឯកសារពាក់ព័ន្ធផ្សេងទៀត ។

៤.២៣.៤.៥ ធ្វើរបាយការណ៍លំអិតអំពីភស្តុតាងនៃអំពើល្មើស និងលទ្ធផលនៃការរកឃើញជូន គជប ជាបន្ទាន់ ក្នុងករណីដែលក្រុមស្រាវជ្រាវនៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត បានរកឃើញថាមានការក្លែងបន្លំក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ។

៤.២៣.៤.៦ វេចខ្ចប់កញ្ចប់ " ក " ដែលមានបញ្ហាឡើងវិញ រួចបន្តពិនិត្យកញ្ចប់ " ក " ដទៃទៀត ដោយអនុវត្តតាមនីតិវិធីដូចចែងចាប់ពីចំណុច ៤.២៣.២.១ ដល់ ៤.២៣.២.៥ ខាងលើ ។

៤.២៣.៤.៧ ក្នុងពេលអនុវត្តចំណុច ៤.២៣.២.៣ ខាងលើ ត្រូវសរសេរបន្ថែមនូវមូលវិចារអំពីកញ្ចប់ " ក " ដែលត្រូវរុះរើ និងកត់ត្រាលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ លើលិខិតបញ្ជាក់ការវេចខ្ចប់និងបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) គ្រប់ច្បាប់ ។

៤.២៣.៥ គជប ត្រូវមានវិធានការផ្តន្ទាទោសចំពោះជនល្មើស ដោយផ្អែកលើរបាយការណ៍និងភស្តុតាង ដែលមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតបានបញ្ជូនមក ដូចចែងក្នុងចំណុច ៤.២៣.៤.៥ ខាងលើ ។

៤.២៣.៦ បន្ទាប់ពីកញ្ចប់ " ខ " ទាំងអស់ត្រូវបានបើកត្រួតពិនិត្យសម្ភារៈឯកសារខាងក្នុងត្រឹមត្រូវរួចហើយ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវធានាថា៖

៤.២៣.៦.១ សំណៅនៃរបាយការណ៍លទ្ធផល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត ( ទម្រង់បែបបទលេខ ១០១១ ) មួយច្បាប់ត្រូវបានកិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ " ក " នៅមុនពេលវេចខ្ចប់កញ្ចប់ " ខ " ឡើងវិញ និងមួយច្បាប់ត្រូវបានចងក្រងទុកជាឯកសារ ។

៤.២៣.៦.២ សំណៅនៃលិខិតបញ្ជាក់ការវេចខ្ចប់ និង ការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ដែលបានចុះហត្ថលេខា កាលបរិច្ឆេទ និង បោះត្រារួចហើយមួយច្បាប់ ត្រូវបានចងក្រងទុកជាឯកសារ ។

៤.២៣.៦.៣ កញ្ចប់ " ក " ឬ/និង កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬ/និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀត ត្រូវបានដាក់ទៅក្នុងកញ្ចប់ " ខ " ដដែលវិញ រួចច្រកលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) មួយច្បាប់ ក្នុងស្រោមសំបុត្រដាក់ទៅក្នុងកញ្ចប់ " ខ " និងដាក់មួយច្បាប់ទៀត ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " ។

៤.២៣.៦.៤ កញ្ចប់ " ខ " ដែលបានវេចខ្ចប់រួចហើយ ដូចចែងក្នុងចំណុច ៤.២៣.៦.៣ ខាងលើ ត្រូវបានចងភ្ជិតជាថ្មី ត្រៀមសម្រាប់ការវេចខ្ចប់ដាក់ក្នុងកញ្ចប់ " គ " ដើម្បីបញ្ជូនទៅ គជប ។

៤.២៣.៧ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវរៀបចំគំរោងផែនការទទួលត្រួតពិនិត្យវេចខ្ចប់ និងបញ្ជូនសម្ភារៈឯកសារនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតទៅ គជប ដែលអាចនឹងត្រូវអនុវត្ត នៅចន្លោះរយៈពេលបួនថ្ងៃ ទៅដប់ពីរថ្ងៃ ក្រោយថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ។ ដោយឡែក នៅគ្រប់ពេលនៃការចុះទៅទទួលយកសម្ភារៈឯកសារខាងលើ នៅតាមឃុំ សង្កាត់ ប្រសិនបើមាន ត្រូវចាត់ឱ្យមានមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត យ៉ាងតិចពីរ(២)រូប និងមន្ត្រីសន្តិសុខចូលរួមដំណើរផង ។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ប្រចាំខេត្ត ក្រុងពាក់ព័ន្ធ ក៏អាចចូលរួមបានដែរ ។

៤.២៣.៨ នៅពេលបានទទួល ត្រួតពិនិត្យ និងវេចខ្ចប់កញ្ចប់ " ខ " ឡើងវិញរួចហើយ មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់ " ខ " ដោយដាក់ក្នុងកញ្ចប់ " គ " សម្រាប់បញ្ជូន និងប្រគល់ទៅមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ឱ្យឆាប់បំផុត តាមដែលអាចធ្វើបាន ។

៤.២៣.៨.១ រាល់ការបញ្ជូននិងការប្រគល់កញ្ចប់ " គ " ត្រូវធ្វើឡើងដោយមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត យ៉ាងតិចណាស់ពីរ (២)រូបនិងអមដំណើរដោយមន្ត្រីសន្តិសុខផង ។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក៏អាចចូលរួមបានដែរ ។

៤.២៣.៩ នៅមួយថ្ងៃ មុនថ្ងៃបញ្ជូន និងប្រគល់កញ្ចប់ " គ " ទៅមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវ ៖

៤.២៣.៩.១ ច្រកកញ្ចប់ " ខ " ទាំងអស់ដែលបានចងភ្ជិតរួចហើយ ដូចចែងក្នុងចំណុច ៤.២៣.៦.៤ ខាងលើបញ្ចូលទៅក្នុងកញ្ចប់ " គ " តាមចំនួនដែលត្រូវការចាំបាច់ ដើម្បីដាក់ឱ្យអស់កញ្ចប់ " ខ " ។

៤.២៣.៩.២ បំពេញ ព្រមទាំងចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ខ " ( ទម្រង់បែបបទលេខ ១០១៤ ) ដោយមានបញ្ជាក់ច្បាស់ចំនួនកញ្ចប់ " ខ " និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងៗ ដែលបានផ្ទុកក្នុងកញ្ចប់ " គ " នីមួយៗ ។ ត្រូវបំពេញទម្រង់បែបបទនេះបី( ៣ )ច្បាប់សម្រាប់កញ្ចប់ " គ " មួយ ។

៤.២៣.៩.៣ ច្រកសំណៅនៃលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ខ " ( ទម្រង់បែបបទលេខ ១០១៤ ) មួយច្បាប់ក្នុងស្រោមសំបុត្ររួចដាក់ទៅក្នុងកញ្ចប់ " គ " ហើយដាក់លិខិតបញ្ជាក់នេះមួយច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " គ " និងប្រគល់មួយច្បាប់ឱ្យមន្ត្រីទទួលបន្ទុកការបញ្ជូន សម្រាប់ប្រើនៅពេលប្រគល់/ទទួល នៅមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ។

៤.២៣.៩.៤ ដាក់រាល់ស្រោមសំបុត្រ ដែលមានលិខិតបញ្ជាក់សុពលភាព នៃការប្រើប្រាស់សម្ភារៈឯកសារចុះឈ្មោះបោះឆ្នោតបំរុង ដែលបានផ្គត់ផ្គង់បន្ថែម ( ទម្រង់លេខ ១០១៥ ) ដែលត្រូវធ្វើជូនមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ។

៤.២៣.៩.៥ រូតខ្សែចងភ្ជិតកញ្ចប់ " គ " រួចត្រូវបំពេញលេខកូដខេត្ត ក្រុង នៅក្នុងប្រឡោះដែលបោះពុម្ពស្រាប់ នៅផ្នែកខាងលើហោប៉ៅខាងក្រៅនៃកញ្ចប់ " គ " នីមួយៗ ។

៤.២៣.១០ ទន្ទឹមនឹងការបញ្ជូននិងប្រគល់កញ្ចប់ " គ " ខាងលើនេះ ទៅមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប មន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវគួបផ្សំបញ្ជូនទៅជាមួយនូវរាល់សម្ភារៈឧបករណ៍ និងឯកសារបំរើការចុះឈ្មោះផ្សេងទៀតដែលតម្រូវឱ្យប្រគល់មក គជប វិញ ។ សម្ភារៈឧបករណ៍នៅសល់ ត្រូវប្រគល់ទទួលនៅឃ្លាំងរបស់ គជប ។

៤.២៣.១១ នៅរាល់ពេលនៃការប្រគល់ទទួលកញ្ចប់ " គ " នៅ គជប មន្ត្រីទទួលបន្ទុកការបញ្ជូននៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវធានាថា មន្ត្រីទទួលឯកសារនៃមជ្ឈមណ្ឌលកុំព្យូទ័ររបស់ គជប បានចុះហត្ថលេខាលើសំណៅទាំងបី(៣)ច្បាប់នៃលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ខ " ( ទម្រង់បែបបទលេខ ១០១៤ ) ដូចចែងក្នុងចំណុច ៤.២៣.៩.៣ ខាងលើ រួចប្រគល់ឱ្យមន្ត្រីទទួលបន្ទុកការបញ្ជូន នៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតវិញមួយច្បាប់ ដើម្បីបញ្ជាក់ថា បានទទួលគ្រប់ចំនួនមែន ។

**ការបិទផ្សាយបញ្ជីដំបូង សម្រាប់គោលដៅនៃការពិនិត្យកែតម្រូវជាសាធារណៈតាមរយៈការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់**

**ប្រការ ៤.២៤** ផ្អែកតាមការណែនាំរបស់ គជប ស្មៀនឃុំ សង្កាត់ និងជំនួយការស្មៀនត្រូវបិទផ្សាយបញ្ជីបោះឆ្នោតនៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់ដែលបានធ្វើបច្ចុប្បន្នភាពរួចចំនួនពីរ(២)ច្បាប់ ជាបញ្ជីបោះឆ្នោតដំបូង សម្រាប់បំរើគោលដៅនៃការពិនិត្យកែតម្រូវជាសាធារណៈ តាមរយៈការប្តឹងតវ៉ា ឬ/និង ការប្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនោះ ។

៤.២៤.១ នៅមុនការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ស្មៀនឃុំ សង្កាត់ត្រូវធានាឱ្យប្រាកដថា បានចម្លងឈ្មោះអ្នកបោះឆ្នោតថ្មីចេញពីគល់សន្លឹកទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ និងបានចម្លងឈ្មោះអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតទៅក្នុងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយផ្អែកតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានយល់ព្រមលើបណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះ ។

៩.២៨.២ បញ្ជីបោះឆ្នោតដំបូងដែលត្រូវបិទផ្សាយក្នុងឃុំ សង្កាត់ រួមមានបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាព គួបផ្សំនឹងបញ្ជីបោះឆ្នោតបន្ថែមនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ព្រមទាំងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដែលបានបង្កើតថ្មី ( ប្រសិនបើមាន ) ។ ស្មៀនឃុំ សង្កាត់ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតដំបូងដែលបានរៀបចំរួចជាស្រេច ដូចចែងក្រោមប្រការ ៩.១៥ និងក្នុងចំណុច ៩.១៥.៩ ខាងលើ សម្រាប់ការិយាល័យទាំងអស់មួយច្បាប់ នៅសាលាឃុំ សង្កាត់ ហើយត្រូវបំបែក និងបិទផ្សាយមួយច្បាប់ៗ នៅតាមទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយអនុវត្តតាមកាលបរិច្ឆេទកំណត់ដូចខាងក្រោម ៖

៩.២៨.២.១ ប្រសិនបើ ក្រុមប្រឹក្សាឃុំ សង្កាត់ ពុំបានទទួលពាក្យបណ្តឹងតវ៉ាទាក់ទងនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតណាមួយទេ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនឹងត្រូវធ្វើ នៅក្នុងរយៈពេលបួន(៤)ថ្ងៃ ក្រោយពីថ្ងៃបញ្ចប់រយៈពេល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៩.២៨.២.២ ប្រសិនបើ មានបណ្តឹងតវ៉ាមួយ ឬច្រើនត្រូវបានដាក់នៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេលកំណត់សម្រាប់ការដាក់ពាក្យបណ្តឹងតវ៉ា ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនឹងត្រូវធ្វើនៅរយៈពេលប្រាំមួយ( ៦ ) ថ្ងៃ ក្រោយពីការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

៩.២៨.២.៣ ប្រសិនបើ មានបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេច របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានដាក់នៅ គជប ក្នុងរយៈពេលកំណត់សម្រាប់ការដាក់ពាក្យបណ្តឹងតវ៉ា ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនឹងត្រូវធ្វើនៅក្នុងរយៈពេលប្រាំមួយ(៦)ថ្ងៃ ក្រោយពីការសម្រេចរបស់ គជប ។

៩.២៨.២.៤ ប្រសិនបើ មានបណ្តឹងតវ៉ាទៅនឹងសេចក្តីសំរេចរបស់ គជប ត្រូវបានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនឹងត្រូវធ្វើ នៅថ្ងៃបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាធម្មនុញ្ញបានសំរេច ។ ក្នុងករណីនេះ គជប ត្រូវជូនដំណឹង ឬ/និងផ្ញើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទៅក្រុមប្រឹក្សាឃុំ សង្កាត់/ស្មៀនឃុំ សង្កាត់ពាក់ព័ន្ធជាបន្ទាន់ ។

៩.២៨.៣ នៅពេលដែលត្រូវបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនេះ ស្មៀនឃុំ សង្កាត់ត្រូវធ្វើកំណត់ហេតុស្តីពីការបិទផ្សាយនេះ ដោយមានបញ្ជាក់អំពីពេលវេលា កាលបរិច្ឆេទ និង

ទីកន្លែងនៃការបិទផ្សាយ ហើយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោតផង ។ ស្មៀនឃុំ សង្កាត់ត្រូវបិទផ្សាយកំណត់ហេតុនេះមួយច្បាប់ អមជាមួយនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង នៅសាលាឃុំ សង្កាត់ រួចផ្ញើជូន គជប មួយច្បាប់ និងរក្សាទុកមួយច្បាប់ជាឯកសាររបស់ឃុំ សង្កាត់ ។

៤.២៤.៤ បញ្ជីបោះឆ្នោតដំបូងទាំងពីរ(២)ច្បាប់នេះ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេលប្រាំ(៥)ថ្ងៃ ដែលក្នុងរយៈពេលកំណត់នេះ ជនណាក៏ដោយ ក៏មានសិទ្ធិប្តឹងតវ៉ា ឬ/និង ប្តឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងបានដែរ ហើយត្រូវដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

៤.២៤.៥ គណបក្សនយោបាយនានា ដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតដំបូង នៃការិយាល័យបោះឆ្នោតមួយ ឬច្រើនចំនួនមួយច្បាប់ ដោយបង់ថ្លៃ ដែលគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។ ការផ្គត់ផ្គង់ចំពោះការស្នើសុំខាងលើនេះត្រូវ ផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់លំដោយនៃការស្នើសុំ ។ រាល់ការស្នើសុំ តម្រូវឱ្យបង់ប្រាក់កក់ជាមុនស្មើនឹង ១០០ ភាគរយ នៃតម្លៃផលិតផលស្នើសុំ ។

៤.២៤.៦ អាជ្ញាធររៀបចំការបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់ រួមទាំងក្រុមប្រឹក្សា / ស្មៀនឃុំ សង្កាត់ ដែល គជប បានធ្វើប្រតិភូកម្មអំណាចឱ្យទទួលបន្ទុកការងារត្រួតពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ត្រូវទទួលផលិតបញ្ជីបោះឆ្នោតដំបូងដោយផ្ទាល់តាមលទ្ធភាពជាក់ស្តែងរបស់មូលដ្ឋាន ដើម្បីផ្គត់ផ្គង់តាមសំណើសុំ ដូចចែងក្នុងចំណុច ៤.២៤.៥ ខាងលើ និងមិនត្រូវអនុញ្ញាតឱ្យអ្នកស្នើសុំខ្ចីបញ្ជីបោះឆ្នោតដំបូងច្បាប់ដើម ទៅថតចម្លងដោយខ្លួនឯងឡើយ ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ និងការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង**

**ប្រការ ៤.២៥** គោលបំណងនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនេះ គឺដើម្បីធ្វើសុក្រឹតភាពបញ្ជីបោះឆ្នោត ។ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិប្តឹងតវ៉ា ឬ/និង ប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងនេះ ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេលប្រាំ(៥)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។

៤.២៥.១ ប្រជាពលរដ្ឋគ្រប់រូបដែលមានបំណងប្តឹងតវ៉ាឬ/និងប្តឹងជំទាស់ អាចទៅទទួលយក នៅសាលាឃុំ សង្កាត់ នៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការនូវទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ។ អ្នកប្តឹង ឬតំណាង ត្រូវបំពេញពាក្យបណ្តឹងតវ៉ាចំនួនបួន(៤)ច្បាប់ ឬ/និង បណ្តឹងជំទាស់ចំនួនប្រាំ(៥) ច្បាប់ រួចដាក់ពាក្យបណ្តឹងនោះ នៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

៤.២៥.១.១ មេឃុំ ចៅសង្កាត់ ឬ ជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានប្រគល់សិទ្ធិ ត្រូវទទួលពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ ក្នុងរយៈពេលកំណត់ ដូចចែងក្នុងប្រការ ៤.២៥ ខាងលើ ។

៤.២៥.២ នៅក្នុងរយៈពេលប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ប្រសិនបើពុំមានបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ណាមួយ ត្រូវបានដាក់នៅក្រុមប្រឹក្សា ឃុំ សង្កាត់ទេ ស្មៀនឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍ស្តីពីករណីគ្មានបណ្តឹងតវ៉ាឬ/និង បណ្តឹងជំទាស់នេះ ចុះហត្ថលេខា និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត រួចត្រូវផ្ញើរបាយការណ៍នេះជាបន្ទាន់ ទៅមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៤.២៥.៣ អ្នកប្តឹងតវ៉ា ឬតំណាងត្រូវបំពេញពាក្យបណ្តឹងតវ៉ា (ទម្រង់បែបបទលេខ ១២០២) ចំនួនបួន(៤)ច្បាប់ ដោយបញ្ជាក់ច្បាស់អំពីកម្មវត្ថុ និងភស្តុតាងនៃការតវ៉ាក្នុងករណីណាមួយ ដូចខាងក្រោម ៖

៤.២៥.៣.១ សាមីអ្នកប្តឹងតវ៉ាបានទៅសុំចុះឈ្មោះពិតប្រាកដ ជាមួយនឹងស្មៀនឃុំ សង្កាត់ ត្រូវបានទទួលចុះឈ្មោះ និងមានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោត ដែលគាត់បានចុះឈ្មោះ ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតផ្សេង ។

៤.២៥.៣.២ សាមីអ្នកប្តឹងតវ៉ាបានចុះឈ្មោះ និង មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ព័ន្ធ ដែលគេបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូង មានភាពមិនច្បាស់លាស់ ឬមិនត្រឹមត្រូវតាមព័ត៌មានដែលគាត់បានផ្តល់ឱ្យ ហើយដែលគាត់ទាមទារឱ្យកែតម្រូវឡើងវិញ ។

៩.២៥.៣.៣ សាមីអ្នកប្តឹងតវ៉ាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយដែលគាត់បានទៅពិនិត្យមើលឃើញរួចហើយ ប៉ុន្តែឈ្មោះរបស់គាត់បែរជាត្រូវបានលុបចេញពីបញ្ជីបោះឆ្នោតដំបូង ។

៩.២៥.៤ អ្នកប្តឹងជំទាស់ ឬតំណាងត្រូវបំពេញពាក្យបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០២ ) ចំនួនប្រាំ(៥)ច្បាប់ ដោយបញ្ជាក់ច្បាស់អំពីកម្មវត្ថុនៃការជំទាស់ក្នុងករណីណាមួយ ដូចខាងក្រោម ៖

៩.២៥.៤.១ ជំទាស់ទៅនឹងជនណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ប៉ុន្តែជននោះគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោត ដោយមិនបំពេញបានតាមលក្ខខណ្ឌមាត្រា ៥០ថ្មី នៃច្បាប់បោះឆ្នោត ពីព្រោះជននោះ ៖

មិនមានសញ្ជាតិខ្មែរ ។

មិនទាន់គ្រប់អាយុចុះឈ្មោះបោះឆ្នោត ស្របតាមការកំណត់នៃបទបញ្ជា និងនីតិវិធីរបស់ គជប ។

មិនមានទីលំនៅក្នុងឃុំ សង្កាត់នោះ ។

មានទោសជាប់ពន្ធនាគារ ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់របស់ស្ថាប័នមានសមត្ថកិច្ច ។

៩.២៥.៤.២ ជំទាស់ទៅនឹងជនណាម្នាក់ ដែលទោះបីមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្តី ឬគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោតក្តី ប៉ុន្តែ ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពីរ ឬច្រើន ។

៩.២៥.៥ បណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ដែលពុំបានបំពេញតាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ៩.២៥.៣ និង ៩.២៥.៤ នៃបទបញ្ជា និងនីតិវិធីរបស់ គជប និងច្បាប់ស្តីពីការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបដិសេធពាក្យបណ្តឹងនោះ ឬទាំងនោះ ។

៩.២៥.៦ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថា រាល់បណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ទាក់ទិននឹងបញ្ជីបោះឆ្នោតដំបូង ដូចចែងក្នុងចំណុច ៩.២៥.៣ និង ៩.២៥.៤ ខាងលើ ដែលបានដាក់ពាក្យបណ្តឹងក្នុងរយៈពេលប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់បើកការប្រជុំសម្រេចជាសាធារណៈក្នុងរយៈពេលយ៉ាងយូរបី(៣)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

៩.២៥.៧ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានប្រគល់សិទ្ធិ ត្រូវទទួលពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ទាក់ទិននឹងបញ្ជីបោះឆ្នោតដំបូង និងត្រូវកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការប្រជុំសម្រេចជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយបំពេញព័ត៌មានទាំងនេះលើពាក្យបណ្តឹងតវ៉ាទាំងបួន(៤)ច្បាប់ ( ៥ច្បាប់ ចំពោះបណ្តឹងជំទាស់ ) ។ បន្ទាប់មក ត្រូវចាត់ចែងពាក្យបណ្តឹងទាំងនោះ ដូចខាងក្រោម ៖

៩.២៥.៧.១ ប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬអ្នកប្តឹងជំទាស់ ឬតំណាងវិញ នៅកន្លែងដាក់ពាក្យបណ្តឹងមួយច្បាប់ ។

៩.២៥.៧.២ បញ្ជូនឱ្យអ្នកដែលត្រូវគេប្តឹងជំទាស់មួយច្បាប់(ករណីប្តឹងជំទាស់) ។

៩.២៥.៧.៣ បិទផ្សាយនៅសាលាឃុំ សង្កាត់មួយច្បាប់ ជាសេចក្តីជូនដំណឹងស្តីពីការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើបណ្តឹងពាក់ព័ន្ធ ។

៩.២៥.៧.៤ ត្រៀមទុកចំនួនពីរ(២)ច្បាប់ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រើក្នុងការប្រជុំសម្រេចលើបណ្តឹងពាក់ព័ន្ធ ។

៩.២៥.៨ ចំពោះករណី បណ្តឹងជំទាស់ ដែលមានការពាក់ព័ន្ធនឹងអ្នកដែលត្រូវគេប្តឹងជំទាស់ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សា ដែលបានប្រគល់សិទ្ធិ ត្រូវកំណត់កាលបរិច្ឆេទនៃការប្រជុំសម្រេចជាសាធារណៈក្នុងលក្ខណៈសមស្រប ដែលអាចមានពេលវេលាគ្រប់គ្រាន់ ក្នុងការជូនដំណឹងដល់អ្នកដែលត្រូវគេប្តឹងជំទាស់នោះ ដោយអនុលោមតាមរយៈពេលដែលច្បាប់បានកំណត់ ។

៩.២៥.៩ ការប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ ត្រូវបើកធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវដឹកនាំដោយមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬ សមាជិកក្រុមប្រឹក្សាដែលបានប្រគល់សិទ្ធិ ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

៩.២៥.១០ លក្ខណៈវិនិច្ឆ័យសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រកាន់យកជាមូលដ្ឋាន ដើម្បីសម្រេចលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ គឺត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដែលកំណត់អំពីភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះ ដូចមានចែងក្រោមប្រការ ៩.៨ ខាងលើ និងផ្អែកលើមូលហេតុទាំងឡាយសម្រាប់ការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងជំហានទី៧ ក្រោមប្រការ ៩.១១ នៃបទបញ្ជា និងនីតិវិធីរបស់ គជប ។

៤.២៥.១១ ក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានសិទ្ធិអំណាចណាមួយ ក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួនដោយពឹងផ្អែកលើលក្ខណៈវិនិច្ឆ័យណាផ្សេង ក្រៅអំពីលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងច្បាប់បោះឆ្នោត និងបទបញ្ជានិងនីតិវិធីរបស់ គជប ឡើយ ។

៤.២៥.១២ ស្មៀនឃុំ សង្កាត់ ត្រូវតែមានវត្តមាននៅក្នុងការប្រជុំសម្រេចជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ស្មៀនឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ ជូនក្រុមប្រឹក្សាឃុំ សង្កាត់ដោយចំហ ។

៤.២៥.១៣ នៅក្នុងការប្រជុំសម្រេចជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកប្តឹងតវ៉ា ឬអ្នកប្តឹងជំទាស់ត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់អំពីការតវ៉ា ឬ ការចោទប្រកាន់ស្របច្បាប់របស់ខ្លួន ។ ភស្តុតាងអាចជាកសិណសាក្សី ការដឹងឮ ឬ ឯកសារ ។ ប្រសិនបើមានការស្នើសុំដោយក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកប្តឹងតវ៉ា ឬអ្នកប្តឹងជំទាស់ត្រូវផ្តល់ព័ត៌មានបន្ថែមទាក់ទិននឹងការតវ៉ាឬការចោទប្រកាន់នោះ ។

៤.២៥.១៣.១ ប្រសិនបើ អ្នកប្តឹងតវ៉ា ឬអ្នកប្តឹងជំទាស់ពុំបានបង្ហាញភស្តុតាងណាមួយបញ្ជាក់លើការតវ៉ាឬការចោទប្រកាន់របស់ខ្លួនទេ ឬបានបង្ហាញភស្តុតាងដែលក្រុមប្រឹក្សាឃុំ សង្កាត់យល់ថា មានលក្ខណៈមិនគ្រប់គ្រាន់ បណ្តឹងតវ៉ាឬបណ្តឹងជំទាស់នោះត្រូវតែបានបដិសេធ ។

៤.២៥.១៤ ជនដែលត្រូវគេប្តឹងជំទាស់ អាចបដិសេធពាក្យចោទប្រកាន់របស់ដើមបណ្តឹងជំទាស់បាន ដោយការបង្ហាញរាល់ឯកសារដែលបញ្ជាក់ថា ខ្លួនពិតជាមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ស្របទៅតាមច្បាប់ ។

៤.២៥.១៥ ក្នុងករណី ក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចបដិសេធលើបណ្តឹងតវ៉ា មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលទទួលដឹកនាំការប្រជុំសម្រេចជាសាធារណៈនោះ ត្រូវ ៖

៤.២៥.១៥.១ ចារបដិសេធ និងចុះហត្ថលេខាលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ាឬតំណាងមួយច្បាប់និងរក្សាទុកជាឯកសារមួយច្បាប់ ។

៤.២៥.១៥.២ ចាត់ចែងបំពេញសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) ជាបី(៣)ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

៤.២៥.១៥.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់លើសេចក្តីសម្រេចបដិសេធដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងតវ៉ា ឬតំណាងមួយច្បាប់ ផ្ញើជូន គជប មួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៤.២៥.១៥.៤ ប្រគល់ជូនអ្នកប្តឹងតវ៉ា ឬតំណាងតាមសំណើសុំនូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គជប និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងតវ៉ាអំពីករណីនេះ ទៅ គជប យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ។

៤.២៥.១៦ ក្នុងករណី ក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចយល់ព្រមលើបណ្តឹងតវ៉ា មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលទទួលដឹកនាំការប្រជុំសម្រេចជាសាធារណៈនោះ ត្រូវ ៖

៤.២៥.១៦.១ ចារយល់ព្រម និងចុះហត្ថលេខាលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាងមួយច្បាប់ និង រក្សាទុកជាឯកសារមួយច្បាប់ ។

៤.២៥.១៦.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចយល់ព្រម លើបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) ជាបី (៣)ច្បាប់ ។

៤.២៥.១៦.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់លើសេចក្តីសម្រេចដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងតវ៉ាឬតំណាងមួយច្បាប់ ផ្ញើជូន គជប មួយច្បាប់ និងប្រគល់ឱ្យស្មៀនឃុំ សង្កាត់មួយច្បាប់ ដែលក្រោយមក ត្រូវរក្សាទុកជាឯកសាររបស់ឃុំ សង្កាត់ ។

៤.២៥.១៧ យោងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានយល់ព្រមលើបណ្តឹងតវ៉ា ស្មៀនឃុំ សង្កាត់ត្រូវធ្វើការកែតម្រូវឈ្មោះ និងទិន្នន័យពាក់ព័ន្ធ ឬចុះឈ្មោះរបស់សាមីអ្នកប្តឹងតវ៉ាបន្ថែម ជាបន្ទាន់ នៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ( បញ្ជីបោះឆ្នោតជាបណ្តោះអាសន្នរបស់ឃុំ សង្កាត់ ) ។ ស្មៀនឃុំ សង្កាត់ត្រូវស្រង់កត់ត្រាទុកក្នុងទម្រង់បែបបទលេខ ១០២០ នូវឈ្មោះ

អ្នកបោះឆ្នោត និងទិន្នន័យពាក់ព័ន្ធដែលបានកែតម្រូវ ឬ/និង ឈ្មោះសាមីអ្នកប្តឹងតវ៉ាសុំចុះឈ្មោះ ដែលបានចុះឈ្មោះបន្ថែម ដើម្បីត្រៀមធ្វើរបាយការណ៍សរុបផ្ញើជូនមជ្ឈមណ្ឌលកំព្យូទ័រនៃ គជប នៅពេលបញ្ចប់ដំណើរការប្តឹង និងដោះស្រាយបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ។

៨.២៥.១៨ ក្នុងករណី ក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចបដិសេធលើបណ្តឹងជំទាស់ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលទទួលដឹកនាំការប្រជុំសម្រេចជាសាធារណៈនោះ ត្រូវ ៖

៨.២៥.១៨.១ ចារបដិសេធ និងចុះហត្ថលេខាលើបណ្តឹងជំទាស់នោះ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៨.២៥.១៨.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចបដិសេធ លើបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) ជាបួន(៤)ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

៨.២៥.១៨.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់លើសេចក្តីសម្រេចដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយច្បាប់ ផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ មួយច្បាប់ផ្ញើជូន គជប មួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៨.២៥.១៨.៤ ប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងតាមសំណើសុំ នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គជប និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងជំទាស់បន្ត អំពីករណីនេះ ទៅ គជប យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងជំទាស់ ។

៨.២៥.១៩ ក្នុងករណី ក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចយល់ព្រមលើបណ្តឹងជំទាស់ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សា ដែលទទួលដឹកនាំការប្រជុំសម្រេចជាសាធារណៈនោះ ត្រូវ ៖

៨.២៥.១៩.១ ចារយល់ព្រម និងចុះហត្ថលេខាលើបណ្តឹងជំទាស់នោះ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាង មួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៩.២៥.១៩.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចយល់ព្រម លើបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) ជាបួន (៤)ច្បាប់ ។

៩.២៥.១៩.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់លើសេចក្តីសម្រេចយល់ព្រម ដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹងជំទាស់មួយច្បាប់ ផ្ញើជូន គជប មួយច្បាប់ និង រក្សាទុកជាឯកសារមួយច្បាប់ ។

៩.២៥.១៩.៤ ប្រគល់ជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬ តំណាងតាមសំណើសុំនូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេច របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានបដិសេធការចុះឈ្មោះបោះឆ្នោតរបស់គាត់ ទៅ គជប និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងតវ៉ាអំពីករណីនេះ ទៅ គជប យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចយល់ព្រមលើបណ្តឹងជំទាស់ ។

៩.២៥.២០ យោងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានយល់ព្រមលើបណ្តឹងជំទាស់ ស្មៀនឃុំ សង្កាត់ត្រូវគូសបន្ទាត់លុបឈ្មោះរបស់អ្នកដែលត្រូវគេប្តឹងជំទាស់ ជាបន្ទាន់ នៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ( បញ្ជីបោះឆ្នោតជាបណ្តោះអាសន្នរបស់ឃុំ សង្កាត់ ) និងត្រូវចារត្រង់ឈ្មោះជននោះថា" ប្តឹងជំទាស់ " ។ ស្មៀនឃុំ សង្កាត់ត្រូវស្រង់កត់ត្រាទុកក្នុងទម្រង់បែបបទលេខ ១០២០ នូវឈ្មោះអ្នកបោះឆ្នោត ដែលត្រូវបានលុបចេញពីបញ្ជីបោះឆ្នោត ដើម្បីត្រៀមធ្វើរបាយការណ៍សរុបផ្ញើជូនមជ្ឈមណ្ឌលកំព្យូទ័រនៃ គជប នៅពេលបញ្ចប់ដំណើរការប្តឹង និងដោះស្រាយបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ និងការបើកសវនាការរបស់ គជប ដោះស្រាយបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង**

**ប្រការ ៩.២៦** អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ដែលមានបំណងប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ លើពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គជប ក្នុងរយៈពេលប្រាំ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង ។

៩.២៦.១ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងត្រូវបំពេញពាក្យប្តឹងតវ៉ាឬប្តឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ( ទម្រង់បែបបទលេខ ១២០២ ) រួចដាក់ពាក្យបណ្តឹងនេះនៅ គជប ។ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងដែលក្រុមប្រឹក្សាឃុំ សង្កាត់បានប្រគល់ទម្រង់បែបបទសម្រាប់ប្តឹងតវ៉ា ឬប្តឹងជំទាស់រួចហើយ ដូចចែងក្នុងចំណុច ៩.២៥.១៥.៤ ៩.២៥.១៨.៤ និង ៩.២៥.១៩.៤ ខាងលើ ប៉ុន្តែមិនបានមកដាក់ពាក្យបណ្តឹងតវ៉ារបស់ខ្លួននៅ គជប តាមពេលវេលាកំណត់ដូចចែងក្នុងប្រការ ៩.២៦ ត្រូវបានចាត់ទុកថា មិនប្តឹងតវ៉ា ឬមិនប្តឹងជំទាស់ ។

៩.២៦.២ ប្រសិនបើ គ្មានពាក្យបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ត្រូវបានគេដាក់នៅ គជប ក្នុងអំឡុងពេលដូចចែងក្នុងប្រការ ៩.២៦ ខាងលើទេ គជប ត្រូវបង្គាប់ទៅនាយកដ្ឋានប្រតិបត្តិការ (មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប) ជាបន្ទាន់ ដើម្បីចាត់ចែងរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ។ ដោយឡែក ចំពោះឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ គជប ត្រូវអនុវត្តលក្ខខណ្ឌ ដូចចែងចាប់ពីចំណុច ៩.២៦.៣ ដល់ ៩.២៦.១១ ខាងក្រោម ។

៩.២៦.៣ គជប ត្រូវធានាថា រាល់បណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ដូចចែងក្នុងចំណុច ៩.២៦.១ ខាងលើ ដែលបានដាក់ពាក្យបណ្តឹងក្នុងអំឡុងពេលកំណត់ ដូចចែងក្នុងប្រការ ៩.២៦ ខាងលើ ត្រូវបាន គជប បើកសវនាការសម្រេច ក្នុងរយៈពេលយ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ទាំងនោះ ។

៩.២៦.៤ សាធារណជនមានសិទ្ធិក្នុងការចូលរួមស្តាប់សវនាការរបស់ គជប ដើម្បីដោះស្រាយរាល់បណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ។

៩.២៦.៥ ដើម្បីបង្កលក្ខណសម្បត្តិ សម្រាប់ការបើកសវនាការរបស់ គជប ដោះស្រាយលើបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ ដូចចែងក្នុងចំណុច ៩.២៦.៣ នៅរាល់ពេលទទួលពាក្យបណ្តឹងទាំងនោះ គជប ត្រូវធានាថា ៖

៩.២៦.៥.១ នាយកដ្ឋានសេវាកម្មច្បាប់បានប្រមូលផ្តុំ រាល់សេចក្តីសំរេចបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ពាក់ព័ន្ធ ដែលបានផ្ញើជូន គជប ដោយឡែកក្តី ឬតាមការបញ្ជូនកញ្ចប់ " ខ " និងកញ្ចប់ " គ " ក្តី ។

៩.២៦.៥.២ នៅពេលទទួលពាក្យបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្ម ដែលបានប្រគល់សិទ្ធិ ត្រូវបំពេញលើពាក្យបណ្តឹងតវ៉ាទាំងពីរ(២)ច្បាប់ នូវពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង រួចប្រគល់ជូនអ្នកប្តឹងតវ៉ា ឬអ្នកត្រូវគេប្តឹងជំទាស់ ឬអ្នកប្តឹងជំទាស់ ឬតំណាង មួយច្បាប់ និងត្រូវជំរាបគាត់ថា ពេលវេលា កាលបរិច្ឆេទ និងទីកន្លែងដែលនឹងត្រូវបើកសវនាការដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់នោះ នឹងជូនដំណឹងជាក្រោយ ក្នុងរយៈពេលយ៉ាងតិចពីរ( ២ )ថ្ងៃ មុនថ្ងៃបើកសវនាការ ។

៩.២៦.៥.៣ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ដែលបានប្រគល់សិទ្ធិ ត្រូវថតចម្លងពាក្យបណ្តឹង ដែលបានទទួលនិងបំពេញរួចហើយនោះបន្ថែមចំនួនបី(៣)ច្បាប់សម្រាប់បណ្តឹងតវ៉ា និងចំនួនបួន(៤)ច្បាប់សម្រាប់បណ្តឹងជំទាស់ ដែលក្នុងនោះ ត្រូវរក្សាទុកច្បាប់ចម្លងមួយច្បាប់ជាឯកសារនៅនាយកដ្ឋានសេវាកម្មច្បាប់ បិទផ្សាយជាសេចក្តីជូនដំណឹងមួយច្បាប់នៅទីស្តីការ គជប និងត្រៀមពាក្យបណ្តឹងពីរ(២)ច្បាប់ទៀតសម្រាប់ប្រើប្រាស់ក្នុងសវនាការរបស់ គជប ។ ចំពោះករណីបណ្តឹងជំទាស់ ត្រូវផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ មួយច្បាប់ ។

៩.២៦.៦ ក្នុងករណី គជប សម្រេចបដិសេធលើបណ្តឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

៩.២៦.៦.១ ចារបដិសេធ ចុះហត្ថលេខា និងកាលបរិច្ឆេទលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាងមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៩.២៦.៦.២ ចាត់ចែងឱ្យបំពេញសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបី(៣)ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

៩.២៦.៦.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប លើសេចក្តីសម្រេចដែលបានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬ តំណាងមួយច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញមួយច្បាប់ និង រក្សាទុកជាឯកសារមួយច្បាប់ ។

៤.២៦.៦.៤ ប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាង នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ តាមសំណើសុំសម្រាប់បំពេញពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ារបស់ គជប ទៅក្រុមប្រឹក្សាធម្មនុញ្ញ និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងតវ៉ា អំពីករណីនេះ ទៅក្រុមប្រឹក្សាធម្មនុញ្ញ យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ។

៤.២៦.៧ ក្នុងករណី គជប សម្រេចយល់ព្រមលើបណ្តឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

៤.២៦.៧.១ ចារយល់ព្រម ចុះហត្ថលេខា និងកាលបរិច្ឆេទលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬ តំណាងមួយ(១)ច្បាប់ និងរក្សាទុកជាឯកសារមួយ(១)ច្បាប់ ។

៤.២៦.៧.២ ចាត់ចែងឱ្យបំពេញសេចក្តីសម្រេចយល់ព្រមលើបណ្តឹងតវ៉ា (ទម្រង់បែបបទលេខ ១២០៣ ) ជាបី(៣)ច្បាប់ ។

៤.២៦.៧.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប លើសេចក្តីសំរេចដែលបានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាងមួយច្បាប់ និងរក្សាទុកជាឯកសារមួយ(១)ច្បាប់ ។

៤.២៦.៧.៤ ជូនដំណឹង ឬ/និង ផ្ញើជូនក្រុមប្រឹក្សាឃុំ សង្កាត់នូវសេចក្តីសម្រេចយល់ព្រមលើបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) មួយ(១)ច្បាប់ ។

៤.២៦.៨ គជប ត្រូវធានាថា រាល់សេចក្តីសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ដូចចែងក្នុងចំណុច ៤.២៦.៧.៤ ខាងលើ ត្រូវតែបានជូនដំណឹងតាមរយៈទូរសារ ឬវិទ្យុទាក់ទង ឬ/និង ផ្ញើច្បាប់ដើមជូនក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបាន ។

៤.២៦.៩ យោងតាមសេចក្តីសំរេចរបស់ គជប ដែលបានយល់ព្រមលើបណ្តឹងតវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវណែនាំស្មៀនឃុំ សង្កាត់ឱ្យកែតម្រូវឈ្មោះ និងទិន្នន័យពាក់ព័ន្ធ ឬ ចុះបន្ថែមជាបន្ទាន់នូវឈ្មោះអ្នកដែលបានចុះឈ្មោះរួចហើយ តែបានបាត់ឈ្មោះពីបញ្ជីបោះឆ្នោតដំបូង នៅក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោត

ពាក់ព័ន្ធ ( បញ្ជីបោះឆ្នោតជាបណ្តោះអាសន្នរបស់ឃុំ សង្កាត់ ) ។ ស្មៀនឃុំ សង្កាត់ត្រូវស្រង់កត់ត្រាទុកក្នុងទម្រង់បែបបទលេខ ១០២០ នូវឈ្មោះអ្នកបោះឆ្នោត និងទិន្នន័យពាក់ព័ន្ធដែលបានកែតម្រូវ ឬ/និង ឈ្មោះសាមីអ្នកប្តឹងតវ៉ាដែលបាត់ឈ្មោះ និងដែលបានចុះឈ្មោះបន្ថែម ដើម្បីត្រៀមធ្វើរបាយការណ៍សរុបផ្ញើជូនមជ្ឈមណ្ឌលកំព្យូទ័រនៃ គជប នៅពេលបញ្ចប់ដំណើរការប្តឹង និងដោះស្រាយបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ។

៤.២៦.១០ ក្នុងករណី គជប សម្រេចបដិសេធលើបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

៤.២៦.១០.១ ចារបដិសេធ និងចុះហត្ថលេខាលើបណ្តឹងជំទាស់នោះ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយ(១)ច្បាប់ និងរក្សាទុកជាឯកសារមួយ(១)ច្បាប់ ។

៤.២៦.១០.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចបដិសេធ លើបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) ជាបួន(៤)ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

៤.២៦.១០.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប លើសេចក្តីសម្រេចដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់មួយច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៤.២៦.១០.៤ ប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងតាមសំណើសុំ នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចបដិសេធរបស់ គជប ទៅក្រុមប្រឹក្សាធម្មនុញ្ញ និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងជំទាស់បន្តអំពីករណីនេះ ទៅក្រុមប្រឹក្សាធម្មនុញ្ញ យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងជំទាស់ ។

៤.២៦.១១ ក្នុងករណី គជប សម្រេចយល់ព្រមលើបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

៤.២៦.១១.១ ចារយល់ព្រម និងចុះហត្ថលេខាលើបណ្តឹងជំទាស់នោះ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៤.២៦.១១.២ ចាត់ចែង ឱ្យបំពេញសេចក្ដីសម្រេចយល់ព្រម លើបណ្ដឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) ជាបួន(៤)ច្បាប់ ។

៤.២៦.១១.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប លើសេចក្ដីសម្រេចយល់ព្រម ដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្ដឹងជំទាស់ ឬតំណាងមួយច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្ដឹងជំទាស់មួយច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

៤.២៦.១១.៤ ប្រគល់ជូនអ្នកត្រូវគេប្ដឹងជំទាស់ ឬ តំណាងតាមសំណើសុំ នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២) ច្បាប់សម្រាប់បំពេញពាក្យបណ្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គជប ដែលបានបដិសេធការចុះឈ្មោះបោះឆ្នោតរបស់គាត់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ និងជម្រាបគាត់ថា គាត់មានសិទ្ធិប្ដឹងតវ៉ាអំពីករណីនេះ ទៅក្រុមប្រឹក្សាធម្មនុញ្ញ យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចយល់ព្រមលើបណ្ដឹងជំទាស់ ។

៤.២៦.១២ យោងតាមសេចក្ដីសំរេចរបស់ គជប ដែលបានយល់ព្រមលើបណ្ដឹងជំទាស់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវណែនាំស្មៀនឃុំ សង្កាត់ ឱ្យគូសបន្ទាត់លុបឈ្មោះអ្នកដែលត្រូវគេប្ដឹងជំទាស់ ចេញពីបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ( បញ្ជីបោះឆ្នោតជាបណ្ដោះអាសន្នរបស់ឃុំ សង្កាត់ ) ជាបន្ទាន់ និងត្រូវចារត្រង់ឈ្មោះជននោះថា " ប្ដឹងជំទាស់ " ។ ស្មៀនឃុំ សង្កាត់ត្រូវស្រង់កត់ត្រាទុកក្នុងទម្រង់បែបបទលេខ ១០២០ នូវឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានលុបចេញពីបញ្ជីបោះឆ្នោតដំបូង ដើម្បីត្រៀមធ្វើរបាយការណ៍សរុបផ្ញើជូនមជ្ឈមណ្ឌលកំព្យូទ័រនៃ គជប នៅពេលបញ្ចប់ដំណើរការប្ដឹង និងដោះស្រាយបណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ។

**ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ និងការបើកសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយបណ្ដឹងតវ៉ា ឬ/និង បណ្ដឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង**

**ប្រការ៤.២៧** អ្នកប្ដឹងតវ៉ា អ្នកប្ដឹងជំទាស់ និងអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាង ដែលមានបំណងប្ដឹងចំពោះសេចក្ដីសម្រេចរបស់ គជប លើពាក្យបណ្ដឹងតវ៉ា ឬ/និង បណ្ដឹងជំទាស់របស់ខ្លួនទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង មានសិទ្ធិប្ដឹងតវ៉ា ឬ ប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ

ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចយល់ព្រម ឬ បដិសេធលើពាក្យបណ្តឹង ។

៤.២៧.១ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងត្រូវបំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់គជប ( ទម្រង់បែបបទលេខ ១២០២ ) ចំនួនពីរ(២)ច្បាប់ រួចដាក់ពាក្យបណ្តឹងរបស់ខ្លួននៅក្រុមប្រឹក្សាធម្មនុញ្ញ ។ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងដែល គជប បានប្រគល់ទម្រង់បែបបទសម្រាប់ប្តឹងតវ៉ា ឬ ប្តឹងជំទាស់រួចហើយ ដូចចែងក្នុងចំណុច ៤.២៦.៦.៤ ៤.២៦.១០.៤ និង ៤.២៦.១១.៤ ខាងលើ ប៉ុន្តែមិនបានមកដាក់ពាក្យបណ្តឹងរបស់ខ្លួន នៅក្រុមប្រឹក្សាធម្មនុញ្ញ តាមការកំណត់ដូចចែងក្នុងប្រការ ៤.២៧ ត្រូវបានចាត់ទុកថា មិនប្តឹងតវ៉ា ឬមិនប្តឹងជំទាស់ ។

៤.២៧.២ ប្រសិនបើ គ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ត្រូវបានគេដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអំឡុងពេលដូចចែងក្នុងប្រការ ៤.២៧ ខាងលើទេ គជប ត្រូវជូនដំណឹងនេះជាបន្ទាន់ទៅក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ និងត្រូវបង្គាប់ទៅនាយកដ្ឋានប្រតិបត្តិការ (មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប) ដើម្បីចាត់ចែងរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ។

៤.២៧.៣ អនុលោមតាមមាត្រា ៦៦ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញនឹងបើកសវនាការសម្រេចជាសាធារណៈ ក្នុងអំឡុងពេលយ៉ាងយូរដប់( ១០ )ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ទៅនឹងសេចក្តីសំរេចរបស់ គជប ពាក់ព័ន្ធនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

៤.២៧.៤ នៅក្នុងពេលបើកសវនាការជាសាធារណៈរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងមានសិទ្ធិបង្ហាញភស្តុតាងជាឯកសារផ្សេងៗ ប្រសិនបើមាន ដែលបញ្ជាក់អំពីភាពត្រឹមត្រូវនៃការតវ៉ា ឬ ការចោទប្រកាន់របស់ខ្លួន ស្របតាមច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៤.២៧.៥ ក្រុមប្រឹក្សាធម្មនុញ្ញអនុវត្តការទទួលពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ ក្រោមនីតិវិធីរបស់ខ្លួន រួចជូនដំណឹងទៅ គជប អំពីសេចក្តីសំរេចរបស់ខ្លួន ។

៤.២៧.៦ ក្នុងករណី ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធលើបណ្ដឹងតវ៉ា ឬបដិសេធលើបណ្ដឹងជំទាស់ ក្រុមប្រឹក្សាធម្មនុញ្ញ នឹង ៖

៤.២៧.៦.១ ចេញសេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ា ឬបដិសេធលើបណ្ដឹងជំទាស់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុ នៃការបដិសេធនោះ និងបញ្ជាក់ថា សេចក្ដីសំរេចនេះជាសេចក្ដីសំរេចចុងក្រោយ ។

៤.២៧.៦.២ ប្រគល់ ឬផ្ញើសេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ា ឬបដិសេធលើបណ្ដឹងជំទាស់ ជូនអ្នកប្ដឹងតវ៉ា ឬអ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ឬ តំណាងមួយ(០១)ច្បាប់ ។

៤.២៧.៦.៣ ផ្ញើសេចក្ដីសម្រេចបដិសេធបណ្ដឹងតវ៉ា ឬ បដិសេធបណ្ដឹងជំទាស់ជូន គជប មួយ(០១)ច្បាប់ ។

៤.២៧.៧ ក្នុងករណី ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមតាមបណ្ដឹងតវ៉ា ឬយល់ព្រមតាមបណ្ដឹងជំទាស់ ក្រុមប្រឹក្សាធម្មនុញ្ញ នឹង ៖

៤.២៧.៧.១ ចេញសេចក្ដីសម្រេចយល់ព្រមបណ្ដឹងតវ៉ា ឬ យល់ព្រមបណ្ដឹងជំទាស់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការយល់ព្រមនោះផង ។

៤.២៧.៧.២ ប្រគល់ ឬ ផ្ញើសេចក្ដីសម្រេចយល់ព្រមបណ្ដឹងតវ៉ា ឬ យល់ព្រមបណ្ដឹងជំទាស់ជូនអ្នកប្ដឹងតវ៉ា ឬ អ្នកប្ដឹងជំទាស់ ឬ អ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាង មួយ(០១)ច្បាប់ ។

៤.២៧.៧.៣ ផ្ញើសេចក្ដីសម្រេចយល់ព្រមបណ្ដឹងតវ៉ា ឬ យល់ព្រមបណ្ដឹងជំទាស់ជូន គជប មួយ(០១)ច្បាប់ ។

៤.២៧.៨ គជប ត្រូវធានាថារាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលបានបដិសេធបណ្ដឹងតវ៉ា ឬបដិសេធបណ្ដឹងជំទាស់ ដូចចែងក្នុងចំណុច ៤.២៧.៦.៣ និងដែលបានយល់ព្រមបណ្ដឹងតវ៉ា ឬ យល់ព្រមបណ្ដឹងជំទាស់ដូចចែងក្នុងចំណុច ៦.២៧.៧.៣ ខាងលើ ត្រូវតែបានជូនដំណឹងតាមរយៈទូរសារ ឬ វិទ្យុទាក់ទង ឬ/និង ផ្ញើច្បាប់ដើមជូនក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។ ផ្អែកតាមសេចក្ដីសម្រេចសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះករណីនីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្គាប់ស្មៀនឃុំ សង្កាត់ឱ្យអនុវត្ត ដូចខាងក្រោម ៖

៤.២៧.៨.១ ករណីបដិសេធបណ្តឹងតវ៉ា ត្រូវរក្សាបញ្ជីបោះឆ្នោតដដែល ។
៤.២៧.៨.២ ករណីបដិសេធបណ្តឹងជំទាស់ ត្រូវរក្សាបញ្ជីបោះឆ្នោតដដែល ។
៤.២៧.៨.៣ ករណីយល់ព្រមបណ្តឹងតវ៉ា ត្រូវធ្វើការកែតម្រូវឈ្មោះ និងទិន្នន័យពាក់ព័ន្ធ ឬ ចុះបន្ថែមជាបន្ទាន់ នូវឈ្មោះរបស់សាមីអ្នកប្តឹងតវ៉ា ឬឈ្មោះអ្នកត្រូវគេប្តឹងជំទាស់ ដែលជាអ្នកប្តឹងតវ៉ា នៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ( បញ្ជីបោះឆ្នោតជាបណ្តោះអាសន្នរបស់ឃុំ សង្កាត់ ) ។
៤.២៧.៨.៤ ករណីយល់ព្រមបណ្តឹងជំទាស់ ត្រូវគូសបន្ទាត់លុបឈ្មោះអ្នក ដែលត្រូវគេប្តឹងជំទាស់ជាបន្ទាន់ ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ( បញ្ជីបោះឆ្នោតជាបណ្តោះអាសន្នរបស់ឃុំសង្កាត់ ) និងត្រូវចារត្រង់ឈ្មោះជននោះថា " ប្តឹងជំទាស់ " ។
៤.២៧.៨.៥ ត្រូវស្រង់កត់ត្រាទុកក្នុងទម្រង់បែបបទលេខ ១០២០ នូវឈ្មោះអ្នកបោះឆ្នោតនិងទិន្នន័យពាក់ព័ន្ធដែលបានកែតម្រូវ ឬ/និង ឈ្មោះសាមីអ្នកប្តឹងតវ៉ាដែលបាត់ឈ្មោះ ឬ ឈ្មោះអ្នកត្រូវគេប្តឹងជំទាស់ដែលបានឈ្នះការប្តឹងតវ៉ា ដែលត្រូវបានចុះឈ្មោះបន្ថែម ឬ/និងឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានលុបចេញ ពីបញ្ជីបោះឆ្នោតដំបូង ដើម្បីត្រៀមធ្វើរបាយការណ៍សរុបផ្ញើជូនមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ។

៤.២៧.៩ ក្នុងចន្លោះពេលចាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង រហូតទល់នឹងថ្ងៃបញ្ចប់ការដោះស្រាយបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ទាក់ទងបញ្ជីបោះឆ្នោតដំបូង នៅក្រុមប្រឹក្សាធម្មនុញ្ញ ស្មៀនឃុំ សង្កាត់ត្រូវធ្វើសុក្រឹតភាពបញ្ជីបោះឆ្នោត ដោយត្រូវ ៖
៤.២៧.៩.១ បំពេញ និង ចុះហត្ថលេខា កាលបរិច្ឆេទលើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ១០១៦ ) ចំនួនពីរ (២) ច្បាប់ ដោយត្រូវមានឯកសារជាភស្តុតាងបញ្ជាក់ផង ក្នុងករណីមានអ្នកបោះឆ្នោតបានទទួលមរណភាព ឬវិកលចរិត ឬ ស្ថិតក្រោមអាណាព្យាបាល ឬត្រូវកាត់ទោសជាប់ពន្ធនាគារ ឬផ្លាស់ទីលំនៅចេញ ។
៤.២៧.៩.២ ផ្អែកលើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត( ១០១៦ ) គូសបន្ទាត់លុបឈ្មោះអ្នកបោះឆ្នោតទាំងនោះ ចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ និងត្រូវចារបញ្ជាក់នៅទន្ទឹមនឹងជួរឈ្មោះរបស់ជននោះថា " ស្លាប់ " ឬ " បាត់បង់សិទ្ធិ " ឬ " ផ្លាស់ចេញ " ។

៤.២៧.៩.៣ ត្រូវស្រង់កត់ត្រាទុកក្នុងទម្រង់បែបបទលេខ ១០២០ នូវឈ្មោះអ្នកបោះឆ្នោត ដែលត្រូវបានលុបចេញពីបញ្ជីបោះឆ្នោត ដូចចែងក្នុងចំណុច ៤.២៧.៩.២ ដើម្បីត្រៀមធ្វើរបាយការណ៍សរុបផ្ញើជូនមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ។

៤.២៧.១០ នៅពេលបញ្ចប់ដំណើរការប្តឹង និង ដោះស្រាយបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង នៅក្រុមប្រឹក្សាធម្មនុញ្ញ ស្មៀនឃុំ សង្កាត់ត្រូវធានាថា របាយការណ៍សរុបស្តីពីការកែតម្រូវលើបញ្ជីបោះឆ្នោតដំបូង ដោយផ្អែកលើរបាយការណ៍ដែលបានស្រង់កត់ត្រាជាបណ្តើរៗដូចចែងក្នុងចំណុច ៤.២៥.១៧ ៤.២៥.២០ ៤.២៦.៩ ៤.២៦.១២ ៤.២៧.៤.៥ និង ៤.២៧.៩.៣ ខាងលើ ត្រូវបានបំពេញ និងផ្ញើជាបន្ទាន់ជូនមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ។

**ការប្រគល់ទទួលសម្ភារៈឯកសារ នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅ គជប និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតក្នុងប្រព័ន្ធកុំព្យូទ័រ**

**ប្រការ ៤.២៨** មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ( NECC ) ត្រូវទទួលបន្ទុកការទទួល ការត្រួតពិនិត្យ និងការគ្រប់គ្រងសម្ភារៈឯកសារនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលត្រូវបានវេចខ្ចប់តាមលំដាប់លំដោយក្នុងកញ្ចប់ " ក " កញ្ចប់ " ខ " និងកញ្ចប់ " គ " ហើយដែលបានបញ្ជូន និងប្រគល់ឱ្យដោយលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវរាយការណ៍តាមឋានានុក្រមទៅ គជប ជាប្រចាំ ។

៤.២៨.១ រាល់សម្ភារៈឯកសារនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតទាំងអស់ត្រូវតែបានប្រគល់ និងទទួលនៅបន្ទប់ទទួលឯកសាររបស់មជ្ឈមណ្ឌលកុំព្យូទ័រ នៃ គជប ។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចចូលរួមសង្កេតការណ៍ ក្នុងការប្រគល់ទទួលនេះ ។

៤.២៨.១.១ នៅពេលបានទទួលកញ្ចប់ " គ " ពីមន្ត្រីទទួលបន្ទុកការបញ្ជូននៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវពិនិត្យសុវត្ថិភាពនៃរាល់កញ្ចប់ " គ " បន្ទាប់មកត្រូវបើកកញ្ចប់ " គ " ម្តងមួយៗ ដើម្បីត្រួតពិនិត្យកញ្ចប់ " ខ " ទាំងអស់ដែលមានខាងក្នុង ដោយផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ខ " ( ទម្រង់បែបបទលេខ ១០១៤ ) ដែលមានដាក់ក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " គ " ។

៤.២៨.១.២ ប្រសិនបើ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ខាងលើនេះបង្ហាញថា មានភាពត្រឹមត្រូវ មន្ត្រីទទួលឯកសារ នៃមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវប្រមូលយកលិខិតបញ្ជាក់ការវេចខ្ចប់ និងការបញ្ជូនកញ្ចប់ " ខ " ( ទម្រង់បែបបទលេខ ១០១៤ ) មួយច្បាប់ពីក្នុងស្រោមសំបុត្រក្នុងកញ្ចប់ " គ " មួយច្បាប់ពីក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " គ " និងមួយច្បាប់ទៀត ពីមន្ត្រីទទួលបន្ទុកការបញ្ជូន នៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត រួចចុះហត្ថលេខា និងកាលបរិច្ឆេទបញ្ជាក់ថា បានទទួលគ្រប់ចំនួនមែន ។

៤.២៨.១.៣ មន្ត្រីទទួលឯកសារនៃមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវប្រគល់ទម្រង់បែបបទលេខ ១០១៤ ដែលបានចុះហត្ថលេខារួច មួយច្បាប់ ជូនមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតវិញ និងត្រូវចងក្រងមួយ(០១)ច្បាប់ជាឯកសារ ។

៤.២៨.២ ប្រសិនបើ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ខាងលើនេះ ត្រូវបានរកឃើញភស្តុតាងដែលអាចបញ្ជាក់ថា មានកញ្ចប់ " ខ " ណាមួយត្រូវបានគេរុះរើ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវ ៖

៤.២៨.២.១ ផ្ទៀងផ្ទាត់ចំនួន និងពិនិត្យស្ថានភាពនៃកញ្ចប់ " ខ " ទាំងអស់ដែលមានក្នុងកញ្ចប់ " គ " យ៉ាងម៉ត់ចត់ទៅនឹងលិខិតបញ្ជាក់ការវេចខ្ចប់ និង ការបញ្ជូនកញ្ចប់ " ខ " ( ទម្រង់បែបបទលេខ ១០១៤ ) ដែលមានដាក់ក្នុងហោប៉ៅខាងក្រៅកញ្ចប់ " គ " នោះ ។

៤.២៨.២.២ ផ្ទៀងផ្ទាត់ចំនួន និងពិនិត្យស្ថានភាពនៃកញ្ចប់ " ក " ឬ/និងកញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃ ឬ/និងស្រោមសំបុត្រដាក់ឯកសារចុះឈ្មោះទាំងអស់ដែលមានក្នុងកញ្ចប់ " ខ " និងដែលត្រូវគេរុះរើនោះ ជាមួយនឹងលិខិតបញ្ជាក់ការវេចខ្ចប់ និង ការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ដែលមានដាក់ក្នុងកញ្ចប់ " ខ " និងហោប៉ៅខាងក្រៅកញ្ចប់ " ខ " នោះ ។

៤.២៨.២.៣ ប្រសិនបើ នៅក្នុងការផ្ទៀងផ្ទាត់ខាងលើបានបង្ហាញឱ្យឃើញថា មានភាពមិនប្រក្រតី ដោយមានកញ្ចប់ " ក " ឬ/និង កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃណាមួយ ឬ ច្រើនត្រូវបានគេរុះរើនោះ

ត្រូវស្នើឱ្យមន្ត្រីទទួលបន្ទុកការបញ្ជូននៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ធ្វើការបំភ្លឺអំពីបញ្ហានេះ បន្ទាប់មកត្រូវជូនដំណឹងនេះជាបន្ទាន់ ទៅមន្ត្រីទទួលបន្ទុកលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

៤.២៨.២.៤ ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរដូចបញ្ជាក់ខាងលើ ត្រូវលើកស្នើសុំ គជប តែងតាំងក្រុមអធិការកិច្ចមួយជាបន្ទាន់ ដើម្បីធ្វើការត្រួតពិនិត្យករណីមិនប្រក្រតីនោះ ។ ប្រសិនបើចាំបាច់ ក្រុមអធិការកិច្ចត្រូវធ្វើដំណើររួមជាមួយនឹងមន្ត្រីទទួលបន្ទុកការបញ្ជូន នៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ទៅកាន់ឃុំ សង្កាត់ពាក់ព័ន្ធនឹងកញ្ចប់ " ខ " និងកញ្ចប់ " ក " ដែលត្រូវគេរុះរើនោះ ដើម្បីស្រាវជ្រាវបន្ថែម ។

៤.២៨.៣ ក្រុមអធិការកិច្ចត្រូវបើកកញ្ចប់ " ខ " ដែលត្រូវបានគេរុះរើនោះ រួចផ្ទៀងផ្ទាត់ចំនួន និងពិនិត្យស្ថានភាពនៃកញ្ចប់ " ក " ឬ/និង កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃ ឬ/និងស្រោមសំបុត្រដាក់ឯកសារចុះឈ្មោះទាំងអស់ ដែលមានក្នុងកញ្ចប់ " ខ " ជាមួយនឹងលិខិតបញ្ជាក់ការវេចខ្ចប់និងការបញ្ជូនកញ្ចប់ " ក " ( ទម្រង់បែបបទលេខ ១០១៣ ) ដែលមានដាក់ក្នុងកញ្ចប់ " ខ " និងហោប៉ៅខាងក្រៅកញ្ចប់ " ខ " នោះ សាជាថ្មីឡើងវិញ ។

៤.២៨.៣.១ ក្នុងករណី គ្មានកញ្ចប់ " ក " ឬ/និង កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃណាមួយ ត្រូវបានគេរុះរើទេ ក្រុមអធិការកិច្ចគ្រាន់តែត្រូវផ្ទៀងផ្ទាត់ចំនួនកញ្ចប់ ឬ/និង ស្រោមសំបុត្រ ដែលមានក្នុងកញ្ចប់ " ខ " នោះប៉ុណ្ណោះ ។

៤.២៨.៣.២ ក្នុងករណី មានកញ្ចប់ " ក " ឬ/និង កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃណាមួយ ឬច្រើន ត្រូវបានគេរុះរើ ក្រុមអធិការកិច្ចត្រូវតែបើកកញ្ចប់ " ក " ឬ/និង កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃនោះ និងបន្តផ្ទៀងផ្ទាត់សម្ភារៈឯកសារនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលមាននៅខាងក្នុងបន្ថែមទៀត ជាមួយនឹងរបាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត តាមការិយាល័យ ( ទម្រង់លេខ ១០១១ ) និងរបាយការណ៍សរុបលទ្ធផល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ( ទម្រង់លេខ ១០១២ )។

៩.២៨.៣.៣ ប្រសិនបើ ក្រុមអធិការកិច្ចរកឃើញថា មានការបាត់ ឬការបន្ថែម ឬការកែបន្លំនៅលើបញ្ជីបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពរួច នៃការិយាល័យបោះឆ្នោតណាមួយ ក្រុមអធិការកិច្ចត្រូវធ្វើរបាយការណ៍ពិស្តារអំពីលទ្ធផលនិងភស្តុតាងដែលបានរកឃើញ ដាក់ជូន គជប ពិនិត្យសំរេច និងមានវិធានការ ។

៩.២៨.៤ ផ្អែកលើរបាយការណ៍ និងភស្តុតាងរបស់ក្រុមអធិការកិច្ច គជប ត្រូវ ៖

៩.២៨.៤.១ មានវិធានការផ្តន្ទាទោស ឬ/និង ពិន័យចំពោះជនល្មើស ។

៩.២៨.៤.២ សម្រេចលុបឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោត ចេញពីបញ្ជីបោះឆ្នោត ក្នុងករណីមានការកែបន្លំលើឯកសារនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតពាក់ព័ន្ធ ។

៩.២៨.៤.៣ ត្រូវបង្គាប់ទៅមជ្ឈមណ្ឌលកុំព្យូទ័រ និងក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឱ្យលុបឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោតនោះចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ជាបន្ទាន់ ។

៩.២៨.៥ ប្រសិនបើ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ខាងលើនេះ ពុំមានឃើញភស្តុតាងបញ្ជាក់ថា មានកញ្ចប់ " ខ " ណាមួយ ក្នុងកញ្ចប់ " គ " ត្រូវបានគេរុះរើទេនោះ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវអនុវត្តនីតិវិធី ចាប់ពីចំណុច ៩.២៨.១.១ ដល់ ៩.២៨.១.៣ ខាងលើ ។

៩.២៨.៦ នៅពេលដែលការពិនិត្យផ្ទៀងផ្ទាត់រាល់កញ្ចប់ " ខ " ដែលផ្ទុកក្នុងកញ្ចប់ " គ " ត្រូវបានបញ្ចប់ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវចាប់ផ្តើមចាត់ចែងដំណើរការនៃការធ្វើបច្ចុប្បន្នភាពក្នុងកុំព្យូទ័រ នូវបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ ដោយអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនិងនីតិវិធីផ្ទាល់របស់ខ្លួន ។ មន្ត្រីការិយាល័យទទួល បញ្ជូន និងស្តុកសម្ភារៈឯកសាររបស់មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវបន្តបើកកញ្ចប់ " ខ " ដើម្បីពិនិត្យនិងចាត់ចែងបញ្ជូន ឬទុកដាក់សំភារៈឯកសារចុះឈ្មោះបោះឆ្នោតទៅតាមការកំណត់ ដែលក្នុងនោះត្រូវ ៖

៤.២៨.៦.១ បើកកញ្ចប់ " ខ១ " នៃឃុំ សង្កាត់ម្តងមួយៗតាមលំដាប់លំដោយលេខកូដ ផ្ទៀងផ្ទាត់កញ្ចប់ដាក់ទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានប្រើ និងនៅសល់ និងរាល់ស្រោមសំបុត្រដាក់ឯកសារផ្សេងទៀតជាមួយនឹងទម្រង់បែបបទលេខ១០១៣ ដែលមានមួយច្បាប់នៅក្នុងកញ្ចប់ " ខ១ " និងមួយច្បាប់ទៀតនៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ១ " រួចចុះហត្ថលេខាលើទម្រង់បែបបទលេខ ១០១៣ ទាំងពីរច្បាប់ ដែលក្នុងនេះ ត្រូវចងក្រងមួយច្បាប់ទុកជាឯកសារ ។

៤.២៨.៦.២ ថតចម្លងរាល់របាយការណ៍សរុបលទ្ធផល នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្នុងឃុំ សង្កាត់ ( ទម្រង់លេខ ១០១២ ) រាល់លិខិតបញ្ជាក់សុពលភាព នៃការប្រើប្រាស់សម្ភារៈឯកសារបំរុងដែលផ្គត់ផ្គង់បន្ថែម ( ទម្រង់ ១០១៥ ) ដែលមាននៅក្នុងកញ្ចប់ " ខ១ " ឬដែលលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតផ្ញើមក ដោយឡែកក្នុងមួយមុខមួយច្បាប់ រួចប្រគល់ឱ្យផ្នែកប្រតិបត្តិការ ។

៤.២៨.៦.៣ ដកយកស្រោមសំបុត្រ ដាក់សេចក្តីសំរេចបដិសេធការសុំចុះឈ្មោះ ( ទម្រង់ ១០០៩ ) បណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះ ( ទម្រង់ ១២០២ ) ដែលដាក់ក្រោយពេលកំណត់ និងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បដិសេធបណ្តឹងតវ៉ាសុំចុះឈ្មោះ ( ទម្រង់ ១២០៣ ) រួចប្រគល់ជូននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ។

៤.២៨.៦.៤ ដាក់កញ្ចប់និងស្រោមសំបុត្រដាក់សំភារៈឯកសារ ដូចចែងក្នុងចំណុច ៤.២៨.៦.១ ខាងលើ ដែលនៅសល់ទៅក្នុងកញ្ចប់ " ខ១ " វិញ ដាក់ទម្រង់បែបបទលេខ ១០១៣ ដែលបានចុះហត្ថលេខារួចមួយច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ១ " និងត្រូវយកទៅរក្សាទុកក្នុងបន្ទប់ស្តុកសម្ភារៈឯកសារ តាមលំដាប់លេខកូដឃុំ សង្កាត់ និងតាមខេត្ត ក្រុងដោយឡែកពីគ្នា ។

៤.២៨.៦.៥ បើកកញ្ចប់ " ខ " ផ្សេងទៀតនៃឃុំ សង្កាត់ដែលកញ្ចប់ " ខ១ " នៃឃុំ សង្កាត់នោះត្រូវបានបើកផ្ទៀងផ្ទាត់រួចហើយ ដោយបើកម្តងមួយៗតាមលំដាប់លំដោយ ។ ផ្ទៀងផ្ទាត់កញ្ចប់ " ក " ទាំងអស់

ជាមួយនឹងទម្រង់បែបបទលេខ ១០១៣ ដែលមានមួយច្បាប់នៅក្នុងកញ្ចប់ " ខ " និងមួយច្បាប់ទៀតនៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " រួចចុះហត្ថលេខាលើទម្រង់បែបបទលេខ ១០១៣ ទាំងពីរច្បាប់ ដែលក្នុងនេះ ត្រូវចងក្រងមួយច្បាប់ទុកជាឯកសារ ។

៤.២៨.៦.៦ ដកយកកញ្ចប់ " ក " ម្តងមួយៗពីក្នុងកញ្ចប់ " ខ " មកកត់ត្រាក្នុងបញ្ជីនូវលេខកូដការិយាល័យបោះឆ្នោត ដែលមានសរសេរសំគាល់លើកញ្ចប់ " ក " នីមួយៗ រួចដកយករបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត ( ទម្រង់លេខ ១០១១ ) ដែលកិបភ្ជាប់នឹងផ្នែកខាងក្រៅនៃកញ្ចប់ " ក " រួចប្រគល់ជូនផ្នែកប្រតិបត្តិការ ។ បន្ទាប់មកត្រូវយកកញ្ចប់ " ក " ទៅរក្សាទុកក្នុងបន្ទប់ស្តុកសម្ភារៈឯកសារតាមលំដាប់លេខកូដនៃការិយាល័យបោះឆ្នោត តាមឃុំ សង្កាត់ និងតាមខេត្ត ក្រុង ដោយឡែកពីគ្នា ។

៤.២៨.៦.៧ ចាត់ចែងការផ្ទៀងផ្ទាត់រាល់សំភារៈឯកសារក្នុងកញ្ចប់ " ក " នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ដូចចែងក្នុងចំណុច ៤.២៨.៦.៦ ខាងលើ ជាមួយនឹងរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត ( ទម្រង់លេខ ១០១១ ) ដែលមានមួយច្បាប់ក្នុងកញ្ចប់ " ក " និងជាមួយសំភារៈឯកសារក្នុងកញ្ចប់ " ខ១ " ដូចចែងក្នុងចំណុច ៤.២៨.៦.៤ ខាងលើ ដើម្បីឱ្យប្រាកដថា ពិតជាមានលក្ខណៈត្រឹមត្រូវមែន ។

៤.២៨.៦.៨ រៀបចំត្រៀមបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពរួច និងឯកសារពាក់ព័ន្ធមានក្នុងកញ្ចប់ " ក " នីមួយៗ និងសំភារៈឯកសារមានក្នុងកញ្ចប់ " ខ១ " នៃឃុំ សង្កាត់ពាក់ព័ន្ធ សម្រាប់ប្រគល់ទៅឱ្យការិយាល័យគ្រប់គ្រងនិងបញ្ចូលទិន្នន័យ ដែលនៅទីនោះ ការីកំព្យូទ័រនឹងធ្វើបច្ចុប្បន្នភាពលើទិន្នន័យបញ្ជីបោះឆ្នោតចុងក្រោយ នៃការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ដែលមានស្រាប់ក្នុងកុំព្យូទ័រ ឬ/និងបញ្ចូលទិន្នន័យ និងឈ្មោះអ្នកបោះឆ្នោតថ្មីក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតបង្កើតថ្មី ។

៤.២៨.៧ នៅក្នុងដំណើរការធ្វើបច្ចុប្បន្នភាពទិន្នន័យបញ្ជីបោះឆ្នោត តាមការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ដោយកុំព្យូទ័រ ដូចចែងក្នុងចំណុច ៤.២៨.៦.៤ ខាងលើ ការិយាល័យគ្រប់គ្រងនិងបញ្ចូលទិន្នន័យ ដែលរួមមានការីកំព្យូទ័រជាកំលាំងសំខាន់ ត្រូវទទួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារតាមតួនាទីភារកិច្ច និងនិយាមកំណត់ ព្រមទាំងត្រូវអនុវត្តឱ្យបានល្អតាមបទបញ្ជាផ្ទៃក្នុង និង នីតិវិធីរបស់មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ។ ក្នុងនោះ ត្រូវធានាថា ៖

៤.២៨.៧.១ បញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗក្នុងកំព្យូទ័រ ត្រូវតែបានរៀបចំក្នុងទម្រង់ឯកភាពគ្នាតែមួយដែលរួមមាន ៖ ឈ្មោះ និងលេខកូដខេត្ត ក្រុង ឈ្មោះនិងលេខកូដឃុំ សង្កាត់ ឈ្មោះទីតាំងនិងលេខកូដការិយាល័យបោះឆ្នោត កូនប្រអប់សម្រាប់គូសសំគាល់លេខរៀងនៃឈ្មោះក្នុងបញ្ជី លេខសំគាល់ផ្ទាល់ខ្លួន ( លេខប័ណ្ណឬលេខបង្កាន់ដៃចុះឈ្មោះ ) នាមត្រកូល និងនាមខ្លួនដែលរៀបចំតាមអក្ខរក្រមខ្មែរ ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋានក្នុងឃុំ សង្កាត់នៃអ្នកបោះឆ្នោត និងប្រឡោះទំនេរសម្រាប់ចារសម្គាល់ផ្សេងៗ ។

៤.២៨.៧.២ នៅគ្រប់ទំព័រ នៃបញ្ជីបោះឆ្នោត តាមការិយាល័យបោះឆ្នោតនីមួយៗត្រូវមានបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតផ្លូវការ ហើយនៅទំព័រចុងក្រោយរបស់បញ្ជីបោះឆ្នោត ត្រូវរៀបចំឱ្យមានប្រឡោះសម្រាប់ចុះហត្ថលេខាកាលបរិច្ឆេទ និងបោះត្រា គជប ។ នៅគ្រប់ទំព័រផ្សេងទៀតនៃបញ្ជីបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតនីមួយៗ ក៏ត្រូវមានបោះត្រា គជប ផងដែរ ។

៤.២៨.៧.៣ អ្នកបោះឆ្នោតណា ដែលឈ្មោះរបស់គាត់នៅលើបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតដែលទើបបានធ្វើបច្ចុប្បន្នភាពរួច ត្រូវបានគេគូសបន្ទាត់លុបចោលដោយសារមូលហេតុ ៖ ស្លាប់ ឬបាត់បង់សិទ្ធិបោះឆ្នោត ឬផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ ឬគ្មានទីលំនៅអចិន្ត្រៃយ៍ឬបណ្តោះអាសន្នក្នុងឃុំ សង្កាត់ ឬមានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់តែមួយ ឬការិយាល័យផ្សេងគ្នាក្នុងឃុំ សង្កាត់ផ្សេង ឬប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់តែមួយ ដូចចែងក្រោមប្រការ ៤.១៤ ខាងលើ ។ ក្នុងករណីនេះ ការីកំព្យូទ័រត្រូវពិនិត្យផ្ទៀងផ្ទាត់បន្ថែម នូវទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ទម្រង់លេខ ១០១៦ ឬ ១០១៧ ) និងបែបបទឯកសារ

ដែលមានការបញ្ជាក់ឯកភាពពីអាជ្ញាធរឃុំ សង្កាត់ ដោយអនុវត្តតាមការណែនាំរបស់ គជប ។

៩.២៨.៧.៤ លុបឈ្មោះអ្នកបោះឆ្នោត ដែលធ្លាប់បានចុះឈ្មោះចុងក្រោយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយ ក្នុងឃុំ សង្កាត់ផ្សេង ប៉ុន្តែអ្នកបោះឆ្នោតនោះបានផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ថ្មី និងបានសុំចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យថ្មីរួចហើយ ដូចចែងក្រោមចំណុច ៦.១៩.៩ ខាងលើ ។ ក្នុងករណីនេះ ការីកុំព្យូទ័រត្រូវផ្អែកទាំងស្រុង លើទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ទម្រង់លេខ ១០១៧ ) ដែលក្នុងនោះ អ្នកបោះឆ្នោតនោះបានផ្តល់លេខកូដការិយាល័យបោះឆ្នោត ឃុំ សង្កាត់ និងខេត្ត ក្រុង និងផ្តិតមេដៃ ជាសំអាងស្រាប់ ។

៩.២៨.៧.៥ រក្សាឈ្មោះអ្នកបោះឆ្នោតណា ដែលឈ្មោះរបស់គាត់មាននៅលើបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោត ដែលទើបបានធ្វើបច្ចុប្បន្នភាពរួច ហើយដែលពុំត្រូវបានស្មៀនឃុំ សង្កាត់គូសបន្ទាត់លុបចេញពីបញ្ជីបោះឆ្នោតពាក់ព័ន្ធនោះ ។

៩.២៨.៧.៦ កែតម្រូវឈ្មោះ ឬ/និង ទិន្នន័យពាក់ព័ន្ធឱ្យបានត្រឹមត្រូវ ដោយផ្អែកតាមកំណែប៊ិចក្រហម ដែលស្មៀនឃុំ សង្កាត់បានកែតម្រូវនៅលើបញ្ជីបោះឆ្នោត ដែលទើបបានធ្វើបច្ចុប្បន្នភាពរួច ដូចចែងក្នុងជំហានទី១ ក្រោមប្រការ ៩.១១ ខាងលើ និងដោយផ្អែកតាមសេចក្តីសំរេចរបស់ស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹងនៅគ្រប់លំដាប់ថ្នាក់ ដែលបានយល់ព្រមតាមបណ្តឹងតវ៉ា ដែលអនុញ្ញាតឱ្យកែតម្រូវឈ្មោះ ឬ/និងទិន្នន័យពាក់ព័ន្ធ ។

៩.២៨.៧.៧ វាយបញ្ចូលឈ្មោះនិងទិន្នន័យថ្មីបន្ថែម ចំពោះអ្នកបោះឆ្នោតណាដែលត្រូវបានយល់ព្រមចុះឈ្មោះ នៅលើបញ្ជីបោះឆ្នោតបន្ថែម ដូចចែងក្នុងជំហានទី៦ ក្រោមប្រការ ៩.១១ ខាងលើ ហើយដែលត្រូវបានដាក់ភ្ជាប់នឹងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ដែលទើបបានធ្វើបច្ចុប្បន្នភាពរួច ឬ/និងនៅលើបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដែលបានបង្កើតថ្មី ។ ក្នុងករណីនេះ ប្រសិនបើចាំបាច់ ការីកុំព្យូទ័រអាចពិនិត្យបន្ថែម នូវគល់សន្លឹកទម្រង់បែបបទចុះឈ្មោះ / បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលដាក់រួមគ្នាក្នុងកញ្ចប់មួយដោយឡែកសម្រាប់ឃុំ សង្កាត់ ។

៩.២៨.៧.៤ រាយបញ្ចូលឈ្មោះនិងទិន្នន័យថ្មីបន្ថែម ចំពោះអ្នកបោះឆ្នោតណាដែល ដែលបានប្ដឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត និង ត្រូវបានការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬសវនាការ របស់ គជប ឬសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចយល់ ព្រមឱ្យចុះឈ្មោះរបស់គាត់ ក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះ ឆ្នោតពាក់ព័ន្ធ ។ ក្នុងករណីនេះ ប្រសិនបើចាំបាច់ ការីកុំព្យូទ័រអាច ពិនិត្យផ្ទៀងផ្ទាត់បន្ថែមនូវសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ គជប ឬ ក្រុមប្រឹក្សាធម្មនុញ្ញដែលបានដោះស្រាយបណ្ដឹងតវ៉ា របស់សាមីជន ។

៩.២៨.៨ នៅក្នុងដំណើរការធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោត តាមការិយាល័យបោះ ឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ ដោយកុំព្យូទ័រ ប្រសិនបើមជ្ឈមណ្ឌលកុំព្យូទ័របាន រកឃើញមានកំហុស ដែលបណ្ដាលមកពីករណីប្រើប្រព័ន្ធលេខកូដ ឬករណីចុះ ឈ្មោះបោះឆ្នោតពីរដង ឬករណីមានភាពខុសគ្នារវាងចំនួនអ្នកបោះឆ្នោតដែលមាន ឈ្មោះក្នុងបញ្ជីបោះឆ្នោត និងចំនួនអ្នកបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាពទិន្នន័យ ក្នុងកុំព្យូទ័រនោះ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវ ៖

៩.២៨.៨.១ ផ្ទៀងផ្ទាត់ទិន្នន័យក្នុងកំព្យូទ័រ ទៅនឹងបញ្ជីបោះឆ្នោត ដែលបានធ្វើ បច្ចុប្បន្នភាពរួច និងឯកសារពាក់ព័ន្ធនៃការិយាល័យបោះឆ្នោតដែល បានសម្គាល់ថា មានកំហុស ដើម្បីកំណត់ថា តើភាពខុសគ្នានោះ កើតឡើងដោយសារកំហុសបច្ចេកទេស ឬយ៉ាងណា ។

៩.២៨.៨.២ កែតម្រូវជាបន្ទាន់ ប្រសិនបើកំហុសនោះជាកំហុសបច្ចេកទេស ។

៩.២៨.៨.៣ រាយការណ៍ និងស្នើសុំការណែនាំពី គជប ជាបន្ទាន់ និងជាប្រចាំ ប្រសិនបើ ភាពខុសគ្នានៅតែមាន ។

៩.២៨.៨.៤ រាយការណ៍ជូន គជប ជាបន្ទាន់ អំពីភាពមិនប្រក្រតីនៃដំណើរការ កុំព្យូទ័រកម្ម ប្រសិនបើមាន ។

**ការផ្ទេរឈ្មោះរបស់បេក្ខជន សហព័ទ្ធ និងកូន ពីបញ្ជីបោះឆ្នោតដើមដែលបានចុះឈ្មោះហើយ ទៅបញ្ជីបោះ ឆ្នោតនៃការិយាល័យក្នុងមណ្ឌលដែលបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់ឆ្នាំមានការរៀបចំការបោះឆ្នោត**

**ប្រការ៩.២៩** បេក្ខជននៃគណបក្សនយោបាយដែលបានយល់ព្រមឱ្យឈរឈ្មោះបោះឆ្នោត ក្នុងមណ្ឌលខេត្ត ក្រុងណាមួយ មានសិទ្ធិស្នើសុំផ្ទេរឈ្មោះបោះឆ្នោតរបស់ខ្លួន សហព័ទ្ធ និងកូនដែលបានចុះ

ឈ្មោះបោះឆ្នោតរួចហើយ ទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយនៃមណ្ឌល ខេត្ត ក្រុង ដែលបេក្ខជននោះឈរឈ្មោះបោះឆ្នោត ។ នៅក្រោយពេលដែល គជប បាន ផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រសិនបើ មានសំណើរបស់បេក្ខជននៃគណបក្សនយោបាយ ឈរឈ្មោះបោះឆ្នោត សុំឱ្យផ្ទេរឈ្មោះខ្លួន សហព័ទ្ធ និងកូន ពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនៅមណ្ឌលផ្សេង ទៅបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនៅមណ្ឌលដែលខ្លួនបានឈរឈ្មោះ គជប ត្រូវដោះស្រាយនិងកែសម្រួលបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធតាមសំណើសុំ ។

៤.២៩.១ បេក្ខជនឈរឈ្មោះបោះឆ្នោតត្រូវដាក់លិខិតស្នើសុំ ដូចចែងក្នុងប្រការ ៤.២៩ មក គជប ក្នុងរយៈពេលគិតចាប់ពីរយៈពេលមួយសប្តាហ៍ ក្រោយថ្ងៃប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំ រហូតដល់រយៈពេលមួយ(១)ថ្ងៃ មុនថ្ងៃចាប់ឆ្នោតជ្រើសរើសលេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ។

៤.២៩.១.១ ការស្នើសុំនេះ ត្រូវតែមានការយល់ព្រមពីសហព័ទ្ធ និងកូនរបស់បេក្ខជនដោយផ្ទាល់ ។

៤.២៩.១.២ ការស្នើសុំនេះ ត្រូវតែមានភ្ជាប់ជាមួយ នូវបញ្ជីរាយនាមបេក្ខជន សហព័ទ្ធ និងកូនដែលត្រូវសុំផ្ទេរឈ្មោះ ដោយត្រូវមានបញ្ជាក់ច្បាស់អំពីលេខកូដ និងទីតាំងការិយាល័យបោះឆ្នោត ដែលពួកគាត់បានចុះឈ្មោះបោះឆ្នោត និងដាក់ភ្ជាប់មកជាមួយ នូវច្បាប់ចម្លងឯកសារបញ្ជាក់អត្តសញ្ញាណស្របច្បាប់របស់សាមីខ្លួនផង ។

៤.២៩.២ គជប ត្រូវដោះស្រាយតាមសំណើសុំដោយត្រូវផ្ទេរឈ្មោះបេក្ខជន សហព័ទ្ធ និងកូនរបស់បេក្ខជនបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងមណ្ឌលខេត្ត ក្រុងដែលបេក្ខជនឈរឈ្មោះ និងត្រូវលុបឈ្មោះអ្នកទាំងនោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដើម អនុលោមតាមមាត្រា ៥១ថ្មី នៃច្បាប់បោះឆ្នោត ។ គជប ត្រូវបង្គាប់នាយកដ្ឋានប្រតិបត្តិការ ( ផ្នែកប្រតិបត្តិការនិងមជ្ឈមណ្ឌលកុំព្យូទ័រ ) ឱ្យកែតម្រូវចំនួនអ្នកបោះឆ្នោត និងឱ្យលុបឈ្មោះចេញ ឬចុះឈ្មោះបន្ថែមក្នុងបញ្ជីបោះឆ្នោតពាក់ព័ន្ធ នៅមុនពេលត្រូវបោះពុម្ព សម្រាប់បញ្ជូនទៅអាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីចាត់ចែងប្រើប្រាស់ក្នុងការបោះឆ្នោត ។ គជប ត្រូវធានាថា ការបញ្ចូលឈ្មោះបេក្ខជន សហព័ទ្ធ និងកូនដែលបានសុំផ្ទេរទៅក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យថ្មី មិនត្រូវឱ្យចំនួនអ្នកបោះឆ្នោតសរុបក្នុងការិយាល័យនោះមានលើសពីប្រាំពីររយ( ៧០០ )នាក់ឡើយ ។

៩.២៩.៣ ផ្អែកតាមសេចក្តីសំរេចរបស់ គជប ដូចចែងក្នុងប្រការ ៩.២៩.២ ខាងលើ នាយកដ្ឋានប្រតិបត្តិការត្រូវ ៖

៩.២៩.៣.១ ចាត់ចែងឱ្យបញ្ចូលឈ្មោះបេក្ខជន សហព័ទ្ធ និងកូន ដែលបានស្នើសុំផ្ទេរ ទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ក្នុងមណ្ឌលខេត្ត ក្រុងដែលបេក្ខជនឈរឈ្មោះជាបន្ទាន់ តាមសំណើសុំ ។

៩.២៩.៣.២ ចាត់ចែងឱ្យលុបឈ្មោះបេក្ខជន សហព័ទ្ធ និងកូន ដែលបានស្នើសុំផ្ទេរចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដើម ដែលបានចុះឈ្មោះបោះឆ្នោតពីមុន ។

៩.២៩.៣.៣ ធានាថា កិច្ចការដូចចែងក្នុងចំណុច ៩.២៩.៣.១ និង ៩.២៩.៣.២ ខាងលើ ត្រូវតែបានអនុវត្តមុនពេលត្រូវបោះពុម្ព និង វេចខ្ចប់បញ្ជីបោះឆ្នោត សម្រាប់បញ្ជូនទៅអាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីចាត់ចែងប្រើប្រាស់ក្នុងការបោះឆ្នោត ។

៩.២៩.៣.៤ ផ្ញើបញ្ជីឈ្មោះបេក្ខជន សហព័ទ្ធនិងកូន ដែលត្រូវផ្ទេរចូលមួយច្បាប់ជូនក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីធ្វើការកែតម្រូវក្នុងសៀវភៅបញ្ជីបោះឆ្នោតផ្លូវការនៃឃុំ សង្កាត់ ។

៩.២៩.៣.៥ ផ្ញើបញ្ជីឈ្មោះបេក្ខជន សហព័ទ្ធ និងកូន ដែលត្រូវផ្ទេរចេញមួយច្បាប់ ជូនក្រុមប្រឹក្សា / ស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីធ្វើការកែតម្រូវក្នុងសៀវភៅបញ្ជីបោះឆ្នោតផ្លូវការនៃឃុំ សង្កាត់ ។

៩.២៩.៤ ដើម្បីធានាថា ប្រជាពលរដ្ឋម្នាក់ៗ មានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យតែមួយគត់ ក្នុងករណី បេក្ខជន សហព័ទ្ធ និងកូនដែលបានផ្ទេរឈ្មោះបោះឆ្នោតតាមលក្ខខ័ណ្ឌក្រោមចំណុច ៩.២៩.៣ ខាងលើ ប៉ុន្តែបែរជាមានបំណងចង់ចុះឈ្មោះបោះឆ្នោតនៅការិយាល័យបោះឆ្នោតដើម ឬការិយាល័យបោះឆ្នោតផ្សេង ពួកគាត់ត្រូវប្រកាសលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យ ដែលបានផ្ទេរទៅ និងត្រូវទៅបង្ហាញខ្លួនបំពេញបែបបទសុំចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យថ្មី នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

**ការកែតម្រូវបញ្ជីបោះឆ្នោតដំបូង ការរៀបចំ និងការបោះពុម្ព ដើម្បីដាក់ជូន គជប សំរេចផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំ**

**ប្រការ ៩.៣០** បន្ទាប់ពីការប្តឹងតវ៉ា ឬ/និង ការប្តឹងជំទាស់ទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ត្រូវបានដោះស្រាយតាមលំដាប់ថ្នាក់ រួចរាល់ជាស្ថាពរហើយ គជប ត្រូវចាត់ចែងឱ្យមជ្ឈមណ្ឌល

កុំព្យូទ័រកែតម្រូវបញ្ជីបោះឆ្នោត ដោយផ្អែកលើរាល់សេចក្ដីសំរេចដោះស្រាយបណ្ដឹងតវ៉ា ឬ/និង បណ្ដឹងជំទាស់ និងរបាយការណ៍របស់ស្មៀនឃុំ សង្កាត់ដែលបានផ្ញើជូន ដូចចែងក្នុងចំណុច ៤.២៧.១០ ខាងលើ ។ មជ្ឈមណ្ឌលកុំព្យូទ័រត្រូវរៀបចំ និង បោះពុម្ពបញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ រួចដាក់ជូន គជប ចុះហត្ថលេខា កាលបរិច្ឆេទនិងបោះត្រា ផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំ ។

៤.៣០.១ ផ្អែកលើរបាយការណ៍សរុបស្ដីពីការកែតម្រូវលើបញ្ជីបោះឆ្នោតដំបូង ដែលស្មៀនឃុំ សង្កាត់បានបំពេញ ដោយផ្អែកលើសេចក្ដីសំរេចដោះស្រាយបណ្ដឹងតវ៉ាឬ/និង បណ្ដឹងជំទាស់នៅគ្រប់លំដាប់ថ្នាក់ ដែលតម្រូវឱ្យកែប្រែបញ្ជីបោះឆ្នោតតាមករណីនីមួយៗ និងដែលបានស្រង់កត់ត្រាជាបណ្ដើរៗ ដូចចែងក្នុងចំណុច ៤.២៥.១៧ ៤.២៥.២០ ៤.២៦.៩ ៤.២៦.១២ ៤.២៧.៤.៥ និង ៤.២៧.៩.៣ ខាងលើ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវចាត់ចែងកែតម្រូវជាបន្ទាន់ លើទិន្នន័យបញ្ជីបោះឆ្នោតដំបូង នៃការិយាល័យបោះឆ្នោតនីមួយៗ ដែលមានស្រាប់ក្នុងប្រព័ន្ធកុំព្យូទ័រ ។ ក្នុងនោះ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវធានាថា ផ្អែកលើរបាយការណ៍ឯកសារខាងលើ និងរាល់សេចក្ដីសំរេចដោះស្រាយបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) និងទម្រង់បែបបទលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ( ទម្រង់លេខ ១០១៦ ) ការីកុំព្យូទ័របានកែតម្រូវទិន្នន័យបញ្ជីបោះឆ្នោតដំបូងក្នុងកុំព្យូទ័រ ដោយត្រូវ ៖

៤.៣០.១.១ កែតម្រូវឈ្មោះអ្នកបោះឆ្នោត ឬទិន្នន័យពាក់ព័ន្ធ ក្នុងបញ្ជីបោះឆ្នោតដំបូង ក្នុងករណីដែលការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ សវនាការរបស់ គជប ឬ សវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បានសំរេចយល់ព្រមលើពាក្យបណ្ដឹងតវ៉ាសុំកែតម្រូវឈ្មោះ ឬ ទិន្នន័យពាក់ព័ន្ធ ។

៤.៣០.១.២ បញ្ចូលឈ្មោះអ្នកបោះឆ្នោតបន្ថែម ក្នុងបញ្ជីបោះឆ្នោតដំបូង ដោយផ្អែកលើសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ គជប ឬ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានយល់ព្រម លើពាក្យបណ្ដឹងតវ៉ាសុំបញ្ចូលឈ្មោះអ្នកបោះឆ្នោតឡើងវិញ ក្នុងករណីគាត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយដែលបានបិទផ្សាយ ឬបានចុះឈ្មោះបោះឆ្នោតត្រឹមត្រូវហើយ ប៉ុន្តែ បែរជាបាត់ឈ្មោះ / គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ឬអ្នកត្រូវគេប្ដឹងជំទាស់ដែលបានឈ្នះការប្ដឹងតវ៉ា ។

៤.៣០.១.៣ លុបចេញពីបញ្ជីបោះឆ្នោតដំបូង នូវឈ្មោះអ្នកត្រូវគេប្តឹងជំទាស់ណា ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ ឬ គជប ឬ ក្រុមប្រឹក្សាធម្មនុញ្ញសំរេចយល់ព្រមលើពាក្យបណ្តឹងជំទាស់ របស់អ្នកដទៃ ឬបដិសេធលើពាក្យបណ្តឹងតវ៉ារបស់ខ្លួន ទាក់ទងទៅនឹងឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូង ។

៤.៣០.១.៤ លុបចេញពីបញ្ជីបោះឆ្នោតដំបូង នូវឈ្មោះអ្នកបោះឆ្នោតណា ដែលបានស្លាប់ ឬផ្លាស់ទីលំនៅចេញ ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល ឬត្រូវកាត់ទោសជាប់ពន្ធនាគារ ក្នុងចន្លោះពេលក្រោយការបិទបញ្ជីបោះឆ្នោតដំបូង ។

៤.៣០.១.៥ លុបចេញពីបញ្ជីបោះឆ្នោតដំបូងតាមសេចក្តីសំរេចរបស់ គជប នូវឈ្មោះជនណា ដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដែលបានរកឃើញភស្តុតាងបញ្ជាក់ថា មានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតលើសពីមួយកន្លែង ។

៤.៣០.២ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ត្រូវរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រនូវបញ្ជីបោះឆ្នោតផ្លូវការតាមការិយាល័យបោះឆ្នោតនីមួយៗ ក្នុងទម្រង់ឯកភាពគ្នាតែមួយ ដែលក្នុងនោះរួមមាន ៖

៤.៣០.២.១ ឈ្មោះ និងលេខកូដខេត្ត ក្រុង ឈ្មោះ និងលេខកូដឃុំ សង្កាត់ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត ។

៤.៣០.២.២ កូនប្រឡោះតូចសម្រាប់គូសសំគាល់ ។

៤.៣០.២.៣ លេខរៀងនៃឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ។

៤.៣០.២.៤ លេខសំគាល់ផ្ទាល់ខ្លួននៃអ្នកបោះឆ្នោត ( លេខប័ណ្ណ ឬលេខបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ) ។

៤.៣០.២.៥ នាមត្រកូល និងនាមខ្លួន (រៀបចំតាមអក្ខរក្រមខ្មែរ) ភេទ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានក្នុងឃុំ សង្កាត់នៃអ្នកបោះឆ្នោត ។

៤.៣០.២.៦ ចន្លោះទំនេរសម្រាប់ចារសម្គាល់ផ្សេងៗ ។

៤.៣០.២.៧ ការបញ្ជាក់ចំនួនអ្នកបោះឆ្នោតសរុបក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនីមួយៗ ។

៤.៣០.២.៨ ការបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតផ្លូវការ នៅគ្រប់ទំព័រ ។

៤.៣០.២.៩ ចន្លោះបំរុងទុកសម្រាប់ការចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប នៅលើទំព័រចុងក្រោយ ។

៤.៣០.៣ នាយកដ្ឋានប្រតិបត្តិការ ( មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ) ត្រូវធានាថា សេចក្តីព្រាងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតទាំងអស់ ក្នុងទម្រង់ឯកភាពតែមួយ ដែលបានពិនិត្យកែតម្រូវរួចក្នុងកុំព្យូទ័រ ត្រូវតែបានបោះពុម្ពដោយឡែកពីគ្នាតាមការិយាល័យបោះឆ្នោតនីមួយៗ និងដាក់ជូន គជប ពិនិត្យសម្រេច ។

៤.៣០.៣.១ បញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ៤.៣០.២ និង ៤.៣០.៣ ត្រូវតែបានដាក់ជូន គជប ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា បញ្ជាក់ថា ជាបញ្ជីបោះឆ្នោតផ្លូវការ នៅលើទំព័រចុងក្រោយ ។ ដោយឡែក នៅគ្រប់ទំព័រផ្សេងទៀត នៃបញ្ជីបោះឆ្នោតផ្លូវការនេះ ក្រៅពីទំព័រចុងក្រោយ ត្រូវតែមានបោះត្រារបស់ គជប ។

៤.៣០.៣.២ ច្បាប់ដើមនៃបញ្ជីបោះឆ្នោតផ្លូវការ តាមការិយាល័យបោះឆ្នោតមួយច្បាប់ៗ ត្រូវរក្សាទុកជាឯកសារនៅមជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប ។

៤.៣០.៣.៣ សម្រាប់ឆ្នាំដែលគ្មានការរៀបចំការបោះឆ្នោត បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ៤.៣០.៣.២ ត្រូវតែបានថតចម្លងបន្ថែមចំនួនមួយ(២)ច្បាប់ ដែលត្រូវរៀបចំតាមលំដាប់លេខកូដនៃការិយាល័យបោះឆ្នោតក្នុងឃុំសង្កាត់នីមួយៗ និងវេចខ្ចប់បញ្ជូនទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតមួយច្បាប់ និងក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់មួយច្បាប់ ដើម្បីរក្សាទុកជាសៀវភៅបញ្ជីបោះឆ្នោតអចិន្ត្រៃយ៍នៃឃុំ សង្កាត់ សម្រាប់ជាកម្មវត្ថុបំរើសាធារណជន ។

៤.៣០.៣.៤ សម្រាប់ឆ្នាំដែលមានការរៀបចំការបោះឆ្នោត បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ៤.៣០.៣.២ ត្រូវតែបានថតចម្លងបន្ថែមចំនួនប្រាំ(៥)ច្បាប់ទៀត ដែលត្រូវរៀបចំតាមលំដាប់លេខកូដនៃការិយាល័យបោះឆ្នោត ក្នុងឃុំសង្កាត់នីមួយៗ និងវេចខ្ចប់ដោយឡែកពីគ្នាតាមឃុំ សង្កាត់ និងខេត្ត ក្រុង ។ ក្នុងការវេចខ្ចប់បញ្ជីបោះឆ្នោតផ្លូវការនេះ ត្រូវតែត្រៀមលក្ខណសម្បត្តិសម្រាប់បែងចែកជាស្រេចឱ្យដល់ គខ/កប មួយច្បាប់ ក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់មួយច្បាប់ គឃ/សប មួយច្បាប់ និងការិយាល័យបោះឆ្នោតពីរ(២)ច្បាប់ ។

៤.៣០.៣.៥ រាល់កញ្ចប់បញ្ជីបោះឆ្នោតផ្លូវការ ដែលវេចខ្ចប់និងបញ្ជូនខាងលើនេះ ត្រូវតែមានសរសេរសម្គាល់លេខកូដខេត្ត ក្រុង ឃុំ សង្កាត់ និង ការិយាល័យបោះឆ្នោត ព្រមទាំងគោលដៅដែលត្រូវទទួល និងប្រើប្រាស់បញ្ជីបោះឆ្នោតនោះផង ។

៤.៣០.៤ ចំពោះបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗ ក្នុងខេត្ត ក្រុងដែលត្រូវថតចម្លងនិងបញ្ជូនទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬ គខ/កប ដូចចែងក្នុងចំណុច ៤.៣០.៣.៣ និង ៤.៣០.៣.៤ ខាងលើ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប អាចរៀបចំផ្តល់ជូនដោយផ្ទុកក្នុងថាសទន់ ( CD ) ក៏បាន ។

៤.៣០.៥ គជប ត្រូវធានាថា មជ្ឈមណ្ឌលកុំព្យូទ័រនៃ គជប បានចាត់វិធានការម៉ត់ចត់ក្នុងការថែរក្សាសុវត្ថិភាពបញ្ជីបោះឆ្នោតផ្លូវការ ដូចចែងក្នុងចំណុច ៤.៣០.៣.២ ជាឯកសាររបស់ គជប និង រក្សាសុវត្ថិភាពទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការនេះក្នុងកុំព្យូទ័របានល្អប្រសើរ ដើម្បីត្រៀមសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជារៀងរាល់ឆ្នាំ ។

៤.៣០.៦ បញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំនៃការិយាល័យបោះឆ្នោតនីមួយៗ ដែលត្រូវបានផ្តល់សុពលភាពចុងក្រោយដោយ គជប រួចហើយ អាចនឹងត្រូវដាក់បញ្ចូលគ្នា ដើម្បីបង្កើតបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ថ្នាក់ឃុំ សង្កាត់ ឬថ្នាក់ខេត្ត ក្រុង ឬថ្នាក់ជាតិ ស្របតាមច្បាប់កំណត់ ។

៤.៣០.៧ គណបក្សនយោបាយ និង អង្គការមិនមែនរដ្ឋាភិបាលនានា មានសិទ្ធិស្នើសុំពី គជប នូវច្បាប់ចម្លងនៃបញ្ជីបោះឆ្នោតផ្លូវការមួយច្បាប់ ដោយបង់ថ្លៃ ដែលតម្លៃនេះគិតត្រឹមតម្លៃផលិតតែប៉ុណ្ណោះ ។ ការផ្គត់ផ្គង់ចំពោះការស្នើសុំខាងលើនេះត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់លំដោយនៃការស្នើសុំ ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់កក់ជាមុនស្មើនឹង ១០០ ភាគរយ នៃតម្លៃផលិតផលស្នើសុំ ។

**ប្រការ ៤.៣១** ជំពូកទី ៦ នៃច្បាប់ស្តីពីការបោះឆ្នោត បានបញ្ញត្តិនីតិវិធីនៃការដាក់ពាក្យបណ្តឹង និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ដែលបានចែងលំអិតរួចហើយក្នុងជំពូកទី៤ នៃបទបញ្ជា និងនីតិវិធីរបស់ គជប ។ រាល់ការដាក់ពាក្យបណ្តឹង និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និងការបណ្តឹងជំទាស់ ដែលចែងក្នុងជំពូកទី ៤ នេះ ត្រូវតែអនុវត្តដោយគួបផ្សំផងដែរនូវនីតិវិធីពាក់ព័ន្ធ ដូចមានចែងក្នុងជំពូកទី ៧ នៃបទបញ្ជានិងនីតិវិធីរបស់ គជប ។

# ឧបសម្ព័ន្ធទី ៥

## សេចក្តីសម្រេច

ស្តីពី

## ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ត.រ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៥ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)
- យោងសេចក្តីសម្រេចលេខ ១២.០៩៦/០២ គ.ជ.ប ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- យោងជំពូកទី ៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ប.ន.ព.ច.ឆ) ឆ្នាំ២០០៥
- យោងសេចក្តីណែនាំរួម រវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០១១ សណន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការរៀបចំត្រៀមបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ប.ន.ត.រ) ឆ្នាំ ២០០៨
- យោងសេចក្តីណែនាំរួម រវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០២៧ សណន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការពង្រឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- យោងសេចក្តីសម្រេច របស់ គ.ជ.ប លេខ ១៣៥៖១១ គ.ជ.ប ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ឱ្យអនុវត្តនីតិវិធីស្តីពីការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់
- យោងសេចក្តីណែនាំរួម រវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០២៣ សណន ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើឱ្យការបោះឆ្នោត
- យោងសេចក្តីសម្រេចអង្គប្រជុំ គ.ជ.ប ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ។

## <u>សម្រេច</u>

**ប្រការ ១** : ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតសម្រាប់ឆ្នាំ២០១១ ចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១១ ដូចបានកំណត់ក្នុងប្រតិទិនភ្ជាប់ជាមួយ ។

**ប្រការ ២** : ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុ ១៨ ឆ្នាំឡើងទៅ គិតដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១២ (កើតមុន ឬត្រឹមថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៤) ដែលមិនទាន់ចុះឈ្មោះបោះឆ្នោត ឬបានផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ មានសិទ្ធិសុំចុះឈ្មោះបោះឆ្នោតក្នុងការិយាល័យណាមួយក្នុងឃុំ សង្កាត់ ដែលខ្លួនកំពុងរស់នៅ ។

**ប្រការ ៣** : ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១ ត្រូវអនុវត្តតាម ប.ន.ព.ច.ឆ លើកលែងតែចំណុចមួយចំនួនដូចខាងក្រោម ដែលត្រូវកែសម្រួល ឬលុបចោល ។

៣.១ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រាប់ឆ្នាំ២០១១ នៅតាមឃុំ សង្កាត់ទូទាំងប្រទេស គិតចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ។

៣.២ ចំនួនបញ្ជីបោះឆ្នោតចុងក្រោយដែល គ.ជ.ប ត្រូវថតចម្លង និងផ្ញើជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន សម្រាប់បម្រើគោលដៅនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដូចចែងក្នុងចំណុច ៤.១.៣ ៤.១.៤ ៤.៥.១.៣ និង ៤.៥.១.៤ នៃ ប.ន.ព.ច.ឆ ត្រូវបានកែសម្រួល ដោយកាត់បន្ថយពីប្រាំមួយ (៦) ច្បាប់ មកនៅត្រឹមពីរ (២) ច្បាប់ ។

៣.៣ ការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ឃុំ សង្កាត់ទើបបង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ត្រូវអនុវត្តតាមនីតិវិធីស្តីពីការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ។

៣.៤ នៅពេលចុះឈ្មោះអ្នកបោះឆ្នោតថ្មី ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យអ្នកបោះឆ្នោត ស្មៀនឃុំ សង្កាត់ត្រូវចុះលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកបោះឆ្នោតនោះទៅក្នុងគល់ និងចុងសន្លឹកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ចំពោះអ្នកសុំចុះឈ្មោះថ្មី) និងទៅក្នុងគល់ និងចុងសន្លឹកបង្កាន់ដៃបញ្ជាក់ការសុំកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ (ចំពោះអ្នកសុំកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ) ។

៣.៥ បញ្ជីបោះឆ្នោតបន្ថែមអាចសរសេរដោយដៃ ឬដោយកុំព្យូទ័រ (ចំពោះឃុំ សង្កាត់ណាដែលអាចធ្វើទៅបាន) ។

៣.៦ ស្មៀនឃុំ សង្កាត់ត្រូវចារបញ្ជាក់នៅលើសន្លឹកចុងក្រោយបង្អស់នៃបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពរួច នូវចំនួនសរុបនៃឈ្មោះអ្នកបោះឆ្នោតដែលត្រូវលុប ចំនួន សរុបនៃឈ្មោះអ្នកបោះឆ្នោត ដែលត្រូវរក្សាទុកក្នុងបញ្ជីបោះឆ្នោត ចំនួនសន្លឹកនៃបញ្ជីបោះឆ្នោតបន្ថែម ដែលត្រូវដាក់ភ្ជាប់មកជាមួយ និងត្រូវដាក់លេខទូរស័ព្ទរបស់ខ្លួន (ប្រសិនបើមាន) ដើម្បីងាយស្រួលក្នុងការធ្វើទំនាក់ទំនងដោយផ្ទាល់ ។

៣.៧ លធ/ខប ត្រូវចាត់វិធានការឱ្យមានប្រសិទ្ធភាព តាមសភាពការណ៍ជាក់ស្តែង ដើម្បីធ្វើការថតចម្លងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនានាក្នុងឃុំ សង្កាត់ចំណុះរាជធានី ខេត្ត

ពាក់ព័ន្ធ ដែលស្មៀនឃុំ សង្កាត់បានធ្វើបច្ចុប្បន្នភាពរួច បន្ថែមចំនួនបី (៣) ច្បាប់ទៀត គម្រប់បួន (៤) ច្បាប់ ដើម្បីប្រើប្រាស់ ទៅតាមការកំណត់ដូចចែងក្នុង ប.ន.ព.ច.ឆ ចំណុច ៤.១.៤.២ និងបិទផ្សាយនៅសាលាឃុំ សង្កាត់ និងនៅទីតាំងណាមួយក្នុងឃុំ សង្កាត់ ជាបញ្ជីបោះឆ្នោតដំបូង ។

៣.៨ ខ្លឹមសារដូចមានក្នុង ប.ន.ព.ច.ឆ ចំណុច ៤.៣.១.៩ ៤.៣.៣.៦ ប្រការ ៤.៣ ចំណុច ៤.៧.២.៣ ប្រការ ៤.៧ ចំណុច ៤.១១.១ ប្រការ ៤.១១ ចំណុច ៤.២៥.៤.១ ប្រការ ៤.២៥ ត្រូវបានកែសម្រួល ដោយលុបចោលពាក្យ " ចល័តការិយាល័យចុះឈ្មោះបោះឆ្នោតទៅតាមមន្ទីរឃុំឃាំង " និងកែសម្រួលពាក្យ " អ្នកដែលត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ឬត្រូវបានសម្រេចព្យួរទោស ដែលមិនទាន់អនុវត្តទោសរួច និងមិនទាន់មាននីតិសម្បទាឡើងវិញ" ជំនួសដោយពាក្យ " អ្នកដែលស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ " ។

៣.៩ ខ្លឹមសារដូចមានក្នុង ប.ន.ព.ច.ឆ ចំណុច ៤.១៩.៦ និង ៤.១៩.៧ ប្រការ ៤.១៩ ត្រូវបានកែសម្រួល ដោយបន្ថែមខ្លឹមសារថា " ទម្រង់បែបបទចុះឈ្មោះ/បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលនៅសល់ ត្រូវរក្សាទុកនៅសាលាឃុំ សង្កាត់ ហើយ លធ ខប ត្រូវត្រួតពិនិត្យជាក់ស្តែងលើរបាយការណ៍របស់ស្មៀនឃុំ សង្កាត់ ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បែបបទចុះឈ្មោះ បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតនេះ ។

៣.១០ ការប្រើប្រាស់កញ្ចប់សុវត្ថិភាព " ក " និងសោឃ្លុំ ត្រូវបានជំនួសដោយការប្រើប្រាស់ " កញ្ចប់ និងខ្សែចងធម្មតា " ។

៣.១១ ការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើឱ្យការបោះឆ្នោត ដើម្បីប្រើក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិដូចមានចែងក្នុងសេចក្តីណែនាំរួម រវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០២៣ សណន ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើឱ្យការបោះឆ្នោត ។

៣.១២ គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិស្នើសុំពី គ.ជ.ប នូវច្បាប់ថតចម្លងនៃបញ្ជីបោះឆ្នោតដំបូង ឬ ផ្លូវការ មួយ (១) ច្បាប់ ដោយបង់ថ្លៃត្រឹមតែតម្លៃផលិត ។

៣.១៣ ការប្តឹងតវ៉ា ឬជំទាស់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ លើបញ្ជីបោះឆ្នោតដំបូងមានរយៈពេល (១០) ថ្ងៃ តាមប្រតិទិនកំណត់ដោយ គ.ជ.ប ។

**ប្រការ ៤** : រាល់ការដាក់ពាក្យបណ្តឹង និងការដោះស្រាយបណ្តឹងតវ៉ា ឬ និងបណ្តឹងជំទាស់ ត្រូវអនុវត្ត តាម ប.ន.ព.ច.ឆ និងនីតិវិធីពាក់ព័ន្ធ ដូចមានចែងក្នុងជំពូកទី ១១ នៃ ប.ន.ត.រ ។

**ប្រការ ៥** : លេខយោង ដូចមានក្រោមចំណុច ៤.២៩.៣ ប្រការ ៤.២៩ នៃ ប.ន.ព.ច.ឆ ត្រូវបាន កែតម្រូវ លេខ ៤.៣០.២ ៤.៣០.៣ ៤.៣០.៣.២ ៤.៣០.៣.៣ និង ៤.៣០.៣.៤ ទៅជា ៤.២៩.២ ៤.២៩.៣ ៤.២៩.៣.២ ៤.២៩.៣.៣ និង ៤.២៩.៣.៤ វិញ ។

**ប្រការ ៦** : រាល់សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ ទុកជានិរាករណ៍ ។

**ប្រការ ៧** : អគ្គលេខាធិការ គ.ជ.ប ប្រធាន លធ/ខប ក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្មៀនឃុំ សង្កាត់ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ។

# ឧបសម្ព័ន្ធទី ៦

## នីតិវិធី

### ស្តីពី

### ការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ឃុំ សង្កាត់បង្កើតថ្មី និង ឃុំ សង្កាត់កែប្រែព្រំប្រទល់

**ប្រការ ១ :** ឃុំ សង្កាត់បង្កើតថ្មី គឺឃុំ សង្កាត់ដែលត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ ឃុំ សង្កាត់កែប្រែព្រំប្រទល់ គឺឃុំ សង្កាត់ដែលត្រូវបានកែប្រែព្រំប្រទល់រដ្ឋបាលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ ឃុំ សង្កាត់ដើម គឺឃុំ សង្កាត់មុនត្រូវបានកែប្រែព្រំប្រទល់ ។

**ប្រការ ២ :** ចំពោះឃុំ សង្កាត់បង្កើតថ្មីដែលត្រូវធ្វើការបោះឆ្នោតឡើងវិញតាមមាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយ ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តតាមជំពូកទី១៤ ស្តីពីការបោះឆ្នោតឡើងវិញនៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ៣ :** ចំពោះឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ដែលពុំស្ថិតក្នុងករណីត្រូវធ្វើការបោះឆ្នោតឡើងវិញ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបន្តស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សានៃឃុំ សង្កាត់ដើម រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**ប្រការ ៤ :** គ.ជ.ប ត្រូវរៀបចំបញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់ កែប្រែព្រំប្រទល់ ដើម្បីប្រើប្រាស់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។

**ប្រការ ៥ :** គ.ជ.ប ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ណែនាំដល់ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ/ខប) ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ពាក់ព័ន្ធទាំងអស់ ដើម្បីផ្តល់កិច្ចសហការ និងការគាំទ្រដល់ការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយនៅឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ តាមករណីដូចចែងក្នុងប្រការ ៤ ខាងលើ ។

**ប្រការ ៦ :** គ.ជ.ប អាចសម្រេចឱ្យជ្រើសរើសមន្ត្រីជំនួយការបន្ថែម តាមការចាំបាច់នៅ លធ/ខប ពាក់ព័ន្ធ ឬ/និង ជំនួយការស្មៀននៃឃុំ សង្កាត់ដើម ។

៦.១ ជំនួយការស្មៀននៃឃុំ សង្កាត់ដើម អាចត្រូវបានជ្រើសរើសឱ្យធ្វើការក្នុងរយៈពេលកំណត់មួយ តាមការសម្រេចរបស់ គ.ជ.ប ដើម្បីបំពេញការងារត្រៀមមុនពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

៦.២ ស្មៀន និងជំនួយការស្មៀននៃឃុំ សង្កាត់ដើម ដែលបំពេញការងារដូចបានកំណត់ក្នុងចំណុច ៦.១ ខាងលើ ត្រូវទទួលបានប្រាក់កម្រៃ តាមការកំណត់ដោយ គ.ជ.ប ។

**ប្រការ ៧ :** ដើម្បីកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតសម្រាប់ឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ សម្រាប់ធ្វើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត លធ/ខប ត្រូវសហការជាមួយក្រុមប្រឹក្សានៃឃុំ សង្កាត់ដើម ដើម្បីត្រួតពិនិត្យពីការប្រែប្រួលការិយាល័យបោះឆ្នោតនៅក្នុងឃុំ សង្កាត់ និងលើកសំណើទៅ គ.ជ.ប ដើម្បីរក្សាទុក ឬផ្លាស់ប្តូរឈ្មោះទីតាំងការិយាល័យបោះឆ្នោត ឬបង្កើតការិយាល័យបោះឆ្នោតថ្មី នៅក្នុងឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ដោយត្រូវផ្អែកលើការិយាល័យបោះឆ្នោតចាស់ និងការប្រែប្រួលភូមិសាស្ត្រ ប្រជាសាស្ត្រ និងព្រំប្រទល់រដ្ឋបាល ដោយត្រូវអនុវត្តតាមចំណុចដូចខាងក្រោម ៖

៧.១ ការិយាល័យបោះឆ្នោតចាស់ ដែលមានទីតាំងនៅក្នុងព្រំប្រទល់នៃឃុំ សង្កាត់បង្កើតថ្មី ឬឃុំ សង្កាត់កែប្រែព្រំប្រទល់ ត្រូវចាត់ទុកជាការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នោះ ។

៧.២ ក្នុងករណីការិយាល័យបោះឆ្នោតចាស់នៅឃុំ សង្កាត់បង្កើតថ្មី ឬនៅឃុំ សង្កាត់កែប្រែព្រំប្រទល់ មានចំនួនតិចមិនសមស្របតាមចំនួនប្រជាពលរដ្ឋដែលត្រូវចុះឈ្មោះបោះឆ្នោត លធ/ខប ត្រូវស្នើសុំទៅ គ.ជ.ប ដើម្បីបង្កើតការិយាល័យបោះឆ្នោតថ្មីតាមចំនួនចាំបាច់ ។

៧.៣ ក្នុងករណីពុំមានការិយាល័យបោះឆ្នោតចាស់នៅឃុំ សង្កាត់បង្កើតថ្មី លធ/ខប ត្រូវស្នើសុំទៅ គ.ជ.ប ដើម្បីបង្កើតការិយាល័យបោះឆ្នោតថ្មីតាមចំនួនចាំបាច់ ។

៧.៤ ចំពោះឃុំ សង្កាត់បង្កើតថ្មី លេខកូដនៃការិយាល័យបោះឆ្នោតចាស់ត្រូវរក្សាទុកដដែល លើកលែងតែការិយាល័យបោះឆ្នោតចាស់នៃឃុំ សង្កាត់បង្កើតថ្មីត្រូវកាត់ចេញពីរាជធានី ខេត្តដើម ។ ក្នុងករណីមានការិយាល័យបោះឆ្នោតចាស់ ត្រូវប្តូរឈ្មោះទីតាំងថ្មី ឈ្មោះទីតាំងការិយាល័យចាស់ត្រូវដាក់ក្នុងរង្វង់ក្រចក ។ ឈ្មោះទីតាំងចាស់នៃការិយាល័យបោះឆ្នោត ដែលនៅក្នុងរង្វង់ក្រចកនឹងត្រូវលុបចេញនៅឆ្នាំបន្ទាប់ ។

៧.៥ គ.ជ.ប ត្រូវសម្រេចជាបន្ទាន់លើការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ផ្អែកតាមសំណើរបស់ លធ/ខប ។

**ប្រការ ៨ :** ការរៀបចំបញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោតចាស់ក្នុងឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ដើម្បីធ្វើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវផ្អែកលើបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងនោះ ដែលត្រូវបាន គ.ជ.ប ផ្តល់សុពលភាពចុងក្រោយ និងត្រូវអនុវត្តតាមជំហានដូចខាងក្រោម ៖

៨.១ នាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវស្រង់ឈ្មោះអ្នកបោះឆ្នោត ដោយផ្អែកលើអាសយដ្ឋានបច្ចុប្បន្ននៃអ្នកបោះឆ្នោត ដែលមានលើបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតចាស់ ក្នុងឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ រួចផ្ទេរដាក់បញ្ចូលឈ្មោះអ្នកបោះឆ្នោតទាំងនោះ ទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតចាស់ក្នុងព្រំប្រទល់ កែប្រែថ្មីនៃឃុំ សង្កាត់ ឱ្យបានត្រឹមត្រូវទៅតាមទីតាំងជាក់ស្តែងនៃអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកបោះឆ្នោតម្នាក់ៗ ដែលត្រូវបានប្រែប្រួលដោយការបង្កើតឃុំ សង្កាត់ថ្មី និងការកែប្រែព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ។

៨.២ ក្នុងការស្រង់ និងផ្ទេរឈ្មោះអ្នកបោះឆ្នោតដូចក្នុងចំណុច ៨.១ ខាងលើ ត្រូវយកចិត្តទុកដាក់ដូចខាងក្រោម :

- ឈ្មោះអ្នកបោះឆ្នោតណាដែលមានអាសយដ្ឋានបច្ចុប្បន្ន លើបញ្ជីបោះឆ្នោតត្រឹមត្រូវក្នុងព្រំប្រទល់កែប្រែថ្មីនៃឃុំ សង្កាត់ ត្រូវរក្សាទុកក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដដែល ។
- ឈ្មោះអ្នកបោះឆ្នោតដែលត្រូវផ្ទេរ ត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណា ដែលមានទីតាំងនៅជិតអាសយដ្ឋានបច្ចុប្បន្ននៃអ្នកបោះឆ្នោត ដែលមានលើបញ្ជីបោះឆ្នោត ។
- ចំនួនអ្នកបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតនីមួយៗ មិនត្រូវឱ្យលើសពីប្រាំពីររយ (៧០០)នាក់។ ក្នុងករណីមានការិយាល័យបោះឆ្នោតណាមួយ ត្រូវបញ្ចូលឈ្មោះអ្នកបោះឆ្នោតលើសពីប្រាំពីររយ (៧០០) នាក់ ត្រូវសុំការសម្រេចពី គ.ជ.ប ដើម្បីបំបែកជាការិយាល័យបោះឆ្នោតភ្លោះ ។
- ក្នុងករណី នៅឃុំ សង្កាត់បង្កើតថ្មីពុំមានការិយាល័យបោះឆ្នោតចាស់ ត្រូវសុំការសម្រេចពី គ.ជ.ប ដើម្បីបញ្ចូលឈ្មោះអ្នកបោះឆ្នោតទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទើបបង្កើតថ្មី ។

៨.៣ ក្នុងដំណាក់កាលត្រៀមរៀបចំមុនពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវបញ្ជូនបញ្ជីបោះឆ្នោតចុងក្រោយ ដែលរៀបចំរួចហើយដោយនាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប និងបញ្ជីបោះឆ្នោតចុងក្រោយនៃឃុំ សង្កាត់ដើម ទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ ។

៨.៤ ដោយមានកិច្ចសហការពី លធ/ខប និងមានស្មៀន និងជំនួយការស្មៀនឃុំ សង្កាត់ជាជំនួយក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់រវាងបញ្ជីបោះឆ្នោតចុងក្រោយទាំងពីរ ដូចមាន

ក្នុងចំណុច ៨.៣ ខាងលើ ដោយផ្អែកលើអាសយដ្ឋានបច្ចុប្បន្ននៃអ្នកបោះឆ្នោត ដែលមានលើបញ្ជីបោះឆ្នោត និងព្រំប្រទល់កែប្រែថ្មីនៃឃុំ សង្កាត់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ។ បន្ទាប់ពីការពិនិត្យផ្ទៀងផ្ទាត់រួច ក្នុងករណីយល់ព្រម ឬមានការកែតម្រូវ មេឃុំ សង្កាត់ ត្រូវធ្វើការបញ្ជាក់លើបញ្ជីបោះឆ្នោតនេះ និងផ្ញើជូន គ.ជ.ប វិញតាមការកំណត់របស់ គ.ជ.ប ។

៨.៥ នាយកដ្ឋានប្រតិបត្តិការ ត្រូវកែតម្រូវបញ្ជីបោះឆ្នោត ដូចក្នុងចំណុច ៨.៤ ខាងលើ និងបោះពុម្ពដើម្បីដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។ បញ្ជីបោះឆ្នោតដែលបានសម្រេចដោយ គ.ជ.ប រួចហើយនេះ ត្រូវបញ្ជូនទៅបិទផ្សាយជាបញ្ជីបោះឆ្នោតចុងក្រោយនៅឃុំ សង្កាត់ដើមទាំងអស់ នៅមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ តាមការសម្រេចរបស់ គ.ជ.ប ។

៨.៦ បញ្ជីបោះឆ្នោតចុងក្រោយនៃការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់បង្កើតថ្មី ត្រូវដាក់ឈ្មោះ និងលេខកូដឃុំ សង្កាត់ថ្មី តាមសេចក្តីសម្រេចរបស់ គ.ជ.ប ។

**ប្រការ ៩ :** ផ្អែកលើបញ្ជីបោះឆ្នោតចុងក្រោយដែលបានសម្រេចដោយ គ.ជ.ប ដូចក្នុងចំណុច ៨.៥ ខាងលើ គ.ជ.ប ត្រូវផលិត និងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ជូនអ្នកបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់បង្កើតថ្មី និងឃុំ សង្កាត់កែប្រែព្រំប្រទល់ ដើម្បីផ្តល់ព័ត៌មាន និងអញ្ជើញអ្នកទាំងនោះ ឱ្យទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

**ប្រការ ១០ :** ក្នុងដំណាក់កាលត្រៀមមុនពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សា និងស្មៀនឃុំ សង្កាត់ដើម ត្រូវអនុវត្តតាមសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប លេខ ០១១ សណន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការរៀបចំត្រៀមបម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងជំពូកទី ៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

**ប្រការ ១១ :** ការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទៅលើបញ្ជីបោះឆ្នោតដំបូង ត្រូវធ្វើទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម ។

**ប្រការ ១២ :** ក្រុមប្រឹក្សា និងស្មៀនឃុំ សង្កាត់ដើម ត្រូវធ្វើរបាយការណ៍ ដាច់ដោយឡែកពីគ្នា ស្តីពីការងារត្រៀមមុនពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងក្រោយពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដើមដែលកែប្រែ និងក្នុងភូមិសាស្ត្រដែលត្រូវកាត់ចេញឃុំ សង្កាត់ដើម រួចហើយ និងផ្ញើជូន គ.ជ.ប តាមរយៈ លធ/ខប ។

# ឧបសម្ព័ន្ធទី ៧

## សេចក្តីណែនាំរួម

## ស្តីពី

## នីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បម្រើឱ្យការបោះឆ្នោត

- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់នេះ
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- យោងសេចក្តីសម្រេចរបស់ គ.ជ.ប លេខ ១២.០៩៦/០២ គ.ជ.ប ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- យោងតាមការចាំបាច់

ដើម្បីធានាដល់សិទ្ធិពលរដ្ឋដែលមានសិទ្ធិក្នុងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ប៉ុន្តែពុំមានឯកសារបញ្ជាក់អត្តសញ្ញាណ និងដើម្បីពង្រឹងការចេញ **លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត** ជូនដល់ប្រជាពលរដ្ឋប្រព្រឹត្តទៅរលូនល្អ ត្រឹមត្រូវ មានគណនេយ្យភាព តម្លាភាព និងជៀសវាងនូវបាតុភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ក្រសួងមហាផ្ទៃនិងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការណែនាំនីតិវិធីអនុវត្តដូចខាងក្រោម ៖

### I. អំពីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

មាត្រា ៥៤ថ្មី (ពីរ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានប្រគល់សិទ្ធិឱ្យមេឃុំ ចៅសង្កាត់ក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត ដែលហៅថាលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ។ លិខិតបញ្ជាក់អត្តសញ្ញាណនេះក៏ត្រូវបានអនុញ្ញាតឱ្យប្រើសម្រាប់ការបោះឆ្នោតផងដែរ ។

លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតត្រូវបានផលិតដោយ គ.ជ.ប ជាទម្រង់បោះពុម្ព ចងជាសៀវភៅបញ្ជី មានគល់បញ្ជី និងចុងសន្លឹក មានលេខរៀង និងមានចំណុចផ្នែកបច្ចេកទេសបង្ការការក្លែងបន្លំ (ឧបសម្ព័ន្ធ ក) ។

លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតជាឯកសារផ្លូវការ ដោយបញ្ជាក់ពីអត្តសញ្ញាណ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់ សម្រាប់បំពេញលក្ខខណ្ឌដើម្បីសុំចុះឈ្មោះបោះឆ្នោត ឬ/និងសម្រាប់បោះឆ្នោត ។

លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតត្រូវមានបិទរូបថតសាមីជន ។

មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិពីមេឃុំ ចៅសង្កាត់ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់មានសមត្ថកិច្ចចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនតាមការស្នើសុំរបស់សាមីខ្លួនដើម្បីយកទៅប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ឬ/និងការបោះឆ្នោត ។

មេឃុំ ចៅសង្កាត់ត្រូវចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតជូនប្រជាពលរដ្ឋក្នុងអំឡុងពេលដូចខាងក្រោម ៖

ទី១-នៅក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត តាមការស្នើសុំរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ដែលពុំមានឯកសារបញ្ជាក់អត្តសញ្ញាណ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់ ដើម្បីបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត និង

ទី២-នៅឆ្នាំដែលមានរៀបចំការបោះឆ្នោតជាសកល នៅក្នុងរយៈពេលចាប់ពី គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត រហូតដល់ម៉ោង ៥:៣០នាទីល្ងាចនៃថ្ងៃសុក្រចុងក្រោយមុនថ្ងៃបោះឆ្នោត តាមការស្នើសុំរបស់ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ប៉ុន្តែបានបាត់បង់ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយសម្រាប់ប្រើក្នុងការបោះឆ្នោត ។

## II. នីតិវិធីនៃការស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

១- ប្រជាពលរដ្ឋ ដែលពុំមានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បំពេញលក្ខខណ្ឌ ក្នុងការចុះឈ្មោះបោះឆ្នោត ឬ/និងបោះឆ្នោត ត្រូវទៅបង្ហាញខ្លួនផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត ក្នុងរយៈពេលដូចបានកំណត់ខាងលើ ដោយត្រូវនាំទៅជាមួយនូវសាក្សីពីរ(២)រូប ដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដើម្បីធានាអះអាងការស្នើសុំរបស់ខ្លួន ។

២- សាក្សីត្រូវមានលក្ខណសម្បត្តិ និងបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានទីលំនៅក្នុងឃុំ សង្កាត់នោះ
- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ឬមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់នោះ
- យល់ព្រមបង្ហាញឯកសារផ្សេងៗដែលអាចសន្និដ្ឋានថា សាក្សីបានចុះឈ្មោះបោះឆ្នោតរួចហើយ ឬមានលក្ខណសម្បត្តិ និងបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់នោះ តាមការទាមទារសុំរបស់មេឃុំ ចៅសង្កាត់
- យល់ព្រមផ្តិតមេដៃធានាអះអាងអំពីអត្តសញ្ញាណ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់របស់អ្នកស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត
- មិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងស្មៀនឃុំ សង្កាត់ ។

៣-អ្នកស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ត្រូវតែភ្ជាប់មកជាមួយនូវរូបថតរបស់ខ្លួនចំនួនពីរ(២)សន្លឹក សម្រាប់បិទនៅផ្នែកខាងលើចំហៀងខាងស្តាំនៃគល់បញ្ជី និងចុងសន្លឹកនៃលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ។ រូបថតត្រូវថតចំពីមុខដែលបង្ហាញមុខ និងស្មា និងដែលអាចបញ្ជាក់អត្តសញ្ញាណរបស់សាមីអ្នកស្នើសុំបានត្រឹមត្រូវ និងច្បាស់លាស់ ។

៤-ក្នុងករណីដែលបាត់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតត្រូវស្នើសុំជាថ្មី តាមបែបបទដូចចែងក្នុងចំណុច៍ នេះ ។

## III. បែបបទ និងនីតិវិធីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ដោយមេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ មានសមត្ថកិច្ចក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនតាមការស្នើសុំរបស់សាមីខ្លួនក្នុងរយៈពេលដូចបានកំណត់ខាងលើ(ចំណុចII) ដោយមិនតម្រូវឱ្យបង់ថ្លៃឡើយ ។

**១-ករណីមេឃុំ ចៅសង្កាត់យល់ព្រមចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**

ក្នុងករណីអ្នកស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតបានបំពេញលក្ខខណ្ឌដូចចែងក្នុងចំណុច II ខាងលើ មេឃុំ ចៅសង្កាត់ត្រូវសួរសាមីអ្នកស្នើសុំ និងសាក្សីនូវព័ត៌មានចាំបាច់ពាក់ព័ន្ធនឹងការស្នើសុំបញ្ជាក់ និងការធានាអះអាង ដែលត្រូវបំពេញក្នុងទម្រង់ ។ ប្រសិនបើអ្នកស្នើសុំ និងសាក្សីផ្តល់ព័ត៌មាន និងការធានាអះអាង គ្រប់គ្រាន់ និងត្រឹមត្រូវ មេឃុំ ចៅសង្កាត់ត្រូវយល់ព្រមចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតជូនអ្នកស្នើសុំដោយត្រូវ ៖

- ក-បំពេញទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតនៅលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ ។
- ខ-បន្ទាប់ពីបំពេញទម្រង់ហើយ ណែនាំឱ្យសាមីអ្នកស្នើសុំ និងសាក្សី ផ្តិតមេដៃបញ្ជាក់ការធានាអះអាងនៅលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ ។
- គ-ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់នៅលើហត្ថលេខារបស់ខ្លួន បោះត្រានៅលើផ្នែកពាក់កណ្តាលខាងក្រោមនៃរូបថតរបស់អ្នកស្នើសុំនៅលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ និងបោះត្រាបន្ថែមនៅចំពាក់កណ្តាលរវាងគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ ។
- ឃ-ហែកផ្តាច់ចុងសន្លឹក ពីគល់បញ្ជីនៃទម្រង់ រួចប្រគល់ចុងសន្លឹកនៃទម្រង់ជូនអ្នកស្នើសុំដោយរក្សាទុកគល់បញ្ជីក្នុងសៀវភៅបញ្ជីនៃទម្រង់ជាឯកសាររបស់ឃុំ សង្កាត់ ។

**២-ករណីមេឃុំ ចៅសង្កាត់មិនយល់ព្រមចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**

ក្នុងករណីអ្នកស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ពុំបានបំពេញលក្ខខណ្ឌដូចចែងក្នុងចំណុចII ខាងលើ ឬប្រសិនបើអ្នកស្នើសុំ និងសាក្សីពុំបានផ្តល់ព័ត៌មាន និងការធានាអះអាង គ្រប់គ្រាន់ និងត្រឹមត្រូវ មេឃុំ

ចៅសង្កាត់ត្រូវបដិសេធដោយផ្ទាល់មាត់លើការស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ។ ក្នុងការបដិសេធ មេឃុំ ចៅសង្កាត់ ត្រូវណែនាំអ្នកស្នើសុំឱ្យបំពេញលក្ខខណ្ឌ និងព័ត៌មានឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវដើម្បីធ្វើការស្នើសុំជាថ្មី ។

**៣- ករណីបំពេញទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតខុស**

មេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់បំពេញទៅលើទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតឱ្យបានច្បាស់ និងត្រឹមត្រូវ។ ករណីបំពេញទម្រង់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតខុស និងមិនអាចចេញឱ្យប្រើប្រាស់បាន មេឃុំ ចៅសង្កាត់ត្រូវគូសខ្វែងលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ និងរក្សាទុកទាំងគល់បញ្ជី និងចុងសន្លឹកដែលខុសនោះនៅក្នុងសៀវភៅបញ្ជី ។

**៤-ការរក្សាសៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**

មេឃុំ ចៅសង្កាត់ត្រូវរក្សាទុកសៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ឱ្យបានល្អប្រកបដោយសុវត្ថិភាពនៅសាលាឃុំ សង្កាត់សម្រាប់ធ្វើការត្រួតពិនិត្យតាមការចាំបាច់។ សៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ បម្រើឱ្យការបោះឆ្នោតដែលត្រូវរក្សាទុកមាន ៖

- សៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតដែលពុំទាន់បានប្រើ
- សៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតដែលប្រើប្រាស់ខ្លះហើយ
- សៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតដែលប្រើប្រាស់អស់ហើយ និងនៅសល់តែគល់បញ្ជីគិតទាំងសន្លឹកទម្រង់ដែលបំពេញខុសផង ( ប្រសិនបើមាន) ។

## IV. ការធ្វើរបាយការណ៍បូកសរុបអំពីការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

មេឃុំ ចៅសង្កាត់ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលអំពីការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ជូនក្រសួងមហាផ្ទៃ និង គ.ជ.ប តាមពេលវេលា និងតាមគំរូរបាយការណ៍ដូចភ្ជាប់មកជាមួយ( ឧបសម្ព័ន្ធទី២) ដូចខាងក្រោម ៖

**១-នៅពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់**

នៅពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់របស់ខ្លួនមេឃុំ ចៅសង្កាត់ត្រូវធ្វើរបាយការណ៍ចំនួនបួន (៤)ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាឃុំ សង្កាត់ មួយ(១)ច្បាប់រក្សាទុកជាឯកសារនៅឃុំ សង្កាត់មួយ(១)ច្បាប់ត្រូវបិទផ្សាយនៅសាលាឃុំ សង្កាត់របស់ខ្លួន មួយ(១)ច្បាប់ផ្ញើជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងមួយ(១)ច្បាប់ទៀតត្រូវផ្ញើជូនលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ/ខប) របស់ខ្លួនជាបន្ទាន់ស្របពេលជាមួយគ្នានិងការបញ្ជូនសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត។

បន្ទាប់ពីបានទទួលរបាយការណ៍ពីឃុំ សង្កាត់ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុបរបាយការណ៍នេះ ក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួន រួចហើយផ្ញើជូនគណៈអភិបាលរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុបរបាយការណ៍ក្នុងរាជធានី ខេត្តរបស់ខ្លួនរួចផ្ញើជូនក្រសួងមហាផ្ទៃ ។

ចំពោះ លធ/ខប បន្ទាប់ពីទទួលបានរបាយការណ៍ពីឃុំ សង្កាត់ត្រូវធ្វើការបូកសរុបរបាយការណ៍នៅក្នុងរាជធានី ខេត្តរបស់ខ្លួនដើម្បីផ្ញើជូន គ.ជ.ប ជាបន្ទាន់ស្របពេលជាមួយគ្នានិងការបញ្ជូនសម្ភារឯកសារចុះឈ្មោះបោះឆ្នោតទៅ គ.ជ.ប ។

**២-នៅមុនថ្ងៃបោះឆ្នោត**

ក្នុងឆ្នាំដែលមានរៀបចំការបោះឆ្នោតជាសកល នៅវេលាម៉ោង ៥:៣០នាទីល្ងាចនៃថ្ងៃសុក្រ ចុងក្រោយមុនថ្ងៃបោះឆ្នោត មេឃុំ ចៅសង្កាត់ត្រូវបញ្ឈប់ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ។ មេឃុំ ចៅសង្កាត់ត្រូវធ្វើរបាយការណ៍ចំនួនប្រាំមួយ(៦)ច្បាប់ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាឃុំ សង្កាត់ មួយ(១)ច្បាប់រក្សាទុកជាឯកសារនៅឃុំ សង្កាត់ មួយ(១)ច្បាប់ ត្រូវបិទផ្សាយនៅសាលាឃុំ សង្កាត់ របស់ខ្លួន មួយ(១)ច្បាប់ត្រូវផ្ញើជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងបី(៣)ច្បាប់ត្រូវផ្ញើជូនគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត (គឃ/សប) នៅក្នុងឃុំ សង្កាត់របស់ខ្លួនជាបន្ទាន់ ។

បន្ទាប់ពីបានទទួលរបាយការណ៍ពីឃុំ សង្កាត់ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុបរបាយការណ៍នេះ ក្នុងក្រុង ស្រុក ខណ្ឌ របស់ខ្លួនរួចហើយផ្ញើជូនគណៈអភិបាលរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុបរបាយការណ៍ក្នុងរាជធានី ខេត្តរបស់ខ្លួនរួចផ្ញើជូនក្រសួងមហាផ្ទៃ ។

ចំពោះ គឃ/សប បន្ទាប់ពីទទួលបានរបាយការណ៍ពីឃុំ សង្កាត់ត្រូវរក្សាទុកជាឯកសារនៅ គឃ/សប មួយ (១) ច្បាប់ ត្រូវបិទផ្សាយភ្លាមនៅ គឃ/សប មួយ(១)ច្បាប់ និងត្រូវផ្ញើជូន គធ/ខប របស់ខ្លួនមួយ(១)ច្បាប់ជាបន្ទាន់ ។

គធ/ខប បន្ទាប់ពីបានទទួលរបាយការណ៍ពី គឃ/សប ត្រូវធ្វើការបូកសរុបរបាយការណ៍នៅក្នុងរាជធានី ខេត្ត របស់ខ្លួនដើម្បីផ្ញើជូន គ.ជ.ប ជាបន្ទាន់ ។

## V. សុពលភាពប្រើប្រាស់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត និងទណ្ឌកម្ម

លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតត្រូវដាក់ឱ្យប្រើប្រាស់ជំនួសលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និងអាយុ នៃអ្នកសុំចុះឈ្មោះបោះឆ្នោត និងការបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដែលហៅថាទម្រង់បែបបទលេខ ១០១៨ ចាប់ពីក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ នេះតទៅ ។ ទម្រង់បែបបទលេខ ១០១៨ ត្រូវទុកជាមោឃៈ ។

លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតប្រើប្រាស់សម្រាប់បំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ឬ/និងបោះឆ្នោតតែប៉ុណ្ណោះ ។

លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ដែលថតចម្លង កែ កោស ឬ លុប មិនអាចប្រើជាផ្លូវការបានឡើយ ។

មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិពីមេឃុំ ចៅសង្កាត់ ឬជនណាម្នាក់ដែលក្លែងបន្លំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ឬក៏ចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត មិនបានត្រឹមត្រូវតាមនីតិវិធីត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## VI. ការផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីណែនាំរួម

ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ស្មៀនឃុំ សង្កាត់ មេភូមិ ត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិរបស់ខ្លួនអំពីខ្លឹមសារសំខាន់ៗនៃសេចក្តីណែនាំរួមនេះ ពិសេសអំពីមោឃភាព និងការបញ្ឈប់ប្រើប្រាស់ទម្រង់បែបបទលេខ ១០១៨ និងបំផុសប្រជាពលរដ្ឋ ដែលពុំមានឯកសារបញ្ជាក់អត្តសញ្ញាណឱ្យត្រៀមរៀបចំឯកសារ និងសាក្សីដើម្បីបំពេញលក្ខខណ្ឌស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ដើម្បីបំពេញលក្ខខណ្ឌសុំចុះឈ្មោះបោះឆ្នោត ឬ/និងបោះឆ្នោត ។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន និង អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ អគ្គលេខាធិការ គ.ជ.ប លធ/ខប ឬ គធ/ខប និង គឃ/សប ត្រូវចាត់ចែងផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងណែនាំអនុវត្តសេចក្តីណែនាំរួមនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

## ឧបសម្ព័ន្ធ ក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

បិទរូបថត សាមីខ្លួន

**លេខ :** 0.000.001 **រាជធានី/ខេត្ត :**..................

**ក្រុង/ស្រុក/ខណ្ឌ :**.................. **ឃុំ/សង្កាត់ :**..................

ត្រា

### លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

គោត្តនាមនិងនាម :.................. ប្រុស☐ ស្រី☐ ថ្ងៃខែឆ្នាំកំណើត / /

ទីលំនៅបច្ចុប្បន្នផ្ទះលេខ ..........ផ្លូវ..........ភូមិ.................. ក្នុងឃុំ សង្កាត់នេះ ។

ស្នាមមេដៃសាមីខ្លួន

យើងខ្ញុំឈ្មោះ..................ភេទ..........អាយុ..........ឆ្នាំ ទីលំនៅ..................

..................និងឈ្មោះ..................ភេទ..........អាយុ..........ឆ្នាំ

ទីលំនៅ..................ជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់នេះ

សូមធានាអះអាងថា ពិតជាស្គាល់សាមីអ្នកស្នើសុំខាងលើប្រាកដមែន បើខុសពីការពិតយើងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ត្រា

ស្នាមមេដៃអ្នកធានាទី១ ស្នាមមេដៃអ្នកធានាទី២

ការធានាខាងលើត្រូវបានធ្វើនៅចំពោះមុខយើងមេឃុំ ចៅសង្កាត់ ( ឬជំទប់ ចៅសង្កាត់រងដែលត្រូវបានប្រគល់សិទ្ធិ )។ យើងចេញលិខិតបញ្ជាក់នេះ ជូនសាមីខ្លួនសម្រាប់ប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ឬ/និងបោះឆ្នោតស្របតាមការកំណត់នៃច្បាប់ ។

..................ថ្ងៃទី..........ខែ..........ឆ្នាំ២០..........

**ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់**

ត្រា

*លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត*


**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

បិទរូបថត សាមីខ្លួន

**លេខ :** 0.000.001 **រាជធានី/ខេត្ត :**..................

**ក្រុង/ស្រុក/ខណ្ឌ :**.................. **ឃុំ/សង្កាត់ :**..................

ត្រា

### លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

គោត្តនាមនិងនាម :.................. ប្រុស☐ ស្រី ថ្ងៃខែឆ្នាំកំណើត / /

ទីលំនៅបច្ចុប្បន្នផ្ទះលេខ ..........ផ្លូវ..........ភូមិ.................. ក្នុងឃុំ សង្កាត់នេះ ។

ស្នាមមេដៃសាមីខ្លួន

យើងខ្ញុំឈ្មោះ..................ភេទ..........អាយុ..........ឆ្នាំ ទីលំនៅ..................

..................និងឈ្មោះ..................ភេទ..........អាយុ..........ឆ្នាំ

ទីលំនៅ..................ជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់នេះ

សូមធានាអះអាងថា ពិតជាស្គាល់សាមីអ្នកស្នើសុំខាងលើប្រាកដមែន បើខុសពីការពិតយើងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ស្នាមមេដៃអ្នកធានាទី១ ស្នាមមេដៃអ្នកធានាទី២

ការធានាខាងលើត្រូវបានធ្វើនៅចំពោះមុខយើងមេឃុំ ចៅសង្កាត់ ( ឬជំទប់ ចៅសង្កាត់រងដែលត្រូវបានប្រគល់សិទ្ធិ )។ យើងចេញលិខិតបញ្ជាក់នេះ ជូនសាមីខ្លួនសម្រាប់ប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ឬ/និងបោះឆ្នោតស្របតាមការកំណត់នៃច្បាប់ ។

..................ថ្ងៃទី..........ខែ..........ឆ្នាំ២០..........

**ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់**

ត្រា

*លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបសម្ព័ន្ធ ២**

**ក្រសួងមហាផ្ទៃ និង**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

## របាយការណ៍ស្តីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

### ១.លក្ខណៈសម្គាល់រាជធានី ខេត្ត និងឃុំ សង្កាត់

<table>
<tr><td>ឈ្មោះ និងលេខកូដរាជធានី ខេត្ត</td><td></td><td colspan="2"></td><td></td></tr>
<tr><td>ឈ្មោះ និងលេខកូដឃុំ សង្កាត់</td><td></td><td></td><td></td><td></td></tr>
</table>

### ២.របាយការណ៍នៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

☐ **ក. លទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត**

☐ **ខ. លទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត នៅមុនថ្ងៃបោះឆ្នោត**

<table>
<tr><td>កាលបរិច្ឆេទនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត</td><td colspan="3">ចាប់ពីថ្ងៃទី / / ដល់ថ្ងៃទី / /</td></tr>
<tr><td>លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតដែលបានទទួល</td><td colspan="3">ចំនួន ក្បាល សរុប សន្លឹក</td></tr>
<tr><td rowspan="3">លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតដែលបានចេញ</td><td rowspan="3">លេខរៀងទី..................................<br>ដល់លេខរៀងទី............................</td><td colspan="2">ចំនួនសរុប នាក់</td></tr>
<tr><td>ស្រី</td><td>ប្រុស</td></tr>
<tr><td></td><td></td></tr>
<tr><td>លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតដែលបំពេញខុស</td><td colspan="3">ចំនួន សន្លឹក</td></tr>
<tr><td>លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតដែលនៅសល់</td><td colspan="3">ចំនួនសរុប សន្លឹក</td></tr>
<tr><td>លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតដែលបានចេញសាជាថ្មី</td><td colspan="3">ចំនួនសរុប សន្លឹក</td></tr>
</table>

### ៣.សម្រាប់មេឃុំ ចៅសង្កាត់

កាលបរិច្ឆេទ ៖ ថ្ងៃទី................/..................../.................

ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់

---

❖ **កំណត់សំគាល់**

- ក្នុងការបំពេញរបាយការណ៍មេឃុំ ចៅសង្កាត់ត្រូវគោសសញ្ញា ✓ ក្នុងប្រអប់ចំណុច ក ឬ ខ តាមករណីនីមួយៗ ។
- ចំពោះរបាយការណ៍ដូចចំណុច ក ត្រូវបំពេញជាបួន (៤)ច្បាប់ ក្នុងនោះ មួយ(១)ច្បាប់ទុកជាឯកសារនៅឃុំ សង្កាត់ មួយ(១)ច្បាប់បិទផ្សាយនៅសាលាឃុំ សង្កាត់របស់ខ្លួន មួយ(១)ច្បាប់ផ្ញើជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងមួយ(១)ច្បាប់ផ្ញើជូន លធ/ខប របស់ខ្លួនស្របពេលជាមួយគ្នានឹងការបញ្ជូនសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតជាបន្ទាន់ ។
- ចំពោះរបាយការណ៍ដូចក្នុងចំណុច ខ ត្រូវបំពេញជាប្រាំមួយ(៦ )ច្បាប់ ក្នុងនោះមួយ(១)ច្បាប់ទុកជាឯកសារនៅសាលាឃុំ សង្កាត់ មួយ(១)ច្បាប់បិទផ្សាយនៅសាលាឃុំ សង្កាត់របស់ខ្លួន មួយ(១)ច្បាប់ផ្ញើជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួន បី(៣)ច្បាប់ផ្ញើជូន គឃ/សប នៅក្នុងឃុំ សង្កាត់របស់ខ្លួនជាបន្ទាន់ (គឃ/សប ត្រូវទុកជាឯកសារនៅ គឃ/សប មួយ(១)ច្បាប់ បិទផ្សាយភ្លាមនៅ គឃ/សប មួយ(១)ច្បាប់ និងត្រូវផ្ញើជូន គធ/ខប របស់ខ្លួនមួយ(១)ច្បាប់ ជាបន្ទាន់ ) ។

# ឧបសម្ព័ន្ធទី ៨

## ស្តីពី

## សម្ភារៈ ឯកសារ ដែលត្រូវប្រគល់ជូន គជ/ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល

១_ ប័ណ្ណសម្គាល់សមាសភាព គកប ចំនួនប្រាំ (៥) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត ( ត្រូវបញ្ជូនមុន ) ។

២_ ប័ណ្ណសម្គាល់តំណាងគណបក្សនយោបាយចំនួនដប់ (១០) សន្លឹក គុណនឹងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ( ត្រូវបញ្ជូនមុន ) ។

៣_ ប័ណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិ ចំនួនពីរ (២) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត ( ត្រូវបញ្ជូនមុន ) ។

៤_ ទម្រង់បែបបទលេខ ១០០២ សម្រាប់បំពេញកិច្ចសន្យាបម្រើការងាររបស់សមាសភាព គកប ចំនួនដប់ (១២) សន្លឹក គុណនឹងការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត ( ត្រូវបញ្ជូនមុន ) ។

៥_ ទម្រង់បែបបទលេខ ១០០៤ សម្រាប់បំពេញបញ្ជីវត្តមាន និងប្រាក់កម្រៃសមាសភាព គកប ចំនួនបី (៣) ច្បាប់ (ត្រូវបញ្ជូនមុន) ។

៦_ ទម្រង់បែបបទលេខ ១១០៥ធខ សម្រាប់បំពេញក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ/ខប ចំនួនបី (៣) ច្បាប់ គុណនឹងចំនួនឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត ។

៧_ ទម្រង់បែបបទលេខ ១១០៦ ចំនួនបី (៣) ច្បាប់ សម្រាប់កត់ត្រាការត្រួតពិនិត្យការបែងចែក និងបញ្ជូនសន្លឹកឆ្នោត ។

៨_ ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោត ចំនួនប្រាំបួន (៩) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត ។

៩_ ទម្រង់បែបបទលេខ ១១១០ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ចំនួនបី (៣) ច្បាប់ និងថាសទន់ផ្ទុកទម្រង់បែបបទលេខ ១១១០ ចំនួនមួយ (១) ។

១០_ ទម្រង់បែបបទលេខ ១១១១ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ចំនួនប្រាំ (៥) ច្បាប់ ។

១១_ ទម្រង់បែបបទលេខ ១១១៦គព សម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ចំនួនប្រាំ (៥) ច្បាប់ គុណានឹង ចំនួនឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត ។

១២_ ទម្រង់បែបបទលេខ ១២០២ ចំនួនប្រាំ (៥) ក្បាល ក្នុងមួយក្បាលមានម្ភៃ (២០) ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។

១៣_ ទម្រង់បែបបទលេខ ១២០៣ ចំនួនប្រាំ (៥) ក្បាល ក្នុងមួយក្បាលមានម្ភៃ (២០) ច្បាប់ សម្រាប់បំពេញសម្រង់សេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។

១៤_ ស្រោមសំបុត្រធំចំនួនពីរ (២) គុណានឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត ស្រោមសំបុត្រមធ្យមចំនួនប្រាំពីរ (៧) និងបន្ថែមស្រោមសំបុត្រមធ្យម ចំនួនគិតសមាមាត្រនឹងស្បោង " ឃ " ដែលត្រូវប្រើនៅ គធ/ខប ។

១៥_ ម៉ាស៊ីនគិតលេខចំនួនមួយ (១) គ្រឿង ។

១៦_ ប៊ិចហ្វឺតធំលុបមិនជ្រះ ចំនួនពីរ (២) ដើម ។

១៧_ ប៊ិចហ្វឺតធំខៀវ ចំនួនមួយ (១) ដើម ។

១៨_ កញ្ចប់សុវត្ថិភាព " ឃ ពិសេស " បែងចែកតាមរាជធានី ខេត្ត តូច ឬធំ ។

១៩_ ស្បោង " ឃ " បែងចែកតាមរាជធានី ខេត្ត តូច ឬធំ ។

២០_ សោឃ្លុំជ័រធំមានលេខ សម្រាប់ឃ្លុំកញ្ចប់ " ឃ " ចំនួនស្មើនឹងកញ្ចប់ " ឃ " ។

# ឧបសម្ព័ន្ធទី ៩
## ស្តីពី
## សម្ភារៈ ឯកសារ ដែលត្រូវប្រគល់ជូន គឃ/សប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតនាថ្ងៃបោះឆ្នោតនិងនីតិវិធីរាប់សន្លឹកឆ្នោត

១_ បណ្ណសម្គាល់សមាសភាព គកប ចំនួនប្រាំមួយ (៦) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ត្រូវបញ្ជូនមុន) ។

២_ បណ្ណសម្គាល់ភ្នាក់ងារនៃគណបក្សនយោបាយ ចំនួនដប់ប្រាំមួយ (១៦) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ត្រូវបញ្ជូនមុន) ។

៣_ ត្រា គឃ/សប ចំនួនមួយ (១) (ត្រូវបញ្ជូនមុន) ។

៤_ តាំប៉ុងក្រហម ចំនួនមួយ (១) ប្រអប់ និងទឹកតាំងប៉ុងពណ៌ក្រហម ចំនួនមួយ (១) ដប (ត្រូវបញ្ជូនមុន) ។

៥_ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ បី (៣) ច្បាប់ (ត្រូវបញ្ជូនមុន)។

៦_ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ពីរ (២) ច្បាប់ សម្រាប់បិទផ្សាយ

៧_ ទម្រង់បែបបទលេខ ១១០៣ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួនប្រាំ (៥) ច្បាប់ ។

៨_ ទម្រង់បែបបទលេខ ១១០៦ ចំនួនបី (៣) ច្បាប់ សម្រាប់កត់ត្រាការត្រួតពិនិត្យការបែងចែកសន្លឹកឆ្នោត ។

៩_ ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោត ចំនួនប្រាំមួយ (៦) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់។

១០_ ទម្រង់បែបបទលេខ ១១០៩ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួនប្រាំ (៥) ច្បាប់ ។

១១_ ទម្រង់បែបបទលេខ ១១១៣ សម្រាប់បំពេញការវាយតម្លៃសមាសភាពនៃ គកប ចំនួនដប់ពីរ (១២) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

១២_ ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ចំនួនបី (៣) ក្បាល ក្នុង១ក្បាល មានថ្លៃ (២០) ច្បាប់ ។

១៣_ ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ចំនួនប្រាំ (៥) ក្បាល ក្នុង១ក្បាលមានថ្លៃ (២០) ច្បាប់ ។

១៤_ ស្រោមសំបុត្រធំ ១ មធ្យម ៥ និងបន្ថែមស្រោមសំបុត្រមធ្យមចំនួនគិតសមាមាត្រនឹងស្នៀង " គ " ដែលត្រូវប្រើនៅ គឃ/សប ។

១៥_ ម៉ាស៊ីនគិតលេខ មួយ (១) គ្រឿង ។

១៦_ ក្រដាសវ៉ាម ចំនួនហាសិប (៥០) សន្លឹក សម្រាប់ប្រើប្រាស់ការងារផ្សេងៗ ។

១៧_ ប៊ិចខៀវ ចំនួនប្រាំ (៥) ដើម ។

១៨_ ប៊ិចហ្វឺតធំលុបលាងមិនជ្រះចំនួនពីរ (២) ដើម ។

១៩_ ប៊ិចហ្វឺតធំពណ៌ខៀវ ចំនួនពីរ (២) ដើម ។

២០_ កញ្ចប់សុវត្ថិភាព " គពិសេស " ចំនួនមួយ (១) ។

២១_ ស្នៀង " គ " ចំនួនគិតតាមសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតតិច ឬច្រើន ក្នុងឃុំសង្កាត់ ។

២២_ សោឃ្លុំជ័រធំសម្រាប់ឃ្លុំស្នៀង " គ " ចំនួនស្មើនឹងស្នៀង " គ " ។

# ឧបសម្ព័ន្ធទី ១០

## ស្ដីពី

## សម្ភារៈ ឯកសារ ដែលត្រូវប្រគល់ជូន គកប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត

១_ ស្លាកសម្គាល់ " ការិយាល័យបោះឆ្នោត " បោះពុម្ពលើកំណាត់ប្លាស្ទិក ចំនួនមួយ (១) ។

២_ បណ្ណប្រកាសហាមប្រើទូរស័ព្ទដៃ និងម៉ាស៊ីនថត ចំនួនពីរ (២) សន្លឹក ។

៣_ ត្រាការិយាល័យបោះឆ្នោត ចំនួនមួយ (១) ។

៤_ តាំប៉ុងពណ៌ក្រហម ចំនួនមួយ (១) ប្រអប់ និងទឹកតាំប៉ុងក្រហម ចំនួនមួយ (១) ដប ។

៥_ ប៊ិចមានខ្សែចងសម្រាប់គូសសន្លឹកឆ្នោត និងប៊ិចធម្មតាសម្រាប់ គកប សរុបទាំងពីរមុខ ចំនួនប្រាំបី (៨) ដើម ។

៦_ ប៊ិចហ្វឺតធំលុបមិនជ្រះ ចំនួនមួយ (១) ដើម ។

៧_ ប៊ិចហ្វឺតធំ ចំនួនមួយ (១) ដើម ។

៨_ បន្ទាត់ជ័រ ចំនួនមួយ (១) ដើម ។

៩_ ជ័រការពារមួយ (១) ដប ។

១០_ កៅស៊ូកងមួយចំនួន សម្រាប់ចងសន្លឹកឆ្នោតតាមគណបក្ស ។

១១_ ស្រោមសំបុត្រធំ ចំនួនមួយ (១) មធ្យម ចំនួនប្រាំបួន (៩) និងតូចចំនួនពីរ (២) ។

១២_ ក្រដាសស្តើង សម្រាប់បិទពាសសន្ធះបិទប្រឡោះស៊កសន្លឹកឆ្នោត ចំនួនបួន (៦) សន្លឹក ។

១៣_ ក្រដាសវ៉ាម សម្រាប់សរសេរសម្គាល់លេខការិយាល័យបោះឆ្នោតបិទលើហិបឆ្នោត និងសម្រាប់ប្រើប្រាស់ការងារផ្សេងៗ ចំនួនម្ភៃ (២០) សន្លឹក ។

១៤_ ផ្ទាំងក្រដាស សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ចំនួនពីរ (២) ផ្ទាំង ។

១៥_ ផ្ទាំងក្រដាសធំ សម្រាប់កត់ត្រាសម្លេងឆ្នោត មួយ (១) សន្លឹក ។

១៦_ ទម្រង់បែបបទលេខ ១១០១ ចំនួនប្រាំ (៦) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត ។

១៧_ ទម្រង់បែបបទលេខ ១១០២ ចំនួនប្រាំ (៦) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

១៨_ ទម្រង់បែបបទលេខ ១១០៤ សម្រាប់ចម្លងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត ចំនួនម្ភៃ (២០) សន្លឹក ។

១៩_ ទម្រង់បែបបទលេខ ១១០៧ ចំនួនប្រាំមួយ (៦) ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈឯកសារបោះឆ្នោត ។

២០_ ទម្រង់បែបបទលេខ ១១០៨ ចំនួនបួន (៤) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោត ។

២១_ ទម្រង់បែបបទលេខ ១១១២ ចំនួនបួន (៤) ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារៈឯកសារបោះឆ្នោតដែល គកប បានទទួល ។

២២_ ទម្រង់បែបបទលេខ ១១១៥ ចំនួនពីរ (២) ច្បាប់ សម្រាប់ស្រង់វត្តមានភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោត ។

២៣_ ទម្រង់បែបបទលេខ ១២០២ ចំនួនពីរ (២) ក្បាល ក្នុងមួយក្បាលមានម្ភៃ (២០) ច្បាប់សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។

២៤_ ថង់ប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតដែលមិនទាន់ប្រើ និងគល់សន្លឹកឆ្នោតដែលប្រើហើយចំនួនមួយ (១) ។

២៥_ ថង់ប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ចំនួនមួយ (១) ។

២៦_ កញ្ចប់សុវត្ថិភាព " ក " សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត និងសម្ភារៈ ឯកសារបោះឆ្នោត ចំនួនមួយ (១) ។

២៧_ កញ្ចប់ " ខ " សម្រាប់ដាក់កញ្ចប់សុវត្ថិភាព " ក " និងសម្ភារៈ ឯកសារបោះឆ្នោត ចំនួនមួយ (១)។

២៨_ ស្លាយឃុំជ័រមានលេខសម្រាប់បិទគម្របខាងក្នុង និងខាងក្រៅនៃហិបឆ្នោត ចំនួនបី (៣) ។

២៩_ ស្លាយឃុំជ័រសម្រាប់ឃ្លុំបិទមាត់កញ្ចប់ " ខ " ចំនួនមួយ (១) ។

# ឧបសម្ព័ន្ធទី ១១
# ស្តីពី
## រូបមន្តរកកម្រិតលម្អៀងសំឡេងឆ្នោត
## ដើម្បីកំណត់កម្រិតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន

ប្រការ ១ ការរកកម្រិតលំអៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ (២) ឬច្រើន ត្រូវអនុវត្តតាមរូបមន្តដូចប្រការ ៣ និងប្រការ ៤ ខាងក្រោម ។

ប្រការ ២ ក្រុមត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត គធ/ខប ត្រូវអនុវត្តរូបមន្តដើម្បីរកកម្រិតលម្អៀងសំឡេងឆ្នោត ដូចចែងក្នុងប្រការ ១ តាមការសម្រេចរបស់ គធ/ខប ។ ក្រុមត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត គ.ជ.ប ត្រូវអនុវត្តរូបមន្តដើម្បីរកកម្រិតលំអៀងសំឡេងឆ្នោត ដូចចែងក្នុងប្រការ ១ តាមការសម្រេចរបស់ គ.ជ.ប ។

ប្រការ ៣ ក្នុងការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ (២) ក្រុមត្រួតពិនិត្យលទ្ធផលត្រូវ ៖

៣.១ ស្រង់ចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងពីរ ដែលត្រូវបានយល់ថា អាចមានលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ ។

<u>ឧទាហរណ៍ទី១</u>

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** មាន ១.០០៥ សំឡេង
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** មាន ១.០០០ សំឡេង

៣.២ កំណត់យកសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលទាបជាងគេធ្វើជាភាគបែង សម្រាប់ប្រៀបធៀបរកភាគរយ ។

<u>ឧទាហរណ៍ទី២</u>

ប្រៀបធៀបបញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** ដែលមាន ១.០០៥ សំឡេង និងបញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** ដែលមាន ១.០០០ សំឡេង ដូចក្នុងឧទាហរណ៍ទី១ ក្រុមត្រួតពិនិត្យត្រូវកំណត់យកចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយ **ខ** ដែលមានចំនួន ១.០០០ សំឡេង ធ្វើជាភាគបែងសម្រាប់រកកម្រិតលម្អៀង ។

៣.៣ យកចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** ដកនឹងចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** គុណនឹង ១០០ ចែកនឹងភាគបែង (ចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ**) តាមរូបមន្តខាងក្រោម ៖

$$\text{ល} = \frac{(\text{ស}_{\text{ប}}\text{ក} - \text{ស}_{\text{ប}}\text{ខ}) \quad ១០០}{\text{ស}_{\text{ប}}\text{ខ} \ (\text{ភាគបែង})}$$

**ល** = តាងឱ្យចំនួននៃកម្រិតលម្អៀង រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** និង **ខ** (គិតជាភាគរយ ដល់ពីរ (២) ខ្ទង់ក្រោយក្បៀស) ។

$\text{ស}_{\text{ប}}$**ក** = តាងឱ្យចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក**

$\text{ស}_{\text{ប}}$**ខ** = តាងឱ្យចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** និងជាភាគបែង ។

អនុវត្តតាមរូបមន្តខាងលើចំពោះឧទាហរណ៍ទី១ យើងបាន ៖

$$\text{ល} = \frac{(១.០០៥ - ១.០០០) \quad ១០០}{១.០០០} = ០,៥$$

ដូចនេះ កម្រិតលម្អៀងរវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** និង **ខ** គឺ **ល** ស្មើនឹង ០,៥ ភាគរយ ។

ប្រការ ៨ ក្នុងការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនច្រើន ក្រុមត្រួតពិនិត្យលទ្ធផលត្រូវ ៖

៨.១ ជ្រើសរើសយកបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ដែលមានចំនួនសំឡេងឆ្នោតខុសគ្នាតិចជាងគេ ពីក្នុងចំណោមបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងឡាយ ដែលត្រូវបានយល់ថា អាចមានសំឡេងឆ្នោតលម្អៀងរវាងគ្នានឹងគ្នាយ៉ាងច្រើន ០,៥ ភាគរយ ។

<u>ឧទាហរណ៍ទី៣</u>

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** មាន ១.០០៥ សំឡេង

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ មាន ១.០០០ សំឡេង
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ គ មាន ១.០០២ សំឡេង

ផ្អែកតាមសម្មតិកម្មក្នុងឧទាហរណ៍ទី៣ យើងពិនិត្យឃើញថា ៖

- រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក និងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ មានសំឡេងឆ្នោតខុសគ្នា ៥ សំឡេង ។
- រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក និងបញ្ជីបេក្ខជននៃគណបក្សនយោបាយ គ មានសំឡេងឆ្នោតខុសគ្នា ៣ សំឡេង ។
- រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ និងបញ្ជីបេក្ខជននៃគណបក្សនយោបាយ គ មានសំឡេងឆ្នោតខុសគ្នា ២ សំឡេង ។

ដូចនេះ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ និង គ ដែលមានសំឡេងឆ្នោតខុសគ្នាតិចជាងគេ (២ សំឡេង) មកគណនារកកម្រិតលម្អៀងសំឡេងឆ្នោតរវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងពីរ ។

៤.២ ការគណនារកកម្រិតលម្អៀងសំឡេងឆ្នោត (ល) រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងពីរ ដែលមានសំឡេងឆ្នោតខុសគ្នាតិចជាងគេ ក្នុងចំណោមបញ្ជីបេក្ខជននៃគណបក្សនយោបាយពាក់ព័ន្ធ ត្រូវអនុវត្តតាមរូបមន្ត ដូចកំណត់ក្នុងចំណុច ៣.៣ ។

# ឧបសម្ព័ន្ធទី ១២

# ក្រមសីលធម៌

## សម្រាប់គណបក្សនយោបាយ បេក្ខជន និង

## ភ្នាក់ងារនៃគណបក្សនយោបាយ

## I. សេចក្តីផ្តើម

ប្រទេសដែលមាននិន្នាការប្រកាន់លទ្ធិប្រជាធិបតេយ្យបច្ចុប្បន្ន តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតទាំងឡាយ ប្រព្រឹត្តទៅដោយ សេរី ត្រឹមត្រូវ យុត្តិធម៌ និងស្របទៅតាមលទ្ធិប្រជាធិតេយ្យពិតប្រាកដ ។ ដើម្បីសម្រេចនូវគោលដៅដ៏ធំធេងនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ អាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ ត្រូវតែរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជានីតិវិធីបោះឆ្នោត លិខិតបទដ្ឋានពាក់ព័ន្ធនានា និងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន ។

ក្រមសីលធម៌នេះ រៀបចំតាក់តែងឡើងស្របទៅនឹងច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ។ ការប្រតិបត្តិតាមក្រមសីលធម៌ ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោតតាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលស្ថាពរមានដំណើរប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ។ ការប្រតិបត្តិក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់អាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងគណបក្សនយោបាយ ជាដៃគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នាក្នុងការសហការបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន ។ ការគោរពក្រមសីលធម៌បោះឆ្នោតបានល្អ ជាកត្តាកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែកចំពោះអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម ។ ការគោរពក្រមសីលធម៌បានល្អ ជាកត្តាលើកស្ទួយកិត្យានុភាពជាតិ លើឆាកអន្តរជាតិខាងវិស័យបោះឆ្នោត ដើម្បីបង្ហាញឱ្យគេមើលឃើញពីការគោរពច្បាប់ ឯកភាពជាតិ ការទុកចិត្តគ្នា រវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងស្ថាប័នទាំងអស់ក្នុងសង្គម ។

## II. គោលបំណងនៃក្រមសីលធម៌

គោលបំណងនៃក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ គឺដើម្បីឱ្យ ៖

- ការបោះឆ្នោតប្រព្រឹត្តទៅស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងបទប្បញ្ញត្តិផ្សេងៗ ។
- ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ។

## III. សិទ្ធិ និងភារកិច្ចរបស់គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ

គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិពេញលេញ និងស្មើភាពចូលរួមក្នុងការបោះឆ្នោតដូចជា សិទ្ធិចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត សិទ្ធិឃោសនាបោះឆ្នោត សិទ្ធិសង្កេតមើលដំណើរការបោះឆ្នោត សិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់ និងសិទ្ធិទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ។

បេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មេភូមិ អនុប្រធានភូមិ ជំនួយការភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយសង្កេតការណ៍បោះឆ្នោតឡើយ ។

### ក. សិទ្ធិ និងភារកិច្ចរបស់គណបក្សនយោបាយ និងបេក្ខជន

គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ៖

១. គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ មានសិទ្ធិស្នើសុំចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ។

២. គណបក្សនយោបាយមានសិទ្ធិ ៖

- ប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ពីការសម្រេចបដិសេធមិនយល់ព្រមចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- ប្ដឹងតវ៉ាទៅ គ.ជ.ប ពីការសម្រេចមិនយល់ព្រមចុះបញ្ជីគណៈបក្សនយោបាយបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ប្ដឹងតវ៉ាទៅ គ.ជ.ប ពីការសម្រេចមិនយល់ព្រមចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់ គធ/ខប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

៣. គណបក្សនយោបាយ បេក្ខជន មានសិទ្ធិសុំជួលមណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ទៅអ្នកគ្រប់គ្រង ដើម្បីប្រើប្រាស់សម្រាប់បម្រើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ ។

៤. គណបក្សនយោបាយ បេក្ខជន មានសិទ្ធិធ្វើសកម្មភាពឃោសនានៅលើទីធ្លាឯកជន ឬសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងទៅអាជ្ញាធររៀបចំការបោះឆ្នោតពាក់ព័ន្ធ ។

៥. ការឃោសនាបោះឆ្នោត មានទិសដៅឱ្យគណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយនូវកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោតតែប៉ុណ្ណោះ ។

៦. ក្នុងការឃោសនា ការរិះគន់គណបក្សនយោបាយដទៃ ត្រូវឆ្លុះបញ្ចាំងតែទៅលើគោលនយោបាយ កម្មវិធីនយោបាយ និងបទពិសោធន៍ការងារ ។ ត្រូវចៀសវាងដាច់ខាតចំពោះការរិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ ។

៧. រាល់សេចក្ដីថ្លែងការណ៍ សេចក្ដីប្រកាស ខិត្តប័ណ្ណ រូបភាពបិទផ្សាយទាំងឡាយ និងសម្ភារៈឃោសនាផ្សេងទៀត ត្រូវចៀសវាងដាច់ខាតការប្រើភាសា ឬរូបភាពរំលោភ បំពានខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សា ។ល។

៨. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវទទួលខុសត្រូវផ្ទាល់លើខ្លឹមសារ និងសកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន ។

៩. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ។

១០. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវយកចិត្តទុកដាក់គោរពឱ្យបានល្អនូវរាល់កម្មវិធីឃោសនាទាំងអស់ ដែលសម្របសម្រួលដោយអាជ្ញាធរដែនដី ។

១១. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយសេរី ក្នុងទីស្នាក់ការគណបក្សនយោបាយរបស់ខ្លួនទូទាំងប្រទេស ។

១២. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មានសិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់ទៅតាមបទបញ្ជា និងនីតិវិធី គ.ជ.ប ប្រសិនបើពិនិត្យឃើញ និងមានភ័ស្ដុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធី គ.ជ.ប ក្នុងដំណើរការរៀបចំការបោះឆ្នោត ។

១៣. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មានសិទ្ធិស្មើភាពគ្នាក្នុងការការពារសន្ដិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានា ក្នុងដំណើរការបោះឆ្នោតទាំងមូល ។

**ខ. សិទ្ធិ និងភារកិច្ចរបស់តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ**

ក្នុងការសង្កេតមើលដំណើរការនៃការបោះឆ្នោត តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ៖

១. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិមានវត្តមាន នៅតាមទីកន្លែងចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលខ្លួនបានទទួលការអនុញ្ញាតតាមទីកន្លែង និងពេលវេលា ដែលបានកំណត់ដោយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ ។ តំណាង ឬ/និងភ្នាក់ងារបម្រុង នៃគណបក្សនយោបាយត្រូវរង់ចាំនៅក្រៅការិយាល័យ ដើម្បីជំនួសតំណាង ឬ/និងភ្នាក់ងារ ពេញសិទ្ធិក្នុងករណីមានការផ្លាស់ប្តូរ ។

៣. គណបក្សនយោបាយមានសិទ្ធិសុំផ្លាស់ប្តូរតំណាង ឬ/និងភ្នាក់ងារពេញសិទ្ធិ និងតំណាង ឬ/និង ភ្នាក់ងារបម្រុង របស់ខ្លួនទៅតាមមូលហេតុសមស្រប និងទៅតាមកាលកំណត់ចុងក្រោយរបស់ គ.ជ.ប ។

៤. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬ លើបទបញ្ជា និងនីតិវិធី ដែលខ្លួនបានឃើញផ្ទាល់ ។ ការជំទាស់ត្រូវធ្វើឡើងទៅប្រធាន គកប។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់អាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គ.ជ.ប ។

៥. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ ហេតុផ្សេងៗដែលកំណត់ដោយ គ.ជ.ប ។

៦. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ ដែលចូលរួមសង្កេតការណ៍បោះឆ្នោតអាចចុះ ហត្ថលេខា ឬផ្តិតមេដៃ នៅលើកំណត់ហេតុបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការ រៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរដែនដី អ្នកសង្កេត ការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ។

៨. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅតាមបទបញ្ជា និង នីតិវិធី របស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញថា ភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធី របស់ គ.ជ.ប ក្នុងដំណើរការរៀបចំការបោះឆ្នោត ។

៩. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើភាពគ្នា ក្នុងការទទួលបាន ការការពារ សន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានា ក្នុងដំណើរការបោះឆ្នោតទាំង មូល ។

## IV. បម្រាមចំពោះគណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ

ក្នុងពេលបំពេញការងារ គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃ គណបក្សនយោបាយ ត្រូវអនុវត្តដូចខាងក្រោម ៖

១. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវ ប្រើកម្លាំង អំពើហិង្សា ឬបំភិតបំភ័យដល់អ្នកបោះឆ្នោត ។

២. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវញុះញង់ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។

៣. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំគេឱ្យធ្វើសម្បថបោះឆ្នោតឱ្យគណបក្សនយោបាយខ្លួនឡើយ ។

៤. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។

៥. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវរារាំងបេក្ខជន និង អ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប ។

៦. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើកម្លាំង អំពើហិង្សា បំភិតបំភ័យ ឬប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាចការភាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

៧. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវបង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន ។

៨. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវបង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត ។

៩. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

១០. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាស ។

១១. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវបង្គាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

១២. បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាព ហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

១៣. គណបក្សនយោបាយ និងបេក្ខជន ត្រូវគោរពគោលការណ៍ឃោសនាបោះឆ្នោត ដែលមានរយៈពេលដូចមានចែងក្នុងច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី គ.ជ.ប ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោត ត្រូវបញ្ឈប់ម្ភៃបួន (២៤)ម៉ោងមុនថ្ងៃបោះឆ្នោត ។ គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយបេក្ខជន ត្រូវឈប់សម្រាកចន្លោះពីម៉ោងដប់ (១០)យប់ ដល់ម៉ោងប្រាំមួយ (៦)ព្រឹក ។ សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវហាមឃាត់ចាប់ពីម៉ោងដប់ពីរ (១២)ថ្ងៃត្រង់ ដល់ម៉ោងពីរ (២)រសៀល ។

១៤. ក្នុងពេលឃោសនាបោះឆ្នោតគ្រប់គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ សមាជិក និងអ្នកគាំទ្រទាំងអស់ ត្រូវគោរពបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី គ.ជ.ប ក្រមសីលធម៌គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

១៥. ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គ្រប់គណបក្សនយោបាយ បេក្ខជន មិនត្រូវប្រើអំពើហិង្សា អំពើរំលោភ ប្រើពាក្យសម្ដីប្រមាថមើលងាយ មិនត្រូវធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់ បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

១៦. គណបក្សនយោបាយ និងបេក្ខជន មិនត្រូវទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយនោះទេ ។

១៧. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីចុះឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោតឡើយ ។

១៨. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោតឡើយ ។

១៩. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយទាំងអស់មិនត្រូវរិះគន់ ឬរើសអើងប្រកាន់បក្សពួក ជាតិសាសន៍ ភេទ ឋានៈក្នុងសង្គមសាសនា និងតាមគ្រប់រូបភាពទាំងអស់ ។

២០. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវ ៖

- រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាជនមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀតឡើយ ។
- ប្រើប្រាស់នូវភាសា ពាក្យសំដីដែលស្ដែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយឡើយ ។
- យល់ព្រមឱ្យដាក់តាំង ឬបង្ហាញ ឬចែកចាយការពិពណ៌នាអំពីការវាយប្រហារ ឬអាវុធនោះឡើយ ។

២១. គណបក្សនយោបាយ បេក្ខជន មិនត្រូវចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗ លុបលើសំឡេងឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀតឡើយ ។

២២. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកគាំទ្រ មិនត្រូវប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ឬព្រះនាមព្រះមហាក្សត្រ ឬព្រះនាមព្រះមហាវីរក្សត្រ ឬស្លាកសញ្ញា គ.ជ.ប ដើម្បីឃោសនារកសំឡេងឆ្នោតឡើយ ។

២៣. គណបក្សនយោបាយ បេក្ខជន មិនត្រូវចម្លងយកសញ្ញាសម្គាល់ របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន ។

២៤. គណបក្សនយោបាយ បេក្ខជន មិនត្រូវបិទប័ណ្ណ ខិត្តប័ណ្ណ រូបភាពឃោសនា សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសារឃោសនាដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃឡើយ ។

២៥. គណបក្សនយោបាយ បេក្ខជន តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកគាំទ្រទាំងអស់មិនត្រូវបក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវប័ណ្ណបិទផ្សាយ ខិត្តប័ណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសារឃោសនា ឬសេចក្តីណែនាំផ្សេងៗ របស់គណបក្សនយោបាយដទៃ ស្ថាប័ននានា ឬអាជ្ញាធរដែនដីឡើយ ។

២៦. គណបក្សនយោបាយ បេក្ខជន មិនត្រូវបិទប័ណ្ណផ្សព្វផ្សាយរូបភាពឃោសនា សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារឃោសនាដទៃទៀត ក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង ១០០ម៉ែត្រ និងមិនត្រូវចងបដា ឬរូបសញ្ញាឃោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈឡើយ ។

២៧. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬរដ្ឋ ន.ប ខ.ម និងរាជរដ្ឋាភិបាល ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

២៨. គណបក្សនយោបាយ បេក្ខជន មិនត្រូវទិញសន្លឹកឆ្នោត ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារៈ ដើម្បីទទួលបានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលឃោសនាបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត ។

២៩. គណបក្សនយោបាយ បេក្ខជន តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកគាំទ្រទាំងអស់មិនត្រូវប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបានការគាំទ្រ ។

៣០. គណបក្សនយោបាយ បេក្ខជន តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកគាំទ្រទាំងអស់ មិនត្រូវក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោតឡើយ ។

៣១. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរស័ព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។

៣២. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវនៅក្បែរបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោត ។

## V. ទោសប្បញ្ញត្តិសម្រាប់តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ

ដោយពុំទាន់គិតដល់ទោសប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់បោះឆ្នោត ប្រធានការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតមានសិទ្ធិបណ្តេញចេញពីការិយាល័យចំពោះតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយណាដែលមានចេតនារារាំង ឬបង្កឧបសគ្គដល់ការបំពេញភារកិច្ចរៀបចំការបោះឆ្នោត ។

កប/ឃស ឬ លធ/ខប ឬ គធ/ខប ឬ គឃ/សប និង គកប/គករ មានសិទ្ធិបដិសេធលើលិខិតអនុញ្ញាតចំពោះតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយណាម្នាក់ ឬច្រើននាក់ ក្នុងករណីដែលតំណាងនោះ ៖

- មិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។
- បង្កឱ្យមានឧបសគ្គ ឬរំខានដល់ដំណើរការរៀបចំការបោះឆ្នោត ឬមន្ត្រីបោះឆ្នោតក្នុងការបំពេញការងារ ។
- មិនអនុវត្ត ឬរំលោភក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ ។

# ឧបសម្ព័ន្ធទី ១៣

# ក្រមសីលធម៌

## សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត

### I. សេចក្ដីផ្ដើម

ក្នុងគោលបំណងធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងត្រូវបានគ្រប់មជ្ឈដ្ឋានទាំងអស់ទទួលស្គាល់ អ្នកសង្កេតការណ៍ត្រូវមានជំហរអព្យាក្រឹត មិនលំអៀង មិនប្រកាន់បក្ខពួក និងមិនជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានអនុម័តក្រមសីលធម៌នេះសម្រាប់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដើម្បីអនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងព្រះរាជាណាចក្រកម្ពុជា ។

### II. ការបកស្រាយ

១. ពាក្យ " **ការបោះឆ្នោត** " និង " **ដំណើរការបោះឆ្នោត** " មានន័យរួមបញ្ចូលទាំងការចុះឈ្មោះបោះឆ្នោត កុំព្យូទ័រកម្មបញ្ជីបោះឆ្នោត ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ការចុះបញ្ជីបេក្ខជន ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលបណ្ដោះអាសន្ន និងបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ឬ/និងបណ្ដឹងទាក់ទងនឹងករណីខាងលើ ។ ប៉ុន្តែពាក្យនេះ ក៏មានន័យ រួមបញ្ចូលផងដែរនូវសកម្មភាពនានា មុន និងក្រោយថ្ងៃបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងគណបក្សនយោបាយ ។

២. ពាក្យ " **អ្នកសង្កេតការណ៍** " ក្នុងក្រមសីលធម៌នេះ គឺសំដៅតែលើអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិប៉ុណ្ណោះ មិនបានគិតបញ្ចូលអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយទេ។

### III. គោលដៅ នៃក្រមសីលធម៌

គោលដៅនៃក្រមសីលធម៌នេះ គឺដើម្បីធានាឱ្យ ៖

១. កិច្ចសង្កេតការណ៍ការបោះឆ្នោត ត្រូវធ្វើឡើងដោយសុចរិត និង តម្លាភាព ។

២. អ្នកសង្កេតការណ៍បំពេញការងារដោយពុំមានការជ្រៀតជ្រែក ។

## IV. តួនាទីនៃអ្នកសង្កេតការណ៍

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមជាអ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោតទាំងមូល ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានាឱ្យចូលរួមសង្កេតការណ៍ការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ។

បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានទទួលស្គាល់ជាផ្លូវការហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍ដោយឯករាជ្យពីរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធរដែនដី គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៀតផង ។

អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិសង្កេតមើលគ្រប់សកម្មភាព ដែលទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត ។ ប៉ុន្តែអ្នកសង្កេតការណ៍មិនត្រូវជ្រៀតជ្រែក ឬប៉ុនប៉ងប្រើឥទ្ធិពលរបស់ខ្លួន ក្នុងគោលបំណងរំខាន ឬរារាំងដំណើរការនៃការបោះឆ្នោតឡើយ ។

## V. សិទ្ធិ ភារកិច្ច និងបម្រាមសម្រាប់អ្នកសង្កេតការណ៍

### ក. សិទ្ធិ និងភារកិច្ចរបស់អ្នកសង្កេតការណ៍

នៅពេលបានទទួលស្គាល់ជាផ្លូវការ និងបានទទួលប័ណ្ណសម្គាល់អ្នកសង្កេតការណ៍រួចហើយ អ្នកសង្កេតការណ៍ទាំងឡាយនឹងមានឯករាជភាព ព្រមទាំងមានសិទ្ធិ និងភារកិច្ច ដូចខាងក្រោម ៖

១. អ្នកសង្កេតការណ៍អន្តរជាតិ : អាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ ។

២. អ្នកសង្កេតការណ៍ជាតិ : អាចធ្វើដំណើរសង្កេតការណ៍ក្នុងរង្វង់រាជធានី ខេត្ត ដែលខ្លួនបានស្នើសុំប៉ុណ្ណោះ ។

៣. ក្នុងករណីអ្នកសង្កេតការណ៍មានជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីជួយដោះស្រាយទាន់ពេលវេលា ។

៤. អាចអមដំណើរគណៈប្រតិភូនៃ គកប/គករ គឃ/សប គធ/ខប គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនហិបឆ្នោត និងសម្ភារៈបោះឆ្នោតទាំងទៅ និងមក ។

៥. សង្កេតការណ៍នូវរាល់សកម្មភាពនានារបស់ កបឃ/ស ស្មៀនឃុំ សង្កាត់ ឬ គកប/គករ ឬ គឃ/សប ឬ លធ/ខប ឬ គធ/ខប និង គ.ជ.ប ទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលបោះឆ្នោត ។

៦. ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលផ្លូវការជាមួយនឹងលទ្ធផលបណ្ដោះអាសន្នដែលបានកត់ត្រាក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោតនៅថ្ងៃរាប់សន្លឹកឆ្នោត ។

៧. ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធីដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ។ អាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះមួយ(១)ច្បាប់ទៅ គ.ជ.ប ផង ។

៨. រក្សាការសម្ងាត់នៃការបោះឆ្នោត ។

៩. មានសេរីភាពធ្វើរបាយការណ៍ស្ដីពីការរកឃើញ ការកត់សម្គាល់ និងសេចក្ដីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន ។

១០. មានសេរីភាពក្នុងការជួប ឬនិយាយ ឬលើកសំណួរជាមួយគ្រប់បេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោត ប្រសិនបើកម្មវត្ថុនៃការជជែកនោះ មិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំង នឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

១១. ត្រូវគោរពច្បាប់ដែលមានជាធរមាននៅកម្ពុជា និងត្រូវទទួលស្គាល់អធិបតេយ្យភាព នៃព្រះរាជាណាចក្រកម្ពុជា។

១២. ត្រូវតែយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ។ ក្នុងករណីមានការរំលោភត្រូវធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន ។

១៣. មានសិទ្ធិចេញចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

១៤. ចំនួនអ្នកសង្កេតការណ៍ ដែលចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងពេលតែមួយ ត្រូវបានកំណត់ត្រឹម ៤(បួន)នាក់ យ៉ាងច្រើន ។ ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពី ៤ (បួន)នាក់ អ្នកសង្កេតការណ៍ទាំងនោះ ត្រូវធ្វើការផ្លាស់ប្ដូរតាមការកំណត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

១៥. ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្សពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀតដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំង នឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

១៦. ត្រូវបង្ហាញភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ច ដែលបានសាកសួរដល់ខ្លួន ហើយត្រូវពាក់ប័ណ្ណសម្គាល់ខ្លួនដែលបានសម្រេចទទួលស្គាល់ និង ចេញឱ្យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

១៧. ពុំមានសិទ្ធិចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្ដឹងណាមួយក្នុងអំឡុងពេលបោះឆ្នោតឡើយ ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយបណ្ដឹងនេះបាន ។

១៨. ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត រាប់សន្លឹកឆ្នោតណាមួយ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និង នីតិវិធី ដែលបានកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរនៃការបោះឆ្នោតឡើយ ។

១៩. ត្រូវទទួលខុសត្រូវទូទាត់ផ្ទាល់ដោយខ្លួនឯង ឬ/និងដោយអង្គការរបស់ខ្លួនលើរាល់តម្លៃ និងការចំណាយផ្សេងៗទៀតនៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន ។

### ខ. បម្រាមសម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត

ក្នុងការសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានា នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោត អ្នកសង្កេតការណ៍ត្រូវជៀសវាង ៖

១. ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា ។

២. ការជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត ។

៣. ការរំខាន ឬការជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ នៅពេលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ ។

៤. ការយកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន ។

៥. ការប៉ះពាល់ឯកសារ ឬសម្ភារៈ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង ។

៦. ការប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរស័ព្ទថតរូបនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧. ការនៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

៨. ការផ្តល់ដំបូន្មាន ឬការស្តីបន្ទោសឱ្យកែតម្រូវកំហុសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោតដែលខ្លួនបានរកឃើញ និងការបង្អាក់ដំណើរការបោះឆ្នោត ។

## VI. ទោសប្បញ្ញត្តិ

ដោយមិនទាន់គិតពីទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់បោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអំណាចឆន្ទានុសិទ្ធិ ក្នុងការបដិសេធលែងទទួលស្គាល់អង្គការសង្កេតការណ៍ ឬអ្នកសង្កេតការណ៍ណាមួយ នៅពេលដែល គ.ជ.ប យល់ឃើញថា អង្គការ ឬអ្នកសង្កេតការណ៍នោះ ៖

ក. មិនគោរពតាមសេចក្តីណែនាំ និងសេចក្តីបង្គាប់បញ្ជារបស់មន្ត្រីបោះឆ្នោតមានសមត្ថកិច្ចថ្នាក់ណាមួយ ។

ខ. បង្ហាញជាសាធារណៈថា បានលំអៀងទៅលើបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

គ. បង្អាក់ ឬធ្វើឱ្យរាំងស្ទះក្នុងការបំពេញការងារនៃមន្ត្រីបោះឆ្នោត ។

ឃ. រំលោភបំពានលើក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រគល់សិទ្ធិជូនគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមឱ្យបណ្តេញចេញពីទីស្នាក់ការ ឬការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនូវអ្នកសង្កេតការណ៍ទាំងឡាយណា ដែលពុំបានគោរពតាមក្រមសីលធម៌នេះ ។ ដើម្បីអនុវត្តសិទ្ធិអំណាចខាងលើ គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ត្រូវរាយការណ៍ពីព្រឹត្តិការណ៍នេះ តាមឋានានុក្រមមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## VII. នីតិវិធីទទួលស្គាល់អ្នកសង្កេតការណ៍

### ក. អ្នកសង្កេតការណ៍ជាតិ

១. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យពាក្យសុំ និងសម្រេចទទួលស្គាល់អ្នកសង្កេតការណ៍ជាតិ ។

២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រគល់សិទ្ធិអំណាចឱ្យមន្ត្រី លធ/ខប គធ/ខប ពាក់ព័ន្ធ ចេញប័ណ្ណសម្គាល់ខ្លួនឱ្យអ្នកសង្កេតការណ៍ជាតិ និងប័ណ្ណសម្គាល់ខ្លួនអ្នកសង្កេតការណ៍គណបក្សនយោបាយ ដែលមិនមានបេក្ខជនឈរឈ្មោះបោះឆ្នោត ។ ប័ណ្ណសម្គាល់ខ្លួននេះអនុញ្ញាត ឱ្យអ្នកសង្កេតការណ៍ជាតិមានសិទ្ធិ និងបំពេញភារកិច្ចរបស់ខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចំណុះរាជធានី/ខេត្ត ។ ប័ណ្ណសម្គាល់ខ្លួននេះ ត្រូវតែជាប័ណ្ណ ដែលផលិតដោយ គ.ជ.ប ។

៣. បណ្ណសម្គាល់ខ្លួននេះ ក៏អាចប្រើប្រាស់បាននៅក្នុងការបោះឆ្នោតសាជាថ្មីណាមួយ ដែលអាចធ្វើឡើង បន្ទាប់ពីមានការបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយនោះ ។

### ខ. អ្នកសង្កេតការណ៍អន្តរជាតិ

១. អ្នកសង្កេតការណ៍អន្តរជាតិ អង្គការអន្តរជាតិណាមួយដែលចង់ចូលរួមសង្កេតមើលការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា អាចទាក់ទងជាមួយស្ថានឯកអគ្គរាជទូតកម្ពុជា ដែលប្រចាំនៅសាមីប្រទេស ។

២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យ សម្រេច និងចេញប័ណ្ណសម្គាល់ខ្លួនឱ្យអ្នកសង្កេតការណ៍អន្តរជាតិ ។ អ្នកសង្កេតការណ៍អន្តរជាតិត្រូវបានអនុញ្ញាតឱ្យសង្កេតការណ៍នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## VIII. សំណូមពរ

បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ សាមីអង្គការសង្កេតការណ៍ទាំងឡាយត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងដំណើរការនៃការបោះឆ្នោត ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានគ្រឹះសម្រាប់ធ្វើការវាយតម្លៃជាចុងក្រោយ ។

# ឧបសម្ព័ន្ធទី ១៤

## ស្តីពី

## គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

### I- គោលបំណង

- ដើម្បីធានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាម ច.ប.ឃ.ស និងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ។
- ដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយ ។
- ដើម្បីអនុវត្តនូវ មាត្រា ១០ថ្មី មាត្រា ៨៣ថ្មី នៃ ច.ប.ឃ.ស ។
- ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន មានភាពអព្យាក្រឹតក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កំណត់នូវគោលការណ៍មួយចំនួនសំរាប់ប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន ដូចខាងក្រោម ។

### II- គោលការណ៍ទូទៅ

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងដែលអាចទទួលយកបាននូវលទ្ធផលនៃការបោះឆ្នោត អ្នកយកព័ត៌មានជាតិ ( រដ្ឋ និងឯកជន ) និងអន្តរជាតិ មានតួនាទីសំខាន់ក្នុងការប្រមូលព័ត៌មាន និងរាយការណ៍អំពីដំណើរការបោះឆ្នោតទូទាំងប្រទេស។

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានលក្ខណៈប្រជាធិបតេយ្យ និងតម្លាភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញគោលការណ៍សំរាប់គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមានបំណងចូលរួមយកព័ត៌មាន ក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោត ដូចខាងក្រោម ៖

១_ ប្រព័ន្ធផ្សព្វផ្សាយពត៌មានត្រូវផ្តល់ពត៌មានឱ្យបានត្រឹមត្រូវ មិនលំអៀង និងដោយមានការថ្លឹងថ្លែងអោយមានតុល្យភាព ។

២_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលផ្តល់ព័ត៌មានអំពីការបោះឆ្នោតត្រូវតែផ្ទៀងផ្ទាត់អំពី ប្រភពព័ត៌មាន ភាពសុក្រឹត និងភាពច្បាស់លាស់នៃហេតុការណ៍ និងព្រឹត្តិការណ៍ដែលខ្លួនត្រូវរាយការណ៍ ។

៣_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែផ្ដល់ព័ត៌មាន និងការអប់រំអំពីការបោះឆ្នោតដែលងាយយល់សំរាប់អ្នកបោះឆ្នោត ។

៤_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវជៀសវាងការប្រើប្រាស់ភាសាញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្ដាប់ធ្នាប់ ឬអាចឱ្យមានអំពើហិង្សា និងត្រូវថ្លឹងថ្លែងជាមុន មុននឹងធ្វើការផ្សព្វផ្សាយ ។

៥_ ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកគ្រប់គ្រងត្រូវខិតខំប្រឹងប្រែងឱ្យអស់សមត្ថភាព ចូលរួមធ្វើឱ្យការបោះឆ្នោតមានលក្ខណៈសេរីនិងយុត្តិធម៌ តាមរយៈការផ្ដល់ព័ត៌មានអំពីការបោះឆ្នោត និងចាត់ទុកព័ត៌មានអំពីការបោះឆ្នោតជាព័ត៌មានអាទិភាព ។

៦_ អ្នកសារព័ត៌មានមិនត្រូវបោះបង់គោលជំហរ ឬក្រមសីលធម៌របស់ខ្លួន ដោយសារតែអំណោយផលប្រយោជន៍ ឬចំណង់ចំណូលចិត្តពិសេសទេ ។

៧_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវមានភារកិច្ច និងការទទួលខុសត្រូវក្នុងការស៊ើបអង្កេត និងរាយការណ៍នូវបញ្ហាដែលទាក់ទងដល់ការបោះឆ្នោតឱ្យបានត្រឹមត្រូវ ដើម្បីរក្សាស្ថេរភាពនយោបាយ និងសណ្ដាប់ធ្នាប់សង្គម ។

៨_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវស្វែងរក និងត្រូវផ្សព្វផ្សាយព័ត៌មានអំពីទស្សនៈ និងគំនិតផ្សេងៗគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបោះឆ្នោត ។

៩_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ ត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប នៅក្នុងដំណើរការបោះឆ្នោត ។

១០_ គ.ជ.ប លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងលក្ខណៈជាដៃគូជាមួយ គ.ជ.ប និងសង្គមស៊ីវិល ដើម្បីធ្វើការផ្ដល់ព័ត៌មាន និងអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត ។

១១_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែជៀសវាងការផ្ដល់ព័ត៌មានដែលពាក់ព័ន្ធនឹងការរើសអើងដល់ស្ត្រីភេទ និងជនពិការ ។

១២_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្សព្វផ្សាយព័ត៌មាន អំពីសារៈសំខាន់នៃការចូលរួម របស់ស្ត្រី និងជនពិការក្នុងជីវភាពសង្គម និងនយោបាយដើម្បីបង្កើនការយល់ដឹងជាសាធារណៈ ។

១៣_ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និងឯកជន ត្រូវតែធ្វើការបែងចែកឱ្យបានច្បាស់ ក្នុងការផ្សព្វផ្សាយព័ត៌មាន អំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោតដែលធ្វើឡើងក្នុងនាម គណបក្សនយោបាយបេក្ខជន ឬអ្នកគាំទ្រណាមួយ ។

១៤_ អ្នកយកព័ត៌មាន អ្នករាយការណ៍ និងអ្នកធ្វើអត្ថាធិប្បាយ ត្រូវជៀសវាងសំដែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថតាមរយៈការលើកដាក់សំលេង ឬឥរិយាបថជាក់ស្តែងផ្សេងទៀត ។

១៥_ ការផ្សព្វផ្សាយដែលមានលក្ខណៈបរិហារកេរ្តិ៍ គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយនោះ មានសិទ្ធិប្តឹងពីបទបរិហារកេរ្តិ៍ ឬការប្រមាថមើលងាយ ឬ/និងសុំឱ្យអ្នកផ្សព្វផ្សាយ ឬជនដែលបានបរិហារកេរ្តិ៍នោះ ធ្វើការកែតម្រូវ ឬបញ្ឈប់ការផ្សព្វផ្សាយនូវព័ត៌មានទាំងនោះ ។ ក្នុងករណីនេះ អ្នកផ្សព្វផ្សាយ ឬជនដែលបានបរិហារកេរ្តិ៍ ត្រូវធ្វើការឆ្លើយតបទៅនឹង គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយនោះ ឬក៏ធ្វើការកែតំរូវលើការផ្សព្វផ្សាយព័ត៌មានឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ។ ការផ្សព្វផ្សាយព័ត៌មានឡើងវិញ អំពីខ្លឹមសារ កែតំរូវត្រូវផ្សព្វផ្សាយក្នុងរយៈពេលប្រហែលគ្នានឹងរយៈពេលដែលបានផ្សព្វផ្សាយបរិហារកេរ្តិ៍ ។

១៦_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋត្រូវបង្ហាញនូវកំរិតគុណភាពខ្ពស់ នៃវិជ្ជាជីវៈសារព័ត៌មាន និងត្រូវផ្តល់ព័ត៌មាន និងហេតុការណ៍ថ្មីៗ ឱ្យបានសមរម្យ ពិតប្រាកដ និងឥតលំអៀង ដើម្បីធានានូវយុត្តិធម៌ និងតុល្យភាពព័ត៌មានសំរាប់គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតទាំងអស់ ។

# ឧបសម្ព័ន្ធទី ១៥
# ស្តីពី
# ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត

## I. គោលបំណង និងការប្រតិបត្តិតាមក្រមសីលធម៌

### ក. គោលបំណងនៃក្រមសីលធម៌

គោលបំណងនៃក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត គឺដើម្បីផ្តល់លទ្ធភាពឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) និងមន្ត្រីបោះឆ្នោតទាំងអស់សម្រេចបាននូវ ៖

- ការបោះឆ្នោតដែលធ្វើឡើងទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។
- ការបោះឆ្នោតដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ដែលទទួលយកបានដោយប្រជាពលរដ្ឋកម្ពុជា ដោយគណបក្សនយោបាយចូលរួមបោះឆ្នោត និងដោយសហគមន៍អន្តរជាតិ
- ការបោះឆ្នោតដែលប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ឬការផ្ចាញ់ផ្ចាល ។

### ខ. ការប្រតិបត្តិតាមក្រមសីលធម៌

សមាជិកគ្រប់រូបរបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងមន្ត្រីដែលត្រូវបានធ្វើប្រតិភូកម្មអំណាចឱ្យដោយ គ.ជ.ប គឺជាមន្ត្រីបោះឆ្នោត ។ មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិតាមក្រមសីលធម៌នេះ នៅពេលដែលមន្ត្រីបុគ្គលិកទាំងនោះកំពុងស្ថិតនៅទីកន្លែងបំពេញការងាររបស់ខ្លួន ឬកំពុងបំពេញភារកិច្ចរបស់ខ្លួន ។

### គ. ការអនុវត្តរបស់មន្ត្រីបោះឆ្នោត

**១. ការអនុវត្តច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម និងគាំទ្រច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

**២. លក្ខខណ្ឌការងារ**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមអាណត្តិ និងលក្ខខណ្ឌការងាររបស់ខ្លួន ។ លក្ខខណ្ឌការងារនេះរាប់បញ្ចូលទាំងក្រមសីលធម៌នេះផងដែរ ។

**៣. ការអនុវត្តក្រមសីលធម៌**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម គាំទ្រ និងអនុវត្តក្រមសីលធម៌ ។

**៤. ការគាំទ្រ និងការផ្សព្វផ្សាយ**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តផ្តល់ការគាំទ្រ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌នេះ ។

## II. ការប្រព្រឹត្តជានិច្ច

### ១. ការផ្តន្ទាទោសចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តគ្រប់ពេលវេលាទាំងអស់ ដើម្បីអនុវត្តទៅតាមសិទ្ធិអំណាចរបស់ខ្លួនក្នុងការផ្តន្ទាទោស និងរារាំងចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យណាមួយទាក់ទិនដល់ការបោះឆ្នោត ។

### ២. ភាពមិនលំអៀងរវាងគណបក្សនយោបាយ

២.១ មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវលំអៀងជាដាច់ខាត និងមិនត្រូវធ្វើសកម្មភាពសំដែងឥរិយាបថ ឬថ្លែងសុន្ទរកថា ឬថ្លែងការណ៍អ្វីមួយដែលបង្ហាញឱ្យឃើញនូវភាពលំអៀង ឬការចូលចិត្តទៅលើគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារនៃគណបក្សនយោបាយណាមួយក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ។

២.២ មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវធ្វើអ្វីមួយដែលជះឥទ្ធិពលទៅលើអ្នកបោះឆ្នោត អាចធ្វើឱ្យមានការបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

២.៣ មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវពាក់ ឬបង្ហាញនូវផ្លាកសញ្ញាណាមួយ និមិត្តសញ្ញា ឬពាក្យស្លោកជាប់នឹងសម្លៀកបំពាក់ដែលមានការពាក់ព័ន្ធទៅនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយឡើយ ។

### ៣. បរិយាកាសការងារ

៣.១ ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវបង្ក និងរក្សាភាពមិនលំអៀង ភាពបោះឆ្នោតជាសម្ងាត់ និងសេចក្តីថ្លៃថ្នូរ ។

៣.២ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវត្រៀមលក្ខណៈចាត់វិធានការសមស្រប ទៅតាមព្រឹត្តិការណ៍ពិសេស ឬចៃដន្យដែលកើតមានឡើងក្នុងដំណើរការរៀបចំការបោះឆ្នោត ។

មន្ត្រីបោះឆ្នោតត្រូវ ៖

- អនុវត្តភារកិច្ចរបស់ខ្លួនក្នុងកាលៈទេសៈលំបាក
- អនុវត្តកិច្ចការថ្មី ឬកិច្ចការបន្ថែមទៀតដែលសមស្របតាមសមត្ថភាពរបស់ខ្លួន ប៉ុន្តែកិច្ចការនោះស្ថិតនៅក្រៅពីទីកន្លែងដែលខ្លួនកំពុងបំពេញការងារ ។

៣.៣ ក្នុងករណីមានការជ្រៀតជ្រែក ឬការរំខាន មន្ត្រីបោះឆ្នោតត្រូវ ៖

- បន្តអនុវត្តភារកិច្ចរបស់ខ្លួនដោយប្រុងប្រយ័ត្ន និងខ្ជាប់ខ្ជួន
- រក្សាសុវត្ថិភាពចំពោះសម្ភារៈបរិក្ខារបោះឆ្នោតទាំងអស់ដែលខ្លួនទទួលខុសត្រូវ ។ សម្ភារៈបោះឆ្នោតរាប់បញ្ចូលទាំងទម្រង់បែបបទផ្សេងៗ លិខិតបញ្ជាក់ សន្លឹកឆ្នោត សេចក្តីជូនដំណឹងសោឃ្លុំ និងស្រោមសំបុត្រ ឬប្រដាប់ដាក់សម្ភារៈបោះឆ្នោត
- ធ្វើសកម្មភាពជាបន្ទាន់ទៅតាមសេចក្តីណែនាំផ្សេងៗពីមន្ត្រីថ្នាក់លើរបស់ខ្លួន ។

## ៤. ជំនួយពិសេស

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវផ្តល់ជំនួយពិសេសក្នុងសមត្ថកិច្ចរបស់ខ្លួនតាមសំណូមពរដល់បុគ្គលដែល ៖

- មិនចេះអក្សរ ( ក្នុងពេលចុះឈ្មោះបោះឆ្នោត ) ឬពិការ
- មិនដឹងថាខ្លួនត្រូវធ្វើអ្វី ឬមិនប្រាកដអំពីអ្វីដែលខ្លួនត្រូវធ្វើ ដើម្បីចុះឈ្មោះបោះឆ្នោត ឬមិនដឹងពីរបៀបដាក់ពាក្យប្តឹងតវ៉ា ឬប្តឹងជំទាស់
- មិនមានឯកសារតាមលក្ខខណ្ឌតម្រូវឱ្យ ឬឈ្មោះរបស់គាត់បានបាត់ចេញពីបញ្ជីបោះឆ្នោត ឬសិទ្ធិចុះឈ្មោះ ឬសិទ្ធិបោះឆ្នោតរបស់គាត់ត្រូវបានបដិសេធ ។

## ៥. ការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះ

៥.១ មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវជៀសវាងសកម្មភាពពាក់ព័ន្ធទៅនឹង ៖

- ការគំរាមកំហែង
- អំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យដល់បុគ្គលណាម្នាក់ ឬប្រឆាំងទៅនឹងបុគ្គលណាម្នាក់
- ការធ្វើឱ្យខូចខាតដល់បរិវេណការិយាល័យបោះឆ្នោតណាមួយ
- ការធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញ ឬលាក់ទុកសម្ភារៈបរិក្ខារ ឬទ្រព្យសម្បត្តិបោះឆ្នោតណាមួយ
- ការបង្អាក់ ឬរាំងអ្នកមានសិទ្ធិណាម្នាក់មិនឱ្យទៅការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៥.២ មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវមានវិធានការទប់ស្កាត់ និងដោះស្រាយឱ្យបានសមស្របតាមសមត្ថកិច្ចរបស់ខ្លួនទៅនឹងការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះ ដូចខាងលើ ។

## ៦. ការជក់បារី និងការបង្ការភ្លើង

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវ ៖

- ជក់បារីនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។
- គូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយគ្មានភារកិច្ចបញ្ជាក់ឱ្យធ្វើ ។

## ៧. ការហូបចុក

មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវបរិភោគនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ លើកលែងតែមានការបញ្ជាក់អនុញ្ញាតពីមន្ត្រីថ្នាក់លើរបស់ខ្លួន ។

៨. គ្រឿងស្រវឹង និងគ្រឿងញៀន

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវមានភេសជ្ជៈដែលមានផ្ទុកជាតិស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនណាមួយនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះឡើយ ។

៩. ល្បែង

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងកន្លែង និងក្នុងពេលម៉ោងធ្វើការឡើយ ។

# III. លក្ខខណ្ឌចាំបាច់សម្រាប់ការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

## ក. លក្ខខណ្ឌចាំបាច់សម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោត ៖

១. ភារកិច្ចទូទៅ

មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួនដើម្បីធានាបានថា ប្រជាពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិរបស់ខ្លួនដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលា សមស្របក្នុងការសុំចុះឈ្មោះបោះឆ្នោត ។

២. ជំនួយសម្រាប់ប្រជាពលរដ្ឋដែលមានពិការភាព ឬមិនចេះអក្សរ

២.១ ប្រជាពលរដ្ឋដែលងងឹតភ្នែក មិនមាំមួន មានពិការភាពណាមួយ ឬមិនចេះអក្សរ មានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយ ឬកម្រិតណាមួយដែលខ្លួនត្រូវការជាជំនួយក្នុងការចុះឈ្មោះបោះឆ្នោត ។

២.២ មន្ត្រីបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកចុះឈ្មោះដែលងងឹតភ្នែក មិនមាំមួន មានពិការភាព ឬមិនចេះអក្សរនោះ ត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំដោយអ្នកពិការ ឬអ្នកមិនចេះអក្សររូបនោះតែប៉ុណ្ណោះ ។

## ខ. លក្ខខណ្ឌចាំបាច់ទូទៅសម្រាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

១. ការិយាល័យបោះឆ្នោត

មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាថាអ្នកដែលបានចុះឈ្មោះបោះឆ្នោតទាំងអស់អាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតដោយសម្ងាត់ ដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្រប និងធានាថាសម្ភារៈបរិក្ខារបោះឆ្នោតទាំងអស់ ត្រូវតែមានសុវត្ថិភាពត្រឹមត្រូវ និងគ្រប់ចំនួន ។

**២. ការិយាល័យរាប់សន្លឹកឆ្នោត**

មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការិយាល័យរាប់សន្លឹកឆ្នោតត្រូវអនុវត្ត ភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាថាសន្លឹកឆ្នោតទាំងអស់ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និង គ្រប់ចំនួន ។

**៣. ការប៉ះពាល់សម្ភារៈបោះឆ្នោត**

៣.១ មន្ត្រីបោះឆ្នោតដែលកំពុងបំរើការងារនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មិនត្រូវ ប៉ះពាល់សៀវភៅសន្លឹកឆ្នោត សន្លឹកឆ្នោត បញ្ជីបោះឆ្នោត សោឃ្លុំ ត្រាសម្ងាត់ ត្រាផ្លូវការ ទម្រង់បែបបទ ឬសម្ភារៈបោះឆ្នោតផ្សេងទៀត ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ ទោះបីជាភារកិច្ចរបស់ខ្លួនក៏ដោយ ។

៣.២ ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹក ឆ្នោតមិនត្រូវ ៖

- ស្រាយចំណង ឬបើកសោឃ្លុំ សៀវភៅសន្លឹកឆ្នោត ហិបឆ្នោត កញ្ចប់ ឬស្រោមសំបុត្រ ដែលមានផ្ទុកសម្ភារៈបោះឆ្នោត ។
- យកចេញនូវសៀវភៅសន្លឹកឆ្នោត ហិបឆ្នោត ឬកញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុក សម្ភារៈបោះឆ្នោតនៅខាងក្នុង ។
- យកសម្ភារៈបោះឆ្នោតណាមួយចេញពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬជួយ ឱ្យអ្នកណាម្នាក់ផ្សេងទៀតឱ្យធ្វើដូច្នេះ ។
- គូសសំគាល់ ឬសរសេរលើសម្ភារៈបោះឆ្នោតណាមួយ ឬលុបគំនូស ឬលុបសំណេរណាមួយ ចេញពីសម្ភារៈបោះឆ្នោតណាមួយ ។

**៤. សន្លឹកឆ្នោត និង ហិបឆ្នោត**

ប្រសិនបើមន្ត្រីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយមិនមានការបញ្ជាក់ អនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតរូបនោះមិនត្រូវ ៖

- ផ្តល់សន្លឹកឆ្នោតទៅជនណាម្នាក់
- បោះត្រាសម្ងាត់ជាផ្លូវការនៅលើសន្លឹកឆ្នោតណាមួយ
- ផ្លាស់ប្តូរ ឬបំផ្លាញត្រាសម្ងាត់ជាផ្លូវការនៅលើសន្លឹកឆ្នោត
- ផ្លាស់ប្តូរ ឬបំផ្លាញសន្លឹកឆ្នោត
- គូសនៅលើសន្លឹកឆ្នោត
- ចាប់យក ឬប៉ះពាល់ហិបឆ្នោត
- ដាក់សន្លឹកឆ្នោត ឬរបស់ផ្សេងទៅក្នុងហិបឆ្នោត
- យកសន្លឹកឆ្នោតចេញពីហិបឆ្នោតឡើយ ។

## គ. លក្ខខណ្ឌចាំបាច់ពិសេសសម្រាប់ការិយាល័យបោះឆ្នោត

### ១. ការិយាល័យបោះឆ្នោត

១.១ មន្ត្រីបោះឆ្នោតដែលកំពុងបំរើការងារនៅក្នុងការិយាល័យបោះឆ្នោត មិនត្រូវព្យាយាម ៖

- ចង់ដឹងពីបំណងដែលអ្នកបោះឆ្នោតចង់បោះឆ្នោត ឬបានបោះឆ្នោត
- ធ្វើឱ្យអ្នកបោះឆ្នោតបង្ហាញ ឬប្រាប់ឱ្យដឹងអំពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោត
- គូសសញ្ញាសំគាល់ណាមួយនៅលើសន្លឹកឆ្នោតដែលអាចធ្វើឱ្យគេស្គាល់ដល់អត្តសញ្ញាណនៃអ្នកបោះឆ្នោត
- ប្រើឥទ្ធិពលទៅលើ ឬជួយអ្នកណាម្នាក់ដើម្បីបានបោះឆ្នោតដោយដឹងថាអ្នកនោះមិនមានសិទ្ធិបោះឆ្នោត
- ដើរទៅជិតធ្វើជាសញ្ញា ឬនិយាយទៅកាន់អ្នកបោះឆ្នោតណាម្នាក់ដោយគ្មានភារកិច្ចអនុញ្ញាត ចាប់ពីពេលដែលអ្នកបោះឆ្នោតដើរចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត រហូតដល់អ្នកបោះឆ្នោតចាកចេញពីបរិវេណខាងក្នុងការិយាល័យបោះឆ្នោត
- ដើរចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយគ្មានភារកិច្ច ។

១.២ មន្ត្រីបោះឆ្នោតត្រូវរាយការណ៍ជាបន្ទាន់ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច នូវសកម្មភាពរបស់បុគ្គលណាម្នាក់ទាក់ទិនដល់ការសុំឱ្យបង្ហាញ ឬការចង់ដឹងអំពីរបៀបដែលអ្នកបោះឆ្នោតណាម្នាក់បានបោះឆ្នោត ។

### ២. ជំនួយសម្រាប់អ្នកបោះឆ្នោតដែលពិការដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន

២.១ អ្នកបោះឆ្នោតដែលពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយក៏រិតណាមួយដែលខ្លួនត្រូវការជាជំនួយក្នុងការបោះឆ្នោត ។

២.២ មន្ត្រីបោះឆ្នោតត្រូវធ្វើទៅតាមក៏រិតដែលបានស្នើសុំដោយអ្នកបោះឆ្នោតរូបនោះតែប៉ុណ្ណោះ និងទៅតាមការកំណត់នៃបទបញ្ជា និងនីតិវិធី របស់ គ.ជ.ប ។ កិច្ចការនេះតម្រូវឱ្យមន្ត្រីបោះឆ្នោតដែលត្រូវបានតែងតាំងនោះសួរទៅអ្នកបោះឆ្នោតអំពីគណបក្សនយោបាយណាមួយដែលគាត់ចង់បោះឆ្នោតឱ្យ និងត្រូវគូសលើសន្លឹកឆ្នោតក្នុងនាមអ្នកបោះឆ្នោតរូបនោះ ។ មន្ត្រីបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកពិការត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតនេះ ។

## ឃ. លក្ខខណ្ឌចាំបាច់ពិសេសសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោត

មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោតដែលគ្មានភារកិច្ចអនុញ្ញាតឱ្យធ្វើ មិនត្រូវព្យាយាមលាតត្រដាង ៖

- សន្លឹកឆ្នោតណាមួយដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ
- លទ្ធផលនៃការត្រួតពិនិត្យ និងការគណនាណាមួយធ្វើឡើងដោយមន្ត្រីបោះឆ្នោត
- ចំនួនសន្លឹកឆ្នោតមិនបានការដែលកំពុងមានវិវាទ
- ចំនួនសម្លេងឆ្នោតដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ ។

## IV. ទំនាក់ទំនងជាមួយគណបក្សនយោបាយ ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

### ១. ទំនាក់ទំនង

១.១ មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវរាក់ទាក់ មិនលំអៀង និងត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយបេក្ខជន ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ និងគ្រប់ពេលវេលាទាំងអស់ ។

១.២ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវទទួលស្គាល់តួនាទីត្រឹមត្រូវតាមច្បាប់របស់ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែល ៖

- មានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះ ដើម្បីសង្កេតការណ៍មើលដំណើរការបោះឆ្នោត
- ធ្វើការតវ៉ា ឬជំទាស់ ឬធ្វើពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់អំពីភាពមិនប្រក្រតីនៃការអនុវត្តបទបញ្ជា និងនីតិវិធី ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច (សម្រាប់ភ្នាក់ងារនៃគណបក្សនយោបាយតែប៉ុណ្ណោះ) ។

១.៣ មន្ត្រីបោះឆ្នោតដែលមានភារកិច្ចទទួលដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវទទួលយកគ្រប់ពាក្យបណ្ដឹង ទោះជាពាក្យបណ្ដឹងនោះហួសអាជ្ញាយុកាល ឬមិនមានលក្ខណៈគ្រប់គ្រាន់ក៏ដោយ ។ ក្នុងករណីទាំង២ចុងក្រោយនេះ មន្ត្រីនោះត្រូវចារបដិសេធលើពាក្យបណ្ដឹងដោយបញ្ជាក់មូលហេតុសមស្រប ។

### ២. ភាពគ្មានសិទ្ធិអំណាច

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវដឹងថា ៖

- គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារនៃគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ មិនមានសិទ្ធិធ្វើសេចក្ដីណែនាំណាមួយដល់មន្ត្រីបោះឆ្នោតណាម្នាក់ឡើយ ។
- មិនត្រូវប្រតិបត្តិតាមសេចក្ដីណែនាំណាមួយរបស់គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារនៃគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ ។

### ៣. ការជូនរង្វាន់ និងការសន្យា

៣.១ មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវទទួលយកទោះដោយផ្ទាល់ ឬដោយប្រយោលក្ដីនូវចំនួនទឹកប្រាក់ រង្វាន់ ឬការសន្យាណាមួយពីគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារនៃគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ ។

៣.២ រង្វាន់មានរាប់បញ្ចូលទាំងស្បៀងអាហារ ឬភេសជ្ជៈ ឬសេវាកម្មផ្ទាល់ខ្លួនផ្សេងទៀតដែលផ្ដល់ផ្គង់ដល់មន្ត្រីបោះឆ្នោតណាម្នាក់ដោយគណបក្សនយោបាយណាមួយ បេក្ខជន ភ្នាក់ងារនៃគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយគ្មានការយល់ព្រមដោយចំហពីភ្នាក់ងារនៃគណបក្សនយោបាយទាំងអស់ដែលមានវត្តមាននៅក្នុងការិយាល័យនោះ ។

៤. **សកម្មភាពដែលត្រូវហាមឃាត់**

មន្ត្រីបោះឆ្នោតម្នាក់ៗ នៅក្នុងអំឡុងពេលបោះឆ្នោត មិនត្រូវ ៖

- មានឈ្មោះជាបេក្ខជននៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ
- ធ្វើការងារឱ្យ ឬទទួលថ្លៃឈ្នួលពីគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់
- ជាអ្នកកាន់មុខតំណែងណាមួយ នៅក្នុងការិយាល័យគណបក្សនយោបាយ ។

## V. ការបណ្តុះបណ្តាល

មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវចូលរួមរៀនសូត្រគ្រប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាទាំងអស់ដែលខ្លួនត្រូវទទួល ។

## VI. ទោសប្បញ្ញត្តិ

មន្ត្រីបោះឆ្នោតគ្រប់រូបដែលអនុវត្តផ្ទុយពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី និងក្រមសីលធម៌នេះនឹងត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។

# ឧបសម្ព័ន្ធទី ១៦
# ស្តីពី
# ក្រមសីលធម៌សម្រាប់
# សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ

## ផ្នែកទី ១

## I. សេចក្តីផ្តើម

ការបោះឆ្នោតនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលបានឆ្លុះបង្ហាញឱ្យឃើញកាន់តែច្បាស់ពីការខិតខំពង្រឹង និងការវិវត្តរីកចំរើននៃលទ្ធិប្រជាធិបតេយ្យ នៅព្រះរាជាណាចក្រកម្ពុជា។

ដូចនេះ ដើម្បីឱ្យដំណើរការនៃការបោះឆ្នោតមួយលើកៗតាមនីតិកាល ឬអាណត្តិ ប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សុវត្ថិភាព សេរី ត្រឹមត្រូវ យុត្តិធម៌ និងដើម្បីពង្រឹងបរិយាកាសសង្គមឱ្យបានល្អ សម្រាប់ការរៀបចំការបោះឆ្នោតដែលមានការយោគយល់គ្នា មានការគោរពច្បាប់ មិនមានការបំពុលបរិយាកាសសង្គមនាំឱ្យមានការភ័យខ្លាច ការច្របូកច្របល់ ការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សាផ្សេងៗ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុម័តក្រមសីលធម៌ សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ដែលមានខ្លឹមសារលំអិតដូចខាងក្រោម ៖

## II. គោលបំណង

គោលបំណង នៃក្រមសីលធម៌គឺ ៖

- ដើម្បីឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ប្រព្រឹត្តទៅបានជោគជ័យ គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ និងគ្មានអំពើហិង្សាផ្សេងៗ ។
- ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពជូនបេក្ខជន វាគ្មិន ឬឃោសនិក ភ្នាក់ងារ និងតំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត មន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកបោះឆ្នោត និងរក្សាស្ថិរភាពសម្រាប់សង្គមជាតិទាំងមូល ។
- ដើម្បីចាត់វិធានការបង្ការរារាំង ទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើស អំពើរំខានផ្សេងៗ និងអំពើភេរវកម្មផ្សេងៗ ដែលអាចបង្កឱ្យមានការរាំងស្ទះដល់ដំណើរការបោះឆ្នោត ។

## III. សំណូមពរ

- សមាជិក នៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិទាំងមូល ជាពិសេស កងកម្លាំងដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខ សម្រាប់ការបោះឆ្នោត ហៅកាត់ "ភ្នាក់ងារសន្តិសុខបោះឆ្នោត" ត្រូវប្រមូលផ្តុំកម្លាំងសហការឱ្យបានល្អ និងប្រើប្រាស់តាមគ្រប់វិធានការជំនាញគ្រប់មធ្យោបាយនិងសម្ភារៈ លើកកំពស់ស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ក្នុងកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវផ្អែកលើច្បាប់ពិសេស ច.ប.ត.រ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប សម្រាប់ការបោះឆ្នោត យកមកធ្វើជាមូលដ្ឋានសំខាន់ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវចូលរួមការពារសុវត្ថិភាព ក្នុងដំណើរការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការការពារសុវត្ថិភាពសម្ភារៈ ឧបករណ៍ គ្រឿងសង្ហារិមផ្សេងៗ សម្រាប់ដំណើរការបោះឆ្នោតទាំងមូល ។

## IV. សិទ្ធិទទួលការការពារសន្តិសុខ

ក្នុងដំណើរការបោះឆ្នោតនៅថ្នាក់ជាតិ_ថ្នាក់ក្រោមជាតិនីមួយៗ សមាជិកនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវប្រកាន់ជំហរអព្យាក្រឹត មិនលំអៀង និងមិនត្រូវបង្ហាញការគាំទ្រ ឬប្រឆាំងដល់គណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ឡើយ ។ សមាជិកនៃកងយោធ ពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវចងចាំថា ៖

- អ្នកបោះឆ្នោតគ្រប់រូបមានសិទ្ធិទទួលការការពារសន្តិសុខនិងសុវត្ថិភាព ដើម្បីឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។
- បេក្ខជន វាគ្មិន ឬឃោសនិក ភ្នាក់ងារ និងតំណាងនៃគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាព ក្នុងគ្រប់សកម្មភាពស្របច្បាប់ ។

## V. សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវនៃភ្នាក់ងារសន្តិសុខបោះឆ្នោត

### ក- ភ្នាក់ងារសន្តិសុខបោះឆ្នោត មានភារកិច្ច ៖

១. ត្រូវសហការ និងត្រៀមលក្ខណៈសហការជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សុវត្ថិភាព ក្នុងដំណើរការបោះឆ្នោត ។

២. ត្រូវរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ក្នុងពេលបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ បញ្ជីបេក្ខជន ពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត ។

៣. ត្រូវធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពនៅក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៤. ត្រូវចូលរួមចំណែកការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ដែលជាបរិវេណរដ្ឋបាល និងសន្តិសុខ ។

៥. នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួន ៣(បី)នាក់ ដើម្បីការពារបរិវេណសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវមានឯកសណ្ឋានត្រឹមត្រូវ និងមានពាក់ប្រទ្បង់ដៃសន្តិសុខរបស់ គ.ជ.ប ។

៦. ត្រូវយាម និងត្រួតពិនិត្យគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត យ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧. មិនត្រូវអនុញ្ញាតឱ្យជនណាម្នាក់ដែលប្រដាប់អាវុធ ឬមានលាក់អាវុធនៅក្នុងខ្លួនចូល ឬឈរក្បែរការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត លើកលែងតែជាសមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ឬកងនគរបាលជាតិ ដែលមានភារកិច្ច និងត្រូវបានស្នើសុំដោយប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ដើម្បីដោះស្រាយបាតុភាពដែលអាចនឹងកើតមាន ។

៨. ត្រូវស្ថិតនៅជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដើម្បីត្រៀមបំពេញភារកិច្ចក្នុងករណីមានសំណូមពរពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យណាមួយនោះ ។

៩. ត្រូវបានស្នើឱ្យជួយការពារការដឹកជញ្ជូនសម្ភារៈបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោតកំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយ តាមការកំណត់របស់ គ.ជ.ប ឬ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

១០. មេបញ្ជាការ ឬតំណាងនៃកងយោធពលខេមរភូមិន្ទ កងរាជអាធវុហត្ថ និងកងនគរបាលជាតិត្រូវចូលរួមប្រជុំជាមួយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដើម្បីចាត់វិធានការការពារសន្តិសុខ និងសុវត្ថិភាព ក្នុងដំណើរការបោះឆ្នោតទាំងមូល ។

១១. មេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវចេញសេចក្តីណែនាំ ឬបទបញ្ជាទៅដល់មន្ត្រីនៅក្រោមឱវាទ ដើម្បីពិនិត្យមើលសកម្មភាពរបស់មន្ត្រីនៃអង្គភាពរៀងៗខ្លួនពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោបាយ និងប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងការការពារនូវសិទ្ធិសេរីភាពជាមូលដ្ឋាន ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ខ- សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវអនុវត្តបម្រាម ដូចតទៅនេះ ៖**

១. សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ មិនត្រូវចូលរួមសកម្មក្នុងគ្រប់សកម្មភាពឃោសនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយឡើយ ។ ការចូលរួមសកម្មត្រូវបានកំណត់ ដូចតទៅ ៖

១.១ ការធ្វើជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ វ៉ាគ្នីន ឬក្រុមអ្នកឃោសនាបោះឆ្នោតនៃគណបក្សនយោបាយ ។

១.២ ការចូលរួមក្នុងក្បួនដង្ហែ ការជួបជុំ និងក្បួនព្យុហយាត្រាដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៣ ការដាក់តាំងរូបភាពផ្សាយ ឬឯកសារផ្សេងៗដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់នៅតាមយានជំនិះផ្ទាល់របស់ខ្លួន ឬ/និងរបស់អង្គភាព ។

១.៤ ការស្នងមតិសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៥ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៦ ការធ្វើសកម្មភាពចែកចាយសម្ភារៈដល់អ្នកបោះឆ្នោត ក្នុងគោលដៅគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៧ ការចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈក្នុងការគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៨ ការលេងភ្លេងគាំទ្រគណបក្សនយោបាយ ឬ/និងការច្រៀងចម្រៀង ឬ/និងការផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសម្លេងនានា ដើម្បីគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

២. មិនត្រូវចូលរួមក្នុងសកម្មភាពឃោសនាជាសាធារណៈណាមួយ ក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ ។

៣. មិនត្រូវចូលរួមក្នុងសកម្មភាពឃោសនាណាមួយ ក្នុងពេលបំពេញភារកិច្ច ។

៤. មិនត្រូវដើរ ឬឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៥. មិនត្រូវជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ។

៦. មិនត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ ឬ/និងយកអាវុធ សារជាតិផ្ទុះ ឬឧបករណ៍ប្រកបដោយគ្រោះថ្នាក់តាមខ្លួនចូលក្នុងបរិវេណខាងក្រៅ និងខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧. មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលនេះឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀត ។ ការគំរាមកំហែង ការបំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

៧.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញនិង ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។

៧.២ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថា នឹងធ្វើទារុណកម្ម ។

៧.៣ ការវាយតប់បន្តិចបន្តួច ឬធ្វន់ធ្ងរលើបុគ្គលណាម្នាក់ ។

៧.៤ ការរំលោភដោយពាក្យសម្តីថា នឹងធ្វើទុក្ខទោសដល់រាងកាយ ។

៧.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ។

៧.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរដែលយោងទៅលើព្រឹត្តិការណ៍ ពីអតីតកាល ដូចជា : ឃាតកម្ម ការវាយដំ ឬការបង្ករបួសស្នាម ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

៧.៧ ការបាញ់កាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

៧.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខ ផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬ ដល់បងប្អូនគ្រួសាររបស់ខ្លួន ។

៧.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើ ឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬ សុវត្ថិភាពគ្រួសាររបស់ខ្លួន ។

៧.១០ ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង ។

៧.១១ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង និងផលប្រយោជន៍ផ្សេងទៀត ។

៨. មិនត្រូវចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត លើកលែងតែមានករណីចាំបាច់ និងមានការស្នើសុំពីប្រធាន គ.ជ.ប ប្រធាន គធ/ខប ប្រធាន គឃ/សប ឬពីប្រធាន ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

## VI. ការរៀបចំយន្តការ និងសហប្រតិបត្តិការផ្នែកសន្តិសុខ

ដើម្បីការពារសន្តិសុខ ស្ថិរភាព សុវត្ថិភាព សម្រាប់ការបោះឆ្នោតទាំងនៅថ្នាក់ជាតិ_ថ្នាក់ក្រោមជាតិ កងយោធពលខេមរភូមិន្ទ ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងកម្លាំងនគរបាលជាតិ ត្រូវចាត់ឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ។ ជាគោលការណ៍យន្តការរចនាសម្ព័ន្ធចាត់តាំង និងកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ មានការរៀបចំដូចតទៅ ៖

## ១_ អំពីយន្តការផ្នែកសន្តិសុខរវាង គ.ជ.ប និងរាជរដ្ឋាភិបាល

### ក- រចនាសម្ព័ន្ធសន្តិសុខរបស់ គ.ជ.ប

- គ.ជ.ប
- អគ្គលេខាធិការដ្ឋាន
- លធ/ខប ឬ គធ/ខប
- គឃ/សប
- គណៈកម្មការការិយាល័យបោះឆ្នោត (គកប)
- កបឃ/ស (នៅពេលចុះឈ្មោះបោះឆ្នោត)

### ខ- រចនាសម្ព័ន្ធសន្តិសុខរបស់រាជរដ្ឋាភិបាល

- គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ (គ.ស.អ)
- លេខាធិការដ្ឋាននៃ គ.ស.អ
- គណៈអភិបាល ឬគណៈបញ្ជាការឯកភាពរាជធានី ខេត្ត
- គណៈអភិបាល ឬគណៈបញ្ជាការឯកភាព ក្រុង ស្រុក ខណ្ឌ
- មន្ត្រីអនុវត្តច្បាប់ រួមមាន កងយោធពលខេមរភូមិន្ទ ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងនគរបាលជាតិ ត្រូវបានរៀបចំចាត់តាំងជាភ្នាក់ងារសន្តិសុខបោះឆ្នោត ។

## ២_ កិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខបោះឆ្នោតរវាង គ.ជ.ប និង គ.ស.អ



# ផ្នែកទី ២
# មុខសញ្ញានិងគោលដៅ ប្រព័ន្ធការពារសន្តិសុខការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត និងយន្តការការពារសន្តិសុខបោះឆ្នោត

## I. មុខសញ្ញា និងគោលដៅដែលត្រូវការពារជាអាទិភាព

ចំពោះកិច្ចការពារមុខសញ្ញា និងគោលដៅសំខាន់ៗ ត្រូវរៀបចំជាផែនការដោយតម្រូវឱ្យមានការការពារជាលក្ខណៈប្រយោល ។

មុខសញ្ញា និងគោលដៅជាអាទិភាពដែលត្រូវការពារ រួមមាន ៖

### ១_ មុខសញ្ញាដែលត្រូវការពារ

- ប្រធាន អនុប្រធាន និងសមាជិក សមាជិកា គ.ជ.ប
- មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- បេក្ខជនឈរឈ្មោះបោះឆ្នោត
- ឃោសនិក ឬវាគ្មិន និងក្រុមឃោសនាបោះឆ្នោត របស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត
- តំណាង ឬភ្នាក់ងាររបស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត
- អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ
- ប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត
- អ្នកបោះឆ្នោត ។

### ២_ គោលដៅដែលត្រូវការពារ

- ទីស្តីការរបស់ គ.ជ.ប
- ទីកន្លែងស្នាក់នៅនៃបេក្ខជនឈរឈ្មោះបោះឆ្នោត ឃោសនិក ឬវាគ្មិន ឬក្រុមឃោសនាបោះឆ្នោត និងតំណាងនៃគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត
- ទីស្នាក់ការរបស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត
- ទីកន្លែងស្នាក់នៅរបស់អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ
- ទីស្នាក់ការរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
- ការិយាល័យពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

- ការដឹកជញ្ជូនសម្ភារៈបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុប លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយតាមការកំណត់របស់ គ.ជ.ប ឬ/និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

## II. ប្រព័ន្ធការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

គ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានបរិវេណខាងក្នុងជារង្វង់មណ្ឌលមួយដែលមានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រ និងមានបរិវេណខាងក្រៅដែលជាតំបន់នៅជុំវិញការិយាល័យទាំងនោះមានកាំប្រវែង ១០០ម៉ែត្រ ឬមានទម្រង់ផ្សេងៗ ឬមានកាំតូចជាងស្របទៅតាមស្ថានភាពភូមិសាស្ត្រជាក់ស្ដែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗនោះ ។




**គំនូសទំហំនៃបរិវេណខាងក្នុង និងបរិវេណខាងក្រៅ នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**




**គំនូសប្រព័ន្ធការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

 - ពណ៌សមានរង្វង់មណ្ឌលកាំប្រវែង ១៥ម៉ែត្រ គឺជាបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

 - ពណ៌ខ្មៅមានរង្វង់មណ្ឌលកាំប្រវែង ១០០ម៉ែត្រ គឺជាបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

 - ភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងឯកសណ្ឋានត្រឹមត្រូវ និងពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប ។

**សេចក្ដីបញ្ជាក់ៈ**

❈ ភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួន ០៣ (បី)នាក់ ស្លៀកពាក់ឯកសណ្ឋាន និងមានពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប ការពារនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ៖

- ភ្នាក់ងារសន្តិសុខ ០១(មួយ)នាក់ ត្រូវចល័តការពារជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬចល័តការពារនៅក្នុងបរិវេណខាងក្រៅ នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយត្រូវស្ថិតនៅក្នុងចម្ងាយពី ១៥_១០០ម៉ែត្រ គ្មានសិទ្ធិប្រើអាវុធឡើយ ។
- ភ្នាក់ងារសន្តិសុខ ០២(ពីរ)នាក់ទៀតត្រូវចល័តការពារជុំវិញបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយត្រូវស្ថិតនៅក្នុងចម្ងាយពី ១០០_១៥០ម៉ែត្រ មានសិទ្ធិប្រើប្រាស់នូវអាវុធវែង ០១ដើម បង់ ០១ និងមានគ្រាប់យ៉ាងច្រើនចំនួន ៣០គ្រាប់ ។

❈ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវប្រមូលផ្តុំកម្លាំងយាមទីកន្លែងរក្សាទុក ឬ/និងការពារការដឹកជញ្ជូនសម្ភារៈបោះឆ្នោត និងឯកសារបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយ តាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

## III. គោលការណ៍ និងយន្តការការពារសន្តិសុខបោះឆ្នោត

ភ្នាក់ងារសន្តិសុខបោះឆ្នោតដែលបំពេញភារកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ដំណើរការរៀបចំការបោះឆ្នោតទាំងនៅថ្នាក់ជាតិ_ថ្នាក់ក្រោមជាតិ ត្រូវគោរពអនុវត្តតាមគោលការណ៍សំខាន់ៗ ដូចតទៅ ៖

### ១_ គោលការណ៍ទូទៅ

- រក្សាបរិយាកាសនយោបាយអព្យាក្រឹត និងគោរពវិន័យយ៉ាងម៉ឺងម៉ាត់ដើម្បីឱ្យការបោះឆ្នោតមានដំណើរការទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សា ។
- ត្រូវផ្អែកលើច្បាប់ និងបទបញ្ជា និងនីតិវិធី គ.ជ.ប ធ្វើជាមូលដ្ឋានក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។
- ពង្រឹងការពារសន្តិសុខសម្រាប់សង្គមជាតិទាំងមូល ។
- ត្រូវមានអព្យាក្រឹតក្នុងមុខនាទី ក្នុងសកម្មភាពការងារ និងក្នុងនាមជាកងកម្លាំងរបស់ជាតិ ។
- ហាមឃាត់ការប្រើមុខងារ ការបំពេញភារកិច្ច និងការប្រើប្រាស់មធ្យោបាយ សម្ភារៈរបស់រដ្ឋ ដើម្បីបំរើឱ្យសកម្មភាព និងផលប្រយោជន៍របស់គណបក្សនយោបាយណាមួយ ។

### ២_ ការរៀបចំយន្តការការពារសន្តិសុខសម្រាប់ការបោះឆ្នោត

- ចាត់តាំងកម្លាំងការពារគ្រប់ទីតាំងបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ ។
- ចាត់តាំងកម្លាំងការពារសកម្មភាពឃោសនាបោះឆ្នោត របស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត ។

- ការពារការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការពារការដឹកជញ្ជូនសម្ភារៈ ឯកសារបោះឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត ដោយត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយ គ.ជ.ប លធ/ខប ឬ គធ/ខប និងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- បន្តរក្សាសន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

**បញ្ជាក់ ៖**

- នៅថ្ងៃបោះឆ្នោតភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ០៣(បី)នាក់ ស្លៀកពាក់ឯកសណ្ឋានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប ត្រូវការពារនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត រហូតដល់ចប់ភារកិច្ច។
- ប្រធានការិយាល័យបោះឆ្នោត ប្រកាសបើកការបោះឆ្នោតនៅម៉ោង ៧:០០ និងប្រកាសបិទការបោះឆ្នោតនៅម៉ោង១៥:០០ នៅថ្ងៃដដែល ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ហើយចាត់វិធានការរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត ឱ្យបានតឹងរ៉ឹងបំផុត ។
- ក្នុងករណីមានសំណូមពរពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងគោលបំណងស្នើសុំឱ្យជួយថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវបានបំពាក់អាវុធសមស្រប ឬ/និងភ្នាក់ងារសង្គ្រោះ អាចចូលធ្វើអន្តរាគមន៍ នៅក្នុងការិយាល័យបាន ។
- កម្លាំងនគរបាលការពារសន្តិសុខ ត្រូវប្រមូលផ្តុំកម្លាំងចូលរួមការពារការរក្សាទុក និង/ឬការដឹកជញ្ជូនសម្ភារៈបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយ តាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

# ផ្នែកទី ៣
# តួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់អាជ្ញាធរដែលទទួលខុសត្រូវលើ ការងារសន្តិសុខ និងអំពីទោសប្បញ្ញត្តិដែលកំណត់ដោយច្បាប់

សមាជិក នៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវយល់និងចងចាំនូវមាត្រាមួយចំនួន នៃច្បាប់ស្តីពីការបោះឆ្នោតគ្រប់ប្រភេទ សេចក្តីណែនាំ និងបទបញ្ជាផ្សេងៗ ដែលកំណត់អំពីតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់គ្រប់អាជ្ញាធរដែលទទួលខុសត្រូវលើការងារសន្តិសុខ នៃរាជរដ្ឋាភិបាល និងអំពីទោសប្បញ្ញត្តិ ៖

**១. អំពីតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់អាជ្ញាធរ :**

**មាត្រា ១៦_ថ្មី** (សម្រង់ចំណុចទី ៥) នៃ ច.ប.ត.រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិអំណាច និងភារកិច្ច ៖ "លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត"។

**មាត្រា ២៩_ថ្មី** នៃ ច.ប.ត.រ

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតតាមសំណើរបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

**មាត្រា ៧៦_ថ្មី** នៃ ច.ប.ត.រ

ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គណបក្សនយោបាយនិងបេក្ខជនទាំងអស់មិនត្រូវប្រើអំពើហិង្សា អំពើរំលោភ សំដីប្រមាថមើលងាយ មិនត្រូវសាបព្រោះឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់ បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

**មាត្រា ១០០_** នៃ ច.ប.ត.រ

ហាមដាច់ខាតមិនឱ្យយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងហាមមិនឱ្យស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេសពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ទីធ្លាការិយាល័យបោះឆ្នោតត្រូវមានទំហំប្រមាណ ២០០០ ម៉ែត្រការ៉េ ហើយរង្វង់ការពារសន្តិសុខត្រូវស្ថិតនៅចម្ងាយប្រមាណ ២០០ ម៉ែត្រជុំវិញការិយាល័យបោះឆ្នោត លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**២. អំពីទោសប្បញ្ញត្តិ :**

**មាត្រា ១២៤_ថ្មី** នៃ ច.ប.ត.រ

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា និងគណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម :

- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។
- ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។
- ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។
- ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។
- រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។
- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសម្តីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាចការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកទុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន ។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន ។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។
- ទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាស ។

**មាត្រា ១២៥_ថ្មី** នៃ ច.ប.ត.រ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(៥)ឆ្នាំ ចំពោះសមាជិកគណៈកម្មាធិការជាតិ សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិច ដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

**មាត្រា ១២៦_ថ្មី** នៃ ច.ប.ត.រ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ដល់ហាសិបលាន (៥០.០០០.០០០) រៀល និងត្រូវបញ្ឈប់ពីការងារបោះឆ្នោតជារៀងរហូត ចំពោះភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិ ឬភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតណា ដែលប្រព្រឹត្តល្មើសនឹងវាក្យខ័ណ្ឌទី ២ មាត្រា ១២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ១២៧_ថ្មី** នៃច្បាប់ ច.ប.ត.រ

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៥ថ្មី ឬមាត្រា ១០០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងករណីដែលមិនព្រមអនុវត្តតាមការព្រមាននេះ ត្រូវឃាត់ខ្លួន និងដកហូតអាវុធសម្រាប់រយៈពេលសែសិបប្រាំបី(៤៨)ម៉ោង ដោយភ្នាក់ងារមានសមត្ថកិច្ច និងផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ដល់ហាសិបលាន (៥០.០០០.០០០)រៀល ។

ប្រសិនបើជនល្មើសនោះជាមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ដើម្បីឱ្យដាក់ពិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែង យោលទៅតាមកម្រិតនៃបទល្មើស ។
- លប់ឈ្មោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាសមាជិក ឬជាបុគ្គលិករបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារភ្លាម និងមិនឱ្យចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់(១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខណ្ឌទី១ នៃមាត្រានេះ ។

**មាត្រា ១២៨_ថ្មី** នៃច្បាប់ ច.ប.ត.រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(៥)ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាលចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែង ចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៩ថ្មី នៃច្បាប់នេះ ។

**មាត្រា ១២៩_ថ្មី នៃ ច.ប.ត.រ**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលបង្ខាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនប្រព្រឹត្តល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៣០_ថ្មី នៃ ច.ប.ត.រ**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលមានចេតនាធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនល្មើសនោះជាបេក្ខជនវិញ ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៣១_ថ្មី នៃ ច.ប.ត.រ**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬនិងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណា ឬគណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ថ្មី ឬមាត្រា ៧៦ នៃច្បាប់នេះ ។

**មាត្រា ១៣៣_ថ្មី នៃ ច.ប.ត.រ**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនិងមាត្រា ៧២នៃច្បាប់នេះ ។ ក្នុងករណីដែលនៅពុំព្រម អនុវត្តតាម ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(៥)ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ។

# ឧបសម្ព័ន្ធទី ១៧
## ស្តីពី
# បទបញ្ជាផ្ទៃក្នុងពេលបើកសវនាការ ឬ អង្គប្រជុំផ្សះផ្សាដោះស្រាយបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់សវនាការ ឬបន្ទប់ប្រជុំផ្សះផ្សា ជនគ្រប់រូប ដែលមានវត្តមានក្នុងបន្ទប់សវនាការ ឬបន្ទប់ប្រជុំផ្សះផ្សាត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ ៖

១. ហាមជក់បារីក្នុងបន្ទប់សវនាការ ឬបន្ទប់ប្រជុំផ្សះផ្សា

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់សវនាការ ឬបន្ទប់ប្រជុំផ្សះផ្សា ដូចជា ៖
- ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត
- ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ ។

៣. ហាមយកក្មេងអាយុក្រោម ១៨ ឆ្នាំ ចូលក្នុងបន្ទប់សវនាការ ឬបន្ទប់ប្រជុំផ្សះផ្សា លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់សវនាការ ឬបន្ទប់ប្រជុំផ្សះផ្សា ។

៥. ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ។

៦. ហាមប្រើប្រាស់ទូរស័ព្ទដៃ វិទ្យុទាក់ទងផ្សេងៗក្នុងបន្ទប់សវនាការ ឬបន្ទប់ប្រជុំផ្សះផ្សា ។

៧. ក្នុងករណីជនណាម្នាក់ ឬច្រើននាក់បង្កភាពណាមួយដែលក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សាយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយនៃសវនាការ ឬការប្រជុំផ្សះផ្សា ក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សា អាចបណ្តេញជននោះ ឬទាំងនោះចេញពីបន្ទប់សវនាការ ឬបន្ទប់ប្រជុំផ្សះផ្សា ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលសវនាការ ឬប្រជុំផ្សះផ្សា ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

# ឧបសម្ព័ន្ធទី ១៨
## ស្ដីពី
## ខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំធ្វើឡើងដោយមន្ត្រីសវនាការ ឬលេខាធិការសវនាការមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្ដិសិទ្ធិ នៅទីកន្លែងបើកសវនាការនីមួយៗ ។

មុននឹងចាប់ផ្ដើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជានៅចំពោះមុខវត្ថុសក្ដិសិទ្ធិ ដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មកមន្ត្រីសវនាការ ឬលេខាធិការសវនាការ ត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗឱ្យអ្នកស្បថស្ដាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម ។

ក្រោយពីធ្វើសម្បថរួច មន្ត្រីសវនាការ ឬលេខាធិការសវនាការ ត្រូវធ្វើកំណត់ហេតុនៃការធ្វើស្បថនោះ ដោយបញ្ជាក់ថា បានធ្វើត្រឹមត្រូវ ហើយសេចក្ដីបានចេញវាចាឱ្យស្បថយ៉ាងណាត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង ។

## ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្ដិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតឆ្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវីវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ត្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថា ជាអ្នកបានដឹង បានឃើញ បានឮ និង បានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមការណ៍ពិត ។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និង បានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និង បារមីដ៏សក្ដិសិទ្ធិបំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្ដាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំបីរយជាតិ ។

បើអ្នកណាឆ្លើយឱ្យការណ៍ ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏សក្ដិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរព ស្រឡាញ់រាប់អាន លុះអនាគតជាតិបានជួបតែសេចក្ដីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្ដីបំណងប្រាថ្នា កុំបីអាក់ខានឡើយ ។

# ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និង បានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិទាំងអស់បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និង ស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៏ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

បោះពុម្ពដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត